«ខ្ញុំមិនស្គាល់គ្រីស្ទបរិស័ទណាលើពិភពលោកនេះដែលមានគុណសម្បត្តិលើសជាងលោក អាជីត ហ្វឺនេនដូ (Ajith Fernando) ក្នុងការនិពន្ធសៀវភៅអំពីអ្នកដឹកនាំនៅផ្ទះ។ គ្រួសាររបស់គាត់គឺជាស្មរបន្ទាល់របស់គាត់។ លើសពីនោះទៅទៀត ខ្ញុំក៏មិនអាចគិតដល់ទីប្រឹក្សាណាផ្សេងទៀត ដែលក្រុមជំនុំត្រូវការនៅបច្ចុប្បន្ននេះ ជាជាងអ្វីដែលគាត់បានលើកឡើងដោយមានការបន្ទាបខ្លួននៅក្នុងសៀវភៅនេះខ្ញុំទេ»។

**លោក Robert E. Coleman**, Distinguished Senior Professor of Discipleship and Evangelism, Gordon Conwell Theological Seminary

«ជីវិតគ្រួសារមិនដែលងាយស្រួលទេ។ សៀវភៅមួយក្បាលនេះពីអ្នកមានប្រាជ្ញាដែលមានបទពិសោធន៍អាចជួយលោកអ្នកបាន មិនថាគ្រួសាររបស់លោកអ្នកស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ សៀវភៅនេះមានពេញទៅដោយអំណាចដែលដកស្រង់ចេញពីព្រះគម្ពីរ ការប្រឹក្សាដែលអាចអនុវត្តបាន ហើយសៀវភៅនេះនឹងជួយផ្គត់ផ្គង់ដល់លោកអ្នកក្នុងការធ្វើជាប្តី ប្រពន្ធ ឪពុក ឬក៏អ្នកម្តាយដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យលោកអ្នកធ្វើ»។

**លោក Russell D. Moore**, President, The Ethics & Religious Liberty Commission; author, Onward

«ចំណុចគាំទ្រដ៏ខ្ពស់ និងផ្ទាល់បំផុតដែលខ្ញុំអាចឲ្យបានសម្រាប់សៀវភៅនេះគឺថា ខ្ញុំត្រូវការវាណាស់។ ហើយខ្ញុំក៏សង្ស័យយ៉ាងខ្លាំងផងដែរថា លោកអ្នកក៏ត្រូវការសៀវភៅនេះដែរ។ ជាដំបូង ខ្ញុំបានស្គាល់ ហើយមិនមានសេចក្តីស្ញើចសម្រាប់ព័ន្ធកិច្ចរបស់លោក អាជីត កាលខ្ញុំជាសិស្សនៅមហាវិទ្យាល័យ Urbana ឆ្នាំ ១៩៩០។ នៅឆ្នាំ២០០៦ ខ្ញុំបានរួមចំណែកលើឆាកជាមួយនឹងលោក អាជីត ក្នុងសិក្ខាសាលា Lausanne Younger Leaders Gathering។ ហើយមកដល់សព្វថ្ងៃនេះ ខ្ញុំមានអំណរក្នុងការដែលអាចហៅលោក អាជីត ថាជាមិត្តភក្តិម្នាក់ ខ្ញុំនៅបន្តទទួលបានព្រះពរតាមរយៈសេចក្តីបង្រៀនរបស់គាត់ ដែលមានពេញទៅដោយការឆេះឆួល និងការអនុវត្តយោងតាមព្រះគម្ពីរ»។

**លោក Michael Oh**, Global Executive Director, the Lausanne Movement

«លោក អាជីត ហ្វឺនេនដូ មានសមត្ថភាពមិនធម្មតាក្នុងការទាញយកប្រាជ្ញាចេញពីព្រះគម្ពីរដាក់ចូលគ្នា ដោយមានការយល់ដឹងដ៏ជ្រាលជ្រៅក្នុងការអនុវត្តក្នុងជីវិតប្រចាំថ្ងៃ ហើយគាត់ក៏បានប្រើប្រាស់ទេពកោសល្យនេះក្នុងការនិពន្ធសៀវភៅដ៏ងាយស្រួលអាននេះ។ ខ្ញុំគាំទ្រ និងលើកទឹកចិត្តឲ្យលោកអ្នកអានសៀវភៅនេះ។ នេះមិនមែនគ្រាន់តែ

ជាសៀវភៅឧត្តមគតិសម្រាប់តែគ្រូគង្វាល និងអ្នកដឹកនាំស្ម័គ្រចិត្តប៉ុណ្ណោះនោះទេ តែក៏សម្រាប់អស់អ្នកដែលកំពុងទទួលការបង្ហាត់បង្រៀនសម្រាប់ក្រុមជំនុំនៅអនាគត និងអ្នកដឹកនាំដែលនឹងធ្វើការជាមួយនឹងក្រុមជំនុំ។ ខ្ញុំនឹងប្រាកដជាប្រើវាជាមួយនឹងនិស្សិតនៅមហាវិទ្យាល័យ ដែលខ្ញុំកំពុងបម្រើ»។

**លោក Matthew Pinson**, President, Welch College

«លោក អាជីត ហ្វឺនេនដូ បានផ្តល់មកយើងនូវអណ្តូងរ៉ែមាសនៃប្រាជ្ញាដែលកោតខ្លាចព្រះសម្រាប់ទ្រទ្រង់ជីវិតអាពាហ៍ពិពាហ៍ និងការចិញ្ចឹមបីបាច់គ្រួសារ។ ជំពូកនីមួយៗមាននូវការទទួលស្គាល់យ៉ាងស្មោះត្រង់នៅបញ្ហាជីវិតពិតៗ សេចក្តីជំនឿដែលមានទំនុកចិត្តមើលព្រះគុណរបស់ព្រះជាម្ចាស់ដែលគ្រប់គ្រាន់ និងអំណរដែលមានពេញទៅដោយសេចក្តីសង្ឃឹម ក្នុងការស្រវាដេញតាមជីវិត ដែលថ្វាយព្រះកិត្តិយសដល់ព្រះអម្ចាស់។ សូមអានសៀវភៅនេះ នោះលោកអ្នកនឹងទទួលបានការប្តេជ្ញាចិត្តជាថ្មី ក្នុងការថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់ក្នុងជីវិតអាពាហ៍ពិពាហ៍ និងជីវិតគ្រួសាររបស់លោកអ្នក»។

**លោក Colin S. Smith**, Senior Pastor, The Orchard, Arlington Heights, Illinois

«លោក អាជីត ហ្វឺនេនដូ បានកាត់ស្រាយសេចក្តីពិតនៃព្រះបន្ទូលយ៉ាងស្មោះត្រង់ ហើយក៏បានចែកចាយដែលមានការបន្ទាបខ្លួននូវប្រាជ្ញានៃបទពិសោធន៍របស់គាត់ ដើម្បីលើកទឹកចិត្តអ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទ ក្នុងការដឹកនាំដោយយកចិត្តទុកដាក់បានស្រឡាញ់គ្រួសារខ្លួនក្នុងរបៀបដែលនាំសិរីល្អទៅកាន់ព្រះជាម្ចាស់»។

**លោក Ed Stetzer**, President, LifeWay Research; author, Subversive Kingdom

«ជាទូទៅ គ្រួសារ និងដៃគូជីវិតដែលបម្រើក្នុងព័ន្ធកិច្ច គឺជាអ្នកដែលមានអារម្មណ៍ថាពួកគាត់កំពុងតែថប់ដង្ហើមក្រោមទម្ងន់នៃការត្រាស់ហៅឲ្យបម្រើព័ន្ធកិច្ច។ លោក អាជីត ហ្វឺនេនដូ បានរម្លឹកយើងថា គឺសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលផ្តល់ជូននូវខ្យល់ដង្ហើមថ្មីវិញក្នុងជីវិតរបស់យើង ខណៈពេលដែលយើងបម្រើទ្រង់ ក្នុងរបៀបដែលព្រះអង្គបានបង្កើតឲ្យយើងធ្វើ។ សៀវភៅនេះគឺជាសៀវភៅដែលយើងគួរយកចិត្តទុកដាក់ជាមួយ នឹងយកទៅអនុវត្តផងដែរ។ វាជាសៀវភៅដែលមានមូលដ្ឋានលើព្រះគម្ពីរ មានការជំរុញចិត្ត និងជាជំនួយក្នុងរបៀបដែលនឹងបំផ្លាស់បំប្រែទិសដៅនៃព័ន្ធកិច្ចគ្រួសារនៅជុំវិញពិភពលោក»។

**លោក Dan Wolgemuth**, President/CEO, Youth for Christ

# ជីវិតគ្រួសាររបស់ អ្នកដឹកនាំគ្រីស្ទបរិស័ទ

# The Family Life of a Christian Leader

Ajith Fernando

plovpit.com

*The Family Life of a Christian Leader*
English Edition © 2016 by Ajith Fernando
English Edition Published by Crossway
1300 Crescent Street
Wheaton, Illinois 60187, USA

ជីវិតគ្រួសាររបស់អ្នកដឹកនាំគ្រីស្ទបរិស័ទ
រក្សាសិទ្ធិ © ២០២៣ ដោយ Crossway
Khmer Edition © 2023 by Crossway

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើមដែលនៅប្រទេសអាមេរិកឡើយ។

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
បកប្រែដោយ៖ លោក ឈាង បូរ៉ា
ជំនួយការបកប្រែ៖ លោក វ៉ែល ណាថាន
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក ធីម៉ូថេ និងលោក ឯក សត្យា
ថ្លែងអំណរគុណចំពោះ៖ លោកស្រី កែវ សិរីវុឌ្ឍី, លោកស្រី ឡូញ ស្រីរដ្ឋ, និងលោកស្រី ថាវ ប៊ុនរី
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក ខែម បូឡុង

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ familylife.plovpit.com
បោះពុម្ពលើកទី១ ចំនួន ២000 ក្បាល គ.ស. ២០២៣។
ISBN-១៣: ៩៧៨-៩៩២៤-៥៦៦-០៦-៩

ជូនចំពោះមិត្តសម្លាញ់របស់ខ្ញុំ

ឡូគី (Lokki) និង ម៉ូហ៊ីនី អាបាយ៉ារ៉ាតនេ (Mohini Abhayaratne)

អានបាហាន (Anbahan) និង ស៊ីលវ៉ានធី អារីយ៉ាដូរ៉ៃ (Sylvanthi Ariyadorai)

ធីម៉ូធី (Timothy) និង សួរេនដ្រានី ដឺ អាលវីស (Surendrani de Alwis)

សេរ៉ាមែន (Ceraman) និង ស៊ូរេស៊ីនី ម៉ូសេ (Sureshini Moses)

អែម៉ាញូអែល (Emmanuel) និង ស៊ូហ្គានថា គូណារ៉ាតណាម (Sugantha Gunaratnam)

អូស្ទិន (Austen) និង រ៉ាឌីកា ម៉ាសក្រាងហេ (Radhika Mascranghe)

ដូក្លិស (Douglas) និង ស៊ីរ៉ានធិ ប៉ុនញា (Shiranthi Ponniah)

អែនឌ្រូ (Andrew) និង រ៉ូដា សាន់ឌ័រ ស៊ីញ (Rhoda Sunder Singh)

ដែលទទួលបានជោគជ័យក្នុងជីវិតអាពាហ៍ពិពាហ៍!

# មាតិកា


អារម្ភកថា...............................១៥

១ ព្រះជាម្ចាស់..............................២១

*ព្រះជាម្ចាស់មានការប្ដេជ្ញាព្រះទ័យចំពោះជីវិតអាពាហ៍ពិពាហ៍របស់យើង*

*សូមព្យាយាមឲ្យសមាជិកគ្រួសារទាំងអស់គ្នាមានការប្ដេជ្ញាចិត្តចំពោះព្រះជាម្ចាស់*

អំណាចនៃជីវិតដែលស្រស់ស្អាត

អំណាចនៃការអធិស្ឋាន

*ដាក់ព្រះជាម្ចាស់មុន*

*ការអធិស្ឋាន*

២ ការលះអាល័យខ្លួនឯង.....................៤៣

*ការមិនចង់លះអាល័យខ្លួនឯង៖ មូលហេតុចម្បងនៃជម្លោះ*

*របៀបនៃការលះអាល័យខ្លួនឯង ដែលជួយឲ្យគ្រួសារមានសុភមង្គល*

*មានជំនួយ*

*ចូរជឿថាព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ*

៣ សេចក្តីស្រឡាញ់ .........................៦១
*សេចក្តីស្រឡាញ់ជាគោលដៅនៅក្នុងខ្លួនវាផ្ទាល់១*
*វាជារឿងពិបាកណាស់ក្នុងការបង្ហាញសេចក្តីស្រឡាញ់ដល់អស់អ្នកដែលមិនចេះស្តាប់ចិត្ត*
*អាហ្គាពេ (Agape)៖ ការស្រឡាញ់ដោយសម្រេចចិត្ត*
៤ ផែនការដ៏ល្អរបស់ព្រះជាម្ចាស់...............៧៩
*ផែនការរបស់ព្រះជាម្ចាស់មានភាពស៊ីគ្នាជាមួយនឹងលក្ខណៈរបស់មនុស្ស*
ប្តីស្រឡាញ់ប្រពន្ធខ្លួន
ប្រពន្ធចុះចូល និងផ្តល់កិត្តិយសដល់ប្តីខ្លួន
*សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ប្រទាននូវកម្លាំងដល់យើង*
*ការរស់នៅដោយមានតុល្យភាពជាទូទៅជាឈើឆ្កាងរបស់យើង*
៥ ការស្រឡាញ់គ្នាផ្នែកផ្លូវភេទ..................៩៧
*មូលហេតុដែលព្រះជាម្ចាស់បង្កើតការរួមដំណេក*
*ការស្រឡាញ់គ្នាខាងផ្នែកផ្លូវភេទផ្តល់នូវសុវត្ថិភាពក្នុងទំនាក់ទំនងជីវិតអាពាហ៍ពិពាហ៍*
*បញ្ហាបទពិសោធន៍ផ្នែកផ្លូវភេទ និងអាកប្បកិរិយា*
*សេចក្តីស្រឡាញ់តយុទ្ធនឹងការខ្វះទំនុកចិត្ត*

៦ អំណរ ................................ ១២៣

*អំណរគឺជាទ្រព្យសម្បត្តិពិតប្រាកដនៅក្នុងផ្ទះ*

*របាំងជាខ្មាំងសត្រូវនៃអំណរ*

*អំណរលាតត្រដាងចេញតាមរយៈការសរសើរ*

៧ ការខកចិត្ត និងការឈឺចាប់ ................. ១៤១

*មិនមានគ្រួសារណាល្អឥតខ្ចោះទេ*

*ការឈឺចាប់ក្នុងគ្រួសារ*

*ការខកបំណង ការរអ៊ូរទាំ ការអត់ធ្មត់ ព្រះវត្តមានរបស់ព្រះជាម្ចាស់*

ការខកបំណង

ការរអ៊ូរទាំ

ការអត់ធ្មត់

ព្រះវត្តមានរបស់ព្រះជាម្ចាស់

ចូរទទួលសេចក្តីពិតខាងឯព្រះគម្ពីរ

*មានចំណុចខ្លះដែលអាចផ្លាស់ប្តូរបាន*

*ចូរតស៊ូក្នុងការអធិស្ឋាន*

*កុំអនុញ្ញាតឲ្យបញ្ហាបង្ខាំងការមើលថែគ្រួសារ*

៨ ការរួបរួមគ្នា ............................ ១៦៩

*ការរួបរួមគ្នាក្នុងភាពចម្រុះគ្នា*

*ការសន្ទនាកាន់តែនាំឲ្យមានការរួបរួមគ្នា*

*ការរួបរួមគ្នាក្នុងព័ន្ធកិច្ចរបស់យើង*
៩ ការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នា ..........១៨៩
*ច្បាប់ទី១៖ និយាយតែការពិត*
*ច្បាប់ទី២៖ ចូរខឹងចុះ តែកុំប្រព្រឹត្តអំពើបាប*
*ច្បាប់ទី៣៖ កុំឲ្យថ្ងៃលិចដោយនៅមានកំហឹង*
*ច្បាប់ទី៤៖ កុំផ្តល់ឱកាសដល់អារក្ស*
*គោលដៅគឺការរួបរួមគ្នា មិនមែនការយកឈ្នះ*
*ការសុំទោសគ្នា*
*ព្រះជាម្ចាស់នៅទីនោះ*
១០ ការសប្បាយចិត្តជាមួយនឹងកូនៗ............២០៩
*កូនៗគឺជាព្រះពរ*
*សូមប្រាប់ឲ្យកូនៗដឹងថាលោកអ្នកសប្បាយចិត្តនឹងពួកគាត់*
ការចង់ជួយ
ពេលយើងមិនអាចនៅទីណាមួយ ដើម្បីគាំទ្រពួកគាត់បាន
ការរក្សាសេចក្តីសន្យា
ការចំណាយពេលជាមួយនឹងកូនៗរបស់យើង
*បណ្តាំទៅកាន់ឪពុកម្តាយដែលមិនធ្លាប់ទទួលបានបទពិសោធន៍នៃ*
*ការសប្បាយចិត្តពីឪពុកម្តាយខ្លួន*

១១  ការសប្បាយ ទំនៀមទម្លាប់ និងសុវត្ថិភាព
សម្រាប់កូនៗ.................................២៣៣

*កូនក្មេង និងក្មេងជំទង់ចូលចិត្តមានការសប្បាយ*

ពាណិជ្ជភាវូបនីយកម្ម និងការប្រកួតប្រជែងគ្នាក្នុងការសប្បាយ

ទូរទស្សន៍ និងពិភពបណ្តាញសង្គម

ទំនៀមទម្លាប់ និងពិធីអបអរសាទរ

*ការមើលថែរក្សាកូនៗឲ្យមានសុវត្ថិភាព*

*សេចក្តីស្រឡាញ់របស់អ្នកម្តាយការពារកូនៗ*

ការមិនផ្តោតអារម្មណ៍ពេញលេញអាចនាំឲ្យកូនៗមានបញ្ហា

សេចក្តីស្រឡាញ់របស់ឪពុកម្តាយប្រយុទ្ធនឹងការប្រៀបធៀប

១២  ការដាក់ពិន័យកូនៗ.......................២៥៩

*ចូរណែនាំឲ្យពួកគាត់ស្គាល់ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់*

*ចូរស្តាប់តាមការដំបូន្មានរបស់សាវ័ក ប៉ុល*

កុំឲ្យចាក់រុកកូន

ដាក់ពិន័យដោយស្រឡាញ់

ណែនាំដោយមានចំណេះដឹង

ការថែរក្សា

*ឆ្លើយតបដោយមានភាពដូចៗគ្នា*

ឯកភាពគ្នាលើការដាក់ពិន័យ

ឈរឲ្យមាំ

*លើកទឹកចិត្តឲ្យមានអាកប្បកិរិយាដោយចេះគោរព*

*សម្រាប់សុភមង្គលរបស់ពួកគាត់ មិនមែនកេរ្តិ៍ឈ្មោះរបស់យើងទេ*

១៣ ការណែនាំកូនៗ ........................ ២៨៣

*ការណែនាំតាមរយៈជីវិត*

*នៅពេលដែលឪពុកម្ដាយបរាជ័យ*

*ការណែនាំតាមរយៈការបង្រៀន*

ចូរបង្រៀនព្រះបន្ទូល

ចូរនិយាយអំពីព្រះបន្ទូល[៨]

ចូរឲ្យតម្លៃលើព្រះបន្ទូល

ចូរផ្សាភ្ជាប់នូវដំណើររឿងនៃសេចក្ដីសង្គ្រោះ

ចូរប្រើប្រាស់ជំនួយដែលអាចមើលឃើញ (Visual Aids)

សេចក្ដីសន្និដ្ឋាន ........................ ៣១១

កំណត់យោង........................ ៣១៥

លិបិក្រមទូទៅ........................ ៣២៥

លិបិក្រមតាមព្រះគម្ពីរ........................ ៣៣៣

# អារម្ភកថា

សៀវភៅខ្ញុំភាគច្រើនកើតចេញផ្ទាល់ពីព័ន្ធកិច្ចរបស់ខ្ញុំ និងការដែលខ្ញុំខំព្យាយាមឆ្លើយតប ដោយមានមូលដ្ឋានលើព្រះគម្ពីរ ចំពោះចំណុចពិបាកៗដែលខ្ញុំជួបប្រទះក្នុងព័ន្ធកិច្ច។ ហើយការនោះក៏ជាការពិតសម្រាប់សៀវភៅនេះផងដែរ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំបានចំណាយពេលជាច្រើនក្នុងការផ្ដល់ប្រឹក្សាដល់ដៃគូជីវិតមុន និងក្រោយពិធីអាពាហ៍ពិពាហ៍ ដែលភាគច្រើនពួកគាត់បម្រើក្នុងព័ន្ធកិច្ច ខ្លះពេញពេល ហើយខ្លះទៀតស្ម័គ្រចិត្ត។ ហើយខ្ញុំក៏បានជួយមើលថែគ្រីស្ទបរិស័ទមួយចំនួនដែលជាអ្នកដឹកនាំ និងជាគ្រូគង្វាល ដែលបានចែកចាយជាមួយនឹងខ្ញុំអំពីជីវិតគ្រួសាររបស់ពួកគាត់ផងដែរ។

ខ្ញុំបានរៀបការអស់រយៈពេល៣៩ឆ្នាំ ហើយការនោះក៏បានបង្រៀនខ្ញុំជាច្រើន។ នៅប្រទេសកម្ពុជា អ្នករៀនបើកបរត្រូវមានស្លាក ឬក៏តែម «រៀនបើកបរ» នៅលើដំបូល សងខាង និងពីមុខពីក្រោយឡាន ដែលពួកគាត់កំពុងតែបើកបរ រហូតដល់ពេលដែលគាត់ទទួលបានប័ណ្ណបើកបរ។ ខ្ញុំត្រូវលើកឡើងថា ទោះបីខ្ញុំបានរៀបការអស់រយៈពេល៣៩ឆ្នាំហើយក៏ដោយ ក៏ខ្ញុំនៅបន្តបើកបរជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំដែលមានស្លាក «រៀនបើកបរ» ដែរ។ មានចំណុចជាច្រើនដែលខ្ញុំសរសេរនៅក្នុងសៀវភៅនេះគឺជាចំណុចដែលខ្ញុំបានរៀនសូត្រពីកំហុសរបស់ខ្ញុំ។ មានចំណុចមួយចំនួនគឺជាចំណុចដែលយើងត្រូវតយុទ្ធជាមួយ អស់ពេលពេញមួយជីវិត ដែលត្រង់នេះយើងត្រូវប្រើ

ប្រាស់ព្រះគុណដ៏គ្រប់គ្រាន់របស់ព្រះជាម្ចាស់។ ខ្ញុំពិតជាអរព្រះគុណដល់ព្រះជាម្ចាស់មែន ដែលទ្រង់បានប្រទានមកខ្ញុំនូវប្រពន្ធដែលអត់ធ្មត់ ហើយក៏បានទទួលយកខ្ញុំ ដែលមានពេញទៅដោយភាពទន់ខ្សោយ។ គាត់គឺជាហេតុផលចម្បងផ្នែកខាងមនុស្ស ដែលយើងទាំងពីរនាក់មានភាពអរសប្បាយក្នុងជីវិតគ្រួសារ។ ខ្ញុំជឿជាក់ថា មូលហេតុមួយដែលព្រះជាម្ចាស់បានប្រទានមកយើងនូវជីវិតគ្រួសារដែលអរសប្បាយគឺ ដើម្បីឲ្យយើងអាចជួយគ្រួសារផ្សេងៗទៀតដែលកំពុងតែតយុទ្ធ។ ប៉ុន្តែ ការអរសប្បាយរបស់យើងក៏កើតចេញពីការតយុទ្ធផងដែរ—គឺការតយុទ្ធដែលមានការទ្រទ្រង់ពីព្រះគុណរបស់ព្រះជាម្ចាស់។

អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានបង្រៀនគ្រីស្ទបរិស័ទដែលភាគច្រើនជាអ្នកដឹកនាំនូវគោលការណ៍ព្រះគម្ពីរដែលទ្រទ្រង់ការពារផ្ទះគ្រីស្ទបរិស័ទ ដែលមានដូចជា អាទិភាពចម្បងរបស់ព្រះជាម្ចាស់ សេចក្តីស្រឡាញ់ អំណារ និងភាពរួបរួមគ្នា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងព័ន្ធកិច្ចផ្ទាល់ខ្លួនរបស់ខ្ញុំ ក៏ខ្ញុំបានប្រឈមមុខនឹងចំណុចពិបាកៗ ទាក់ទងនឹងអ្វីដែលខ្ញុំបានបង្រៀនផងដែរ។ ឧទាហរណ៍៖ ខ្ញុំធ្លាប់ឃើញគ្រួសារដែលមិនសូវសប្បាយចិត្តជាច្រើន ហើយឪពុកម្តាយហាក់បីដូចជាមានការប្តេជ្ញាចិត្តជាមួយនឹងព្រះជាម្ចាស់ និងគោលការណ៍ព្រះគម្ពីរ។ ខ្ញុំក៏បានប្រតាយប្រតប់ចំណុចមិនធម្មតាទាំងនេះ ហើយស្វែងរករបៀបដែលយើងអាចឆ្លើយតបចំពោះវា ដោយយោងតាមព្រះគម្ពីរ។

ដូច្នេះ លោកអ្នកនឹងឃើញថា បន្ទាប់ពីការពិភាក្សាលើការបញ្ជាក់អះអាងចម្បងណាមួយអំពីជីវិតគ្រួសារ នោះខ្ញុំក៏បានដាក់បញ្ចូលនូវការពិភាក្សាដែលឆ្លុះបញ្ចាំងចេញពីព្រះគម្ពីរ និងការអនុវត្តមួយចំនួនអំពីរបៀបឆ្លើយតបចំពោះការលំបាកៗនៃការបញ្ជាក់អះអាងនោះ។ បន្ទាប់ពីជំពូកអំពីព្រះជាម្ចាស់ក៏មានជំពូកអំពីការលះអាល័យខ្លួនឯងផងដែរ។ ការពិភាក្សារបស់យើងលើប្រធានបទស្រឡាញ់ក៏រាប់បញ្ចូលនូវការពិភាក្សាលើភាពស្មុគស្មាញនៃការស្រឡាញ់ផងដែរ។ ការពិភាក្សាលើការរួមដំណេកក៏មាននូវការពិភាក្សាទាក់ទងទៅនឹងបញ្ហានៃការរួមដំណេកផងដែរ។ បន្ទាប់ពីជំពូកអំណារ យើងក៏មានមួយជំពូក

អំពីការខកចិត្ត និងការឈឺចាប់ ហើយបន្ទាប់ពីជំពូកនៃការរួបរួមគ្នា យើងក៏មានមួយជំពូកលើការឈ្លោះគ្នាដោយស្រឡាញ់ផងដែរ។ ហើយក៏មានការត្រាស់ហៅឲ្យមានការសប្បាយចិត្តជាមួយនឹងកូនៗ និងការត្រាស់ហៅមួយទៀតក្នុងការដាក់ពិន័យកូនៗ។

សៀវភៅព្យាយាមមានមូលដ្ឋានយ៉ាងរឹងមាំលើព្រះគម្ពីរ ហើយខណៈពេលនោះក៏ព្យាយាមអនុវត្តព្រះបន្ទូលក្នុងកាលៈទេសៈជាក់ស្តែងនៅក្នុងផ្ទះ។ លោកអ្នកនឹងឃើញថា ខ្ញុំមិនគ្រាន់តែរែកញែកលើខគម្ពីរដែលលើកឡើងចំៗលើបញ្ហាទាក់ទងនឹងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏យកគោលការណ៍មូលដ្ឋានព្រះគម្ពីរនៃអាកប្បកិរិយា ហើយព្យាយាមអនុវត្តចំណុចទាំងនោះនៅក្នុងជីវិតគ្រួសារដែរ។ ការនេះគាំទ្រការទទួលស្គាល់ថា ប្រសិនបើយើងអនុវត្តជំនឿគ្រីស្ទបរិស័ទយោងតាមព្រះគម្ពីរ យ៉ាងម៉ឹងម៉ាត់នៅឯផ្ទះ នោះយើងនឹងឈានទៅដល់ការដែលមានផ្ទះសំបែងដែលពេញទៅដោយសេចក្តីស្រឡាញ់ អំណរ និងភាពបរិសុទ្ធ តាមផែនការដ៏ល្អរបស់ព្រះ។

ខ្ញុំសូមថ្លែងអំណរគុណដល់អស់អ្នកដែលបានចែកចាយដំណើររឿងជីវិតរបស់ពួកគាត់ជាមួយនឹងខ្ញុំ ហើយក៏បានជួយឲ្យខ្ញុំមានការយល់ដឹងកាន់តែល្អប្រសើរ អំពីជីវិតរស់នៅនៃជំនឿគ្រីស្ទបរិស័ទដ៏ភ្លៀវភ្លា។ ហើយខ្ញុំក៏ចង់ថ្លែងអំណរគុណដល់គ្រូគង្វាលជាច្រើន និងអ្នកដឹកនាំគ្រីស្ទបរិស័ទ ដែលបានលើកទឹកចិត្តឲ្យខ្ញុំសរសេរចុះនូវប្រធានបទ ដែលខ្ញុំបានណែនាំនៅឯសិក្ខាសាលាអំពីគ្រួសារ។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសទៅកាន់លោក Andrew Sunder Singh ដែលជាប្រធានគណៈកម្មការ Youth for Christ គាត់បានជំរុញជាច្រើនដងឲ្យខ្ញុំសរសេរសៀវភៅដូចនេះ ដែលកំពុងមានតម្រូវការ។ ខ្ញុំក៏ចង់ថ្លែងអំណរគុណដល់ប្រពន្ធរបស់ខ្ញុំឈ្មោះ Nelun និង Nirmali and Asiri ដែលជាកូនៗរបស់យើង ពួកគាត់បានបង្រៀនអំពីជីវិតគ្រួសារដល់ខ្ញុំច្រើនជាងអ្នកផ្សេងៗទៀត។ ពួកគាត់បានបង្ហាញអំពីការអនុវត្ត ដែលមានការយោងតាមព្រះគម្ពីរ ទាក់ទងនឹងការអត់ធ្មត់ជាមួយនឹងប្តី និងឪពុកដែលមានចំណុចខ្សោយ

ជាច្រើន។ ខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងប្រពន្ធខ្ញុំ ទាក់ទងនឹងសៀវភៅនេះច្រើនជាងសៀវភៅផ្សេងៗទៀតដែលខ្ញុំបាននិពន្ធ ហើយការពិចារណារបស់គាត់ក៏បន្ថែមគុណសម្បត្តិជាច្រើនទៀតក្នុងសៀវភៅនេះ។ ខ្ញុំក៏ចង់ថ្លែងអំណរគុណដល់ឪពុកម្ដាយខ្ញុំ ដែលបានបង្ហាញថា មនុស្សពីរនាក់ដែលមិនមានភាពស៊ីគ្នាទាល់តែសោះ ក៏ជាមនុស្សដែលមិនព្រមបោះបង់គ្នាចោល ក៏អាចផ្ដល់ជូនដល់កូនៗរបស់ខ្លួននូវផ្ទះដែលមានភាពអរសប្បាយ និងសុវត្ថិភាពក្នុងការធំធាត់ឡើងក្នុងគ្រប់ផ្លូវ ជាពិសេសក្នុងផ្លូវរបស់ព្រះជាម្ចាស់ ដល់ថ្នាក់ថាកូនទាំងប្រាំរបស់ពួកគាត់ (ទាំងអស់ជាអ្នកជឿ ហើយមានចិត្តចង់បម្រើព្រះ) ទទួលឥទ្ធិពលពីជីវិតរបស់ពួកគាត់ ក្នុងជីវិតរបស់កូនៗ។

នៅពេលដែលខ្ញុំចាប់ផ្ដើមរៀបចំជាស៊េរីនៃការបង្រៀនដែលជាលទ្ធផលមាននៅក្នុងសៀវភៅនេះ មិនមានសៀវភៅណាដែលជួយខ្ញុំច្រើនជាងសៀវភៅ «ព្រះជាម្ចាស់ ជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារ៖ សង់មូលដ្ឋានគ្រឹះព្រះគម្ពីរជាថ្មី» (“God, Marriage, and Family: Rebuilding the Biblical Foundation”) និពន្ធដោយលោក Andreas J. Köstenberger ជាមួយនឹងលោក David W. Jones។[1] សៀវភៅដ៏ល្អមួយក្បាលនេះផ្ដល់ជូននូវមូលដ្ឋានគ្រឹះ យោងតាមព្រះគម្ពីរ សម្រាប់ទិដ្ឋភាពខុសៗគ្នា ទាក់ទងនឹងជីវិតរស់នៅក្នុងគ្រួសារគ្រីស្ទបរិស័ទ។ ខ្ញុំមានការភ្ញាក់ផ្អើល ហើយក៏ខ្មាសត្រង់ថា មិនសូវបានលើកជាសម្រង់សម្ដីប៉ុន្មានទេចេញពីសៀវភៅនោះ។ ខ្ញុំគិតថាមូលហេតុគឺដោយសារខ្ញុំបានទទួលគោលការណ៍ជាច្រើនចេញពីព្រះគម្ពីរតាមរយៈសៀវភៅនោះ ហើយបន្ទាប់មកខ្ញុំក៏បានស្វែងរកការអនុវត្តផ្ទាល់ខ្លួនតាមគោលការណ៍ទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំបានជំពាក់គុណសៀវភៅនេះយ៉ាងខ្លាំង។ ហើយខ្ញុំក៏ចង់ប្រាថ្នាសរសេរចុះនូវការដឹងគុណរបស់ខ្ញុំទៅកាន់លោក Greg Bailey ដែលធ្វើការនៅក្រុម Crossway គាត់ជាអ្នកឯកទេសកែសម្រួលសៀវភៅនេះ។

ខ្ញុំជឿជាក់ថា អំណោយដ៏ល្អបំផុតមួយដែលយើងអាចឲ្យដល់ក្រុមជំនុំលើ

ពិភពលោកសព្វថ្ងៃនេះគឺ ការមានការយល់ដឹងលើជីវិតគ្រួសារ ដែលមានសុខភាពល្អ ហើយចេះអនុវត្តយ៉ាងពេញទី។ ប៉ុន្តែ ប្រសិនបើយើងចង់ផ្តល់វិភាគទានទៅកាន់ជាតិសាសន៍យើង ដាច់ខាតជាដំបូងយើងត្រូវអនុវត្តដោយខ្លួនឯងផ្ទាល់សិន! ខ្ញុំសូមអធិស្ឋានថា សៀវភៅនេះនឹងជួយបម្រើមនុស្សជាច្រើននាក់ ជាប្រភពនៃការលើកទឹកចិត្តដល់ពួកគាត់ឲ្យត្រាប់តាមរបៀបនៃការរស់នៅក្នុងគ្រួសារ តាមព្រះគម្ពីរ។

# ១

# ព្រះជាម្ចាស់

ជាទូទៅ អ្នកដឹកនាំគ្រីស្ទបរិស័ទទទួលស្គាល់ថា ព្រះជាម្ចាស់គឺជាចំណុចដ៏សំខាន់បំផុតក្នុងជីវិតគ្រួសាររបស់ពួកគាត់ ដែលនេះមានន័យថា ការប្ដេជ្ញាចិត្តរបស់ពួកគាត់ទៅកាន់ព្រះជាម្ចាស់ និងការប្ដេជ្ញាចិត្តរបស់ព្រះជាម្ចាស់មកកាន់ពួកគាត់គឺជាចំណុចដ៏សំខាន់បំផុតក្នុងជីវិតគ្រួសាររបស់ពួកគាត់។ ប៉ុន្តែខណៈពេលដែលយើងទទួលស្គាល់ថាចំណុចនេះជាការពិត វាគឺជាការចាំបាច់ណាស់ដែលខ្ញុំត្រូវលើកឡើងនូវចំណុចមួយចំនួនទៀតអំពីតួនាទីរបស់ព្រះជាម្ចាស់នៅក្នុងជីវិតគ្រួសាររបស់យើង ក្នុងការចាប់ផ្ដើមសៀវភៅនេះ។

## ព្រះជាម្ចាស់មានការប្ដេជ្ញាព្រះទ័យចំពោះជីវិតអាពាហ៍ពិពាហ៍របស់យើង

ជារឿយៗ យើងចូលចិត្តលើកជាសម្រង់សម្ដីនៃប្រយោគរបស់លោក យ៉ូស្វេ ទាក់ទងនឹងការប្ដេជ្ញាចិត្តរបស់គាត់ក្នុងការបម្រើព្រះជាមួយនឹងគ្រួសាររបស់គាត់៖ «តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ» (យ៉ូស្វេ ២៤:១៥)។ ប៉ុន្តែ សំខាន់ជាងការសម្រេចចិត្តរបស់យើងជាគ្រួសារ ក្នុងការបម្រើព្រះអម្ចាស់ គឺការសម្រេចព្រះ

ទ័យរបស់ព្រះជាម្ចាស់ ក្នុងការប្រទានពរដល់ជីវិតអាពាហ៍ពិពាហ៍ និងគ្រួសាររបស់យើង។

ទាក់ទងនឹងជីវិតអាពាហ៍ពិពាហ៍ ព្រះយេស៊ូវបានមានបន្ទូលថា «ដូច្នេះកុំឲ្យអ្នកណាពង្រាត់មនុស្ស ដែលព្រះទ្រង់បានផ្សំផ្គុំគ្នាឡើយ» (ម៉ាថាយ ១៩:៦)។ ប្រយោគនេះបានក្លាយជាការប្រកាសដ៏ចម្បងមួយនៅក្នុងពិធីអាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទ។

នៅពេលដែលដៃគូជីវិតណាមួយរៀបចំពិធីអាពាហ៍ពិពាហ៍ ពួកគេពិនិត្យមើលចំណុចជាច្រើន៖ តើត្រូវអញ្ជើញនរណាខ្លះ? តើពួកគាត់គួរស្លៀកពាក់យ៉ាងដូចម្ដេច? តើអ្នកណានឹងតុបតែងព្រះវិហារ? តើអ្នកណានឹងលេងភ្លេង អធិប្បាយ ហើយផ្សំផ្គុំពិធីអាពាហ៍ពិពាហ៍ជាផ្លូវការ? តើអ្នកណានឹងចុះហត្ថលេខាធ្វើជាសាក្សី? តើនឹងមានពិធីកាត់ចំណងដៃផ្សេង ឬក៏គ្រាន់តែមានអាហារសម្រន់នៅព្រះវិហារបន្ទាប់ពីកម្មវិធី? ទាំងនេះគឺជាចំណុចសំខាន់ៗដែលត្រូវគិតគូ។ ទោះជាយ៉ាងណាក៏ដោយក៏មានដៃគូជីវិតតិចណាស់ ដែលគិតដោយយកចិត្តទុកដាក់អំពីពាក្យសច្ចាដែលពួកគាត់នឹងធ្វើនៅចំពោះព្រះជាម្ចាស់។ ពួកគេតែងតែចាត់ទុកពាក្យសច្ចាថាជាចំណុចចាំបាច់មួយនៃកម្មវិធី ប៉ុន្តែមិនមែនជាផ្នែកមួយដែលទាមទារឲ្យមានការរៀបចំខ្លាំងប៉ុន្មានទេ។

ទោះជាយ៉ាងណាក៏ដោយក៏ពាក្យសច្ចាជាគន្លឹះនៃជីវិតអាពាហ៍ពិពាហ៍ដែរ។ វាជាផ្នែកមួយនៃការតាំងសញ្ញាដែលធ្វើឡើងនៅថ្ងៃនោះ ជាការតាំងសញ្ញាដែលព្រះជាម្ចាស់ជាដៃគូចម្បង។ ព្រះអង្គមកប្រទានពរ ដៅចំណាំ និងការពារជីវិតអាពាហ៍ពិពាហ៍។ ហើយព្រះយេស៊ូវបានមានបន្ទូលថា ដោយសារព្រះជាម្ចាស់ភ្ជាប់ដៃគូជីវិតនោះជាមួយគ្នា នោះមិនគួរមានមនុស្ស ឬក៏ក្រុមមនុស្សណាមកបំបែកបំបាក់ពួកគាត់ឡើយ។ នេះសូម្បីតែក្នុងករណីដែលបុគ្គលបានរៀបការហាក់បីដូចជាមិនសមគ្នាក៏ដោយ។ បន្ទាប់ពីព្រះជាម្ចាស់បានភ្ជាប់ដៃគូជីវិតនោះជាមួយគ្នារួចហើយ ព្រះអង្គអាចប្រទានពួកគាត់នូវព្រះគុណក្នុងការរស់នៅជាមួយគ្នា ហើយបង្កើតឲ្យមានគ្រួសារល្អ។

ប្រាកដណាស់ ដៃគូជីវិតនោះនឹងទំនងជាប្រឈមមុខនឹងបញ្ហាពិបាកៗ ដែលហាក់បីដូចជាមិនអាចដោះស្រាយបានទាល់តែសោះ។ ប៉ុន្តែ ចំណុចពិតដែលថា ព្រះជាម្ចាស់បានចងភ្ជាប់ពួកគាត់ជាមួយគ្នាក៏ផ្ដល់ជូនពួកគាត់នូវទំនុកចិត្តដែលថា ព្រះអង្គក៏មានសមត្ថភាពថែរក្សាពួកគាត់ទុកជាមួយគ្នាផងដែរ។ ពួកគាត់ត្រូវខំយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហារបស់ខ្លួន ប៉ុន្តែពួកគាត់អាចធ្វើដូច្នោះបានដោយមានទំនុកចិត្តថា ប្រសិនបើពួកគាត់ស្ដាប់បង្គាប់ព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងជួយពួកគាត់ឲ្យដោះស្រាយបាន។ ដូច្នេះ ពួកគាត់មិនគួរនិយាយអំពីការលែងលះគ្នាឡើយ។ ពួកគាត់ម្នាក់ៗមិនត្រូវប្រាប់បុគ្គលណាផ្សេងទៀត ដែលមិនមែនជាដៃគូជីវិតរបស់ខ្លួនថា «អ្នកជាប្រភេទមនុស្សដែលខ្ញុំគួរបានរៀបការជាមួយ»។ ខ្ញុំធ្លាប់បានឮគ្រីស្ទបរិស័ទប្រាប់បុគ្គលម្នាក់ផ្សេងទៀត ដែលមានភេទខុសពីខ្លួនថា «ប្ដី/ប្រពន្ធរបស់ខ្ញុំមិនធ្វើឲ្យខ្ញុំស្កប់ចិត្តទេ» ដោយថ្លែងបញ្ជិតបញ្ជៀងថា បុគ្គលម្នាក់នោះអាចផ្ដល់ជូននូវការស្កប់ចិត្ត ដែលពួកគាត់នឹកចង់បានពីដៃគូជីវិតរបស់ខ្លួន។ ប្រយោគបែបនេះមិនត្រូវមានក្នុងជីវិតអាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទឡើយ។ ប្រយោគបែបនេះបង្ហាញថា ដៃគូមិនជឿថាព្រះជាម្ចាស់នឹងជួយឲ្យពួកគាត់មានជោគជ័យក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនឡើយ។

ការជឿគឺជាមូលដ្ឋានមួយនៃជំនឿគ្រីស្ទបរិស័ទ ហើយមានការអនុវត្តក្នុងគ្រប់ផ្នែកនៃជីវិត។ ទាក់ទងនឹងការអនុវត្តក្នុងជីវិតអាពាហ៍ពិពាហ៍ យើងជឿជាក់ថា ព្រះជាម្ចាស់បានដៅចំណាំការតាំងសេចក្ដីសញ្ញាជីវិតអាពាហ៍ពិពាហ៍ ក៏នឹងជួយរក្សាឲ្យជីវិតអាពាហ៍ពិពាហ៍របស់យើងមានសុវត្ថិភាព និងលូតលាស់រហូតដល់ទីបញ្ចប់។ ជំនឿនេះជួយឲ្យយើងមានកម្លាំងតយុទ្ធឲ្យបានគ្រួសារដែលមានសុភមង្គលដោយមិនចុះចាញ់នៅពេលដែលបញ្ហាកាន់តែធំ ឬក៏កាន់តែពិបាកមកដល់។ គ្រីស្ទបរិស័ទដែលមានជំនឿនឹងបដិសេធមិនព្រមចុះចាញ់សេចក្ដីល្បួង ដោយបោះដៃខ្លួនឡើងលើដោយអស់សង្ឃឹម ឬក៏អាណិតខ្លួនឯងនៅពេលដែលមានបញ្ហា។ តាមរយៈការទុកចិត្តលើសមត្ថភាពរបស់ព្រះ

ជាម្ចាស់ ពួកគាត់តយុទ្ធដោយមានជំនឿសម្រាប់ជីវិតអាពាហ៍ពិពាហ៍ដោយមានការបន្ទាបខ្លួន ដោយដឹងថាអាកប្បកិរិយានៃអំពើបាបរបស់ពួកគាត់អាចរារាំងការព្យាបាលរបស់ព្រះជាម្ចាស់តាមរយៈជំនឿ (យើងនឹងលើកឡើងបន្ថែមទៀតអំពីចំណុចនេះនៅក្នុងជំពូកបន្ទាប់)។

ការធានាថាព្រះជាម្ចាស់ដែលបានប្ដេជ្ញាព្រះទ័យទ្រង់ចំពោះគ្រួសាររបស់យើង គឺធំជាងគ្រប់បញ្ហាទាំងអស់ដែលយើងប្រឈមមុខដាក់ ក៏ជាប្រភពនៃសន្តិភាពដ៏ខ្ពស់ និងពេញទៅដោយសុវត្ថិភាពផងដែរ។ ព្រះគម្ពីរសន្យាថា «គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» (រ៉ូម ៨:២៨)។ នេះគឺជាការធានាដែលយើងនឹងយកមកប្រើប្រាស់ក្នុងគ្រប់វិបត្តិដែលជីវិតអាពាហ៍ពិពាហ៍ និងគ្រួសាររបស់យើងជួបប្រទះ។ យើងជឿថា ព្រះជាម្ចាស់អាចប្ដូរវិបត្តិណាមួយទៅជាអ្វីដែលល្អបាន។

ក្នុងការចាប់ផ្ដើមជីវិតអាពាហ៍ពិពាហ៍របស់យើង ខ្ញុំ ហើយនិងប្រពន្ធបានសម្រេចចិត្តគ្រាប់តាមការណែនាំរបស់សាវ័ក ប៉ុល «កុំឲ្យសេចក្ដីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ» (អេភេសូរ ៤:២៦) នៅពេលដែលយើងមិនឯកភាពគ្នា នោះយើងនឹងមិនចូលគេង លុះត្រាតែយើងដោះស្រាយវាសិនហើយស្ដារឡើងវិញនូវការរួបរួមគ្នា។ យើងទាំងពីរមានចរិតលក្ខណៈខុសគ្នាខ្លាំងណាស់ ដូច្នេះយើងត្រូវចំណាយពេលពីរបីឆ្នាំ ដើម្បីបន្សាំខ្លួនជាមួយគ្នា។ ជាលទ្ធផល ក្នុងឆ្នាំដំបូងៗនោះ យើងបានឈ្លោះគ្នាដោយមានសេចក្ដីស្រឡាញ់ជាច្រើនដង រហូតដល់យប់ជ្រៅ ទាល់តែយើងរកបានដំណោះស្រាយសិន។ ខ្ញុំរៀនបានមេរៀនដ៏សំខាន់មួយក្នុងអំឡុងពេលនោះ។ ដោយប្រើមាត់របស់ខ្ញុំ ខ្ញុំបាននិយាយទៅកាន់ប្រពន្ធរបស់ខ្ញុំ ហើយដោយប្រើត្រចៀករបស់ខ្ញុំ ខ្ញុំក៏បានស្ដាប់គាត់។ ប៉ុន្តែ នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំបានអធិស្ឋានទៅកាន់ព្រះជាម្ចាស់។ ជាទូទៅ ការអធិស្ឋានរបស់ខ្ញុំមានលក្ខណៈដូចនេះ៖ «ឱព្រះអង្គអើយ! ឱព្រះអើយ! សូមជួយពួកយើង!»។

ចំណេះដឹងដែលថា ព្រះជាម្ចាស់មានចំណែកក្នុងបញ្ហារបស់យើងបាន

ផ្លាស់ប្តូរទស្សនៈរបស់យើងទាំងស្រុងលើវា។ ក្នុងជម្រៅចិត្ត យើងបានទទួលបទពិសោធន៍នូវ "សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត" (ភីលីព ៤:៧) ដែលកើតឡើងជាលទ្ធផលនៃការដែលយើងឲ្យ "សេចក្តីអធិស្ឋាន នឹងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង" (ខ៦)។ សេចក្តីសុខសាន្តនោះបានគ្រប់គ្រងដួងចិត្តរបស់យើង" (កូឡូស ៣:១៥)។ ជាលទ្ធផល ការនោះបានបន្ធូរបន្ថយការឈ្លោះប្រកែកគ្នារបស់យើង។ តើយើងអាចនិយាយស្តីដោយមានចិត្តអាក្រក់ទៅកាន់ដៃគូជីវិត ឬក៏កូនៗរបស់យើង ឬក៏ប្រើប្រាស់ពាក្យជេរប្រមាថគ្នាដោយរបៀបណាបាន ខណៈពេលដែលព្រះជាម្ចាស់កំពុងតែគង់នៅទីនោះ ជាផ្នែកមួយនៃការសន្ទនាគ្នា? ហេតុអ្វីបានជាយើងគួរភ័យខ្លាច នៅពេលដែលយើងមានសេចក្តីសុខសាន្ត ដោយដឹងថា ព្រះជាម្ចាស់គង់នៅជាមួយយើង ដើម្បីជួយឲ្យយើងទទួលបានដំណោះស្រាយ? ការដឹងថាព្រះជាម្ចាស់បានប្តេជ្ញាព្រះទ័យទ្រង់ចំពោះជីវិតអាពាហ៍ពិពាហ៍របស់យើងនឹងជះឥទ្ធិពលយ៉ាងខ្លាំងលើអាកប្បកិរិយារបស់យើង ក្នុងការប្រឈមមុខជាមួយនឹងបញ្ហាដែលយើងជួបប្រទះ។

## សូមព្យាយាមឲ្យសមាជិកគ្រួសារទាំងអស់គ្នា មានការប្តេជ្ញាចិត្តចំពោះព្រះជាម្ចាស់

យើងមិនអាចនិយាយរំលងបានទេត្រង់ថា សេចក្តីប្រាថ្នាដ៏ធំបំផុតរបស់អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទសម្រាប់សមាជិកនៃគ្រួសាររបស់យើង គឺឲ្យពួកគាត់ក្លាយជាកូនរបស់ព្រះជាម្ចាស់ ហើយដើរតាមទ្រង់។ បំណងព្រះទ័យរបស់ព្រះជាម្ចាស់សម្រាប់សាសន៍អ៊ីស្រាអែលក៏ជាសេចក្តីប្រាថ្នារបស់យើងសម្រាប់គ្រួសារយើងដែរ៖ "ឱបើសិនជាគេមានចិត្តយ៉ាងនោះជាដរាបទៅអេះ ដើម្បីឲ្យគេបានកោតខ្លាចដល់អញ ហើយកាន់តាមគ្រប់ទាំងបញ្ញត្តិរបស់អញ ប្រយោជន៍ឲ្យគេ និងពួកកូនចៅគេ បានសប្បាយនៅជារៀងរាបដរាបទៅ" (ចោទិយកថា ៥:២៩)។

ខ្ញុំនឹងមិនចំណាយពេលច្រើនពេកក្នុងការលើកឡើងអំពីចំណុចដែលថា វាគឺជាចំណុចដ៏សំខាន់ណាស់ដែលគ្រីស្ទបរិស័ទពិតប្រាកដក៏ត្រូវរៀបការជាមួយនឹងគ្រីស្ទបរិស័ទពិតប្រាកដផងដែរ។ ការរិះគន់ជាចំហយ៉ាងខ្លាំងក្លានៅក្នុងកណ្ឌគម្ពីរអែសរ៉ាជំពូក៩ និង១០អំពីការរៀបការជាមួយនឹងអស់អ្នកដែលមិនដើរតាមព្រះជាម្ចាស់ផ្តល់ឲ្យយើងនូវការព្រមានយ៉ាងធ្ងន់ធ្ងរ ប្រឆាំងនឹងការពិចារណាចង់ធ្វើដូចនោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាជាការដ៏គួរឲ្យសោកស្តាយណាស់ ដែលគ្រីស្ទបរិស័ទជាច្រើនបានប្រព្រឹត្តដូចនោះ។ អំណាចនៃសេចក្តីស្រឡាញ់ ឬក៏ការបង្ខំពីឪពុកម្តាយខ្លាំងមិនអាចទប់ទល់បានដល់ថ្នាក់ថា ពួកគាត់ជ្រើសរើសមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយរៀបការជាមួយនឹងអ្នកមិនជឿ។ ប៉ុន្តែ អរព្រះគុណព្រះជាម្ចាស់ ដែលទ្រង់មិនបានបោះបង់ចោលអស់អ្នកដែលបានកែប្រែចិត្តចេញពីការសម្រេចចិត្តខុសឡើយ។ សាវ័ក ប៉ុល បង្រៀនថាបុគ្គលដែលបានរៀបការជាមួយនឹងអ្នកមិនជឿគួរបន្តនៅស្មោះត្រង់ជាមួយនឹងដៃគូជីវិតខ្លួន (១កូរិនថូស ៧:១២-១៣)។ គាត់ថែមទាំងបានលើកឡើងថា ដោយសារអ្នកជឿ នោះក្នុងអត្ថន័យមួយ ដៃគូជីវិតដែលមិនមែនជាអ្នកជឿក៏ទទួលបានភាពបរិសុទ្ធ ដែលជាលទ្ធផលនាំឲ្យកូនៗដែលកើតក្នុងជីវិតអាពាហ៍ពិពាហ៍នោះបរិសុទ្ធដែរ។

តើយើងអាចធ្វើអ្វីខ្លះ ដើម្បីលើកទឹកចិត្តឲ្យសមាជិកគ្រួសារយើងដើរតាមព្រះ? សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវសកម្មភាពដ៏មានប្រសិទ្ធភាពពីរយ៉ាងដែលយើងអាចធ្វើបាន។

### *អំណាចនៃជីវិតដែលស្រស់ស្អាត*

សាវ័ក ពេត្រុស បង្ហាញអំពីរបៀបដ៏សំខាន់ក្នុងការដែលគ្រីស្ទបរិស័ទព្យាយាមនាំដៃគូជីវិតរបស់ខ្លួនដែលមិនមែនជាអ្នកជឿទៅកាន់ព្រះគ្រីស្ទ។ គាត់បានថ្លែងបញ្ជិតបញ្ជៀងអំពី ចំណុចស្អាតស្អំនៃការរស់នៅរបស់ពួកគាត់ ជាជាងពាក្យពេចន៍គឺជាអ្វីដែលមានអំណាចខ្លាំងជាងគេក្នុងការពិភាក្សាគ្នាជាមួយ

នឹងដៃគូជីវិតដែលមិនមែនជាអ្នកជឿ។ គាត់បានលើកឡើងថា “ពួកស្រីៗ ត្រូវចុះចូលចំពោះប្ដីខ្លួនបែបដូច្នោះដែរ ដើម្បីបើមានអ្នកណា ដែលមិនព្រមស្ដាប់បង្គាប់ តាមព្រះបន្ទូល នោះប្រពន្ធនឹងទាញចិត្តមកបាន ដោយសារកិរិយាល្អ ក្រៅពីព្រះបន្ទូល ដោយអ្នកនោះឃើញកិរិយាបរិសុទ្ធ ដែលប្រពន្ធប្រព្រឹត្តយ៉ាងកោតខ្លាចដល់ព្រះ” (១ពេត្រុស ៣:១-២)។ ហើយគាត់ក៏បន្តបង្ហាញអំណាចនៃជីវិតដែលស្រស់ស្អាត៖ “គឺតែងចំពោះមនុស្សលាក់កំបាំងក្នុងចិត្តវិញ ដោយគ្រឿងដ៏មិនចេះពុករលួយរបស់វិញ្ញាណសំឡូត ហើយរម្យទម នោះឯងជាសេចក្តី ដែលមានតម្លៃវិសេសនៅចំពោះព្រះ” (៤)។ សព្វថ្ងៃនេះ មានការផ្ដោតយ៉ាងខ្លាំងក្នុងការឲ្យមនុស្សមានភាពស្រស់ស្អាត នៅពេលដែលពួកគាត់នៅក្រៅផ្ទះរបស់ខ្លួន។ នៅត្រង់នេះសាវ័ក ពេត្រុស កំពុងតែបង្រៀនថា ការបំពេញចិត្តដៃគូជីវិតយើងក្នុងការបង្ហាញអាកប្បកិរិយា គឺសំខាន់ខ្លាំងណាស់។ កណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនក៏បានសរសើរភាពស្រស់ស្អាតខាងរាងកាយខាងក្រៅដែរ។ ទោះជាយ៉ាងណាក៏ដោយក៏នៅក្នុងចំណុចនោះ ទាំងប្ដី និងប្រពន្ធក៏ត្រូវស្អាតសម្រាប់គ្នាផងដែរ មិនមែនសម្រាប់ឲ្យលោកីយ៍ខាងក្រៅឃើញនោះទេ។ របៀបមានគ្រួសារដែលយោងតាមព្រះគម្ពីរគឺពិតជាផ្ទុយគ្នាពីប្រពៃណីមែន! គោលដៅចម្បងរបស់យើងក្នុងការមានភាពស្រស់ស្អាត គឺដើម្បីនាំឲ្យដៃគូជីវិតរបស់យើងមានអំណរ!

លោក រ៉ុដនី “ចុបស៊ី” ស្មិត (Rodney “Gypsy” Smith) ដែលជាអ្នកផ្សាយដំណឹងល្អម្នាក់ (ឆ្នាំ១៨៦០–១៩៤៧) បានបម្រើបេសកកម្មវេស្លី (Wesleyan) មួយរយៈ នៅឯទីក្រុងមែនឆិស្ទ័រ ប្រទេសអង់គ្លេស។ មានស្ត្រីម្នាក់ក្នុងព័ន្ធកិច្ចនោះតែងតែសុំឲ្យគេអធិស្ឋានឲ្យប្តីគាត់ឈ្មោះ ចន កែប្រែចិត្ត។ គួរឲ្យសោកស្ដាយណាស់ដែល ស្ត្រីម្នាក់នោះក៏ងាយច្រឡោតខឹងផងដែរ។ ពេលខ្លះ នៅពេលដែលប្តីរបស់គាត់ហៀបនឹងចុះចូលចំពោះអំណះអំណាងរបស់ព្រះគ្រីស្ទ គាត់តែងតែធ្វើឲ្យប្ដីរបស់គាត់ខឹង ដោយគាត់ច្រឡោតខឹង។ ប្ដីរបស់គាត់តែងតែនិយាយថា “ម៉ារា អូនអើយ! ប្រសិនបើនេះជាសាសនា

នោះបងមិនចង់មានអ្វីពាក់ព័ន្ធនឹងវាទេ»។ បន្ទាប់ពីនោះ គាត់ក៏បានសូមអភ័យទោស ហើយសូមឲ្យប្តីគាត់អត់ទោសគាត់ ប៉ុន្តែគាត់ក៏បានប្រើប្រាស់ជាទម្លាប់នូវការច្រឡោតខឹងរបស់ប្រពន្ធគាត់ជាលេសមិនដើរតាមព្រះគ្រីស្ទ។

មានថ្ងៃមួយលោក ស្មិត បាននិយាយជាមួយនឹងស្ត្រីនោះដោយស្មោះត្រង់ ហើយបានប្រាប់គាត់ថា គាត់ត្រូវយកឈ្នះលើការច្រឡោតខឹង។ គាត់បានធានាថា ព្រះគ្រីស្ទនឹងប្រទាននូវព្រះគុណដល់គាត់ ដើម្បីឲ្យមានសមត្ថភាពទប់ទម្លាប់គាត់។ ដោយជឿលើព្រះជាម្ចាស់ គាត់បានប្តេជ្ញាចិត្តចាប់ផ្តើមជំពូកថ្មីក្នុងជីវិតរបស់គាត់។ ការនោះបានកើតឡើងនាពេលមួយដែលពួកគាត់កំពុងតែជួសជុលផ្ទះរបស់ខ្លួន។ លោកស្រី ម៉ារា ទើបតែដាក់កម្រាលព្រំ និងអំពូលពិដានថ្មី ដែលគាត់បានព្យួរលើរបៀង។ ដោយមិនបានដឹងអំពីអំពូលថ្មីលោក ចន បានមកផ្ទះដោយលីអ្វីមួយលើស្មាគាត់។ ពេលដែលគាត់កាច់ជ្រុង គាត់ក៏បានប៉ះអំពូល ហើយវាក៏បានធ្លាក់បែក។

លោក ចន បានត្រៀមខ្លួនសម្រាប់ការឆ្លើយតបទូទៅរបស់ប្រពន្ធគាត់ ពាក្យពេចន៍កំហឹងឥតល្ហែ និងការនិយាយរិះគន់ខ្លាំងៗ។ ប៉ុន្តែ ជាជាងប្រឈមមុខនឹងការឆ្លើយតបតាមធម្មតាលោក ចន មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលមិនឮអ្វីសោះ។ ផ្ទុយទៅវិញ ប្រពន្ធរបស់គាត់បានមើលពីកាំជណ្តើរ ហើយគ្រាន់តែនិយាយយ៉ាងសាមញ្ញថា៖ «មិនអីទេបង! មិនអីទេ។ យើងអាចទិញអំពូលថ្មីមួយទៀត»។ ដោយមានការភាន់ភាំង និងមានការភ្ញាក់ផ្អើល លោក ចន ក៏បានមើលទៅកាន់គាត់។

«ម៉ារា មានបញ្ហាអីអូន?»។

គាត់បានឆ្លើយយ៉ាងស្ងប់ស្ងាត់ថា «ឱបងអើយ! អូនបានជឿលើព្រះយេស៊ូវ ហើយសូមឲ្យទ្រង់ព្យាបាលអូននូវការច្រឡោតខឹង»។

ដោយនៅមានការភ្ញាក់ផ្អើល និងការឆ្លើយតបដែលមិននឹកស្មានដល់របស់ប្រពន្ធគាត់លោក ចន បានបន្លឺថា «អើ បើព្រះអង្គបានព្យាបាលអូន ឥឡូវសូមចុះមកក្រោម ហើយអធិស្ឋានសម្រាប់បង ដ្បិតនោះជាអ្វីដែលបងចង់

បាន។ ប្រសិនបើមានចំណុចល្អមគ្រប់គ្រាន់ក្នុងសាសនានេះ ដើម្បីព្យាបាលការច្រឡោតខឹងរបស់អូន នោះបងក៏ចង់បានសាសនានោះដែរ»។ បន្ទាប់ពីបានអធិស្ឋានអស់ជាច្រើនឆ្នាំ ហើយនៅថ្ងៃនោះលោក ចន ក៏បានកែប្រែចិត្ត។[១]

នៅខាងមុខទៀតយើងនឹងឃើញអំពីរបៀបនៃចំណុចសំខាន់នៃពាក្យពេចន៍នៅក្នុងផ្ទះ ប៉ុន្តែដោយឡែកពីភាពស្រស់ស្អាតនៃជីវិតនៃសេចក្តីស្រឡាញ់ នោះពាក្យពេចន៍គ្មានអំណាចទេ។ មានសាច់រឿងជាច្រើនអំពីកូនៗដែលបះបោរ ប៉ុន្តែក្រោយមកទៀតមិនអាចបំភ្លេចគំរូនៃសេចក្តីស្រឡាញ់ ដែលមានក្នុងជីវិតម្តាយខ្លួន ហើយនៅចុងបញ្ចប់ក៏បានថ្វាយខ្លួនទៅកាន់ព្រះគ្រីស្ទ។

## *អំណាចនៃការអធិស្ឋាន*

អមគ្នាជាមួយនឹងជីវិតដែលស្រស់ស្អាត ការអធិស្ឋានក៏ជះឥទ្ធិពលយ៉ាងខ្លាំងក្នុងការនាំឲ្យសមាជិកគ្រួសារទទួលបានសេចក្តីសង្គ្រោះ។ លោក អេប៉ាប្រាស ទំនងជាបុគ្គលដែលបាននាំដំណឹងល្អទៅកាន់ទីក្រុងកូឡូស (កូឡូស ១:៧)។ គាត់បាននៅជាមួយនឹងសាវ័ក ប៉ុល នៅពេលដែលសាវ័ក ប៉ុល សរសេរសំបុត្រទៅកាន់ក្រុមជំនុំកូឡូស។ សាវ័ក ប៉ុល សរសេរអំពីលោក អេប៉ាប្រាស ថា៖ «អ្នកអេប៉ាប្រាស ជាបាវបម្រើនៃព្រះគ្រីស្ទ ដែលមកពីពួកអ្នករាល់គ្នា គាត់សូមជម្រាបសួរមកអ្នករាល់គ្នាដែរ គាត់ខំប្រឹងអធិស្ឋានជានិច្ច ឲ្យអ្នករាល់គ្នាបានឈរជាគ្រប់លក្ខណ៍ ហើយពេញខ្នាត តាមព្រះហឫទ័យនៃព្រះគ្រប់ជំពូក» (កូឡូស ៤:១២)។ ឪពុកខាងឯវិញ្ញាណកំពុងតែខំប្រឹង ឬក៏ «តយុទ្ធ» (គខប) ក្នុងការអធិស្ឋានសម្រាប់បងប្អូនក្រុមជំនុំកូឡូសដែលជាអ្នកជឿ ខណៈពេលដែលគាត់នៅឃ្លាតពីពួកគេ។ ដូចគ្នាផងដែរ មិនយូរប៉ុន្មានបន្ទាប់ពីគាត់បានលើកឡើងនូវទុក្ខព្រួយដ៏ខ្លាំង ទាក់ទងនឹងចំណុចពិតដែលថាបងប្អូនរបស់គាត់ សាសន៍យូដា មិនទាន់បានទទួលសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទ (រ៉ូម ៩:១-៣) សាវ័ក ប៉ុល មានប្រសាសន៍ថា «បងប្អូនអើយ បំណងចិត្តខ្ញុំ និងសេចក្តីដែលខ្ញុំអង្វរដល់ព្រះ ឲ្យសាសន៍អ៊ីស្រាអែល នោះគឺឲ្យគេបានសង្គ្រោះ»

(១០:១)។ មិនថាយើងមានទេវវិទ្យាយ៉ាងដូចម្ដេចទេ ទាក់ទងទៅនឹងការជ្រើសតាំង ក៏យើងត្រូវតែទទួលស្គាល់ថា ព្រះជាម្ចាស់ប្រើប្រាស់ការអធិស្ឋានជាយានដើម្បីនាំឲ្យមនុស្សទទួលបានសេចក្ដីសង្គ្រោះ។

ជាទូទៅ មានសង្គ្រាមដ៏ធំកំពុងកើតឡើងសម្រាប់ព្រលឹងនៃសមាជិកគ្រួសារយើង។ ទោះបើពេលខ្លះយើងមិនអាចនិយាយទៅកាន់ពួកគាត់អំពីព្រះជាម្ចាស់បាន ក៏យើងនៅអាចនិយាយទៅកាន់ព្រះជាម្ចាស់អំពីពួកគាត់បានដែរ។ លោកគ្រូ អហ្គូស្ទីន អ័រិលឡីស៍ (Augustine Aurelius ឆ្នាំ៣៥៤–៤៣០) ដែលជាអ្នកដឹកនាំម្នាក់នៅទីក្រុងហិផ្ពូ (Hippo) នៅឯអាហ្វ្រិកខាងជើង គឺជាទេវវិទូដែលបានជះឥទ្ធិពលយ៉ាងខ្លាំងមួយរូប ក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ។ គាត់បានទទួលឥទ្ធិពលយ៉ាងខ្លាំង តាមរយៈការគោរពបូជាចំពោះសាសនា និងគំរូនៃអ្នកម្ដាយរបស់គាត់លោកស្រី ម៉ូនីកា ដែលជាគ្រីស្ទបរិស័ទម្នាក់។ ប៉ុន្តែ ការនោះមិនគ្រប់គ្រាន់ក្នុងការនាំឲ្យគាត់កែប្រែចិត្តបែរទៅរកព្រះគ្រីស្ទ ឬក៏រារាំងគាត់មិនឲ្យរស់នៅជីវិតបែបអសីលធម៌ទេ។ គឺកាលគាត់មានអាយុ៣៣ឆ្នាំទើបគាត់ពិតជាបានចុះចូលចំពោះព្រះគ្រីស្ទមែន។ ក្នុងសៀវភៅជីវប្រវត្តិរបស់គាត់ដែលមានចំណងជើងថា *«ការលន់តួ»*[២] គាត់បានលើកឡើងយ៉ាងក្បោះក្បាយអំពីការជះឥទ្ធិពលនៃការអធិស្ឋានរបស់អ្នកម្ដាយគាត់ ក្នុងការកែប្រែចិត្តរបស់គាត់។ ជាការដ៏គួរឲ្យចាប់អារម្មណ៍ វាមិនមែនគ្រាន់តែការអធិស្ឋានរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានរួមនូវជីវិតគំរូរបស់គាត់ផ្ទាល់ និងការអង្វរឥតឈប់ឈររបស់ម្ដាយគាត់សូមឲ្យគាត់កែប្រែជីវិតរស់នៅរបស់គាត់ ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងលើគាត់។ ព័ន្ធកិច្ចលើផែនដីរបស់គាត់ក៏បានឈានដល់ទីបញ្ចប់ ហើយគាត់ក៏បានស្លាប់ប៉ុន្មានថ្ងៃបន្ទាប់ពីកូនរបស់គាត់បានកែប្រែចិត្ត។

ក្នុងការសិក្សាអំពីបេសកកម្មនៅអាស៊ីខាងត្បូង ឈ្មោះលោកស្កូដ័រ គឺជាឈ្មោះដ៏សំខាន់មួយ។ លោកបណ្ឌិត ចន ស្កូដ័រ (John Scudder) មានស្រុកកំណើតនៅប្រទេសអាមេរិក គាត់បានមកប្រទេសស្រីលង្កា (Sri Lanka) ដើម្បីធ្វើជាបេសកជន ហើយបន្ទាប់មកក៏បានទៅប្រទេសឥណ្ឌា។ កូនទាំង

ប្រាំពីរនាក់របស់គាត់ក៏បានក្លាយជាបេសកជនផងដែរ។ លោក ចន បាន មានប្រសាសន៍ថា អ្នកម្ដាយនៃកូនទាំងប្រាំពីរនាក់របស់គាត់ គឺលោកស្រី ហ៉ារីអាត (Harriet) បានអធិស្ឋានឲ្យកូនគាត់ចូលនគរព្រះ។ ប្រពន្ធគាត់មាន ទម្លាប់ចំណាយពេលនៅថ្ងៃខួបកំណើតកូននីមួយៗ ដោយការតមអាហារ និង អធិស្ឋានឲ្យកូននោះ។ លោកស្រី Ida Scudder (១៨៧០-១៩៥៩) ដែល ជាចៅទួតរបស់លោក ចន និងលោកស្រី ហ៉ារីអាត បានបើកមហាវិទ្យាល័យ សាលាពេទ្យ និងមន្ទីរពេទ្យ វិលឡូរ ( Vellore Medical College) នៅខេត្ត តាមីល ណាឌូ ប្រទេសឥណ្ឌាខាងត្បូង ( Tamil Nadu, South India)។

ឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទត្រូវតែបង្កើតរបៀបណាមួយ ដើម្បីអធិស្ឋាន ឲ្យកូនៗរបស់ខ្លួន។ ខ្ញុំលើកឡើង «របៀបណាមួយ» ពីព្រោះការធ្វើបែបនោះ យើងងាយនឹងធ្វេសប្រហែសឲ្យវារំលងពីគំនិតយើង ហើយយើងក៏អាចភ្លេច អធិស្ឋានផងដែរ។ ដូច្នេះ យើងត្រូវតែបង្កើតទម្លាប់ ដែលនឹងធានាថាយើង នឹងអធិស្ឋានសម្រាប់កូនៗរបស់យើង។ នៅពេលដែលឪពុកម្ដាយអធិស្ឋាន ជាមួយគ្នា ការអធិស្ឋានសម្រាប់កូនៗរបស់ខ្លួនក៏ត្រូវតែមានចំណែកដោយមិន អាចរំលងបាន ក្នុងពេលនៃការអធិស្ឋាននោះ។ ក្នុងចំណោមសំបុត្រទាំង១៣ របស់សាវ័ក ប៉ុល គាត់បានលើកឡើងអំពីការដែលគាត់អធិស្ឋានសម្រាប់អ្នក ទទួលសំបុត្រគាត់១០ក្រុម។ ប៉ុន្តែ សម្រាប់លោក ធីម៉ូថេ ដែលជាកូនខាងឯ វិញ្ញាណរបស់គាត់ គាត់បានលើកឡើងថាគាត់បានអធិស្ឋាន «ទាំងយប់ទាំង ថ្ងៃ» (២ធីម៉ូថេ ១:៣) ។ ក្នុងជីវិតអធិស្ឋានរបស់យើង យើងត្រូវអធិស្ឋានជា គោលសម្រាប់ទាំងកូនខាងឯសាច់ឈាម និងដៃគូជីវិតរបស់យើង ក៏ដូចជា កូនខាងឯវិញ្ញាណរបស់យើងផងដែរ។ យើងគួរអធិស្ឋានសម្រាប់ពួកគាត់ជា ប្រចាំថ្ងៃ ទំនងជាច្រើនដងក្នុងមួយថ្ងៃ។ នៅពេលដែលកូនៗរបស់យើងចាក ចេញពីផ្ទះ របៀបមួយដែលយើងអាចបំពេញតួនាទីជាឪពុកម្ដាយ គឺតាមរយៈ ការអធិស្ឋានសម្រាប់ពួកគាត់។ យើងអាចតាមដានការរីកចម្រើនរបស់គាត់តាម រយៈការអធិស្ឋានរបស់យើង ហើយលើកនូវតម្រូវការរបស់ពួកគាត់ទៅកាន់

ព្រះជាម្ចាស់។ ហើយប្រសិនបើពួកគាត់មិនទាន់បានកែប្រែចិត្តនៅឡើយ នោះយើងអាចអធិស្ឋានសូមឲ្យពួកគាត់បានសង្គ្រោះ។

នៅក្នុងជំពូក១៣ ខ្ញុំនឹងពិភាក្សាអំពីចំណុចសំខាន់នៃការបង្រៀនព្រះបន្ទូលក្នុងជីវិតកូនៗ។

## ដាក់ព្រះជាម្ចាស់មុន

ព្រះបន្ទូលរបស់ព្រះយេស៊ូវ «ចូរស្វែងរកនគរ នឹងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង» (ម៉ាថាយ ៦:៣៣) គឺសម្រាប់គ្រីស្ទបរិស័ទទាំងអស់គ្នា ដែលមានរួមទាំងអ្នកដឹកនាំ។ គោលការណ៍នៅពីក្រោយការប្រឹក្សារបស់សាវ័ក ប៉ុល ទៅកាន់កូនៗទាក់ទងទៅនឹងការមើលថែឪពុកម្ដាយដែលមានវ័យចំណាស់—«នោះត្រូវឲ្យកូនចៅនោះរៀនឲ្យចេះគោរពប្រតិបត្តិ ដល់ពួកផ្ទះខ្លួនជាដើម» (១ធីម៉ូថេ ៥:៤)—ក៏ទាក់ទងទៅនឹងឪពុកម្ដាយផងដែរ។ នៅពេលដែលអ្នកដឹកនាំអនុវត្តគោលជំនឿគ្រីស្ទបរិស័ទនៅក្នុងផ្ទះរបស់ខ្លួន ការនេះនាំឲ្យមានទំនុកចិត្តក្នុងការដឹកនាំ និងព័ន្ធកិច្ចរបស់ពួកគាត់។ យើងលើកទឹកចិត្តឲ្យសមាជិកគ្រួសាររបស់យើងមានការប្ដេជ្ញាចិត្តទាំងស្រុងចំពោះព្រះជាម្ចាស់ ហើយអស់អ្នកដែលយើងកំពុងតែធ្វើការជាមួយនឹងឃើញអំពីចំណុចនេះ។ ដូចជាអ្នកដឹកនាំដ៏ល្អក្នុងការថ្លែងសន្ទរកថាដ៏ល្បីរបស់លោក យ៉ូស្វេ ទៅកាន់សាសន៍អ៊ីស្រាអែល គាត់បានលើកទឹកចិត្តឲ្យរាស្ត្ររបស់ព្រះអង្គមានការប្ដេជ្ញាចិត្តទាំងស្រុងចំពោះព្រះជាម្ចាស់៖ «ដូច្នេះ ឥឡូវនេះ ចូរកោតខ្លាចដល់ព្រះយេហូវ៉ា ហើយគោរពប្រតិបត្តិដល់ទ្រង់ដោយចិត្តស្មោះត្រង់ ហើយពិតប្រាកដចុះ ចូរលះចោលអស់ទាំងព្រះដែលពួកឰយុកោឯងបានគោរពប្រតិបត្តិ នៅខាងនាយទន្លេ ហើយនៅស្រុកអេស៊ីព្ទនោះចេញ ត្រូវឲ្យឯងរាល់គ្នាគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាវិញ» (យ៉ូស្វេ ២៤:១៤)។ គាត់បានអមការបបួលគ្នានោះជាមួយនឹងការប្ដេជ្ញាចិត្តរបស់គាត់ផ្ទាល់ ក្នុងការធ្វើដូចគ្នាជាមួយនឹងគ្រួសាររបស់គាត់ដែរ៖ «តែឯ

អញ នឹងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ» (ខ១៥)។

ទោះជាយ៉ាងណាក៏ដោយក៏អ្នកដឹកនាំនៅតែងាយធ្លាក់ចូលក្នុងសេចក្ដីល្បួង ទាក់ទងនឹងការសម្រេចចិត្តសម្រាប់គ្រួសារ ដែលទទួលឥទ្ធិពលពីស្ដង់ដាលោកីយ៍ ហើយប្រព្រឹត្តិល្មើសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ វាជាការងាយស្រួលណាស់ក្នុងការដែលយើងមើលរំលងចំណុចពិតដែលថា ប្រសិនបើយើងដើរតាមផ្លូវរបស់ព្រះជាម្ចាស់ នោះព្រះអង្គនឹងប្រទាននូវរាល់គ្រប់អ្វីៗដែលយើងត្រូវការ ដើម្បីឲ្យជីវិតល្អប្រសើរឡើងដែលអាចទៅរួចបាន។ យើងអាចមានមហិច្ឆតាសម្រាប់ខ្លួនឯង និងសម្រាប់កូនៗរបស់យើង ដែលទំនងជានឹងនាំយើង ហើយនិងពួកគាត់មានភាពអន់ថយក្នុងជីវិតខាងវិញ្ញាណ។ នៅក្រោមឥទ្ធិពលនៃសេចក្ដីប្រាថ្នា សម្រាប់ជោគជ័យលើផែនដីនេះ យើងក៏ទំនងជាភ្លេចសំណួរនានារបស់ព្រះយេស៊ូវ៖ «ដ្បិតបើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរ ឲ្យបានព្រលឹងខ្លួនវិញ?» (ម៉ាថាយ ១៦:២៦)។

យើងមិនអាចសន្មតថាអ្នកដឹកនាំនឹងប្រតិបត្តិតាមជំនឿគ្រីស្ទបរិស័ទជាស្វ័យប្រវត្តិជាមួយនឹងគ្រួសាររបស់ពួកគាត់បានឡើយ។ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវឧទាហរណ៍មួយចំនួន ដែលលើកឡើងនូវចំណុចលំបាកៗមួយចំនួនដែលអ្នកដឹកនាំប្រឈមមុខជាមួយ។

នៅពេលដែលកូនប្រុសកំពុងរៀន ដើម្បីត្រៀមប្រលង ហើយត្រូវការការណែនាំពិសេសខ្លះៗ នោះឪពុកម្ដាយមិនសូវជាខ្វល់ក្នុងការឲ្យគាត់ទៅរៀនគួរបន្ថែម ដែលជាន់គ្នានឹងម៉ោងថ្វាយបង្គំនៅថ្ងៃអាទិត្យ—ជាថ្ងៃនៃព្រះអម្ចាស់។ ពួកគាត់ក៏ទំនងជាឲ្យកូនប្រុសខ្លួនឈប់ចូលរួមក្រុមយុវជននៅឯព្រះវិហារ ពីព្រោះគាត់ត្រូវការរៀន។ ប្រាកដណាស់ នៅពេលដែលការប្រលងកាន់តែកៀក កូនប្រុសនោះទំនងត្រូវអាក់ខានការជួបជុំជាមួយក្រុមយុវជន ហើយអាចនៅបន្តទៅចូលរួមកម្មវិធីថ្វាយបង្គំនៅថ្ងៃអាទិត្យ។ ប៉ុន្តែ ការមិនយកចិត្តទុក

ដាក់ចំពោះការប្រកបគ្នាដែលមានតម្រូវការយ៉ាងខ្លាំងនេះ ពេលខ្លះកើតឡើងយូរមុនពេលប្រលងទៀតផង។ កូននោះក៏យល់ឃើញថា ការសិក្សាសំខាន់ជាងសុខភាពខាងវិញ្ញាណ។ លោកគ្រូ ឌី. អិល. មូឌី (D. L. Moody) បានមានប្រសាសន៍ថា «ប្រសិនបើខ្ញុំស្លាប់យប់នេះ ខ្ញុំនឹងជ្រើសរើសឲ្យកូនខ្ញុំមានសេចក្តីសង្ឃឹមរបស់ព្រះគ្រីស្ទ ជាជាងមានលុយរាប់លានដុល្លារ។ ចំពោះខ្ញុំវាហាក់បីដូចជាថាប្រសិនបើយើងមានមហិច្ឆតាខ្ពស់ពេកក្នុងការឲ្យពួកគាត់មានកេរ្តិ៍ឈ្មោះ ជាជាងបង្រៀនពួកគាត់ឲ្យមានជីវិតដែលពួកគាត់នឹងរស់នៅអស់កល្បជានិច្ច។»[៣]

សូមមើលឧទាហរណ៍អំពីរបៀបរបស់គ្រីស្ទបរិស័ទទាក់ទងទៅនឹងការថ្វាយ។ ដៃគូជីវិតដែលមានវ័យក្មេងមួយគូកំពុងតែរៀបចំទិញផ្ទះ។ ពួកគាត់បានសន្សំលុយអស់ជាច្រើនឆ្នាំ ដើម្បីធ្វើការនោះ។ ពួកគាត់ក៏បានរកឃើញផ្ទះ ដែលជាប្រភេទផ្ទះដែលពួកគាត់ចង់បាន ធ្វើជាផ្ទះរបស់ខ្លួន។ ពួកគាត់ក៏បានគណនាចំនួនទឹកលុយដែលពួកគាត់ត្រូវបង់ថ្លៃប្រាក់កម្ចី ដែលពួកគាត់នឹងត្រូវខ្ចី ដើម្បីទិញផ្ទះនោះ។ ពួកគាត់ក៏ឃើញថា មានតែមធ្យោបាយមួយដែលពួកគាត់អាចនឹងមានសមត្ថភាពបង់ថ្លៃប្រាក់ការកម្ចី គឺពួកគាត់ត្រូវកាត់បន្ថយការថ្វាយទៅកាន់ព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ និងជួយអ្នកក្រីក្រ។ ការនេះទាក់ទងនឹងការដាក់ដង្វាយរបស់ពួកគាត់ ដែលកាលពីមុនពួកគាត់ធ្លាប់រាប់ថាជាការប្តេជ្ញាចិត្តដែលមិនអាចចរចាបាន។ មានក្មេងពីផ្ទះអ្នកក្រីក្រម្នាក់ ដែលពួកគាត់បានសម្រេចចិត្តជួយឧបត្ថម្ភការរៀនសូត្រ ដោយជួយចេញថ្លៃយ៉ាងក្រាស់ជាប្រចាំខែ។ តើពួកគាត់នឹងបោះបង់ចោលផ្ទះដោយក្តីស្រមៃមួយនេះដោយបន្តនៅឧបត្ថម្ភទៀតដែរឬទេ? ដោយសារការថ្វាយជាផ្នែកមួយនៃការចំណាយដ៏ជាមូលដ្ឋានមួយរបស់គ្រីស្ទបរិស័ទ ដែលមិនអាចចរចាបាន នោះដៃគូជីវិតនេះក៏បានសម្រេចចិត្តបោះបង់ចោលនូវអ្វីដែលមើលទៅហាក់បីដូចជាឱកាសដ៏ល្អ។

មានម៉ោងកម្មវិធីទូរទស្សន៍មួយចំនួនដែលពេញទៅដោយការរីករាយ ដែល

គេចាក់ក្នុងអំឡុងពេលម៉ោងកូនៗនៅផ្ទះ ដែលអាចជាពេលដ៏ល្អសម្រាប់គ្រួសារ។ ម៉ោងកម្មវិធីទូរទស្សន៍ដែលចាប់អារម្មណ៍ខ្លាំងជាងគេបំផុត ក៏អាចជាមានក្នុងអំឡុងម៉ោងគ្រួសារដ៏សំខាន់បំផុតផងដែរ។ វាជារឿងល្អក្នុងការដែលសមាជិកគ្រួសារមើលកម្មវិធីទូរទស្សន៍ល្អៗ (ខ្ញុំផ្ទាល់ចូលចិត្តមានឱកាសមើលការទាត់បាល់ ឬក៏រឿងស៊ើបអង្កេត) ប៉ុន្តែវាជារឿងដ៏សំខាន់ណាស់ដែលគ្រួសារត្រូវតែទទួលស្គាល់ថា ការមើលកម្មវិធីទូរទស្សន៍ណាដែលពួកគាត់ចូលចិត្ត គឺជារឿងសំខាន់ទី២។ វាមិនត្រូវបង្ខាំងពេលវេលានៃការអធិស្ឋានជាគ្រួសារ ឬក៏សកម្មភាពណាផ្សេងទៀតដែលសំខាន់ ដែលមានដូចជាការជួបជុំគ្នានៅព្រះវិហារ ឬក៏ការជួបជុំក្រុមតូច ដែលគ្រួសារជាសមាជិកនៅក្រុមនោះ។ ឪពុកម្តាយទំនងជាត្រូវផ្អាកការមើលការប្រកួតដ៏សំខាន់ណាមួយ ដែលគេកំពុងតែចាក់លើទូរទស្សន៍ ដោយសារពួកគាត់ត្រូវទៅលេងបុគ្គលដែលមានតម្រូវការម្នាក់នៅឯមន្ទីរពេទ្យ។ ពេលខ្លះ ក៏អាចមានអ្នកមកលេងផ្ទះ ខណៈពេលដែលពួកគាត់កំពុងតែមើលដល់ពាក់កណ្តាលទីនូវខ្សែភាពយន្តដែលពួកគាត់ចូលចិត្តមើលដែរ។ ឪពុកម្តាយក៏សម្រេចចិត្តបិទទូរទស្សន៍ចោល។ នៅពេលដែលកូនៗឃើញអំពីការដែលឪពុកម្តាយលះបង់ដូច្នោះ នោះពួកគាត់នឹងឃើញថា មានអ្វីខ្លះសំខាន់នៅក្នុងផ្ទះរបស់ខ្លួន។

ប្រសិនបើយើងភ្លេចថាព័ន្ធកិច្ចរបស់ព្រះគ្រីស្ទបានបំផ្លាញរបាំងមនុស្ស នោះយើងអាចបដិសេធសេចក្តីបង្រៀនតាមព្រះគម្ពីរដ៏អស្ចារ្យ ទាក់ទងនឹងភាពស្មើគ្នា ដោយរារាំងកូនយើងមិនឲ្យមានមិត្តភាពជាមួយនឹងអស់អ្នកដែលយើងរាប់ថាមានឋានៈទាបជាងយើង។ លោកគ្រូ មូឌី បានប្រាប់អំពីរឿងដ៏គួរឲ្យសោកស្តាយមួយ ដែលស្ត្រីម្នាក់បានប្រាប់គាត់អំពីកូនប្រុសតែមួយគត់របស់គាត់។ កូននោះមានចំណែកក្នុងព័ន្ធកិច្ចផ្សាយដំណឹងល្អជាមួយនឹងក្រុម Young Men’s Christian Association (YMCA) ហើយនិងចេញចែកខិត្តប័ណ្ណតាមផ្លូវ។ ម្តាយកូនប្រុសនោះមានមហិច្ឆតាចង់ឲ្យកូនគាត់បង្កើតកេរ្តិ៍ឈ្មោះសម្រាប់ខ្លួនឯង ហើយចង់ឲ្យកូនគាត់ចំណាយពេលបង្កើតទំនាក់ទំនងជាមួយ

នឹងអស់អ្នកដែលមានឋានៈខ្ពស់ក្នុងសង្គម។ អ្នកម្ដាយនោះបានគិតថា ការធ្វើបែបនោះទាបជាងកិត្តិយសរបស់កូនគាត់ ទាក់ទងនឹងការរាប់អានជាមួយអ្នកក្រ ទាក់ទងនឹងការរាប់អានជាមួយនឹងយុវជនក្រីក្រនៅក្នុងក្រុម YMCA។ គាត់ចង់ឲ្យកូនគាត់ឈប់ទៅទីនោះ ប៉ុន្តែកូនគាត់មិនព្រមឈប់ទៅ។ ដូច្នេះ គាត់ក៏រេចបង្វេចឲ្យកូនគាត់ទៅរៀនសាលាឆ្ងាយ។ ចេញពីកន្លែងនោះ គាត់ក៏បានទៅរៀននៅមហាវិទ្យាល័យ យិល (Yale University) ដែលជាសាលាដ៏ថ្លៃថ្នូរមួយ ហើយនៅទីនោះគាត់ក៏បានបាត់បង់ជំនឿគាត់។

នៅពេលដែលម្ដាយឃើញការនោះ គាត់ក៏សរសេរសំបុត្រផ្ញើទៅកូនគាត់ជាញឹកញាប់ ដោយព្យាយាមអំពាវនាវឲ្យកូនគាត់ត្រឡប់មកជំនឿវិញ។ ប៉ុន្តែ វាមិនមានប្រយោជន៍ទេ។ ឪពុកម្ដាយកូននោះមិនបានឮដំណឹងពីគាត់អស់រយៈពេល២ឆ្នាំ។ ក្រោយមកទៀត ពួកគាត់ក៏បានទទួលដំណឹងថាកូនគាត់នៅទីក្រុងឈីកាហ្គោ (Chicago)។ បន្ទាប់ពីបានចាប់ផ្ដើមទំនាក់ទំនងជាមួយនឹងកូនគាត់វិញ ឪពុកក៏បានឲ្យលុយជាច្រើនទៅកាន់កូនគាត់ជាដើមទុនចាប់ផ្ដើមរកស៊ី។ ពួកគាត់បានគិតថា ការធ្វើបែបនោះនឹងផ្លាស់ប្ដូរកូនគាត់ ប៉ុន្តែវាមិនបានធ្វើទេ។ លើកចុងក្រោយដែលពួកគាត់បានឮអំពីកូនខ្លួន គឺនៅពេលដែលគាត់បានលង់ទឹកស្លាប់នៅក្នុងទន្លេ មីឆីហ្គិន (Lake Michigan)។ អ្នកម្ដាយនោះមានវិប្បដិសារីយ៉ាងខ្លាំង ប៉ុន្តែវាហួសពេលហើយ![៤]

ឪពុកម្ដាយក៏បានធ្វើខុសស្រដៀងនោះដែរ នៅពេលដែលពួកគេបដិសេធជម្រើសរបស់កូនប្រុសខ្លួន ទាក់ទងនឹងការជ្រើសរើសគូស្រករជីវិត ពីព្រោះនាងកើតចេញពីគ្រួសារ ដែលគេរាប់ថា មានឋានៈអន់ជាងខ្លួនក្នុងសង្គម។ នារីនោះគឺជាគ្រីស្ទបរិស័ទដ៏ល្អម្នាក់ ហើយក៏សមនឹងគាត់គ្រប់ចំណុច។ ប៉ុន្តែ ទស្សនៈនៃឋានៈសង្គមបានធ្វើឲ្យគ្រួសារនោះខ្វាក់មើលមិនឃើញគន្លឹះគោលការណ៍ព្រះគម្ពីរមួយ។ ការសម្រេចចិត្តប្រឆាំងនឹងគោលការណ៍នោះគឺបានបង្ហាញថាៈ ចំពោះគ្រួសារនេះ ឋានៈសង្គមសំខាន់ជាងព្រះជាម្ចាស់ និងគោលការណ៍នានារបស់ទ្រង់។

## ការអធិស្ឋាន

ចំណុចសម្គាល់ដែលងាយឃើញមួយអំពីភាពខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់នៅក្នុងផ្ទះគ្រីស្ទបរិស័ទគឺការអធិស្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ក៏ការអធិស្ឋានមិនកើតឡើងដោយឯងៗនោះទេ។ យើងត្រូវតែធ្វើឲ្យវាកើតឡើង។ នៅត្រង់ចំណុចនេះ ខ្ញុំចង់សរសេរ «សូមចំណាយពេលអធិស្ឋាន» ប៉ុន្តែខ្ញុំកំពុងតែនិយាយថា «សូមញែកពេលដើម្បីអធិស្ឋាន»។ យើងត្រូវតែសង្វាតដេញតាមយ៉ាងសកម្ម ក្នុងការផ្ដល់អាទិភាពនៃការអធិស្ឋាននៅផ្ទះ ហើយញែកពេលវេលាដើម្បីការនោះដែរ។

ប្រភេទនៃការអធិស្ឋានដ៏សាមញ្ញបំផុតនៅក្នុងផ្ទះគឺ ការអធិស្ឋានតែម្នាក់ឯងដោយផ្ទាល់ជាសម្ងាត់។ នេះគឺជាបរិបទដែលព្រះយេស៊ូវបានប្រើប្រាស់នៅពេលដែលព្រះអង្គសព្វព្រះហឫទ័យចង់បង្រៀនអំពីការអធិស្ឋានដ៏ពិត។ ព្រះអង្គបានមានបន្ទូលថា «តែឯអ្នក កាលណាអធិស្ឋាន នោះត្រូវឲ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ រួចអធិស្ឋានដល់ព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅទីលាក់កំបាំងចុះ» (ម៉ាថាយ ៦:៦)។ ក្នុងអំឡុងពេលនេះ ដូចដែលខ្ញុំបានលើកឡើងនៅខាងលើ យើងអធិស្ឋានសម្រាប់សមាជិកគ្រួសារយើង។ ទម្លាប់នៃការដែលបុគ្គលណាម្នាក់នៅតែឯង ហើយអធិស្ឋានទៅកាន់ព្រះជាម្ចាស់ គឺជាចំណុចសម្គាល់មួយអំពីផ្ទះ ដែលជាផ្ទះរបស់គ្រីស្ទបរិស័ទ។ កាលខ្ញុំនៅជាកុមារ ដែលបានចូលរួមការបោះជំរុំព្រះគម្ពីរ ជាមួយនឹងគ្រួសាររបស់ខ្ញុំ ខ្ញុំបានឮអំពីការដែលលោក ហ៎របឺធ អែម (Herbert Epp) និយាយអំពីលោក ស៊ីអូដ័រ អែម (Theodore Epp) ដែលត្រូវជាឪពុករបស់គាត់ ហើយក៏ជាអ្នកចាប់ផ្ដើមផ្សាយកម្មវិធីវិទ្យុឈ្មោះថាការត្រឡប់ទៅរកព្រះគម្ពីរវិញ (Back to the Bible Broadcast)។ គាត់បានមានប្រសាសន៍ថា មានពេលជាច្រើនដងដែលឪពុករបស់គាត់បានចំណាយពេលនៅក្នុងបន្ទប់ដោយបិទទ្វារ។ កូនៗដឹងថាពួកគាត់មិនគួរទៅរំខានឪពុកខ្លួនក្នុងអំឡុងពេលនោះឡើយ ដោយសារគាត់កំពុងតែអធិស្ឋាន។ ខ្ញុំក៏មានការចងចាំស្រដៀងគ្នានោះ អំពីអ្នកម្ដាយ និងជីទួត

របស់ខ្ញុំផងដែរ។ ពេលដែលខ្ញុំទៅនៅផ្ទះតាយាយរបស់ខ្ញុំ ពេលខ្លះខ្ញុំត្រូវការប្រើប្រាស់បន្ទប់ទឹកនៅពេលព្រឹកព្រលឹម មុនថ្ងៃរះ។ ខ្ញុំត្រូវដើរកាត់បន្ទប់យាយតាខ្ញុំ ហើយខ្ញុំក៏តែងតែឃើញយាយរបស់ខ្ញុំកំពុងលុតជង្គង់អធិស្ឋាន នៅក្បែរគ្រែរបស់គាត់ដោយគ្របក្បាល។ ខ្ញុំក៏បានឃើញអ្នកម្តាយរបស់ខ្ញុំធ្វើការនោះដូចគ្នាផងដែរ ខ្ញុំតែងតែឃើញគាត់លុតជង្គង់ជារៀងរាល់ព្រឹក។

ខ្ញុំជឿជាក់ថា ការអធិស្ឋានគឺជាចំណុចដ៏សំខាន់បំផុតដែលយើងធ្វើនៅលើផែនដីនេះ។ កូនៗរបស់យើងនិងទទួលស្គាល់ការនេះ នៅពេលដែលពួកគាត់មើលឃើញភាពម៉ឺងម៉ាត់ដែលយើងធ្វើ ទាក់ទងនឹងការអធិស្ឋាន។ ការនេះលើកទឹកចិត្តឲ្យពួកគាត់គោរព និងថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់។

ជារឿយៗ អ្នកម្តាយដែលមានកូនតូចៗមានការពិបាកក្នុងការញែកពេលវេលាដែលមានការផ្ចិតផ្ចង់សម្រាប់អធិស្ឋាន។ ពួកគាត់ត្រូវតែប្រើប្រាស់ការច្នៃប្រឌិតរបស់ខ្លួនក្នុងការរកពេលវេលាដែលសមរម្យ។ មានពេលមួយ ខ្ញុំបានសួរមិត្តភក្តិរបស់ខ្ញុំម្នាក់ដែលមានវ័យក្មេង ដែលមានកូនតូចៗពីរនាក់ អំពីរបៀបដែលប្រពន្ធរបស់គាត់រកពេលវេលាញែក ដើម្បីអធិស្ឋាន។ គាត់បានប្រាប់ខ្ញុំថា នៅពេលដែលកូនៗរបស់គាត់គេងពេលថ្ងៃ ភ្លាមនោះប្រពន្ធរបស់គាត់នឹងឆក់យកឱកាស ដើម្បីមានពេលតែម្នាក់ឯងជាមួយនឹងព្រះជាម្ចាស់។

មានស្ត្រីម្នាក់បានចាប់អារម្មណ៍យ៉ាងខ្លាំងលើអ្នកជិតខាងរបស់គាត់។ អ្នកជិតខាងនោះជាម្តាយដែលមានកូនច្រើន ដែលហាក់បីដូចជាថា គាត់មានអត្តចរិតដែលបង្ហាញថាគាត់មានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលជាមួយនឹងព្រះជាម្ចាស់។ ស្ត្រីម្នាក់នោះក៏បានសួរអ្នកជិតខាងរបស់គាត់អំពីរបៀបដែលគាត់អាចធ្វើការនោះបាន។ អ្នកជិតខាងនោះក៏បានចង្អុលអាវចុងភៅដែលគាត់តែងតែពាក់។ គាត់បានលើកឡើងថា នៅពេលដែលគាត់អង្គុយលើកៅអីជាក់លាក់ណាមួយ ហើយយកអាវចុងភៅគ្របក្បាលគាត់ នោះកូនៗដឹងថាគាត់កំពុងតែអធិស្ឋាន។ មានច្បាប់មួយនៅក្នុងផ្ទះដែលថា កូនៗត្រូវតែនៅស្ងៀមនៅពេលនោះ។

កូនៗត្រូវតែដឹងថា ឪពុកម្ដាយរបស់ខ្លួនញែកពេលអធិស្ឋាន ពីព្រោះចំពោះពួកគាត់ព្រះជាម្ចាស់សំខាន់។ ដោយអចេតនា ពួកគាត់ជ្រួតជ្រាបគំនិតនៃការអធិស្ឋានផ្ទាល់ខ្លួនថាជាអាទិភាពដ៏សំខាន់មួយនៃជីវិត។ ការនេះនឹងក្លាយជាការលើកទឹកចិត្តដល់ពួកគាត់ឲ្យក្លាយជាមនុស្សដែលអធិស្ឋានផងដែរ។ មានពេលមួយ «ទ្រង់កំពុងតែអធិស្ឋាននៅកន្លែង១ លុះទ្រង់ឈប់ហើយ នោះសិស្សម្នាក់ទូលថា “ព្រះអម្ចាស់អើយ សូមទ្រង់បង្រៀនយើងខ្ញុំ ឲ្យចេះអធិស្ឋានផង ដូចជាលោកយ៉ូហានបានបង្រៀនដល់សិស្សលោកដែរ”» (លូកា ១១:១)។ សំណួរនោះក៏បានបណ្ដាលឲ្យព្រះយេស៊ូវបង្រៀនពួកគាត់អំពីការអធិស្ឋាននៃព្រះអម្ចាស់ (ខ២-៤)។ ការដែលពួកសិស្សឃើញព្រះយេស៊ូវអធិស្ឋានក៏បានជំរុញឲ្យពួកគាត់ប្រាថ្នាចង់ក្លាយជាមនុស្សដែលអធិស្ឋានផងដែរ។

ដប់បួនជំពូកដំបូងនៃកណ្ឌគម្ពីរកិច្ចការផ្ដល់ជូនយើងនូវការឃើញខ្លះៗនៃជីវិតក្រុមជំនុំសម័យដំបូង។ មានការលើកឡើងអំពីការអធិស្ឋាន២២ដងនៅក្នុងជំពូកទាំងនោះ ហើយការអធិស្ឋានភាគច្រើនគឺជាការអធិស្ឋានជុំគ្នា។ ប្រសិនបើការអធិស្ឋានជុំគ្នាសំខាន់ខ្លាំងណាស់ក្នុងជីវិតក្រុមជំនុំ ដាច់ខាតវាក៏ត្រូវតែសំខាន់ណាស់ដែរ ក្នុងក្រុមនីមួយៗជាមូលដ្ឋាននៃក្រុមជំនុំ—គឺគ្រួសារ។ ទម្លាប់នៃការដែលដៃគូជីវិតអធិស្ឋានជាមួយគ្នាឲ្យបានទៀងទាត់ និងការដែលឪពុកម្ដាយអធិស្ឋានជាមួយនឹងកូនៗរបស់ខ្លួន គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃអត្តសញ្ញាណ និងភាពនឹងនរក្នុងគ្រួសារ។ យើងក៏គួរអធិស្ឋានជាមួយគ្នានៅឯកម្មវិធីគ្រួសារពិសេសៗ ហើយនៅពេលដែលគ្រួសារប្រឈមមុខនឹងភាពលំបាកដែរ។ ក្រុមគ្រួសារគួរតែយល់ថា ការអធិស្ឋានគឺមិនមែនគ្រាន់តែជាក្បួននោះទេ តែផ្ទុយទៅវិញ គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការប្រារព្ធ។ ការអធិស្ឋានមុនចាប់ផ្ដើមចេញដំណើរដ៏វែងឆ្ងាយ ឬក៏មុនសមាជិកគ្រួសារណាម្នាក់ចេញដំណើរសម្រាប់កម្មវិធីសំខាន់ណាមួយ ក៏ជាការជួយសម្របសម្រួលព្រះពររបស់ព្រះជាម្ចាស់សម្រាប់ដំណើរ ឬក៏កម្មវិធីនោះ។ វាក៏ជាការបង្ហាញថា

ព្រះជាម្ចាស់គឺជាអង្គដែលយើងទទួលជំនួយ ក្នុងពេលវេលាដ៏សំខាន់ៗដែរ។
កាលកូនប្រុសខ្ញុំនៅវ័យជំទង់ គាត់បានលេងកីឡា។ យើងមានទម្លាប់អធិស្ឋានជាមួយគាត់ មុនគាត់ចេញទៅប្រកួត។ មានថ្ងៃមួយ ខ្ញុំបានឌុបគាត់ទៅកន្លែងប្រកួត ប៉ុន្តែខ្ញុំបានភ្លេចអធិស្ឋានជាមួយគាត់។ ដល់ពេលដែលខ្ញុំកំពុងតែបើកបរ គាត់បានសួរខ្ញុំថា «តើប៉ាអាចអធិស្ឋានឲ្យកូនបានទេ?»។ គាត់បានទទួលស្គាល់ថា ការថ្វាយការប្រកួតទៅកាន់ព្រះអម្ចាស់ គឺជាផ្នែកដ៏សំខាន់មួយនៃជីវិតគាត់។

នៅពេលដែលកូនៗធំធាត់ឡើង ពួកគាត់នឹងមិនភ្លេចថា អត្តសញ្ញាណ និងសុវត្ថិភាពរបស់គាត់ក្នុងនាមជាកូនមានការវេចខ្ចប់ក្នុងការអធិស្ឋានទៅកាន់ព្រះជាម្ចាស់។ ពេលខ្លះ នៅពេលដែលពួកគាត់កំពុងឆ្លងកាត់វ័យបះបោរ ហើយមានការល្បួងចង់បោះបង់ជំនឿចោល អនុស្សាវរីយ៍នៃពេលវេលាដ៏ល្អទាំងនោះជាមួយនឹងព្រះជាម្ចាស់ បែបជាគ្រួសារ នឹងធ្វើឲ្យពួកគាត់មានការពិបាកក្នុងការបោះបង់ជំនឿដែលខ្លួនធ្លាប់មានតាំងពីក្មេងចោល។ ទោះបើពួកគាត់បានបោះបង់ចោលអស់មួយរយៈក៏ដោយ ក៏អនុស្សាវរីយ៍ទាំងនោះអាចកេះឲ្យគាត់ត្រឡប់បែរទៅរកព្រះជាម្ចាស់វិញដែរ។ ខ្ញុំប្រាកដថា លោកអ្នកក៏ស្គាល់កូនៗដែលបានបែរចេញពីព្រះជាម្ចាស់ ប៉ុន្តែពួកគាត់ក៏នៅស្នើសូមឲ្យឪពុកម្ដាយខ្លួនអធិស្ឋានឲ្យពួកគាត់ ពេលដែលពួកគាត់មានតម្រូវការពិសេស។

យើងក៏មិនគួរភ្លេចលើកឡើងថា ការអធិស្ឋានជាគ្រួសារមិនគួរជាការធ្វើឡើងបែបក្រឹត្យវិន័យនិយម ជាបន្ទុក ឬក៏ជាការស្មុគស្មាញដែរ។ ឪពុកម្ដាយត្រូវព្យាយាមធ្វើឲ្យអស់ពីសមត្ថភាពដែលខ្លួនអាចធ្វើបាន ក្នុងការប្រើប្រាស់ការច្នៃប្រឌិត ដើម្បីធ្វើឲ្យមានការចាប់អារម្មណ៍ និងសប្បាយ៖ ជាអ្វីមួយដែលសប្បាយ ដែលឪពុកម្ដាយ និងកូនៗធ្វើជាលក្ខណៈគ្រួសារ។ ពេលអធិស្ឋានយើងគួរព្យាយាមបង្កើតរបៀបឲ្យកូនៗមានចំណែក ក្នុងរបៀបដែលមានន័យ។ នៅពេលដែលកូនៗរបស់យើងមានវ័យក្មេង ជាដំបូងយើងពិភាក្សាអំពីចំណុចដែលយើងគួរអធិស្ឋាន។ បន្ទាប់មកខ្ញុំតែងតែសួរថា «តើអ្នកណានឹងអធិស្ឋាន

អំពីចំណុចណា?»។ ការលើកឡើងបែបនោះបានក្លាយជាប្រភពនៃការអស់សំណើចមួយនៅក្នុងផ្ទះ ប៉ុន្តែក៏ជាការអនុវត្តក្នុងការជួយឲ្យកូនៗមានចំណែកក្នុងពេលអធិស្ឋាន។ ពិតណាស់ តម្រូវការរបស់កូនៗគឺជាផ្នែកដ៏សំខាន់មួយពេលអធិស្ឋាន។ ចំណុចដែលថាពួកគាត់ដឹងថាអាចលើកឡើងនូវសំណូមពរទាំងនោះមកកាន់គ្រួសារ ហើយអធិស្ឋានសម្រាប់សំណូមពរទាំងនោះ ក៏បានក្លាយជាប្រភពដ៏ចម្បងមួយនៃសុវត្ថិភាពសម្រាប់ពួកគាត់ផងដែរ។

ជាថ្មីម្តងទៀត សូមអនុញ្ញាតឲ្យខ្ញុំលើកឡើង៖ មិនថាយើងព្យាយាមខំធ្វើឲ្យមានចំណាប់អារម្មណ៍ខ្លាំងប៉ុណ្ណានៅក្នុងការអធិស្ឋានបែបលក្ខណៈជាគ្រួសារ ក៏វាមិនមែនជាអ្វីដែលកើតឡើងជាធម្មតា ក្នុងគ្រួសារដែលជួបជុំគ្នាឲ្យបានទៀងទាត់ ដើម្បីអធិស្ឋានផងដែរ។ វាជាការដ៏ប្រសើរក្នុងការដែលបុគ្គលណាម្នាក់យកទំនួលខុសត្រូវ ក្នុងការប្រាកដថាឲ្យមានការជួបជុំគ្នា។ នៅពេលដែលកូនៗនៅក្មេងនៅឡើយ ឪពុក ឬក៏ម្តាយគួរយកទំនួលខុសត្រូវលើតួនាទីនេះ។ ខណៈពេលដែលកូនៗកាន់តែធំពេញវ័យឡើង ម្នាក់ក្នុងចំណោមពួកគេគួរទទួលទំនួលខុសត្រូវនេះ។ គោលការណ៍នេះក៏សំខាន់សម្រាប់ដៃគូជីវិតដែលមិនមានកូន ឬក៏កូនៗបានចាកចេញពីផ្ទះហើយផងដែរ។ សព្វថ្ងៃនេះ វាជាការដ៏គួរឲ្យសោកស្តាយណាស់ ដែលដៃគូជីវិតដែលជាគ្រីស្ទបរិស័ទមិនមានពេលវេលាទៀងទាត់ ដើម្បីអធិស្ឋានជាមួយគ្នា។ ការនេះត្រូវតែមានការផ្លាស់ប្តូរ! មិនថា ប្តីឬក៏ប្រពន្ធ ពួកគាត់ត្រូវតែប្រាកដថាឲ្យមានពេលវេលាអធិស្ឋាន។

## សេចក្តីសន្និដ្ឋាន

ចំណុចចម្បងនៃជំពូកនេះគឺថា ការដែលព្រះជាម្ចាស់មានចំណែកក្នុងជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារយើងគឺជាចំណុចដ៏សំខាន់បំផុត។ ព្រះអង្គគឺជាដៃគូចម្បងដែលបានប្តេជ្ញាព្រះទ័យក្នុងការតាំងសេចក្តីសញ្ញាអាពាហ៍ពិពាហ៍ ព្រះអង្គជាអង្គដែលជួយយើងបំពេញលក្ខន្តិកៈនៃសេចក្តីសញ្ញា ហើយធ្វើក្នុងគ្រប់កាលៈទេសៈទាំងអស់សម្រាប់ជាប្រយោជន៍ដល់យើង។ ទាក់ទងនឹង

ចំណែកយើង ដាច់ខាតយើងត្រូវតែមានការប្ដេជ្ញាចិត្តជាមួយព្រះជាម្ចាស់ និងគោលការណ៍របស់ទ្រង់។ បរាជ័យក្នុងការប្ដេជ្ញាចិត្តនឹងនាំឲ្យយើងធ្លាក់ក្នុងផ្លូវនៃការបំផ្លាញខ្លួនឯង។ នៅពេលដែលគ្រួសារស្ថិតក្រោមការវាយប្រហារ នៅពេលដែលបណ្ដាញសង្គម និងផ្នែកជាច្រើននៃវប្បធម៌ហាក់បីដូចជាកំពុងធ្វើសង្គ្រាមទាស់ប្រឆាំងនឹងការយល់ដឹងយោងតាមព្រះគម្ពីរអំពីជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារ នោះគ្រីស្ទបរិស័ទត្រូវតែបន្តមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការណែនាំ ដែលព្រះជាម្ចាស់បានបង្កើតមក។

## ២

# ការលះអាល័យខ្លួនឯង

នៅក្នុងជំពូកមុន យើងបានលើកឡើងថា ការប្ដេជ្ញាព្រះទ័យ និងការមានចំណែករបស់ព្រះជាម្ចាស់នៅក្នុងគ្រួសារធានាទៅកាន់គ្រីស្ទបរិស័ទជាប់លាប់ថានឹងមានជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារដែលពេញដោយអំណរ។ បើដូច្នោះមែន ហេតុអ្វីបានជាមានគ្រីស្ទបរិស័ទដែលជាអ្នកដឹកនាំជាច្រើនមានជីវិតអាពាហ៍ពិពាហ៍ដែលមិនមានសុភមង្គល ហើយថែមទាំងមានជម្លោះជាច្រើនទៀតផង? ក្នុងសៀវភៅនេះ ខ្ញុំនឹងលើកឡើងនូវចំណុចជាច្រើនដែលនឹងផ្ដល់ជាចម្លើយលើសំណួរទាំងនោះ ប៉ុន្តែជាដំបូងខ្ញុំសូមលើកឡើងនូវការអនុវត្តមួយ ដែលសំខាន់ សម្រាប់ឲ្យទីលំនៅគ្រីស្ទបរិស័ទមានសុភមង្គល។ តាមពិតទៅ វាគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតគ្រីស្ទបរិស័ទទាំងមូល ប៉ុន្តែសូម្បីតែគ្រីស្ទបរិស័ទដែលជាអ្នកដឹកនាំក៏មានការជំពប់ដួល ក្នុងការតភ្ជាប់ជាមួយនឹងវាដែរ។

### ការមិនចង់លះអាល័យខ្លួនឯង៖ មូលហេតុចម្បងនៃជម្លោះ

បន្ទាប់ពីបានរៀបការអស់រយៈពេល៣៩ឆ្នាំកន្លងទៅ និងបានការជួបប្រឹក្សាដែលរាប់មិនអស់ ខ្ញុំក៏ចាប់ផ្ដើមសង្កេតឃើញថា ចំណុចទូទៅដែលដកចេញនូវអំណរ និងសន្តិភាពនៅក្នុងផ្ទះរបស់យើង គឺការបដិសេធមិនព្រមលះអាល័យ

ខ្លួនឯង។ បញ្ហានេះក៏ឃើញកើតមាននៅក្នុងក្រុមជំនុំដែរ។ មូលហេតុជាក់ស្ដែងសម្រាប់ជម្លោះជាច្រើនក្នុងក្រុមជំនុំ គឺមិនមែនបញ្ហាដែលមើលឃើញដែលគួរជាមូលហេតុនៃបញ្ហានោះទេ។ បញ្ហាជាក់ស្ដែងទំនងជាទាក់ទងទៅនឹងគោលជំនឿ ជីវិតខាងឯវិញ្ញាណ យុទ្ធសាស្ត្រ ផ្នែករដ្ឋបាល ឬក៏ទាក់ទងទៅនឹងបុគ្គលិកលក្ខណៈ។ ប៉ុន្តែ ជាទូទៅ របួសនៃភាពអាត្មានិយម ដែលមិនចេះផ្លាស់ប្ដូរគំនិតគឺជាសាំងចាក់បញ្ឆេះជម្លោះ។

នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់គ្រីស្ទបរិស័ទ ឬក៏នៅក្នុងក្រុមជំនុំ នៅពេលមានជម្លោះ ឬក៏ការមិនឯកភាពគ្នាកើតឡើង ចំណុចបញ្ចប់នៃសេចក្ដីប៉ងប្រាថ្នារបស់យើងគឺមិនមែនជាការទទួលបានជ័យជម្នះនោះទេ ប៉ុន្តែជាការរួបរួមនៅក្រោមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់វិញ។ ភាគីទាំងអស់គួរតយុទ្ធចង់បានព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយនៅពេលដែលពួកគេរកឃើញព្រះហឫទ័យ នោះពួកគាត់គួរចុះចូលក្រោមព្រះហឫទ័យនោះ។ ប៉ុន្តែ ជម្លោះជាច្រើន ទោះបើយើងនិយាយថាយើងចង់បានព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ដោយ ក៏តាមពិតទៅអ្វីដែលយើងពិតជាចង់បានគឺមិនមែនថ្វាយព្រះកិត្តិយសទៅកាន់ព្រះគ្រីស្ទ ប៉ុន្តែគឺចង់ឲ្យខាងយើងឈ្នះ ឲ្យខាងយើងប្រើប្រាស់អំណាច សិទ្ធិ ឬក៏ឥទ្ធិពល ដើម្បីឲ្យឈ្នះវិញ។ មនុស្សតូចតាចចង់បានជ័យជម្នះតូចតាច ហើយពួកគាត់ក៏បានភ្លេចអំពីប្រយោជន៍រួម ក្នុងការដែលពួកគេព្យាយាមយកឈ្នះ។ វាជាការងាយស្រួលណាស់ក្នុងការអនុញ្ញាតឲ្យការប្ដេជ្ញាចិត្តរបស់យើងចំពោះខ្លួនឯងយកឈ្នះលើការងាយស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ រហូតដល់ថ្នាក់ថាយើងមិនព្យាយាមចុះចូលក្រោមព្រះហឫទ័យនោះ។ នៅពេលដែលមនុស្សយើងអាម៉ាស់មុខពីព្រោះពួកគាត់មានអារម្មណ៍ថាអំណាចរបស់ខ្លួន ឬក៏ឥទ្ធិពលរបស់ខ្លួនត្រូវបានកាត់បន្ថយ ឬក៏មានអារម្មណ៍ថា ភាគីដែលគេមិនឯកភាពបានចាញ់ នោះជាទូទៅពួកគេភ្លេចគោលការណ៍គ្រីស្ទបរិស័ទ ក្នុងការឆ្លើយតបរបស់ខ្លួនក្នុងកាលៈទេសៈនោះ។ ការឆ្លើយតបរបស់ពួកគាត់កាន់តែធ្វើឲ្យបញ្ហាធ្ងន់ធ្ងរ។

បើនិយាយតាមភាសាព្រះគម្ពីរទៅគឺថា ពួកគាត់បានបដិសេធមិនព្រមលះអាល័យខ្លួនឯងចោល។

ការអាល័យខ្លួនឯងគឺជាមូលដ្ឋានគ្រឹះនៃការអនុវត្តដ៏សំខាន់ក្នុងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទ។ វាគឺជាផ្នែកចម្បងមួយនៃការត្រាស់ហៅរបស់ព្រះយេស៊ូវទាក់ទងនឹងការធ្វើជាសិស្ស «បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ» (លូកា ៩:២៣)។ ការលះអាល័យខ្លួនឯង និងការលីឈើឆ្កាងគឺជាការអនុវត្តប្រចាំថ្ងៃសម្រាប់ជីវិតគ្រីស្ទបរិស័ទ។ សាវ័ក ប៉ុល អង្វរយើង «ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង» (រ៉ូម ១២:១)។ ក្នុងរចនាសម្ព័ន្ធចាស់នៃការថ្វាយយញ្ញបូជា គេបានយកសត្វទៅបូជា។ ឥឡូវនេះ យើងថ្វាយជីវិតរបស់យើង ហើយយើងក៏ធ្វើការនោះម្តងហើយម្តងទៀតផងដែរ។ ខណៈពេលដែលយើងរស់នៅ យើងក៏កំពុងតែស្លាប់ដែរ។ នេះមិនមែនគ្រាន់តែជាក្បួនពិធីសាស្ត្រនោះទេ។ វាគឺជាករណីនៃការស្លាប់ជាប្រចាំថ្ងៃ។ ទាក់ទងទៅនឹងគាត់ផ្ទាល់សាវ័ក ប៉ុល មានប្រសាសន៍ថា «ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ» (កាឡាទី ២:២០)។ ជារៀងរាល់ថ្ងៃ យើងប្រឈមមុខក្នុងពេលវេលាដែលឆន្ទៈរបស់យើងប្រឆាំងជាមួយនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយដឹងថា ការគិតគូរ និងរបៀបរបស់យើងមានការខុសគ្នាខ្លាំងណាស់ពីគំនិត និងផ្លូវរបស់ព្រះអង្គ (អេសាយ ៥៥:៨-៩) នោះយើងគួរទូលសូមព្រះជាម្ចាស់ជាប្រចាំថ្ងៃអំពីអ្វីដែលព្រះអង្គសព្វព្រះទ័យឲ្យយើងលះអាល័យ។ ប្រសិនបើយើងមិនលះអាល័យខ្លួនឯងក្នុងផ្ទះសំបែងអាចនាំឲ្យខ្វះសុភមង្គលនៅក្នុងផ្ទះ។

## របៀបនៃការលះអាល័យខ្លួនឯង ដែលជួយឲ្យគ្រួសារមានសុភមង្គល

តោះ! ចូរមើលឧទាហរណ៍មួយចំនួនដែលបង្ហាញថាការលះអាល័យខ្លួនឯងគឺជាគន្លឹះក្នុងការបង្កើតឲ្យគ្រួសាររបស់លោកអ្នកមានសុភមង្គលៈ

- ជាធម្មតា ខ្ញុំតែងតែធ្វើការដល់យប់ជ្រៅ ដូច្នេះនៅពេលដែលខ្ញុំក្រោកពីគេងនៅពេលព្រឹក ខ្ញុំមានអារម្មណ៍មិនស្វាង ហើយនៅតែងងុយគេង។ ក្នុងនាមខ្ញុំជាជនជាតិស្រីលង្កាដ៏ពិតប្រាកដម្នាក់ផង ខ្ញុំចូលចិត្តញ៉ាំតែ នៅពេលដែលខ្ញុំក្រោកពីព្រលឹម។ ប្រពន្ធរបស់ខ្ញុំគឺជាម្នាក់ដែលចូលចិត្តក្រោកពីព្រលឹម ហើយគាត់ក៏ក្រោកមុនខ្ញុំទៅទៀត។ គាត់ក្រោកឆុងតែរបស់ខ្ញុំដាក់ចូលក្នុងដបតូច។ អ្វីដែលខ្ញុំត្រូវធ្វើមុនគេនៅពេលខ្ញុំក្រោកពីគេងនោះគឺដើរទៅផ្ទះបាយដើម្បីយកតែរបស់ខ្ញុំ។ ចុះប្រសិនបើខ្ញុំឃើញថាគាត់មិនបានឆុងតែឲ្យខ្ញុំទេ? ការឆ្លើយតបដំបូងរបស់ខ្ញុំទំនងជាការខឹង។ ហើយខ្ញុំក៏ប្រហែលជាបញ្ចេញកំហឹងនោះ ដោយមានសំណួរ ឬក៏ការចោទប្រកាន់មិនចាំបាច់ ទោះបើខ្ញុំបានចាប់ផ្តើមយល់ឃើញហើយថា ប្រសិនបើប្រពន្ធរបស់ខ្ញុំមិនបានឆុងតែទុកមុន នោះជាទូទៅគឺដោយសារគាត់មានមូលហេតុល្អៗ។ ក្នុងនាមជាគ្រីស្ទបរិស័ទម្នាក់ ខ្ញុំត្រូវលះអាល័យទំនោរនៃការផ្អែកលើសពីសភាវគតិរបស់ខ្ញុំក្នុងការបង្ហាញកំហឹង។ មានគេសម្ភាសន៍បុគ្គលម្នាក់ដែលបានរៀបការអស់រយៈពេល៥០ឆ្នាំ ទាក់ទងទៅនឹងគន្លឹះដែលនាំឲ្យមានជីវិតអាពាហ៍ពិពាហ៍របស់គាត់ដែលមានភាពអរសប្បាយ។ គាត់បានឆ្លើយតបថា ជារៀងរាល់ថ្ងៃតែងតែមានអ្វីមួយដែលគាត់មិននិយាយ។[២] គាត់បានលះអាល័យខ្លួនឯងចោលជាប្រចាំថ្ងៃ។
- មនុស្សប្រុសអាចមានការឆ្លើយតបដោយមិនសមហេតុសមផល នៅពេលដែលប្រពន្ធរបស់ខ្លួនបដិសេធនូវសំណើរបស់ពួក

គេក្នុងការរួមដំណេក។ ពេលក្រោយ ខ្ញុំនឹងលើកឡើងអំពីចំណុចសំខាន់នៃការរួមដំណេក ដើម្បីឲ្យជីវិតអាពាហ៍ពិពាហ៍មានភាពពេញលេញ និងអំពីរបៀបដែលជាទូទៅមនុស្សប្រុសចង់បានពេលខ្លះច្រើនជាងប្រពន្ធចង់បានទៅទៀត។ ទោះជាយ៉ាងណាក៏ដោយក៏វាមិនត្រឹមត្រូវទេក្នុងការដែលប្ដីបង្ខំប្រពន្ធ ទោះបើការបដិសេធរបស់ប្រពន្ធជាការវាយប្រហារអំនួតរបស់គាត់ក៏ដោយ។ វាទំនងជារឿងធម្មតាទេ ដែលគាត់ឆ្លើយតបដោយកំហឹង ហើយធ្វើឲ្យប្រពន្ធរបស់គាត់មានការឈឺចាប់ តាមរយៈការប្រើប្រាស់ពាក្យសម្ដី ឬក៏វាយគាត់ផ្ទាល់តែម្ដង។ ប៉ុន្តែ មនុស្សប្រុសដែលចេះព្រះបន្ទូលនឹងលះអាល័យទំនោរមួយនោះចោល ហើយគ្រប់គ្រងការឆ្លើយតបរបស់គាត់។ គាត់ស្រឡាញ់ប្រពន្ធរបស់គាត់ដូចដែលគាត់ស្រឡាញ់ខ្លួនឯង ហើយលះបង់ផែនការរបស់គាត់ ដោយសារបំណងប្រាថ្នា និងអារម្មណ៍ប្រពន្ធរបស់គាត់។

- ប្រពន្ធក៏អាចរងការឈឺចាប់ដោយសារតែពាក្យសម្ដីដែលប្ដីរបស់ខ្លួននិយាយនៅមុខកូនៗរបស់គាត់នៅតុបាយ (ជាទង្វើដែលមិនមានប្រាជ្ញារបស់ប្ដី)។ ហើយប្រពន្ធក៏អាចឆ្លើយតបដោយមានកំហឹង នៅមុខកូនៗផងដែរ។ ហើយគាត់ក៏អាចឆ្លើយតបដោយកំហឹងទៅវិញ ដែលនឹងក្លាយដូចជាល្បែងពីងប៉ុងនៃការឈ្លោះគ្នា ដោយមានការតបទៅតបមកនៅឯតុបាយ។ កូនៗក៏មានការក្រៀមក្រំឈឺចាប់ នៅពេលឃើញឪពុកម្ដាយពួកគេឈ្លោះគ្នាដូចនោះ។ ក្នុងរាល់ជំហាននៃល្បែងនេះ មិនថាប្ដីឬក៏ប្រពន្ធ ទាំងពីរអាចបញ្ឈប់ការតបត ដោយមិនវាយបកវិញ។ ប្រាកដណាស់ពួកគាត់ត្រូវតែនិយាយអំពីចំណុចនេះ ដែលបានបណ្ដាលឲ្យមានការមិនពេញចិត្តគ្នា ប៉ុន្តែតុញ៉ាំបាយមិនមែនជាកន្លែងធ្វើដូច្នោះនោះទេ ហើយបរិយាកាសនៃការសន្ទនាក៏មិនគួរបន្តទៅមុខទៀតដែរ។ អស់អ្នកដែលច្រឡោត នៅពេលខឹង នឹងតែងតែ

បញ្ចេញសម្តីដែលមិនល្អ—ដែលកាលនោះនាំឲ្យពួកគាត់ក្លាយជាមនុស្សមិនល្អដែរ។ គ្រីស្ទបរិស័ទដែលមានប្រាជ្ញានឹងជ្រើសរើសលះអាល័យទំនោរធម្មជាតិរបស់គាត់ចោល ហើយចេះផ្អាកពេលក្នុងការឈ្លោះគ្នា រហូតដល់មានពេលវេលា និងទីកន្លែងដែលសមរម្យ ហើយឲ្យអារម្មណ៍បានស្ងប់សិន ដើម្បីឲ្យការសន្ទនាប្រកបដោយការសមហេតុសមផល។

- ដូចដែលការសិក្សា និងការរៀបចំតែងតែជាបញ្ហាសម្រាប់ខ្ញុំ ខ្ញុំតែងតែអង្គុយនៅតុរបស់ខ្ញុំ ដើម្បីសិក្សា និងរៀបចំរហូតដល់នៅសល់ពេលពីរទៅបីនាទីមុនពេលខ្ញុំត្រូវចេញទៅការិយាល័យ ឬការណាត់ជួបប្រជុំរបស់ខ្ញុំ។ ជាញឹកញាប់ ខ្ញុំតែងតែចំណាយពេលសិក្សាយូរពេក។ ហើយបន្ទាប់មក ខ្ញុំក៏ស្លៀកពាក់យ៉ាងប្រញាប់ប្រញាល់តាមដែលអាចធ្វើបាន ហើយចេញពីផ្ទះយ៉ាងលឿន។ ក្នុងអំឡុងឆ្នាំរៀបការដំបូងៗ ខ្ញុំតែងតែភ្លេចប្រាប់ប្រពន្ធរបស់ខ្ញុំថា «បងចេញទៅហើយ»។ បើតាមអ្វីដែលខ្ញុំចាំបាន នេះមិនមែនជាបញ្ហាអ្វីទេនៅក្នុងក្រុមគ្រួសាររបស់ខ្ញុំ ដែលបានធំធាត់ឡើង។ ប៉ុន្តែ នេះមិនមែនជារបៀបដែលប្រពន្ធរបស់ខ្ញុំបានធំធាត់ឡើងនោះទេ។ ជាញឹកញាប់ គាត់តែងតែមានការអន់ចិត្តយ៉ាងខ្លាំង នៅពេលដែលគាត់ឃើញថា ខ្ញុំចេញទៅដោយមិនបានប្រាប់។ ខ្ញុំក៏ត្រូវរៀនផ្លាស់ប្តូរទម្លាប់របស់ខ្ញុំ ហើយប្រាប់គាត់មុនពេលដែលខ្ញុំចេញទៅក្រៅ។ ពេលខ្លះ ខ្ញុំភ្លេច ហើយបានចេញទៅដោយមិនបានប្រាប់គាត់ ទោះបីជាខ្ញុំគ្មានចេតនាធ្វើបែបហ្នឹងក៏ដោយ។ យើងមិនទាន់មានទូរស័ព្ទប្រើនៅឡើយទេ នៅគ្រាដំបូងៗរបស់យើង។ ដូច្នេះ ខ្ញុំត្រូវត្រឡប់មកផ្ទះវិញ ដើម្បីនិយាយពាក្យ «បងទៅហើយ» ហើយបន្តដំណើររបស់ខ្ញុំទៅមុខទៀត—ជាដំណើរការដែលមិនសំខាន់នោះទេ! ខ្ញុំត្រូវលះអាល័យភាពស្រណុករបស់ខ្លួនចោល ក្នុងការស្រឡាញ់ប្រពន្ធរបស់ខ្ញុំ ដូច

ដែលខ្ញុំគួរតែធ្វើ។

- មានឪពុកម្នាក់បានត្រឡប់មកផ្ទះវិញ ដោយអស់កម្លាំងយ៉ាងខ្លាំង ហើយចង់ចូលគេងឲ្យបានឆាប់។ កូនស្រីរបស់គាត់នឹងទៅកម្មវិធីជប់លៀងមួយនៅយប់នោះ ហើយបានសួរគាត់ថា តើគាត់អាចជួយទៅយកនាងមកផ្ទះវិញនៅប្រហែលពាក់កណ្ដាលយប់បាន ឬក៏អត់។ គាត់បានរអ៊ូក្នុងចិត្ត នៅពេលដែលឮកូនស្នើសុំដូច្នេះ ប៉ុន្តែគាត់លះអាល័យបំណងប្រាថ្នារបស់គាត់ក្នុងការគេង ហើយក៏យល់ព្រមក្នុងការទៅយកកូនស្រីរបស់គាត់។ តាមពិតទៅ ការយល់ព្រមជាមួយសំណើកូនស្រីរបស់គាត់ គឺជាអ្វីដែលល្អបំផុតដែលឪពុកអាចធ្វើបាន។ ខ្ញុំបានធ្វើការនេះជាញឹកញាប់ជាមួយកូនៗរបស់ខ្ញុំ ហើយខ្ញុំក៏តែងតែសប្បាយចិត្តដែលអាចជួយពួកគេបាន នៅក្នុងរបៀបនេះ។ មានចំណុចស្រស់ស្អាតអំពីការលះអាល័យតិចតួច ដោយក្ដីស្រឡាញ់ ដែលបានធ្វើឡើងសម្រាប់អ្នកដែលយើងស្រឡាញ់។ សុភមង្គលគឺជាទ្រព្យសម្បត្តិដ៏ធំបំផុតសម្រាប់ផ្ទះរបស់អ្នក។ វាមានតម្លៃយ៉ាងខ្លាំងក្នុងការលះអាល័យការគេងបន្តិចបន្តួច ដើម្បីទទួលបានសុភមង្គលនៅក្នុងរបៀបនេះ។
- មានម្ដាយម្នាក់ស្រឡាញ់ការងាររបស់គាត់ ហើយក៏ធ្វើវាបានយ៉ាងល្អដែរ សម្រាប់សិរីល្អរបស់ព្រះជាម្ចាស់។ គាត់ក៏ស្រឡាញ់គ្រួសារដែលព្រះជាម្ចាស់បានប្រទានឲ្យគាត់ដែរ។ ថ្មីៗនេះ គាត់បានចាប់ផ្ដើមឃើញថា កូនៗរបស់គាត់មានបន្ទុក ដោយសារការងាររបស់គាត់បានរារាំងគាត់មិនឲ្យមានពេលគ្រប់គ្រាន់ តាមដែលពួកគាត់ត្រូវការ។ បើគាត់សម្រាកពីរបីឆ្នាំពីការងាររបស់គាត់ វាហាក់បីដូចជា ធ្វើឲ្យគាត់បាត់បង់ឱកាសឡើងតំណែងនៅកន្លែងធ្វើការ។ ប៉ុន្តែ គាត់ក៏បានសម្រេចចិត្តឈប់ ដោយលះអាល័យបំណងប្រាថ្នារបស់គាត់ចោល សម្រាប់អំណរដែលគាត់

មានក្នុងការងាររបស់គាត់ និងគោលដៅដែលមានហេតុផលរបស់គាត់ក្នុងការឡើងតំណែង។

- ឱកាសដ៏ល្អមួយបានមកដល់ប្ដី ក្នុងការចេញទៅទទួលការរៀនសូត្រ នៅប្រទេសក្រៅអស់រយៈពេលបីខែ។ ដំណើរនោះនឹងជួយឲ្យគាត់ឡើងតំណែងក្នុងការងាររបស់គាត់ ហើយក្នុងការងារដែលគាត់ស្រឡាញ់ និងធ្វើសម្រាប់ជាសិរីល្អដល់ព្រះជាម្ចាស់។ ប៉ុន្តែ ពីរអាទិត្យមុនគាត់ត្រូវចេញទៅ ប្រពន្ធរបស់គាត់ក៏បានឆ្លងវីរុសមួយ ដែលធ្វើឲ្យគាត់អស់កម្លាំង។ គ្រូពេទ្យបានប្រាប់ថាប្រហែលជាពីរបីអាទិត្យទៀតទើបគាត់អាចចាប់ផ្ដើមមានកម្លាំងឡើងវិញ។ ប្ដីក៏ឃើញថា ប្រពន្ធរបស់ខ្លួននឹងមានការពិបាកក្នុងការនៅមើលថែផ្ទះ ដោយមិនមានគាត់នៅជាមួយ។ គាត់ក៏បានលះអាល័យបំណងប្រាថ្នារបស់ខ្លួនក្នុងការទទួលបានការបង្ហាត់បង្រៀនបន្ថែម ដើម្បីឲ្យគាត់អាចជួយប្រពន្ធរបស់គាត់បាន។ ហើយអ្នកផ្សេងទៀតទៅទទួលការបង្ហាត់បង្រៀនជំនួសគាត់។
- ដៃគូមួយគូកំពុងតែជជែកគ្នាអំពីជម្លោះដែលកំពុងកើតឡើងនៅក្នុងទំនាក់ទំនងរបស់ពួកគាត់។ ខណៈពេលដែលពួកគាត់កំពុងតែជជែកគ្នា មិនយូរមិនឆាប់ ពួកគាត់ក៏បានឃើញយ៉ាងច្បាស់លាស់ថា ទាំងពីរនាក់បានធ្វើខុស ក្នុងការបង្កើតឲ្យមានជម្លោះនេះ។ លក្ខណៈជាគ្រីស្ទបរិស័ទគឺថា ពួកគាត់នឹងសូមទោសគ្នាទៅវិញទៅមក ទាក់ទងនឹងចំណុចខុសដែលពួកគាត់បានប្រព្រឹត្តឡើង។ ប៉ុន្តែ ការធ្វើបែបនោះនឹងបង្ហាញពីការអាម៉ាស់ និងហាក់បីដូចជាថាម្ខាងបានឈ្នះ។ ម្នាក់ក្នុងចំណោមពួកគាត់ត្រូវការលះអាល័យខ្លួនឯង មានការបន្ទាបខ្លួន ហើយសូមការអភ័យទោសជាមុនសិន។ ហើយជាទូទៅ បន្ទាប់ពីនោះ ម្នាក់ទៀតក៏នឹងសូមអភ័យទោសផងដែរ។ នៅពេលក្រោយ យើងនឹងបង្ហាញថា អ្នកដែលមិនសូមទោសគេ គឺជាមនុស្សទន់ខ្សោយ។ កម្លាំងដ៏

ខ្លាំងបំផុតនៅក្នុងជីវិតរបស់យើងគឺជាការស្ថិតនៅក្រោមព្រះគុណរបស់ព្រះជាម្ចាស់។ ការមិនបានសុំទោសរាំងព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការចូលមកជីវិតរបស់យើង។ ដែលនោះធ្វើឲ្យយើងក្លាយជាមនុស្សទន់ខ្សោយ ដោយគ្មានសេចក្តីអំណរក្នុងការរស់នៅក្រោមព្រះគុណរបស់ព្រះអង្គ។

• ប្រពន្ធបានប្រព្រឹត្តការយ៉ាងអាក្រក់មួយ។ គាត់បានសារភាពអំពើបាបរបស់គាត់ ហើយក៏ទទួលបានការអត់ទោសពីព្រះជាម្ចាស់ និងពីប្តីរបស់ខ្លួន។ ពួកគាត់បានចាប់ផ្តើមទំនាក់ទំនងរបស់ពួកគេជាថ្មីម្តងទៀតដោយឈរយ៉ាងមាំនៅក្រោមព្រះគុណរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ឥឡូវនេះ ជាច្រើនខែបានកន្លងផុតទៅ ពួកគាត់កំពុងប្រឈមមុខនឹងជម្លោះ ហើយកំពុងជជែកគ្នាយ៉ាងក្តៅគគុក។ ប្តីដឹងថា ប្រសិនបើគាត់លើកឡើងអំពីកំហុសប្រពន្ធរបស់គាត់ពីអតីតកាល នោះគាត់នឹងអាចមានខ្សែលើ។ ប៉ុន្តែ ដូចដែលព្រះជាម្ចាស់បានអត់ទោស ហើយក៏បំភ្លេចចំពោះអំពើបាបរបស់យើងដែរ (យេរេមា ៣១:៣៤) នោះគ្រីស្ទបរិស័ទដែលទទួលបានការអត់ទោសបាបទាស់ប្រឆាំងនឹងខ្លួនក៏ត្រូវតែប្រព្រឹត្តដូចដែលពួកគាត់បានភ្លេចអំពើបាបទាំងនោះដែរ។ បុរសជាប្តីបានលះអាល័យខ្លួនឯងដោយទប់ទល់នឹងសេចក្តីល្បួងក្នុងការលើកឡើងនូវបញ្ហាចាស់ៗ មកដាក់ក្នុងការជជែកគ្នានោះ។

• ប្តីបានសង្កេតឃើញថា ខ្លួនបានវង្វេងចូលមើលគេហទំព័រដែលមិនត្រឹមត្រូវ ហើយចម្អែតការស្កប់ចិត្តរបស់ខ្លួនតាមរយៈអ្វីដែលគាត់បានមើល។ ការនេះអាចបំផ្លាញទំនាក់ទំនងរបស់គាត់ជាមួយនឹងប្រពន្ធរបស់គាត់ ហើយជាលទ្ធផល ប្រពន្ធបានប្រែទៅជាមិនគួរឲ្យចាប់អារម្មណ៍ក្នុងការរួមដំណេកចំពោះគាត់ដោយសារការកុហក និងប្រភពនៃការរួមដំណេក ដែលបំផ្លាញការស្កប់ចិត្តចោល ដែលមាននៅលើបណ្តាញអ៊ីនធឺណិត។ ក៏ត្រូវតែ

ប្តេជ្ញាចិត្តក្នុងការលះអាល័យសេចក្តីប្រាថ្នារបស់គាត់ ក្នុងការមើលរូបអាសអាភាស (មិនមែនគ្រាន់តែលើបណ្តាញអ៊ីនធឺណិត ប៉ុន្តែក៏លើកញ្ចក់ទូរទស្សន៍ និងផ្ទាំងប៉ាណូដែរ) ដើម្បីស្រឡាញ់ព្រះ និងប្រពន្ធរបស់គាត់។ ដោយសារអ៊ីនធឺណិតគឺជាអន្ទាក់ ខ្ញុំបានសង្កេតឃើញថា ការមានប្រព័ន្ធរាំងបណ្តាញអ៊ីនធឺណិតខ្លាំង និងកម្មវិធីពិនិត្យគ្រប់គ្រង គឺជាការល្អ។ ខ្ញុំមានមិត្តភក្តិម្នាក់ដែលគាត់ជួយមើលការខុសត្រូវលើជីវិតខ្ញុំទទួលបានការរាយការណ៍អំពីគេហទំព័រដែលខ្ញុំចូលមើលជាប្រចាំអាទិត្យ។

- ស្ត្រីដែលជាគ្រីស្ទបរិស័ទម្នាក់បានបង្កើតទំនាក់ទំនងនៅកន្លែងធ្វើការដែលចម្រើនការងារ និងកក់ក្តៅជាមួយនឹងអ្នកធ្វើការម្នាក់ដែលជាមនុស្សប្រុស ដែលគាត់ធ្វើការជាមួយ។ ដោយសារពួកគាត់ចំណាយពេលជាច្រើនជាមួយគ្នា អារម្មណ៍ដែលពិបាកពន្យល់នៃការយល់គ្នាអំពីការដែលបុគ្គលម្នាក់ទៀតគិត ក៏ហាក់បីដូចជាចាប់ផ្តើមបានកើតឡើង។ ពួកគាត់ចូលចិត្តចំណាយពេលជាមួយគ្នា ហើយក៏ឃើញថា វាជារឿងធម្មតាដែលពួកគាត់ចំណាយពេលជាមួយគ្នា នៅពេលតម្រង់ជួរញ៉ាំបាយថ្ងៃ និងអ្វីផ្សេងទៀត។ មិនយូរមិនឆាប់ ស្ត្រីនោះក៏ឃើញថា គាត់កំពុងតែចាប់ផ្តើមមានបំណងប្រាថ្នាក្នុងការនៅជាមួយនឹងបុរសនោះ ហើយក៏ចាប់ផ្តើមប្រាប់បុរសនោះអំពីរឿងផ្ទាល់ខ្លួនអំពីជីវិតគាត់។ ស្ត្រីនោះឃើញថា គាត់មានការស្ទាក់ស្ទើរក្នុងការប្រាប់ប្តីរបស់គាត់អំពីចំណុចលម្អិតនៃទំនាក់ទំនងរបស់គាត់ជាមួយនឹងបុរសម្នាក់នោះ។ ពិតណាស់ នោះគឺជាចំណុចសម្គាល់នៃគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ។ វាជារឿងធម្មតាទេដែលគ្រីស្ទបរិស័ទដែលជួបបុគ្គលណាម្នាក់ផ្សេងទៀត ដែលមានភេទខុសគ្នា ក្នុងការចាប់អារម្មណ៍ខ្លាំងជាងបុគ្គលណាម្នាក់ផ្សេងទៀត។ វាមិនមែនជារឿងខុសទេក្នុងការចូលចិត្តមនុស្សដូចនោះ។ ប៉ុន្តែ វាគឺជារឿងដ៏ងាយស្រួលណាស់

ក្នុងការទៅហួសព្រំដែន ហើយបង្កើតទំនាក់ទំនងដែលមិនសមរម្យជាមួយនឹងមនុស្សបែបនោះ។ គ្រីស្ទបរិស័ទដែលគោរពតាមព្រះគម្ពីរនឹងលះអាល័យសេចក្តីប្រាថ្នារបស់ខ្លួន ក្នុងការនៅជាមួយនឹងមនុស្សបែបនោះរាល់ពេល ហើយនឹងជ្រើសរើសបោះបង់ភាពសប្បាយរីករាយចោលនៃការនៅក្បែរគាត់។ និយាយអញ្ចឹង សព្វថ្ងៃនេះ បណ្តាញសង្គមដូចជា ហ្វេសបុក (Facebook) កំពុងតែបង្កើតទំនាក់ទំនងមិនសមរម្យដូចនេះ។

- បុរសជាប្តីម្នាក់កំពុងមានពេញទៅដោយសំពាធនៅកន្លែងធ្វើការ។ គាត់រវល់ខ្លាំងមែនទែន ហើយក៏មិនបានគេងគ្រប់គ្រាន់តាមអ្វីដែលគាត់ត្រូវការដែរ។ ជាលទ្ធផល គាត់ឆាប់ខឹង ហើយងាយនឹងទទួលបានការរំខានមែនទែន ជាពិសេសនៅផ្ទះ។ គាត់កត់សម្គាល់ឃើញថា បញ្ហាមួយនេះគឺដោយសារតែមានសំពាធពីការងាររបស់គាត់។ ការនេះបានដាស់តឿនគាត់ក្នុងការដែលគាត់អាចនឹងធ្វើអ្វីមួយដែលមិនគប្បី។ ដូច្នេះ នៅពេលដែលគាត់មានសេចក្តីល្បួងក្នុងការច្រឡោតនឹងប្រពន្ធ ឬកូនៗរបស់ខ្លួន គាត់ក៏បានលះអាល័យខ្លួនឯងអំពីបំណងប្រាថ្នាមួយនោះដោយដឹងខ្លួន ហើយជ្រើសរើសដោយមិនសម្តែងឲ្យឃើញពីសកម្មភាពរបស់គាត់ទេ។ តាមពិតទៅ កាលពេលដែលកូនៗរបស់ខ្ញុំនៅតូច ខ្ញុំឃើញថាវាជាជំនួយមួយនៅពេលដែលខ្ញុំប្រាប់ពួកគាត់ថា ខ្ញុំកំពុងស្ថិតក្រោមភាពតានតឹង ដើម្បីឲ្យពួកគេបានដឹងថា ការដែលខ្ញុំឆាប់នឹងខឹងគឺមិនមែនមកពីពួកគាត់នោះទេ។
- ម្តាយម្នាក់បានសម្រេចចិត្តថា កូនរបស់គាត់នឹងយកប្រពន្ធដែលមានលក្ខណៈដូចម្តេចរួចហើយ។ គាត់មានបញ្ជីមួយដែលមានរៀបរាប់ពីលក្ខណសម្បត្តិ ដែលកូនក្រមុំរបស់កូនប្រុសគាត់ត្រូវតែមាន។ កូនប្រុសរបស់គាត់បានលង់ស្នេហ៍ជាមួយនារីដែល

> ជាគ្រីស្ទបរិស័ទដ៏ល្អម្នាក់ ប៉ុន្តែស្ត្រីនោះមិនមាននូវគ្រប់ចំណុចដូចដែលម្តាយរបស់កូនប្រុសនោះបានទាមទារនោះទេ។ គាត់មានស្បែកខ្មៅពេក ម្តាយបានចាត់ទុករូបរាងរបស់គាត់ថា មិនស្អាតផ្នែកឯរូបរាងខាងក្រៅ។ គ្រួសាររបស់កូនស្រីនោះមិនមានជីវភាពធូរធារដូចគ្រួសាររបស់គាត់ ហើយគាត់ក៏មិនទទួលបានការរៀនសូត្រគ្រប់គ្រាន់ ដូចអ្វីដែលម្តាយកូនប្រុសនោះចង់ឲ្យប្រពន្ធកូនគាត់មានដែរ។ ម្តាយនោះក៏មានការតូចចិត្តដែលគាត់មិនបានចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តដ៏សំខាន់របស់កូនប្រុសគាត់ក្នុងការស្រឡាញ់មិត្តស្រីរបស់គាត់។ តើគាត់នឹងធ្វើអ្វី? ក្នុងការបដិសេធការជ្រើសរើសរបស់កូនប្រុសគាត់មិនមានចែងនៅក្នុងព្រះគម្ពីរនោះទេ។ គាត់ត្រូវតែលះអាល័យបំណងប្រាថ្នារបស់ខ្លួនដើម្បីឲ្យកូនប្រុសរបស់គាត់អាចរៀបការដោយមានសុភមង្គលជាមួយកូនស្រីម្នាក់នេះ។

ការបដិសេធមិនព្រមលះអាល័យខ្លួនយើងគឺជាចំណុចសម្គាល់នៃភាពកម្សោយរបស់យើងផ្ទាល់។ មនុស្សយើងចូលចិត្តប្រកាន់ខ្ជាប់ជាមួយគំនិតរបស់ខ្លួន ហើយខ្លាចក្នុងការចុះចូលជាមួយអ្នកដទៃ ដើម្បីទទួលបានការល្អប្រសើរជាងនេះ។ ពួកគេមើលឃើញថាវាជាសញ្ញានៃការបរាជ័យ។ ការភ័យខ្លាចនៃ «ការបរាជ័យ» បែបនេះ គឺជាសញ្ញាសម្គាល់នៃការមិនមានសុវត្ថិភាព។ ជាការគួរឲ្យសោកស្តាយ ដោយសារភាពរឹងចចេសរបស់ខ្លួន ពួកគេធ្វើឲ្យអ្នកដទៃទៀតឈឺចាប់។ ប្តីប្រពន្ធ និងកូនរបស់ពួកគាត់ក៏មានស្នាមជាំក្នុងចិត្តតាមរយៈការបដិសេធមិនចុះចូលឆន្ទៈរបស់ខ្លួន ដើម្បីទទួលបានប្រយោជន៍ល្អប្រសើរជាងនោះ។ ពួកគាត់ទំនងជាមនុស្ស «សុចរិត» ប៉ុន្តែពួកគាត់ក៏បានក្លាយជាមនុស្សដែលមានចិត្តអាក្រក់ដែរ។ កូនៗដែលធ្វើឲ្យឪពុកម្តាយឈឺចាប់តាមរយៈភាពរឹងរូសដែលមានពេញទៅដោយកំហឹងរបស់ខ្លួន ទាក់ទងនឹងការចង់ធ្វើតាមចិត្ត ក៏ត្រូវតែទទួលស្គាល់ថា ពួកគាត់ក៏បានក្លាយជាមនុស្សដែល

មានចិត្តអាក្រក់ផងដែរ។ បុរសៗជាប្តីដែលប្រើប្រាស់សម្តីឈឺចាប់ទៅកាន់ប្រពន្ធរបស់ខ្លួន នៅពេលដែលពួកគេខឹងក៏បានក្លាយជាប្តីមិនល្អដែរ។ គាត់ត្រូវតែបញ្ឈប់ការនោះជាបន្ទាន់!

គ្រីស្ទបរិស័ទមិនត្រូវធ្វើឲ្យអ្នកដទៃឈឺចាប់នោះទេ! ពួកគាត់ត្រូវដឹងថា ការធ្វើបែបនោះគឺពួកគាត់កំពុងតែធ្វើឲ្យព្រះជាម្ចាស់មិនសប្បាយព្រះទ័យ ហើយក៏កំពុងតែបំផ្លាញខ្លួនឯងផ្ទាល់ និងអ្នកដទៃយ៉ាងខ្លាំងផងដែរ។ នៅចុងបញ្ចប់ វាគឺជាចំណុចដែលថា តើយើងស្រឡាញ់ព្រះជាម្ចាស់ និងសមាជិកគ្រួសារយើងល្មមដល់ថ្នាក់ថាហ៊ានចុះចូលឆន្ទៈរបស់ខ្លួន និងបោះបង់ចំណុចទាំងនោះខ្លះចោល ដែលយើងមិនចង់បោះបង់ចោលដែរឬទេ។ ពេលខ្លះ គ្រីស្ទបរិស័ទដែលមានជំនឿស៊ប់នឹងមានការពិបាកទាក់ទងនឹងចំណុចនេះ។ ពួកគាត់ទំនងជាអ្នកដឹកនាំគ្រីស្ទបរិស័ទជាអចិន្ត្រៃយ៍មែន ប៉ុន្តែពួកគាត់ជាមនុស្សដែលមិនបរិសុទ្ធ។ ពួកគាត់មិនគួរមានតំណែងជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំទេ។

## មានជំនួយ

ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំត្រូវតែបញ្ជាក់ឲ្យបានច្បាស់ថា ការលះអាល័យខាងឯសាច់ឈាមរបស់ខ្លួនឯងគឺមិនមែនជាអ្វីដែលយើងអាចធ្វើបានដោយកម្លាំងខ្លួនឯងនោះទេ។ ព្រះជាម្ចាស់ប្រទានព្រះគុណដល់យើងក្នុងការធ្វើវា។ របៀបមួយដែលព្រះអង្គធ្វើការនេះគឺព្រះអង្គប្រទានឲ្យយើងមានមិត្តភក្តិ ដើម្បីជួយយើងនៅពេលដែលយើងមានតម្រូវការ។ ការមានអ្នកជួយមើលខុសត្រូវជីវិតរបស់យើងអាចជួយឲ្យយើងកត់ត្រាលើអាកប្បកិរិយារបស់យើងក្នុងចំណុចទន់ខ្សោយ ដែលមានដូចជាការងាយខឹង និងការប្រើប្រាស់អ៊ីនធឺណិតក្នុងរបៀបមិនត្រឹមត្រូវ។ មិត្តភក្តិ និងអ្នកដឹកនាំដែលយើងឲ្យតម្លៃអាចផ្តល់ជាប្រឹក្សាដល់យើងបាន។ អ្នកស្តាប់ដែលមានការយល់ដឹងអាចងាយឃើញឫសគល់នៃបុព្វហេតុដែលបណ្តាលឲ្យមានការមិនព្រមព្រៀងគ្នាក្នុងគ្រួសារ ដែលអ្នកកំពុងស្ថិតក្នុងបញ្ហានោះមើលមិនឃើញ។ នៅពេលដែល

គ្រប់យ៉ាងមើលទៅស្រអាប់ នោះអ្នកដទៃអាចជួយយើងឲ្យមើលឃើញអ្វីៗនោះក្នុងពន្លឺ និងបើកផ្លូវសម្រាប់យើងក្នុងការបន្តទៅមុខទៀត ដើម្បីស្វែងរកដំណោះស្រាយដោយមានប្រសិទ្ធភាពដែរ។

ខ្ញុំធ្លាប់បានធ្វើការជាមួយនឹងដៃគូជីវិត ដែលបានគិតថា បញ្ហាដែលពួកគាត់កំពុងតែឆ្លងកាត់ ពួកគាត់មិនអាចរកដំណោះស្រាយបានឡើយ។ ដូចដែលការចុះអន្តរាគមន៍របស់អ្នកណាម្នាក់ផ្សេងទៀតអាចផ្តល់នូវឱកាសដល់ពួកគាត់ក្នុងការស្តាប់គ្នាទៅវិញទៅមក ហើយយល់អាកប្បកិរិយារបស់គ្នាទៅវិញទៅមកអាចនាំឲ្យមានជាលទ្ធផលនៃការផ្លាស់ប្តូរដ៏ខ្លាំងក្លា សម្រាប់ជាប្រយោជន៍ក្នុងទំនាក់ទំនងរបស់ពួកគាត់ដែរ។ នេះគឺជាចំណុចដែលជាជំនួយដ៏ជាក់លាក់ក្នុងឆ្នាំដំបូងៗនៅជីវិតអាពាហ៍ពិពាហ៍ នៅពេលដែលដៃគូជីវិតម្ខាងបានទទួលការឈឺចាប់ តាមរយៈទង្វើនៃដៃគូជីវិតម្ខាងទៀត។ គាត់គិតថាដៃគូជីវិតរបស់គាត់កំពុងតែមានចិត្តអាក្រក់ នៅពេលដែលជាក់ស្តែង តាមពិតទៅបញ្ហាមានការតភ្ជាប់ជាមួយនឹងបុគ្គលិកលក្ខណៈនៃដៃគូជីវិត ឬក៏របៀបនៃការដែលដៃគូជីវិតនោះបានធំធាត់ឡើង (ដែលនេះទាក់ទងទៅនឹងប្រវត្តិរបស់ពួកគាត់វិញ)។

ប៉ុន្តែ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺថា ព្រះជាម្ចាស់ជួយយើងដោយប្រទានឲ្យយើងមានសមត្ថភាព និងកម្លាំងក្នុងការលះអាល័យសាច់ឈាមយើងចោល។ សាវ័ក ប៉ុល បានលើកឡើងថា «តែបើសម្លាប់អំពើរបស់រូបសាច់ចេញ ដោយសារព្រះវិញ្ញាណ» (រ៉ូម ៨:១៣)។ ព្រះវិញ្ញាណមានវត្តមានក្នុងការជួយយើងឲ្យអាចធ្វើការនេះបាន។ យើងត្រូវតែទទួលស្គាល់ថា យើងមានបញ្ហា។ យើងត្រូវតែអធិស្ឋាន ហើយទូលសូមឲ្យព្រះជាម្ចាស់ជួយយើង។ ព្រះជាម្ចាស់អាចជួយបានដោយផ្តល់ដំណោះស្រាយរបស់ព្រះអង្គ ប៉ុន្តែទំនួលខុសត្រូវរបស់យើងគឺ យើងត្រូវតែស្ម័គ្រចិត្តលះអាល័យខ្លួនឯងចោល។ ព្រះអង្គប្រទានកម្លាំងដល់យើងក្នុងការធ្វើវា។ ព្រះជាម្ចាស់អាចធ្វើការយ៉ាងមហិមាបានជាមួយអស់អ្នកដែលស្ម័គ្រចិត្តក្នុងការផ្លាស់ប្តូរ ដើម្បីឲ្យព្រះអង្គអាចធ្វើនូវអ្វីដែលព្រះអង្គសព្វព្រះហឫទ័យធ្វើជាមួយពួកគេ។

ពេលខ្លះ បញ្ហាក៏មានភាពស្មុគស្មាញខ្លាំងជាងការគ្រាន់តែត្រូវលះអាល័យខ្លួនឯងទៅទៀត។ ហើយក៏អាចមានកត្តាផ្សេងទៀត ដែលបង្កឲ្យមានការឆ្លើយតប ដូចដែលបានពណ៌នាខាងលើ។ របួសដែលមិនទាន់បានទទួលការព្យាបាលពីមុនៗក្នុងជីវិតអាចនាំឲ្យបុគ្គលណាម្នាក់ឆ្លើយតបក្នុងរបៀបហួសហេតុ នៅពេលដែលកំពុងឆ្លងកាត់ការមិនឯកភាពគ្នា។ ឧទាហរណ៍៖ អស់អ្នកដែលធ្លាប់ទទួលទារុណកម្មដោយគ្មានក្តីមេត្តាករុណា ហើយទទួលការឈឺចាប់កាលគាត់នៅក្មេងអាចនឹងមិនងាយចុះសម្រុងគ្នា នៅពេលឈ្លោះគ្នា ដោយសារធ្លាប់មានអ្នកផ្សេងកេងប្រវ័ញ្ចក្នុងកាលៈទេសៈដូចៗនោះ ហើយបានធ្វើឲ្យពួកគាត់ឈឺចាប់ កាលគាត់នៅក្មេងនៅឡើយ។ ពិរុទ្ធភាពលើអំពើបាបដែលធ្លាប់បានប្រព្រឹត្តមុន ឬក៏ក្នុងអំឡុងពេលនៃជីវិតអាពាហ៍ពិពាហ៍ក៏អាចនាំឲ្យពួកគាត់មានការលំបាកក្នុងការស្រឡាញ់ខ្លួនឯងដែរ ដែលជាលទ្ធផលនាំឲ្យពួកគាត់ជំទាស់ជាមួយនឹងអស់អ្នកក្នុងគ្រួសារ ដែលកំពុងតែព្យាយាមស្រឡាញ់ពួកគាត់។ មានក្មេងៗមួយចំនួនបានធំធាត់ឡើងជា “ក្មេងទម្រើស” ដែលទទួលបានសឹងតែគ្រប់អ្វីៗដែលពួកគាត់ទារ ប្រសិនបើពួកគាត់ស្រែកយំខ្លាំងល្មម។ នៅពេលដែលពួកគាត់ពេញវ័យ ពួកគាត់ក៏មានការពិបាកក្នុងការបោះបង់ចោលសេចក្តីប្រាថ្នារបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ពីព្រោះពួកគាត់មិនមានជំនាញក្នុងការរស់នៅដោយមិនទទួលបានការបំពេញសេចក្តីប្រាថ្នារបស់ខ្លួន។ យើងនឹងឆ្លើយតបលើបញ្ហាទាំងនោះនៅពេលក្រោយក្នុងសៀវភៅមួយនេះ។ ប៉ុន្តែ សូម្បីតែចំពោះអស់អ្នកណាដែលប្រឈមមុខនឹងពិការភាពដូចនេះ ក៏ព្រះគុណរបស់ព្រះជាម្ចាស់នៅមានភាពគ្រប់គ្រាន់ក្នុងការព្យាបាល និងធ្វើឲ្យពួកគាត់មានអាកប្បកិរិយាដែលចេះកោតខ្លាចព្រះដែរ។

## ចូរជឿថាព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ

គន្លឹះដ៏សំខាន់មួយ ដើម្បីពិចារណា គឺទាក់ទងទៅនឹងអ្វីដែលព្រះគម្ពីរបានលើកឡើង អំពីផលផ្លែដោយការលះអាល័យខ្លួនឯងចោល។ ភ្លាមៗបន្ទាប់

ពីពេលដែលព្រះយេស៊ូវត្រាស់ហៅឲ្យលះអាល័យខ្លួនឯងចោល ហើយលីឈើឆ្កាង ព្រះអង្គបានមានបន្ទូលថា «ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំ នោះនឹងបានជីវិតវិញ» (លូកា ៩:២៤)។ ការលះអាល័យខ្លួនឯងចោល ដើម្បីស្តាប់បង្គាប់ព្រះគ្រីស្ទ គឺមិនមែនជាអ្វីដែលនឹងធ្វើឲ្យយើងមានការឈឺចាប់នោះទេ។ វាគឺជាផ្លូវឆ្ពោះទៅកាន់ជីវិត។ វាគឺជាចំណុចដ៏ល្អប្រសើរបំផុត ដែលយើងអាចធ្វើបានក្នុងដំណើរ និងអំណរនៃជីវិតរបស់យើង។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា នៅពេលដែលយើង «បានថ្វាយរូបកាយ [របស់យើង] ទុកជាយញ្ញបូជារស់» នោះយើងបាន «ស្គាល់» ថា «បំណងព្រះហឫទ័យនៃព្រះ» គឺ «ល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង» (រ៉ូម ១២:១-២)។ យើងត្រូវតែជឿលើការនេះ—ថាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ។ ប្រសិនបើយើងជឿ នោះយើងនឹងទទួលយកនូវការប្រថុយនៃការលះអាល័យខ្លួនឯងចោល ដោយទទួលស្គាល់ថាយើងបានប្រព្រឹត្តខុស ហើយសូមអភ័យទោស ដោយដឹងថាព្រះជាម្ចាស់នឹងថែរក្សាយើង ដោយសារយើងបានឈានដោយស្តាប់បង្គាប់។

ពិតណាស់ យើងក៏អាចធ្លាប់មានបទពិសោធន៍នៃការមិនសប្បាយចិត្ត ហើយមានពេញដោយការឈឺចាប់ទាក់ទងទៅនឹងការបោះបង់អ្វីមួយចោល។ ប៉ុន្តែ នៅពេលដែលព្រះជាម្ចាស់បង្គាប់ឲ្យយើងធ្វើអ្វីមួយ នោះគឺដោយសារតែវាជាការដ៏ល្អបំផុតសម្រាប់យើង។ ដូច្នេះ នៅពេលដែលយើងលះអាល័យខ្លួនឯង យើងធ្វើការនោះដោយជឿថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺល្អបំផុតសម្រាប់យើង។ ហើយប្រសិនបើយើងមិនទទួលជឿលើព្រះជាម្ចាស់ទេ នោះមិនថាយើងលះអាល័យខ្លួនឯង ឬក៏អត់នោះក៏យើងនឹងបាត់បង់សន្តិភាព និងសេចក្តីអំណររបស់យើងជាមិនខានឡើយ។ សាវ័ក ប៉ុល បានលើកឡើងថា «ព្រះនៃសេចក្តីសង្ឃឹម [នឹង] ប្រទានឲ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្តីអំណរ និងសេចក្តីសុខសាន្តដ៏ពោរពេញ ដោយសារសេចក្តីជំនឿ» (រ៉ូម ១៥:១៣)។ ដូចនៅក្នុងគ្រប់ចំណុចទាំងអស់នៅក្នុងជីវិតជាគ្រីស្ទ

បរិស័ទ ជំនឿគឺជាផ្លូវនាំទៅកាន់ជ័យជម្នះ។ យើងជឿលើការល្អនៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយធ្វើការសម្រេចចិត្តដែលមើលទៅហាក់បីដូចជាការលះបង់ ដោយគ្រាន់តែដឹងថាការសម្រេចចិត្តទាំងនោះកំពុងតែនាំយើងទៅកាន់ផ្លូវនៃការទទួលបានការប្រទានពរ។

ប្រសិនបើយើងកំពុងតែបង្កឲ្យមានការឈឺចាប់ និងការមិនសប្បាយនៅក្នុងជីវិតនៃគ្រួសាររបស់យើង ដោយសារបញ្ហាមួយចំនួនរបស់យើងផ្ទាល់ខ្លួន នោះយើងត្រូវតែរាប់វាថាជាបញ្ហាបន្ទាន់ ដែលត្រូវការដំណោះស្រាយភ្លាមៗ។ យើងមិនអាចចរចាបានឡើយ។ ការធ្វើបែបនោះគឺជារឿងដ៏ល្ងីល្ងើណាស់ ពីព្រោះជាលទ្ធផល យើងនឹងធ្វើឲ្យខ្លួនឯងឈឺចាប់ និងអស់អ្នកដែលយើងស្រឡាញ់ក៏ឈឺចាប់ដែរ។ ប៉ុន្តែ ធ្ងន់ធ្ងរជាងនេះទៅទៀត នេះគឺជាការបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់—ជាការដែលល្ងង់ និងគ្រោះថ្នាក់ខ្លាំងបំផុតក្នុងការប្រព្រឹត្ត។ យើងគួរតែធ្វើឲ្យអស់ពីសមត្ថភាព ហើយរកឲ្យគេជួយតាមដែលយើងអាចធ្វើបាន ដើម្បីឲ្យយើងអាចយកឈ្នះលើបញ្ហានេះបាន។

## សេចក្តីសន្និដ្ឋាន

ដូចដែលសេចក្តីសង្គ្រោះគឺជាអំណោយទាននៃព្រះគុណ នោះការញែកឲ្យបរិសុទ្ធក៏ជាអំណោយដែរ។ ព្រះជាម្ចាស់មានវត្តមានក្នុងការជួយអស់អ្នកដែលស្ម័គ្រចិត្តឲ្យព្រះហឫទ័យរបស់ទ្រង់មានចំណុចខ្ពស់បំផុតនៅក្នុងជីវិតរបស់ពួកគាត់។ ហើយនៅក្នុងជីវិតគ្រួសារ ក៏ដូចជាក្នុងរាល់ចំណុចផ្សេងទៀតនៃជីវិតនៅពេលដែលឆន្ទៈរបស់យើងប៉ះទង្គិចគ្នាជាមួយនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះយើងត្រូវតែលះអាល័យសាច់ឈាមយើងចោល។

៣

# សេចក្ដីស្រឡាញ់

ព្រះគម្ពីរបានបង្ហាញឲ្យយើងដឹងថាសេចក្ដីស្រឡាញ់ជាលក្ខណសម្បត្តិដ៏សំខាន់មួយរបស់គ្រីស្ទបរិស័ទ។ សាវ័ក ប៉ុល បានពណ៌នាសេចក្ដីស្រឡាញ់ជាលក្ខណសម្បត្តិដ៏សំខាន់បំផុតនៃអត្តចរិតជាគ្រីស្ទបរិស័ទ (១កូរិនថូស ១៣:១-៣, ១៣)។ ប្រសិនបើដូច្នោះមែន សេចក្ដីស្រឡាញ់ក៏ត្រូវតែជាលក្ខណសម្បត្តិដ៏សំខាន់មួយក្នុងផ្ទះរបស់គ្រីស្ទបរិស័ទដែរ។ វាពិតជាសំខាន់ណាស់ ដែលដំបូន្មានដំបូងគេបង្អស់ដែលបានបង្គាប់ទៅកាន់ប្ដីទាំងឡាយ ទាក់ទងទៅនឹងជីវិតអាពាហ៍ពិពាហ៍នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគឺថា ត្រូវឲ្យពួកគាត់ស្រឡាញ់ប្រពន្ធរបស់ខ្លួន (អេភេសូរ ៥:២៥, ២៨, ៣៣; កូឡូស ៣:១៩)។ មានគំនិតទូទៅមួយសម្រាប់ប្រជាជននៅប្រទេសស្រីលង្កាថា គូរស្រករដែលស្រឡាញ់គ្នាគួរតែរីករាយជាមួយគ្នាឲ្យបានច្រើន តាមដែលពួកគេអាចធ្វើបាន មុនពេលដែលពួកគេរៀបការ ពីព្រោះបន្ទាប់ពីនោះមក ទំនាក់ទំនងរបស់ពួកគាត់នឹងប្រែជាល្វីងជូរចត់ ហើយផ្កាភ្លើងនៃសេចក្ដីស្រឡាញ់ក៏នឹងចាប់ផ្ដើមអស់ពន្លឺដែរ។ យើងជំទាស់គំនិតមួយនេះយ៉ាងពេញទំហឹង! យើងគាំទ្រថា សេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទដែលមានការអនុវត្តនៅក្នុងផ្ទះដឹកនាំឲ្យមានជាលទ្ធផលនៃជីវិតអាពាហ៍ពិពាហ៍ដែលពេញទៅដោយអំណរ ជាទីកន្លែង

ដែលសេចក្តីស្រឡាញ់នោះនឹងនៅបន្តជាថ្មី ពេញមួយជីវិតលើផែនដីនេះ។ ក្នុងជំពូកនេះ និងជំពូកបន្ទាប់ យើងនឹងពិនិត្យមើលការអនុវត្តនៃការឃើញសេចក្តីស្រឡាញ់ថាជាលក្ខណសម្បត្តិចម្បងក្នុងផ្ទះគ្រីស្ទបរិស័ទ។

## សេចក្តីស្រឡាញ់ជាគោលដៅនៅក្នុងខ្លួនវាផ្ទាល់[១]

សាវ័ក ប៉ុល បានលើកទឹកចិត្តឲ្យក្រុមជំនុំកូរិនថូស "ដេញតាមសេចក្តីស្រឡាញ់" (១កូរិនថូស ១៤:១)។ កិរិយាសព្ទក្នុងភាសាក្រិកដែលគេបានបកប្រែថា "ដេញតាម" (ដីអូខូ "diōkō") គឺជាពាក្យដែលមានអត្ថន័យខ្លាំងមួយ "ដេញតាម រត់តាម ឬក៏បរបាញ់"។ យើងក៏អាចបកប្រែខគម្ពីរនេះម្យ៉ាងទៀតថា "ចូរយកសេចក្តីស្រឡាញ់ធ្វើជាគោលដៅ"។ ការស្រឡាញ់គឺជាមហិច្ឆតាដ៏ធំមួយក្នុងជីវិតគ្រីស្ទបរិស័ទ។ វាគឺជាអ្វីមួយដែលយើងដេញតាម។ នេះគឺជាផ្លូវដោះស្រាយក្នុងជីវិតគ្រួសារ។ យើងសម្លឹងរកឱកាសស្រឡាញ់សមាជិកនៅក្នុងក្រុមគ្រួសាររបស់យើង។

យើងអាចហៅផ្លូវដោះស្រាយនៃទំនាក់ទំនងគ្រួសារជាច្រើនថាជាការសុខចិត្ត។ មនុស្សជាច្រើនឈានចូលកាលៈទេសៈនេះដែលមានអាកប្បកិរិយាដូចតទៅ៖ "ខ្ញុំនឹងទៅដល់កម្រិតនេះ តែមិនលើសពីនេះទេ"។ "ក្នុងរបៀបណាមួយខ្ញុំត្រូវតែធ្វើឲ្យគាត់ឯកភាពលើចំណុចនេះ ហើយខ្ញុំនឹងប្រើប្រាស់ជំនាញនៃការបញ្ចុះបញ្ចូលរបស់ខ្ញុំ ដើម្បីសម្រេចការនោះ"។ ឬក៏ "អូខេ ខ្ញុំនឹងឯកភាពដោយមិនសប្បាយចិត្ត ដើម្បីឲ្យគាត់នៅស្ងៀម"។ គេបានរាប់ការទទួលបានអ្វីមួយពីអ្នកដទៃថាជាការទទួលបានជ័យជម្នះពីមនុស្សម្នាក់នោះ។ គេបានរាប់ការឲ្យអ្វីមួយទៅកាន់អ្នកដទៃថាជាការព្រមផ្តល់ឲ្យដោយសុខចិត្ត។ នៅក្នុងគ្រួសាររបស់គ្រីស្ទបរិស័ទដ៏ពិតប្រាកដ មិនមានអ្នកឈ្នះ ហើយក៏មិនមានអ្នកចាញ់ដែរ។ យើងបានឈ្នះ ប្រសិនបើយើងបានយល់ស្របទៅលើអ្វីមួយយ៉ាងអស់ពីចិត្ត និងប្រសិនបើយើងបានបង្ហាញសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក។ ដូច្នេះ យើងសួរសំណួរដូចនេះថា៖ "តើខ្ញុំអាចជួយកាត់បន្ថយបន្ទុក

ការងាររបស់គាត់ដោយរបៀបណា?» «តើខ្ញុំអាចធ្វើអ្វីខ្លះបាន ដើម្បីឲ្យគាត់មានអំណរនៅថ្ងៃនេះ?» ឬក៏ថា «តើខ្ញុំអាចបង្ហាញគាត់បានដោយរបៀបណាថា ខ្ញុំពិតជាមានអំណរនៅពេលដែលខ្ញុំបាននៅក្បែរគាត់?» ការស្រឡាញ់សមាជិកនៅក្នុងគ្រួសារយើងគឺជាមហិច្ឆតានៅក្នុងជីវិតយើង ហើយក៏ជារង្វាស់នៃភាពជោគជ័យរបស់យើងដែរ។

គន្លឹះដ៏សំខាន់មួយក្នុងការយល់ដឹងដោយយោងតាមព្រះគម្ពីរគឺថា សេចក្តីស្រឡាញ់គឺជាគោលដៅនៅក្នុងខ្លួនវាផ្ទាល់ មិនមែនគ្រាន់តែជាមធ្យោបាយឆ្ពោះទៅរកគោលដៅផ្សេងនោះទេ។ ដែលនោះមានន័យថា នៅពេលដែលយើងបានស្រឡាញ់ នោះយើងក៏បានសម្រេចគោលបំណងរបស់យើងហើយដែរ (ដូចអ្វីដែលកណ្ឌគម្ពីរ ១កូរិនថូស ១៤:១ បានលើកឡើងដែរ)។ យើងបានទទួលជ័យជម្នះ។ យើងមិនស្រឡាញ់ ដើម្បីឲ្យយើងអាចទទួលបានអ្វីមួយសម្រាប់ខ្លួនយើងនោះទេ។ នៅពេលដែលយើងបានស្រឡាញ់ នោះយើងក៏បានទទួលគ្រប់ទាំងអស់ដែលយើងចង់បានដែរៈ គឺធ្វើជាមនុស្សដែលមានសេចក្តីស្រឡាញ់។ ការស្រឡាញ់គឺជាចលនានៃជីវិតរបស់យើង ជារបៀបនៃការរស់នៅ និងជាបំណងប្រាថ្នារបស់យើង។ យើងសប្បាយចិត្តក្នុងការដែលស្រឡាញ់ ហើយលទ្ធផលយើងទទួលបានគឺជាចំណុចសំខាន់បន្ទាប់បន្សំ។

ផ្លូវដោះស្រាយនៃទំនាក់ទំនងគ្រួសារដោយមានការសុខចិត្តឈានដល់ការបង្ហាញយ៉ាងពេញទី នៅពេលដែលមានយុទ្ធសាស្ត្រនៃការតថ្លៃ ដែលយើងឃើញនៅក្នុងរឿងប្រលោមលោក ឬក៏ក្នុងបណ្តាញសង្គម។ ហើយក៏ថែមទាំងមានការគាំទ្រក្នុងសៀវភៅដែលមានប្រជាប្រិយភាពថាជារបៀបដ៏ត្រឹមត្រូវមួយក្នុងការបំពេញទំនាក់ទំនងដែរ។ នៅក្នុងរបៀបនេះ ភាគីម្ខាងប្រើប្រាស់ភាពប៉ិនប្រសប់ទៅលើភាគីម្ខាងទៀត ដោយការបង្ហាញសេចក្តីស្រឡាញ់ ដោយដាក់បុគ្គលម្នាក់នោះក្នុងអារម្មណ៍ដែលនឹងឲ្យអ្វីដែលបុគ្គលម្នាក់ទៀតចង់បាន។ នាង ដេលីឡា បានធ្វើបែបនេះទៅកាន់លោក សាំសុន។ ប៉ុន្តែ ជាញឹកញាប់វាមានកលល្បិចខ្លាំងជាងភ្លើងរបស់នាង ដេលីឡា សម្រាប់ភាពត្រេកត្រអាល

របស់លោក សាំសុន ទៅទៀត។ បុរសម្នាក់អាចឲ្យផ្កាទៅកាន់ប្រពន្ធខ្លួន ដើម្បីឲ្យនាងមានអារម្មណ៍ល្អក្នុងការឯកភាពទៅលើអ្វីមួយ។ ឬក៏គាត់អាចឲ្យផ្កាដែលជាការបង្ហាញពីសេចក្តីស្រឡាញ់របស់គាត់ចំពោះនាង។ ស្ត្រីម្នាក់អាចអនុញ្ញាតឲ្យប្តីខ្លួនមើលការប្រកួតកីឡានៅលើទូរទស្សន៍ក្នុងពេលកំពុងរវល់នៅផ្ទះ ពីព្រោះគាត់ចង់ឲ្យប្តីត្រៀមខ្លួនក្នុងការដែលគាត់នឹងស្នើសុំទិញខោអាវថ្មី។ ឬក៏គាត់អាចឲ្យប្តីគាត់មើលការប្រកួតដោយសារគាត់ស្រឡាញ់ប្តីរបស់គាត់ ហើយរីករាយក្នុងការឃើញប្តីកំពុងសប្បាយជាមួយអ្វីដែលគាត់ចូលចិត្ត។

ក្នុងផ្ទះដែលមានសេចក្តីស្រឡាញ់ មានការសហការគ្នានៃការស្រឡាញ់ដែលកើតចេញពីបទពិសោធន៍ជាច្រើននៃការស្រឡាញ់ដែលមានសេរីភាព ការលះបង់ និងការផ្តល់ជូនដោយមានអំណរ។ ទង្វើនៃការស្រឡាញ់មិនមែនជាការធ្វើឡើងដោយសុខចិត្តដែលមានចិត្តទើសទាល់នោះទេ ប៉ុន្តែជាអំណោយដែលផ្តល់ជូនដោយមានចិត្តសប្បាយវិញ។ យើងដើរតាមចៅហ្វាយដែលបានប្រាប់ឲ្យយើងដើរពីរយោជន៍បន្ថែម នៅពេលដែលមានគេបង្ខំឲ្យលីបន្ទុកដើរមួយយោជន៍ (ម៉ាថាយ ៥:៤១)។ មិនមាន «ការធ្វើដើម្បីសោយរាជ្យ» នៅទីនេះនោះទេ! ផ្ទុយទៅវិញ វាគឺជាការ៖ «មានអំណរក្នុងការបម្រើ»។ ឧទាហរណ៍៖ ជាទូទៅ ប្រពន្ធលាងចាននៅពេលយប់។ នៅយប់មួយបន្ទាប់ពីពេលញ៉ាំអាហារពេលល្ងាចហើយ គាត់បានជាប់និយាយទូរស័ព្ទជាមួយម្តាយរបស់គាត់យ៉ាងយូរ។ ប្តីរបស់គាត់បានលះបង់ការមិនមើលកម្មវិធីយ៉ាងល្អមួយនៅលើប៉ុស្តិ៍ទូរទស្សន៍ ហើយបែរជាបានទៅលាងចាន ខណៈពេលដែលប្រពន្ធកំពុងតែនិយាយទូរស័ព្ទជាមួយម្តាយគាត់—មិនមែនធ្វើឡើងដោយការទើសទាល់ចិត្តទេ ប៉ុន្តែដោយសប្បាយចិត្ត ដែលជាការបង្ហាញអំពីសេចក្តីស្រឡាញ់។ ឬក៏ថា កូនប្រុសម្នាក់បានមកដល់ផ្ទះ ហើយឃើញម្តាយគាត់កំពុងគេងនៅលើគ្រែដោយឈឺក្បាលផង។ អាហារពេលល្ងាចមិនទាន់បានធ្វើនៅឡើយ។ ភ្លាមៗនោះ កូនប្រុសក៏ចាប់ផ្តើមរៀបចំអាហារពេលល្ងាចទោះបើគាត់មិនចូលចិត្តធ្វើម្ហូបក៏ដោយ។

អាកប្បកិរិយា និងទង្វើបែបនោះក៏នឹងជះឥទ្ធិពល ដោយមានចំណុចសម្គាល់ លើបរិយាកាសនៅក្នុងផ្ទះជាមិនខាន។ មានការជះពន្លឺ និងអំណរនៅពេលដែលសមាជិកគ្រួសារដឹងថាគ្រប់គ្នាបានប្ដេជ្ញាចិត្តចំពោះសុភមង្គល និងអំណររបស់អ្នកដទៃ។ នៅពេលដែលមានសមាជិកគ្រួសារណាម្នាក់ ដែលជាទូទៅគាត់ចេះគិតពិចារណា មានការធ្វេសប្រហែស ហើយមិនបំពេញការងាររបស់គាត់ ការថ្លោះធ្លោយនោះមិនសូវជាបញ្ហាខ្លាំងប៉ុន្មានទេ។ អ្នកផ្សេងទៀតនៅក្នុងផ្ទះដឹងថា អ្នកដែលបានប្រព្រឹត្តខុសក៏នៅមានការប្ដេជ្ញាចិត្តចំពោះសុភមង្គលរបស់ពួកគាត់ ហើយការថ្លោះធ្លោយនោះមិនមែនជាលំនាំទូទៅនោះទេ។ ទាក់ទងនឹងប្រពន្ធ និងម្ដាយដែលមានសេចក្ដីស្រឡាញ់ កណ្ឌគម្ពីរសុភាសិតបានលើកឡើងថា «កូនរបស់នាងទាំងប៉ុន្មាន ក្រោកឈរឡើងគោរពដល់ម្ដាយ ថាជាអ្នកមានពរ ប្ដីក៏ក្រោកឈរឡើងសរសើរដល់នាងដែរ» (៣១:២៨)។ ក្នុងគ្រួសារដែលមានការផ្ដល់ឲ្យសេចក្ដីស្រឡាញ់ដោយសេរីក៏មានការដឹងគុណដែរ។

ខ្ញុំតែងតែព្យាយាមអានស្លាកបិទនៅពីក្រោយរម៉កកង់បី ឬក៏ Pass App ដែលជាយានយន្តធ្វើដំណើរទូទៅមួយនៅក្នុងប្រទេសស្រីលង្កា។ ស្លាកខ្លះទាក់ទងទៅនឹងសាសនា ដូចជា «សរសើរតម្កើងព្រះអម្ចាស់» ឬ «ផ្លូវរបស់ព្រះពុទ្ធ៖ ផ្លូវទៅកាន់សេរីភាព»។ ខ្លះជាសុភាសិត «អ្នកដែលមិនខំឡើងខ្ពស់ពេកក៏នឹងមិនធ្លាក់ទាបពេកផងដែរ» (មិនមែនជាអ្វីដែលខ្ញុំគាំទ្រនោះទេ)។ ប៉ុន្តែ ក្នុងការសិក្សារបស់ខ្ញុំដែលមិនទាក់ទងទៅនឹងវិទ្យាសាស្ត្រ ប្រធានបទដែលមានប្រជាប្រិយភាពខ្លាំងជាងគេដែលខ្ញុំបានឃើញគឺទាក់ទងទៅនឹងម្ដាយរបស់អ្នកបើកបរ។ ភាគច្រើនស្លាកទាំងនោះគឺជាប្រយោគកំប្លែងដែលបង្ហាញអំពីការដឹងគុណដល់អ្នកម្ដាយ។ អ្នកបើកបរដឹងថា គ្មាននរណាម្នាក់ខ្វល់ខ្វាយដល់គាត់ដោយសេចក្ដីស្រឡាញ់ និងមានការលះបង់ដូចជាម្ដាយគាត់នោះទេ។ ដូច្នេះ នៅពេលដែលពួកគាត់ចង់បង្ហាញអ្វីមួយដែលនឹងឲ្យតែមដល់លក្ខណៈនៃរថយន្តរបស់ពួកគាត់ នោះពួកគាត់នឹងជ្រើសរើសនិយាយអ្វី

ម៉្យាងអំពីម្ដាយរបស់ពួកគាត់។ យើងគួរប្រាថ្នាថាគួរមានអារម្មណ៍កក់ក្ដៅដូចនោះសម្រាប់សមាជិកទាំងអស់ក្នុងគ្រួសារ។

## វាជារឿងពិបាកណាស់ក្នុងការបង្ហាញសេចក្ដីស្រឡាញ់ដល់អស់អ្នកដែលមិនចេះស្កប់ចិត្ត

ប្រសិនបើសមាជិកម្នាក់តែងតែស្ម័គ្រចិត្តស្រឡាញ់ម្នាក់ទៀតដោយមានការលះបង់ ខណៈពេលដែលបុគ្គលម្នាក់ទៀតតែងតែព្យាយាមយកអ្វីដែលគាត់ចង់បានពីបុគ្គលដំបូង នោះគំរូនៃសេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទប្រឈមមុខនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរ។ នៅពេលដែលមនុស្សតែងតែចង់ទទួលបាននូវអ្វីដែលពួកគេចង់បាន នោះពួកគេទំនងជាអាចនឹងសប្បាយចិត្តមួយរយៈពេល ប៉ុន្តែមិនយូរមិនឆាប់ ពួកគេនឹងចង់បានថែមទៀត។ មនុស្សបែបនោះនឹងមិនចេះសប្បាយចិត្តទេ ហើយដៃគូជីវិតរបស់ពួកគេនឹងមានការពិបាកជាមួយនឹងការខកចិត្ត ក្នុងការព្យាយាមស្រឡាញ់ជាមិនខាន។

ពេលខ្លះ មនុស្សទាំងនេះមិនមានការសប្បាយចិត្ត ទាក់ទងនឹងអ្វីដែលមិនអាចផ្លាស់ប្ដូរបាន។ ប្ដីម្នាក់មិនអាចផ្លាស់ប្ដូរការងាររបស់គាត់ ដោយសារតែមានអ្វីមួយចំនួនអំពីការងារនោះដែលប្រពន្ធរបស់គាត់មិនចូលចិត្តនោះទេ។ ប្រពន្ធដែលកំពុងឈឺក៏មិនអាចធ្វើឲ្យខ្លួនបានជាប្រសើរឡើងវិញ ដើម្បីបំពេញចំណង់ចិត្តខាងផ្លូវភេទរបស់ប្ដីបាននោះដែរ។ គ្រួសារមួយក៏មិនអាចផ្លាស់ប្ដូរទីលំនៅទៅកាន់ផ្ទះដែលធំជាងមុន ហើយមានអ្នកជិតខាងដែល «ល្អប្រសើរ» ជាងមុនបាននោះទេ ប្រសិនបើពួកគេមិនមានចំណូលគ្រប់គ្រាន់ក្នុងការផ្លាស់ប្ដូរទេនោះ។

ការស្កប់ចិត្តគឺជាគន្លឹះមួយដែលត្រូវដើរទន្ទឹមគ្នាជាមួយនឹងការកោតខ្លាចព្រះ ហើយសាវ័ក ប៉ុល បានលើកឡើងថា ការដែលចំណុចទាំងពីររួមផ្សំគ្នាគឺជាប្រយោជន៍ដ៏ធំ (១ធីម៉ូថេ ៦:៦)។ ដោយសរសេរផ្ញើចេញពីគុកសាវ័ក ប៉ុល បានមានប្រសាសន៍ថា «ខ្ញុំនិយាយដូច្នេះ មិនមែនដោយខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំ

បានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង» (ភីលីព ៤:១១)។ លោក យ៉ូហាន-បាទីស្ទ បានប្រាប់ពួកទាហានដែលបានមករកគាត់ថា «ចូរស្កប់ចិត្តតែនឹងប្រាក់ខែរបស់អ្នករាល់គ្នាប៉ុណ្ណោះ» (លូកា ៣:១៤)។ កណ្ឌគម្ពីរ ហេព្រើរ ១៣:៥ បានផ្តល់ជូននូវចំណុចគន្លឹះនៃការស្កប់ចិត្តៈ «ចូរឲ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្ត បានឥតលោភឡើយ ឲ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ ដ្បិតទ្រង់មានបន្ទូលថា "អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ"»។ ដាច់ខាត យើងត្រូវតែដឹងឲ្យគ្រប់ពេលថា យើងក៏អាចស្រឡាញ់របស់នៃលោកីយ៍នេះខ្លាំងពេកបានដែរ។ នៅពេលដែលយើងលះបង់ចោលការស្រឡាញ់លុយកាក់ នោះមានន័យថា យើងបានចាប់ផ្តើមឈានក្នុងជំហានដ៏សំខាន់នៃវិថីនៃការមានជីវិតស្កប់ចិត្ត។ ប៉ុន្តែ ខគម្ពីរនេះលើកឡើងថា សេចក្តីពិតជាគន្លឹះគឺថាព្រះយេស៊ូវគង់នៅជាមួយយើង។ ព្រះអង្គធ្វើឲ្យបំណងប្រាថ្នាដ៏ជ្រាលជ្រៅរបស់យើងមានការស្កប់ចិត្ត។ ប្រសិនបើព្រះអង្គដកសេចក្តីប៉ងប្រាថ្នាចំពោះលោកីយ៍ចេញពីជីវិតយើង ហើយបំពេញឲ្យយើងមានចំណង់ចិត្តលើព្រះអង្គ នោះមានន័យថា យើងបានក្លាយជាមនុស្សដែលចេះស្កប់ចិត្តហើយ។ ដូច្នេះ ខបន្ទាប់ក៏បានលើកឡើងថា «យើងរាល់គ្នាអាចនឹងនិយាយ ដោយក្លាហានថា "ខ្ញុំមិនព្រមខ្លាចឡើយព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន"» (ហេព្រើរ ១៣:៦)។

ជាថ្មីម្តងទៀត ដោយសរសេរផ្ញើចេញពីគុកសាវ័ក ប៉ុល បានលើកឡើងអំពីរបៀបនៃការមានព្រះយេស៊ូវ ថាជាការចេះស្កប់ចិត្តខ្លាំងជាងការមានគ្រប់ទាំងកិត្តិយសទាំងអស់នៅផែនដីនេះ ដែលគាត់ត្រូវតែបោះបង់ចោលនៅពេលដែលគាត់បានក្លាយជាគ្រីស្ទបរិស័ទ។ បន្ទាប់ពីបានរាយចុះនូវកិត្តិយសទាំងនេះ ហើយ គាត់បានលើកឡើងថា «ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្តីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាតគ្រប់ទាំងអស់

ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឲ្យបានព្រះគ្រីស្ទវិញ» (ភីលីព ៣:៨)។

ជាការដ៏គួរឲ្យសោកស្តាយ ខ្ញុំធ្លាប់បានឃើញមនុស្សជាច្រើននាក់ ដែលមើលទៅហាក់បីដូចជាគ្រីស្ទបរិស័ទដែលមានការប្តេជ្ញាចិត្ត ដោយមានបំណងចិត្តចង់បម្រើព្រះជាម្ចាស់យ៉ាងខ្លាំង តែទោះជាយ៉ាងណាក៏ដោយក៏ពួកគាត់នៅតែជាមនុស្សដែលមិនមានការស្កប់ចិត្ត និងសប្បាយចិត្តដែរ។ ហើយជាលទ្ធផល ផ្ទះរបស់ពួកគាត់គឺជាកន្លែងដែលមិនមានសុភមង្គល។ តើលោកអ្នកជាមនុស្សដែលសប្បាយចិត្តដែរឬទេ? តើលោកអ្នកជាមនុស្សដែលសប្បាយចិត្តក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវដែរឬទេ? ឱបងប្អូនមិត្តអ្នកអានជាទីស្រឡាញ់អើយ! ព្រះយេស៊ូវគឺជាទីស្កប់ចិត្តដ៏លើសលប់ទៅទៀត! សូមរៀនពឹងផ្អែកលើព្រះអង្គដូចដែលកូនក្មេងម្នាក់ពឹងផ្អែកលើឪពុកម្តាយរបស់ខ្លួនចុះ។ ក្នុងទំនាក់ទំនងដែលមានសុវត្ថិភាពបែបនេះជាមួយព្រះគ្រីស្ទ នោះលោកអ្នកនឹងមានការស្កប់ចិត្តមិនខាន។

សូមកុំអនុញ្ញាតឲ្យបុគ្គលិកលក្ខណៈរបស់លោកអ្នកដកលោកអ្នកចេញពីការមានអំណរ ក្នុងការក្លាយជាគ្រីស្ទបរិស័ទដែលមានការស្កប់ចិត្តឡើយ។ សូមតយុទ្ធឲ្យបានសេចក្តីអំណររបស់ព្រះអម្ចាស់ចុះ!  សូមស្វែងរកការប្រឹក្សាឬក៏ជំនួយពីអស់អ្នកដែលលោកអ្នកគោរព និងទុកចិត្តក្នុងការជួយឲ្យលោកអ្នកឈានដល់កន្លែងដែលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដកចេញនូវស្រទាប់នៃការឈឺចាប់ ក្នុងជីវិតរបស់លោកអ្នក ដែលរារាំងលោកអ្នកមិនឲ្យមានអំណរ។ ព្រះយេស៊ូវប្រទានការស្កប់ចិត្ត។ តាមរយៈការស្កប់ចិត្តរបស់ទ្រង់នោះលោកអ្នកនឹងមានកម្លាំងក្នុងការប្រឈមមុខនឹងការលំបាកនៃទុរគតភាពដែលលោកអ្នកនឹងដកបទពិសោធន៍ជាមួយនៅឯផ្ទះ ហើយលោកអ្នកក៏នឹងមានសេរីភាពនៃការផ្តល់តម្លៃយ៉ាងខ្ពស់ ទាក់ទងនឹងសេចក្តីស្រឡាញ់ដែលដៃគូជីវិតលោកអ្នកបង្ហាញ។ ការនោះនឹងនាំមកនូវការបំពេញចិត្តដល់ដៃគូជីវិតរបស់លោកអ្នក ហើយធ្វើឲ្យពួកគាត់មានសេចក្តីអំណរយ៉ាងខ្លាំង ក្នុង

ការដែលពួកគាត់ស្រឡាញ់ ដោយមានការលះបង់ចិត្ត។

ផ្លូវទៅកាន់សេរីភាពនៃការស្អប់ចិត្តនេះអាចជាផ្លូវមួយដែលវែងឆ្ងាយ។ ទំនងជាអាចមានស្រទាប់នៃការឈឺចាប់ដែលត្រូវការបើកចំហ និងទទួលការព្យាបាលមុនពេលដែលលោកអ្នកអាចស្គាល់អំពីការស្អប់ចិត្ត និងអំណរដ៏ពិតប្រាកដ។ ប៉ុន្តែ ដំណើរមួយនេះមានតម្លៃក្នុងការឆ្លងកាត់ណាស់។ ជាមូលដ្ឋាន ដំណើរមួយនេះគឺជាការបើកចំហជីវិតរបស់យើង ដើម្បីឲ្យយើងអាចកាន់តែទទួលបានព្រះពរដែលព្រះជាម្ចាស់បានសន្យានៅក្នុងព្រះបន្ទូលរបស់ទ្រង់។ អរព្រះគុណព្រះអង្គដែលទ្រង់មានព្រះគុណគ្រប់គ្រាន់សម្រាប់ការនេះ។ ប៉ុន្តែ ដាច់ខាតយើងក៏ត្រូវតែព្យាយាមបើកចំហជីវិតរបស់យើងចំពោះព្រះគុណនេះ និងដកចេញនូវចំណុចដែលរាំងយើងមិនឲ្យទទួលបានព្រះគុណនោះ។ នេះគឺជាចំណុចរាំងមួយចំនួនដែលខ្ញុំបានឃើញ៖

- មិនបានអត់ទោសដល់អ្នកណាម្នាក់ដែលបានធ្វើឲ្យលោកអ្នកឈឺចាប់
- មិនព្រមទទួលស្គាល់ថា ព្រះជាម្ចាស់អាចបំផ្លាស់បំប្រែបទពិសោធន៍នៃការមិនល្អរបស់លោកអ្នកឲ្យទៅជាអ្វីមួយដែលល្អ ដើម្បីកុំឲ្យយើងនៅចាត់ទុកការនោះថាជា “បទពិសោធន៍មិនល្អ” ទៀតឡើយ
- បន្តអនុញ្ញាតឲ្យជីវិតរបស់លោកអ្នកនៅមានភាពស្រអាប់ឥតឈប់ឈរ តាមរយៈអ្វីដែលមិនល្អ ដែលអ្នកផ្សេងធ្លាប់ធ្វើដាក់លោកអ្នក
- មិនព្រមលះអាល័យខ្លួនឯងចោល ដល់ថ្នាក់ថាលោកអ្នកមិនព្រមបើកចំហជីវិតខ្លួនជាប្រចាំថ្ងៃ ក្នុងការបោះបង់ចោលនូវអ្វីដែលលោកអ្នកចង់បាន ឬក៏ធ្វើ
- មានការអាម៉ាស់មុខចំពោះអតីតកាល រូបរាងខាងក្រៅ និងប្រវត្តិគ្រួសាររបស់ខ្លួន ឬក៏ការខ្វះខាតក្នុងផ្នែកសិក្សាអប់រំ។ ជា

ទូទៅ អ្វីដែលមនុស្សយើងព្យាយាមលាក់បាំងតែងតែមានរបៀបមួយដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអារម្មណ៍ និងអាកប្បកិរិយារបស់ពួកគាត់។

- ការបដិសេធមិនព្រមទទួលយកបុគ្គលិកលក្ខណៈនៃដៃគូជីវិត ការបដិសេធមិនព្រមអត់ធ្មត់ក្នុងភាពកម្សោយ និងការមានអំណរក្នុងការជឿថា ព្រះជាម្ចាស់នឹងប្រទានឲ្យលោកអ្នកមានជីវិតដែលចុះសម្រុងគ្នា ទោះបីជាមានភាពកម្សោយទាំងនោះក៏ដោយ
- បដិសេធន៍មិនព្រមជឿថា ព្រះជាម្ចាស់ពិតជាសព្វព្រះហឫទ័យចង់ឲ្យលោកអ្នកទទួលបានការល្អបំផុត និងព្រមទាំងប្រទានការល្អបំផុតដល់លោកអ្នក ប្រសិនបើលោកអ្នកស្ដាប់បង្គាប់ព្រះអង្គ។

ដើម្បីឲ្យគ្រួសារមានសុភមង្គល លោកអ្នកត្រូវតែជាមនុស្សដែលសប្បាយចិត្ត រីករាយជាមួយនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់ខ្លួន និងមានការស្កប់ចិត្តនៅក្នុងសេចក្ដីពិតដែលថា ព្រះអង្គនឹងថែរក្សាលោកអ្នក ហើយប្រទានដល់លោកអ្នកនូវអ្វីៗគ្រប់យ៉ាងដែលលោកអ្នកត្រូវការសម្រាប់បំពេញជីវិតនេះ។ ហើយវិថីទៅកាន់អំណរនេះក៏កាន់តែមានភាពងាយស្រួលតាមរយៈដៃគូជីវិត ដែលបន្តស្រឡាញ់ភាគីម្ខាងទៀត ដោយមិនអាស្រ័យលើអារម្មណ៍មិនល្អរបស់គាត់ ឬក៏ការមិនស្កប់ចិត្តរបស់គាត់ឡើយ។ ការបង្ហាញសេចក្ដីស្រឡាញ់ក្នុងរបៀបផ្សេងៗគ្នា ពីដៃគូជីវិតដែលពេញដោយសេចក្ដីស្រឡាញ់ នឹងជួយដកចេញនូវស្រទាប់នៃការឈឺចាប់ ដែលភាគីម្ខាងទៀតបានឆ្លងកាត់។ ការទទួលសេចក្ដីស្រឡាញ់បែបនោះនឹងជួយឲ្យបុគ្គលនោះបើកចំហចិត្តទទួលសេចក្ដីស្រឡាញ់ដែលបរិបូណ៌ និងការទទួលស្គាល់ព្រះជាម្ចាស់ប្រទានឲ្យ។ ប្រសិនបើជីវិតរបស់លោកអ្នកមានស្នាមជាំឈឺចាប់ និងមិនទទួលបានការឆ្លើយតបពីដៃគូជីវិត សូមកុំឈប់ស្រឡាញ់គាត់!

## អាហ្គាពេ (Agape)៖ ការស្រឡាញ់ដោយសម្រេចចិត្ត

នៅក្នុងជំពូកបន្ទាប់ ខ្ញុំនឹងបង្ហាញពីរបៀបដែលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដាក់សម្ពាធលើយើង ដោយជំរុញឲ្យយើងឆ្លើយតបដោយមានសេចក្តីស្រឡាញ់គ្រប់ពេលវេលា។ ប៉ុន្តែ ទោះបើយើងអាចប្រើប្រាស់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក៏ដោយ ក៏យើងនៅមិនចង់ដើរតាមផ្លូវនៃសេចក្តីស្រឡាញ់ដែរ។ នៅពេលដែលកូនប្រុសណាម្នាក់មកដល់ផ្ទះពីសាលា គាត់ស្រែកថា "ម៉ាក់! ម៉ាក់!"។ ម្តាយរបស់គាត់កំពុងមានតែមានភាពតានតឹង ពីព្រោះគាត់មានការជាប់រវល់យ៉ាងខ្លាំង ក្នុងការរៀបចំអាហារពេលល្ងាចសម្រាប់ភ្ញៀវដែលមកលេងនៅថ្ងៃនោះ។ ការឆ្លើយតបដោយអចេតនារបស់គាត់ទៅកាន់កូនប្រុសរបស់គាត់គឺ ការឆ្លើយតបដោយភ្លាមៗដោយក្តីមួហ្មងថា៖ "ស្អីគេ?"។ ប៉ុន្តែសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងគាត់ក៏បានជំរុញឲ្យគាត់ឆ្លើយតបក្នុងរបៀបមួយផ្សេងទៀត។ គាត់ឆ្លើយតបដោយមានការដាស់តឿនពីសេចក្តីស្រឡាញ់របស់ព្រះ ចេះគ្រប់គ្រងអារម្មណ៍ខ្លួនឯង ហើយនិយាយយ៉ាងសុភាពថា "មានការអ្វីកូនសម្លាញ់?"។ កូនប្រុសក៏បានប្រាប់ម្តាយដោយក្តីរីករាយថា "គ្រូបង្វឹកបានជ្រើសរើសកូនឲ្យចូលក្នុងក្រុមកីឡាហើយ!"។ ដោយឮដំណឹងនោះ អ្នកម្តាយក៏បានស្រែកហ៊ោដោយមានអំណរជាមួយនឹងកូនប្រុសរបស់គាត់។ ចុះប្រសិនបើគាត់ធ្វើតាមទំនោរចិត្តធម្មជាតិក្នុងការឆ្លើយតប ដោយមិនអើពើលើការដាស់តឿនពីសេចក្តីស្រឡាញ់នោះ? បើបែបនោះមែន នោះគាត់នឹងធ្វើឲ្យកូនប្រុសរបស់គាត់ឈឺចាប់យ៉ាងខ្លាំង ហើយក៏បាត់បង់ឱកាសក្នុងការមានអំណរក្នុងគ្រួសារផងដែរ។

ការស្តាប់បង្គាប់គឺជាកូនសោ ដើម្បីបើកទ្វារជោរជន់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ដូចដែលយើងបានលើកឡើង នៅក្នុងព្រះជាម្ចាស់មិនមានការខ្វះខាតនៃសេចក្តីស្រឡាញ់នោះទេ ប៉ុន្តែយើងអាចរារាំងលំហូរនៃសេចក្តីស្រឡាញ់របស់ទ្រង់ ដោយការមិនស្តាប់បង្គាប់។ សេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទគឺជាការស្រឡាញ់ដោយសម្រេចចិត្ត។ វាមិនកើតឡើងតែ

ឯកឯងនោះទេ ដែលនេះគឺជាអ្វីដែលកើតឡើងនៅពេលដែលយើងស្រឡាញ់នរណាម្នាក់ដែលយើងចាប់អារម្មណ៍។ យើងធ្វើឲ្យវាកើតឡើងតាមរយៈការស្តាប់បង្គាប់។ វាមិនមែនជារឿងធម្មជាតិទេក្នុងការដែលយើងស្រឡាញ់ខ្មាំងសត្រូវរបស់យើង ប៉ុន្តែយើងសម្រេចចិត្តស្រឡាញ់ពួកគេ។ ការសម្រេចចិត្តរបស់យើងក្នុងការស្តាប់បង្គាប់ធ្វើឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គមានសកម្មភាពឡើង ហើយយើងរកបានកម្លាំងក្នុងការធ្វើបែបនោះ។

នេះគឺជាសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានសម្រាប់យើង។ សាវ័ក ប៉ុល បានលើកឡើងថា «តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា» (រ៉ូម ៥:៨)។ ការនេះនាំយើងចូលទៅកាន់ចំណុចស្នូលនៃការយល់ដឹងអំពីសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ។ វាគឺជាការសម្រេចចិត្តដែលយើងធ្វើឡើងក្នុងការស្រឡាញ់ សូម្បីតែនៅពេលដែលយើងមិនមានទំនោរបែបធម្មជាតិក្នុងការធ្វើដូចនោះក៏ដោយ ហើយនៅពេលដែលអ្នកដែលទទួលសេចក្តីស្រឡាញ់នោះហាក់បីដូចជាមិនស័ក្តិសមក្នុងការទទួលបានសេចក្តីស្រឡាញ់របស់យើងដែរ។ នៅពេលដែលគ្រីស្ទបរិស័ទសម័យដំបូងស្វែងរកពាក្យក្នុងការពណ៌នាអំពីសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ ពួកគាត់ជ្រើសរើសពាក្យ អាហ្គាពេ (Agape) ជាជាងពាក្យផ្សេងៗទៀត ដែលសាមញ្ញជាងនោះដែលមានការប្រើប្រាស់នៅសម័យនោះ ដែលមានដូចជា ហ្វេលលីអា (Philia)។ វាហាក់បីដូចជាថាពួកគេចង់ញែកញែកសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទចេញពីការយល់ដឹងទូទៅលើសេចក្តីស្រឡាញ់។

តោះ! ចូរយើងមើលឧទាហរណ៍មួយចំនួនអំពីរបៀបដែលពាក្យ អាហ្គាពេ មានដំណើរការនៅក្នុងគ្រួសារ។

- សាវ័ក ប៉ុល បានមានប្រសាសន៍ថា សេចក្តីស្រឡាញ់ «មិនដែលប្រព្រឹត្តបែបមិនគួរសម» (១កូរិនថូស ១៣:៥)។ ប៉ុន្តែ ជារឿយៗ ការសន្ទនានៅក្នុងគ្រួសារមិនសូវជាការគួរសមនោះទេ។

នៅក្នុងគ្រួសារ វាហាក់បីដូចជាកន្លែងមួយដែលពិបាកក្នុងការអនុវត្តភាពគួរសមណាស់។ គេរំពឹងថាឲ្យយើងត្រូវមានភាពគួរសមនៅកន្លែងការងារ និងនៅក្នុងក្រុមជំនុំរបស់យើង។ ដូច្នេះយើងក៏មានភាពគួរសម ទោះបើជាយើងមានអារម្មណ៍ថា យើងចូលចិត្ត ឬក៏មិនចូលចិត្តក៏ដោយ។ ប៉ុន្តែ យើងមិនចាំបាច់ត្រូវធ្វើពុតដូចនោះនៅផ្ទះទេ ដូច្នេះកូនៗក៏មានទំនោរបែបធម្មជាតិក្នុងការមិនមានភាពគួរសម នៅពេលដែលនិយាយទៅកាន់ឪពុកម្ដាយរបស់ខ្លួន ហើយឪពុកម្ដាយក៏ធ្វើបែបនេះនៅពេលនិយាយគ្នានៅផ្ទះដែរ។ ខ្ញុំធ្លាប់បានអានសាច់រឿងអំពីប្រពន្ធរបស់គ្រូគង្វាលម្នាក់ ដែលបានប្រាប់ប្ដីរបស់គាត់ថា៖ «តោះ! ថ្ងៃនេះ ចូរយើងផ្លាស់ប្ដូរទម្លាប់។ ហេតុអ្វីបានជាបងមិនប្រព្រឹត្តនៅផ្ទះដូចដែលបងប្រព្រឹត្តនៅឯក្រុមជំនុំនៅថ្ងៃនេះដែរ។ ហេតុអ្វីបានជាបងមិនប្រព្រឹត្តនៅផ្ទះដូចដែលបងប្រព្រឹត្តនៅក្នុងក្រុមជំនុំ ហើយប្រព្រឹត្តិនៅឯក្រុមជំនុំដូចដែលបងប្រព្រឹត្តិនៅឯផ្ទះ?»។ មានគ្រួសារជាច្រើនដែលត្រូវការដំបូន្មានដ៏ល្អរបស់សាវ័ក ប៉ុល៖ «ចូរឲ្យពាក្យសម្ដីរបស់អ្នករាល់គ្នាបានប្រកបដោយព្រះគុណជានិច្ច» (កូឡូស ៤:៦)។ ទោះបើជាធម្មតា យើងប្រហែលជាមិនចូលចិត្តនិយាយគួរសម និងដោយមានការគោរពនៅផ្ទះក៏ដោយ ក៏យើងនៅអាចសម្រេចចិត្តធ្វើបែបនោះដោយស្ដាប់បង្គាប់ព្រះជាម្ចាស់បានដែរ។ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នឹងប្រទានកម្លាំងឲ្យយើងអាចធ្វើការនោះ។

• មានបុគ្គលម្នាក់គិតច្រើនពេកពីបញ្ហានៅកន្លែងការងាររបស់គាត់។ គាត់គិតអំពីវាគ្រប់ពេលវេលា។ មានថ្ងៃមួយនៅផ្ទះ ខណៈពេលដែលគាត់កំពុងគិតអំពីបញ្ហានេះ ហើយក៏កំពុងឆ្លើយសារជាច្រើន គាត់ក៏ប្រញាប់ទៅផ្ទះបាយ ដើម្បីយកទឹកមួយកែវ ហើយក៏បានដើរកាត់ប្រពន្ធរបស់គាត់ ដែលកំពុងអង្គុយនៅឯតុបាយ

នោះ។ មានអ្វីមួយបានដាស់តឿនគាត់ឲ្យឈប់ ហើយឱបប្រពន្ធរបស់គាត់មួយសិន។ ការធ្វើបែបនេះគឺជាការបង្វែរអារម្មណ៍ចេញពីអ្វីដែលគាត់កំពុងតែផ្តោតលើ។ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់បានស្តាប់សម្លេងនៃសេចក្តីស្រឡាញ់ ហើយសម្រេចចិត្តចំណាយពេលមួយទៅពីរនាទីនៅជាមួយប្រពន្ធរបស់គាត់សិនដែរ។

- មានបុរសម្នាក់នៅឯការិយាល័យមួយចាប់ផ្តើមជជែកគ្នាលេងជាមួយស្ត្រីម្នាក់ ដែលបានរៀបការរួចហើយដែលគាត់ជាគ្រីស្ទបរិស័ទ ហើយការជជែកគ្នានោះក៏បានក្លាយជាការចែចង់គ្នា។ ដំបូង គាត់ពេញចិត្តនឹងការយកចិត្តទុកដាក់ដែលបុរសនេះផ្តល់ឲ្យគាត់ណាស់។ ប៉ុន្តែ បន្ទាប់មក សេចក្តីស្រឡាញ់បានប្រាប់គាត់ថា ការពេញចិត្តបែបនេះគឺអាចមានតែជាមួយប្តីរបស់គាត់តែម្នាក់ប៉ុណ្ណោះ ហើយគាត់ក៏បដិសេធទំនោរធម្មជាតិរបស់គាត់ក្នុងការលើកទឹកចិត្តឲ្យមានការសន្ទនាបែបនោះ។ ផ្ទុយទៅវិញ គាត់ក៏បានបង្ហាញដោយសមរម្យថា គាត់មិនមានចំណាប់អារម្មណ៍ក្នុងការបន្តសន្ទនាបែបនេះទៀតទេ។ គាត់បានប្តេជ្ញាចិត្តថា គាត់នឹងស្វែងរកការស្កប់ចិត្តបែបនេះតែជាមួយនឹងប្តីរបស់គាត់តែប៉ុណ្ណោះ។
- មានប្តីម្នាក់ ដែលឲ្យតម្លៃលើជំនាញ និងភាពរហ័សរហួន ហើយគាត់បានរៀបការជាមួយនឹងស្ត្រីម្នាក់កោតខ្លាចព្រះ ប៉ុន្តែធ្វើការយឺតយ៉ាវ។ ជាញឹកញាប់ គាត់ក៏ច្រឡោតចិត្ត ព្រោះមិនចេះអត់ធ្មត់។ ប៉ុន្តែ សេចក្តីស្រឡាញ់បានធ្វើឲ្យគាត់សម្រេចចិត្តថា គាត់ត្រូវតែកាត់ពាក្យដែលគាត់ហៀបនឹងនិយាយចេញមកពីមាត់របស់គាត់ចោល។ ផ្ទុយទៅវិញ ប្តីក៏បានផ្តោតលើចំណុចល្អៗជាច្រើនរបស់គាត់ ហើយក៏បាន «រាប់អាន [គាត់] ឲ្យលើសជាងខ្លួន [ខ្ញុំ] ដោយចិត្តសុភាពវិញ» (ភីលីព ២:៣)។ គាត់បានសម្រេចចិត្ត

ប្ដូរការមើលងាយ ទាក់ទងនឹងភាពទន់ខ្សោយរបស់ប្រពន្ធគាត់ជាមួយនឹងការគោរពលើចំណុចល្អៗវិញ។

- ខ្ញុំតែងតែមានបញ្ហាជាមួយភាពភ្លេចភ្លាំង និងការមិនចេះប្រុងប្រយ័ត្នរបស់ខ្ញុំ។ បញ្ហាមួយនេះក៏ចាប់ផ្ដើមកាន់តែធ្ងន់ធ្ងរទៅៗ នៅពេលដែលខ្ញុំកាន់តែចាស់ទៅៗ។ ខ្ញុំចំណាយពេលជាច្រើនក្នុងការស្វែងរកកូនសោ វ៉ែនតា ទូរស័ព្ទ និងកូនសៀវភៅកត់ចំណាំរបស់ខ្ញុំជាដើម។ ខ្ញុំតែងតែភ្លេចយកទូរស័ព្ទរបស់ខ្ញុំទៅជាមួយ នៅពេលដែលខ្ញុំទៅក្រៅ។ ខ្ញុំតែងតែត្រឡប់មកផ្ទះវិញដោយភ្លេចទិញអ្វីដែលខ្ញុំបានសន្យានឹងប្រពន្ធខ្ញុំថាខ្ញុំនឹងទិញឲ្យគាត់។ នេះគឺជារឿងដែលពិបាកសម្រាប់ប្រពន្ធខ្ញុំ។ ជាទូទៅ គាត់ក៏មានចំណែកជាមួយខ្ញុំក្នុងការខំស្វែងរកអ្វីដែលខ្ញុំកំពុងតែព្យាយាមរក មុនចេញទៅក្រៅ។ ខ្ញុំធ្លាប់ប្រាប់គាត់ថា ប្រសិនបើយើងចង់ នោះយើងអាចច្នៃផ្ទះយើងឲ្យក្លាយជាកន្លែងធ្វើសង្គ្រាមក៏បាន រាល់ពេលណាដែលយើងមានការឆ្លើយតបខ្លាំងៗពេលប៉ះទង្គិចគ្នា។ ប៉ុន្តែ ព្រះគម្ពីរបានចែងថា «ឯសេចក្ដីស្រឡាញ់តែងតែអត់ធ្មត់» (១កូរិនថូស ១៣:៤)។ ដូច្នេះ យើងក៏បានសម្រេចចិត្តថានឹងមិនបង្ហាញការមិនចេះអត់ធ្មត់ ដែលមានក្នុងយើង។ មានចំណុចជាច្រើនដែលយើងអាចនឹងមានអំណរជាមួយនឹងគ្នាបាន ដែលនាំឲ្យយើងមិនគួរទើសចិត្តគ្នាលើចំណុចទន់ខ្សោយរបស់យើងរៀងៗខ្លួនឡើយ។

វាពិតជាងាយស្រួលណាស់ក្នុងការដែលដៃគូជីវិតឲ្យតម្លៃគ្នាទៅវិញទៅមកក្នុងដំណើរការ ហើយមើលរំលងការបង្ហាញសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ លោក អេជ. ណូរម៉ែន រ៉ិច (H. Norman Wright) ផ្ដល់ការប្រឹក្សាដល់ដៃគូជីវិតថា «សូមចំណាយពេលបួននាទីដំបូងជាមួយគ្នា (ព្រឹក ល្ងាច។ល។) ទុកជាពេលវេលាល្អសម្រាប់ស្គាល់គ្នា និងបញ្ជាក់អះអាងអំពីការពេញចិត្តគ្នាជាប្រចាំថ្ងៃ»។[២] ទោះបើខ្ញុំមិនគ្រាប់តាមដំបូន្មានមួយនេះយ៉ាងពិតប្រាកដក៏ដោយ ក៏ខ្ញុំបានឃើញថាគោលការណ៍ក៏អាចជួយខ្លាំង

មែនទែនដែរ។ យើងត្រូវតែយកពេលឈប់ ដើម្បីប្រាប់ដៃគូជីវិតយើង ក្នុងរបៀបណាមួយដែលបង្ហាញថា គាត់គឺជាមនុស្សដ៏សំខាន់បំផុតនៅក្នុងជីវិតរស់នៅរបស់យើង។ មានការឱបប្ដី ឬប្រពន្ធនៅពេលដែលយើងជួបគ្នានៅពេលព្រឹក ការសួរនាំអំពីការដែលគាត់គេងពីយប់មិញ ឬក៏អំពីការងារនៅឯការិយាល័យនៅថ្ងៃនេះ ការទូរស័ព្ទរកគាត់សួរនាំអំពីសុខទុក្ខគាត់ក្នុងអំឡុងពេលដែលយើងកំពុងតែរវល់៖ ទាំងនេះគឺជារបៀបនៃការបញ្ជាក់អំពីសេចក្ដីស្រឡាញ់។

នៅពេលដែលខ្ញុំធ្វើដំណើរទៅឆ្ងាយ ខ្ញុំតែងតែផ្ញើសារទៅកាន់ប្រពន្ធរបស់ខ្ញុំពីរបីដង ក៏ដូចជាផ្ញើសារតាមបណ្ដាញសង្គមរាល់ថ្ងៃដែរ ដើម្បីឲ្យគាត់ដឹងថាខ្ញុំកំពុងធ្វើអ្វី ហើយថា ខ្ញុំក៏កំពុងតែគិតអំពីគាត់ដែរ។ មានមនុស្សមួយចំនួននិយាយថា «ខ្ញុំមិនចាំបាច់ធ្វើដូចនេះទេ ពីព្រោះគាត់ដឹងហើយថា ខ្ញុំកំពុងគិតអំពីគាត់រួចហើយ»។ ទោះបើថាការនោះជាការពិតមែន ការបង្អង់ជាញឹកញាប់ដើម្បីបញ្ជាក់អំពីសេចក្ដីស្រឡាញ់នឹងជួយឲ្យសេចក្ដីស្រឡាញ់នៅថ្មី និងមានភាពអរសប្បាយ។ គឺជាទិដ្ឋភាពនៃគោលការណ៍នៃអាហ្គាពេ ទាក់ទងនឹងការសម្រេចចិត្តបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់ដៃគូជីវិតរបស់យើង។

មុនបញ្ចប់ជំពូកមួយនេះ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវចំណុចពិបាកមួយអំពីសេចក្ដីស្រឡាញ់អាហ្គាពេ ដែលយើងអាចពណ៌នាថាជាគោលដៅក្នុងវាផ្ទាល់ ជាជាងជាយានយន្តទៅកាន់គោលដៅ។ វាជាការត្រាស់ហៅឲ្យមើលថែឪពុកម្ដាយចាស់ជរា និងសមាជិកក្នុងគ្រួសារ។ អ្នកខ្លះនឹងមិនអាចឆ្លើយតបមកកាន់សេចក្ដីស្រឡាញ់របស់យើង ពីព្រោះពួកគាត់មានការភ្លេចភ្លាំង ឬក៏ពិការភាពខាងឯរូបកាយ។ អ្នកខ្លះ ដែលមានដូចជាជំងឺបាត់ការចងចាំ មានលក្ខណៈខុសគ្នាឆ្ងាយណាស់ពីអស់អ្នកដែលយើងស្គាល់ ពីព្រោះអាកប្បកិរិយា និងលក្ខណសម្បត្តិរបស់ពួកគាត់មានការផ្លាស់ប្រែទាំងស្រុង។ ការជួយពួកគាត់ហាក់បីដូចជាមិនមានប្រសិទ្ធភាពទាល់តែសោះ។ ដូច្នេះ យើងស្រឡាញ់ពួកគាត់ដោយមិនរំពឹងថានឹងទទួលបានឆ្លើយតបបែបវិជ្ជមានពីពួកគាត់។ យើងធ្វើដូច្នោះ ពីព្រោះនេះគឺជាអ្វីដែលកូនៗធ្វើសម្រាប់ឪពុកម្ដាយ

ដែលមានវ័យចាស់ជរារបស់ខ្លួន។ ទំនងនេះប្រហែលមកពីមានគ្រីស្ទបរិស័ទមានការល្បួងក្នុងការមើលរំលងតួនាទីនេះហើយបានជាសាវ័ក ប៉ុល ប្រើប្រាស់ភាសាខ្លាំងៗក្នុងកន្លែងដែលគាត់លើកឡើងអំពីការមើលថែស្ត្រីមេម៉ាយ។ គាត់បានមានប្រសាសន៍ថា «បើមានអ្នកណា ដែលមិនផ្គត់ផ្គង់ឲ្យពួកញាតិសន្តានខ្លួន គឺឲ្យពួកអ្នកផ្ទះខ្លួនជាដើម អ្នកនោះឈ្មោះថាបានបោះបង់ចោលសេចក្តីជំនឿហើយ ក៏អាក្រក់ជាងមនុស្សដែលមិនបានជឿទៅទៀត» (១ធីម៉ូថេ ៥:៨)។

## ការសន្និដ្ឋាន

ការស្រឡាញ់សមាជិកនៅក្នុងក្រុមគ្រួសាររបស់យើងនឹងនៅតែបន្តមានការពិបាក។ នៅមានចំណុចជាច្រើនដែលយើងត្រូវបន្តរៀនក្នុងការស្រឡាញ់អ្នកដទៃ ហើយយើងក៏នឹងនៅតែបន្តរៀនទៀត ខណៈពេលដែលយើងរស់នៅលើផែនដីនេះ។ ដូច្នេះ យើងក៏នឹងប្រើប្រាស់ជំពូកបន្ទាប់នេះ ដើម្បីមើលនូវចំណុចលម្អិតមួយចំនួនទៀតអំពីអត្ថន័យនៃការស្រឡាញ់គ្រួសាររបស់យើង។

# ៤

# ផែនការដ៏ល្អរបស់ព្រះជាម្ចាស់

នៅក្នុងជំពូកមុន យើងបានបញ្ចប់ដោយបានអះអាងថា ខណៈពេលដែលយើងរស់នៅ នោះយើងនឹងបន្តរៀនស្រឡាញ់គ្រួសាររបស់យើងក្នុងនាមជាគ្រីស្ទបរិស័ទ។ ជាការប្រពៃណាស់ ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវការណែនាំជាច្រើនអំពីការនេះ។ នៅក្នុងជំពូកនេះ យើងនឹងមើលជាមួយគ្នាអំពីការណែនាំទាំងនោះ។

## ផែនការរបស់ព្រះជាម្ចាស់មានភាពស៊ីគ្នា ជាមួយនឹងលក្ខណៈរបស់មនុស្ស

យើងអាចសង្ខេបគន្លឹះនៃការបង្រៀននៅក្នុងព្រះគម្ពីរអំពីតួនាទីរបស់ប្តី និងប្រពន្ធបានដូចនេះថាៈ  ប្តីត្រូវតែស្រឡាញ់ប្រពន្ធរបស់ខ្លួនដោយមានការលះបង់ ហើយប្រពន្ធគួរតែចុះចូលដោយមានការគោរពចំពោះប្តីរបស់ខ្លួនដែរ។

### *ប្តីស្រឡាញ់ប្រពន្ធខ្លួន*

កណ្ឌគម្ពីរ អេភេសូរ ៥:២៥ បានចែងថា “បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះ

អង្គទ្រង់ជំនួសផង» ខ២៨ មានចែងថា «ត្រូវឲ្យប្ដីស្រឡាញ់ប្រពន្ធបែបយ៉ាងនោះឯង គឺដូចជាស្រឡាញ់រូបកាយរបស់ខ្លួនដែរ អ្នកណាដែលស្រឡាញ់ប្រពន្ធខ្លួន នោះក៏ឈ្មោះថាស្រឡាញ់ដល់ខ្លួនឯងហើយ»។ ខដំបូងបានផ្ដល់ជាយោបល់ដែលថា ប្ដីទាំងអស់គួរហ៊ានប្ដូរជីវិតជំនួសប្រពន្ធរបស់ខ្លួន។ នៅពេលដែលប្រពន្ធឮបែបនោះ នោះគាត់ទំនងជាអាចនិយាយដូចនេះថា៖ «សូមកុំឲ្យប្ដីរបស់ខ្ញុំប្ដូរជីវិតជំនួសខ្ញុំអី។ អ្វីដែលខ្ញុំចង់បានគឺសាមញ្ញជាងនេះខ្លាំងណាស់។ គឺគ្រាន់តែសូមឲ្យគាត់និយាយលេងជាមួយខ្ញុំនៅពេលដែលគាត់ត្រឡប់មកពីធ្វើការវិញ បន្ទាប់ពីខ្ញុំបានអត់ធ្មត់ពេញមួយថ្ងៃជាមួយកូនៗដ៏សែនខូចរបស់ខ្ញុំ!»។ តាមពិតទៅ វាទំនងអាចជារបៀបនៃការស្លាប់មួយរបស់ប្ដីក្នុងការដែលគាត់និយាយលេងជាមួយនឹងប្រពន្ធគាត់នៅពេលនោះ! ប្រសិនបើគាត់មានភាពតានតឹង ដោយសាររវល់ខ្លាំងនៅកន្លែងធ្វើការ នោះគាត់ទំនងជាមិនមានទំនោរក្នុងការសន្ទនាជាមួយនឹងប្រពន្ធគាត់ក្នុងមួយរំពេចដែលគាត់ទើបតែបានមកដល់ផ្ទះ។ ផ្ទុយទៅវិញ គាត់ទំនងជាចង់សម្រាកនៅលើគ្រែ ឬក៏មើលទូរទស្សន៍ខ្លះសិន។ សេចក្ដីស្រឡាញ់ធ្វើឲ្យគាត់សម្លាប់សេចក្ដីប្រាថ្នានោះចោល ហើយនិយាយលេងវិញ។

កណ្ឌគម្ពីរកូឡូសណែនាំនូវគោលគំនិតនៃការមានចិត្តជិនឆ្អន់។ សាវ័កប៉ុល បានលើកឡើងថា «ពួកប្រុសៗអើយ ចូរស្រឡាញ់ប្រពន្ធចុះ កុំឲ្យមានចិត្តជិនឆ្អន់ឡើយ» (កូឡូស ៣:១៩)។ ដោយផ្ដល់មតិយោបល់លើខគម្ពីរនេះលោក វ៉ារិន វាស្ប៊ី (Warren Wiersbe) បានលើកឡើងថា៖ « ភាពជាមេមិនមែនជាការប្រើអំណាចផ្ដាច់ការ ឬក៏ជាចៅហ្វាយនោះទេ។ ប៉ុន្ដែ ជាការដឹកនាំដែលពេញដោយសេចក្ដីស្រឡាញ់។»[១] ផ្ទុយពីការមានចិត្តជិនឆ្អន់—គឺការឲ្យតម្លៃ—យើងក៏ឃើញនៅក្នុងដំបូន្មានរបស់សាវ័ក ពេត្រុស៖ «រីឯប្ដីរាល់គ្នាក៏ដូច្នោះដែរ ត្រូវរស់នៅជាមួយប្រពន្ធរបស់ខ្លួនដោយយល់ថាមនុស្សស្រីជាភាជនៈដែលខ្សោយជាង ហើយចូរផ្ដល់កិត្តិយសដល់នាងទុកជាអ្នករួមទទួលមរតកព្រះគុណនៃជីវិត ដើម្បីកុំឲ្យមានអ្វីមកបង្អាក់សេចក្ដីអធិស្ឋានរបស់អ្នក

រាល់គ្នាឡើយ» (១ពេត្រុស ៣:៧ គគខ)។ គ្មានកន្លែងណានៅក្នុងព្រះគម្ពីរដែលមានចែងថា ប្តីគួរតែបង្ខំឲ្យប្រពន្ធចុះចូលខ្លួននោះទេ។ ការចុះចូលគឺជាអ្វីមួយដែលប្រពន្ធសប្បាយចិត្តក្នុងការឲ្យដល់ប្តីដែលស្រឡាញ់ និងប្រព្រឹត្តចំពោះពួកគាត់ដោយការគោរព។ នៅពេលដែលភាពអាត្មានិយម និងការមានចិត្តជិនឆ្អន់ចូលមក នោះទំនាក់ទំនងក៏បានក្លាយទៅជាការរំលោភបំពាន។ ជារឿងដ៏គួរឲ្យក្រៀមក្រំណាស់ ដែលការនេះបានកើតឡើងជាច្រើនដងពេករហូតបណ្តាលឲ្យមនុស្សយើងមានការបះបោរទាស់ប្រឆាំងនឹងគំនិតទាំងមូលនៃការដែលមនុស្សស្រីគួរចុះចូល។ នេះមិនមែនជាចម្លើយនោះទេ! ចម្លើយដែលស្របតាមព្រះគម្ពីរគឺត្រូវឲ្យប្តីស្រឡាញ់ប្រពន្ធរបស់ខ្លួន ហើយប្រព្រឹត្តចំពោះពួកគាត់ដោយមានកិត្តិយស។ សាវ័ក ពេត្រុស បានប្រាប់ទៅកាន់ប្តីទាំងឡាយថាប្រសិនបើពួកគេធ្វើដូចនេះ នោះ «សេចក្តីអធិស្ឋាន» របស់យើង «[នឹង] មិនត្រូវបានរារាំងនោះទេ»  ព្រះជាម្ចាស់នឹងមិនឆ្លើយតបសេចក្តីអធិស្ឋានរបស់អស់អ្នកដែលមិនស្រឡាញ់ និងផ្តល់កិត្តិយសដល់ប្រពន្ធរបស់ខ្លួននោះឡើយ!

ការស្រឡាញ់ដែលផ្តល់កិត្តិយសគឺជារបៀបដែលប្តីនាំឲ្យមានភាពពេញលេញដល់ប្រពន្ធរបស់ខ្លួន។ មនុស្សស្រីទទួលបានភាពពេញលេញតាមរយៈការទទួលសេចក្តីស្រឡាញ់។ នោះគឺជារបៀបដែលព្រះជាម្ចាស់បានបង្កើតពួកគាត់មក។ ខ្ញុំបានសួរប្រពន្ធបុគ្គលិករបស់យើងមួយចំនួនដែលធ្វើការជាមួយអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ (Youth for Christ) អំពីរបៀបដែលពួកគាត់ចង់ឲ្យប្តីរបស់ខ្លួនបង្ហាញសេចក្តីស្រឡាញ់ដល់ពួកគាត់។ នេះគឺជាចម្លើយមួយចំនួនដែលខ្ញុំទទួលបាន។ ពួកគាត់បាននិយាយថា «ខ្ញុំចង់ឲ្យគាត់៖

- ជឿលើខ្ញុំ»។
- និយាយល្អពីខ្ញុំ ហើយមិននិយាយពីភាពកម្សោយរបស់ខ្ញុំនៅមុខអ្នកដទៃ ជាពិសេសនៅមុខគ្រួសាររបស់គាត់»។
- ចង្អុលបង្ហាញពីចំណុចអវិជ្ជមានរបស់ខ្ញុំដោយសេចក្តីស្រឡាញ់ ដោយមិនមានការស្រែកគំហកដាក់ខ្ញុំ»។

- និយាយជាមួយខ្ញុំដោយសុភាពនៅពេលដែលគាត់អន់ចិត្តនឹងខ្ញុំ»។
- ឲ្យតម្លៃ ហើយសរសើរអ្វីដែលខ្ញុំធ្វើ»។
- ជួយការងារផ្ទះ ជាពិសេសជួយមើលកូនៗ ការគ្រាន់តែនិយាយមិនគ្រប់គ្រាន់នោះទេ»។
- ស្ម័គ្រចិត្តជួយកិច្ចការកំប៉ិកកំប៉ុករបស់ខ្ញុំ»។
- ឈប់សម្រាកនៅថ្ងៃឈប់ប្រចាំសប្តាហ៍របស់គាត់ដោយមិនមានការខកខាន ហើយធ្វើអ្វីដែលខ្ញុំចូលចិត្តធ្វើនៅថ្ងៃនោះ»។
- មានការបារម្ភអំពីព្រលឹងវិញ្ញាណ និងសុខុមាលភាពរបស់ខ្ញុំ»។
- សួរពីសុខទុក្ខខ្ញុំ»។
- មានសកម្មភាពឆ្លើយតបភ្លាមៗនៅពេលខ្ញុំបង្ហាញពីតម្រូវការអ្វីមួយ»។
- ចេះមើលថែខ្លួនឯង ចេះរៀបចំខ្លួន និងមានភាពស្អាតបាត»។
- ស្តាប់ខ្ញុំ»។
- យល់ចិត្តខ្ញុំ»។
- ប្រាប់ខ្ញុំមុនប្រសិនបើគាត់មកផ្ទះវិញយឺត»។
- នាំខ្ញុំចំណាយពេលតែពីរនាក់នៅខាងក្រៅជាមួយគាត់»។

ខ្ញុំមានការភ្ញាក់ផ្អើលណាស់ដែលគ្មាននរណាម្នាក់ក្នុងចំណោមប្រពន្ធទាំងនោះនិយាយអំពីការចង់ឲ្យប្តីទិញអ្វីមួយឲ្យពួកគាត់សោះ ជាពិសេសដោយសារខ្ញុំដឹងថា បុគ្គលិករបស់យើងដែលធ្វើការទាំងអស់កំពុងតែខ្វះខាតផ្នែកថវិកា ដើម្បីបំពេញតម្រូវការ! ប៉ុន្តែ នៅគ្រប់ចំណុចដែលបានសរសេរចុះខាងលើស័ក្តិសមជាគំរូនៃសេចក្តីស្រឡាញ់ និងការផ្តល់កិត្តិយសសម្រាប់ប្តីគ្រប់រូបដែលព្រះគម្ពីរសញ្ញាថ្មីបានគាំទ្រ។ ប្តីគ្រប់រូបត្រូវតែខិតខំស្វែងរកថាតើប្រពន្ធរបស់ខ្លួនចូលចិត្តអ្វី ហើយព្យាយាមឲ្យអស់ពីលទ្ធភាពក្នុងការផ្តល់ឲ្យពួកគាត់នូវការទាំងអស់នោះ។

ពេលខ្លះ ប្ដីគិតថាប្រសិនបើពួកគាត់ផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុសម្រាប់គ្រួសារ នោះគាត់បានបំពេញតួនាទីជាប្ដីហើយ។ ប៉ុន្តែ មិនដូច្នេះទេ! ខ្ញុំដឹងយ៉ាងប្រាកដថា លោកអ្នកក៏ធ្លាប់ឮប្រយោគមួយនេះ «ការល្អបំផុតដែលឪពុកអាចធ្វើសម្រាប់កូនៗបាន គឺការស្រឡាញ់ម្ដាយរបស់ពួកគេ»។ យើងទាំងអស់គ្នាដែលជាប្ដីត្រូវតែធ្វើគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់ប្រពន្ធរបស់យើង។

## *ប្រពន្ធចុះចូល និងផ្ដល់កិត្តិយសដល់ប្ដីខ្លួន*

ព្រះគម្ពីរបានលើកបី-បួនដងអំពីការស្នើសុំឲ្យប្រពន្ធចុះចូលចំពោះប្ដីរបស់ខ្លួន (អេភេសូរ ៥:២២, ២៤; កូឡុស ៣:១៨; ១ពេត្រុស ៣:១)។ ប៉ុន្តែ ប្រសិនបើប្ដីមិនមានសេចក្ដីស្រឡាញ់ និងផ្ដល់កិត្តិយសដូចដែលព្រះគម្ពីរសញ្ញាថ្មីបានបង្រៀននោះទេ ផែនការមួយនេះអាចនឹងមានចំណុចអវិជ្ជមានជាច្រើន។ ប្ដីដែលប្រព្រឹត្តតាមព្រះគម្ពីរ គឺជាមនុស្សដែលចេះបន្ទាបខ្លួន ដែលបានរៀន «ចុះចូលចំពោះព្រះគ្រីស្ទ អ្នកដឹកនាំ និងការដាក់វិន័យរបស់ក្រុមជំនុំតាមតំបន់ ទាំងអាជ្ញាធរស៊ីវិល និងនៅកន្លែងធ្វើការ»។[២] មនុស្សបែបនោះមានគុណសម្បត្តិក្នុងការធ្វើជាមេដឹកនាំគ្រួសារ។ ហើយនៅពេលដែលប្រពន្ធចុះចូលដោយស្ម័គ្រចិត្តក្នុងការស្រឡាញ់ភាពជាមេ នោះនឹងមានសុភមង្គល និងការព្រមព្រៀងគ្នាក្នុងជីវិតគ្រួសារជាមិនខាន។

ការស្ម័គ្រចិត្តក្នុងការចុះចូលរបស់ប្រពន្ធចំពោះប្ដីក៏ជារបៀបមួយក្នុងការបំពេញប្ដីដែរ។ សាវ័ក ប៉ុល បានពន្យល់បន្ថែមអំពីការនេះនៅក្នុងកណ្ឌគម្ពីរអេភេសូរ ៥:៣៣ ដោយគាត់បានលើកឡើងថា «ហើយប្រពន្ធត្រូវគោរពប្ដី» (គគខ)។ ពាក្យដែលគេបានបកប្រែថា «គោរព» ក៏អាចមានន័យថា «កោតខ្លាច» ប៉ុន្តែនៅក្នុងខគម្ពីរនេះមានន័យថា «គោរព»។ មនុស្សប្រុសទទួលបានភាពពេញលេញតាមរយៈការទទួលបានការគោរព។ ការមិនគោរពប្ដីគឺជាការវាយប្រហារលើបុគ្គលិកលក្ខណៈរបស់គាត់។ ជារឿយៗ ប្រពន្ធមាន «ភាព

សុចរិត» ជាង ឬក៏គោរពតាមសាសនាខ្លាំងជាងគេក្នុងគ្រួសារ។ ប៉ុន្តែ គាត់ក៏អាចឈ្លើយ ឬក៏ថ្កោលទោសពេកក្នុងរបៀបដែលគាត់និយាយទៅកាន់ប្តី។ នេះមិនមែនជាលំនាំតាមព្រះគម្ពីរនោះទេ។ កណ្ឌគម្ពីរសុភាសិតបានលើកឡើងបីដង ទាក់ទងនឹងបទពិសោធន៍ដ៏ពិបាកក្នុងការរស់នៅជាមួយប្រពន្ធដែលចេះតែរករឿង។ ហើយនេះគឺជាឃ្លាមួយក្នុងចំណោមការលើកឡើងទាំងនេះ «ទឹកដែលស្រក់ចុះតក់ៗជានិច្ច នៅថ្ងៃភ្លៀងច្រើន ហើយស្ត្រីដែលចេះតែរករឿងនោះក៏ដូចគ្នា» (សុភាសិត ២៧:១៥; សូមមើលបន្ថែមនៅក្នុងជំពូក ២១:៩; ២៥:២៤)។ ប្តីដែលមានប្រពន្ធដូចនោះទំនងនឹងរកវិធីគេចវេះ ដែលមានដូចជាស្រា ស្រី ធ្វើការច្រើន ឬក៏ចំណាយពេលច្រើនពេកជាមួយនឹងមិត្តភក្តិ។

សាវ័ក ពេត្រុស ក៏បានផ្តល់ដំបូន្មានដល់ស្ត្រីដែលមានប្តីដែលមិនមែនជាអ្នកជឿ ដែលចំណុចនោះក៏មានប្រយោជន៍ដល់ប្រពន្ធទាំងអស់គ្នា «ឯពួកស្រីៗ ត្រូវចុះចូលចំពោះប្តីខ្លួនបែបដូច្នោះដែរ ដើម្បីបើមានអ្នកណា ដែលមិនព្រមស្តាប់បង្គាប់ តាមព្រះបន្ទូល នោះប្រពន្ធនឹងទាញចិត្តមកបាន ដោយសារកិរិយាល្អ ក្រៅពីព្រះបន្ទូល ដោយអ្នកនោះឃើញកិរិយាបរិសុទ្ធ ដែលប្រពន្ធប្រព្រឹត្តយ៉ាងកោតខ្លាចដល់ព្រះ» (១ពេត្រុស ៣:១-៣)។

លោកបណ្ឌិត អមើសិន អែគ័រិច (Dr. Emerson Eggerichs) បានសរសេរសៀវភៅដ៏ជាជំនួយមួយក្បាលទាក់ទងទៅនឹងទំនាក់ទំនងប្តីប្រពន្ធ ដែលមានចំណងជើងថា សេចក្តីស្រឡាញ់ និងការគោរព (Love and Respect)។ គាត់បានលើកឡើងថា «របៀបដ៏ល្អបំផុតក្នុងការស្រឡាញ់ប្តី គឺតាមរយៈការបង្ហាញការគោរពដល់គាត់ក្នុងរបៀបដែលមានន័យចំពោះគាត់»។[៣] ដូច្នេះប្រពន្ធត្រូវតែបង្ហាញចំណាប់អារម្មណ៍លើអ្វីដែលប្តីខ្លួនចូលចិត្តយ៉ាងខ្លាំង ដែលមានដូចជាកីឡា នយោបាយ ឬក៏អ្វីដែលគាត់ចូលចិត្តគិត។ ទោះបើប្រពន្ធមិនចាំបាច់ក្លាយជាអ្នកជំនាញក្នុងចំណុចទាំងនេះក៏ដោយ ដោយកើតចេញពីការស្រឡាញ់ប្តីគាត់ ក៏គាត់ព្យាយាមយល់អំពីចំណុចត្រង់នោះដែរ។ ភាពឯកាគឺជាចំណុចនៃបុគ្គលណាម្នាក់ដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ប៉ុន្តែ

គេអាចកាត់បន្ថយភាពឯកានោះបាន ប្រសិនបើដៃគូជីវិតស្ម័គ្រចិត្តសន្ទនាទាក់ទងនឹងចំណាប់អារម្មណ៍ទាំងនោះ។

ជាទូទៅ យើងមានទំនោរធ្វើតាមអ្វីមួយ ដោយស្វ័យប្រវត្តិ ដែលយើងធ្លាប់បានឃើញឪពុកម្ដាយរបស់យើងធ្វើពីមុនៗមក។ ដូច្នេះ ប្រសិនបើម្ដាយស្រ្តីណាម្នាក់បាននិយាយទៅកាន់ប្ដីរបស់គាត់ដោយពាក្យគម្រោះគម្រើយ នោះកូនស្រីរបស់គាត់អាចនឹងមានទំនោរក្នុងការនិយាយបែបនោះដូចគ្នាដោយស្វ័យប្រវត្តិទៅកាន់ប្ដីដែរ។ គាត់ត្រូវតែមានមនសិការក្នុងការចងចាំថា ការនេះមិនត្រឹមត្រូវនោះទេ ហើយត្រូវមានស្មារតីក្នុងការខិតខំប្រឹងប្រែងយកឈ្នះលើទម្លាប់មួយនេះ។ ពេលខ្លះ ប្ដីក៏វាយប្រពន្ធខ្លួននៅពេលដែលគាត់ខឹង។ ដោយសារការនេះជារឿងធម្មតាទៅហើយ សូម្បីតែបុរសដែលជាគ្រីស្ទបរិស័ទក៏នៅមានសេចក្ដីល្បួងឲ្យចង់វាយប្រពន្ធរបស់ខ្លួននៅពេលដែលគាត់មិនសប្បាយចិត្តដែរ។ ការនេះគឺជាការអាក្រក់ខ្លាំងណាស់! ជាញឹកញាប់ វាស្ទើរតែជាការឆ្លុះបញ្ចាំងអំពីសកម្មភាពដែលធ្វើឲ្យកើតមានឡើងដោយសារកំហឹងយ៉ាងសម្បើម។ ប្ដីទាំងអស់ត្រូវដឹងខ្លួនជាមុនអំពីគ្រោះថ្នាក់ដ៏អាក្រក់មួយនេះ ហើយត្រូវប្រុងប្រយ័ត្ន ដើម្បីទប់ទល់នឹងសេចក្ដីល្បួងនេះ។ ប្រសិនបើប្ដីបានធ្លាក់ក្នុងសេចក្ដីល្បួង គាត់ត្រូវតែធ្វើអ្វីមួយអំពីការនេះភ្លាមៗ។ ខ្ញុំចង់លើកទឹកចិត្តឲ្យគាត់មិនគ្រាន់តែស្វែងរកការអត់ទោសពីប្រពន្ធរបស់គាត់ដោយមានការបន្ទាបខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ឲ្យគាត់ត្រូវចែកចាយជាមួយអ្នកណាម្នាក់ដែលជួយមើលខុសត្រូវលើជីវិតគាត់ផងដែរ។ ទិដ្ឋភាពនៃទំនោរនៃការច្រឡោតដូចនេះដាច់ខាតត្រូវតែមានការព្យាបាលជាក់លាក់។ វាគឺជាជំនួយក្នុងការឲ្យបុគ្គលណាម្នាក់ចូលមកមើលការខុសត្រូវលើបុរសម្នាក់នោះ តាមរយៈការដាក់ពិន័យ ឬក៏របៀបណាមួយផ្សេងទៀត។ ក្រុមជំនុំក៏ត្រូវតែលើកឡើងអំពីការនេះជាញឹកញាប់លើវេទិកាអធិប្បាយថាជាអ្វីមួយដែលគ្រីស្ទបរិស័ទមិនត្រូវមានការអត់ឱនចិត្តបានឡើយ។

គោលគំនិតចម្បងនៃសៀវភៅរបស់លោក អែគ័រិច គឺថានៅក្នុងករណីជា

ច្រើនទាក់ទងនឹងជម្លោះរវាងប្ដីប្រពន្ធ ឫសគល់នៃបញ្ហានេះបណ្ដាលមកពីប្ដីបានបរាជ័យក្នុងការបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់ប្រពន្ធរបស់ខ្លួន និង/ឬប្រពន្ធបានបរាជ័យក្នុងការបង្ហាញការគោរពដល់ប្ដីរបស់គាត់។ វាជាការមួយដ៏ល្អបើដៃគូជីវិតដឹងពីបញ្ហាមួយនេះ។ ដូច្នេះ នៅពេលដែលមានជម្លោះកើតឡើង ប្ដីគួរតែសួរខ្លួនឯងថា «តើខ្ញុំបានបរាជ័យក្នុងការស្រឡាញ់ប្រពន្ធរបស់ខ្ញុំដូចដែលខ្ញុំគួរស្រឡាញ់គាត់ដែរឬទេ?» ហើយប្រពន្ធគួរតែសួរខ្លួនឯងថា «តើខ្ញុំបានបរាជ័យក្នុងការគោរពប្ដីរបស់ខ្ញុំតាមដែលខ្ញុំគួរធ្វើមែនឬ?»។

## សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ប្រទាននូវកម្លាំងដល់យើង

នៅក្នុងជំពូកមួយនេះ ហើយនិងជំពូកមុន ខ្ញុំបានបង្ហាញអំពីគំរូដែលបានដកស្រង់ពីព្រះគម្ពីរអំពីសេចក្ដីស្រឡាញ់ដែលគួរឲ្យកោតសរសើរ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមនុស្សជាច្រើននៅមានចម្ងល់ថា តើយើងអាចយកវាមកអនុវត្តបានដែរឬទេ។ តើវាពិតជាអាចទៅរួចបានទេក្នុងការស្រឡាញ់គ្រួសាររបស់យើងតាមរបៀបដែលព្រះគម្ពីរប្រាប់យើងឲ្យធ្វើ? ចំណុចទីមួយដែលខ្ញុំត្រូវតែលើកឡើងក្នុងការឆ្លើយតបគឺថា ព្រះជាម្ចាស់គឺជាអង្គដែលប្រទានកម្លាំងដល់យើងក្នុងការស្រឡាញ់ក្នុងរបៀបនេះបាន។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «សេចក្ដីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ» (រ៉ូម ៥:៥)។ ពាក្យដែលគេបានបកប្រែថា «បានផ្សាយ» មានអត្ថន័យមកពីពាក្យ «ជាបរិបូរណ៍»។ មិនមានការខ្វះខាតទេចំពោះសេចក្ដីស្រឡាញ់បែបនេះដែលចូលមកក្នុងជីវិតយើង។ គ្រីស្ទបរិស័ទជាអ្នកដឹកនាំដែលបានព្យាយាមធ្វើជាសមាជិកល្អក្នុងគ្រួសារអាចលើកឡើងថាជីវិតគាត់ពិបាកណាស់ ទាំងផ្នែកអារម្មណ៍ និងផ្នែករូបកាយ។ ប៉ុន្តែ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ល្មមគ្រប់គ្រាន់ក្នុងការប្រទានមកយើងនូវកម្លាំង ដើម្បីឲ្យបន្តស្រឡាញ់ មិនថាពិបាកយ៉ាងណាក៏ដោយ។ មានសេចក្ដីអំណរគ្រប់គ្រាន់លើសេចក្ដីស្រឡាញ់របស់

ព្រះជាម្ចាស់ចំពោះយើង ក្នុងការរក្សាយើងឲ្យនៅមានគំនិតវិជ្ជមានអំពីជីវិតដែលរស់នៅសម្រាប់អ្នកដទៃ។

អាថ៌កំបាំងនៃកម្លាំងក្នុងការបម្រើ (នៅផ្ទះ នៅក្នុងក្រុមជំនុំ ឬក៏នៅក្នុងសង្គម) គឺជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលគង់នៅក្នុងដួងចិត្តរបស់យើង។ ដោយនិយាយអំពីជីវិតបម្រើរបស់គាត់ នោះសាវ័ក ប៉ុល បានលើកឡើងថា «ដ្បិតសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ» (២កូរិនថូស ៥:១៤)។ ពាក្យដែលគេបានបកប្រែថា «បង្ខំ» (ស៊ុននីហ្គូ ‘‘sunechō’’) ផ្តល់ជាគោលគំនិតក្នុងការជំរុញឲ្យយើងមានសកម្មភាព។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជំរុញយើងឲ្យស្រឡាញ់ ហើយប្រទានដល់យើងនូវកម្លាំងក្នុងការធ្វើកិច្ចការដែលពេលខ្លះពិបាកក្នុងការស្រឡាញ់។

កាលកូនប្រុសរបស់ខ្ញុំនៅក្មេងនៅឡើយ ពេលខ្លះគាត់បានសុំឲ្យខ្ញុំលេងទាត់បាល់ជាមួយគាត់នៅពេលល្ងាច។ ជារឿយៗ ខ្ញុំអស់កម្លាំង ហើយចង់ធ្វើអ្វីមួយផ្សេងទៀតដូចជាអានសៀវភៅ ឬក៏មើលទូរទស្សន៍។ ហើយផ្ទុយពីកូនប្រុសរបស់ខ្ញុំ ខ្ញុំក៏មិនមែនជាអ្នកពូកែលេងទាត់បាល់នោះទេ! ប៉ុន្តែ សេចក្តីស្រឡាញ់បានជំរុញឲ្យខ្ញុំចេញទៅលេងជាមួយគាត់។ ខ្ញុំមិនដែលមានការសោកស្តាយក្នុងការសម្រេចចិត្តទៅលេងនោះទេ ដ្បិតខ្ញុំតែងតែមានអារម្មណ៍ថាបានស្រស់ស្រាយទាំងផ្លូវកាយ និងផ្លូវចិត្តបន្ទាប់ពីលេងហើយ។ សេចក្តីស្រឡាញ់បានជំរុញឲ្យខ្ញុំលេងជាមួយកូនរបស់ខ្ញុំ ហើយសេចក្តីស្រឡាញ់ក៏បានធ្វើឲ្យខ្ញុំបានស្រស់ស្រាយតាមរយៈសកម្មភាពដែលបានលេងនោះដែរ។

យើងត្រូវតែស្ថិតនៅកន្លែងណាមួយក្នុងការទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មកក្នុងជីវិតរបស់យើង ប្រយោជន៍ឲ្យយើងមានកម្លាំងក្នុងការស្រឡាញ់អ្នកដទៃបាន។ ជាដំបូង យើងត្រូវតែបើកចំហខ្លួនឯងក្នុងការទទួលយកសេចក្តីស្រឡាញ់នេះ។ នៅក្នុងជំពូក១ យើងបានលើកឡើងអំពីអ្នកម្តាយម្នាក់ (ដែលបានបង្ហាញថាការដែលគាត់នៅជិតព្រះជាម្ចាស់ មិនថាគាត់ពិបាកខ្លាំងប៉ុណ្ណាក្នុងការចិញ្ចឹមកូនជាច្រើន) ដែលបានចំណាយពេលអង្គុយលើ

កៅអីដោយយកអៀមធ្វើម្ហូបរបស់គាត់មកទទួលលើក្បាល ដើម្បីឲ្យមានពេលអធិស្ឋាន។ ហោរា អេសាយ បានប្រាប់យើងថា ការរង់ចាំព្រះជាម្ចាស់គឺជាចំណុច អាថ៌កំបាំងនៃកម្លាំង៖ «អស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកម្លាំងចម្រើនជានិច្ច គេនឹងហើរឡើងទៅលើ ដោយស្លាបដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ» (អេសាយ ៤០:៣១)។ ពេលដែលយើងចំណាយពេលនៅក្នុងព្រះវត្តមាននៃព្រះវរបិតារបស់យើងដែលពេញដោយសេចក្ដីស្រឡាញ់ នោះសេចក្ដីស្រឡាញ់នឹងជោរជន់ក្នុងជីវិតយើង។ ពិតណាស់! អ្នកដឹកនាំដែលមានសមាជិកគ្រួសារដែលពួកគាត់ត្រូវមើលថែ មានការពិបាកក្នុងការរកពេលវេលាតែឯង ដើម្បីចំណាយពេលជាមួយនឹងព្រះជាម្ចាស់។ ប៉ុន្តែ ដូចដែលខ្ញុំបានឮពីគ្រូគង្វាលម្នាក់ដែលបានមកលេងពីប្រទេសអាមេរិក កាលខ្ញុំនៅក្មេង ដែលមានឈ្មោះថា លោក លូត ហ្គលស៍ (Lud Golz) «ប្រសិនបើលោកអ្នករវល់ខ្លាំងពេកក្នុងការចំណាយពេលអធិស្ឋាន នោះមានន័យថាលោកអ្នករវល់ខ្លាំងពេកហើយ»។ ការប្រឹក្សានោះមិនដែលចាកចេញពីខ្ញុំទេ!

ខ្ញុំជឿជាក់ថា ផ្នែកមួយដ៏សំខាន់បំផុតនៃការលូតលាស់ក្នុងជីវិតជាគ្រីស្ទបរិស័ទ គឺការរៀនទទួលយកសេចក្ដីស្រឡាញ់ដ៏បរិបូរណ៍របស់ព្រះអង្គមកលើយើង។ វាគឺជាអ្វីមួយដែលយើងទទួលយកដោយជំនឿ ដោយទទួលជឿថា អ្វីដែលព្រះគម្ពីរបានថែងគឺអំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ ប៉ុន្តែ មានមនុស្សមួយចំនួនមានភាពប្រេះស្រាំយ៉ាងខ្លាំងរហូតដល់គិតថា ព្រះជាម្ចាស់មិនអាចទទួលយកពួកគាត់បានទេ។ ចំពោះពួកគាត់ អំណរនៃការដែលព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយនឹងពួកគាត់ ដែលព្រះគម្ពីរបានលើកឡើងជាញឹកញាប់ មិនមែនជាអ្វីដែលពិតឡើយ (ទំនុកតម្កើង ៣៥:២៧; ១៤៧:១១; ១៤៩:៤; អេសាយ ៦២:៤; សេផានា ៣:១៧)។ ដូច្នេះ ពួកគាត់ក៏រស់នៅក្នុងភាពឈឺចាប់នៃការបដិសេធដែលពួកគាត់បានទទួលបទពិសោធន៍នៅលើផែនដីនេះ។ ជាលទ្ធផល ការនោះក៏ធ្វើឲ្យមានភាពស្រអាប់ក្នុងបទពិសោធន៍

របស់ពួកគាត់ ដែលមានរួមទាំងបទពិសោធន៍របស់ពួកគាត់ក្នុងការទទួលយកសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ផងដែរ។ ហើយការនេះក៏ធ្វើឲ្យពួកគាត់ពិបាកបង្ហាញសេចក្តីស្រឡាញ់ទៅកាន់អ្នកដទៃ ដោយអំណរ។

ដូចដែលយើងបានបង្ហាញនៅក្នុងជំពូកមុន គ្រីស្ទបរិស័ទមួយចំនួនក៏ត្រូវការការព្យាបាលចេញពីបទពិសោធន៍នៃការឈឺចាប់ដែលបានធ្វើឲ្យពួកគាត់ប្រេះស្រាំ ហើយនិងមិនអាចមានអំណរក្នុងការទទួលសេចក្តីស្រឡាញ់។ អ្នកខ្លះទៀតអាចណែនាំពួកគាត់ឲ្យអត់ទោសដល់អស់អ្នកដែលធ្វើឲ្យពួកគាត់ឈឺចាប់ ហើយឲ្យទទួលយកការពិតដែលថា ព្រះជាម្ចាស់នឹងប្រើប្រាស់ការឈឺចាប់របស់ពួកគាត់នោះ ដើម្បីសម្រេចនូវអ្វីដែលល្អនៅក្នុងជីវិតរបស់ពួកគាត់។ ការទទួលបានការព្យាបាលបែបនេះអាចនាំឲ្យពួកគាត់មានការបើកចំហក្នុងការទទួលយកសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដើម្បីកុំឲ្យពួកគាត់មើលជីវិតចេញពីទិដ្ឋភាពនៃការឈឺចាប់ និងកំហឹងក្នុងការទទួលបានការឈឺចាប់។ គន្លឹះនៃការទទួលការព្យាបាលនេះគឺ ការជឿលើអ្វីដែលព្រះគម្ពីរបានចែងអំពីទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយយើង។ គួរឲ្យសោកស្តាយណាស់ នៅមានមនុស្សមួយចំនួនបដិសេធមិនទទួលជឿលើការនេះ។ ពួកគាត់ចង់បន្តនៅមានកំហឹង និងការឈឺចាប់ទាក់ទងនឹងអ្វីដែលអ្នកដទៃបានប្រព្រឹត្តចំពោះពួកគាត់។ ជាលទ្ធផល ពួកគាត់ក៏ធ្វើឲ្យខ្លួនឯងឈឺចាប់ ហើយដោយគេចមិនផុតក៏បានធ្វើឲ្យអ្នកដទៃឈឺចាប់តាមរយៈទង្វើរបស់ពួកគាត់ផងដែរ ដែលកើតចេញពីការដែលពួកគាត់មិនមានអំណរក្នុងជីវិត។

មានមនុស្សមួយចំនួនក៏មិនបានឆ្លើយតបចំពោះការបារម្ភខ្វល់ខ្វាយពីសេចក្តីស្រឡាញ់របស់សមាជិកគ្រួសារ ពីព្រោះពួកគាត់កំពុងប្រឈមមុខនឹងសម្ពាធមិនធម្មតា និងជាលទ្ធផលក៏មានអារម្មណ៍មិនល្អ។ សម្ពាធនោះអាចបណ្តាលមកពីលក្ខខណ្ឌផ្នែករាងកាយ ដូចជាការមករដូវរបស់ស្ត្រីជាប្រចាំខែ ឬការអស់រដូវ ការមានជំងឺ ការមានបន្ទុកច្រើនខុសធម្មតាពីការងារ ឬក៏ការប្រឈមជាមួយកន្លែងការងាររបស់គាត់។ ឧទាហរណ៍ សូមគិតអំពី

ករណីម្ដាយវ័យក្មេងម្នាក់ដែលទើបតែឆ្លងទន្លេជាមួយនឹងកូនទីពីររបស់គាត់។ ការមើលថែកូនទីមួយគឺពិបាកស្រាប់ហើយ ហើយការមើលថែកូនពីរនាក់ក៏កាន់តែពិបាកថែមទៀត។ ប្ដីរបស់គាត់ព្យាយាមជួយគាត់ ប៉ុន្តែប្ដីគាត់ក៏មានការឈឺចាប់ដោយគាត់មិនឲ្យតម្លៃលើការលះបង់របស់គាត់។ ទោះជាយ៉ាងណាក្ដី ក៏គាត់ទំនងជាកំពុងឆ្លើយតបដោយមានការគម្រោះគម្រើយទៅកាន់ប្ដី ដោយសារគាត់មានបន្ទុកយ៉ាងខ្លាំងក្នុងការទទួលខុសត្រូវ ដែលការនោះបានធ្វើឲ្យគាត់មានអារម្មណ៍មិនល្អជានិច្ច។ ប្រសិនបើប្ដីខឹងប្រពន្ធដោយការឆ្លើយតបរបស់ប្រពន្ធ ការនោះនឹងកាន់តែនាំឲ្យមានបញ្ហា ដែលបណ្ដាលឲ្យកាន់តែមានការឈឺចាប់ចំពោះប្រពន្ធរបស់គាត់ដែលកំពុងតែឈឺចាប់ស្រាប់ហើយ។ គាត់ត្រូវតែរៀនស៊ូទ្រាំជាមួយប្រពន្ធរបស់គាត់ដោយចេះអត់ធ្មត់ ដោយព្យាយាមធ្វើគ្រប់យ៉ាងដែលគាត់អាចធ្វើបាន ដើម្បីជួយកាត់បន្ថយសម្ពាធរបស់ប្រពន្ធ ហើយអធិស្ឋានឲ្យគាត់មានលទ្ធភាពក្នុងការដោះស្រាយជាមួយនឹងសម្ពាធដែលគាត់កំពុងមានឲ្យបានល្អប្រសើរជាងនេះ។

ពេលខ្លះ អំពើបាបរបស់យើងផ្ទាល់អាចរារាំងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ នៅពេលដែលយើងមិនសារភាពអំពើបាបនៅក្នុងជីវិតរស់នៅរបស់យើង យើងតែងតែមានទំនោរក្នុងការប្រព្រឹត្ត ដែលកើតចេញពីពិរុទ្ធភាពដែលយើងមានចំពោះអំពើបាបនោះ។ ដូច្នេះ ជាលទ្ធផលយើងក៏បានក្លាយជាអ្នកដែលឆាប់ខឹង និងងាយកាត់ទោសគេ។ ចម្លើយគឺថាយើងត្រូវ «ដើរក្នុងពន្លឺ» ដែលនេះមានន័យថា លន់តួបាបរបស់យើង ដើម្បីឲ្យ «ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ…សម្អាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់» (១យ៉ូហាន ១:៧)។ ជាលទ្ធផលនៃការសារភាពបែបនេះ គឺដូចដែលស្ដេច ដាវីឌ បានមានបន្ទូលបន្ទាប់ពីទ្រង់បានប្រែចិត្តថា «ទូលបង្គំមានចិត្តរីករាយចំពោះសេចក្ដីសង្គ្រោះ [របស់ព្រះជាម្ចាស់]» គឺត្រូវបានស្ដារឡើងវិញ ហើយយើង «បានឮសេចក្ដីអំណរ និងសេចក្ដីរីករាយ» (ទំនុកតម្កើង ៥១:១២, ៨)។ ខ្ញុំបានដឹងអំពីកាលៈទេសៈ ដែលគ្រប់គ្នានៅក្នុងគ្រួសារបានដឹងហើយថា ឪពុកបានធ្វើអ្វី

មួយខុស ប៉ុន្តែមិនមានអ្នកណាប្រឈមមុខជាមួយនឹងគាត់អំពីការនោះ។ ពួកគាត់បានធ្វើពុត ហាក់បីដូចជាថា មិនមានអ្វីមិនធម្មតាបានកើតឡើងអញ្ចឹង។ ប៉ុន្តែ មានភាពស្រអាប់យ៉ាងខ្លាំងនៃការមិនសារភាពអំពើបាបនៅក្នុងផ្ទះ ហើយសេរីភាពនៃការស្រឡាញ់ក៏ត្រូវបានបាត់បង់។

ប្រសិនបើលោកអ្នកមិនមានអំណរក្នុងការទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ និងអ្នកដទៃដោយសេរី សូមធ្វើអ្វីមួយដើម្បីឲ្យមានការផ្លាស់ប្រែ! ព្រះជាម្ចាស់បានប្រទានរបៀបជាច្រើនក្នុងការព្យាបាល។ ប្រសិនបើយើងមិនអនុញ្ញាតឲ្យព្រះជាម្ចាស់ព្យាបាលទេ នោះយើងនឹងបន្តរស់នៅដោយគ្មានសុភមង្គល ហើយដោយសារការនោះ យើងក៏នឹងនាំឲ្យគ្រួសារគ្មានសុភមង្គលដែរ។ យើងមិនគួរឱបក្រសោបកំហឹង និងអំពើបាបរបស់យើងទេ។ ការធ្វើបែបនោះនាំឲ្យអ្នកដទៃ និងយើងឈឺចាប់យ៉ាងខ្លាំងដែរ។

## ការរស់នៅដោយមានតុល្យភាពជាទូទៅជាឈើឆ្កាងរបស់យើង

ព្រះជាម្ចាស់បានត្រាស់ហៅគ្រីស្ទបរិស័ទឲ្យមានតុល្យភាពក្នុងជីវិត។ នេះមិនមែនថា យើងធ្វើគ្រប់អ្វីៗឲ្យបានតែមធ្យមនោះទេ ប៉ុន្តែមានន័យថា មានការស្តាប់បង្គាប់ក្នុងគ្រប់ចំណុចនៃជីវិត។ នេះគឺជាកាតព្វកិច្ចដ៏ពិបាកមួយក្នុងការអនុវត្ត នៅក្នុងពិភពលោកពេញដោយការរវល់នេះ។ ចូរយើងប្តេជ្ញាចិត្តជាមួយនឹងការងារ ឬការសិក្សាឲ្យបានល្អ ខណៈពេលដែលយើងមានភាពសកម្មនៅក្នុងក្រុមជំនុំ និងធ្វើជាសមាជិកល្អនៅក្នុងគ្រួសារអាចជារឿងមួយដែលហាត់នឿយណាស់។ យើងមិនអាចទាយទុកអំពីតម្រូវការដែលនឹងមានក្នុងចំណុចទាំងនោះបានឡើយ។ ដៃគូជីវិតម្នាក់អាចខឹងនៅពេលយប់ ខណៈពេលដែលម្នាក់ទៀតកំពុងតែព្យាយាមគេង។ ការមិនរួបរួមគ្នាក៏អាចលេចឡើងខណៈពេលដែលកំពុងតែរវល់យ៉ាងខ្លាំង។ កូនទំនងជាត្រូវការជំនួយក្នុងការសិក្សារបស់គាត់ ក្នុងពេលដែលឪពុកម្តាយចង់មើលទូរទស្សន៍ជាង។ ក្នុងអំឡុងពេលនីមួយៗទាំងនេះ យើងត្រូវជំរុញខ្លួនយើង ហើយត្រូវធ្វើអ្វីដែល

មានប្រយោជន៍សម្រាប់គ្រួសាររបស់យើង។

មនុស្សជាច្រើនដែលខំធ្វើការ ឬក៏បម្រើព័ន្ធកិច្ចគ្រីស្ទបរិស័ទមិនបានយកចិត្តទុកដាក់ចំពោះគ្រួសារខ្លាំងប៉ុន្មានដូចដែលពួកគេគួរធ្វើនោះទេ។ ជារឿយៗ យើងមើលមនុស្សដូច្នោះ ហើយមើលរំលងកំហុសរបស់ពួកគាត់ ដោយសារពួកគាត់មានការប្តេជ្ញាចិត្តយ៉ាងខ្លាំងលើតួនាទីរបស់ខ្លួន។ តាមពិតទៅ ទាំងនោះគឺដោយសារពួកគាត់មិនមានការដាក់ពិន័យ ហើយដោយសារពួកគាត់មិនស្តាប់បង្គាប់តាមរបៀបរបស់ព្រះជាម្ចាស់។ អស់អ្នកដែលមានការប្តេជ្ញាចិត្តក្នុងការមើលថែគ្រួសាររបស់ខ្លួនមិនធ្វើការងារ ឬក៏បម្រើព័ន្ធកិច្ចរបស់ខ្លួនដោយយកចិត្តទុកដាក់នោះទេ។ ពួកគាត់ក៏កំពុងតែគេចវេះពីកាតព្វកិច្ចរបស់ខ្លួនផងដែរ។ ការរស់នៅដោយមានតុល្យភាពអាចពិបាកនៅពេលខ្លះ ប៉ុន្តែនោះគឺជាអ្វីដែលយើងឱបក្រសោប ជាផ្នែកមួយនៃឈើឆ្កាង ដែលអមគ្នាជាមួយនឹងជីវិតគ្រីស្ទបរិស័ទ។ ខ្ញុំជឿថា សម្រាប់គ្រីស្ទបរិស័ទជាច្រើននាក់ ឈើឆ្កាងរបស់ពួកគាត់គឺការរស់នៅក្នុងជីវិតដែលមានតុល្យភាព។

ពេលខ្លះ ការបន្ទាន់ក៏ធ្វើឲ្យយើងលាតសន្ធឹងដែរ។ ដល់ល្ងាចថ្ងៃសៅរ៍ហើយ ហើយការរៀបចំសេចក្តីអធិប្បាយរបស់លោកគ្រូគង្វាលសម្រាប់ថ្ងៃអាទិត្យមិនទាន់បានរួចរាល់នៅឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ កូនស្រីរបស់គាត់ក៏បានធ្លាក់ខ្លួនឈឺដែរ។ គាត់ត្រូវតែយកនាងទៅមន្ទីរពេទ្យ។ ប្រពន្ធរបស់គាត់អាចយកកូនស្រីទៅមន្ទីរពេទ្យដោយមិនចាំបាច់មានគាត់ជូនទៅ។ ប៉ុន្តែ ដោយសារគាត់មើលឃើញពីទុក្ខព្រួយដែលប្រពន្ធកំពុងតែមានចំពោះកូនស្រីរបស់គាត់ គាត់ក៏បានទៅជាមួយ។ ពេលដែលកូនយើងឈឺ យើងមិនអាចនិយាយថាការមើលថែគាត់មិនមែនជាតួនាទីរបស់យើងបានឡើយ! យើងត្រូវតែធ្វើនូវអ្វីដែលយើងត្រូវធ្វើឲ្យបានរួចរាល់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការរៀបចំសេចក្តីអធិប្បាយសម្រាប់ព្រឹកថ្ងៃអាទិត្យក៏ត្រូវតែរៀបចំឲ្យបានរួចរាល់ដែរ។ គ្រូគង្វាលមិនអាចធ្វេសប្រហែសនៅចំណុចនេះបានឡើយ។ ការខាតពេលបួនម៉ោងក្នុងការរៀបចំសេចក្តីអធិប្បាយមានន័យថា គាត់ក៏ត្រូវខាតពេលបួនម៉ោង

ក្នុងការគេងរបស់គាត់ដែរ! ប៉ុន្តែ  ពេលគាត់បានត្រឡប់មកផ្ទះវិញ ហើយគាត់ក៏បានធ្វើកិច្ចការដែលចាំបាច់ត្រូវធ្វើក្នុងការរៀបចំសេចក្ដីអធិប្បាយបញ្ចប់ឲ្យបានល្អសម្រាប់ព្រឹកបន្ទាប់។

ខ្ញុំត្រូវបន្ថែមចំណុចមួយទៀតត្រង់ថា បុគ្គលដែលធ្លាប់សកម្មក្នុងព័ន្ធកិច្ចកាលគាត់នៅលីវ  មិនអាចបន្តសកម្មដូចមុនបន្ទាប់ពីគាត់បានរៀបការរួចហើយ។ ព័ន្ធកិច្ចជាមួយនឹងមនុស្សតម្រូវឲ្យមានការចំណាយពេលជាមួយនឹងមនុស្ស និងការញែកពេលជាច្រើនដើម្បីជជែកគ្នាឲ្យបានយូរ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបុគ្គលណាម្នាក់បានរៀបការហើយ គាត់ក៏ត្រូវធ្វើការនោះដោយមិនលះបង់ពេលវេលាគ្រួសារដែរ។ ឥឡូវនេះ គ្រួសារក៏ជាផ្នែកមួយនៃព័ន្ធកិច្ចរបស់គាត់ដែរ។ ជារឿយៗ អស់អ្នកដែលយើងធ្វើព័ន្ធកិច្ចជាមួយមិនផ្ដល់តម្លៃលើការផ្លាស់ប្ដូរនេះទេ។ យើងត្រូវតែធ្វើឲ្យអស់ពីសមត្ថភាពក្នុងការជួយពួកគេឲ្យយល់ថា មានរឿងធម្មតាថ្មីមួយទៀតបន្ទាប់ពីយើងរៀបការហើយ។

មានពេលខ្លះ បុគ្គលម្នាក់ក៏បានបរាជ័យក្នុងការយល់ការនេះ ហើយបានចំណាយពេលយ៉ាងច្រើនសម្រាប់ព័ន្ធកិច្ច នៅក្នុងឆ្នាំដំបូងៗនៃជីវិតអាពាហ៍ពិពាហ៍ ដែលធ្វើឲ្យគាត់មិនបានយកចិត្តទុកដាក់លើទំនួលខុសត្រូវក្នុងគ្រួសាររបស់គាត់។ យើងនឹងលើកឡើងពីករណីប្ដីដែលបម្រើនៅក្នុងព័ន្ធកិច្ច។ នៅពេលដែលប្រពន្ធរអ៊ូរទាំពីការមិនយកចិត្តទុកដាក់ចំពោះគ្រួសារ គាត់បានប្រាប់ប្រពន្ធថាគាត់ត្រូវតែដើរតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ប្រពន្ធដែលជាគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ក៏ជ្រើសរើសមិន “ប្រឆាំងជាមួយនឹងព្រះជាម្ចាស់” ហើយស៊ូទ្រាំជាមួយនឹងការមិនអើពើរបស់ប្ដីចំពោះគ្រួសារ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីប៉ុន្មានឆ្នាំបានកន្លងផុតទៅ ក៏ប្រពន្ធបានយល់ថា ការមិនយកចិត្តទុកដាក់នេះគឺមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ ប៉ុន្តែជាលទ្ធផលនៃការខ្វះខាតក្នុងការមិនមានវិន័យរបស់ប្ដីរបស់គាត់វិញ។ ជាលទ្ធផល ទំនងជាមានជម្លោះមិនល្អនៅផ្ទះ។ ប្ដីដែលពេញ

ទៅដោយពិរុទ្ធភាព ដែលមកដល់ពេលនេះកំពុងតែរងគ្រោះជិតដល់ការចង់ឈប់បម្រើ ដោយសារគាត់មិនមានការដាក់ពិន័យល្អៗ ក៏ធ្វើនូវអ្វីដែលជ្រុលជាងនោះទៅទៀត។ គាត់ក៏ឈប់ធ្វើព័ន្ធកិច្ច ឬក៏ទៅរកការងារដែលបំពេញកំសាន្តផ្នែកសម្ភារៈនិយមទៅដល់គ្រួសាររបស់គាត់ ប៉ុន្តែការនោះក៏បានដកគាត់ចេញពីការត្រាស់ហៅរបស់គាត់—ឬក៏បន្ថយឋានៈរបស់គាត់ក្នុងព័ន្ធកិច្ចរបស់គាត់ ដោយបំពេញទំនួលខុសត្រូវរបស់គាត់មិនបានត្រឹមត្រូវ។

នៅក្នុងប្រទេសអ៊ីស្រាអែលកាលពីសម័យបុរាណ វាគឺជារឿងសំខាន់ណាស់ដែលប្រុសៗដែលទើបតែរៀបការមិនមានតួនាទីទៅធ្វើសង្គ្រាម ឬក៏កាតព្វកិច្ចជាពលរដ្ឋផ្សេងៗទៀតដែលអាចនាំឲ្យពួកគេចេញឆ្ងាយពីផ្ទះរបស់ខ្លួន។ តើមូលហេតុអ្វី? «[គឺ] ត្រូវឲ្យ [បុរស] នៅទំនេរនៅផ្ទះរយៈពេលមួយឆ្នាំ ដើម្បីឲ្យគេបានរីករាយជាមួយប្រពន្ធដែលគេបានរៀបការ» (ចោទិយកថា ២៤:៥)។ ការត្រាស់ហៅជាចម្បងរបស់បុរសជាប្តីគឺការនាំសុភមង្គលដល់ប្រពន្ធរបស់ខ្លួន។ នោះគឺជាសេចក្តីប្រាថ្នាដ៏ល្អមួយដែលប្តីទាំងអស់ត្រូវមាន។ យើងត្រូវតែបង្រៀនគូស្វាមី ដែលបម្រើនៅក្នុងព័ន្ធកិច្ចដោយស្ម័គ្រចិត្ត ឬពេញម៉ោងក្តីក្នុងការអនុវត្តនូវតុល្យភាពដ៏ត្រឹមត្រូវនៅក្នុងជីវិតរស់នៅចាប់តាំងពីការចាប់ផ្តើមក្នុងជីវិតរៀបការរបស់ពួកគេ។

ហោរា នេហេមា ជាអ្នកដឹកនាំដ៏ល្អម្នាក់ ដែលទទួលបានជោគជ័យដ៏ល្អៗជាច្រើន តាមរយៈការបម្រើដោយមានការលះបង់សម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់។ លោកបានបោះបង់ដំណែងដ៏សុខស្រួលរបស់គាត់ចោលក្នុងនាមជាអ្នកលើកស្រាថ្វាយស្តេច ហើយបានចេញទៅទីក្រុងយេរូសាឡឹមដើម្បីដឹកនាំគម្រោងការដ៏លំបាក និងមានគ្រោះថ្នាក់។ គាត់បានដឹកនាំពួកហ្វូងមនុស្សដោយមានភាពឆ្លាតវាងវៃ ហើយក៏បានបញ្ចប់ការកសាងកំផែងទីក្រុងយេរូសាឡឹមឡើងវិញ ទោះបើគាត់បានប្រឈមមុខនឹងការលំបាកខ្លាំងជាច្រើនក៏ដោយ។ បន្ទាប់ពីគាត់បានទទួលការអនុញ្ញាតពីស្តេច ទាក់ទងនឹងសំណើរបស់គាត់ឲ្យទៅកសាងកំផែងឡើងវិញ គាត់បានសូម «ព្រះរាជ

សាសន៍មួយច្បាប់ដល់អេសាភ ជាមេព្រៃហ្លួង ឲ្យលោកបានបើកឈើដល់ទូលបង្គំ សម្រាប់ធ្វើធ្នឹមទ្វារបន្ទាយ ដែលនៅក្បែរព្រះវិហារ និងទ្វារកំផែងនៃទីក្រុង ហើយសម្រាប់ផ្ទះ ដែលទូលបង្គំត្រូវអាស្រ័យនៅផង ស្តេចក៏អនុញ្ញាតឲ្យ តាមដែលព្រះហស្តល្អរបស់ព្រះនៃខ្ញុំបានសណ្ឋិតលើខ្ញុំ» (នេហេមា ២:៨)។ សូមកត់សម្គាល់អំពីរបៀបដែលគាត់សូមឈើ មិនមែនគ្រាន់តែសម្រាប់ការងារទាំងអស់របស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ការសាងសង់ផ្ទះរបស់គាត់ផងដែរ—ទំនងជាផ្ទះជីដូនជីតារបស់គាត់ ដែលកំពុងស្ថិតក្នុងលក្ខណៈទ្រុឌទ្រោម។

អ្នកបម្រើរបស់ព្រះជាម្ចាស់មួយចំនួន ដែលខំធ្វើការយ៉ាងខ្លាំងទាក់ទងនឹងព័ន្ធកិច្ច មិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការដ៏សំខាន់ក្នុងគ្រួសារ—ដែលមានដូចជាការរក្សាផ្ទះឲ្យបានល្អ ឬក៏ប្រាកដថាឲ្យគ្រួសារមានផ្ទះរស់នៅ។ គ្រូគង្វាលម្នាក់ទំនងជារវល់ខ្លាំងដល់ថ្នាក់ថា គាត់ពន្យារពេលក្នុងការនាំប្រពន្ធរបស់គាត់ទៅជួបពេទ្យក្នុងការព្យាបាលជំងឺណាមួយ។ ទម្រាំតែដល់ពេលដែលគាត់ទៅ ពួកគាត់ក៏ឃើញថា ជំងឺនោះបានក្លាយជាបញ្ហាធ្ងន់ធ្ងរមួយទៅហើយ ដូចជាជំងឺមហារីក ដែលត្រូវទទួលបានការព្យាបាលភ្លាមៗនៅពេលកើតឡើង។ មានកូនៗរបស់គ្រូគង្វាលជាច្រើននាក់ដែលខឹងលើការមិនយកចិត្តទុកដាក់របស់ប៉ាពួកគេ ដែលបង្កឲ្យមានបញ្ហាធំដល់គ្រួសារដែលពាក់ព័ន្ធ។ ពេលខ្លះ បញ្ហានេះក៏បានបើកចំហឡើងនៅពេលក្រោយទៀតក្នុងជីវិត។ ដាច់ខាត យើងមិនត្រូវព្រងើយកន្តើយចំពោះការងារដែលពិបាកៗ រកស៊ីច្រើនម៉ោងដែលទាក់ទងជាមួយនឹងគ្រួសារ ដោយសារយើងរវល់ខ្លាំងពេកជាមួយនឹងទំនួលខុសត្រូវផ្នែកព័ន្ធកិច្ច។

## សេចក្តីសន្និដ្ឋាន

ការស្រឡាញ់មានផលពិបាកជាច្រើន នៅពេលដែលយើងអនុវត្តផ្ទាល់នៅផ្ទះ។ យើងនឹងកាន់តែរៀនបន្ថែមទៀតអំពីតម្លៃនៃសេចក្តីស្រឡាញ់ ខណៈពេលដែលយើងឆ្លងកាត់ជាច្រើនឆ្នាំក្នុងជីវិតអាពាហ៍ពិពាហ៍។ ប្រសិនបើគោលបំណង

សម្រេចរបស់យើងគឺការព្យាយាមស្រឡាញ់សមាជិកគ្រួសារយើង នោះជីវិតរបស់យើងនឹងក្លាយជាដំណើរនៃការរុករកដែលមិនចេះចប់ ក្នុងសុភមង្គលនៃជីវិតគ្រួសារជាមិនខាន។ យើងមិនអាចប៉ាន់ស្មានហួសប្រមាណនូវកេរ្តិ៍ដំណែលនៃទង្វើជាច្រើននៃសេចក្តីសប្បុរសដែលមានការលះបង់ និងការគិតគូរនៅក្នុងគ្រួសារ។ មានអំណរ និងសន្តិសុខយ៉ាងអស្ចារ្យនៅពេលដែលយើងដឹងថា សមាជិកគ្រួសារពិតជាស្រឡាញ់គ្នាទៅវិញទៅមក ហើយចង់បានអ្វីដែលល្អបំផុតសម្រាប់គ្នាទៅវិញទៅមកដែរ។

# ៥

# ការស្រឡាញ់គ្នាផ្នែកផ្លូវភេទ

នៅពេលដែលយើងនិយាយអំពីសេចក្តីស្រឡាញ់ ក្នុងសម័យដែលវប្បធម៌ផ្តោតយ៉ាងខ្លាំងទៅលើផ្នែកផ្លូវភេទ ភ្លាមនោះគេក៏គិតអំពីការរួមដំណេក។ ទោះបីជាយ៉ាងណាក៏ដោយ គួរឲ្យសោកស្តាយណាស់ដែលនៅពេលគេនិយាយអំពីការមានអំណរខាងឯផ្នែកផ្លូវភេទ ពួកគេមិនបានគិតអំពីទំនាក់ទំនងរវាងប្តី និងប្រពន្ធនោះទេ។ លោក ភីលីព រ៉ៃយកិន (Philip Ryken) បានលើកឡើងជាសម្រង់សម្តីអំពីការស្រាវជ្រាវមួយចំនួន ដែលបង្ហាញថា «ជាមួយនឹងការជួបប្រទះ និងអត្ថន័យបញ្ឆិតបញ្ឆៀង ជាធម្មតាជនជាតិអាមេរិកទូទៅមើលរូបភាព ឬក៏វីដេអូផ្នែកផ្លូវភេទច្រើនជាង ១០.០០០ ដងក្នុងមួយឆ្នាំ»[១] គាត់បានមានប្រសាសន៍ថា «លើសពីមនុស្សម្នាក់ ក្នុងចំណោម១០នាក់ ដៃគូសម្តែងលើកញ្ញក់ទូរទស្សន៍មានការរួមដំណេកនៅក្រៅពីជីវិតអាពាហ៍ពិពាហ៍។»[២] ផលិតករផ្នែកទូរទស្សន៍ម្នាក់បានពន្យល់អំពីមូលហេតុនៃការមានឈុតឆាកនៃការរួមដំណេកនៅក្នុងប៉ុស្តិ៍ទូរទស្សន៍ ដែលជាទូទៅគឺរវាងដៃគូសម្តែងដែលមិនទាន់បានរៀបការថា «តួសម្តែងដែលបានរៀបការហើយ ឬក៏នៅលីវមិនសូវជាសប្បាយប៉ុន្មានទេ។»[៣] នៅពេលដែលគេបានសម្ភាសន៍សិល្បៈការិនីម្នាក់ដែលជាជនជាតិឥណ្ឌា គាត់បានឆ្លើយថា «ការមានប្តី ឬក៏ប្រពន្ធតែមួយគឺជា

រឿងចម្លែកណាស់។ ការមានតែមួយ គឺគួរឲ្យធុញទ្រាន់ណាស់។»[៤]

ការឆ្លើយតបរបស់យើងចំពោះផ្នត់គំនិតបែបនេះត្រូវតែមិនមែនជាការមើលស្រាលលើតម្លៃនៃការរួមដំណេកនៅក្នុងចំណងអាពាហ៍ពិពាហ៍នោះឡើយ ប៉ុន្តែគឺការមើលអំពីការណែនាំនៅក្នុងព្រះគម្ពីរអំពីការរួមដំណេកនេះ។ ព្រះគម្ពីរបានបង្ហាញពីចំណុចដ៏សំខាន់មួយក្នុងការរួមដំណេក ហើយឃើញពីតម្លៃវាថាជាការបង្ហាញអំពីសេចក្តីស្រឡាញ់ដ៏សំខាន់មួយរវាងប្តី និងប្រពន្ធ។

## មូលហេតុដែលព្រះជាម្ចាស់បង្កើតការរួមដំណេក

ខណៈពេលដែលខ្ញុំមិនមានបំណងវែកញែកឲ្យស៊ីជម្រៅ ទាក់ទងនឹងការរួមដំណេកក្នុងជីវិតអាពាហ៍ពិពាហ៍ក្នុងសៀវភៅនេះ វាក៏ជារឿងល្អក្នុងការសង្ខេបមូលហេតុមួយចំនួនដែលព្រះគម្ពីរបានលើកឡើងអំពីការរួមដំណេកដែរ។ យើងអាចលើកឡើងនូវមូលហេតុ៥យ៉ាងដូចតទៅ៖

មូលហេតុដែលច្បាស់លាស់ជាងគេគឺជាការបង្កើតកូនចៅ។ បទបញ្ញត្តិមុនគេបង្អស់ដែលព្រះអាទិករបានបង្គាប់ទៅកាន់មនុស្សលោកគឺថា «ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ» (លោកុប្បត្តិ ១:២៨)។ នៅក្នុងការពិភាក្សារបស់យើងអំពីកូនៗនៅក្នុងជំពូក១០ យើងនឹងបង្ហាញអំពីចំណុចសំខាន់ទាក់ទងទៅនឹងទំនួលខុសត្រូវនេះ និងអំពីការដែលឲ្យតម្លៃលើភាពងាយស្រួលសព្វថ្ងៃនេះបាននាំឱ្យមនុស្សជាច្រើនទទួលស្គាល់ថា ការចិញ្ចឹមកូនគឺជាអ្វីដែលធ្វើឲ្យមានការរំខាន។

មូលហេតុទីពីរទាក់ទងនឹងការរួមដំណេកគឺថា វាជាគំនិតគន្លឹះនៃការរួបរួមគ្នារវាងប្តី និងប្រពន្ធ។ នៅពេលព្រះជាម្ចាស់បង្កើតអាពាហ៍ពិពាហ៍ ព្រះអង្គបានមានបន្ទូលថា «ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ» (លោកុប្បត្តិ ២:២៤)។ ប្រយោគមួយនេះដែលថា អ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធគឺជាការបញ្ជាក់អះអាងនៃការរួបរួមគ្នាខាងឯ

ផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍ ហើយមានលើកឡើងចំនួន៦ដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (ម៉ាថាយ ១៩:៥-៦; ម៉ាកុស ១០:៧-៨; ១កូរិនថូស ៦:១៦; អេភេសូរ ៥:៣១)។ នេះជាការសង្កត់ធ្ងន់ឲ្យដឹងថា ការរួបរួមគ្នាខាងឯផ្លូវភេទមានសារៈសំខាន់ខ្លាំងណាស់ក្នុងជីវិតអាពាហ៍ពិពាហ៍។ ប្រសិនបើទំនាក់ទំនងខាងឯផ្លូវភេទមានន័យថាជាការរួបរួម នោះវាមិនមែនជាអ្វីមួយដែលគួរប្រញាប់ធ្វើពេកនោះទេ។ គូស្រករមួយមិនពិតជាអាចមានភាពតែមួយដ៏ប្រាកដខាងឯរូបកាយបាននោះទេ ប្រសិនបើពួកគេមិនមានគំនិត និងវិញ្ញាណតែមួយសិន។ ដូច្នេះ ការសន្ទនាគ្នាយូរៗគឺជាគន្លឹះដំបូងមួយក្នុងការចូលទៅក្នុងទំនាក់ទំនងផ្នែកផ្លូវភេទ។ ត្រូវមានការចំណាយពេលវេលានិយាយគ្នា ដើម្បីឲ្យស្គាល់អំពីអ្វីដែលបានកើតឡើងក្នុងជីវិតរៀងៗខ្លួន។ លំដាប់លំដោយដំបូងគឺមានភាពតែមួយជាមួយគ្នាផ្នែកចិត្តគំនិត និងវិញ្ញាណ បន្ទាប់មកការមានភាពតែមួយផ្នែករូបកាយ។ តាមពិតទៅ ការរួមដំណេកលើកទឹកចិត្តឲ្យមានការរួបរួមគ្នា។ ដោយដឹងថា ពួកគាត់មិនពិតជាអាចមានអំណរផ្នែកផ្លូវភេទបានដោយមិនមានការរួបរួមគ្នា ដូច្នេះយើងអាចលើកទឹកចិត្តគូស្រករឲ្យព្យាយាមមានការរួបរួមគ្នាដោយទទួលបានការជំរុញតាមរយៈទស្សនីយភាពនៃទំនាក់ទំនងផ្នែកផ្លូវភេទ។

មូលហេតុទីបីក្នុងការរួមដំណេកគឺថាវាជាការផ្តល់ឲ្យ និងការទទួលយកពីគ្នាទៅវិញទៅមក។ ការពិភាក្សាអំពីការរួមដំណេកនៅក្នុងកណ្ឌគម្ពីរសុភាសិត និងបទចម្រៀងសាឡូម៉ូនបានបង្ហាញថា សេចក្តីស្រឡាញ់គឺជាការផ្តល់ឲ្យ និងជាការទទួលបាននៅពេលរួមដំណេក។ គូស្រករចេះរៀនពីរបៀបនាំឲ្យមានអំណរដល់គ្នាទៅវិញទៅមក។ ម្នាក់ៗចេះយល់ចិត្តគ្នាទៅលើអ្វីដែលម្ខាងចូលចិត្ត និងអ្វីដែលម្ខាងទៀតមិនចូលចិត្ត។ ពួកគាត់និយាយគ្នាអំពីការនោះ ហើយស្វែងរករបៀបដែលពួកគាត់អាចផ្តល់ក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមកបាន។ ការរួមដំណេកគឺជាការមានអំណរនៅពេលដែលម្នាក់មានអំណរ ហើយម្នាក់នោះក៏នាំឲ្យមានអំណរដល់ម្នាក់ទៀតផងដែរ។ សេចក្តីស្រឡាញ់គឺមិនមែនជាការប្រព្រឹត្តតែម្ខាងនោះទេ។ វាមានភាពពេញលេញនៅពេលដែលទាំងសង

ខាងមានការចែកចាយសេចក្ដីអំណរជាមួយគ្នាទៅវិញទៅមក។

មូលហេតុទីបួនក្នុងការរួមដំណេកគឺថា វាជាការទទួលបានអារម្មណ៍រីករាយខាងឯរាងកាយ។ ភាពខ្មាសអៀនលើចំណុចនេះបាននាំឲ្យមនុស្សមួយចំនួនមើលជាចម្បងលើកណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនថាជារឿងប្រៀបប្រដូចដែលពណ៌នាអំពីទំនាក់ទំនងរបស់មនុស្សជាមួយនឹងព្រះជាម្ចាស់។ ខណៈពេលដែលបុគ្គលម្នាក់អាចអានកណ្ឌគម្ពីរនេះក្នុងរបៀបនោះបាន ក៏នេះមិនមែនជាគោលបំណងចម្បងនៃកណ្ឌគម្ពីរនេះផងដែរ។ ក្នុងសៀវភៅបកស្រាយច្បាស់លាស់អំពី «ការរួមដំណេក ការចែចង់ និងសិរីល្អរបស់ព្រះជាម្ចាស់» (“Sex, Romance, and the Glory of God”) និពន្ធដោយលោកគ្រូ ស៊ី. ចេ. ម៉ាហេនី (C. J. Mahaney) គាត់បានពណ៌នាកណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនថាជា «ការរៀបរាប់អស់ប្រាំបីជំពូកអំពីការជប់លៀង ដែលពុំមានការត្រួតពិនិត្យការទប់ចិត្ត អំណរនៃការជ្រមុជក្នុងពាក្យពេចន៍ និងខាងឯសាច់ឈាមនៃការបង្ហាញភាពឆេះឆួលរវាងមនុស្សប្រុស និងមនុស្សស្រី»។[៥] ប្រធានបទនេះត្រូវតែជាប្រធានបទដ៏សំខាន់ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធបានបណ្ដាលឲ្យតែងសៀវភៅដ៏វែងមួយ ហើយបានដាក់បញ្ចូលក្នុងព្រះគម្ពីរ។ គ្រីស្ទបរិស័ទត្រូវតែរៀនមើលទៅឯការរួមដំណេកថាជាភាពបរិសុទ្ធខាងឯព្រលឹងវិញ្ញាណ និងទង្វើខាងឯរូបកាយដែលគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់។

ខណៈពេលដែលគ្រីស្ទបរិស័ទជាច្រើនចាត់ទុកការនិយាយបែបនេះថាជាការមិនសមរម្យ ជាពិសេសសម្រាប់មនុស្សស្រី យើងអាច ហើយគួរតែបញ្ជាក់ថា បំណងប្រាថ្នាក្នុងការរួមដំណេកគឺជារឿង។ ជាការពិតណាស់ អ្នកនៅលីវត្រូវតែរៀនក្នុងការគ្រប់គ្រងអារម្មណ៍ក្នុងការមានចំណង់មួយនេះ។ គូស្រករដែលបានរៀបការរួចហើយចាប់ផ្ដើមដំណើរលើវិថីនៃការរៀនផ្ដល់ឲ្យការស្កប់ចិត្តជាមួយនឹងបំណងប្រាថ្នារបស់គ្នាទៅវិញទៅមក និងជាការស្វែងរកការស្កប់ចិត្តយ៉ាងពេញទីតែជាមួយគ្នាទៅវិញទៅមកប៉ុណ្ណោះ។

ការរក្សាទុកទស្សនៈតាមព្រះគម្ពីរលើការស្រឡាញ់គ្នាផ្នែកផ្លូវភេទ គឺជា

ចំណុចដ៏ពិបាកមួយក្នុងពេលបច្ចុប្បន្ននេះ។ វប្បធម៌ផ្តល់ជូននូវគំនិតនៃការមានអំណរក្នុងការរួមដំណេកក្នុងរបៀបដែលគូស្រករជាច្រើនមិនអាចទទួលយកបាន។ បណ្ដាញសង្គមផ្ដល់អត្ថន័យលើការរួមដំណេក ដោយផ្ដោតលើអត្តចរិតខាងឯរូបកាយ ដែលមនុស្សជាច្រើននាក់មិនអាចឈោងដល់។ ដូច្នេះយើងមានការជ្រើសរើសប្រចាំឆ្នាំសម្រាប់បុរសដែលសង្ហាជាងគេ និងនារីដែលស្អាតជាងគេ។ ភាគច្រើន ប្ដីឬក៏ប្រពន្ធរបស់យើងនឹងមិនរាប់ចូលក្នុងតារាងឈ្មោះនោះទេ។ ប៉ុន្តែ ជំនឿគ្រីស្ទបរិស័ទបង្រៀនយើងថា ការមានអំណរដ៏ពេញលេញនៃការរួមដំណេកគឺរវាងមនុស្សដែលមានការប្ដេជ្ញាចិត្តចំពោះគ្នាទៅវិញទៅមកអស់មួយជីវិត។ ការប្ដេជ្ញានោះផ្ដល់ឲ្យពួកគាត់នូវសេរីភាពក្នុងការផ្ដល់ឲ្យពួកគាត់មានអំណរយ៉ាងពេញទីបាន។ ជាទូទៅ ការអនុវត្តជាក់ស្ដែងគឺឲ្យមនុស្សរៀបចំខ្លួនឲ្យបានស្រស់ស្អាត នៅពេលដែលពួកគាត់ចេញទៅក្រៅផ្ទះតែប៉ុណ្ណោះ។ ដូច្នេះ មនុស្សជាច្រើនមិនសូវខ្វល់ខ្វាយ ជាពិសេសអំពីសណ្ឋានរបស់ខ្លួនឯង នៅពេលដែលពួកគាត់នៅផ្ទះ។ សេចក្ដីបង្រៀននៅក្នុងកណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូន និងកណ្ឌគម្ពីរសុភាសិតគឺថា ហេតុផលដ៏ចម្បងមួយក្នុងការមានភាពស្រស់ស្អាតគឺជាការផ្គាប់ចិត្តប្ដី ឬប្រពន្ធខ្លួន។

ខ្ញុំចាំអំពីពេលខ្ញុំបានអានអត្ថបទមួយដែលនិយាយអំពីភាពលំបាករបស់តារាបង្ហាញម៉ូតក្នុងការមានសុភមង្គលនៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់។ នៅក្នុងអត្ថបទនោះបានលើកឡើងថា ពួកគាត់ផ្ដោតយ៉ាងខ្លាំងទៅលើការសម្ដែងពីភាពសិចស៊ីរបស់ខ្លួននៅមុខអ្នកដទៃ ដែលវាពិបាកសម្រាប់ពួកគាត់ក្នុងការប្រព្រឹត្តិក្នុងរបៀបដែលមានសេចក្ដីស្រឡាញ់យ៉ាងពិតប្រាកដជាប្ដី ឬប្រពន្ធរបស់ខ្លួន។ ការបំពេញយ៉ាងជ្រាលជ្រៅបំផុតនៅក្នុងជំនឿរបស់គ្រីស្ទបរិស័ទគឺតាមរយៈទំនាក់ទំនងនៃការប្ដេជ្ញាចិត្ត។ គ្រីស្ទបរិស័ទត្រូវតែមានការដាក់វិន័យលើខ្លួនឯងផ្ទាល់ ក្នុងការរក្សាការមានអំណរខាងឯផ្លូវភេទនៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនតែប៉ុណ្ណោះ។

ជាច្រើនឆ្នាំមុន នៅក្នុងដំណើរហោះហើរត្រឡប់មកផ្ទះវិញ ខ្ញុំបានមើល

ភាពយន្តមួយសម្តែងដោយតារាស្រីម្នាក់ដែលមានឈ្មោះថា ចិនីហ្វ័រ ឡូផាស៍ (Jennifer Lopez)។ ខ្ញុំបានប្រាប់កូនប្រុសធំទង់របស់ខ្ញុំនៅកាលនោះថា “អ្នកនាង ចិនីហ្វ័រ ឡូផាស៍ ស្អាតខ្លាំងណាស់”។ គាត់បានសើច ហើយនិយាយថា “មនុស្សប្រុសរាប់លាននាក់នៅជុំវិញពិភពលោកនេះនឹងយល់ស្របជាមួយប៉ាលើចំណុចនេះ!” បន្ទាប់មក ខ្ញុំបានប្រាប់គាត់ថា “ប៉ុន្តែ នៅពេលប៉ាភ្ញាក់ពីគេង គ្មាននរណាម្នាក់ដែលប៉ាចង់ឃើញខ្លាំងជាងម៉ាក់របស់កូននោះទេ”។ ពិតណាស់! នៅលើផែនដីនេះមានមនុស្សស្អាតលើសពីធម្មតាមួយចំនួនមែន។ ប៉ុន្តែ យើងរៀនស្វែងរកភាពស្រស់ស្អាតបំផុតនៅក្នុងប្តី ឬក៏ប្រពន្ធរបស់យើង។ ខ្ញុំគិតថា គ្រីស្ទបរិស័ទដែលបានរៀបការហើយគួរតែសួរខ្លួនឯងថា “តើខ្ញុំបានប្រាប់ប្តី ឬប្រពន្ធរបស់ខ្ញុំអំពីគំនិតដែលខ្ញុំឃើញថា គាត់ជាម្នាក់ដែលពិតជាស្រស់ស្អាតហើយឬនៅ?” ប្រសិនបើប្តី ឬប្រពន្ធរបស់យើងមិនឃើញថា យើងគិតថាគាត់ស្រស់ស្អាតនោះទេ គឺយើងទេដែលជាអ្នកបរាជ័យ មិនមែនគាត់ឡើយ។

កណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនបានបង្ហាញថាបុរស និងស្ត្រីសញ្ជឹងគិតពិចារណាទៅលើរូបរាងកាយរបស់ប្តី ឬប្រពន្ធរបស់ខ្លួន ហើយបង្ហាញជាផ្លែផ្កានៃការគិតនោះចេញជាពាក្យសម្តី។ សូមពិនិត្យមើលការសញ្ជឹងគិតរបស់ប្តីនៅខាងក្រោមនេះ៖

> “ឱមាសសម្លាញ់អើយ ឯងស្រស់របស់ល្អ ហើយប្រិមប្រិយ គួររីករាយណាស់ហ្ន៎ កម្ពស់ឯងដូចជាដើមលម៉ើ ហើយដោះឯងដូចជាចង្កោមផ្លែលម៉ើ អញបានថា អញនឹងឡើងដើមនោះ អញនឹងចាប់ធាងតោងឡើង សូមឲ្យដោះឯងបានដូចជាចង្កោមទំពាំងបាយជូរ ហើយក្លិនខ្យល់ដង្ហើមឯងបានដូចជាផ្លែសារី និងមាត់ឯងក្រអូបដូចជាស្រាទំពាំងបាយជូរយ៉ាងឯក” (បទចម្រៀងសាឡូម៉ូន ៧:៦-៩)។

ហើយនេះជាការសញ្ជឹងគិតរបស់ប្រពន្ធ៖

> “ស្ងួនសម្លាញ់របស់ខ្ញុំសប្បុរស មានថ្ពាល់ក្រហម ទ្រង់ជាឯកអង្គក្នុងពួក១ម៉ឺន

> នាក់ ព្រះសិរទ្រង់ល្អ ដូចជាមាសនព្វគុណ ព្រះកេសាទ្រង់រំកាញ់ ហើយខ្មៅដូចសារិកា ព្រះនេត្រទ្រង់ដូចជាព្រាបនៅមាត់ផ្លូវទឹក ដែលលាងដោយទឹកដោះ ហើយដាំក្នុងគ្រោង យ៉ាងសមល្អ ព្រះគណ្ឌៈទ្រង់ដូចជាទីដាំគ្រឿងក្រអូប ដូចជាដំណាំស្មៅមានក្លិនផ្អែមព្រះរឹមទ្រង់ដូចជាផ្កាកំភ្លឹងដែលស្រក់ទឹកក្រអូប ព្រះហស្តទ្រង់ដូចជាចិញ្ចៀនមាសដាំដោយត្បូងបេរីល ព្រះកាយទ្រង់ដូចជារចនាភ្លុកស្រោបដោយនិលរ័តន៍ ព្រះបាទទ្រង់ដូចជាសសរថ្មកែវ តម្កល់នៅលើជើងមាសនព្វគុណ ឯភាពទ្រង់មានលំអដូចជាភ្នំល្បាណូន វិសេសដូចជាដើមតាត្រៅ ព្រះឱស្ឋទ្រង់ក៏ផ្អែមក្រអូប អើ ទ្រង់គួរស្រឡាញ់ពេញទីហើយ ឱពួកកូនស្រីក្រុងយេរូសាឡិមអើយ នេះហើយជាស្ងួនសម្លាញ់ ហើយជាភឿនជីវិតរបស់ខ្ញុំ» (បទចម្រៀងសាឡូម៉ូន ៥:១០-១៦)។

ជាការពិតណាស់ ការលើកឡើងខាងលើនេះបង្ហាញឲ្យយើងដឹងថា យើងត្រូវតែរៀបចំខ្លួនឲ្យបានល្អសម្រាប់ប្តី ឬប្រពន្ធរបស់យើង។ បទគម្ពីរមុនហ្នឹងបានលើកឡើងអំពី «ក្លិនខ្យល់ដង្ហើមឯងបានដូចជាផ្លែសារី នឹងមាត់ ឯងក្រអូបដូចជាស្រាទំពាំងបាយជូរយ៉ាងឯក»។ ប្រសិនបើនេះជាការពិត នេះមានន័យថាយើងត្រូវតែដុសសម្អាតធ្មេញយើងឲ្យបានស្អាតដែរ! ការសម្អាតខ្លួនឲ្យបានស្អាតបាតគឺជាគន្លឹះសំខាន់នៃទំនាក់ទំនងខាងឯផ្លូវភេទ!

មូលហេតុទីប្រាំនៃទំនាក់ទំនងនឹងការរួមដំណេកគឺថា វាជាកញ្ចក់ឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរបស់យើងជាមួយព្រះគ្រីស្ទ។ បន្ទាប់ពីបានលើកឡើងឃ្លាដែលថា «ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១វិញ» (អេភេសូរ ៥:៣១) នៅក្នុងចំណងជីវិតអាពាហ៍ពិពាហ៍ហើយ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «សេចក្តីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រីស្ទ និងពួកជំនុំវិញ» (ខ៣២)។ នៅពេលសាវ័ក ប៉ុល ប្រើប្រាស់ពាក្យ «សេចក្តីអាថ៌កំបាំង» គឺគាត់កំពុងតែនិយាយអំពីអ្វីដែលបានលាក់បាំង ដែលឥឡូវនេះបានបើកសម្តែងនៅក្នុងដំណឹងល្អ។ គាត់កំពុងលើកឡើងថា មានអ្វីមួយដែលអស្ចារ្យអំពីជម្រៅនៃភាពរួមគ្នាតែមួយ ដែលយើងមានជាមួយព្រះ

គ្រីស្ទ។ ការបើកបង្ហាញមួយអំពីចំណុចនេះគឺការរួបរួមគ្នាខាងឯសាច់ឈាម រវាងមនុស្សប្រុស និងប្រពន្ធរបស់គាត់។ មានចំណុចស្រដៀងគ្នាជាច្រើន ក្នុងទំនាក់ទំនងទាំងពីរប្រភេទនេះ។ ទាំងពីរមានការបើកចំហ ភក្ដីភាពទាំងស្រុង ការផ្ដល់ជូន និងការទទួលយក ការយោគយល់ ទំនាក់ទំនង និងសេចក្ដីស្រឡាញ់ដែលមានភាពរីករាយ។ វាមិនមែនជារឿងចៃដន្យនោះទេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលគេប្រើពាក្យស្គាល់ សំដៅទៅលើការស្គាល់ព្រះជាម្ចាស់ (១សាំយ៉ូអែល ៣:៧; យេរេមា ៣១:៣៤) និងសម្រាប់ទំនាក់ទំនងខាងឯផ្លូវភេទដែរ (ឧទាហរណ៍៖ សូមមើលនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៤:១, ១៧)។ យោងតាមព្រះគម្ពីរ របៀបមួយដែលមនុស្សយើងអាចចាប់ផ្ដើមយល់អំពីទំនាក់ទំនងរវាងព្រះជាម្ចាស់ (និងព្រះគ្រីស្ទ) និងគ្រីស្ទបរិស័ទ គឺតាមរយៈការមើលទៅកាន់ប្ដី-ប្រពន្ធដែលមានទំនាក់ទំនងល្អជាមួយគ្នា។

## ការស្រឡាញ់គ្នាខាងផ្នែកផ្លូវភេទផ្ដល់នូវសុវត្ថិភាព ក្នុងទំនាក់ទំនងជីវិតអាពាហ៍ពិពាហ៍

កណ្ឌគម្ពីរ១កូរិនថូសជំពូក៧បានពិភាក្សាអំពីបញ្ហាជាច្រើន ទាក់ទងទៅនឹងជីវិតអាពាហ៍ពិពាហ៍។ ប្រាំពីរខដំបូងនិយាយអំពីបញ្ហាដែលគូស្រករមាន ក្នុងការរក្សាទំនាក់ទំនងផ្នែកផ្លូវភេទ។ ខ៣បានលើកឡើងថា «ត្រូវឲ្យប្ដីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស [ខាងឯផ្នែកផ្លូវភេទ] ហើយត្រូវឲ្យប្រពន្ធប្រព្រឹត្តនឹងប្ដីក៏ដូច្នោះដែរ»។ សាវ័ក ប៉ុល បានលើកឡើងទៅកាន់អស់អ្នកដែលកំពុងមានបំណងក្នុងការឈប់មានទំនាក់ទំនងផ្នែកផ្លូវភេទ ដើម្បីឲ្យបានចំណាយពេលអធិស្ឋាន ដោយលើកឡើងថា «ដូច្នេះ កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល ដើម្បីឲ្យបានជាទំនេរនឹងអធិស្ឋាន» (ខ៥ ក)។ ប៉ុន្ដែ ដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍ ការនេះគឺសម្រាប់តែពេលវេលាកំណត់មួយតែប៉ុណ្ណោះ។ គាត់បន្តរៀបរាប់ថា «រួចត្រូវវិលមកនៅជាមួយគ្នាវិញ ក្រែងអារក្សសាតាំងល្បួងលួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ» (ខ៥ ខ)។ ចំណុច

បញ្ចិតបញ្ចៀងគឺថា គូស្រករដែលមិនមានការរួមដំណេកទៀងទាត់ទំនងជាកំពុងតែដាក់ខ្លួនក្នុងកន្លែងដែលមិនចាំបាច់ ដែលងាយធ្លាក់ក្នុងសេចក្តីល្បួងនៃការប្រព្រឹត្តអំពើកំផិត។

ខ្ញុំគិតថា សព្វថ្ងៃនេះមានមនុស្សតិចណាស់ដែលជៀសវាងចេញពីការមានទំនាក់ទំនងផ្នែកផ្លូវភេទ ពីព្រោះពួកគាត់ចង់ចំណាយពេលតែឯងក្នុងការអធិស្ឋាន។ ហេតុផលទូទៅមួយទៀតក្នុងការមិនមានទំនាក់ទំនងផ្នែកផ្លូវភេទគឺភាពមមាញឹក និងការអស់កម្លាំង។ វាមានការពិបាកណាស់ក្នុងការដោះស្រាយបញ្ហានេះ ដោយសារយើងកំពុងតែរស់នៅក្នុងពិភពលោកដែលជឿនលឿន។ អ្នកខ្លះសម្រេចចិត្តមើលរូប ឬក៏វីដេអូអាសអាភាសជំនួស។ ការធ្វើបែបនោះមិនសូវមានការទាមទារប៉ុន្មាន ទាក់ទងទៅនឹងចំណង់អារម្មណ៍ ប៉ុន្តែនាំឲ្យមានការបំផ្លាញសុភមង្គលក្នុងជីវិតអាពាហ៍ពិពាហ៍។ មនុស្សដែលរវល់តែងតែយកចិត្តទុកដាក់ដោយផ្តល់អាទិភាពលើទំនាក់ទំនងខាងឯផ្លូវភេទក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់។ តាមមធ្យោបាយយ៉ាងណាមួយ យើងតែងតែញែកពេលវេលាសម្រាប់អ្វីដែលយើងរាប់ថាសំខាន់។

ដោយបានប្រើប្រាស់ភាសាជាក់ស្តែងមួយចំនួន កណ្ឌគម្ពីរ សុភាសិត ៥:១៥-២០ បានបង្ហាញពីរបៀបមួយដែលបុរសត្រូវគេចចេញពីការមានសេចក្តីកំផិតគឺ ការស្វែងរកការស្កប់ចិត្តផ្នែកផ្លូវភេទជាមួយ «ប្រពន្ធដែលបានគ្នាពីកាលក្រមុំកំលោះ»៖

«ចូរផឹកទឹកពីពាងរបស់ខ្លួនឯង
  ព្រមទាំងទឹកដែលហូរចេញពីអណ្តូងរបស់ខ្លួនចុះ

តើគួរឲ្យរន្ធទឹកឯងហូរសាចចេញទៅក្រៅ
  ហើយគន្លងទឹកឯងហូរទៅក្នុងផ្លូវឬអី

ត្រូវឲ្យទុកសម្រាប់ខ្លួនឯងតែ១ប៉ុណ្ណោះ
  មិនមែនសម្រាប់មនុស្សដទៃជាមួយនឹងឯងផងនោះទេ

សូមឲ្យរន្ធទឹកឯងបានពរ
ចូរឲ្យឯងបានរីករាយចំពោះប្រពន្ធដែលបានគ្នាពីកាលក្រមុំកំលោះចុះ
ប្រៀបដូចជាក្តាន់ញីដែលគួរស្រឡាញ់ នឹងប្រើសញីសមសួន

ត្រូវឲ្យដោះរបស់នាងបានបំពេញចិត្តឯងជាដរាប
ហើយត្រូវឲ្យឯងឈ្លក់ចិត្តនឹងសេចក្តីស្រឡាញ់របស់នាងជានិច្ចផង

ដ្បិតកូនអើយ តើមានទំនងឲ្យឯងទៅឈ្លក់ចិត្តចំពោះស្រីដទៃ
ហើយឱបទ្រូងនៃស្ត្រីក្រៅឬអី»។

នេះគឺជាហេតុផលមួយដែលខ្ញុំមិនគាំទ្រឲ្យគូស្រកររស់នៅដាច់ឆ្ងាយពីគ្នាយូរ ដូចជាកើតមានឡើងនៅពេលដែលប្តី ឬប្រពន្ធចេញទៅប្រទេសក្រៅ ឬតំបន់ផ្សេង ដើម្បីធ្វើការងារ។ ចំពោះយើងរាល់គ្នាដែលធ្វើដំណើរច្រើន យើងគួរតែប្រុងប្រយ័ត្នកុំឲ្យមានការឃ្លាតឆ្ងាយពីគ្រួសាររបស់យើងយូរពេក។

មានគំនិតមួយនៅក្នុងចំណោមគ្រីស្ទបរិស័ទ សូម្បីតែគ្រីស្ទបរិស័ទដែលមានការប្តេជ្ញាចិត្តខ្លាំងដែរ គឺថានៅពេលដែលមានកូនពីរទៅបីនាក់ហើយ នោះពេលវេលាក្នុងការមានទំនាក់ទំនងផ្នែកផ្លូវភេទគឺជារឿងអតីតកាល។ ខ្ញុំស្គាល់គ្រួសារមួយចំនួនដែលបន្ទាប់ពីបានរៀបការដប់ទៅដប់ប្រាំឆ្នាំហើយ ប្រពន្ធក៏បានរើចេញពីបន្ទប់គេងជាមួយប្តី ហើយទៅគេងជាមួយកូនៗវិញ។ គាត់បដិសេធក្នុងការមានទំនាក់ទំនងផ្នែកផ្លូវភេទជាមួយនឹងប្តីរបស់គាត់។ នេះគឺជាការបំពានគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតអាពាហ៍ពិពាហ៍—ឬយើងអាចហៅការនេះបានថាជាទំនាក់ទំនងមិនបរិសុទ្ធ ឬទំនាក់ទំនងមិនកោតខ្លាចព្រះ។

នៅក្នុងបទគម្ពីរដែលយើងបានដកស្រង់ឡើងពីកណ្ឌគម្ពីរសុភាសិតខាងលើនេះ អ្នកនិពន្ធបានលើកទឹកចិត្តឲ្យបុរសដែលមានវ័យចំណាស់មានការអរសប្បាយជាមួយនឹងរូបកាយរបស់ «ប្រពន្ធដែលបានគ្នាពីកាលក្រមុំកំលោះចុះ» (៥:១៨). ឃ្លាដែលថា «ត្រូវឲ្យដោះរបស់នាងបានបំពេញចិត្តឯងជាដរាប ហើយត្រូវឲ្យឯងឈ្លក់ចិត្តនឹងសេចក្តីស្រឡាញ់របស់នាងជានិច្ចផង» (ខ១៩)

បានបង្ហាញដូចដែលលោក ប្រូស៍ វុលគី (Bruce Waltke) បានចង្អុលបង្ហាញថា «គុណភាពនៃសកម្មភាពផ្នែកផ្លូវភេទរបស់គាត់តែងតែមានការស្កប់ស្កល់ចិត្ត»។[៦] គ្រប់គូស្រករទាំងអស់គួរតែមានគោលដៅបែបនេះនៅក្នុងទំនាក់ទំនងរបស់ខ្លួន។ យោងតាមកណ្ឌគម្ពីរសុភាសិត លទ្ធផលមួយនៃការមានអំណរបែបនោះ គឺការមានសន្តិភាពទាស់ប្រឆាំងនឹងទំនាក់ទំនងដែលមិនស្របច្បាប់។

ព្រះគម្ពីរបានពណ៌នារហូតទៅដល់បួនដងអំពីចំណងជីវិតអាពាហ៍ពិពាហ៍ពេលដែលប្ដីប្រកាន់ភ្ជាប់ («នៅជាប់») ជាមួយនឹងប្រពន្ធរបស់គាត់ (លោកុប្បត្តិ ២:២៤; ម៉ាថាយ ១៩:៥; ម៉ាកុស ១០:៧; អេភេសូរ ៥:៣១)។ នៅក្នុងភាសាក្រិកដែលគេបកប្រែថា «នៅជាប់»[៧] មានន័យថា «ការតោង ការបិទជំរការ ការចាក់សាប»។ ក្នុងខយោងទាំងអស់នេះ បន្ទាប់ពីបានលើកឡើងថា «ទៅនៅជាប់នឹងប្រពន្ធ» ខគម្ពីរបានបន្តថែងថា «ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១វិញ»។ ដូចលោកគ្រូ លីអូន ម៉ូរិស៍ (Leon Morris) បានមានប្រសាសន៍ «នេះសំដៅទៅលើសកម្មភាពផ្នែកផ្លូវភេទ ដែលនាំឲ្យប្ដី និងប្រពន្ធមានការរួបរួមគ្នាក្នុងរបៀបដែលស្និទ្ធស្នាលបំផុត»។[៨] ការរួបរួមគ្នាផ្នែកផ្លូវភេទគឺជាគ្រឿងផ្សំគន្លឹះមួយនៃជំរការ ឬក៏ស៊ីម៉ង់ដែលចងភ្ជាប់គូស្រករជាមួយគ្នា។

ពីមុន គេបានចាត់ទុកភាពត្រេកត្រអាលថាជាបញ្ហាចម្បងមួយ ដែលបុរសតយុទ្ធ។ ការនោះត្រូវបានបង្ហាញថាជាការមិនត្រឹមត្រូវ—វាក៏ជាបញ្ហាសម្រាប់ស្ត្រីផងដែរ។[៩] ក្នុងព័ន្ធកិច្ចរបស់យើង ប្រុសៗដែលមានវ័យក្មេងមួយចំនួនបាននិយាយអំពីការដែលស្ត្រីវ័យចំណាស់មួយចំនួនបានប្រើប្រាស់ពួកគាត់ខាងឯផ្នែកផ្លូវភេទ។ ប៉ុន្តែ ជាទូទៅប្រពន្ធជាច្រើននាក់មិនយល់អំពីចំណុចសំខាន់ទាក់ទងទៅនឹងផ្នែកផ្លូវភេទចំពោះមនុស្សប្រុស។ ក្នុងសៀវភៅដែលជះឥទ្ធិពលរបស់គាត់ «តម្រូវការរបស់គាត់ តម្រូវការរបស់នាង៖ ការសង់ជីវិតអាពាហ៍ពិពាហ៍ដែលមិនមានការកំផិត» (“His Needs, Her Needs: Building

an Affair Proof Marriage") លោក វិលឡឺត អេហ្វ. ហ័រលី (Willard F. Harley Jr.) បានមានប្រសាសន៍ថា «ប្រពន្ធទូទៅមិនយល់អំពីជម្រៅនៃតម្រូវការរបស់ប្ដីគាត់ទាក់ទងនឹងផ្លូវភេទ ដូចដែលប្ដីទូទៅមិនយល់អំពីជម្រៅនៃតម្រូវការរបស់ប្រពន្ធគាត់ទាក់ទងនឹងការថ្នាក់ថ្នម»។[១០] នៅពេលដែលប្រពន្ធបដិសេធការសុំរបស់ប្ដីក្នុងការរួមដំណេក វាគឺជារឿងដ៏ធំមួយចំពោះគាត់ជាប្ដី។ មានគេបានប្រៀបធៀបថា វាដូចជាប្រពន្ធបានទះកំផ្លៀងគាត់អញ្ចឹង។ ប៉ុន្តែការនោះមិនបានអនុញ្ញាតឲ្យប្ដីទះកំផ្លៀងប្រពន្ធរបស់ខ្លួនជាការឆ្លើយតបវិញទេ។ នៅចុងបញ្ចប់ គ្រីស្ទបរិស័ទគឺជាអស់អ្នកដែលបែរថ្ពាល់ម្ខាងទៀតនៅពេលដែលគេទះកំផ្លៀង (ម៉ាថាយ ៥:៣៩)។ ប្ដីត្រូវតែយល់អារម្មណ៍ប្រពន្ធរបស់ខ្លួន ហើយក៏មិនត្រូវបង្ខំប្រពន្ធឲ្យធ្វើតាមចិត្តខ្លួនឯង។ ប៉ុន្តែ នៅពេលដែលប្ដីទទួលការបដិសេធពីប្រពន្ធរបស់ខ្លួនក្នុងការរួមដំណេក គាត់ក៏អាចស្ថិតនៅក្រោមសេចក្ដីល្បួងយ៉ាងធ្ងន់ធ្ងរដែរ។ ប្ដីត្រូវតែអធិស្ឋានឲ្យបានច្រើនដើម្បីយកឈ្នះលើការមួយនេះ។

ជារឿយៗ ប្ដីមិនបានគិតអំពី ឬថែចង់ប្រពន្ធរបស់ខ្លួននៅពេលថ្ងៃនោះទេ ហើយបន្ទាប់មក ស្រាប់តែសូមប្រពន្ធរបស់ខ្លួនរួមដំណេកនៅពេលយប់ភ្លាមៗ។ ប៉ុន្តែ អាកប្បកិរិយាបែបនេះមិនមែនជាការល្អក្នុងការរៀបចំសម្រាប់ការរួមដំណេកឡើយ ជាពិសេសសម្រាប់មនុស្សស្រី។ ទោះបើប្ដីអាចមានអារម្មណ៍ក្នុងរបៀបនេះក៏ដោយ ក៏មនុស្សស្រីទទួលបានការបំពេញតាមរយៈការថ្នាក់ថ្នមដែរ។ លោក អេច់. នូម៉ែន រិច បានលើកឡើងថា «ស្ត្រីមួយចំនួនបានត្អូញត្អែរថា ប្ដីរបស់ខ្លួនបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់ពួកគាត់តែនៅពេលដែលពួកគាត់ចង់រួមដំណេកប៉ុណ្ណោះ។ ការបង្ហាញសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់គួរតែកើតមានឡើងរៀងរាល់ថ្ងៃ មិនថាមានគោលបំណងក្នុងការរួមដំណេក ឬក៏អត់នោះទេ»។[១១]

## បញ្ហាបទពិសោធន៍ផ្នែកផ្លូវភេទ និងអាកប្បកិរិយា

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏បញ្ហានេះមិនមែនជារឿងសាមញ្ញដែរ។ ចំពោះស្ត្រីជាច្រើននាក់ ការរួមដំណេកមិនមែនជារឿងសប្បាយនោះទេ។ ប្រពន្ធរបស់ខ្ញុំបានប្រាប់ខ្ញុំថា ស្ត្រីមួយចំនួនដែលគាត់បានស្គាល់ បានពណ៌នាការរួមដំណេកដោយពាក្យពេចន៍ដូចជា “នៅពេលដែលប្ដីរបស់ខ្ញុំចង់រំខានខ្ញុំ...”។ ពួកគាត់រាប់វាថាជារឿងសៅហ្មង ដែលមិនផ្ដល់ជូនការស្កប់ស្កល់ចិត្តដល់ពួកគាត់សោះ។ ដោយកំពុងសំដៅទៅលើការរួមដំណេក ស្ត្រីដែលជាគ្រីស្ទបរិស័ទម្នាក់ធ្លាប់លើកឡើងថា “ប្ដីរបស់ខ្ញុំចាត់ទុកខ្ញុំដូចជាធុងដាក់សំរាមរបស់គាត់”។ ទោះបើជាយ៉ាងណាក៏ដោយ ក៏ព្រះគម្ពីរបានបង្ហាញអំពីទំនាក់ទំនងផ្នែកផ្លូវភេទថាជាអ្វីមួយដែលទាំងប្ដី និងប្រពន្ធមានភាពរីករាយជាមួយគ្នាដែរ។

គ្រីស្ទបរិស័ទជាច្រើនមិនបានចូលទៅកាន់ជីវិតអាពាហ៍ពិពាហ៍ដោយមានអាកប្បកិរិយាចំពោះការរួមដំណេកស្របតាមព្រះគម្ពីរនោះទេ។ នេះជាការដ៏សំខាន់ក្នុងការប្រាប់អំពីចំណុចនេះទៅកាន់យុវជនរបស់យើង។ ជារឿយៗពួកគាត់ទទួលបានព័ត៌មានដំបូងគេបំផុតទាក់ទងទៅនឹងការរួមដំណេកតាមប្រភពមកពីអ្នកមិនជឿ ដូច្នេះហើយបានជាគំនិតដែលពួកគាត់ទទួលបានក៏តែងតែមានភាពផ្ទុយគ្នាពីអ្វីដែលព្រះគម្ពីរបានលើកឡើងដែរ។ ហើយវាកាន់តែសំខាន់ជាងនេះទៅទៀតក្នុងការប្រាប់កូនៗរបស់យើងអំពីសេចក្ដីពិតដែលថា ប្រភេទនៃការបំពេញដ៏ពេញលេញនៃការមានទំនាក់ទំនងផ្នែកផ្លូវភេទគឺសម្រាប់មនុស្សតែពីរនាក់ដែលបានប្ដេជ្ញាចំពោះគ្នាទៅវិញទៅមក នៅក្នុងសេចក្ដីស្រឡាញ់អស់មួយជីវិតនេះ។ ការស្រាវជ្រាវបានបង្ហាញថា គូស្រករដែលបានរៀបការហើយ ជាពិសេសអ្នកដែលបានរៀបការអស់ជាច្រើនឆ្នាំ ភាគច្រើនមានការអរសប្បាយផ្នែកទំនាក់ទំនងខាងផ្លូវភេទច្រើនជាងអស់អ្នកដែលគ្រាន់តែរស់នៅជាមួយគ្នា។[១២] សព្វថ្ងៃនេះ ទោះជាយ៉ាងណាក៏ដោយក៏លោកីយ៍រាប់ការរួមដំណេកក្រៅចំណងអាពាហ៍ពិពាហ៍ថាជារឿងធម្មតា។ នោះគឺជាសារដែលយុវជនកំពុងតែទទួលបានពីវប្បធម៌ដែលពួកគាត់កំពុងតែរស់

នៅជាមួយ—ហើយអ័រម៉ូនរបស់ពួកគាត់ក៏ឯកភាពជាមួយដែរ! ខណៈពេលដែលយុវជនយើងកំពុងតែប្រឈមមុខនឹងបញ្ហាដ៏ធ្ងន់ធ្ងរដូចនេះពីលោកីយ៍ នោះក្រុមជំនុំក៏នឹងនាំឲ្យពួកគាត់បរាជ័យដ៏ធ្ងន់ធ្ងរដែរ ប្រសិនបើក្រុមជំនុំមិនបង្រៀនអ្វីដែលច្បាស់លាស់ និងទៀងទាត់លើបញ្ហានេះ។ ការផ្តល់ជាមតិយោបល់បន្ថែមពីលោក ដានីញ៉ែល ហៃមបាក់ (Daniel Heimbach) ក៏ស័ក្តិសមក្នុងការលើកឡើងម្តងទៀតដែរ៖

> គោលបំណងវិជ្ជមានដែលកំពុងតែប្រឈមមុខគឺហាក់បីដូចជាថា ការរួមដំណេកក្រៅចំណងជីវិតអាពាហ៍ពិពាហ៍ធ្វើឲ្យតម្លៃដ៏ថ្លៃនៃទំនាក់ទំនងផ្នែកផ្លូវភេទនៃភាពសម្រិតសំរាំង និងអត្តទត្ថបុគ្គលខូច ហើយចុងក្រោយត្រូវបំផ្លាញចោលទាំងស្រុង.... ការរួមដំណេកបែបកំផិតមិនអាចមានភាពសម្រិតសំរាំង និងអត្តទត្ថបុគ្គលនិយមទេ។ ក្នុងសភាពធម្មជាតិរបស់វា ការរួមដំណេកបែបកំផិត បដិសេធតម្លៃនៃការរក្សាការរួមដំណេកដែលមានភាពសម្រិតសំរាំង ហើយកើតឡើងតាមចំណាប់អារម្មណ៍អាត្មានិយម ដែលរារាំងទំនួលខុសត្រូវរបស់យើងក្នុងការតែងតែធ្វើអ្វីដែលល្អសម្រាប់អ្នកដទៃ—ក្នុងករណីនេះគឺអស់អ្នកដែលរំពឹងលើយើងក្នុងចំណុចនៃជីវិតអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ។ ប៉ុន្តែ តម្លៃនៃភាពសម្រិតសំរាំង ការរួមដំណេកបែបអត្តទត្ថបុគ្គលនិយម គឺពិតជាល្អណាស់ ដល់ថ្នាក់ថាព្រះជាម្ចាស់នឹងមិនអនុញ្ញាតឲ្យមានអ្វីដែលទាបជាងនោះ។ ព្រះអង្គហាមប្រាមមិនឲ្យមានការរួមដំណេកក្រៅចំណងជីវិតអាពាហ៍ពិពាហ៍ ដើម្បីរក្សាយើងពីការបាត់បង់នូវអ្វីដែលល្អបំផុត។[១៣]

ចំពោះអស់អ្នកដែលបានចាប់ផ្តើមជីវិតអាពាហ៍ពិពាហ៍ដោយឈរលើភាពមិនត្រឹមត្រូវនៃការរួមដំណេកមុនរៀបការ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងថា វាមិនទាន់យឺតពេលពេកនោះទេក្នុងការផ្លាស់ប្តូរ។ ដូចដែលយើងបានលើកឡើងខាងលើ មនុស្សជាច្រើននាក់មិនមានសុភមង្គលក្នុងផ្នែកទំនាក់ទំនងផ្លូវភេទជាមួយនឹងដៃគូជីវិត ដោយសារពួកគាត់ធ្លាប់មានបទពិសោធន៍នៃការរួមដំណេកមុនរៀបការ ឧទាហរណ៍ដូចជាការរំលោភបំពានផ្នែកផ្លូវភេទជាដើម។

មានការព្យាបាលរបួសបែបនេះតាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ដែលបានសម្របសម្រួលតាមរយៈអ្នកប្រឹក្សាយោបល់ គ្រូគង្វាល អ្នកដឹកនាំ ឬមិត្តភក្តិជាដើមដែលមានភាពឈ្លាសវៃ។ អស់អ្នកដែលធ្លាប់មានការរួមដំណេកបែបជាព្រានមុនរៀបការទំនងជាត្រូវការការធានាយ៉ាងពិសេស ទាក់ទងនឹងភាពបរិសុទ្ធដែលកើតឡើងតាមរយៈការអត់ទោស ដែលពួកគាត់ទទួលបានតាមរយៈព្រះហស្តរបស់ព្រះគ្រីស្ទ មុនពួកគាត់អាចចាប់ផ្តើមមានទំនាក់ទំនងល្អជាមួយនឹងដៃគូជីវិត។ គូស្រករនីមួយៗគួរស្វែងរកអ្នកដែលពួកគាត់អាចទុកចិត្តបាន ដែលនឹងជួយពួកគេក្នុងចំណុចនេះ។ ខ្ញុំស្គាល់គូស្រករមួយចំនួន ទោះបើមើលពីក្រៅហាក់បីដូចជាថាពួកគាត់កំពុងតែមានសុភមង្គលក៏ដោយ ក៏ពួកគាត់មិនមានទំនាក់ទំនងផ្នែកផ្លូវភេទដែលត្រឹមត្រូវអស់ជាច្រើនឆ្នាំហើយ។ ជាចុងក្រោយ នៅពេលដែលពួកគាត់ចាប់ផ្តើមមានភាពក្លាហាននិយាយអំពីការនោះជាមួយនឹងនរណាម្នាក់ នោះពួកគាត់ក៏បានឃើញថា បញ្ហានេះអាចមានដំណោះស្រាយបាន។

ប៉ុន្តែ មានមនុស្សមួយចំនួននឹងមិនអាចមានសមត្ថភាពមានបទពិសោធន៍ល្អក្នុងផ្នែកទំនាក់ទំនងខាងឯផ្លូវភេទបាន ទោះបីជាពួកគាត់ទទួលបានការជួយជ្រោមជ្រែងពីអ្នកប្រឹក្សាដ៏មានជំនាញក៏ដោយ។ ខ្ញុំសំដៅលើអស់អ្នកដែលមានដៃគូជីវិត ដែលមានបញ្ហាផ្នែករាងកាយ ឬក៏ជំងឺដែលធ្វើឲ្យការមានទំនាក់ទំនងផ្នែកផ្លូវភេទមានការពិបាក ឬក៏មិនអាចទៅរួចបាន។ អ្នកខ្លះមិនមានសមត្ថភាពជាសះស្បើយពេញលេញ ចេញពីរបួសចាស់នោះទេ ដែលនោះដូចជាការចាប់រំលោភជាដើម។ យើងក៏អាចលើកបញ្ចូលនូវគូស្រករមួយចំនួនដែលរស់នៅឃ្លាតពីគ្នាទាក់ទងនឹងភូមិសាស្ត្រអស់រយៈពេលយូរ។ នេះមិនមែនជារឿងស្រួលទេក្នុងវប្បធម៌ដែលពេញទៅដោយផ្នែកផ្លូវភេទ ដែលគេបានចាត់ទុកថា ការចំអែតអារម្មណ៍ផ្នែកផ្លូវភេទគឺជាសិទ្ធិមនុស្ស ដែលជាលទ្ធផលគឺជាការចាំបាច់ក្នុងការមានជីវិតដែលត្រឹមត្រូវ។ មិនថាលោកីយ៍នេះថាយ៉ាងម៉េចក៏ដោយ ក៏ការស្រាវជ្រាវបានបង្ហាញថា ការរួមដំណេកគឺមិនមែនជាចំណុចចាំ

បាច់ផ្នែកសាច់ឈាមនោះទេ។ ការតមពីការមានទំនាក់ទំនងផ្នែកផ្លូវភេទមិនធ្វើឲ្យមនុស្សយើងមានគ្រោះថ្នាក់នោះទេ។ ហេតុដូច្នេះ ក្នុងជំនឿគ្រីស្ទបរិស័ទការតមគឺជាតម្លៃដ៏ខ្ពស់មួយ។

ដំណោះស្រាយធម្មតាមួយដែលអ្នកដែលបានរៀបការហើយសព្វថ្ងៃនេះធ្វើទាក់ទងទៅនឹងអសមត្ថភាពផ្នែកទំនាក់ទំនងផ្លូវភេទ គឺគាត់សម្រេចការខ្លួនឯងដែលពួកគាត់រាប់ថាជារបៀបមួយដែលពុំមានការខូចខាត ទាក់ទងនឹងការបន្ធូរសម្ពាធផ្នែកភេទ។ ពួកគាត់រើកញែកថា ព្រះគម្ពីរមិនបានហាមប្រាមអំពីការធ្វើបែបនោះឡើយ។ ខណៈពេលដែលសម្ដីនៅជាការពិតមែន ក៏វានៅជាការពិតដែរត្រង់ថា ជាទូទៅការសម្រេចការខ្លួនឯងត្រូវមានគំនិតត្រេកត្រអាលជាមុនសិន ដែលយើងឃើញថាព្រះគម្ពីរហាមយ៉ាងច្បាស់លាស់។ ពេលខ្លះទស្សនីយភាពនៃការអរសប្បាយបែបនេះនាំឲ្យបុគ្គលម្នាក់ចូលក្នុងជីវិតអាពាហ៍ពិពាហ៍ដែលមិនស្អាតស្អំ ដូចជាការមើលរូប ឬក៏វីដេអូអាសអាភាស។ បន្ថែមលើនោះទៀត ជានិច្ចជាកាលវាក៏នាំមនុស្សយើងឲ្យស្វែងរកប្រភពនៃការអរសប្បាយក្រៅពីដៃគូជីវិតខ្លួនផ្ទាល់ ហើយការនោះក៏នាំឲ្យពួកគាត់ឈឺចាប់ ក៏ដូចជានាំឲ្យមានរឿងអាស្រូវក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនដែរ។

ចំណុចគន្លឹះក្នុងការទទួលបានជ័យជម្នះត្រង់នេះគឺ ការបដិសេធមិនព្រមចុះចូលប្រពៃណីដែលបង្រៀនថាគ្រប់គ្នាមានសិទ្ធិក្នុងការចំអែតអារម្មណ៍របស់ខ្លួនផ្លូវភេទ។ ប្រសិនបើយើងទទួលយកចំណុចនេះ នោះយើងនឹងចាប់ផ្ដើមមើលទម្រង់មួយណាផ្សេងទៀតនៃការចំអែតអារម្មណ៍ថាជាផ្នែកមួយដ៏ចាំបាច់នៃការមានជីវិតពេញលេញ។ ដាច់ខាត យើងត្រូវតែប្រឆាំងនឹងអាកប្បកិរិយាបែបនេះដោយសារវាបំផ្លាញសុភមង្គលរបស់យើង។

ការសម្រេចអារម្មណ៍ខ្លួនឯងគឺមិនមែនជាចំណុចចុងក្រោយនៃផែនដីសម្រាប់គ្រីស្ទបរិស័ទទេ។ ប្រសិនបើបុគ្គលណាម្នាក់ចុះចូលចំពោះវា ភ្លាមនោះដាច់ខាតក៏ត្រូវតែលន់តួទៅកាន់ព្រះជាម្ចាស់ ដោយរៀបរាប់អំពីអំពើបាបជាក់ស្ដែងដែលនាំទៅកាន់ការនោះ ហើយទទួលយកការអត់ទោស និងការ

សម្អាតពីទ្រង់ (១យ៉ូហាន ១:៩)។

គ្រីស្ទបរិស័ទជៀសវាងចេញពីការមានទំនាក់ទំនងផ្លូវភេទរហូតទាល់តែពួកគាត់បានរៀបការសិន។ ក្នុងជំនឿគ្រីស្ទបរិស័ទ មានវីរបុរស និងវីរនារីដ៏ល្អប្រពៃមួយចំនួនដែលនៅលីវ ហើយក៏បន្តតមការរួមដំណេកដែរ។ នៅកំពូលនៃបញ្ជីនេះគឺព្រះយេស៊ូវផ្ទាល់—ជាបុគ្គលដែលពេញលេញបំផុត និងមានអំណរខ្លាំងជាងគេដែលធ្លាប់រស់នៅ។ ហើយក៏មានគ្រីស្ទបរិស័ទរឹងមាំមួយចំនួនដែលមានជំនោរផ្នែកផ្លូវភេទជាមួយនឹងភេទដូចគ្នា តែពួកគាត់បានជ្រើសរើសនៅលីវវិញ។ អ្នកខ្លះមានសមត្ថភាពផ្លាស់ប្តូរ ហើយក៏បានចេះស្រឡាញ់ភេទផ្ទុយគ្នាវិញ។ ហើយអ្នកខ្លះទៀតទំនងជាត្រូវបន្តតយុទ្ធជាមួយនឹងជំនោរនៃសេចក្តីប្រាថ្នាផ្នែកផ្លូវភេទដូចគ្នា ខណៈពេលដែលពួកគាត់បន្តនៅលីវរហូតដល់ស្លាប់។

ដោយសារចំណង់ផ្លូវភេទគឺជាបំណងប្រាថ្នាដែលខ្លាំង ខ្ញុំមិនលើកទឹកចិត្តឲ្យមានការភ្ជាប់ពាក្យដែលមានរយៈពេលយូរនោះទេ។ ក្នុងលោកីយ៍ដែលពេញទៅដោយទំនោរចិត្តនៃការរួមដំណេក នៅពេលដែលបុគ្គលម្នាក់នៅជិតស្និទ្ធជាមួយនឹងបុគ្គលដែលគាត់មានបំណងចិត្តរៀបការជាមួយ វាជារឿងដ៏ពិបាកមួយក្នុងការជៀសចេញពីការមានទំនាក់ទំនងផ្លូវភេទ ខណៈពេលភ្ជាប់ពាក្យដែលមានរយៈពេលយូរ។ ជាទូទៅ ហេតុផលដែលគូស្រករពន្យារពេលរៀបការគឺដោយសារបញ្ហាសេដ្ឋកិច្ច។ ប្រហែលជាយើងគួរតែចោទសួរអំពីគំនិតមួយនេះឲ្យបានហ្មត់ចត់។ សាវ័ក ប៉ុល បានផ្តល់ដំបូន្មានយ៉ាងសមរម្យដល់ស្ត្រីមេម៉ាយវ័យក្មេងនៅទីនេះ៖ «ប៉ុន្តែ បើអ្នកទាំងនោះអត់ទ្រាំមិនបាន នោះចូរយកប្តីប្រពន្ធចុះ ដ្បិតដែលយកប្តីប្រពន្ធ នោះជាជាងទ្រាំឲ្យមានសេចក្តីឆេវឆាវិញ» (១កូរិនថូស ៧:៩)។

ដោយសារមានការល្បួងដ៏ខ្លាំង ជាពិសេសសម្រាប់គូស្រករដែលកំពុងស្រឡាញ់គ្នា វាងាយស្រួលណាស់ក្នុងការមានទំនាក់ទំនងផ្លូវខាងឯភេទក្រៅចំណងអាពាហ៍ពិពាហ៍សព្វថ្ងៃនេះ ដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់ក្នុង

ការដែលឪពុកម្ដាយ និងក្រុមជំនុំក្នុងការលើកឡើងឲ្យបានញឹកញាប់អំពីអំពើបាប និងគ្រោះថ្នាក់នៃការរួមដំណេកក្រៅចំណងអាពាហ៍ពិពាហ៍។ ការបរាជ័យក្នុងការធ្វើបែបនេះគឺជាការធ្វើឲ្យពួកគាត់បរាជ័យដែរ។ តម្រូវការនេះកាន់តែបន្ទាន់សម្រាប់ពេលសព្វថ្ងៃនេះ ដោយសារប្រពៃណីកំពុងតែវាយប្រហារពួកគាត់តាមរយៈសារផ្ទុយពីនោះ ដែលទាក់ទាញចំណាប់អារម្មណ៍។ ខ្ញុំខ្លាចថា ដោយសារការរួមដំណេកមុនចំណងអាពាហ៍ពិពាហ៍បានក្លាយជារឿងដែលមានប្រជាប្រិយភាពហើយ នោះគ្រីស្ទបរិស័ទមានការស្ទាក់ស្ទើរក្នុងការប្រឆាំងពួកគាត់ដោយនិយាយអំពីវា។ តាមរយៈការនៅស្ងៀម យើងទំនងជាអាចគេចចេញពីការធ្វើឲ្យពួកគាត់អន់ចិត្ត ប៉ុន្តែយើងធ្វើឲ្យព្រះជាម្ចាស់ខ្វាល់ ដោយសារយើងបានបរាជ័យក្នុងការបើកបង្ហាញសេចក្ដីពិតរបស់ទ្រង់ទៅកាន់រាស្ត្ររបស់ព្រះអង្គ។

យោងតាមទេវវិទ្យា យើងឃើញអំពីចំណុចពិបាកនៃការមិនរួមដំណេកសម្រាប់អស់អ្នកដែលមានសេចក្ដីប្រាថ្នាខាងឯផ្លូវភេទថា ជាទិដ្ឋភាពមួយនៃការធ្វើឲ្យអាក់អន់ចិត្ត ដែលសាវ័ក ប៉ុល បានមានប្រសាសន៍ថាគ្រីស្ទបរិស័ទគ្រប់រូបនឹងត្រូវប្រឈមមុខជាមួយ រហូតទាល់តែពួកគាត់ស្លាប់ (សូមមើលនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:១៨-២៥)។ ការអាក់អន់ចិត្តទាំងនេះធ្វើឲ្យពួកគាត់ថ្ងូរខណៈពេលដែលពួកគាត់ចាំទទួលការធ្វើឲ្យរូបកាយរបស់គាត់ប្រសើរឡើងវិញ ដែលនឹងពិតជាកើតឡើងមែន ហើយក៏នឹងនៅជានិច្ចផងដែរ (ខ២៣)។ យើងទាំងអស់គ្នាសុទ្ធតែមានចំណុចក្នុងជីវិតដែលធ្វើឲ្យយើងអន់ចិត្ត ហើយក៏ធ្វើឲ្យយើងថ្ងូរ ដោយមានការប្រាថ្នាចង់បានដ៏បរិសុទ្ធ ទាក់ទងនឹងការប្រោសលោះចុងក្រោយរបស់យើង។ យើងអាចថ្ងូរបាន ប៉ុន្តែដាច់ខាតយើងមិនអាចប្រព្រឹត្តអំពើបាបបានឡើយ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើនគិតថា អ្វីដែលព្រះគម្ពីរហៅថាជាអំពើបាប ដែលនេះផ្ដោតទៅលើការរួមដំណេកក្រៅចំណងអាពាហ៍ពិពាហ៍ ជាចំណុចចាំបាច់ដើម្បីឲ្យមានជីវិតពេញលេញ។ ប៉ុន្តែ យើងជឿជាក់ថា អស់អ្នកដែលមិនមានទំនាក់ទំនងផ្នែកផ្លូវភេទដែលមានន័យក៏

អាចមានជីវិតដែលពេញលេញ ដូចដែលព្រះយេស៊ូវបានមានបន្ទូលថា ព្រះអង្គអាចប្រទានដល់យើងបានដែរ (យ៉ូហាន ១០:១០)។ ទំនាក់ទំនងខាងឯផ្លូវភេទគឺមិនមែនជាសិទ្ធិមូលដ្ឋានសម្រាប់មនុស្សយើងទេ។

នេះជាមូលហេតុដែលយើងមិនគាំទ្រគ្រីស្ទបរិស័ទដែលមានទំនាក់ទំនងស្និទ្ធស្នាលជាមួយនឹងអ្នកផ្សេងក្រៅចំណងជីវិតអាពាហ៍ពិពាហ៍ ហើយលើកជាលេសថា «ដៃគូជីវិតរបស់ខ្ញុំមិនបានធ្វើឲ្យខ្ញុំស្កប់ចិត្ត»។ សូម្បីតែមនុស្សបែបនោះក៏អាចមានជីវិតពេញលេញក្នុងព្រះគ្រីស្ទបានដែរ។ វាបានធ្វើឲ្យខ្ញុំសោកស្តាយណាស់នៅពេលដែលខ្ញុំបានអានកាសែត ដែលថ្នាក់ដឹកនាំពេទ្យបានអនុញ្ញាតឲ្យក្មេងវ័យជំទង់ម្នាក់ដែលមានជំងឺមហារីកដំណាក់កាលចុងក្រោយរួមដំណេកជាមួយនឹងស្រីពេស្យាមុនគាត់ស្លាប់។ ការនេះកើតឡើងចេញពីរឿងព្រេងនិទានមួយដែលថា ទំនាក់ទំនងខាងឯផ្លូវភេទគឺជាសិទ្ធិមនុស្ស ដែលគ្រប់គ្នាដាច់ខាតត្រូវតែទទួលបាន។ ការជំរុញឲ្យមានការចាក់ប្រេងតាំងឲ្យអ្នកដែលអនុវត្តការរួមដំណេកជាមួយនឹងភេទដូចគ្នាក្នុងព័ន្ធកិច្ច និងការជំរុញឲ្យមានអាពាហ៍ពិពាហ៍ជាមួយនឹងភេទដូចគ្នា ក៏បានកើតឡើងចេញពីគំនិតមិនត្រឹមត្រូវដូចនេះផងដែរ។ យើងជឿថា អស់អ្នកដែលមានសេចក្តីប្រាថ្នាដូចនោះក៏អាចមានជីវិតពេញលេញបានដែរ ខណៈពេលដែលពួកគាត់រស់នៅដោយមិនមានការរួមដំណេក។ យើងធ្វើការនោះដោយការបន្ទាបខ្លួន ដោយដឹងថាពួកគាត់មានសង្គ្រាមដ៏ធំនៅខាងមុខពួកគាត់ នៅក្នុងសង្គមដែលជ្រួតជ្រាបទៅដោយការរួមដំណេក។ ប៉ុន្តែ យើងជឿជាក់ថា ព្រះគុណរបស់ព្រះជាម្ចាស់អាចជួយពួកគាត់រស់នៅដោយមានសុភមង្គល និងជីវិតដែលបរិសុទ្ធបាន។

## សេចក្តីស្រឡាញ់តយុទ្ធនឹងការខ្វះទំនុកចិត្ត[១៤]

នៅចុងបញ្ចប់ គ្រប់ការកំផិតគឺជាការបង្ហាញអំពីការខ្វះទំនុកចិត្ត។ ភាពអាត្មានិយមនៃការចម្អែតអារម្មណ៍ខ្លួនឯងដែលកើតចេញពីចំណាប់អារម្មណ៍ និងការស្រឡាញ់ពីបុគ្គលម្នាក់ផ្សេងទៀត ឬកើតចេញពីអត្ថន័យនៃជ័យជម្នះ—ដោយ

បានយកឈ្នះលើបុគ្គលម្នាក់— បណ្តាលឲ្យបុគ្គលម្នាក់នោះខ្វាក់ភ្នែកមិនឃើញចំណុចអវិជ្ជមានទាំងអស់ ដែលកើតឡើងចេញពីការកំផិត។ មនុស្សជាច្រើនចាញ់ល្បួងក្នុងទំនាក់ទំនងមិនត្រឹមត្រូវគឺមិនមែនដោយសារការរួមដំណេកទាំងស្រុងនោះទេ ប៉ុន្តែគឺដោយសារការបញ្ជាក់អះអាងអំពីខ្លួនឯងដែលពួកគាត់ទទួលបានពីការកំផិតនោះ។ ពេលខ្លះ យើងឮគេលើកឡើងថា «មានប្រពន្ធស្អាតប៉ុណ្ណឹងហើយ ហេតុអ្វីបានជាគាត់ចាប់ផ្តើមមានទំនាក់ទំនងជាមួយអ្នកដែលមានសម្រស់មិនបានពាក់កណ្តាលប្រពន្ធផងដូច្នេះ?»។ ជានិច្ចជាកាល បុរសម្នាក់នោះមិនត្រូវបានទាក់ទាញដោយសម្រស់របស់ស្ត្រីម្នាក់នោះរហូតទេ។ ចំណាប់អារម្មណ៍ដែលនាងបានផ្តល់ចំពោះគាត់ ឬក៏គាត់បានផ្តល់ចំពោះនាង បានបម្រើជាការលើកស្ទួយភាពអាត្មានិយមរបស់គាត់ ដែលដោះស្រាយភាពមិនមានសុវត្ថិភាពរបស់គាត់។ ពេលខ្លះ វាមានក្នុងអត្ថន័យនៃការយកឈ្នះលើគំនិត និងខ្លួនប្រាណ ឬក៏ការមានសមត្ថភាពគ្រប់គ្រងលើបុគ្គលណាម្នាក់ផ្សេងទៀត ដែលនាំមកនូវការស្កប់ចិត្តដែលបង្កឲ្យមានការកំផិត។ ទម្រង់ហួសហេតុនៃ «ជ័យជម្នះ» បែបនោះគឺជាការរំលោភ។

លោកបណ្ឌិត ជេ. ខិសស្លើរ (Dr. Jay Kesler) បានមានប្រសាសន៍ថា «ខ្ញុំបានសង្កេតឃើញថា មនុស្សងាយនឹងធ្លាក់ចូលសេចក្តីល្បួងខាងផ្លូវភេទនៅពេលដែលពួកគាត់មិនមានសមត្ថភាពសម្រេចគោលដៅរបស់ខ្លួន នៅពេលដែលពួកគាត់មានការអន់ចិត្ត ឬក៏ការបាក់ទឹកចិត្ត និងនៅពេលដែលពួកគាត់បាត់បង់ក្តីស្រមៃរបស់ខ្លួន»។[១៥] ជាទូទៅ នេះជាមូលហេតុដែលពួកគេចាប់ផ្តើមមានការកំផិតនៅពេលដែលពួកគេកំពុងមានបញ្ហាធ្ងន់ធ្ងរក្នុងមុខរបរ និងមានការងឿងឆ្ងល់លើតម្លៃមុខរបរខ្លួន។ អារម្មណ៍នៃភាពសំខាន់របស់ពួកគេ ជាពិសេសចំពោះមនុស្សប្រុស មានការស្និទ្ធស្នាលគ្នាយ៉ាងខ្លាំងទៅនឹងតម្លៃដែលពួកគេមានក្នុងមុខរបរជីវិត។ អារម្មណ៍នៃការមានតម្លៃលើខ្លួនឯងដែលមនុស្សប្រុសទទួលបានពីមនុស្សស្រីដែលកំពុងស្រឡាញ់គាត់ ឬក៏ការបានខ្លួនស្ត្រីម្នាក់នឹងបំពេញជាបណ្តោះអាសន្ននូវចន្លោះនៃការខ្វះទំនុក

ចិត្ត ដែលបុរសនោះមានអំពីខ្លួនឯង។

ទ្រឹស្ដីនៃការខ្វះទំនុកចិត្តនេះពន្យល់អំពីមូលហេតុដែលអ្នកដឹកនាំនយោបាយជើងខ្លាំងជាច្រើន មានស្រីក្មេងច្រើន (ដែលគេអាចហៅចំណុចខ្លាំងរបស់គាត់ថាតាមពិតទៅជាការស៊ីសងគ្នាជាមួយនឹងការខ្វះទំនុកចិត្ត)។ គ្រប់ការកោតសរសើរដែលអ្នកដឹកនាំទទួលបានមិនបានដកចេញនូវភាពស្រេកឃ្លានរបស់ពួកគាត់ ទាក់ទងទៅនឹងការបញ្ជាក់អះអាង និងចំណុចសំខាន់។ ជាការគួរឲ្យសោកស្ដាយណាស់ គោលការណ៍ដូចគ្នានោះក៏សំដៅទៅលើអ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទដ៏រឹងមាំ ដែលបានពាក់ព័ន្ធក្នុងរឿងអាស្រូវដែរ។ ខ្ញុំពិតជាសោកស្ដាយណាស់ដែលបានអានកាសែតមួយនៅក្នុងចំណោមព័ត៌មាននៅក្នុងប្រទេសស្រីលង្កាជាច្រើនឆ្នាំមុននេះ ដែលពន្យល់អំពីការដែលគ្រូគង្វាល និងអ្នកដែលនយោបាយមានរឿងអាស្រូវ ដោយសារពួកគាត់ខ្វះទំនុកចិត្ត មិនថាគាត់មានអំណាចលើមនុស្សក៏ដោយ។ ការខ្វះទំនុកចិត្តគឺជាមូលហេតុដែលបាននាំឲ្យមនុស្សមួយចំនួនមានការកំផិត ខណៈពេលដែលពួកគាត់មានវ័យពាក់កណ្ដាលជីវិត។ ដូចដែល លោកបណ្ឌិត ខិសស្លើរ បានលើកឡើង «ជាទូទៅ វ័យពាក់កណ្ដាលជីវិតនាំមកនូវការងាយខូចទាក់ទងនឹងការធ្លាក់ចូលក្នុងការល្បួងខាងផ្លូវភេទ....មនុស្សមួយចំនួនចាប់ផ្ដើមមានការភ័យខ្លាច ខណៈពេលដែលពួកគាត់កាន់តែចាស់ទៅៗ ហើយពួកគាត់ងឿងឆ្ងល់ថា តើមនុស្សស្រីនៅអាចឃើញថាពួកគាត់គួរឲ្យចាប់អារម្មណ៍ដែរឬទេ។ ដូច្នេះ ពួកគាត់ក៏មានការល្បួងក្នុងការសាកល្បង ដើម្បីស្វែងរក»។[១៦]

អស់អ្នកដែលរវល់ ដូចជាវេជ្ជបណ្ឌិត និងអស់អ្នកដែលពាក់ព័ន្ធក្នុងព័ន្ធកិច្ច ក៏ងាយធ្លាក់ក្នុងការកំផិត ប្រសិនបើប្ដី ឬប្រពន្ធមិនសប្បាយចិត្តនឹងភាពមមាញឹករបស់ពួកគាត់។ បន្ទាប់ពីចេញពីធ្វើការ ពួកគាត់មកផ្ទះដោយមានអ្នកចាំរករឿង។ ប្ដី ឬប្រពន្ធនៅតែស្ដីឲ្យពួកគាត់ដោយសារមិនអើពើចំពោះគ្រួសារ។ ប៉ុន្តែ នៅកន្លែងការងារ អ្នកដទៃបានប្រព្រឹត្តិនឹងពួកគាត់ដូចជាព្រះ ដោយសារគេកោតសរសើរចំពោះជំនាញ និងភាពជោគជ័យរបស់ពួកគាត់។

វាងាយស្រួលណាស់ក្នុងការដែលមនុស្សជាប់ក្នុងអន្ទាក់នៃការមានរឿងអាស្រូវជាមួយអ្នកធ្វើការជាមួយគ្នានៅឯកន្លែងធ្វើការ ដែលពួកគាត់តែងតែគាំទ្រគ្នាខណៈពេលដែលប្ដី ឬក៏ប្រពន្ធរបស់ខ្លួនតែងតែទម្លាក់ពួកគាត់ចុះ។

ឥឡូវនេះ ការនេះក៏បានកើតឡើងដូចគ្នាដែរ នៅតាមបណ្ដាញសង្គមដូចជាហ្វេសបុក ជាដើម។ មនុស្សម្នាចាប់ផ្ដើមផ្ញើសារឲ្យគ្នានៅក្នុងពិភពក្លែងក្លាយមួយ ហើយប្រាប់អ្នកដទៃនូវអ្វីដែលគួរតែនិយាយទៅកាន់ប្ដី ឬប្រពន្ធរបស់ខ្លួនតែប៉ុណ្ណោះ។ ម្នាក់និយាយទៅកាន់ម្នាក់ទៀតថា «អ្នកពិតជាធ្វើឲ្យខ្ញុំបានធូរចិត្តច្រើនណាស់។ ខ្ញុំពិតជាឯកាណាស់ ហើយការជជែកជាមួយអ្នកគឺជាព្រះពរខ្លាំងមែនទែន»។ បុគ្គលម្នាក់អាចមានអារម្មណ៍ទាក់ទាញដោយការនិយាយគាំទ្របែបដូចនោះ ហើយមានសេចក្ដីល្បួងកាន់តែជ្រៅទៅៗនៅក្នុងទំនាក់ទំនង។ ជាលទ្ធផល ពួកគាត់ក៏បានមានទំនាក់ទំនងកំផិតជាមួយគ្នាតែម្ដង។

គ្រប់ស្ថានភាពទាំងនេះគឺជាឧទាហរណ៍អំពីការស្រឡាញ់ដែលមិនមានការទទួលខុសត្រូវ។ ព្រះជាម្ចាស់បានបង្កើតយើងមក ដើម្បីឲ្យមានទំនាក់ទំនងដែលមានការប្ដេជ្ញាចិត្ត។ នៅទីបំផុត ការកំផិតតែងតែបំផ្លាញជីវិតយើង ក៏ដូចជាជីវិតអស់អ្នកដែលយើងស្រឡាញ់ដែរ ដោយបន្សល់ទុកអស់អ្នកដែលរងគ្រោះនូវរបួសធ្ងន់ធ្ងរ។ បុគ្គលម្នាក់មិនអាចនាំឲ្យដៃគូជីវិតមានការឈឺចាប់ដោយមិនធ្វើឲ្យខ្លួនឯងឈឺចាប់ជាមុនសិនបានឡើយ។ ចំណង់មានជម្រៅនិងការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងយើង ដល់ថ្នាក់ថាយើងមិនអាចទាត់ដៃគូជីវិតចោល ហើយប្ដូរគាត់ជាមួយនឹងអ្នកផ្សេងបានឡើយ។ ទំនាក់ទំនងដែលមានការប្ដេជ្ញាចិត្តគឺត្រូវមានការថែរក្សាតាមរយៈការខិតខំប្រឹងប្រែង។ ការស្រឡាញ់ដោយមិនមានទំនួលខុសត្រូវគឺងាយស្រួលទេ នៅមុនដំបូង ពីព្រោះវាមានការសង់លើពិភពដែលមិនពិតប្រាកដក្នុងការកំណត់របស់វា។ ប៉ុន្តែ ការឈឺចាប់ដែលកើតមកពីការកំផិតគឺឈឺខ្លាំងណាស់។ ដូច្នេះ យើងត្រូវតែយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយទំនាក់ទំនងរបស់យើងនៅផ្ទះ។ នៅពេលដែលយើងបន្តគាំទ្រគ្នាទៅវិញទៅមក នោះការដែលយើងងាយធ្លាក់ចូលក្នុងអំពើ

កំផិតត្រូវបានកាត់បន្ថយបានយ៉ាងច្រើន។

ទិដ្ឋភាពមួយនៃការខិតខំដែលមានក្នុងសេចក្តីស្រឡាញ់ដែលមានទំនួលខុសត្រូវ គឺការនៅឲ្យឆ្ងាយពីកាលៈទេសៈ ដែលអាចនាំឲ្យមានទំនាក់ទំនងមិនត្រឹមត្រូវ។ ដំបូន្មានរបស់សាវ័ក ប៉ុល ដែលគាត់បានផ្តល់ដល់លោក ធីម៉ូថេ គឺថា “ចូរឲ្យរត់ពីសេចក្តីស្រើបស្រាល” (២ធីម៉ូថេ ២:២២) ក៏សម្រាប់មនុស្សពេញវ័យផងដែរ។ ដូចដែលយើងបានលើកឡើងនៅក្នុងជំពូក២ វាជារឿងធម្មតាទេក្នុងការចូលចិត្តនៅជាមួយមនុស្សដែលមានភេទផ្ទុយគ្នា។ ជាធម្មតាយើងងាយមានចំណាប់អារម្មណ៍លើអ្នកខ្លះ ជាងអ្នកខ្លះទៀតដែរ។ នោះមិនមែនជាអំពើបាបនោះទេ។ ប៉ុន្តែ យើងត្រូវតែមានការប្រុងប្រយ័ត្ននៅក្នុងទំនាក់ទំនងរបស់យើងជាមួយមនុស្សទាំងនោះ។

ឧបមាថា លោកអ្នកចាប់អារម្មណ៍មិត្តរួមការងារ ឬអ្នកនៅកន្លែងធ្វើព័ន្ធកិច្ចជាមួយគ្នា។ លោកអ្នកមានអំណរក្នុងការបម្រើជាមួយគ្នា។ លោកអ្នកហាក់បីដូចជាយល់ពីគ្នាទៅវិញទៅមក ហើយជាលទ្ធផលលោកអ្នកក៏បានធ្វើការងារបានល្អៗ ឬការងារនៅក្នុងព័ន្ធកិច្ច។ ប៉ុន្តែ ចំណង់អារម្មណ៍ដែលមិនល្អក៏អាចកើតមានឡើងបាន ជាចំណង់ដែលលោកអ្នកទំនងមិនបានដឹង ដោយសារទំនាក់ទំនងបានចាប់ផ្តើមបានយ៉ាងល្អ និងបរិសុទ្ធ។ អ្នកដទៃអាចដាស់តឿនលោកអ្នកចំពោះអ្វីដែលកំពុងកើតឡើង ដោយសារពួកគាត់មើលឃើញនូវអ្វីដែលលោកអ្នកមើលមិនឃើញ។ ពួកគាត់ឃើញអ្វីដែលបានកើតឡើង នៅពេលដែលក្រសែភ្នែករបស់លោកអ្នកជួបគ្នា ឬក៏អំពីរបៀបដែលលោកអ្នកចូលចិត្តនៅជិតគ្នាដោយមិនបានដឹងខ្លួន នៅពេលនៅក្នុងបន្ទប់ដែលមានមនុស្សច្រើននាក់។ នៅពេលមិត្តភក្តិរបស់លោកអ្នកដាស់តឿនលោកអ្នកអំពីគ្រោះថ្នាក់ដូចនោះ ជាជាងខឹងពួកគាត់អំពី “ការចេះដឹងរឿងក្នុងជីវិតរបស់លោកអ្នក” លោកអ្នកគួរតែដឹងគុណចំពោះដំបូន្មានរបស់ពួកគេ ហើយអនុវត្តដោយមានការប្រុងប្រយ័ត្នខ្ពស់វិញ។ មានពេលពីរបីដងដែលខ្ញុំបានឃើញ ហាក់បីដូចជាសញ្ញានៃការមានទំនាក់ទំនងដោយមិនដឹងខ្លួន ប៉ុន្តែខ្ញុំមិនមានទំនុក

ចិត្តក្នុងការដាស់តឿនអ្នកដែលពាក់ព័ន្ធ។ ខ្ញុំមានការសោកស្ដាយយ៉ាងខ្លាំង ដោយសារការភ័យខ្លាចរបស់ខ្ញុំបានក្លាយជាការពិត ហើយមនុស្សល្អៗបានរងគ្រោះដោយមានការឈឺចាប់យ៉ាងខ្លាំង។

ដោយសារលោកអ្នកត្រូវរ៉ូវគ្នាខ្លាំង នោះលោកអ្នកទំនងជាចាប់ផ្ដើមមានទំនាក់ទំនងស្និទ្ធស្នាលជាមួយនឹងបុគ្គលនោះ ហើយនិយាយគ្នាពេលជួបគ្នា។ ដាច់ខាត! យើងត្រូវតែមានការប្រុងប្រយ័ត្ន ទាក់ទងទៅនឹងការមានទំនាក់ទំនងបែបនេះច្រើនពេក។ មនុស្សមួយចំនួនទទូចចង់ជួយបុគ្គលដែលមានភេទផ្ទុយគ្នា ទោះបើថាកំពុងតែមានចំណាប់ផ្នែកអារម្មណ៍ ដែលមិនល្អ កំពុងតែកើតឡើងក៏ដោយ។ ប្រយោគដូចជា «មានតែខ្ញុំម្នាក់ទេ ដែលយល់ពីគាត់បាន» អាចជាប្រយោគដែលមានគ្រោះថ្នាក់ នៅពេលដែលនិយាយចំពោះអ្នកដែលមានភេទផ្ទុយគ្នា។ ដើម្បីការពារប្រឆាំងនឹងការនេះ ជាទូទៅខ្ញុំសូមឲ្យប្រពន្ធរបស់ខ្ញុំជួយដោះស្រាយខាងឯផ្នែកទំនាក់ទំនងផ្ទាល់ខ្លួនជាច្រើនរបស់ខ្ញុំជាមួយមិត្តរួមការងារស្រីៗ។ ខ្ញុំក៏ធ្វើដូច្នេះចេញពីការជឿជាក់ថា ក្នុងនាមជាស្ត្រី ប្រពន្ធខ្ញុំអាចធ្វើកិច្ចការនេះបានល្អប្រសើរជាងខ្ញុំទៅទៀត ទាក់ទងនឹងបញ្ហាបែបនេះ។

ការស្រឡាញ់ដ៏ពិតប្រាកដតម្រូវឲ្យមានការខិតខំប្រឹងប្រែង ដូចដែលយើងបានបង្ហាញនៅជំពូកមុននេះ ប៉ុន្តែវាមានតម្លៃណាស់។ មានចំណុចគាំទ្រដែលគួរឲ្យសរសើរក្នុងទំនាក់ទំនងដែលបង្កើតឡើងតាមរយៈការខិតខំប្រឹងប្រែងអនុវត្តសេចក្ដីស្រឡាញ់បែបអាហ្គាពេនៅក្នុងផ្ទះ និងការខិតខំប្រឹងប្រែងគេចចេញពីអាកប្បកិរិយាដែលមិនដឹងខ្លួននៅក្រៅផ្ទះ។ ការបញ្ជាក់អះអាងពីសមាជិកគ្រួសារគឺជាថ្នាំដ៏ល្អមួយសម្រាប់ការខ្វះទំនុកចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងគ្រប់គ្នាសុទ្ធតែខ្វះទំនុកចិត្តក្នុងកម្រិតណាមួយដែរ មិនថាតិចឬច្រើន។ ការបញ្ជាក់អះអាងទៅកាន់ប្ដីប្រពន្ធ ឪពុកម្ដាយ និងកូនៗអាចជាផ្នែកដ៏ធំមួយនៃព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការតយុទ្ធជាមួយនិងភាពអសន្តិសុខទាំងនេះ។ ពួកគាត់គឺជាមនុស្សសំខាន់បំផុតនៅក្នុងជីវិត

របស់យើង។ តើមានកន្លែងណាដែលល្អប្រសើរជាងគ្រួសាររបស់យើង ក្នុងការបញ្ជាក់អះអាងដូចនេះ?

ប៉ុន្តែ ការព្យាបាលដែលល្អប្រសើរជាងគេបំផុតសម្រាប់ការខ្វះទំនុកចិត្តគឺការរំភើបក្នុងការបានក្លាយជាកូនរបស់ព្រះជាម្ចាស់ដែលមានតម្លៃ ពីព្រោះព្រះជាម្ចាស់មានគម្រោងការដ៏ល្អសម្រាប់យើង។ នេះជាមូលហេតុដែលការចំណាយពេលជាមួយព្រះជាម្ចាស់ ដោយមិនមានភាពប្រញិបប្រញាប់ សំខាន់ណាស់។ ក្នុងបទគម្ពីរដែលបានព្រមានអំពីគ្រោះថ្នាក់ពីលោកីយ៍ និងការគិតមិនស្អាតស្អំ លោក យ៉ាកុប បានដាស់តឿនថា «ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នាដែរ ឱពួកមានបាបអើយ ចូរលាងដៃឲ្យស្អាតចុះ ឱពួកអ្នកមានចិត្ត២អើយ ចូរសម្អាតចិត្តឡើង» (យ៉ាកុប ៤:៨)។ ក្នុងពេលវេលារបស់យើងជាមួយនឹងព្រះជាម្ចាស់ យើងមិនគ្រាន់តែបានឆ្អែតដោយសេចក្តីពិតនោះទេ ការនោះក៏ធ្វើឲ្យយើងបានដឹងពីភាពអាក្រក់របស់អំពើបាបដែរ ហើយយើងក៏ថែមទាំងបានឆ្អែតដោយសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ក្នុងការដែលព្រះអង្គបញ្ជាក់អះអាងអំពីយើង ដែលការនោះជួយយើងកាត់បន្ថយភាពទាក់ទាញពីសេចក្តីកំផិតទៀតផង។

ការខ្មាសខ្លួនឯងគឺជារបៀបមួយក្នុងរបៀបជាច្រើន ដែលភាពអសន្តិសុខបង្ហាញអំពីខ្លួនវាផ្ទាល់។ ការបញ្ជាក់អះអាងពីព្រះជាម្ចាស់នៅពេលដែលយើងចំណាយពេលជាមួយព្រះអង្គអាចដកនូវសេចក្តីខ្មាសនោះចេញបាន។ ស្តេចដាវីឌ បានមានបន្ទូលថា «អ្នកណាដែលពឹងដល់ទ្រង់ នោះក៏មានសេចក្តីអំណរដ៏ព្រោងព្រាយហើយមុខគេមិនដែលត្រូវខ្មាសឡើយ» (ទំនុកតម្កើង ៣៤:៥)។ យើងសម្លឹងមើលទៅឯព្រះដែលជាជីវិតដ៏អស់កល្បជានិច្ច។ នៅពេលយើងចំណាយពេលជាមួយព្រះអង្គ នោះយើងទទួលបានបទពិសោធន៍នៃការមានអំណរក្នុងការដឹងអំពីភាពអស់កល្បជានិច្ច និងព្រះដែលមានពេញដោយព្រះចេស្តាគិតអំពីយើង ជាកូនរបស់ព្រះអង្គ (១យ៉ូហាន ៣:១)។ ព្រះគម្ពីរមានចែងថា ព្រះជាម្ចាស់សព្វព្រះទ័យនឹងយើង (ទំនុកតម្កើង ១៤៧:១១;

១៤៩:៤)។ ការមានសេចក្តីរំភើបដ៏ធំបំផុតមួយនៅក្នុងជីវិតនេះគឺជាការដឹងថា ព្រះជាម្ចាស់ដែលមានពេញដោយអំណាចព្រះចេស្តាទតមើលមកកាន់យើង ដោយញញឹមហើយប្រកាសថា «ឯងជាកម្មសិទ្ធិរបស់យើង» ឬក៏ថា «ឯង ជាកូនដ៏មានតម្លៃរបស់យើង»។ ប្រសិនបើដូច្នេះមែន នោះការភ័យខ្លាចដ៏ធំ សម្រាប់គ្រីស្ទបរិស័ទ គឺការដកស្នាមញញឹមរបស់ព្រះជាម្ចាស់ចេញ។ នេះគឺ ជាការការពារដ៏ល្អផុត កុំឲ្យធ្លាក់ចូលក្នុងអំពើបាបខាងឯផ្លូវភេទ។

## សេចក្តីសន្និដ្ឋាន

មិនថាយើងរវល់ ឬក៏មានទុក្ខព្រួយខ្លាំងប៉ុណ្ណាជាមួយនឹងរឿងពិបាកៗ ឬក៏ កាតព្វកិច្ចរបស់យើងក៏ដោយ ក៏យើងមិនគួរមិនអើពើជាមួយនឹងភាពរំភើប ដ៏សែនរីករាយនៃការនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដែរ។ ចូលយើង កុំអនុញ្ញាតឲ្យការមានសុវត្ថិភាពនៃការទទួលបានពីព្រះជាម្ចាស់ចាកចេញ ពីយើងឡើយ។ យើងទទួលបានការជំរុញក្នុងជីវិតតាមរយៈសេចក្តីពិតនៃ កណ្ឌគម្ពីរ ចោទិយកថា ៣៣:២៧៖ «ព្រះដ៏គង់នៅអស់កល្បជានិច្ច ទ្រង់ជា ទីលំនៅរបស់ឯង ហើយព្រះពាហុដ៏នៅជាប់អស់កល្បជានិច្ច»។ ដោយមាន សន្តិភាពដូចនេះ មិនថាលោកអ្នកបានរៀបការហើយ នៅលីវ ជាមេម៉ាយឬក៏ ពោះម៉ាយ ឬក៏បានលែងលះគ្នាក៏ដោយ ក៏លោកអ្នកអាចនៅជាបុគ្គលដែល មានសុភមង្គល និងភាពពេញលេញបានដែរ។

# ៦

# អំណរ

តាមរយៈព្រះគម្ពីរសញ្ញាចាស់ គ្រីស្ទបរិស័ទទទួលបានចំណុចគន្លឹះជាច្រើន ដែលជាលក្ខណៈនៃជីវិតរស់នៅសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់។ ចេញពីចំណុចនោះ យើងរៀនបានអំពីព្រះចិន្តារបស់ព្រះជាម្ចាស់ និងលក្ខណសម្បត្តិដែលព្រះអង្គដែលទ្រង់សព្វព្រះហឫទ័យឲ្យរាស្ត្ររបស់ទ្រង់មាន។

ព្រះគម្ពីរសញ្ញាចាស់បានបង្ហាញថា អំណរជាចំណុចគន្លឹះមួយក្នុងការរស់នៅដែលចេះគោរពកោតខ្លាចព្រះជាម្ចាស់។ ភាសាហេព្រើរមានពាក្យដើមចំនួន ១៣ពាក្យ ដែលមានគំនិតទាក់ទងជាមួយនឹងអំណរ ហើយពាក្យទាំងនោះផ្តល់ជាពាក្យដាច់ដោយឡែកចំនួន២៧ពាក្យទៀតសម្រាប់ពាក្យអំណរ! នៅក្នុងកណ្ឌគម្ពីរ សេផានា ៣:១៤, ១៧ ក្នុងតែពីរខមានពាក្យសរុបចំនួនប្រាំបីសម្រាប់ពាក្យអំណរនេះ។[១] ការសង្កត់ធ្ងន់បែបនេះក៏មាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែរ។ សាវ័ក ប៉ុល បង្គាប់គ្រីស្ទបរិស័ទទាំងអស់ឲ្យអរសប្បាយក្នុងព្រះអម្ចាស់ជានិច្ច (ភីលីព ៤:៤) ហើយព្រះយេស៊ូវបានមានព្រះបន្ទូលថា អំណររបស់យើងនឹងបានពោរពេញ នៅពេលដែលព្រះអង្គប្រទានអំណររបស់ទ្រង់មកកាន់យើង (យ៉ូហាន ១៥:១១)។ យើងអាចលើកឡើងដោយមានសុវត្ថិភាពថា អំណរជះឥទ្ធិពលមកលើសុខភាពក្នុងផ្ទះ ឬក៏ដូចនៅក្នុងកណ្ឌគម្ពីរ ១៧:២២

លើកឡើងថា “ចិត្តដែល “សប្បាយ” ជាថ្នាំយ៉ាងវិសេស”។

ដូច្នេះ វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលទេ ដែលព្រះគម្ពីរសញ្ញាចាស់បានចាត់ទុកផ្ទះថាជាកន្លែងដែលមានអំណរ។ ព្រះជាម្ចាស់បានបង្គាប់ឲ្យគ្រួសារអរសប្បាយ នៅពេលដែលពួកគេថ្វាយបង្គំទ្រង់ និងពេលដែលពួកគេបរិភោគនៅក្នុងទីបរិសុទ្ធរបស់ព្រះអង្គ (ចោទិយកថា ១២:៧, ១២; ១៤:២៦)។ ជាពិសេស យើងអាចឃើញអំណរកើតមាននៅក្នុងគ្រួសារជាក់ស្តែងបាន នៅអំឡុងពេលមានពិធីបុណ្យអ្វីមួយ (ចោទិយកថា ១៦:១១, ១៤; ២របាក្សត្រ ៣០:២១)។ ព្រះគម្ពីរបានប្រាប់គ្រួសារឲ្យ “មានសេចក្តីអំណរ” ពេលដែលពួកគាត់មានពិធីជប់លៀង (ចោទិយកថា ១៦:១៥)។ កណ្ឌគម្ពីរសាស្តាបានផ្តល់ដំបូន្មានដល់បុរសទាំងឡាយថា “ចូររស់នៅដោយអំណរ ជាមួយនឹងប្រពន្ធជាទីស្រឡាញ់របស់ឯង” (សាស្តា ៩:៩)។ កណ្ឌគម្ពីរសុភាសិតបានប្រាប់ដល់បុរសទាំងអស់គ្នាថា “ចូរឲ្យឯងបានរីករាយចំពោះប្រពន្ធដែលបានគ្នាពីកាលក្រមុំកំលោះចុះ” (សុភាសិត ៥:១៨)។ គេបានពណ៌នាអំពីមនុស្សដែលមានកូនច្រើនថាជាអ្នក “សប្បាយហើយ” ឬក៏ “មានព្រះពរ” (ទំនុកតម្កើង ១២៧:៥)។[២] ព្រះគម្ពីរបានជំរុញឲ្យគ្រួសារមានអំណរនៅក្នុងការល្អដែលព្រះជាម្ចាស់បានធ្វើសម្រាប់ពួកគាត់ (ចោទិយកថា ២៦:១១)។

## អំណរគឺជាទ្រព្យសម្បត្តិពិតប្រាកដនៅក្នុងផ្ទះ

កាលប្រទេសស្រីលង្កាកំពុងឆ្លងកាត់ការធ្វើបដិវត្តន៍នៅឆ្នាំ១៩៨៨-៨៩ ការរស់នៅពិតជាមានបញ្ហា ហើយពេញទៅដោយគ្រោះថ្នាក់។ ម្តងហើយម្តងទៀត គេបានបិទសាលារៀនអស់ជាច្រើនខែ។ មនុស្សជាច្រើនក៏បានចាកចេញពីប្រទេស ដោយលើកឡើងថា ពួកគាត់កំពុងតែចាកចេញ ដើម្បីប្រយោជន៍របស់កូនខ្លួន។ ខ្ញុំទើបតែត្រឡប់មកឈប់សម្រាករយៈពេល៦ខែ ពីការសិក្សានៅសាលាព្រះគម្ពីរ ហ្គ័រដិន-ខុនវិល (Gordon-Conwell Theological

Seminary) នៅប្រទេសអាមេរិក។ កាលនោះខ្ញុំពិតជាសប្បាយមែន ព្រោះខ្ញុំបានធ្វើនូវអ្វីដែលខ្ញុំចូលចិត្តធ្វើ—ដូចជាការរៀនសូត្រ ការសរសេរ និងការបង្រៀន។ នៅក្នុងពាក់កណ្ដាលហេតុការណ៍នៃបញ្ហា នៅឆ្នាំ១៩៨៩ សាលាព្រះគម្ពីរ ហ្វ័រដិន-ខុនវិល បានផ្ញើសំបុត្រអញ្ជើញខ្ញុំនូវអ្វីដែលមើលទៅហាក់បីដូចជាការងារដែលខ្ញុំប្រាថ្នា ទាក់ទងនឹងអ្វីដែលខ្ញុំចូលចិត្តធ្វើ។ ប៉ុន្តែ ខ្ញុំ ហើយ និងប្រពន្ធជឿជាក់ថា ការត្រាស់ហៅរបស់យើងគឺធ្វើព័ន្ធកិច្ចអស់មួយជីវិតនៅក្នុងប្រទេសស្រីលង្កា ដូច្នេះខ្ញុំក៏បានបដិសេធការអញ្ជើញនេះ។ ទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវធ្វើឲ្យវាមានប្រយោជន៍សម្រាប់កូនៗរបស់យើង ពេលយើងនៅប្រទេសស្រីលង្កា។ នៅចុងបញ្ចប់ គឺពួកយើង មិនមែនពួកគាត់ទេ ដែលបានឆ្លើយតបចំពោះការត្រាស់ហៅឲ្យនៅប្រទេសស្រីលង្កា។ នៅពេលដែលប្រពន្ធខ្ញុំហើយនិងខ្ញុំនិយាយអំពីការនេះ យើងបានសម្រេចចិត្តថា ព្រះពរដែលល្អបំផុតដែលយើងអាចបន្សល់ទុកសម្រាប់កូនៗយើង គឺការមានសុភមង្គលក្នុងផ្ទះ។ មិនថាពួកគាត់ទទួលបានបទពិសោធន៍នៅខាងក្រៅយ៉ាងណាក៏ដោយ ក៏ពួកគាត់គួរដឹងថា ពួកគាត់នឹងមកកន្លែងដែលកក់ក្ដៅមានការទទួលស្គាល់ និងសុភមង្គល។

មិនយូរប៉ុន្មានខ្ញុំក៏ចាប់ផ្ដើមឃើញថា សុភមង្គលគឺជាទ្រព្យសម្បត្តិពិតប្រាកដនៅក្នុងផ្ទះ។ ប្ដីម្នាក់បានប្រាប់ប្រពន្ធរបស់គាត់ថា “ថ្ងៃមួយ យើងនឹងក្លាយជាអ្នកមាន ហើយយើងនឹងទិញរបស់ជាច្រើន”។ ប្រពន្ធគាត់បានតបថា “យើងបានក្លាយជាអ្នកមានហើយ! ប្រហែលនៅថ្ងៃណាមួយយើងនឹងមានលុយច្រើន និងមានលទ្ធភាពទិញរបស់ជាច្រើន”។ ក្នុងការពិភាក្សាអំពីទ្រព្យសម្បត្តិសាវ័ក ប៉ុល បានលើកឡើងថា “តែការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំងចិត្តស្កប់ស្កល់ផង នោះជាកម្រៃ១យ៉ាងធំមែន” (១ធីម៉ូថេ ៦:៦)។ គាត់បានបន្តរម្លឹកយើងឲ្យគិតអំពីភាពអស់កល្បជានិច្ច ពេលជ្រើសរើសអ្វីដែលយើងឲ្យតម្លៃ៖ “ដ្បិតយើងរាល់គ្នាមិនបានយកអ្វី ចូលមកក្នុងលោកីយ៍នេះទេ ហើយច្បាស់ជាយើងពុំអាចនឹងយកអ្វីចេញទៅវិញបានដែរ” (ខ៧)។

បន្ទាប់មក គាត់បានលើកឡើងថា បើយើងមានអ្វីដែលយើងត្រូវការសម្រាប់ជីវិតនេះហើយ នោះយើងគួរមានការស្កប់ចិត្ត «តែបើមានអាហារទទួលទាន នឹងសំលៀកបំពាក់ នោះក៏ល្មមឲ្យយើងបានស្កប់ចិត្តហើយ» (ខ៨)។ ជាចុងក្រោយ គាត់បានរៀបរាប់អំពីគ្រោះថ្នាក់នៃការប្រាថ្នាចង់ក្លាយជាអ្នកមាន «ឯពួកអ្នកដែលចង់ធ្វើជាអ្នកស្តុកស្តម្ភ នោះនឹងធ្លាក់ទៅក្នុងសេចក្តីល្បួងនឹងអន្ទាក់ ហើយក្នុងបំណងជាច្រើន ដែលផ្តេសផ្តាស ហើយធ្វើទុក្ខដល់ខ្លួន ក៏ពន្លិចមនុស្សទៅក្នុងសេចក្តីហិនវិនាស នឹងសេចក្តីអន្តរធានវិញ» (ខ៩)។ គ្រីស្ទបរិស័ទពិតជាងាយធ្លាក់ចូលក្នុងគ្រោះថ្នាក់នៃការដេញតាមទ្រព្យសម្បត្តិ ដែលបានបំផ្លាញជីវិតរបស់ពួកគាត់ ហើយលួចពីពួកគាត់នូវទ្រព្យសម្បត្តិដ៏មានតម្លៃនៃការស្កប់ចិត្ត។ ខ្ញុំធ្លាប់ឃើញការនោះកើតឡើងជាច្រើនដងហើយ។

ការស្កប់ចិត្តជាលក្ខណសម្បត្តិមួយដែលយើងត្រូវរៀនអភិវឌ្ឍតាមរយៈការអនុវត្ត។ សាវ័ក ប៉ុល បានលើកឡើងថា «ខ្ញុំបានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ។ [ក្នុងគ្រប់សណ្ឋានភាព] ខ្ញុំ [បានរៀន] ធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ» (ភីលីព ៤:១១ខ-១២)។ កន្លែងដែលល្អបំផុតក្នុងការរៀនអំពីការស្កប់ចិត្តគឺនៅផ្ទះ។ ដាច់ខាត! យើងទាំងអស់គ្នាត្រូវតែសង្វាតឲ្យមានការស្កប់ចិត្ត និងមានផ្ទះដែលមានសុភមង្គល។ បន្ទាប់មក ទោះបីយើងមិនមានលុយច្រើន (ហើយអ្នកបម្រើព្រះពេញម៉ោង នៅប្រទេសជាច្រើនក៏ពិតជាមិនមានមែន) នោះសមាជិកគ្រួសារយើងក៏អាចនៅគិតអំពីខ្លួនឯងថាជាអ្នកមានទ្រព្យសម្បត្តិដែរ។

ទោះជាយ៉ាងណាក៏ដោយ ក៏ជាពិសេសអំណរនៅក្នុងគ្រួសារ គឺជាចំណុចគន្លឹះដែលអ្នកខ្លះមិនសូវស្គាល់។ លោក ថិម ស្ទាហ្វឹត (Tim Stafford) បានមានប្រសាសន៍ថា «មនុស្សដែលមានអំណរភាគច្រើនគឺជាមនុស្សដែលបានធំធាត់ឡើងនៅក្នុងផ្ទះដែលពួកគាត់បានឃើញគំរូនៃការមានអំណរជាប្រចាំថ្ងៃ។ ការមានអំណរគឺជាផ្នែកមួយនៃវប្បធម៌ដែលគ្រួសារពួកគាត់មាន ដែល

ពួកគាត់ជ្រើសរើសបន្តមានទៅមុខទៀត»។[៣] ប៉ុន្តែ សព្វថ្ងៃនេះ គ្រីស្ទបរិស័ទជាច្រើននាក់មិនបានមានបទពិសោធន៍នៃការមានអំណរថាជាផ្នែកមួយនៃវប្បធម៌ក្នុងគ្រួសាររបស់ខ្លួនឡើយ។ ដូច្នេះ អំណរគឺជាចំណុចគន្លឹះមួយដែលយើងត្រូវរៀនរៀបឲ្យមាន និងព្យាយាមអនុវត្តដោយដឹងខ្លួន។ នៅចុងបញ្ចប់ព្រះគម្ពីរបានបញ្ជាឲ្យយើងមានអំណរ។ ដូច្នេះ ក្នុងជំពូកនេះ យើងនឹងពិនិត្យមើលចំណុចអនុវត្តន៍មួយចំនួន ដើម្បីបង្កើនរបៀបមានអំណរនៅក្នុងផ្ទះឲ្យកាន់តែច្រើនឡើង។ ជំពូក១១នឹងលើកឡើងអំពីមូលហេតុដែលកូនៗត្រូវមានការអរសប្បាយ និងអំពីរបៀបដែលយើងគួរបង្កើតឲ្យមានវប្បធម៌នៃការមានអំណរនៅក្នុងផ្ទះសម្រាប់កូនៗរបស់យើង។

## របរាំងជាខ្មាំងសត្រូវនៃអំណរ

ដោយសារគ្រួសារជាច្រើនមិនសង្វាតដេញតាមអំណរនៅក្នុងគ្រួសារបែបជាសេចក្តីប៉ងប្រាថ្នា នោះពួកគាត់ងាយនឹងធ្លាក់ចូលក្នុងអន្ទាក់មួយទៀត ដែលអាចនាំឲ្យបំផ្លាញអំណរនោះ។ នេះគឺជាអន្ទាក់នៃទាសករចំពោះរូបរាងពីក្រៅ។ ពួកគាត់គិតថា ប្រសិនបើពួកគាត់មិនអាចមានអំណរបានទេ នោះយ៉ាងហោចណាស់ក៏ពួកគាត់ត្រូវតែព្យាយាមបង្ហាញពីភាពជោគជ័យ ភាពមានបាន ឬក៏ឥទ្ធិពលរបស់ខ្លួន។ ក្នុងការស្វែងរកគោលដៅបែបនេះ ពួកគាត់ងាយធ្លាក់ចូលក្នុងការដើរតាមផ្លូវដ៏មានគ្រោះថ្នាក់ណាស់។

ផ្លូវដែលទូទៅបំផុតគឺជាការចំណាយលុយដែលពួកគាត់មិនមាន។ ពួកគាត់ទិញផ្ទះដែលពួកគាត់មិនមានលទ្ធភាពទិញបាន។ ឬក៏ពួកគាត់ទិញរបស់របរដាក់តាំងដែលធ្វើឲ្យផ្ទះរបស់ពួកគេមើលទៅកាន់តែស្អាតជាងមុន ទោះបីជាពួកគាត់មិនមានថវិកាគ្រប់គ្រាន់ក្នុងការទិញវានៅពេលនោះក៏ដោយ។ នៅពេលមានពិធីអាពាហ៍ពិពាហ៍នៅក្នុងគ្រួសារ ពួកគាត់ចំណាយលុយដែលពួកគាត់មិនមានគ្រប់គ្រាន់ក្នុងការរៀបចំទទួលភ្ញៀវ។ ហើយជាលទ្ធផល ពួកគាត់បានឈានដល់ទីបញ្ចប់ដោយភាពអស់សង្ឃឹម ដោយនៅជំពាក់ អ្នកឲ្យខ្ចី ធនាគារ

ឬក៏អ្នកបញ្ចាំជាដើម។ នៅពេលដែលពួកគាត់មិនអាចបន្តបង់ប្រាក់សងគេបាន នោះព្រលឹងវិញ្ញាណរបស់ពួកគាត់បានបាត់បង់សេរីភាព និងសន្តិភាពជាដើម។ ម្យ៉ាងទៀត ពួកគាត់ក៏ត្រូវបានបង្ខំចិត្តឲ្យកាត់បន្ថយការថ្វាយដង្វាយសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ ហើយពួកគាត់ក៏បានពិបាកក្នុងការចំណាយសម្រាប់របស់ចាំបាច់ដូចជា ម្ហូបអាហារ សុខភាព និងលើការអប់រំជាដើម។

ខ្ញុំពិតជាមានការភ្ញាក់ផ្អើលមែន ដែលឃើញថាមនុស្សជាច្រើនទិញរបស់របរដោយប្រើប្រាក់កម្ចី ដោយមិនបានគណនាដោយយកចិត្តទុកដាក់អំពីរបៀបដែលពួកគាត់នឹងសងវិញ។ ក្នុងប្រទេសជឿនលឿនមួយចំនួន ពួកគាត់ធ្វើការនោះតាមរយៈការប្រើប្រាស់កាតឥណទានកម្ចី២-៣។ ពួកគាត់បានដកលុយពីកាតមួយ ដើម្បីបង់កាតមួយទៀត នៅពេលដែលដល់ពេលសង។ ខ្ញុំធ្លាប់ឃើញមនុស្សមួយចំនួន ដែលពេលកំពុងស្ថិតក្រោមសម្ពាធនៃការទិញអ្វីមួយ ឬក៏ចំណាយលើអ្វីមួយ ពួកគាត់ក៏ខ្ចីលុយ បន្ទាប់ពីបានបង្កើតគម្រោងសងបំណុល ដែលមិនអាចអនុវត្តបាន។ ពួកគាត់មិនបានគិតអំពីការដែលសមាជិកគ្រួសារអាចធ្លាក់ខ្លួនឈឺ ឬក៏រឿងបន្ទាន់ផ្សេងទៀតដែលទំនងជានឹងប្រឈមមុខ។ ប្រសិនបើការនោះកើតឡើង នោះពួកគាត់នឹងនៅជាប់គាំង។ ពួកគាត់ដាក់បញ្ចាំរបស់មានតម្លៃ ដូចជាគ្រឿងអលង្ការ ហើយជាទូទៅក៏ត្រូវបាត់បង់ជាអចិន្ត្រៃយ៍។ ប៉ុន្តែ សំខាន់ជាងនោះទៅទៀត ពួកគាត់បន្តស្ថិតក្រោមភាពជាទាសករនៃប្រាក់កម្ចីនោះ។

នៅក្នុងប្រទេសស្រីលង្កា ប្រជាជនភាគច្រើនចំណាយលើសពីសមត្ថភាពនៅពេលដែលគ្រួសាររបស់ពួកគេមានពិធីអាពាហ៍ពិពាហ៍។ ជាធម្មតា មានការទទួលភ្ញៀវ ឬមានអាហារបរិភោគបែបគ្រឿងក្លែម។ ការមាននំខេកឆ្ងាញ់សម្រាប់អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាផ្នែកដ៏សំខាន់មួយនៅក្នុងកម្មវិធី។ ការអញ្ជើញភ្ញៀវច្រើន និងការទទួលភ្ញៀវដោយចំណាយច្រើនក៏ជាការបញ្ជាក់ពីឋានៈផងដែរ។ ជាលទ្ធផល គូស្រករជាច្រើនក៏រៀបការដោយផ្តើមជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនដោយជំពាក់បំណុលគេ ហើយឪពុកម្តាយក៏ជំពាក់ជាមួយនឹង

ពួកគាត់ដែរ។ ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់អំពីរបៀបដែលពួកគាត់បានចំណាយលើសសមត្ថភាព ទោះបើយើងដែលជាអ្នកដឹកនាំបានព្រមានពួកគេអំពីគ្រោះថ្នាក់នៃការនេះក៏ដោយ។ អ្នកខ្លះហាក់បីដូចជានៅជាប់ក្នុងព្រឹត្តិការណ៍នេះតែម្តង ដល់ថ្នាក់ថាពួកគាត់មិនដឹងថាខ្លួនចំណាយលើសនោះទេ។

កាលពីពីរទៅបីឆ្នាំមុន ខ្ញុំបានធ្វើដំណើរជាមួយបុគ្គលិករបស់ក្រុម យុវជនសម្រាប់ព្រះគ្រីស្ទ ទៅកាន់ភាគខាងជើងនៃប្រទេសស្រីលង្កា ដើម្បីចូលរួមពិធីអាពាហ៍ពិពាហ៍របស់បុគ្គលិកម្នាក់។ បន្ទាប់ពីពិធីអាពាហ៍ពិពាហ៍បានចប់រួចរាល់ យើងបានបរិភោគអាហារឆ្ងាញ់ៗ ហើយបន្ទាប់មកក៏ធ្វើដំណើរផ្លូវឆ្ងាយត្រឡប់មកផ្ទះវិញ។ ខណៈពេលដែលយើងកំពុងតែធ្វើដំណើរ មិត្តរួមការងាររបស់យើងម្នាក់ក៏បាននិយាយភ្លាមៗថា «អេ៎! ពួកគាត់មិនបានដាក់នំខេកឲ្យយើងបរិភោគនោះទេ»។ ដូចដែលបានលើកឡើងនៅខាងលើ គេបានចាត់ទុកនំខេកសម្រាប់ពិធីអាពាហ៍ពិពាហ៍ថាជាផ្នែកដ៏សំខាន់មួយក្នុងពិធីអាពាហ៍ពិពាហ៍នៅប្រទេសស្រីលង្កា។ ដោយចំអន់លេង មានម្នាក់នៅក្នុងឡានក៏បានទូរស័ព្ទទៅកូនកំលោះ ហើយសួរគាត់ថា «តើនំខេកទៅណាបាត់ហើយ?» គាត់បានឆ្លើយថា «នៅពេលដែលយើងគិតគូរពីការចំណាយសម្រាប់អាពាហ៍ពិពាហ៍ យើងឃើញថាយើងមិនមានលទ្ធភាពក្នុងការចំណាយលើទាំងម្ហូបអាហារផង និងទាំងលើនំខេកដ៏ឆ្ងាញ់ផងបានទេ។ ដូច្នេះហើយបានជាយើងសម្រេចចិត្តមិនចំណាយទៅលើនំខេក។» ខ្ញុំបានប្រាប់មិត្តរួមការងាររបស់ខ្ញុំថា «គាត់គឺជាវីរបុរសរបស់ខ្ញុំ!»។ គាត់សុខចិត្តមិនមាននូវអ្វីមួយដែលគេចាត់ទុកថាសំខាន់ ដើម្បីឲ្យគាត់អាចមានអាហារឆ្ងាញ់ៗសម្រាប់ភ្ញៀវដែលចូលរួមដោយមិនជាប់បំណុលគេ។

ខណៈពេលដែលកំពុងនិយាយលើប្រធានបទអាពាហ៍ពិពាហ៍ ខ្ញុំត្រូវតែនិយាយថា ជាទូទៅនៅក្នុងប្រទេសស្រីលង្កា ឪពុកម្តាយដែលជាគ្រីស្ទបរិស័ទរៀបចំអាពាហ៍ពិពាហ៍សម្រាប់កូនៗរបស់ខ្លួនជាមួយនឹងអ្នកដែលរស់នៅក្រៅប្រទេសក្នុងតំបន់លោកខាងលិច។ ពួកគេមានគំនិតថាបើរៀបការបែបដូចនោះ

មែន នោះកូនៗរបស់ពួកគេអាចរើទៅរស់នៅតំបន់លោកខាងលិច។ ពួកគាត់មានគំនិតថា ជីវិតអាពាហ៍ពិពាហ៍បែបនោះនឹងនាំឲ្យកូនៗរបស់ពួកគាត់រើទៅនៅប្រទេសខាងលិច និងធានាបាននូវសន្តិសុខផ្នែកហិរញ្ញវត្ថុនៅពេលអនាគតសម្រាប់គ្រួសារទាំងមូលផងដែរ។ ពួកគាត់ពឹងផ្អែកជម្រើសរបស់ខ្លួនទៅលើការណែនាំរបស់គ្រីស្ទបរិស័ទដទៃ។ ប៉ុន្តែ ជាពិសេសសម្រាប់វប្បធម៌នៅលោកខាងលិច បុគ្គលនិយមគឺជាអ្វីមួយដែលនាំឲ្យមនុស្សអាចមានរបៀបរស់នៅដោយមិនមាននរណាម្នាក់អាចដឹងបានទេ ដោយសារលោក់។ ការអនុវត្តបែបនេះបាននាំឲ្យមានជីវិតអាពាហ៍ពិពាហ៍ខូចខាតច្រើនណាស់ ដែលបង្កើតឲ្យមានការសោកស្ដាយយ៉ាងខ្លាំងដល់ឪពុកម្ដាយ!

ដូចដែលបានកត់ទុកនៅខាងលើ មិនថាពួកគេរស់នៅប្រទេសលោកខាងលិច ឬក៏ប្រទេសលោកខាងកើតក្ដី ឪពុកម្ដាយត្រូវតែមានការប្រុងប្រយ័ត្នអំពីការយករូបរាងខាងក្រៅថាជាការវិនិច្ឆ័យលើការលើកទឹកចិត្តឲ្យរៀបការ ឬមិនឲ្យរៀបការ។ ខ្ញុំធ្លាប់បានឃើញឪពុកម្ដាយបដិសេធគម្រោងអាពាហ៍ពិពាហ៍ដែលគ្រីស្ទបរិស័ទម្នាក់ចង់រៀបការជាមួយគ្រីស្ទបរិស័ទម្នាក់ទៀតដែលល្អ ពីព្រោះពួកគេគិតថា គូស្រករនោះមានឋានៈទាបក្នុងសង្គម ឬក៏មិនស្អាត ឬសង្ហាល្មមសម្រាប់កូនខ្លួន។ ពួកគាត់មើលទៅលើពណ៌សម្បុរនៅលើស្បែក ឬក៏ផ្នែកហិរញ្ញវត្ថុរបស់គាត់ថាជាការមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់។ បុរស និងស្ត្រីទាំងពីរនាក់ស្រឡាញ់ព្រះគ្រីស្ទ ហើយក៏រំពឹងទុកថាពួកគាត់នឹងមានភាពភ្លឺស្វាងចេញពីការរស់នៅដ៏មានសុភមង្គលជាមួយគ្នា។ ប៉ុន្តែ ដោយសារមូលហេតុដែលបានចាត់ទុកក្នុងឋានៈដែលគិតពី «រូបរាងខាងក្រៅ» នោះឪពុកម្ដាយក៏ជំទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍នោះ។ ឪពុកម្ដាយទាំងនោះអាចជាអ្នកដឹកនាំគ្រីស្ទបរិស័ទ ឬក៏ជាគ្រូគង្វាលទៀតផង ប៉ុន្តែអាកប្បកិរិយារបស់ពួកគាត់គឺពោរពេញដោយអំពើបាប និងស្របតាមលោកីយ៍ទៅវិញ!

ជាទូទៅ ការជាប់ក្នុងភាពជាទាសករនឹងរូបរាងខាងក្រៅគឺជាបញ្ហាសម្រាប់អស់អ្នកដែលធ្លាប់ជាអ្នកក្រ ប៉ុន្តែឥឡូវរួចពីភាពក្រីក្រ។ មានគ្រីស្ទបរិស័ទជា

ច្រើនដែលខ្ញុំបានធ្វើការជាមួយ ពួកគាត់បានធំធាត់ឡើងនៅក្នុងផ្ទះដែលរង គ្រោះក្នុងការខ្វះខាតដោយសារភាពក្រីក្រ និងការញៀនស្រា។ បន្ទាប់មក ពួកគាត់ក៏បានស្គាល់ព្រះគ្រីស្ទ។ ពួកគាត់ក៏បានចាប់ផ្ដើមដំណើររកឃើញ អត្តសញ្ញាណថ្មីនៅក្នុងព្រះគ្រីស្ទ។ ពួកគាត់បានដឹងថា ពួកគាត់មិនចាំបាច់ មានអារម្មណ៍ថាខ្លួនតូចទាបជាង ចំពោះអស់អ្នកដែលពួកគាត់ធ្លាប់ចាត់ទុក ថាមានឋានៈខ្ពស់ជាងនោះទៀតឡើយ។ ប៉ុន្តែ ពួកគាត់នៅតែមានស្នាមរបួស ដែលធ្វើឲ្យពួកគាត់ឈឺចាប់ អំឡុងពេលដែលពួកគាត់រស់នៅក្នុងស្ថានភាព ក្រីក្រនោះ។ ការចងចាំអំពីការដែលគេបានសើចចំអកដាក់ ដោយសារពួក គាត់ពាក់ស្បែកជើងចាស់ៗ និងខោអាវរហែកដែលបានប៉ះនៅពេលទៅសាលា នៅតែរម្លឹកក្នុងគំនិតរបស់ពួកគាត់យ៉ាងស្រស់ៗ។ ពួកគាត់មិនចង់ឲ្យកូនៗ របស់ខ្លួនមានបទពិសោធន៍ដូចនោះទេ។ ឥឡូវ ពួកគាត់មានមិត្តភក្តិនៅក្នុង ក្រុមជំនុំដែលមានទ្រព្យសម្បត្តិប្រហាក់ប្រហែលគ្នា។ ពួកគាត់មានអារម្មណ៍ ថា ខ្លួនមានសិទ្ធិក្នុងការមានអំណរជាមួយអ្វីដែលមិត្តភក្តិរបស់ខ្លួនទាំងនោះ មានដែរ។ ការផ្សាយលើកញ្ញក់ទូរទស្សន៍បានល្បួងពួកគាត់ឲ្យមានជម្រើស បង់ថ្លៃរយៈពេលយូរ ក្នុងការទិញអ្វីមួយដែលពីមុនពួកគាត់ធ្លាប់គិតថា ជា ភាពអរសប្បាយដែលមិនអាចទទួលយកបាន។ គេធ្លាប់ហៅចំណុចនេះថា “ការធ្វើបដិវត្តន៍នៃសន្ទុះរំពឹង”។ អស់អ្នកដែលធ្លាប់ឆ្លងកាត់វាក៏អាចធ្លាក់ក្នុង ការជាប់បំណុលយ៉ាងខ្លាំងដែរ។

យើងត្រូវតែចងចាំថា ភាពស្មើគ្នាគឺមិនដូចគ្នានឹងការមានរបៀបរស់នៅ ស្មើគ្នាទៅនឹងគ្រួសារគ្រីស្ទបរិស័ទផ្សេងទៀតនោះទេ។ យើងត្រូវតែរស់នៅ ស្របតាមមធ្យោបាយរបស់យើង ហើយរីករាយជាមួយអ្វីដែលខ្លួនមាន។ ឧទាហរណ៍៖ នៅក្នុងប្រទេសស្រីលង្កា មានសាលាប្រភេទផ្សេងៗគ្នា។ ការ បង់ថ្លៃសាលាថ្លៃបំផុតគឺត្រូវបានគិតដោយសាលាដែលគេហៅថាជាសាលា អន្តរជាតិ។ មានគ្រីស្ទបរិស័ទជាច្រើនបានយកកូនៗរបស់ខ្លួនឲ្យចូលរៀននៅ សាលាទាំងនោះ។ វាមិនមែនជាការអ្វីខុសឆ្គងលើចំណុចទាំងនោះទេ។ ប៉ុន្តែ

មានគ្រីស្ទបរិស័ទមួយចំនួនដែលមិនមានលទ្ធភាពក្នុងការបង់ក៏បានយកកូនៗខ្លួនទៅដាក់នៅសាលាទាំងនោះដែរ។ ពួកគាត់មានការពិបាកក្នុងការបង់ថ្លៃ ហើយពេលខ្លះក៏ជួបបញ្ហាដោយសារពួកគាត់មិនអាចបង់ថ្លៃបាន។ អ្នកខ្លះក៏ត្រូវបង្ខំចិត្តក្នុងការដកកូនខ្លួនចេញពីសាលាវិញ ដោយសារមិនអាចបង់ថ្លៃសាលាបាន។

នៅពេលដែលព្រះយេស៊ូវសព្វព្រះហឫទ័យចង់បង្រៀនយើងអំពីតម្រូវការ ក្នុងការរៀបចំគម្រោងផែនការមុនពេលដែលយើងចាប់ផ្ដើមធ្វើវា មានឧទាហរណ៍មួយដែលព្រះអង្គបានលើកឡើង ហើយនោះគឺជាគម្រោងផែនការក្នុងការសាងសង់៖ «ដ្បិតក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនទេឬអី ដើម្បីឲ្យដឹងជាមានល្មមនឹងធ្វើបង្ហើយបានឬមិនបាន ក្រែងកាលណាដាក់ជើងជញ្ជាំង រួចបង្ហើយមិនបាន នោះអស់អ្នកណាដែលឃើញក៏នឹងសើចចំអកឲ្យ ដោយពាក្យថា អ្នកនេះបានចាប់ផ្ដើមសង់ផ្ទះ តែបង្ហើយមិនបាន» (លូកា ១៤:២៨-៣០)។ យើងមិនត្រូវអនុញ្ញាតឲ្យបំណងប្រាថ្នារបស់យើងទទួលបាន ឬក៏សាងសង់អ្វីមួយដែលមើលទៅស្រស់ស្អាតដែលធ្វើឲ្យយើងសម្រេចចិត្តបែបល្ងង់ខ្លៅក្នុងការចំណាយលើសកំណត់នោះទេ។

មានកូនៗមួយចំនួនរបស់ព្រះបានចាកចេញពីផ្លូវនៃការត្រាស់ហៅរបស់ខ្លួនចេញពីព្រះជាម្ចាស់ ដើម្បីឲ្យទទួលបានភាពជោគជ័យខាងឯផ្នែកហិរញ្ញវត្ថុ។ ទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ អស់អ្នកដែលបានទទួលការត្រាស់ហៅក្នុងការធ្វើព័ន្ធកិច្ចទំនងជាអាចបោះបង់ព័ន្ធកិច្ច ឬចាកចេញពីព័ន្ធកិច្ចណាមួយដែលពួកគាត់បម្រើ ដើម្បីទៅធ្វើនៅកន្លែងមួយទៀតដែលទទួលបានប្រាក់កម្រៃប្រសើរជាងមុនកាលនៅក្នុងព័ន្ធកិច្ច។ ហើយមនុស្សមួយចំនួនក៏ចាកចេញពីប្តី ឬប្រពន្ធ និងកូនៗរបស់ខ្លួន ហើយទៅធ្វើការនៅក្រៅប្រទេស ដើម្បីរកលុយ ហើយអាចជួបគ្នាបានត្រឹមតែម្តងក្នុងរយៈពេលពីរឆ្នាំក៏មាន។

អ្នកដឹកនាំម្នាក់របស់យើងក្នុងនិកាយធំមួយ ក្នុងប្រទេសស្រីលង្កា បាន

ប្រាប់ខ្ញុំអំពីស្ថានភាពទូទៅដូចនោះក្នុងជីវិតគ្រូគង្វាលជាច្រើន។ គ្រួសាររបស់គ្រូគង្វាលម្នាក់មិនទទួលបានបទពិសោធន៍ក្នុងការមានអំណរ។ គ្រួសារត្រូវមានការលះបង់ ដោយសារព័ន្ធកិច្ចរបស់គ្រូគង្វាលនោះ។ ជារឿយៗ គាត់តែងតែប្រាប់គ្រួសារគាត់ថា ការលះបង់គឺដោយសារការត្រាស់ហៅរបស់ព្រះជាម្ចាស់។ គាត់បានរៀបការជាមួយនឹងនារីដែលមានការប្ដេជ្ញាចិត្តខ្លាំងជាងគេម្នាក់នៅក្នុងក្រុមយុវជន ហើយដោយការប្ដេជ្ញាចិត្តរបស់គាត់ចំពោះព្រះគ្រីស្ទ នោះជាលទ្ធផល គាត់ក៏បានទ្រាំទ្រជាមួយនឹងការខ្វះខាតដែលបានកើតឡើងដោយសារការមិនខ្វល់ខ្វាយពីប្ដីរបស់គាត់ ដែលជាគ្រូគង្វាល។ ប៉ុន្តែ បន្ទាប់ពី១៥ឆ្នាំនៃការទ្រាំទ្រដូចនេះ គាត់សម្រេចចិត្តថា គាត់ទ្រាំលែងបានហើយ។ គាត់ដឹងថា ការលំបាកដែលពួកគាត់បានទ្រាំទ្រគឺដោយសារគ្រូគង្វាលមិនដាក់វិន័យលើខ្លួនឯង ឬក៏ជាការខ្វះការយកចិត្តទុកដាក់ជាជាងការស្ដាប់បង្គាប់របស់គាត់ចំពោះព្រះជាម្ចាស់។ គាត់ក៏ចាប់ផ្ដើមបះបោរប្រឆាំងនឹងការត្រាស់ហៅរបស់ប្ដី។ គាត់ធ្វើការទាមទារដែលប្ដីមិនអាចបំពេញបាន។ ដោយមិនមានអំណរ យ៉ាងហោចណាស់គាត់ចង់បានសម្ភារៈមួយចំនួនក្នុងការបំពេញចិត្តដែរ។ ប្ដីមិនអាចបំពេញតម្រូវការរបស់ប្រពន្ធបាន ខណៈពេលដែលគាត់កំពុងធ្វើព័ន្ធកិច្ចនោះបានទេ។ ដូច្នេះ គាត់ក៏បានប្ដូរការងារ—ដោយការចាកចេញពីការត្រាស់ហៅរបស់គាត់ទៅរកការងារដែលផ្ដល់រង្វាន់ផ្នែកហិរញ្ញវត្ថុវិញ។

គ្រូគង្វាលអាចគេចចេញពីស្ថានភាពបែបនេះបាន ប្រសិនបើគាត់មានការប្រាជ្ញាចិត្តក្នុងការនាំឲ្យមានអំណរក្នុងគ្រួសាររបស់គាត់។ មានការជាច្រើនដែលអាចបង្កើតអំណរបាន ដោយមិនចាំបាច់ចំណាយលុយកាក់នោះទេ។ ដោយធ្វើការទាំងអស់នេះ យើងអាចបង្រៀនដល់កូនៗយើងថា បទពិសោធន៍ដ៏មានតម្លៃបំផុតនៅក្នុងជីវិតនេះគឺមិនចាំបាច់ត្រូវផ្សាភ្ជាប់ជាមួយនឹងធនធានផ្នែកហិរញ្ញវត្ថុនោះទេ។

ឪពុករបស់លោក ធិម ស្វាហ្វនដ៍ ដែលជាគ្រូគង្វាល ជាមិត្តភក្តិរបស់ខ្ញុំ

ហើយក៏ជាអ្នកនិពន្ធម្នាក់ គាត់បានធំធាត់ឡើងក្នុងផ្ទះ ដែលគេរាប់ថាក្នុងកម្រិតក្រលួម។ គាត់បានលើកឡើងថា “កាលខ្ញុំនៅតូច...ខ្ញុំមានអារម្មណ៍ថាយើងមិនមានឋានៈគ្រប់គ្រាន់នោះទេ។ ប៉ុន្តែ បើកត់សម្គាល់ឲ្យបានគ្រប់គ្រាន់ទៅ ខ្ញុំមិនដែលមានអារម្មណ៍ថាយើងពិតជាក្រឡើយ”។ គាត់បាននិយាយថា “គន្លឹះនោះ...គឺជាគោលជំហររបស់ឪពុកម្ដាយខ្ញុំ។ ជាជាងនិយាយអំពីភាពខ្វះខាត ពួកគាត់បានផ្ដោតទៅលើអ្វីដែលពួកគាត់មាន។ ពួកគាត់បានព្យាយាមជួយឲ្យកូនៗជឿថា ពួកគាត់កំពុងមានអំណរនៅក្នុងអ្វីដែលល្អបំផុតនៅក្នុងជីវិតនេះដូចជា ការអានសៀវភៅ ការស្ដាប់តន្ត្រី ការបោះតង់ និងការលេងបាល់ជាដើម”។ ជាលទ្ធផល គាត់បាននិយាយថា “យើងគិតថា យើងប្រសើរជាងអស់អ្នកដែលទិញឡានទ្បូយៗ និងញ៉ាំសាច់ឆ្ងាញ់ៗ ដើម្បីឲ្យជីវិតមានភាពរីករាយ”។ ការដែលគ្រួសារអនុវត្តការឲ្យក៏បានជួយពង្រឹងគំនិតដែលថា ពួកគាត់ជាគ្រួសារដែលមានអភ័យឯកសិទ្ធិ។ លោក ស្វាហ្វូនដ៍ បានលើកឡើងថា “ការចងចាំដ៏ច្បាស់លាស់មួយដែលខ្ញុំមានកាលខ្ញុំនៅក្មេងគឺអំពីពេលវេលាមួយដែលអ្នកម្ដាយរបស់ខ្ញុំបាននៅរហូតដល់យប់ជ្រៅ នៅយប់មួយ ដើម្បីសរសេរវិក្កយបត្រលុយផ្ញើទៅកាន់អង្គការគ្រីស្ទបរិស័ទមួយចំនួន។ “ការដាក់ដង្វាយធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំជាអ្នកមាន” អ្នកម្ដាយរបស់ខ្ញុំបាននិយាយមកកាន់ខ្ញុំខណៈពេលដែលគាត់ងើយមើលលើ។ “យើងមានលុយទាំងនេះដើម្បីឲ្យទៅអ្នកដទៃ””»។[៤]

យើងកំពុងតែនិយាយអំពីអ្នកផ្ទះ ដែលទទួលបានសេរីភាពចេញពីភាពជាទាសករនៃការបោកបញ្ឆោត ចំពោះភាពចម្រុងចម្រើនផ្នែកសម្ភារៈនិយម និងរបៀបណាផ្សេងទៀតដែលបង្ហាញថា ខ្លួនជោគជ័យពេលមើលពីខាងក្រៅ។ យើងកំពុងតែនិយាយអំពីអ្នកផ្ទះ ដែលមានការខិតខំប្រឹងប្រែងក្នុងការចិញ្ចឹមបីបាច់កូនៗ ដែលមានការស្កប់ចិត្ត មានអំណរក្នុងព្រះអម្ចាស់ និងក្នុងការស្រឡាញ់ និងការប្ដេជ្ញាចិត្តអំពីហេតុរបស់ខ្លួន។

## អំណរលាតត្រដាងចេញតាមរយៈការសរសើរ

ការសរសើរតម្កើងគឺជាផ្នែកមួយដ៏សំខាន់នៃជីវិតរបស់គ្រីស្ទបរិស័ទ។ ខ្ញុំហ៊ាន ហៅការនេះថា ជាការបង្រៀនដ៏សំខាន់មួយរបស់គ្រីស្ទបរិស័ទ។ ចំណុច ដំបូង និងសំខាន់បំផុតនោះគឺថា យើងសរសើរតម្កើងព្រះជាម្ចាស់។ ហើយ ការសរសើរតម្កើងទាំងនេះមានអត្ថប្រយោជន៍ជាច្រើន។ ជាដំបូង វាថ្វាយព្រះ កិត្តិនាមដល់ព្រះជាម្ចាស់។ ទី២ វាជួយយើងឲ្យចងចាំសេចក្ដីពិតអំពីព្រះជា ម្ចាស់ ដែលអាចមានភាពស្រអាប់ដោយសារសម្ពាធនៃជីវិតនេះ។ ទី៣ វាជួយ យើងឲ្យមានអំណរជាមួយព្រះជាម្ចាស់ថែមទៀត។ សេចក្ដីអំណរមិនមានភាព ពេញលេញនោះទេរហូតទាល់តែត្រូវបានចែកចាយបន្តសិន។ យើងមិនអាច រីករាយពេញលេញជាមួយនឹងអំណោយបានទេ រហូតទាល់តែយើងស្គាល់ពី ការដឹងគុណរបស់យើងចំពោះអ្នកដែលផ្ដល់ឲ្យសិន។ ដូច្នេះ ការសរសើរតម្កើង គឺជាផ្លូវមួយក្នុងការមានអំណរ នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ។

ដូចដែលយើងសរសើរតម្កើងព្រះជាម្ចាស់ យើងក៏សរសើរដល់អ្នកដទៃដែរ ដោយសារយើងរីករាយជាមួយនឹងពួកគាត់។ គ្រីស្ទបរិស័ទគឺជាមនុស្សដែល រីករាយជាមួយនឹងអ្នកដទៃ ដូចដែលស្តេច ដាវីឌ បានលើកឡើងថា «ចំណែក ពួកបរិសុទ្ធដែលនៅផែនដី នោះជាពួកប្រសើរដែលគាប់ចិត្តទូលបង្គំគ្រប់ជំពូក» (ទំនុកតម្កើង ១៦:៣)។ នៅពេលយើងរីករាយជាមួយនឹងពួកគាត់ នោះយើង ក៏សរសើរពួកគាត់ដែរ។ ដូច្នេះហើយបានជាសាវ័ក ប៉ុល បានសរសើរដល់អ្នក ដទៃជាច្រើនដង នៅក្នុងសំបុត្ររបស់គាត់។ នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦ ដែល ជាជំពូកចុងក្រោយនៃសំបុត្រទេវវិទ្យាដ៏អស្ចារ្យរបស់គាត់ គាត់បានលើកឡើង នូវមនុស្សចំនួន៣៥នាក់តាមឈ្មោះ ហើយគាត់មានចំណុចល្អៗដែលនិយាយ អំពីពួកគាត់ចំនួន១៩នាក់! ភាគច្រើនក្នុងសំបុត្ររបស់គាត់ គាត់បានលើក ឡើងថា គាត់អរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់មិត្តអ្នកអានរបស់គាត់ នៅ ក្នុងការអធិស្ឋានឲ្យពួកគាត់។ នៅពីក្រោយការនោះគឺថា គាត់មានអំណរជា មួយមនុស្ស។ ខ្ញុំអាចរកបានខគម្ពីរចំនួន២១ដង នៅក្នុងសំបុត្ររបស់សាវ័ក

ប៉ុល ដែលគាត់បានលើកឡើងពីការដែលគាត់មានអំណរជាមួយមនុស្ស។

ដើម្បីឲ្យមានសេចក្ដីរីករាយចំពោះអ្នកដទៃបាន យើងត្រូវតែដឹងអំពីសេចក្ដីអំណររបស់ព្រះជាម្ចាស់ដែលទ្រង់កំពុងរីករាយចំពោះយើងសិន។ កណ្ឌគម្ពីរទំនុកតម្កើង បានប្រាប់យើងចំនួន៥ដងថា ព្រះជាម្ចាស់មានសេចក្ដីរីករាយ ឬក៏សព្វព្រះទ័យចំពោះរាស្ត្ររបស់ព្រះអង្គ (ទំនុកតម្កើង ៣៥:២៧; ៤១:១១; ៤៤:៣; ១៤៧:១១; ១៤៩:៤)។ ហោរា អេសាយ បានលើកឡើងថា “ព្រះយេហូវ៉ាទ្រង់មានសេចក្ដីរីករាយចំពោះឯង” (អេសាយ ៦២:៤; សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ សេផានា ៣:១៧)។ អស់អ្នកដែលដឹងអំពីអំណររបស់ព្រះជាម្ចាស់ដែលទ្រង់កំពុងរីករាយជាមួយពួកគេនឹងរៀនមានអំណរថាជាទិដ្ឋភាពដ៏សំខាន់មួយក្នុងជីវិតរបស់ខ្លួន។ ការនេះនាំឲ្យគាត់អាចរីករាយជាមួយអ្នកដទៃបាន ជាពិសេសជាមួយនឹងដៃគូជីវិតរបស់ខ្លួន។ លទ្ធផលគឺថា យើងចេះផ្ដល់តម្លៃខ្ពស់ដល់ដៃគូជីវិត ចេះសរសើរ និងលើកតម្កើងពួកគាត់។ អស់អ្នកដែលមិនទាន់ចេះទទួលសេចក្ដីពិតដែលថា ព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយនឹងពួកគាត់ ក៏នឹងមានការពិបាកក្នុងការយកអំណរធ្វើជាចំណុចចម្បងមួយក្នុងការដែលពួកគាត់ដើរក្នុងផ្លូវជីវិតនេះ។ នេះគឺជាបញ្ហាខាងឯវិញ្ញាណ ដែលត្រូវការការកែតម្រង់។

ដូច្នេះ ការសរសើរកើតចេញពីសេចក្ដីអំណរ។ ប៉ុន្តែ វាក៏ធ្វើឲ្យអំណររបស់យើងកាន់តែកើនឡើងផងដែរ។ នៅពេលលោកអ្នកបង្ហាញពីការឲ្យតម្លៃដល់នរណាម្នាក់ នោះលោកអ្នកកំពុងតែបំពេញការវិលជុំនៃការមានអំណរដែលបានចាប់ផ្ដើមដោយចំណុចស័ក្ដិសមនៃទង្វើនៃការសរសើររបស់បុគ្គលនោះ ហើយឈានដល់ការដែលលោកអ្នកឲ្យតម្លៃលើចំណុចនោះ។ ការវិលជុំនៃអំណរទទួលបានការបំពេញ នៅពេលដែលយើងបង្ហាញការឲ្យតម្លៃរបស់យើងក្នុងការសរសើរ។ ទាក់ទងនឹងការត្រាស់ហៅរបស់យើងឲ្យសរសើរព្រះជាម្ចាស់ លោក ស៊ី. អែស. លូវីស (C. S. Lewis) បានលើកឡើងថា “ខ្ញុំគិតថាយើងសប្បាយចិត្តក្នុងការសរសើរនូវអ្វីដែលយើងមានអំណរជាមួយ ពីព្រោះការ

សរសើរមិនគ្រាន់តែបង្ហាញ ប៉ុន្តែក៏បំពេញនូវការមានអំណរផងដែរ។ វាគឺជាវិធីសាស្ត្រដែលទ្រង់បានតែងតាំង ដើម្បីសម្រេចកិច្ចអំណរនៃការសម្រេចកិច្ច»។[៥]

លើសពីនោះទៅទៀត ការអនុវត្តន៍នូវការប្រាប់ពីការល្អៗអំពីប្ដី ឬប្រពន្ធរបស់ខ្លួនក៏ជួយយើងឲ្យបានដឹងពីអំពីចំណុចល្អៗរបស់គាត់ជាថ្មីម្ដងទៀតដែរ។ ការនេះអាចឲ្យយើងមានការលូតលាស់ក្នុងការឲ្យតម្លៃដល់ពួកគាត់។ ជាលទ្ធផល ការនេះជាការបំភ្លឺទំនាក់ទំនងនៅក្នុងរបៀបដ៏ពិសេសមួយ ដោយសារយើងទទួលស្គាល់តម្លៃរបស់ប្ដី ឬប្រពន្ធរបស់យើង។ ដូច្នេះ ការសរសើរផ្ដល់កម្រិតថ្មីមួយទៀតនៃសេចក្ដីអំណរទៅកាន់អ្នកដែលផ្ដល់ឲ្យ និងអ្នកដែលទទួលយកផងដែរ។ ដោយសារសេចក្ដីអំណរមានតម្លៃយ៉ាងសំខាន់ក្នុងជីវិតគ្រីស្ទបរិស័ទ វាមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ដែលការសរសើរក៏មានតម្លៃយ៉ាងសំខាន់ក្នុងការអនុវត្តន៍ក្នុងជីវិតគ្រីស្ទបរិស័ទដែរ។

កណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនមានពេញដោយបទចម្រៀងពីការដែលប្ដីសរសើរដល់ប្រពន្ធរបស់ខ្លួន ហើយប្រពន្ធសរសើរប្ដីខ្លួនដែរ។ គន្លឹះនៃសេចក្ដីបង្រៀនមួយគឺថា យើងរៀនអំពីប្ដី ឬប្រពន្ធរបស់យើង ត្រិះរិះពិចារណាចំពោះអ្វីដែលយើងឃើញ ហើយបង្ហាញផលផ្លែនៃការពិចារណានោះទៅកាន់ប្ដី ឬប្រពន្ធរបស់យើងតាមរយៈការសរសើរ។ នេះគឺជាឧទាហរណ៍មួយៈ ប្ដីបាននិយាយថា «មើល ឯងស្រស់របស់ល្អ មាសសម្លាញ់អើយ មើល ឯងស្រស់របស់ល្អណាស់ ភ្នែកឯងដូចជាភ្នែកព្រាប» (បទចម្រៀងសាឡូម៉ូន ១:១៥)។ ហើយប្រពន្ធក៏បានឆ្លើយតបវិញថា «មើល ព្រះអង្គក៏ល្អ ស្ងួនសម្លាញ់អើយ អើ ទ្រង់គួរស្រឡាញ់ណាស់» (ខ១៦)។

កាលខ្ញុំនៅរៀននៅសាលាព្រះគម្ពីរ ទេវវិទ្យា ហ្វូល័រ (Fuller Theological Seminary) អ្នកនិពន្ធគ្រីស្ទបរិស័ទដ៏មានឈ្មោះល្បីល្បាញម្នាក់ឈ្មោះលោកឆាលី ស្សែដ (Charlie Shedd) បានមកអធិប្បាយនៅសាលា។ នៅថ្ងៃនោះគឺជាថ្ងៃគម្រប់ខួបអាពាហ៍ពិពាហ៍លើកទី២៥ឆ្នាំរបស់គាត់ ហើយប្រពន្ធរបស់គាត់ក៏នៅទីនោះដែរ។ គាត់បានលើកឡើងថា ក្នុងរយៈពេល២៥ឆ្នាំដែលគាត់

បានរៀបការ គាត់បានបង្កើតទំលាប់មួយដែលថាយ៉ាងហោចណាស់ក្នុងមួយថ្ងៃ ដើម្បីសរសើរប្រពន្ធរបស់គាត់ ហើយស្វែងរកចំណុចថ្មីមួយផ្សេងទៀត ដើម្បីសរសើរគាត់រៀងរាល់សប្តាហ៍ដែរ។ វាពិតជារឿងដ៏ភ្ញាក់ផ្អើលមែនចំពោះខ្ញុំ ដែលយើងជាអ្នកអាស៊ីអាគ្នេយ៍បញ្ចេញការសរសើរយ៉ាងខ្លាំងក្នុងទីសាធារណៈ ដូចជានៅក្នុងប៉ុស្តិ៍វិទ្យុ ឬក៏ក្នុងការថ្លែងសន្ទរកថា ប៉ុន្តែធ្វើតិចណាស់នៅពេលដែលយើងមានការសន្ទនាបែបបុគ្គល។ ជាពិសេស កង្វះខាតនេះមាននៅក្នុងផ្ទះសំបែង។ ពេលខ្លះ មនុស្សយើងនិយាយថា «នាងដឹងហើយថា ខ្ញុំឲ្យតម្លៃដល់នាង ដូច្នេះខ្ញុំមិនចាំបាច់ប្រាប់នាងម្តងហើយម្តងទៀតនោះទេ»។ ការឆ្លើយតបរបស់ខ្ញុំគឺថា នៅពេលដែលមានអំបិលច្រើនខ្លាំងពេកនៅក្នុងម្ហូប យើងប្រាកដជាលើកយកមកនិយាយហើយ ទោះបីជាប្រពន្ធបានដឹងរួចហើយក៏ដោយ!

ដូច្នេះ របៀបដ៏ល្អមួយក្នុងការបង្ហាញសេចក្តីស្រឡាញ់ដល់ប្តី ឬប្រពន្ធ ក៏ដូចជាកូនៗរបស់យើងគឺជាការសរសើរពួកគាត់។ កូនៗរបស់យើងនឹងចូលទៅក្នុងពិភពនៃការប្រកួតប្រជែង ដែលអាចនាំឲ្យមានការឈឺចាប់ដល់ពួកគាត់។ វាពិតជារឿងគួរឲ្យអស្ចារ្យណាស់ដែលក្មេងៗអាចធ្វើបាបគ្នាទៅវិញទៅមកនៅសាលារៀនបាន។ យើងមិនអាចការពារកូនៗរបស់យើងពីការវាយប្រហារទាំងអស់នោះបានឡើយ ប៉ុន្តែយើងអាចផ្តល់ភាពកក់ក្តៅដល់ពួកគាត់ ការទទួលយកពីមជ្ឈដ្ឋានពីអ្នកនៅក្នុងផ្ទះ ដែលប្រាប់ពួកគាត់ថា ពួកគេសំខាន់ មិនថាពួកគាត់បានឮអ្វីពីពិភពខាងក្រៅក៏ដោយ។ យើងក៏អាចនិយាយដូចនេះអំពីឪពុកម្តាយមួយចំនួនផងដែរ។ ជារឿយៗ ពួកគាត់តែងតែជួបប្រទះនូវការប្រកួតប្រជែង ការច្រណែន ការនិយាយដើម និងភាពឈឺចាប់នៅកន្លែងការងារ ហើយសូម្បីតែក្នុងក្រុមជំនុំដែរ។ វាពិតជារឿងដែលគួរឲ្យធូរស្បើយណាស់ក្នុងការដែលត្រឡប់មកផ្ទះដែលមានពេញដោយការស្វាគមន៍ និងការឲ្យតម្លៃបែបនេះ!

## សេចក្ដីសន្និដ្ឋាន

យើងនឹងពិភាក្សាបន្ថែមទៀតអំពីសេចក្តីអំណរនៅក្នុងជំពូក១១ ពេលដែលយើងនិយាយអំពីតម្រូវការរបស់កូនៗក្នុងការសប្បាយ និងអំពីភាពរីករាយក្នុងទំនាក់ទំនងគ្រួសារ។ ប៉ុន្តែ សម្រាប់ឥឡូវនេះ ខ្ញុំសូមលើកទឹកចិត្តឲ្យលោកអ្នកព្យាយាមខិតខំប្រឹងប្រែងកែប្រែផ្ទះខ្លួនឲ្យក្លាយជាកន្លែងមួយដែលពេញដោយអំណរ។ នេះគឺជាគោលដៅដ៏ល្អដែលយើងអាចខំប្រឹងប្រែងឈោងចាប់!

៧

# ការខកចិត្ត និងការឈឺចាប់

មិត្តភក្តិរបស់ខ្ញុំម្នាក់ដែលជាអ្នកដឹកនាំក្នុងតំបន់នៃអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ នៅប្រទេសអាមេរិក បានប្រាប់ខ្ញុំកាលពីប៉ុន្មានឆ្នាំមុននេះថា គាត់មានអារម្មណ៍ថា សិក្ខាសាលាអាពាហ៍ពិពាហ៍ទំនងជាអ្វីដែលមានចំណែកយ៉ាងខ្លាំង ក្នុងការនាំឲ្យប្តីប្រពន្ធគ្រីស្ទបរិស័ទជាច្រើនគូលែងលះគ្នា។ គាត់បានមានប្រសាសន៍ថា សិក្ខាសាលាបានធ្វើបទបង្ហាញអំពីអាពាហ៍ពិពាហ៍ក្នុងលក្ខណៈវិជ្ជមានខ្លាំងពេក ដែលនាំឲ្យអ្នកចូលរួមចេញទៅដោយមានការរំពឹងយ៉ាងខ្លាំង។ នៅពេលដែលគូស្រករមិនបានសម្រេចការរំពឹងទាំងនោះ ពួកគាត់ទទួលបានបទពិសោធន៍នៃការខកចិត្តយ៉ាងខ្លាំង។ ពួកគាត់មានទំនោរក្នុងការគិតថា ជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់មិនអាចទទួលបានការស្រមៃល្អបែបជាគ្រីស្ទបរិស័ទនៅក្នុងទំនាក់ទំនងរបស់ពួកគាត់ផ្ទាល់ទេ។ ដូច្នេះ ពួកគាត់ក៏ធ្វើសេចក្តីសន្និដ្ឋានថា ជីវិតអាពាហ៍ពិពាហ៍របស់គាត់គឺមិនមែនជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ហើយពួកគាត់ក៏បែកគ្នាទៅ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅក្នុងព្រះគម្ពីរនៅមានសាច់រឿងជាច្រើនអំពីគ្រួសារដែលមិនមានសុភមង្គលនៅក្នុងចំណោមប្រជាជនដ៏អស្ចារ្យរបស់ព្រះអង្គដែរ។ ហោរា ហូសេ មានប្រពន្ធដែលបានកំផិតជាច្រើនដង។ គ្រួសារ

របស់ព្រះយេស៊ូវបានគិតថាព្រះអង្គឆ្កួត។ ស្តេច យ៉ូសៀស ជាស្តេចល្អ ប៉ុន្តែ ស្តេច យេហូយ៉ាគីម និងស្តេច សេដេគា (ដែលជាបុត្រារបស់ស្តេច យ៉ូសៀស) ដែលបានបន្តតំណែងស្តេច យ៉ូសៀស ជាស្តេចដែលអាក្រក់ៗវិញ។[១]

## មិនមានគ្រួសារណាល្អឥតខ្ចោះទេ

តាមពិតទៅ មិនមានអាពាហ៍ពិពាហ៍ ឬក៏ផ្ទះណាមួយដែលល្អឥតខ្ចោះនោះឡើយ។ គ្រប់គ្រួសារទាំងអស់សុទ្ធតែមានជម្លោះ មានការយល់ច្រឡំគ្នា និងមានការឈឺចាប់ដែរ។ នេះគឺជាមូលហេតុដែលភាពអត់ធ្មត់គឺជាគុណសម្បត្តិដ៏សំខាន់នៅក្នុងជំនឿគ្រីស្ទបរិស័ទ។ នៅក្នុងសៀវភៅមួយក្បាលដែលខ្ញុំបានសរសេរទាក់ទងទៅនឹងសេចក្តីស្រឡាញ់ដោយមានមូលដ្ឋានលើកណ្ឌគម្ពីរ១កូរិនថូសជំពូកទី១៣ ខ្ញុំបានចំណាយបួនជំពូកក្នុងចំណោមដប់ប្រាំបួនជំពូកលើប្រធានបទនៃភាពអត់ធ្មត់។[២] នេះដើម្បីបង្ហាញអំពីចំណុចសំខាន់នៃភាពអត់ធ្មត់ ដើម្បីឲ្យមានជីវិតដែលពេញដោយសេចក្តីស្រឡាញ់។ វាគឺជាប្រធានបទដែលមានជាញឹកញាប់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ នាម “ហ៊ូបផូមូនេ” (hupomonē) និងកិរិយាសព្ទ “ហ៊ូបផូមេនោ” (hupomenō) ដែលទាក់ទងគ្នាទៅនឹង “សេចក្តីទ្រាំទ្រ” មានចំនួន៣២ដង និង១៤ដងតាមលំដាប់លំដោយ ដែលទាក់ទងគ្នាទៅនឹងអាកប្បកិរិយាគ្រីស្ទបរិស័ទ។ នាម “ម៉ាក្រូធូមា” (makrothumia) និងកិរិយាសព្ទ “ម៉ាក្រូធូមេអូ” (makrothumeō) ដែលទាក់ទងគ្នាទៅនឹង “ភាពអត់ធ្មត់” ឬក៏ “ការអត់ធ្មត់យ៉ាងវេទនា” មានចំនួន៩ដង និង៦ដងតាមលំដាប់លំដោយ ដែលទាក់ទងគ្នាទៅនឹងអាកប្បកិរិយាគ្រីស្ទបរិស័ទ។ តួលេខសរុបគឺ៦១ដងទាក់ទងនឹងពាក្យទាំងនេះ។

គ្រប់ដៃគូជីវិតណាដែលបានរៀបការហើយមានសុភមង្គល ពួកគាត់នឹងប្រាប់លោកអ្នកថា ពួកគាត់បានប្រឈមមុខនឹងបញ្ហាលំបាកៗជាច្រើន ដែលទាមទារឲ្យមានការអត់ធ្មត់យ៉ាងខ្លាំង ហើយថាពួកគាត់ក៏នៅតែបន្តរស់នៅ

ដោយមានបញ្ហាបែបនោះទៀតដែរ។ គ្រប់គ្រីស្ទបរិស័ទទាំងអស់សុទ្ធតែមានភាពកម្សោយ ហើយជារឿយៗក៏បានធ្វើខុសដែរ។ ក្នុងការនិយាយជាមួយនឹងគ្រូៗលើបទគម្ពីរទាក់ទងទៅនឹងអណ្តាតលោក យ៉ាកុប បានមានប្រសាសន៍ថា “ដ្បិតយើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ” (យ៉ាកុប ៣:២)។ សាវ័កយ៉ូហាន បានលើកឡើងថា “បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ” (១យ៉ូហាន ១:៨)។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលទ្រង់មិនមានបាបទាល់តែសោះ ហើយក៏ជាព្រះដែលល្អឥតខ្ចោះដែរ។ ប្រសិនបើយើងរំពឹងគិតថាសមាជិកគ្រួសារយើងក៏ត្រូវល្អឥតខ្ចោះដែរ នោះយើងកំពុងតែដាក់បន្ទុកយ៉ាងខ្លាំងលើពួកគាត់ហើយ។ ជារឿយៗ ឪពុកម្តាយតែងតែមើលយ៉ាងអស់សង្ឃឹមខណៈពេលដែលពួកគាត់ព្យាយាមយល់អំពីអ្វីដែលបានកើតឡើងចំពោះ “កូនល្អឥតខ្ចោះ” របស់ខ្លួន ចាប់តាំងពីគាត់បានក្លាយជាមនុស្សវ័យជំទង់។ ខ្ញុំបានមានអារម្មណ៍ថា ក្នុងអំឡុងពេលវ័យជំទង់នៃកូនៗរបស់ខ្ញុំ កាលនោះបានធ្វើឲ្យខ្ញុំក្លាយជាអ្នកជំនាញក្នុងការអធិស្ឋានយ៉ាងខ្លាំងម្នាក់!

នៅពេលណាមួយ គ្រប់គ្រួសារគ្រីស្ទបរិស័ទនឹងជួបប្រទះបទពិសោធន៍នៃការឈឺថ្កាត់ ជម្លោះ ការឈឺចិត្ត ទុក្ខព្រួយ ការខ្វះខាត ការខកចិត្ត និងការបរាជ័យ។ ដូច្នេះ គ្រប់គ្នាត្រូវតែក្លាយជាអ្នកមានជំនាញក្នុងការអនុវត្តការមានភាពអត់ធ្មត់។ នេះគឺជាកិច្ចការដែលយើងត្រូវធ្វើ ដោយមានការប្តេជ្ញាចិត្ត។ គ្រួសារគ្រីស្ទបរិស័ទភាគច្រើនអាចនៅមានបទពិសោធន៍នៃការមានអំណរបាន នៅពេលដែលពួកគាត់កំពុងឈឺចាប់—អំណរដែលនៅចុងបញ្ចប់នឹងយកឈ្នះលើការឈឺចាប់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានគ្រួសារគ្រីស្ទបរិស័ទមួយចំនួនដែលមានការឈឺចាប់យ៉ាងយូរ ហើយក៏បានដកយកនូវសេចក្តីអំណរចេញ ហើយគ្រួសារទាំងនោះត្រូវបានកំណត់ថាមានទុក្ខព្រួយយ៉ាងខ្លាំង។

## ការឈឺចាប់ក្នុងគ្រួសារ

ក្រុមគ្រួសារគ្រីស្ទបរិស័ទ ដែលជាអ្នកដឹកនាំ មានបទពិសោធន៍ឈឺចាប់នៅក្នុងទម្រង់ជាច្រើនបែបបទ។ សូមអនុញ្ញាតឲ្យយើងខ្ញុំលើកឡើងនូវឧទាហរណ៍បួន-ដប់ដូចខាងក្រោមនេះ។

ខ្ញុំបានឮរឿងដ៏គួរឲ្យក្រៀមក្រំមួយ អំពីគ្រូគង្វាលនៃក្រុមជំនុំមួយដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅសហរដ្ឋអាមេរិក ដែលត្រូវលេខាររបស់គាត់បានចោទប្រកាន់ថាមានបំណងប៉ុនប៉ងមានទំនាក់ទំនងស្នេហាជាមួយគាត់។ ក្រុមជំនុំទាំងមូលបានជឿលើសម្ដីលេខានោះ ហើយគ្រូគង្វាលក៏ត្រូវចាកចេញពីព័ន្ធកិច្ចទាំងមានសេចក្ដីអាម៉ាស់យ៉ាងខ្លាំងចំពោះរូបគាត់ និងក្រុមគ្រួសាររបស់គាត់។ ប៉ុន្មានឆ្នាំក្រោយមក លេខាម្នាក់នោះបានសារភាពថា រឿងទាំងនេះគឺជារូបគាត់ទេដែលចង់មានទំនាក់ទំនងជាមួយនឹងគ្រូគង្វាល ហើយគ្រូគង្វាលទេដែលបានប្រឆាំងនឹងការព្យាយាមរបស់គាត់។ អ្វីដែលលេខានោះបាននិយាយកាលពីមុននោះ គឺជាការឆ្លើយតបដោយកំហឹងក្នុងការដែលគ្រូគង្វាលនោះបានបដិសេធគាត់។ ប៉ុន្តែ ដោយសារការឆ្លើយតបរបស់លេខានោះដូចនោះ គ្រូគង្វាលក៏ត្រូវបានចាកចេញពីព័ន្ធកិច្ច ដោយមានភាពអាម៉ាស់អស់រយៈពេលជាច្រើនឆ្នាំ។

មិត្តភក្តិ និងអ្នករួមការងារដ៏ល្អម្នាក់របស់ខ្ញុំ គឺលោក ស៊ូរី វិលាមស៍ (Suri Williams) ដែលមានព័ន្ធកិច្ចដ៏ល្អ ហើយបានជួយអ្នកដឹកនាំជាច្រើននាក់សម្រាប់ក្រុមជំនុំនៅក្នុងប្រទេសស្រីលង្កា គាត់បានមានជំងឺបាត់ការចងចាំកាលគាត់មានអាយុជាង៦០ឆ្នាំក្រាស។ គាត់បានវិវត្តចូលស្ថានភាពដែលកាន់តែធ្ងន់ធ្ងរ ដែលមិនអាចជួយបានទាល់តែសោះ។ ប្រពន្ធដ៏ស្មោះត្រង់របស់គាត់ ដែលជាគ្រីស្ទបរិស័ទដ៏ល្អម្នាក់ បានរងគ្រោះក្នុងការរងទុក្ខដោយរស់នៅជាមួយបុគ្គលដែលជាប្ដី ដែលលែងស្រឡាញ់គាត់ដូចមុន ដូចដែលគាត់ចាំអស់រយៈពេលបីទសវត្សរ៍។

លោក បេនចាមីន ប្រេកឃីនរីជន៍ វើហ្វៀលដ៍ (Benjamin Breckinridge

Warfield) (ឆ្នាំ១៨៥១-១៩២១) គឺជាគ្រូបង្រៀនទេវវិទ្យានៅឯសាលាព្រះគម្ពីរទេវវិទ្យា ព្រីនស្តុន (Princeton Theological Seminary) អស់រយៈពេលជិត៣៤ឆ្នាំ ហើយក៏ជាបុគ្គលម្នាក់ ដែលជាទេវវិទូក្នុងដើមសតវត្សរ៍ទី២០ ដែលគេនៅលើកយកសម្រង់សម្តីរបស់គាត់មកប្រើប្រាស់ជាញឹកញាប់នៅសព្វថ្ងៃនេះ។ បន្ទាប់ពីគាត់បានរៀបការថ្មោងថ្មី គាត់បានចេញទៅនៅអឺរ៉ុបជាមួយប្រពន្ធរបស់គាត់ឈ្មោះ អេននី (Annie)។ នៅទីនោះគូស្នេហ៍ថ្មីថ្មោងបានជាប់ក្នុងព្យុះដែលមានផ្គររន្ទះយ៉ាងខ្លាំង។ លោកស្រី វើហ្វៀលដ៍ បានមានការតក់ស្លុតយ៉ាងខ្លាំងដោយសារព្រឹត្តិការណ៍នោះ ហើយអស់មួយជីវិតរបស់គាត់—ជិត៤០ឆ្នាំ—គាត់ជាមនុស្សពិការទូទៅម្នាក់។ ក្នុងអំឡុងពេលនោះ លោក វើហ្វៀលដ៍ មិនសូវចេញពីផ្ទះច្រើនជាងពីរម៉ោងក្នុងមួយពេលនោះទេ។ គាត់ស្ទើរតែមិនបានចាកចេញពីទីក្រុង ព្រីនស្តុន។ លោក ជេ. ហ្គ្រេសហាំ ម៉ាឈិន (J. Gresham Machen) ដែលជាកូនសិស្សរបស់គាត់ ហើយក្រោយមកក៏បានក្លាយជាបញ្ញវន្តដ៏ល្បីម្នាក់នៃព្រះគម្ពីរសញ្ញាថ្មី គាត់បានសរសេរដូចតទៅ «លោកបណ្ឌិត វើហ្វៀលដ៍ ធ្លាប់អានសៀវភៅឲ្យប្រពន្ធគាត់ស្តាប់ ក្នុងពេលវេលាជាក់លាក់ណាមួយជារៀងរាល់ថ្ងៃ»។ គាត់មិនបានចូលរួមក្នុងការប្រជុំ ឬក៏ក្នុងសកម្មភាពណាផ្សេងទៀត ក្នុងអំឡុងពេលដែលកំពុងមានបញ្ហាខ្លាំងក្នុងនិកាយប្រេសប៊ីធើរៀនរបស់គាត់។ ប៉ុន្តែការនិពន្ធដ៏ឆ្លាតវៃរបស់គាត់ខាងផ្នែកទេវវិទ្យាបានជះឥទ្ធិពលយ៉ាងខ្លាំងលើក្រុមជំនុំ។[៣]

ដូចគ្នានេះដែរ ប្រពន្ធរបស់លោក វេលៀម ខារី (William Carey) ដែលជាបេសកជនដ៏ល្អម្នាក់ទៅកាន់ប្រទេសឥណ្ឌា បានក្លាយជាមនុស្សឆ្កួតនៅពេលដែលកូនប្រុសដែលមានវ័យជាទារករបស់ភរិយាគាត់បានស្លាប់ ហើយលោក វេលៀម ត្រូវរស់នៅជាមួយនឹងអាកប្បកិរិយាដ៏លំបាករបស់គាត់អស់ជាច្រើនឆ្នាំ។

យើងដឹងថា គ្មាននរណាម្នាក់បានទទួលការព្យាបាលយ៉ាងពេញលេញ

ចេញពីការស្លាប់របស់សមាជិកគ្រួសារបាននោះទេ—មិនថាជាកូន ជាបងប្អូន ជាប្ដី ឬប្រពន្ធ ឬជាឪពុកម្ដាយក៏ដោយ។ ក្នុងមួយជីវិតរបស់ពួកគាត់ ពួកគាត់រស់នៅដោយមានដួងចិត្តដែលមានប្រហោងនៃការឈឺចាប់ និងមានទុក្ខព្រួយ។ មានចំណុចច្បាស់លាស់មួយដែលថា ទ្រនិចនៃសេចក្ដីស្លាប់នឹងត្រូវបានដកចេញតែនៅពេលដែលព្រះយេស៊ូវយាងត្រឡប់មកវិញ ដែលយើងកំពុងរង់ចាំអស់រយៈពេលយ៉ាងយូរមកហើយនេះ (១កូរិនថូស ១៥:៥១-៥៧)។

មានមនុស្សជាច្រើនបានប្រាប់ខ្ញុំអំពីភាពឯកាដែលពួកគាត់មានបទពិសោធន៍ដោយសារប្ដី ឬប្រពន្ធរបស់ពួកគាត់មិនយល់ពីពួកគាត់ ឬក៏អំពីការងារដែលពួកគាត់ឆេះឆួលជាមួយយ៉ាងខ្លាំង។ ការរៀបរាប់អំពីប្រពន្ធរបស់លោក អ័ប្រាហាំ លីនខុន (Abraham Lincoln) ខាងក្រោមនេះអាចឲ្យលោកអ្នកមានការភ្ញាក់ផ្អើល៖

> គាត់បានជំរុញឲ្យលោក លីនខុន រកការងារនយោបាយឋានៈខ្ពស់ឥតឈប់ឈរ។ គាត់ត្អូញត្អែរអំពីភាពក្រីក្រមិនចេះឈប់។ គាត់ចំណាយលើសកំណត់ដោយមិនចេះរអៀសខ្លួន ទាំងនៅ ស្ព្រីងហ្វីល (Springfield) និងនៅសេតវិមានប្រធានាធិបតី។ គាត់បានធ្វើបាបអ្នកបម្រើហាក់បីដូចជាថាពួកគាត់ជាទាសករ (ហើយសើចចំអកដាក់លោក លីនខុន នៅពេលដែលគាត់ព្យាយាមឲ្យលុយថែមដល់ពួកគេ) គាត់រំលោភបំពានលើលោក លីនខុន ច្រើនជាងមួយដង (ដោយគប់អូស ឬក៏ដំឡូងបារាំង)។ គាត់ក៏ទំនងជាធ្លាប់ដេញចាក់ប្ដីដោយកាំបិតនៅក្រោយផ្ទះនៅឯស្ព្រីងហ្វីល។ ហើយគាត់ប្រព្រឹត្តចំពោះមិត្តភក្តិធម្មតារបស់ប្ដី ដែលជាស្ត្រីដែលមានរូបរាងស្អាត ដោយមានការគម្រាមកំហែងផ្ទាល់តែម្ដង ខណៈពេលដែលគាត់ដើរញ៉ែអ្នកផ្សេងឥតឈប់ឈរ ហើយស្លៀកពាក់ឆើតឆាយទៀតផង។[៤]

គេធ្លាប់ហៅលោក អៃដែន ដិបលយូ. ថូស័រ (Aiden W. Tozer) ថាជាហោរានៃសតវត្សទី២០។ ព្រះជាម្ចាស់បានប្រើប្រាស់ការយល់ដឹងដ៏ជ្រាលជ្រៅរបស់គាត់បែបជាហោរា ដើម្បីដាស់តឿនក្រុមជំនុំ ឲ្យបែរមករកសេចក្ដីពិតដែល

គ្រីស្ទបរិស័ទជាច្រើនបានភ្លេច ដែលមានដូចជាការផ្តល់អាទិភាពលើការថ្វាយបង្គំ នូវជីវិតខាងឯវិញ្ញាណ និងតម្រូវការនៃការប្តេជ្ញាចិត្តយ៉ាងភ្លៀវក្លាទៅកាន់ព្រះជាម្ចាស់ដោយមិនមានការចរចារជាមួយនឹងលោកីយ៍។ ទោះជាយ៉ាងណាក៏ដោយ ក៏លោក ថូស័រ មិនមានគំរូល្អពីឪពុកនៃការធ្វើជាប្តី កាលគាត់កំពុងពេញវ័យឡើងដែរ។ ទោះបីគាត់បានអានសៀវភៅជាច្រើនក្បាលក៏ដោយ ក៏គាត់ហាក់បីដូចជាមានចំណុចខ្វាក់ ទាក់ទងទៅនឹងចំណេះដឹងនៃទំនួលខុសត្រូវក្នុងគ្រួសារ។ លោកស្រី អាដា (Ada) ដែលជាប្រពន្ធដ៏ស្មោះត្រង់ម្នាក់ បានបំពេញតួនាទីរបស់គាត់ក្នុងនាមជាប្រពន្ធគ្រូគង្វាលយ៉ាងល្អ។ ប៉ុន្តែ ប្តីរបស់គាត់បានធ្វើការសម្រេចចិត្តដែលមានការប៉ះពាល់ដល់សមាជិកគ្រួសាររបស់គាត់ ដោយមិនមានការប្រឹក្សាយោបល់ជាមួយពួកគាត់ ហើយក៏មិនបានជួយផ្គត់ផ្គង់ដល់ប្រពន្ធរបស់គាត់ឲ្យចាយវាយគ្រប់គ្រាន់នៅក្នុងគ្រួសារនោះទេ។

អរព្រះគុណព្រះអង្គដែលលោកស្រី អាដា មិនបានមានភាពជូរចត់ ហើយទោះបីជាគាត់ទទួលរងការឈឺចាប់ពីការមានបញ្ហាខាងផ្នែកហិរញ្ញវត្ថុ ភាពឯកា និងការខ្វះភាពកក់ក្តៅពីប្តីរបស់គាត់ក៏ដោយ ក៏គាត់មិនដែលបង្គាប់ឲ្យកូនៗរបស់គាត់ជំទាស់ជាមួយឪពុករបស់ខ្លួនដែរ។[៥] បន្ទាប់ពីលោក ថូស័រ បានស្លាប់ទៅ គាត់បានរៀបការជាមួយលោក លីអូនាដ អូដាម (Leonard Odam)។ នៅពេលដែលមានមនុស្សសួរនាំអំពីសុភមង្គលរបស់គាត់ដោយសេចក្តីស្រឡាញ់ គាត់បានឆ្លើយថា «ខ្ញុំមិនដែលមានភាពអរសប្បាយជាងនេះនៅក្នុងជីវិតខ្ញុំនោះទេ។ លោក អែដេន ស្រឡាញ់ព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែលោក អូដាម ស្រឡាញ់ខ្ញុំ»។[៦] លោក ថូស័រ គឺជាបុរសដែលល្អ និងគោរពកោតខ្លាចព្រះ ដែលមានឥទ្ធិពលល្អ និងខ្លាំងចំពោះក្រុមជំនុំ។ ខ្ញុំនៅតែមានការជំរុញ និងនៅទទួលបានការលូតលាស់នៅពេលដែលខ្ញុំអានសំណេររបស់គាត់។ ប៉ុន្តែ គាត់គឺជាប្តី និងជាឪពុកម្នាក់ដែលមិនបានផ្តល់ការយកចិត្តទុកដាក់ដល់ប្រពន្ធ និងកូនៗរបស់គាត់ទេ។

ហើយក៏មានបទពិសោធន៍នៃការឈឺចាប់យ៉ាងខ្លាំងរបស់អ្នកដឹកនាំ

គ្រីស្ទបរិស័ទ ដែលកូនៗរបស់ពួកគាត់បានបះបោរទាស់ប្រឆាំងនឹងឪពុកម្តាយ និងព្រះជាម្ចាស់។ ឪពុកម្តាយទាំងនេះគឺជាឪពុកម្តាយដែលល្អៗ។ ពួកគាត់បានធ្វើនូវអ្វីដែលត្រឹមត្រូវ ប៉ុន្តែកូនៗរបស់ពួកគាត់បានប្រាសចាកចេញពីផ្លូវទាំងនោះ។ ខណៈពេលដែលព្រះគម្ពីរបានបង្រៀនថា កូនៗតែងតែបន្តអំពើបាបរបស់ឪពុកម្តាយ ព្រះគម្ពីរក៏បានបង្រៀនដែរថា យើងមិនគួរស្តីបន្ទោសឪពុកម្តាយដោយសារអំពើបាបរបស់កូនៗឡើយ (ចោទិយកថា ២៤:១៦)។ នៅទីបំផុត កូនៗមានទំនួលខុសត្រូវលើទង្វើរបស់ខ្លួន ហើយមួយចំនួនទៀត សូម្បីតែជាកូនៗដែលមកពីគ្រួសារដែលល្អបំផុតក៏ពួកគាត់នៅតែជ្រើសរើសផ្លូវខុសដែរ។ ព្រះយេស៊ូវគឺជាអ្នកបង្កើតសិស្សដ៏ល្អបំផុតក្នុងចំណោមអ្នកបង្កើតសិស្សទាំងអស់ ប៉ុន្តែមានសាវ័កម្នាក់បានក្បត់ព្រះអង្គ ហើយក៏បានសម្លាប់ខ្លួនដោយមានវិប្បដិសារីដ៏ជូរចត់បំផុតដែរ។ មានតួអង្គអស្ចារ្យ ដែលចេះគោរពកោតខ្លាចព្រះជាច្រើននាក់នៅក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរដូចជាលោក អ័ប្រាហាំ អ៊ីសាក យ៉ាកុប អើរ៉ុន ហោរា សាំយូអែល ស្តេច ដាវីឌ ស្តេច យ៉ូសៀស និងស្តេចយ៉ូថាម ដែលមានកូនដែលបានបដិសេធមាគ៌ារបស់ឪពុកម្តាយខ្លួន។ ហើយរឿងដូចៗនេះនៅតែបានបន្តកើតឡើងរាប់មិនអស់នៅក្នុងប្រវត្តិសាស្ត្ររបស់ក្រុមជំនុំដែរ។

ខ្ញុំគិតថា ការឈឺចាប់ខ្លាំងបំផុតគឺកើតមកពីការមិនមានភាពស្មោះត្រង់ខាងឯផ្លូវភេទ។ សព្វថ្ងៃនេះ យើងបានឃើញរឿងដូចនេះច្រើនដងណាស់! ជាញឹកញាប់ អ្នកដឹកនាំគ្រីស្ទបរិស័ទគឺជាអ្នកប្រាសចាកពីផ្លូវ។ ក្នុងចំណោមអាពាហ៍ពិពាហ៍ទាំងនេះ មានខ្លះបានទទួលការសង្គ្រោះតាមរយៈព្រះគុណនៃការព្យាបាលរបស់ព្រះជាម្ចាស់ ទោះបីប្តី ឬក៏ប្រពន្ធត្រូវឆ្លងកាត់ការឈឺចាប់យ៉ាងខ្លាំងក៏ដោយ។ ប៉ុន្តែ ក៏នៅមានអាពាហ៍ពិពាហ៍របស់អ្នកខ្លះទៀតបានបញ្ចប់ដោយលែងលះគ្នាផងដែរ។ ព្រះគម្ពីរមិនលើកទឹកចិត្តឲ្យមានការលែងលះនោះទេ ប៉ុន្តែក៏បានទទួលស្គាល់ថា ពេលខ្លះក៏ជៀសមិនរួចទេដោយសារភាពរឹងរូស

នៃដួងចិត្តម្នាក់ ឬក៏ទាំងពីរដែរ (ម៉ាថាយ ១៩:៨)។ ការឈឺចាប់ខ្លាំងនៃការលែងលះគ្នាគឺអាចដឹងបានតែចំពោះអស់អ្នកដែលមានបទពិសោធន៍អំពីវាប៉ុណ្ណោះ។ មានគ្រីស្ទបរិស័ទដែលមានការប្តេជ្ញាចិត្តមួយចំនួន ដែលបានព្យាយាមកែតម្រូវជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនយ៉ាងខ្លាំងតាមរយៈការអធិស្ឋាន និងការណែនាំពីអ្នកដទៃ ហើយនៅចុងបញ្ចប់ក៏បង្ខំចិត្តលែងលះគ្នា ដោយសារដៃគូជីវិតមិនព្រមផ្សះផ្សាគ្នា។

## ការខកបំណង ការរអ៊ូរទាំ ការអត់ធ្មត់ ព្រះរត្នមានរបស់ព្រះជាម្ចាស់[៧]

ឥឡូវនេះ សូមមើលការឈឺចាប់របស់ក្រុមគ្រួសារតាមទស្សនៈរបស់ព្រះគម្ពីរ។ យើងនឹងមើលកណ្ឌគម្ពីររ៉ូម ជំពូកទី៨ សម្រាប់ការណែនាំនេះ។

### *ការខកបំណង*

ព្រះគម្ពីរបានបង្រៀនយើងថា ការខកបំណងគឺជាផ្នែកមួយដែលមិនអាចជៀសផុតបានទេ ក្នុងជីវិតនៅលើផែនដីដែលបានធ្លាក់ក្នុងអំពើបាបនេះ។ នៅក្នុងការធ្លាក់ចុះនេះ «ជីវិតទាំងឡាយបានត្រូវចុះចូលនឹងសេចក្តីឥតប្រយោជន៍ [ការខកបំណង] តែមិនមែនដោយស្ម័គ្រពីចិត្ត គឺដោយព្រោះព្រះអង្គ ដែលទ្រង់បញ្ចុះបញ្ចូលវិញ ដោយសង្ឃឹម» (រ៉ូម ៨:២០)។ ដូច្នេះ រាល់គ្រប់អ្វីៗក៏ប្រែជាខុសពីធម្មតា។ យើងចាប់ផ្តើមឈឺ យើងមានកំហុសក្នុងការវិនិច្ឆ័យ យើងប្រព្រឹត្តអំពើបាប ហើយយើងក៏ប្រឈមមុខនឹងបញ្ហាដែលមកពីខាងក្នុង និងខាងក្រៅគ្រួសារផងដែរ។ ប៉ុន្តែ ការខកចិត្តក៏មានធាតុផ្សំនៃ «សេចក្តីសង្ឃឹម» នៅក្នុងវា។ សេចក្តីសង្ឃឹមមួយនេះគឺជាការរំដោះចុងក្រោយដែលពេញទៅដោយសិរីរុងរឿងនៃការបង្កើត។ ជីវិតទាំងឡាយកំពុងតែរំពឹងចង់បានការនេះយ៉ាងខ្លាំង ហើយកូនៗរបស់ព្រះជាម្ចាស់នឹងមានតួនាទីចម្បងមួយនៅក្នុងការនេះ។ «ដ្បិតសេចក្តីទន្ទឹងរបស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះ

លេចមកឲ្យឃើញប៉ុណ្ណោះទេ» (ខ១៩; សូមអានបន្ថែមនៅក្នុងខ២១, ២៣)។

## *ការរអ៊ូរទាំ*

ទំរាំតែមានការរំដោះដ៏ពេញដោយសិរីរុងរឿងនៃការបង្កើតជាមួយនឹងការបើកសម្តែងនៃកូនៗរបស់ព្រះជាម្ចាស់ នោះជីវិតទាំងឡាយនឹងនៅបន្តថ្ងូរៈ «ដ្បិតយើងដឹងថា ជីវិតទាំងឡាយក៏ថ្ងូរ ហើយឈឺចាប់ជាមួយគ្នា ដរាបដល់គ្រាឥឡូវនេះ» (ខ២២)។ អ្នកជឿក៏ថ្ងូរផងដែរៈ «មិនតែប៉ុណ្ណោះសោត ខ្លួនយើងរាល់គ្នាដែលមានផលជាដំបូងរបស់ព្រះវិញ្ញាណ ក៏ថ្ងូរក្នុងខ្លួនដែរ ទាំងរង់ចាំទំរាំការទទួលជាកូនចិញ្ចឹម គឺជាសេចក្តីប្រោសលោះដល់រូបកាយយើងផង» (ខ២៣)។ យើងបានភ្លក់នគរស្ថានសួគ៌ដែលសាវ័ក ប៉ុល បានហៅថា «ផលជាដំបូងរបស់ព្រះវិញ្ញាណ» ប៉ុន្តែ ឥឡូវនេះយើងមានការតយុទ្ធជាមួយការខកចិត្តជាច្រើនប្រភេទ។ ការឆ្លើយតបរបស់យើងចំពោះការទាំងនេះគឺការថ្ងូរ។ ការថ្ងូរក៏មានលាយឡំជាមួយក្តីសង្ឃឹមនៃការប្រោសលោះចុងក្រោយ ដូច្នេះហើយបានជាគេហៅវាថាជាដំងូរនៃការឈឺចាប់នៅពេលសម្រាលកូន។ ម្តាយដែលកំពុងឈឺពោះក៏ថ្ងូរដោយសារឈឺចាប់យ៉ាងខ្លាំង ប៉ុន្តែគាត់ដឹងថាការឈឺចាប់នេះនឹងបានផុតទៅយ៉ាងឆាប់ៗ ដោយគាត់នឹងមានអំណរក្នុងការបង្កើតបានកូនម្នាក់។

ការរៀនថ្ងូរគឺជាចំណុចគន្លឹះមួយនៃការឆ្លើយតបរបស់គ្រីស្ទបរិស័ទចំពោះបញ្ហាផ្សេងៗ។ ព្រះគម្ពីរបានអនុញ្ញាតឲ្យយើងបង្ហាញពីការឈឺចាប់របស់យើង។ យើងឃើញថា មួយភាគបីនៃកណ្ឌគម្ពីរទំនុកតម្កើងគឺជាទំនួញដែលអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់បានថ្ងូរអំពីបញ្ហារបស់ពួកគាត់។ គេបានហៅហោរា យេរេមា ថាជា «ហោរាទឹកភ្នែក» ជាញឹកញាប់គាត់បានពណ៌នាពីការឈឺចាប់របស់គាត់នៅក្នុងភាសាដែលឈឺចាប់ (យេរេមា ៩:១-៩; ១៥:១០-២១; ២០:៧-១០)។ ដូច្នេះ គ្រីស្ទបរិស័ទដែលមានភាពចាស់ទុំក៏បានរៀនបង្ហាញពីការឈឺចាប់របស់ខ្លួននៅក្នុងដំងូរ ការដកដង្ហើមធំៗ ការយំសោក

និងអ្វីៗផ្សេងទៀតដែលជារបៀបសមរម្យ។

ការប្ដេជ្ញាចិត្តគឺជាលក្ខណសម្បត្តិដ៏ពិបាកបំផុតមួយសម្រាប់ជីវិតរស់នៅរបស់គ្រីស្ទបរិស័ទនៅក្នុងសតវត្សរ៍ទី២១នេះ ក្នុងការដែលឲ្យអ្នកជឿព្រះអង្គទទួលយកវា។ សព្វថ្ងៃនេះ មនុស្សមានទម្លាប់ចេញពីការរងទុក្ខ និងការឈឺចាប់។ ហេតុដូច្នេះហើយបានជាផ្ទុយពីការបន្តនៅក្នុងទំនាក់ទំនងដែលពិបាក ពួកគាត់ក៏បានបោះបង់ចោល ហើយចេញទៅរកអ្វីផ្សេងទៀត។ ឥឡូវនេះ នៅពេលដែលមានបញ្ហាកើតឡើង គ្រីស្ទបរិស័ទចាកចេញពីព្រះវិហារ ឬអង្គការរបស់ពួកគាត់ ហើយទៅរកកន្លែងផ្សេង ពួកគាត់បោះបង់ការងារ ក្រុមតូច ហើយមិត្តភក្តិរបស់ខ្លួនចោលដែរ។ ពួកគាត់មិនបានរៀនរងទុក្ខ ដើម្បីរក្សាការប្ដេជ្ញារបស់ខ្លួននោះទេ។ ចំពោះជីវិតអាពាហ៍ពិពាហ៍ អ្នកខ្លះក៏មានអាកប្បកិរិយាដូចគ្នាដែរ។ នៅពេលពួកគាត់មានបញ្ហាជាមួយដៃគូជីវិតរបស់ខ្លួន ពួកគាត់បោះបង់អាពាហ៍ពិពាហ៍នោះចោល។

ចំណែកអស់អ្នកដែលបានរៀនមានដំងូរ ពួកគាត់នឹងមិនបោះបង់ចោលដោយស្រួលពេកនោះទេ។ តាមពិតទៅ ការថ្ងូរអាចទប់ស្កាត់ការបោះបង់ចោលបាន។ ប្រសិនបើលោកអ្នកដឹងថា ការឈឺចាប់គឺជារឿងធម្មតាក្នុងទំនាក់ទំនងនោះលោកអ្នកក៏នឹងមិនជ្រើសរើសបោះបង់ នៅពេលមានបញ្ហាចូលមកដែរ។ ផ្ទុយទៅវិញ លោកអ្នកនឹងបង្ហាញពីការឈឺចាប់នោះ ដោយដឹងថា ការរងទុក្ខគឺជាផ្នែកដ៏សំខាន់មួយនៅក្នុងជំនឿគ្រីស្ទបរិស័ទ។ លោកអ្នកបានរៀនរស់នៅជាមួយនឹងការឈឺចាប់ ហើយចេះមានអំណរ សូម្បីតែកំពុងស្ថិតនៅក្នុងការឈឺចាប់ក៏ដោយ។ នៅក្នុងសៀវភៅនិពន្ធដោយលោក ប៉ុល ធ័នៀរ (Paul Tournier) ដែលមានចំណងជើងថា “ការចេះឈឺចាប់” (“Creative Suffering”) គាត់គឺជាបុគ្គលម្នាក់ដែលគេចាត់ទុកថាជាបិតានៃអ្នកប្រឹក្សាគ្រីស្ទបរិស័ទនៅក្នុងសម័យនេះ លោក ប៉ុល បានរៀបរាប់អំពីការមានទុក្ខព្រួយដែលគាត់បានមានបទពិសោធន៍ក្នុងការដែលឪពុករបស់គាត់បានស្លាប់កាលគាត់ទើបតែមានអាយុពីរឆ្នាំ និងអំពីការស្លាប់របស់ម្ដាយគាត់កាលគាត់មាន

អាយុប្រាំឆ្នាំ ហើយក្រោយមកទៀតអំពីការស្លាប់របស់ប្រពន្ធគាត់ដែរ។ គាត់បានលើកឡើងថា «បេះដូងមនុស្សមិនចេះស្តាប់បង្គាប់តាមច្បាប់នៃតក្កវិទ្យានោះទេ៖ វាផ្ទុយពីច្បាប់រដ្ឋធម្មនុញ្ញទាំងស្រុង។ ខ្ញុំអាចនិយាយបានថា ខ្ញុំជាម្នាក់ដែលមានទុក្ខព្រួយយ៉ាងខ្លាំង ហើយថាខ្ញុំក៏ជាបុរសម្នាក់ដែលសប្បាយចិត្តដែរ»។[៩] នេះជាអាកប្បកិរិយារបស់គ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ៖ ពួកគាត់គឺជាមនុស្សដែលមានអំណរ សូម្បីតែនៅពេលដែលកំពុងរស់នៅជាមួយទុក្ខព្រួយយ៉ាងខ្លាំងដែរ។

*ការអត់ធ្មត់*

សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:២៣ ថាយើង «ក៏ថ្ងូរក្នុងខ្លួនដែរ ទាំងរង់ចាំទំរាំការទទួលជាកូនចិញ្ចឹម គឺជាសេចក្តីប្រោសលោះដល់រូបកាយយើងផង»។ នៅថ្ងៃមួយ អ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើងវិញ គឺប្រសើរយ៉ាងខ្លាំង។ ហើយដោយសារសេចក្តីសង្ឃឹមមួយនោះហើយ សាវ័កប៉ុល បានលើកឡើងថា យើងកំពុងតែលត់ដំសេចក្តីអត់ធ្មត់របស់យើង៖ «តែបើយើងសង្ឃឹមនឹងបានអ្វី ដែលមើលមិនឃើញវិញ នោះយើងនឹងរង់ចាំនៅដោយអំណត់» (ខ២៥)។ ខ្ញុំបានលើកឡើងរួចមកហើយអំពីថ្ងៃនៃសេចក្តីអត់ធ្មត់ នៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ។ ពាក្យ «ហ្សូបផូមូនូ» ដែលបានប្រើប្រាស់នៅត្រង់នេះ «មិនមែនគ្រាន់តែផ្តល់អត្ថន័យនៃការទទួលយកដោយស្ងៀមស្ងាត់ ប៉ុន្តែក៏អំពីសេចក្តីទ្រាំទ្របែបវិជ្ជមានដែរ។ (ព្រះគម្ពីរខ្មែរបច្ចុប្បន្នប្រើពាក្យ «ចេះស៊ូទ្រាំ»)។ វាគឺជាអាកប្បកិរិយារបស់ទាហាន ដែលពេលកំពុងស្ថិតក្នុងភាពមមាញឹកនៃសង្គ្រាម ក៏ពួកគាត់មិនមានការស្រងាកចិត្ត ប៉ុន្តែបន្តច្បាំងយ៉ាងក្លាហាន មិនថាមានការពិបាកក៏ដោយ»។[១០] ក្រោយមកសាវ័កប៉ុល បានលើកឡើងថា «តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះតម្រិះទ្រង់» (ខ២៨)។ ប្រសិនបើព្រះជាម្ចាស់កំពុងធ្វើការល្អ សូម្បី

តែតាមរយៈការលំបាក ក៏យើងត្រូវតែចូលរួមជាមួយនឹងព្រះអង្គ ហើយមានចំណែកក្នុងការល្អនោះដែលទ្រង់កំពុងតែធ្វើ។ គ្រីស្ទបរិស័ទមិនមែនគ្រាន់តែជាអ្នកដែលបង្ហាញពីជំនឿលើសាសនា ដោយលើកឡើងថា «នេះជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ខ្ញុំត្រូវតែស៊ូទ្រាំនឹងវា» ទេ។ ប៉ុន្តែ ផ្ទុយទៅវិញយើងនិយាយថា «ព្រះជាម្ចាស់ក៏មានអធិបតេយ្យភាពលើស្ថានភាពនេះដែរ ដូច្នេះខ្ញុំត្រូវតែមានចំណែកជាមួយព្រះអង្គ ដើម្បីឲ្យដល់ចំណុចល្អដែលព្រះអង្គមានសម្រាប់ស្ថានភាពនេះ»។

ទោះបីវាជាការឈឺចាប់យ៉ាងសម្បើមក្នុងការមានប្រពន្ធមិនស្មោះត្រង់ក៏ដោយក៏ហោរា ហូសេ មិនបានបោះបង់ព្រះជាម្ចាស់ចោលដែរ។ ហើយតាមរយៈបទពិសោធន៍នៃការឈឺចាប់យ៉ាងខ្លាំងរបស់គាត់ គាត់ក៏បានយល់អំពីសេចក្ដីស្រឡាញ់ដែលមិនចេះផុត និងសេចក្ដីអត់ធ្មត់របស់ព្រះជាម្ចាស់ចំពោះប្រជារាស្ត្រដែលចេះតែបះបោរទាស់នឹងទ្រង់។ ដូចគ្នាផងដែរ នៅពេលដែលគេបានប្រាប់លោក ដឹបលយូ. អ៊ី. សែងស្ទើរ (W. E. Sangster) ដែលជាគ្រូអធិប្បាយពីប្រទេសអង់គ្លេសដ៏ឆ្នើមម្នាក់នៅនិកាយមេតូឌីសថា គាត់កំពុងតែស្លាប់ដោយសារសាច់ដុំរបស់គាត់កាន់តែរួមស្វិតទៅៗ កាលគាត់កំពុងតែស្ថិតក្នុងវ័យដែលពេញដោយកម្លាំង ក្នុងនាមជាគ្រូអធិប្បាយ។ សម្លេងរបស់គាត់គឺជាអ្វីដែលគាត់បានបាត់បង់មុនគេបង្អស់។ គាត់បានធ្វើការប្ដេជ្ញាចិត្តដោយមានបួនចំណុច នៅពេលដែលគាត់បានដឹងថា ជំងឺរបស់គាត់ធ្ងន់ធ្ងរខ្លាំងមែនទែន។ ការប្ដេជ្ញាចិត្តទាំងនោះមានដូចតទៅ៖ (១) ខ្ញុំនឹងមិនត្អូញត្អែរនោះទេ (២) ខ្ញុំនឹងនៅតែរក្សាផ្ទះរបស់ខ្ញុំឲ្យនៅមានពន្លឺចែងចាំង (៣) ខ្ញុំនឹងរាប់ព្រះពររបស់ខ្ញុំ (៤) ខ្ញុំនឹងព្យាយាមបង្វែរការទាំងនោះឲ្យបានជាការចំណេញវិញ»។[១០] គាត់បានធ្វើឲ្យខ្លួនរវល់រហូតទាល់តែគាត់បានស្លាប់។ គាត់បានសរសេរសៀវភៅចុងក្រោយដោយប្រើម្រាមដៃតែពីរតែប៉ុណ្ណោះ ហើយក៏បានផ្ញើសៀវភៅនោះទៅកន្លែងបោះពុម្ពមួយទៅពីរថ្ងៃមុនពេលគាត់ស្លាប់។[១១]

មានគេធ្លាប់លើកឡើងថា «ការដែលលោក អ័ប្រាហាំ លីនខុន បានទ្រាំ

ទ្រអស់ជាច្រើនឆ្នាំជាមួយប្រពន្ធរបស់គាត់ដែលឆាប់ខឹងបានជួយត្រៀមគាត់ក្នុងការធ្វើការជាមួយមនុស្សដែលពិបាកធ្វើការជាមួយការដែលគាត់បម្រើជាប្រធានាធិបតី»។[១២] លោកគ្រូ ចន ផាបភ័រ បានផ្ដល់ជាមតិយោបល់ថា «ជាតិសាសន៍ទាំងមូលបានទទួលអត្ថប្រយោជន៍ចេញពីការដែលគាត់ឱបក្រសោបការឈឺចាប់» (ហើយអរគុណដល់លោក លីនខុន) ដោយសារការនេះ «គាត់ក៏បានធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយនឹងអស់អ្នកដែលមានពេញទៅដោយភាពអាត្មានិយម ដែលធ្វើការជាមួយគាត់ក្នុងថ្នាក់ដឹកនាំ»។[១៣] ដូច្នេះ នៅពេលមានបញ្ហាកើតឡើងនៅក្នុងជីវិតគ្រួសាររបស់យើង នោះយើងមិនចុះចាញ់ទេ។ យើងត្រូវតែដោះស្រាយរហូតទល់តែមានការល្អកើតចេញពីការនោះ។

### *ព្រះវត្តមានរបស់ព្រះជាម្ចាស់*

ចំណុចមួយទៀតដែលជួយយើងពេលកំពុងជួបការលំបាកគឺការដឹងថា ព្រះជាម្ចាស់គង់នៅជាមួយនឹងយើង។ សាវ័ក ប៉ុល បាននិយាយយ៉ាងក្បោះក្បាយអំពីការនេះនៅក្នុងកណ្ឌគម្ពីររ៉ូមជំពូកទី៨។ នៅក្នុងពីរវគ្គដែលមានឥទ្ធិពល គាត់បានពន្យល់អំពីរបៀបដែលថា គ្មានអ្វីអាចបំបែកយើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទបានឡើយ (ខ៣៥, ៣៨-៣៩)។ ដោយសេចក្ដីស្រឡាញ់បែបនេះ យើងក៏មិនចាំបាច់ត្រូវមានភាពជូរចត់ដែរ។ ទោះបើកាលៈទេសៈអាចអាក្រក់ ហើយសមាជិកគ្រួសារយើងអាចធ្វើអំពើអាក្រក់មកកាន់យើងក៏ដោយ ក៏សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅតែធំប្រសើរជាងនោះទៀត។

ទាក់ទងនឹងចំណុចនេះ ខគម្ពីរដែលខ្ញុំចូលចិត្តគឺ រ៉ូម ៨:២៦ «ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្ដីកម្សោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ»។ ពាក្យក្រិកដែលគេបកប្រែថា «ជួយ» គឺជាពាក្យផ្សំគ្នាតាមរយៈការដាក់ពាក្យបីខុសៗគ្នាឲ្យទៅជាពាក្យមួយ។ អត្ថន័យចំរបស់វាគឺ «មានចំណែកក្នុង»។ នេះគឺជារបៀបដែលបញ្ញវន្តព្រះគម្ពីរសញ្ញាថ្មីម្នាក់គឺលោក អេ.

ធី. រ៉ូប៊ើតសិន (A. T. Robertson) បានពណ៌នាអំពីពាក្យនេះ «ព្រះវិញ្ញាណបរិសុទ្ធជួយភាពកម្សោយរបស់យើងជាមួយនឹងយើង ហើយទ្រទ្រង់ចំណែករបស់ព្រះអង្គនៃបន្ទុកដែលយើងកំពុងតែប្រឈមមុខដាក់ ហាក់បីដូចជាថាបុរសពីរនាក់កំពុងតែលីឈើម្ខាងម្នាក់»។[១៤] គោលគំនិតគឺថា ព្រះវិញ្ញាណយាងមកជិតយើង ហើយរំលែកបន្ទុករបស់យើងជាមួយយើង។ នៅពេលដែលព្រះអង្គទូលអង្វរជំនួសយើង ការចែករំលែកបន្ទុកនោះគឺពិតណាស់ ព្រះអង្គពិតជាបានធ្វើមែន «ដោយដំងូរដែលរកថ្លែងពុំបានវិញ»។ មុនហ្នឹងបន្តិចសាវ័កប៉ុល បានលើកឡើងថាយើងថ្ងូរ។ ហើយឥឡូវនេះ គាត់បានលើកឡើងថាព្រះវិញ្ញាណយល់យើងយ៉ាងខ្លាំងរហូតដល់ថា ដំងូររបស់យើងក៏បានក្លាយជាដំងូររបស់ព្រះអង្គផ្ទាល់ផងដែរ។ ព្រះអង្គបានថ្ងូរជាមួយយើងដែរ។

ទោះបើអ្នកដទៃមិនអាចយល់បាន ក៏ព្រះជាម្ចាស់នៅជ្រាបបាន ហើយព្រះអង្គបានមកឯយើង និងយល់អំពីយើងនៅក្នុងការឈឺចាប់របស់យើងដែរ។ ព្រះអង្គជ្រាបពីការឈឺចាប់របស់យើង ពីព្រោះព្រះអង្គបានទទួលវានៅលើឈើឆ្កាង។ ព្រះអង្គមិនគ្រាន់តែបានទទួលយកអំពើបាបរបស់យើងនៅលើឈើឆ្កាងប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏បានទទួលយកការឈឺចាប់ និងទុក្ខព្រួយរបស់យើងផងដែរ។ ហោរា អេសាយ បានទាយថា «ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងជាពិត» (អេសាយ ៥៣:៤)។ ស្ត្រីដែលជាគ្រីស្ទបរិស័ទម្នាក់បានទទួលរងគ្រោះពីការនិយាយដោយប្រើពាក្យមិនល្អពីប្ដីរបស់គាត់ ភ្លាមៗនោះគាត់ក៏បានឃើញថា អ្នកផ្សេងក៏បានរងគ្រោះពីការនិយាយពាក្យមិនល្អដូចនោះទៅកាន់ព្រះយេស៊ូវដែរ។ នៅក្នុងរបៀបដ៏អាថ៌កំបាំងមួយ គាត់ចាប់ផ្ដើមមានអារម្មណ៍ថាគាត់មានភាពជិតស្និទ្ធជាមួយព្រះជាម្ចាស់។ គាត់បានមានបទពិសោធន៍ក្នុងការប្រកបគ្នាក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ (ភីលីព ៣:១០)។ គាត់បានរងទុក្ខដូចជាព្រះគ្រីស្ទបានរងទុក្ខដែរ ហើយគាត់បានដឹងថា ព្រះគ្រីស្ទបានជ្រាបអំពីការឈឺចាប់របស់គាត់។

កាលខ្ញុំនៅក្មេង ខ្ញុំធ្លាប់បានច្រៀងនៅក្នុងការជួបជុំរបស់គ្រីស្ទបរិស័ទ ហើយជាញឹកញាប់ខ្ញុំបានច្រៀងបទចម្រៀងមួយបទដែលខ្ញុំចាត់ទុកថា បទចម្រៀងរៀបរាប់ពីទីបន្ទាល់របស់ខ្លួនខ្ញុំផ្ទាល់។ ពាក្យពេចន៍ និងភ្លេង នៅក្នុងបទចម្រៀងនោះត្រូវបានសរសេរឡើងដោយអ្នកផ្សាយដំណឹងល្អម្នាក់ដែលមានឈ្មោះថា ឆាលស៍ អេហ្វ. វេហ្គល (Charles F. Weigle) (១៨៧១-១៩៦៦)។ លោក វេហ្គល បានចំណាយពេលស្ទើរពេញមួយជីវិតរបស់គាត់ក្នុងការធ្វើដំណើរ ដើម្បីបង្កើតសិស្សពីកន្លែងមួយទៅកន្លែងមួយទៀត និងការសរសេរបទចម្រៀង។ នៅថ្ងៃមួយ បន្ទាប់ពីគាត់បានត្រឡប់មកផ្ទះវិញក្រោយពីការទៅបង្កើតសិស្ស គាត់បានរកឃើញកូនសៀវភៅកំណត់ហេតុមួយដែលប្រពន្ធរបស់គាត់បានទុកអស់រយៈពេលជាច្រើនឆ្នាំមុន។ ក្នុងសៀវភៅកំណត់ហេតុនោះ ប្រពន្ធរបស់គាត់បានសរសេរថា គាត់បានឆ្អែតនឹងជីវិតនៃការបង្កើតសិស្សរបស់ប្ដីគាត់ ហើយថា គាត់ក៏នឹងចាកចេញពីប្ដីដែរ។ ការនេះជាការពិបាកយ៉ាងខ្លាំងសម្រាប់លោក វេហ្គល ហើយគាត់ក៏បានគាំងស្ទះនៅក្នុងព័ន្ធកិច្ចអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់។ ហើយក៏មានពេលខ្លះដែលគាត់បម្រុងគិតចង់សម្លាប់ខ្លួនទៀតផង។ ហើយក៏មានការអស់សង្ឃឹមយ៉ាងខ្លាំងដល់ថ្នាក់គាត់គិតថា គ្មាននរណាម្នាក់ពិតជាខ្វល់ខ្វាយអំពីគាត់ទាល់តែសោះ។ បន្តិចម្ដងៗ សេចក្ដីជំនឿរបស់គាត់ក៏ត្រូវបានស្ដារឡើងវិញ ហើយជាថ្មីម្ដងទៀតគាត់ក៏បានសកម្មក្នុងព័ន្ធកិច្ចគ្រីស្ទបរិស័ទវិញ។ គាត់បាននិពន្ធបទចម្រៀងមួយបទដែលមានចំណងជើងថា «គ្មាននរណាម្នាក់ខ្វល់ខ្វាយដល់ខ្ញុំដូចព្រះយេស៊ូវឡើយ» ទុកជាការសង្ខេបនៃបទពិសោធន៍នៃការឈឺចាប់ខ្លោចផ្សាពីអតីតកាលរបស់គាត់។[១៥]

ខ្ញុំចង់ប្រាប់លោកអ្នកពីអ្វីដែលខ្ញុំគិតអំពីព្រះយេស៊ូវ
ដោយសារខ្ញុំបានរកឃើញថាទ្រង់ជាមិត្តភក្ដិដ៏ល្អ និងស្មោះត្រង់
ខ្ញុំចង់ប្រាប់លោកអ្នកអំពីរបៀបដែលទ្រង់បានផ្លាស់ប្រែជីវិតរបស់ខ្ញុំយ៉ាង
ពេញលេញ—

ទ្រង់បានធ្វើការដែលគ្មានមិត្តណាផ្សេងអាចធ្វើបាន។

*បន្ទរៈ គ្មាននរណាម្នាក់ខ្វល់ខ្វាយដល់ខ្ញុំដូចព្រះយេស៊ូវឡើយ*
គ្មានមិត្តណាដែលមានចិត្តមេត្តាដូចទ្រង់ឡើយ
គ្មាននរណាម្នាក់អាចដកយកអំពើបាប និងភាពងងឹតចេញពីខ្ញុំបានទ្បើយ
អូហ៍ ទ្រង់បានខ្វល់ខ្វាយដល់ខ្ញុំខ្លាំងណាស់!...

រៀងរាល់ថ្ងៃ ព្រះអង្គបានមកឯខ្ញុំដោយមានការធានាថ្មី
កាន់តែច្រើនឡើង ខ្ញុំយល់ពីព្រះបន្ទូលនៃសេចក្តីស្រឡាញ់របស់ទ្រង់
ប៉ុន្តែ ខ្ញុំនឹងមិនដែលដឹងអំពីមូលហេតុដែលទ្រង់បានយាងមកសង្គ្រោះខ្ញុំ
ទេ
រហូតដល់ថ្ងៃមួយដែលខ្ញុំឃើញព្រះភក្ត្រដែលពេញដោយព្រះពររបស់ព្រះអង្គ។[១៦]

អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានច្រៀងបទចម្រៀងជាច្រើនបទ ប៉ុន្តែខ្ញុំគិតថា មិនមានបទណាបានផ្លាស់ប្តូរមនុស្សច្រើនជាងបទនេះទេ។ ខ្ញុំបានឮថា មានអ្នកជាប់គុកម្នាក់ដែលបានផ្លាស់ប្រែចិត្តមុនគេប្រហារជីវិតបានស្នើសុំគេឲ្យអនុញ្ញាតឲ្យគាត់បទចម្រៀងមួយនេះ មុនពេលដែលគេសម្លាប់គាត់។ នោះគឺជាចំណុចចុងក្រោយដែលគាត់បានធ្វើនៅលើផែនដី។

លោក វេហ្គល បានឆ្លងកាត់ពេលវេលាយ៉ាងយូរដែលយើងអាចហៅថា "យប់ងងឹតនៃព្រលឹងវិញ្ញាណ"។ ប៉ុន្តែ ចុងក្រោយ ព្រះជាម្ចាស់បានឈ្នះការនោះ ហើយលោកក៏បានដឹងថា ព្រះយេស៊ូវគង់នៅជាមួយគាត់ ហើយមានភាពគ្រប់គ្រាន់សម្រាប់តម្រូវការប្រចាំថ្ងៃរបស់គាត់។ មានសេចក្តីល្អជាច្រើនបានកើតមានដល់មនុស្សជាច្រើននាក់តាមរយៈបទចម្រៀងដែលនិពន្ធអំពីបទពិសោធន៍ដ៏ល្វីងជូរចត់នៃជីវិតអ្នកបង្កើតសិស្ស អំពីជីវិតអាពាហ៍ពិពាហ៍របស់គាត់។

## *ចូរទទួលសេចក្តីពិតខាងឯព្រះគម្ពីរ*

នៅពេលយើងជួបប្រទះវិបត្តិនៅក្នុងគ្រួសារ វាជាការសំខាន់ណាស់ក្នុងការដែលយើងទទួលយកនូវអ្វីដែលព្រះគម្ពីរបានលើកឡើងដែលថាៈ ព្រះជាម្ចាស់

កំពុងគង់នៅជាមួយយើងដោយពេញដោយសេចក្តីស្រឡាញ់ក្នុងការឈឺចាប់របស់យើង ហើយថាព្រះអង្គក៏កំពុងបង្វែរការនោះឲ្យទៅជាល្អដែរ។ សាវ័ក ប៉ុលបានលើកឡើងថា «តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» (រ៉ូម ៨:២៨)។ គាត់បានទទួលយកការពិតដោយជំនឿថា ព្រះជាម្ចាស់បង្វែរអ្វីៗឲ្យទៅជាការល្អ។ ដោយជំនឿបែបនោះ យើងអាចនៅមានសង្ឃឹមពេលកំពុងស្ថិតក្នុងភាពងងឹត និងបទពិសោធន៍ពីភាពជិតស្និទ្ធរបស់ព្រះជាម្ចាស់បាន ដោយសារយើងមានផ្នត់គំនិតនៃសេចក្តីជំនឿដែលបើកឲ្យយើងមានបទពិសោធន៍ជាមួយព្រះជាម្ចាស់។

នៅពេលដែលខ្ញុំលាតំណែងចេញពីតួនាទីជាប្រធានអង្គការយុវជនសម្រាប់ព្រះគ្រីស្ទនៅប្រទេសស្រីលង្កា បន្ទាប់ពីខ្ញុំបានបម្រើអស់រយៈពេល ៣៥ឆ្នាំ ដើម្បីទទួលតួនាទីផ្សេងទៀតជាប្រធានបង្រៀន គណៈកម្មការបានឲ្យខ្ញុំមានពេលសម្រាករយៈពេល៣ខែ។ ខ្ញុំ ហើយនិងប្រពន្ធបានរៀបចំផែនការដើរលេងក្នុងអំឡុងពេលនោះ។ គាត់មិនដែលទៅដើរលេងនៅប្រទេសឥណ្ឌា ដែលជាប្រទេសជាប់ប្រទេសយើង។ យើងមានផែនការដើរលេងជាអ្នកទេសចរណ៍ដោយមានពេលអធិប្បាយបន្តិចបន្តួច តែដើរលេងច្រើន។ យើងក៏បានរៀបគម្រោងទៅលេងប្រទេសអាមេរិកដែរ។ ទោះបីជាយ៉ាងណាក៏ដោយ កៀកពេលនៃការឈប់សម្រាកនោះចាប់ផ្តើម ខណៈពេលដែលខ្ញុំនៅប្រទេសអៀរឡង់ខាងជើង (Northern Ireland) ប្រពន្ធខ្ញុំបានទូរស័ព្ទមកថា គាត់មានជំងឺមហារីក។ គាត់បានធ្វើតេស្តខ្លះៗ ហើយគ្រូពេទ្យស្ទើរតែប្រាកដថាវាមិនមែនជាមហារីកនោះទេ ដូច្នេះដំណឹងនេះបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខ្ញុំបានកាត់ការធ្វើដំណើរឲ្យខ្លី ប៉ុន្តែនៅមានពេលបួនថ្ងៃទៀតទម្រាំដល់ពេលដែលខ្ញុំទៅដល់ផ្ទះ។

រដូវក្តៅបានមកដល់ហើយ កាលនោះខ្ញុំបានស្នាក់នៅផ្ទះមួយនៅជាប់មាត់សមុទ្រ។ ខ្ញុំទំនេរនៅល្ងាចនោះ ដូច្នេះខ្ញុំបានចំណាយពេលនោះនៅលើឆ្នេរជាមួយនឹងព្រះគម្ពីរ (នៅក្នុងទូរស័ព្ទរបស់ខ្ញុំ) និងជាមួយព្រះអម្ចាស់។ ខ្ញុំបាន

ត្រឡប់មកផ្ទះវិញ ធ្វើការរៀបចំខ្លះៗ ហើយក៏គេង។ ខ្ញុំមិនចង់គេងនៅលើគ្រែទេ។ ខ្ញុំចង់ត្រឡប់ទៅផ្ទះវិញ! ខ្ញុំក៏បានចាប់ផ្តើមហូរទឹកភ្នែក។ ភ្លាមៗនោះ មានគំនិតមួយបានលេចមកថា ខ្ញុំកំពុងយំស្រែកទៅកាន់ព្រះជាម្ចាស់។ ព្រះអង្គបានគង់នៅជាមួយខ្ញុំ ហើយថាព្រះអង្គក៏នឹងនៅជាមួយយើងក្នុងអំឡុងពេលទាំងមូលនេះដែរ។ បទពិសោធន៍មួយនោះបានជួយឲ្យខ្ញុំត្រៀមខ្លួនសម្រាប់ជំងឺមហារីក។ ជាញឹកញាប់ គំនិតដែលលេចចេញមកម្តងហើយម្តងទៀតគឺ "ប្រសិនបើគ្មានព្រះយេស៊ូវ តើយើងនឹងនៅឯណា?"

យើងត្រូវលុបចោលគម្រោងធ្វើដំណើររបស់យើងទាំងអស់។ ផ្ទុយទៅវិញ ក្នុងអំឡុងពេលឈប់សម្រាកបីខែរបស់ខ្ញុំ ភាគច្រើនខ្ញុំបានចំណាយពេលវេលានៅផ្ទះ។ យើងបានដាក់តុតូចមួយនៅក្នុងបន្ទប់គេងរបស់យើង ហើយខ្ញុំបានចំណាយពេលនៅទីនោះ ដើម្បីសរសេរសៀវភៅមួយដែលនិយាយអំពីសេចក្តីស្រឡាញ់។[១៧] ជាធម្មតា នៅក្នុងរដូវកាលនៃបុណ្យណូអែល ខ្ញុំអធិប្បាយច្រើនដងណាស់។ ពេលនេះ ខ្ញុំមិនសូវអធិប្បាយទេ។ ប៉ុន្តែ ខ្ញុំគិតថា ពេលនោះជាពេលដែលសប្បាយបំផុតមួយក្នុងរដូវកាលនៃបុណ្យណូអែលដែលខ្ញុំមិនធ្លាប់មាន។

ជំងឺមហារីកនោះមិនមែនជាបទពិសោធន៍ដ៏ងាយស្រួលមួយសម្រាប់ពួកយើងនោះទេ។ បទពិសោធន៍នៃការព្យាបាលដោយប្រើគីមីគឺពិតជារឿងដែលពិបាកណាស់។ បន្ទាប់ពីនោះ យើងក៏ត្រូវទៅបាញ់កាំរស្មីអស់២៥ដងទៀត។ ការព្យាបាលហាក់បីដូចជានាំឲ្យប្រពន្ធរបស់ខ្ញុំខ្សោយជាងមានជំងឺមហារីកទៅទៀត។ ទោះជាយ៉ាងណាក៏ដោយ បួនឆ្នាំក្រោយមក គាត់លែងមានជំងឺមហារីកទៀត ទោះបើគាត់បានមានការរាលដាលយ៉ាងរហ័សក៏ដោយ។ ហើយយើងក៏អាចឃើញព្រះពរជាច្រើនដែលព្រះជាម្ចាស់បានប្រទានដល់យើង តាមរយៈពេលវេលាដ៏លំបាកមួយនោះនៅក្នុងជីវិតរបស់យើងដែរ។ ប៉ុន្តែ ចំណុចគន្លឹះគឺការឃើញថា ព្រះជាម្ចាស់បានគង់នៅជាមួយយើង ហើយព្រះអង្គក៏កំពុង និងបានធ្វើការល្អចេញពីបញ្ហារបស់យើងដែរ។

ក្នុងករណីរបស់យើង យើងពិតជាបានឃើញដំណោះស្រាយយ៉ាងច្បាស់ចំពោះបញ្ហារបស់យើង។ ប៉ុន្តែ ពេលខ្លះ ការនេះមិនកើតឡើងឡើយ។ មានមនុស្សមួយចំនួនមិនបានជាសះស្បើយពីជំងឺមហារីករបស់ពួកគាត់នោះទេ។ ពេលខ្លះ ជីវិតអាពាហ៍ពិពាហ៍របស់គ្រីស្ទបរិស័ទដែលល្អក៏ត្រូវបានបញ្ចប់ដោយការលែងលះគ្នាដែរ។ ភាពកម្សោយមួយចំនួនរបស់ប្ដី ឬប្រពន្ធយើងមិនអាចផ្លាស់ប្ដូរបាននៅលើផែនដីនេះទេ។ ខ្ញុំបានឃើញថា ភាពកម្សោយនៃការឆាប់ទទួលអារម្មណ៍រំខានរបស់ខ្ញុំក៏កាន់តែអាក្រក់ទៅៗ នៅពេលដែលខ្ញុំកាន់តែចាស់ទៅៗ ដែលនេះតម្រូវឲ្យប្រពន្ធរបស់ខ្ញុំកាន់តែមានភាពអត់ធ្មត់ច្រើនជាងមុនដែរ។ ប៉ុន្តែ មិនថាយើងបានដោះស្រាយបញ្ហានោះ នៅក្នុងរបៀបដែលយើងសង្ឃឹមទុក ឬក៏អត់ ក៏ចំណុចគោលដែលមាននៅក្នុងកណ្ឌគម្ពីររ៉ូមជំពូកទី៨ដែលខ្ញុំបានពន្យល់នៅក្នុងផ្នែកនេះ អាចអនុវត្តបានក្នុងជីវិតរស់នៅរបស់យើងបានដែរ។ ជាដំបូង យើងត្រូវតែទទួលស្គាល់ថា ការខកបំណងគឺជាផ្នែកមួយនៅក្នុងជីវិតនេះ ហេតុដូច្នេះហើយ ចំណុចទី២គឺថា យើងក៏មានសេរីភាពក្នុងការថ្ងូរ ហើយបង្ហាញនូវការឈឺចាប់របស់យើង។ ទី៣ យើងត្រូវចេះអត់ធ្មត់យ៉ាងសកម្មក្នុងការមានទំនុកចិត្តថា ព្រះជាម្ចាស់នឹងបង្វែរគ្រប់កាលៈទេសៈទាំងអស់ឲ្យទៅជាការល្អ។ ទី៤ តាមរយៈពេលវេលានៃការឈឺចាប់របស់យើង យើងមានបទពិសោធន៍ពីព្រះវត្តមានរបស់ព្រះជាម្ចាស់ដែលកំពុងជួយយើងយល់អំពីយើង និងកម្សាន្តចិត្តយើង។ ទី៥ យើងត្រូវតែទទួលជឿលើការពិតទាំងបួននេះ ហើយអនុវត្តចំណុចទាំងនេះនៅក្នុងជីវិតរស់នៅជាប្រចាំថ្ងៃរបស់យើង ដោយសេចក្ដីជំនឿ។

## មានចំណុចខ្លះដែលអាចផ្លាស់ប្ដូរបាន

នៅក្នុងជំពូកនេះ ខ្ញុំបានរៀបរាប់ជាច្រើនអំពីបញ្ហាដែលមិនអាចផ្លាស់ប្ដូរបាន ហើយថាការនោះតម្រូវឲ្យយើងទ្រាំទ្រដោយសេចក្ដីអត់ធ្មត់។ ប៉ុន្តែ ក៏មានបញ្ហាមួយចំនួនអាចផ្លាស់ប្ដូរបាន។ នៅក្នុងដំណើរឆ្ពោះទៅកាន់ការរក

ដំណោះស្រាយ ដៃគូជីវិតក៏ទំនងជាត្រូវស្វែងរកជំនួយពីមនុស្សដែលអាចទុកចិត្តបាន—ដូចជាគ្រូគង្វាល អ្នកប្រឹក្សាយោបល់ ឬជាអ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទ—ដែលជាអ្នកធ្លាប់មានបទពិសោធន៍ក្នុងការជួយដល់អ្នកផ្សេងទៀតដែរ។

ភាគច្រើននៃបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៅក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ ហើយភាគច្រើននៃសមាជិកក្រុមជំនុំរបស់ខ្ញុំគឺជាអ្នកជឿព្រះ ជំនាន់ដំបូងក្នុងគ្រួសារ។ ពួកគាត់មិនមានគំរូនៃជីវិតគ្រួសារបែបជាគ្រីស្ទបរិស័ទនោះទេ ហើយភាគច្រើនក៏មកពីគ្រួសារដែលមិនល្អ ដោយសារការបំផ្លាញពីគ្រឿងស្រវឹងទៀតផង។ ក្នុងអំឡុងពេលពីរបីឆ្នាំដំបូងនៃជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់ ជាទូទៅពួកគាត់ជួបប្រទះនឹងបញ្ហាធំៗ។ អ្នកខ្លះបានមករកយើងដែលជាអ្នកចាស់ជាង ដើម្បីឲ្យយើងជួយ។ យើងព្យាយាមជួយឲ្យពួកគាត់យល់អំពីប្ដី ឬប្រពន្ធរបស់ខ្លួន ហើយក៏ផ្ដល់ដំបូន្មានមួយចំនួនអំពីការកែប្រែខ្លះៗ ដែលពួកគាត់ត្រូវធ្វើនៅក្នុងអាកប្បកិរិយា និងទម្លាប់របស់ខ្លួន។ ជាធម្មតាពួកគាត់បានឃើញថា បញ្ហារបស់ពួកគាត់គឺមិនមែនជាបញ្ហា ដែលមិនអាចដោះស្រាយបានដូចដែលពួកគាត់បានគិតនោះទេ។ ខ្ញុំបានឃើញគូស្រករដូចនោះជាច្រើនមកហើយ ដែលបានចាប់ផ្ដើមរស់នៅជាមួយគ្នាដោយមានភាពច្របូកច្របល់ ប៉ុន្តែបានក្លាយជាគូស្រករដោយមានសុភមង្គលវិញ។

ពេលខ្លះ ដៃគូដែលរៀបការហើយមានការពិបាកក្នុងការសម្រួលគ្នាក្នុងផ្នែកនៃការរួមដំណេក។ ការនេះទំនងជាដោយសារបទពិសោធន៍ពីអតីតកាលបាននាំឲ្យមានការយល់ច្រឡំអំពីអាកប្បកិរិយាចំពោះការរួមដំណេក។ អស់អ្នកដែលធ្លាប់មានគេរំលោភបំពានផ្នែកផ្លូវភេទអាចបដិសេធការរួមដំណេក ឬក៏មានការចង់មានការរួមដំណេកខ្លាំងពេក។ អស់អ្នកដែលនៅក្នុងក្រុមទី២នឹងទំនងជារស់នៅក្នុងជីវិតដែលមានការលោយឡំគ្នា មូលហេតុមួយគឺដោយសារសេចក្ដីប្រាថ្នា ហើយមូលហេតុមួយទៀតគឺដោយសារពួកគាត់មានអារម្មណ៍ថា ខ្លួនមិនមានភាពបរិសុទ្ធដើម្បីការពារទៀតឡើយ។ អ្នកទាំងនោះអាច

ទទួលបានការជួយក្នុងការមានបទពិសោធន៍នៃការព្យាបាល និងមានភាពបរិសុទ្ធតាមរយៈព្រះគុណរបស់ព្រះគ្រីស្ទ ដែលបានសម្របសម្រួលដោយគ្រូគង្វាល និងអ្នកប្រឹក្សាដទៃទៀត។ យើងអាចនាំអស់អ្នកដែលមានអាកប្បកិរិយាមិនត្រឹមត្រូវចំពោះការរួមដំណេកឲ្យយល់ដឹងអំពីរបៀបដែលមាននៅក្នុងព្រះគម្ពីរទាក់ទងនឹងការរួមភេទ ហើយនិងការរួមដំណេកថាជាអ្វីមួយដែលល្អ ដែលយើងមានចំណង់ចង់រីករាយជាមួយ។ មនុស្សមួយចំនួនទៀតក៏អាចមានទំនាក់ទំនងឈឺចាប់ខាងឯផ្លូវភេទ ហើយការឈឺចាប់អាចទទួលបានការធូរស្បើយ តាមរយៈការវះកាត់ដ៏សាមញ្ញមួយពីគ្រូពេទ្យ។ មានដៃគូជីវិតជាច្រើនមិនទទួលបានការអរសប្បាយផ្នែកផ្លូវភេទក្នុងការស្រឡាញ់គ្នា អស់រយៈពេលដែលមិនចាំបាច់ចាំយូរ ពីព្រោះពួកគាត់មិនបានដឹងអំពីមូលហេតុនៃការឈឺចាប់ និងការដែលគ្រូពេទ្យអាចជួយសម្រួលឲ្យបាន។

ចំពោះមនុស្សដែលឆាប់ខឹង និងមនុស្សមិនសប្បាយចិត្ត ដែលកំហឹងរបស់ពួកគាត់កំពុងបំផ្លាញគ្រួសារខ្លួន ក៏អាចស្វែងរកឫសគល់នៃកំហឹងដ៏មិនធម្មតារបស់ពួកគាត់ ហើយចាប់ផ្តើមព្យាបាលបានដែរ។ ខ្ញុំធ្លាប់បានធ្វើការជាមួយអ្នកដែលមានស្នាមរបួសយ៉ាងខ្លាំង ដែលមានតាំងពីក្មេងៗមក (ជាញឹកញាប់កើតចេញពីការដែលឪពុកមិនមានសេចក្តីសប្បុរស) ប៉ុន្តែ តាមរយៈការប្រឹក្សាយោបល់ គាត់ក៏ទទួលបានការព្យាបាលដោយការអធិស្ឋាន និងការអត់ទោសដល់អស់អ្នកដែលបានបង្កការឈឺចាប់នោះ។ ពួកគាត់បានឃើញការដោះលែង និងសេរីភាពទាក់ទងនឹងការខឹងសម្បារ។

លោក ដាវីឌ ស៊ីមិនដ៍ (David Seamands) បាននិយាយអំពីគ្រូគង្វាលម្នាក់ ដែលបានមកជួបគាត់ជាមួយនឹងប្រពន្ធរបស់ខ្លួន។ គាត់មានបញ្ហាមិនចុះសម្រុងនឹងគ្នា ជាពិសេសជាមួយប្រពន្ធ និងគ្រួសាររបស់ប្រពន្ធគាត់។ គាត់នៅតែបន្តក្នុងការរិះគន់ប្រពន្ធ។ សូម្បីតែសេចក្តីអធិប្បាយរបស់គាត់ក៏សាហាវ និងពេញដោយការស្តីបន្ទោសផងដែរ។ លោក ស៊ីមិនដ៍ បានសរសេរថា “គាត់កំពុងដោះស្រាយរាល់បញ្ហានៃការមិនសប្បាយចិត្តរបស់គាត់ទាំងអស់ដោយ

ដាក់លើអ្នកដទៃ»។

ក្នុងការចាប់ផ្តើមការសម្ភាសន៍របស់គាត់ជាមួយលោក ស៊ីមិនដ៍ «គាត់បានដោះស្រាយបញ្ហាដូចជាបុរសពិតម្នាក់៖ គាត់បានស្តីបន្ទោសប្រពន្ធរបស់គាត់!» ប៉ុន្តែ មួយសន្ទុះក្រោយមក ឫសគល់នៃការឈឺចាប់របស់គាត់ក៏ទទួលការបង្ហាញឡើង។ គាត់បានឈរជើងនៅប្រទេសកូរ៉េ កាលកំពុងបម្រើជាទាហានសម្រាប់ប្រទេសអាមេរិក។ គាត់មានពេលសម្រាកពីរអាទិត្យនៅទីក្រុងតូក្យូ (Tokyo)។ «ក្នុងអំឡុងពេលសម្រាកនោះ ដោយកំពុងតែដើរនៅលើផ្លូវក្នុងទីក្រុងតូក្យូ ហើយមានអារម្មណ៍មិនមានអ្វីសោះ អារម្មណ៍ឯកា ហើយអារម្មណ៍នឹកផ្ទះយ៉ាងខ្លាំងផង គាត់បានធ្លាក់ក្នុងសេចក្តីល្បួង ហើយបានទៅរកស្រីពេស្យារហូតដល់បីទៅបួនដង»។ គាត់មិនអាចអត់ទោសឲ្យខ្លួនគាត់បានហើយក៏មិនមានការធានាដែលថា ព្រះជាម្ចាស់បានអត់ទោសឲ្យគាត់ដែរ។ គាត់ក៏បានត្រឡប់មកផ្ទះវិញ ហើយរៀបការជាមួយគូដណ្តឹងរបស់គាត់ ប៉ុន្តែដោយសារកំហឹងរបស់គាត់ជាមួយខ្លួនឯង នោះគាត់មិនអាចទទួលសេចក្តីស្រឡាញ់របស់ប្រពន្ធបាន។ គាត់បានរស់នៅក្នុងអ្វីដែលលោក អេ. ដឹបលយូ ថូហ្ស៊ែរ បានហៅការនោះថា «ជាវិប្បដិសារីទណ្ឌកម្មនៃការសោកស្តាយជារៀងរហូត»។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សាច់រឿងនេះមានការបញ្ចប់ដោយល្អប្រសើរដែរ៖ គ្រូគង្វាលម្នាក់នោះបានទទួលយកការអត់ទោសរបស់ព្រះជាម្ចាស់ បន្ទាប់មកក៏បានទទួលការអត់ទោសពីប្រពន្ធរបស់គាត់ និងពីខ្លួនគាត់ផងដែរ។[១៨]

វាជារឿងគួរឲ្យសោកស្តាយណាស់ ដែលដៃគូជីវិតជាច្រើនមានបញ្ហាធ្ងន់ធ្ងរបែបនេះនៅតែបន្តពន្យារពេលក្នុងការស្វែងរកជំនួយ។ ខណៈពេលដែលការប្រឹក្សា និងការដែលគ្រូគង្វាលមើលថែមិនមែនជាដំណោះស្រាយចំពោះគ្រប់បញ្ហាទាំងអស់មែន ក៏ទាំងនេះនៅអាចជួយមនុស្សជាច្រើនក្នុងការស្វែងរកការដោះលែងចេញពីបន្ទុករបស់ពួកគាត់ ឬក៏ជាព្រះគុណក្នុងការស៊ូទ្រាំផងដែរ។

## ចូរតស៊ូក្នុងការអធិស្ឋាន

យើងមិនអាចមិននិយាយបានឡើយអំពីចំណុចសំខាន់បំផុត ដែលមនុស្សម្នាក់អាចធ្វើបាននៅពេលដែលមានបញ្ហានៅក្នុងគ្រួសារ ចំណុចនោះគឺការអធិស្ឋាន។ ខ្ញុំបានសរសេរអំពីការនេះនៅក្នុងជំពូក១ ពេលដែលខ្ញុំបានលើកឧទាហរណ៍អំពីអ្នកស្រី ម៉ូនីកា ដែលបានអធិស្ឋានឲ្យកូនប្រុសវង្វេងរបស់គាត់គឺលោកគ្រូ អហ្គូស្ទីន ដែលគាត់បានផ្លាស់ប្រែចិត្តត្រឡប់មករកព្រះអង្គវិញ មុនពេលដែលអ្នកស្រីបានស្លាប់។ លោកស្រី រស់ បែល ហ្គ្រាហាំ (Ruth Bell Graham ដែលជាប្រពន្ធរបស់លោក ប៊ីលី ហ្គ្រាហាំ) បានយល់ពីការឈឺចាប់នៃការស្រឡាញ់ ហើយក៏បានអធិស្ឋានសម្រាប់កូនប្រុសវង្វេងពីរនាក់ គាត់បានសរសេរសៀវភៅដ៏មានឥទ្ធិពលមួយដែលមានចំណងជើងថា “ជនក្បត់ និងអស់អ្នកដែលស្រឡាញ់ពួកគាត់” (“Prodigals and Those Who Love Them”)។ គាត់បានចង្អុលបង្ហាញទៅកាន់សេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវសម្រាប់ពួកសិស្សរបស់ទ្រង់ ហើយបានផ្តល់ជាសម្រង់សម្តីដែលជាទម្រង់សង្ខេបយ៉ាងល្អនៃសេចក្តីអធិស្ឋាន ដែលយើងអាចអធិស្ឋានសម្រាប់កូនៗដែលវង្វេងថា៖

> ឱព្រះវរបិតាជាព្រះដ៏បរិសុទ្ធអើយ! ក្នុងព្រះនាមព្រះអង្គ សូមរក្សាអស់អ្នកដែលទ្រង់បានប្រទានមកកាន់យើងខ្ញុំ....យើងខ្ញុំអធិស្ឋានសូមកុំឲ្យព្រះអង្គដកពួកគាត់ចេញពីផែនដីនេះ ប៉ុន្តែសូមព្រះអង្គរក្សាពួកគាត់ឲ្យរួចពីអំពើអាក្រក់...សូមបន្សុទ្ធពួកគាត់តាមរយៈសេចក្តីពិតរបស់ទ្រង់៖ ព្រះបន្ទូលរបស់ព្រះអង្គជាសេចក្តីពិត.... ឱព្រះវរបិតាអើយ យើងខ្ញុំក៏ទូលសូមឲ្យអស់អ្នកដែលព្រះអង្គបានប្រទានមកឲ្យយើងខ្ញុំនៅកន្លែងដែលយើងខ្ញុំនៅផងដែរ។[១៩]

ខ្ញុំបានឮអំពីរឿងបុរសម្នាក់ដែលប្រពន្ធរបស់គាត់បានចាកចេញពីគាត់ ហើយគាត់ត្រូវតែលែងលះស្ត្រីនោះ។ ប៉ុន្តែ គាត់មិនដែលបោះបង់ចោលសេចក្តីសង្ឃឹមនៃការផ្សះផ្សាជាមួយប្រពន្ធវិញនោះទេ។ គាត់តែងតែដើរ

យ៉ាងទៀងទាត់នៅកន្លែងដែលប្រពន្ធរស់នៅ ដោយអធិស្ឋានសម្រាប់គាត់ និងសម្រាប់ការផ្សះផ្សាគ្នាវិញ។ ប្រាំឆ្នាំក្រោយមក ពួកគាត់ក៏បានរួបរួមគ្នាជាថ្មីម្ដងទៀតក្នុងជីវិតអាពាហ៍ពិពាហ៍។ ពេលខ្លះ សេចក្ដីអធិស្ឋានរបស់ឪពុកម្ដាយសម្រាប់កូនៗដែលវង្វេងមានផលផ្លែតែនៅពេលដែលឪពុកម្ដាយនោះបានស្លាប់ហើយ។ ពេលខ្លះទៀត បងប្អូនដែលមានកំហឹងដាក់គ្នាទៅវិញទៅមក រួបរួមជាមួយគ្នាវិញបានតែនៅក្នុងពិធីបុណ្យសពរបស់ម្ដាយ ដែលបានខូចចិត្តចំពោះការបែកបាក់របស់គាត់តែប៉ុណ្ណោះ។

មានពាក្យមួយក្នុងភាសាក្រិក ដែលជាពាក្យក្រុមក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលមានន័យថា «ការតស៊ូយ៉ាងចចេសក្នុង»។[៧០] គេបានប្រើកិរិយាសព្ទ «ព្រូសខ័រតេរីអូ» (proskartereō) ប្រាំដង (កិច្ចការ ១:១៤; ២:៤២, ៤៦; រ៉ូម ១២:១២; កូឡូស ៤:២) និងនាម «ព្រូសខ័រតេរីសិស៍» (proskarterēsis) មួយដង (អេភេសូរ ៦:១៨)។ យើងមិនត្រូវបោះបង់ការអធិស្ឋានចោលឡើយ យើងត្រូវតែតស៊ូ!!

## កុំអនុញ្ញាតឲ្យបញ្ហាបង្ខាំងការមើលថែគ្រួសារ

លោកអ្នកទំនងជាធ្លាប់បានឮអំពីដៃគូជីវិតដែលមានបញ្ហាធ្ងន់ធ្ងរជាមួយកូន ដូចជាការចាប់ជំរិត ឬក៏ជាជំងឺធ្ងន់ធ្ងរណាមួយ តែបន្ទាប់មកពួកគាត់បានលែងលះគ្នា នៅពេលវិបត្តិនោះបានចប់អស់។ នៅក្នុងករណីនីមួយៗ ពួកគាត់បានចំណាយកម្លាំងច្រើនទៅលើបញ្ហាកូនៗរបស់ពួកគាត់ ដែលធ្វើឲ្យពួកគាត់មិនបានយកចិត្តទុកដាក់ក្នុងការមើលថែទំនាក់ទំនងរបស់ខ្លួន។ ជាទូទៅ ដៃគូជីវិតនោះមានបញ្ហាធ្ងន់ធ្ងរមុនពេលមានវិបត្តិកើតមានហើយ ប៉ុន្តែវិបត្តិនោះបានធ្វើឲ្យពួកគាត់មិនចុះសម្រុងគ្នាបានយ៉ាងឆាប់រហ័ស រហូតដល់ពួកគាត់បាត់បង់ចំណង់ក្នុងការរស់នៅជាមួយគ្នា។

គ្រប់គ្នានៅក្នុងគ្រួសារត្រូវការការទទួលការមើលថែគ្រប់ពេលវេលា។ ពេលខ្លះ ឪពុកម្ដាយដែលមានបញ្ហាធ្ងន់ធ្ងរជាមួយនឹងកូន ដូចជាជំងឺឆ្កួតជ្រូក ខ្វាក់

ជំងឺសរសៃប្រសាទ ការផ្ទង់អារម្មណ៍ខ្លាំង ឬក៏ការបះបោរ ក៏អាចមានអារម្មណ៍អស់ពីខ្លួនយ៉ាងខ្លាំង ដែលនោះជាលទ្ធផលនៃការដែលពួកគាត់ព្យាយាមដោះស្រាយបញ្ហា។ ពួកគាត់មិនយកចិត្តទុកដាក់ចំពោះរូបកាយ អារម្មណ៍ និងសុខភាពខាងឯព្រលឹងវិញ្ញាណរបស់ខ្លួន ហើយពួកគាត់ក៏មិនបានយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក និងចំពោះក្មេងៗដទៃទៀត។ ការនេះអាចបណ្តាលឲ្យមានបញ្ហាយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារ។ នៅពេលដែលមានការប្រកាសណែនាំឲ្យប្រើប្រាស់ខ្យល់អុកស៊ីហ្សែននៅលើយន្តហោះ អ្នកណែនាំតែងតែប្រាប់អស់អ្នកដែលមានកូនៗឲ្យពាក់ម៉ាស់សម្រាប់ខ្លួនឯងជាមុនសិន ហើយបន្ទាប់មកទើបពាក់ឲ្យកូនៗរបស់ពួកគាត់តាមក្រោយ។ ឪពុកម្តាយត្រូវតែមានសុខភាពល្អ និងរឹងមាំខ្លាំងសិន ដើម្បីឲ្យអាចជួយកូនៗរបស់ខ្លួនបាន។

យើងត្រូវតែរម្លឹកឪពុកម្តាយ ដែលមានបញ្ហាដូចនោះ អំពីគ្រោះថ្នាក់នៃការមិនយកចិត្តទុកដាក់ពីជីវិតរបស់ខ្លួន និងទំនាក់ទំនងរបស់ពួកគាត់ជាមួយប្តី ឬប្រពន្ធ។ យើងត្រូវតែធ្វើអ្វីគ្រប់យ៉ាង ដែលអាចធ្វើបាន ដើម្បីកាត់បន្ថយសម្ពាធរបស់ពួកគាត់។ យើងអាចឲ្យឪពុកម្តាយដូចនោះសម្រាក និងទទួលយកទំនួលខុសត្រូវមួយចំនួន (ដូចជាការមើលកូនគាត់) ដើម្បីឲ្យពួកគាត់អាចមានពេលសម្រាកនៅខាងក្រៅបាន។ យើងក៏អាចជួយគ្រួសារទាំងនេះបានដោយសេចក្តីអធិស្ឋានជាពិសេសសម្រាប់ពួកគាត់ដែរ។ ខ្ញុំមានមិត្តភក្តិម្នាក់មានកូន ដែលមានជំងឺសរសៃប្រសាទ ហើយខ្ញុំក៏ទទួលបានការត្រាស់ហៅផ្ទាល់ឲ្យអធិស្ឋានឲ្យគ្រួសារនោះជាប្រចាំ ជាពិសេសអធិស្ឋានឲ្យអ្នកម្តាយទទួលបានព្រះគុណ។ គ្រួសារនេះរស់នៅក្នុងប្រទេសមួយផ្សេងទៀត ប៉ុន្តែខ្ញុំជឿថាខ្ញុំកំពុងតែបន្ថយបន្ទុករបស់ពួកគាត់ ហើយក៏បន្ថែមព្រះគុណ ដែលបានបង្ហាញចំពោះពួកគាត់ តាមរយៈសេចក្តីអធិស្ឋានយ៉ាងទៀតទាត់របស់ខ្ញុំសម្រាប់ពួកគាត់ដែរ។

## សេចក្តីសន្និដ្ឋាន

សូមអនុញ្ញាតឲ្យខ្ញុំបញ្ចប់ជំពូកនេះដោយត្រឡប់ទៅមើលប្រធានបទ ដែលខ្ញុំបានសង្កត់ធ្ងន់នៅក្នុងសៀវភៅនេះ។ មិនគួរមានអ្វីមួយមករំខានយើង ឲ្យងាកចេញពីការកសាងជីវិតអាពាហ៍ពិពាហ៍ និងគ្រួសាររបស់យើងនោះទេ។ យើងប្រឈមមុខនឹងបញ្ហាជាច្រើន—ជំងឺ ភាពកម្សោយ ការយល់ច្រឡំ ខ្មាំងសត្រូវ បញ្ហាផ្នែកហិរញ្ញវត្ថុ កូនៗមានការបះបោរ ការល្បួងខាងផ្លូវភេទ និងបញ្ហាកូនប្រសារនៅក្នុងគ្រួសារ។ ប៉ុន្តែ ចំណុចទាំងនោះមិនត្រូវចូលមករំខានរបៀបនៃការថែរក្សាទំនាក់ទំនងរបស់យើង នៅក្នុងគ្រួសារបានឡើយ។ ព្រះជាម្ចាស់បានមានការប្តេជ្ញាចិត្តចំពោះជីវិតអាពាហ៍ពិពាហ៍ និងគ្រួសាររបស់យើង។ ព្រះអង្គសព្វព្រះហឫទ័យឲ្យពួកគាត់មានភាពអរសប្បាយ និងបរិសុទ្ធ ហើយក៏នឹងប្រទានដល់យើងនូវជំនួយដែលយើងត្រូវការដែរ។ ការនេះអាចផ្តល់ដល់យើងនូវទំនុកចិត្តក្នុងការប្រយុទ្ធតស៊ូក្នុងជីវិតអាពាហ៍ពិពាហ៍ និងគ្រួសាររបស់យើង។ ប៉ុន្តែ យើងត្រូវតែឲ្យអាទិភាពចម្បងទៅកាន់គ្រួសារ និងដោះស្រាយបញ្ហាដែលពួកគាត់ប្រឈមមុខដាក់ដែរ។

## ៨

# ការរួបរួមគ្នា

ជាញឹកញាប់ ព្រះគម្ពីរនិយាយអំពីការដែលគ្រីស្ទបរិស័ទត្រូវមានការរួបរួមគ្នានៅក្នុងក្រុមជំនុំ។ សាវ័ក ប៉ុល បានប្រាប់ក្រុមជំនុំភីលីពថា «នោះចូរបំពេញសេចក្ដីអំណររបស់ខ្ញុំ ដោយអ្នករាល់គ្នាមានគំនិត មានសេចក្ដីស្រឡាញ់តែ១ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នាចុះ» (ភីលីព ២:២)។ កណ្ឌគម្ពីរកិច្ចការបានបង្ហាញថា ក្រុមជំនុំដំបូងមានការរួបរួមគ្នាក្នុងរបៀបនេះ (កិច្ចការ ៤:៣២)។ នៅពេលមានការមិនចុះសម្រុងគ្នាបានកើតឡើង ក្រុមជំនុំក៏មានវិធានការជាបន្ទាន់ក្នុងការស្ដារឲ្យមានការរួបរួមឡើងវិញ (កិច្ចការ ៦:១-៦; ១៥:១-២៩)។ ប្រសិនបើការរួបរួមបែបនេះជាគំរូសម្រាប់ជីវិតក្រុមជំនុំ តើវាកាន់តែសំខាន់ប៉ុណ្ណាចំពោះគ្រួសារ? ព្រះគម្ពីរបានរៀបរាប់យ៉ាងច្រើនអំពីការរួបរួមគ្នាដូចនេះនៅក្នុងក្រុមជំនុំ និងគ្រួសារ។

## ការរួបរួមគ្នាក្នុងភាពចម្រុះគ្នា

កណ្ឌគម្ពីរ១កូរិនថូសជំពូកទី១២បានបង្ហាញពីក្រុមជំនុំថាជាអវយវៈដែលមានការរួបរួមក្នុងភាពចម្រុះគ្នា។ ការនេះក៏ជាការពិតនៅក្នុងជីវិតអាពាហ៍ពិពាហ៍ផងដែរ។ នៅពេលព្រះជាម្ចាស់បានបង្កើតមនុស្ស ព្រះអង្គបានបង្កើតម្នាក់ៗឲ្យ

មានភាពខុសៗគ្នា ដូច្នេះក៏បាននាំឲ្យមានភាពចម្រុះគ្នា និងល្អប្រសើរដល់ជីវិតនៅលើផែនដីនេះ។ មិត្តភក្តិរបស់យើងដែលជាជនជាតិមូស្លីមមានការពិបាកយល់អំពីមូលហេតុដែលត្រូវមានការរៀបរាប់ខុសៗគ្នាបួនយ៉ាងអំពីព្រះយេស៊ូវនៅក្នុងព្រះគម្ពីរ។ ដំណឹងល្អទាំងបួនឆ្លុះបញ្ចាំងអំពីចំណុចចម្លែកអំពីបុគ្គលិកលក្ខណៈ រចនាបថ និងការផ្ដោតលើតាមកណ្ឌគម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន។ ក្នុងគម្ពីរកិច្ចការ យើងឃើញសាវ័ក ពេត្រុស លោក ស្ទេផាន និងសាវ័ក ប៉ុល ប្រើប្រាស់ស្ទាយខុសៗគ្នាក្នុងការអធិប្បាយ។ សព្វថ្ងៃនេះ យើងមានទម្រង់ខុសគ្នានៃការគ្រប់គ្រងក្នុងក្រុមជំនុំ ហើយក្រុមនីមួយៗអះអាងថាមានការគាំទ្រពីព្រះគម្ពីរ ដូចគ្នាផងដែរក៏មានស្ទាយខុសៗគ្នាក្នុងការថ្វាយបង្គំនិងការរំអង្គាស។ ហើយសិស្សដែលមានការប្ដេជ្ញាចិត្តក៏មានការកាត់ស្រាយខុសៗគ្នាលើខគម្ពីរតែមួយដែរ។ ព្រះជាម្ចាស់ស្រឡាញ់ភាពចម្រុះគ្នា។

ប៉ុន្តែ នៅក្នុងជំនឿគ្រីស្ទបរិស័ទ ក្នុងភាពចម្រុះគ្នានោះក៏មានការរួបរួមគ្នានៃគោលបំណងមួយដែរគឺ—ការរស់នៅដែលផ្គាប់ព្រះទ័យដល់ព្រះជាម្ចាស់។ សម្រង់សម្ដីអំពីការរួបរួមដោយចម្រុះនៅក្នុងក្រុមជំនុំ ដែលគេបានលើកឡើងថាអ្នកដឹកនាំក្នុងជំនឿគ្រីស្ទបរិស័ទមួយចំនួនពីអតីតកាលបានលើកឡើងដោយចាប់ផ្ដើមតាំងពីលោកគ្រូ អហ្គូស្ទីន ក៏ជាជំនួយដល់ជីវិតគ្រួសារផងដែរ។ គាត់បានលើកឡើងថា «ចូរមានការរួបរួមគ្នាក្នុងចំណុចសំខាន់ ចូរមានសេរីភាពក្នុងចំណុចដែលមិនសំខាន់ ហើយក្នុងគ្រប់អ្វីៗទាំងអស់ ចូរមានសេចក្ដីស្រឡាញ់»។ មនុស្សដែលមានចិត្តទូលាយគឺជាអ្នកដែលអនុញ្ញាតឲ្យអ្នកដទៃធ្វើតាមចំណង់ចំណូលចិត្តរបស់ខ្លួន ទោះបីជាពួកគាត់ទំនងជាមិនជ្រើសរើសផ្លូវដូចគ្នាក៏ដោយ។ អាកប្បកិរិយាបែបនេះគឺពិតជាសំខាន់ណាស់នៅក្នុងគ្រួសារ ដោយជួយឲ្យសមាជិកគ្រួសាររៀងៗខ្លួនលូតលាស់បានយ៉ាងពេញទំហឹង។

ប្រុសៗភាគច្រើននៅប្រទេសស្រីលង្កាចូលចិត្តមើលកីឡា និងវិស័យនយោបាយនៅលើកញ្ចក់ទូរទស្សន៍ជាងប្រពន្ធខ្លួន។ ហើយឲ្យតែធ្វើបែបនេះ

មិនដល់កម្រិតហួសហេតុពេករហូតធ្វើឲ្យមានការប៉ះពាល់ដល់គ្រួសារ ប្រពន្ធដែលមានចិត្តទូលាយអាចឲ្យប្តីខ្លួនរីករាយក្នុងការមើលកម្មវិធីកីឡា និងវិស័យនយោបាយនៅលើកញ្ចក់ទូរទស្សន៍បាន។ ដោយសារសេចក្តីស្រឡាញ់ដែលគាត់មានចំពោះប្តីខ្លួន គាត់ទំនងជាអាចចាប់ផ្តើមមានការចាប់អារម្មណ៍លើការទាំងអស់នេះដែរ។ ខណៈពេលដែលប្រុសៗកំពុងចូលចិត្តមើលកម្មវិធីចម្អិនម្ហូបនៅលើកញ្ចក់ទូរទស្សន៍ ក៏ស្រីៗនៅប្រទេសលង្កានៅតែចូលចិត្តមើលវាច្រើនជាងប្រុសៗទៅទៀត។ ប្រុសៗអាចមានអំណរក្នុងការឲ្យប្រពន្ធខ្លួនមើលកម្មវិធីទាំងនេះបាន ហើយជួយទទួលយកទំនួលខុសត្រូវមួយចំនួននៅក្នុងអំឡុងពេលទាំងនោះ។

ប្តី និងប្រពន្ធអាចនឹងមានគំនិតខុសៗគ្នាអំពីរបៀបដែលគេគួរតុបតែងផ្ទះ ឬក៏ថាតើគួរលាបជញ្ជាំងពណ៌អ្វីជាដើម។ អាចមានការលេចឡើងនូវចំណង់ចំណូលចិត្តខុសគ្នាក្នុងការជ្រើសរើសម្ហូប ទីកន្លែងដែលគួរទៅលេងក្នុងថ្ងៃឈប់សម្រាក ការទិញកាដូសម្រាប់មនុស្សជាទីស្រឡាញ់ ការដែលគួរក្រោកពីព្រលឹម ឬក៏ក្រោកយឺតនៅពេលព្រឹក និងកិច្ចការជាច្រើនផ្សេងទៀតដែរ។ ជាទូទៅ ជម្រើសទាំងនោះមិនបង្ខូចគោលការណ៍ផ្នែកសីលធម៌ទេ។ ការទាំងនេះទាក់ទងនឹងចំណង់ចំណូលចិត្ត។ មនុស្សដែលមានចិត្តទូលាយអាចចុះចូលក្នុងការធ្វើតាមបំណងរបស់អ្នកដទៃបាន ដោយមិនចាំបាច់ប្រព្រឹត្តបែបមិនមានភាពចាស់ទុំ និងទទូចអង្វរតាមផ្លូវរបស់ខ្លួន។

គេបានសរសេរជាច្រើនអំពីលោកស្រី រស់ បែល ហ្គ្រាហាំ (Ruth Bell Graham) ដែលជាមនុស្សដែលមានប្រយោជន៍ម្នាក់ ទាក់ទងនឹងជីវប្រវត្តិ និងព័ន្ធកិច្ចរបស់លោក ប៊ីលី (Billy) ដែលជាប្តីរបស់គាត់។ ពួកគាត់មានជីវិតអាពាហ៍ពិពាហ៍ដែលមានសុភមង្គល។ ប៉ុន្តែ ជារឿយៗលោកស្រី រស់ តែងតែលើកអំពីជីវិតអាពាហ៍ពិពាហ៍របស់គាត់ និងលោក Billy ថា “យើងមានភាពអរសប្បាយខណៈពេលដែលមិនមានភាពស៊ីគ្នា”។ អ្នកស្រី ហ្គីហ្គី ហ្គ្រាហាំ ត្សីវិជៀន (Gigi Graham Tchividjian) ដែលជាកូនស្រីរបស់ពួកគាត់

បានលើកឡើងថា៖ «ពួកគាត់មានបុគ្គលិកលក្ខណៈ គំនិត និងរបៀបធ្វើអ្វីៗខុសគ្នាខ្លាំងណាស់។ ប៉ុន្តែ អ្នកម្តាយចូលចិត្តនិយាយថា “ប្រសិនបើមនុស្សពីរនាក់ឯកភាពលើគ្រប់ចំណុច នោះបុគ្គលម្នាក់ក្នុងចំណោមពួកគាត់មិនមានភាពចាំបាច់នោះទេ”»។[១] ទោះបើគាត់បានរៀបការជាមួយនឹងគ្រូគង្វាលបាទីស្ទដ៏ល្បីម្នាក់ក៏ដោយក៏គាត់មិនដែលបោះបង់គោលជំនឿមួយចំនួនរបស់និកាយគាត់ពីប្រេសប៊ីធើរៀនចោលដែរ ដែលមានដូចជាការធ្វើពិធីជ្រមុជទឹកឲ្យកូនក្មេងជាដើម។ លោកស្រី រស់ និងលោក ប៊ីលី ហាក់បីដូចជាបង្ហាញរូបរាងនៃគំនិតដែលលោក ឆាក់ (Chuck) និងលោកស្រី បាប ស៊ីដឌ័រ (Barb Snyder) ប្រើប្រាស់ក្នុងប្រធានបទនៃសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ការមិនមានភាពស៊ីគ្នា៖ មូលហេតុឲ្យនៅតែមានជីវិតអាពាហ៍ពិពាហ៍ល្អ» (“Incompatibility: Still Grounds for a Great Marriage”)។ គេបានបន្ថែមពាក្យ «នៅតែ» ក្នុងចំណងជើងក្នុងការកែសម្រួលលើកទី២ ដែលគេបានបោះពុម្ព១១ឆ្នាំក្រោយការបោះពុម្ពលើកទី១។[២]

គន្លឹះមួយក្នុងការមានសុភមង្គលដែលមិនមានភាពស៊ីគ្នាគឺការត្រាប់តាមដំបូន្មានរបស់សាវ័ក ប៉ុល៖ «តែចូររាប់អានគេឲ្យ [ល្អ] លើសជាងខ្លួនដោយចិត្តសុភាពវិញ» (ភីលីព ២:៣)។ អ្នកដទៃសុទ្ធតែមានអ្វីមួយដែលពូកែជាងយើង។ យើងត្រូវតែផ្តោតលើចំណុចទាំងនោះជាជាងលើគោលគំនិតនៃបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់នោះ ដែលចំណុចនោះទំនងជាអាចរំខានយើងបាន។ គ្រីស្ទបរិស័ទដែលមើលងាយប្តី ឬប្រពន្ធរបស់ខ្លួនគឺអ្នកកំពុងបង្ខូចគំរូនៅក្នុងព្រះគម្ពីរ អំពីជីវិតរស់នៅបែបសហគមន៍ហើយ។ ពួកគាត់ត្រូវតែកែប្រែចិត្ត។ សាវ័ក ប៉ុល ក៏បានលើកឡើងផងដែរថា «ខាងឯសេចក្តីរាប់អាននោះឲ្យខំរាប់អានគេជាមុន» (រ៉ូម ១២:១០)។ ជាជាងមើលងាយ យើងត្រូវឲ្យតម្លៃទៅកាន់សមាជិកគ្រួសាររបស់យើងវិញ។ យើងត្រូវប្តេជ្ញាថានឹងនាំមកនូវកិត្តិយសដល់ពួកគេ។ នេះមានន័យថា យើងត្រូវព្យាយាមផ្តោតទៅលើចំណុចខ្លាំងរបស់ពួកគាត់ ហើយរៀនចេះអត់ធ្មត់ជាមួយនឹងចំណុចខ្សោយរបស់ពួក

គាត់។ ពិតណាស់ នេះគឺជាការដាក់វិន័យ។ យើងមានជម្រើសចំពោះអ្វីដែលយើងផ្តោតលើ។ សេចក្តីស្រឡាញ់ជំរុញឲ្យយើងផ្តោតលើចំណុចខ្លាំងរបស់អ្នកដទៃ។

ពេលខ្លះ យើងមានឋានានុក្រមនៃការឲ្យតម្លៃ ដោយផ្អែកលើមូលដ្ឋានដែលយើងចាត់ទុកថាគេមានភាពទាបតូចតាចជាងយើង។ ឧទាហរណ៍៖ មានមនុស្សម្នាក់ដែលទទួលបានការអប់រំខ្ពង់ខ្ពស់ ជាម្នាក់ដែលមានចំណេះដឹងជ្រៅជ្រះផ្នែកនិន្នាការនយោបាយ និងសេដ្ឋកិច្ចពិភពលោក ម្នាក់នោះបានរៀបការជាមួយបុគ្គលម្នាក់ទៀតដែលមិនសូវទទួលបានការអប់រំខ្ពង់ខ្ពស់ ហើយក៏មានចំណាប់អារម្មណ៍តិចតួច ឬមិនមានតែម្តងចំពោះនិន្នាការនយោបាយ និងសេដ្ឋកិច្ច។ ម្នាក់ដែលទទួលបានការអប់រំខ្ពង់ខ្ពស់ងាយនឹងធ្លាក់ចូលសេចក្តីល្បួងដោយចាត់ទុកប្តី ឬប្រពន្ធថាតូចទាបជាងខ្លួនដោយសារការនេះ។ យើងត្រូវតែមានការប្រឆាំងយ៉ាងស្វិតស្វាញលើអាកប្បកិរិយាបែបនេះ។ ប្រសិនបើបុគ្គលដែលមានការអប់រំខ្ពង់ខ្ពស់បើកភ្នែកមើលដោយបើកចំហចិត្ត នោះគាត់នឹងឃើញគុណសម្បត្តិជាច្រើនក្នុងអ្នកដែលមិនសូវទទួលបានការអប់រំច្រើនដែលគាត់អាចកោតសរសើរយ៉ាងខ្លាំងបាន។ នេះជាបទពិសោធន៍នៃការងាររបស់ខ្ញុំក្នុងការធ្វើការជាមួយអ្នកក្រីក្រ និងអ្នកដែលមិនចេះអក្សរ។ ពួកគេបានបង្រៀនខ្ញុំច្រើនណាស់!

ទោះជាយ៉ាងណាក៏ដោយក៏ភាពទន់ខ្សោយនៃសមាជិកនៅក្នុងគ្រួសាររបស់យើង ជាពិសេសប្តី ឬប្រពន្ធយើងអាចធ្វើឲ្យយើងពិបាករស់នៅជាមួយដែរ។ នេះជាមូលហេតុដែលសេចក្តីអត់ធ្មត់មានសារៈសំខាន់ណាស់ នៅក្នុងការឲ្យតម្លៃក្នុងជំនឿគ្រីស្ទបរិស័ទ ជាពិសេសក្នុងជីវិតជាគ្រួសារ។ យើងធ្លាប់បាននិយាយម្តងរួចហើយនូវទម្រង់ក្រុមពាក្យសំខាន់ពីរក្រុមសម្រាប់ពាក្យ “អត់ធ្មត់” មាន៦១ដងនៅក្នុងភាសាក្រិក នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ការនេះបង្ហាញថាសេចក្តីអត់ធ្មត់មានសារៈសំខាន់ខ្លាំងណាស់នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ។ សេចក្តីអត់ធ្មត់គឺជាបុគ្គលិកលក្ខណសម្បត្តិដំបូងគេបង្អស់នៃសេចក្តីស្រឡាញ់

ដែលបានលើកឡើងនៅក្នុងបញ្ជីយ៉ាងវែងក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៣:៤-៧ ហើយក៏ត្រូវបានហៅថាជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធផងដែរ (កាឡាទី ៥:២២)។ ដោយសារនេះជាផលផ្លែនៃព្រះវិញ្ញាណ យើងដឹងថាយើងអាចមានកម្លាំងក្នុងការមានភាពអត់ធ្មត់ តាមរយៈព្រះវិញ្ញាណដែលគង់នៅក្នុងយើង។ ការនេះផ្តល់ឲ្យយើងមានទំនុកចិត្តក្នុងការបន្តស្វែងរកភាពអត់ធ្មត់ និងការតាំងចិត្តឡើងវិញក្នុងការអនុវត្តវា នៅពេលដែលយើងទទួលការរំខាន។ ដោយសារសេចក្តីស្រឡាញ់គឺជាផ្នែកមួយនៃការស្រឡាញ់បែបអាហ្កាពេ (agapē) ដែលយើងបានពណ៌នានៅក្នុងជំពូក៣ នោះយើងដឹងថាយើងត្រូវតែធ្វើការសម្រេចចិត្តយ៉ាងរឹងមាំក្នុងការមានភាពអត់ធ្មត់ នៅពេលដែលយើងមានសេចក្តីល្បួងដែលនាំឲ្យយើងមិនមានភាពអត់ធ្មត់។ ការដែលព្រះជាម្ចាស់ជួយយើង និងការប្តេជ្ញាចិត្តរបស់យើងក្នុងការមានភាពអត់ធ្មត់នឹងដកយករនាំងដែលបាំងមិនឲ្យយើងផ្តល់តម្លៃដល់ប្តី ឬប្រពន្ធ និងកូនៗរបស់យើងចេញ។

វាជាប្រភពនៃសេចក្តីអំណរខ្លាំងណាស់នៅក្នុងការដឹងថាប្តី ឬប្រពន្ធ ឪពុកម្តាយ បងប្អូនប្រុសស្រី និងកូនៗរបស់យើងមើលមកកាន់យើងដោយគោរព និងពេញចិត្តចំពោះគំនិត និងរបៀបនៃការរស់នៅរបស់យើង។ សូម្បីតែនៅពេលដែលយើងមានការប្រកែកគ្នា ក៏យើងធ្វើបែបនោះដោយរក្សាបុគ្គលិកលក្ខណៈនៃសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទដោយ «មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន» (១កូរិនថូស ១៣:៥)។ គ្រីស្ទបរិស័ទគឺជាអ្នកដែលបានលះបង់បំណងប្រាថ្នារបស់ខ្លួនដោយចុះចូលចំពោះព្រះជាម្ចាស់ ដូចដែលយើងបានឃើញនៅក្នុងជំពូក២។ ដូច្នេះ វាមិនមែនជាបញ្ហាធំក្នុងការដែលពួកគាត់បត់បែន ដើម្បីជួយលក្ខណៈខុសៗគ្នាជាធម្មតានៃសមាជិកគ្រួសារយើងនោះទេ។

ពិតណាស់ ក៏នៅមានបញ្ហាមួយចំនួនដែលយើងមិនអាចមានលទ្ធភាពបន្ធូរខ្វែងគំនិតគ្នាបានដែរ។ ទាក់ទងនឹងរឿងបែបនេះ យើងត្រូវតែនិយាយគ្នា និងអធិស្ឋានរហូតទាល់តែមានការឯកភាពគ្នា។ បញ្ហាមួយនៅក្នុងចំណោមបញ្ហាទាំងនេះគឺទាក់ទងជាមួយនឹងកូនៗផងដែរ។ ខ្ញុំបានឮអំពីប្រពន្ធជាច្រើននាក់

ដែលបានឈប់លេបថ្នាំពន្យារកំណើត ដោយមិនបានប្រាប់ប្ដីរបស់ខ្លួន។ ពួកគាត់បានដឹងថា ប្ដីរបស់ខ្លួនមិនទាន់ចង់បានកូននៅអំឡុងពេលហ្នឹងនៅឡើយ ប៉ុន្តែពួកគាត់ចង់។ ដូច្នេះ ពួកគាត់ក៏មានទម្ងន់ ដោយដឹងថាប្ដីនឹងទទួលយកកូននោះ។ នៅក្នុងជំពូក១២ យើងនឹងមើលជាមួយគ្នាអំពីចំណុចសំខាន់ក្នុងការដែលឪពុកម្ដាយត្រូវឯកភាពគ្នាអំពីរបៀបអប់រំកូនៗ នៅពេលដែលកូនៗបានធ្វើខុស។

ប្ដី និងប្រពន្ធក៏ត្រូវតែមានការឯកភាពគ្នាអំពីរបៀបចាយវាយលុយកាក់របស់ខ្លួនដែរ។ វាតែងតែមានការចំណាយមិនសំខាន់ ដែលមិនចាំបាច់ឲ្យមានការព្រមព្រៀងគ្នា នៅក្នុងជីវិតប្ដីប្រពន្ធនោះទេ។ ប៉ុន្តែ សម្រាប់ការសម្រេចចិត្តធំៗវិញ ការឯកភាពគ្នាគឺពិតជាសំខាន់ណាស់។ តើពួកគាត់នឹងថ្វាយប៉ុន្មានសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ និងចំណាយប៉ុន្មានសម្រាប់អ្នកមានតម្រូវការ? តើពួកគាត់ត្រូវទិញឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះសំខាន់ៗណាខ្លះ? នៅប្រទេសស្រីលង្កា ខ្ញុំស្គាល់អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទជាច្រើននាក់ ដែលប្រពន្ធរបស់ពួកគាត់បានខ្ចីលុយធនាគារសម្រាប់ការចំណាយផ្ទាល់ខ្លួន ដោយប្ដីខ្លួនមិនបានដឹង។ នៅពេលដែលប្ដីបានដឹងអំពីរឿងនេះ ការឆ្លើយតបរបស់គាត់គឺមិនសប្បាយចិត្តទាល់តែសោះ ហើយជីវិតអាពាហ៍ពិពាហ៍ទាំងនោះបានរងទុក្ខយ៉ាងខ្លាំងដល់ការរួបរួមគ្នារបស់ពួកគាត់។

នៅលើកញ្ចក់ទូរទស្សន៍ ជាញឹកញាប់យើងឃើញថា ប្ដី ឬក៏ប្រពន្ធប្រើប្រាស់ការប៉ុនប្រសព្វដាក់គ្នា ដើម្បីបញ្ចុះបញ្ចូលគ្នាឲ្យយល់ព្រមក្នុងការធ្វើអ្វីមួយ។ ពេលខ្លះ ម្នាក់មានល្បិចកលជាង ដែលការនោះធ្វើឲ្យបុគ្គលម្នាក់ទៀតគ្មានជម្រើសផ្សេង ក្រៅពីយល់ព្រមតាមប្ដី ឬប្រពន្ធ។ ការយល់ព្រមធ្វើបែបនេះគឺមិនបានធ្វើចេញពីចិត្តទាំងស្រុងនោះទេ។ ខណៈពេលដែលបុគ្គលម្នាក់បានទទួលអ្វីដែលខ្លួនចង់បាន ដែលបានធ្វើឲ្យគាត់ស្កប់ចិត្ត ក៏ការរួបរួមគ្នាក្នុងគ្រួសារនោះនៅមានភាពតានតឹងដែរ។ ប្ដី ឬប្រពន្ធដែលជាគ្រីស្ទបរិស័ទ “ដើរក្នុងពន្លឺ” ជាមួយនឹងគ្នា (១យ៉ូហាន ១:៧)។ ម្នាក់ដែលប្រើប្រាស់ការប៉ុនប្រសព្វដាក់ម្នាក់

ទៀត ដើម្បីឲ្យទទួលបានអ្វីមួយ គឺគាត់កំពុងប្រព្រឹត្តិល្មើសនឹងគោលការណ៍នៅក្នុងព្រះគម្ពីរហើយ។ គ្រីស្ទបរិស័ទត្រូវតែបង្ហាញការមិនយល់ស្របរបស់ខ្លួនចំពោះសកម្មភាព ឬក៏គម្រោងរបស់ប្ដី ឬប្រពន្ធរបស់ខ្លួន ប្រសិនបើពួកគាត់មិនសប្បាយចិត្តនឹងការទាំងនោះ។ ប៉ុន្តែ ពួកគាត់ធ្វើបែបនោះចេញពីដួងចិត្ត ដែលចុះចូលចំពោះព្រះជាម្ចាស់។ ដូច្នេះ ពួកគាត់កំពុងលះអាល័យចិត្តរបស់ខ្លួនឯង ក្នុងការផ្លាស់ប្ដូរគំនិត ហើយបន្ទាប់មកក៏ចាប់ផ្ដើមគាំទ្រលើអ្វីមួយដែលពីដំបូងពួកគេមិនចូលចិត្តទាល់តែសោះ។

## ការសន្ទនាកាន់តែនាំឲ្យមានការរួបរួមគ្នា

នៅក្នុងជំពូកដែលនិយាយអំពីសេចក្ដីអំណរ ខ្ញុំបានលើកឡើងអំពីរបៀបដែលលោក ឆាលី ស្ពែរ្យដ បានរៀបរាប់នៅក្នុងពិធីគម្រប់ខួបអាពាហ៍ពិពាហ៍លើកទី២៥ឆ្នាំរបស់គាត់ ដែលគាត់បានព្យាយាមសរសើរប្រពន្ធរបស់គាត់ជារៀងរាល់ថ្ងៃ។ នៅក្នុងខួបអាពាហ៍ពិពាហ៍លើកទី៣០របស់គាត់ គាត់បានសរសេរអត្ថបទមួយដែលមានចំណងជើងថា «និយាយ! និយាយ! និយាយ!» (“Talk! Talk! Talk!”)។ គំនិតសំខាន់របស់គាត់គឺថា គន្លឹះដើម្បីឲ្យជីវិតអាពាហ៍ពិពាហ៍មានសុភមង្គលគឺថាដៃគូត្រូវតែនិយាយគ្នាឲ្យបានទៀងទាត់អំពីកិច្ចការរបស់ព្រះ ជាពិសេសអ្វីៗដែលពួកគាត់រៀនបានចេញពីព្រះគម្ពីរ។[៣] បន្ទាប់ពីបានលើកឡើងថាពាក្យពេចន៍ដែលគាត់បានបង្គាប់ជនជាតិអ៊ីស្រាអែលថាគួរឲ្យនៅជាប់ក្នុងចិត្តរបស់ពួកគេ នោះលោក ម៉ូសេ បាននិយាយថា «ត្រូវឲ្យប្រិតប្រៀនសេចក្ដីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាល ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយក្រោកឡើងផង» (ចោទិយកថា ៦:៧)។ នេះគឺជាការពណ៌នាអំពីផ្ទះដែលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាចំណុចកណ្ដាល។

ដៃគូជីវិតខ្លះនិយាយស្ទើរតែទាំងស្រុងអំពីបញ្ហា ឱកាស ការសម្រេចចិត្ត និងអ្វីៗជាក់ស្ដែងផ្សេងទៀតប្រឈមនឹងគ្រួសារ។ រឿងទាំងអស់នេះសុទ្ធតែ

សំខាន់។ ប្រសិនបើដៃគូជីវិតមិនមានពេលនិយាយគ្នាអំពីបញ្ហាដែលពួកគាត់ប្រឈមមុខនោះទេ នោះទំនាក់ទំនងរបស់ពួកគាត់នឹងឃ្លាតឆ្ងាយទៅៗពីគ្នាជាមិនខាន។ នៅពេលដែលគ្រួសារប្រឈមមុខដាក់បញ្ហា ត្រូវតែមានពេលញែកទុកសម្រាប់ការសន្ទនាដែលសំខាន់។ ប៉ុន្តែ គ្រួសារដែលមានសុភមង្គលមិនមានមូលដ្ឋានលើបញ្ហាដែលគ្រួសារនោះកំពុងប្រឈមមុខនោះទេ វាមានមូលដ្ឋានលើព្រះជាម្ចាស់ និងរបៀបរបស់ទ្រង់វិញ។ ដូច្នេះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវតែដើរតួយ៉ាងសំខាន់បំផុតនៅក្នុងការសន្ទនាដែលមាននៅក្នុងគ្រួសារ។ ប្រសិនបើបញ្ហាដែលគ្រួសារប្រឈមជារឿងដ៏សំខាន់បំផុត នោះនៅពេលដែលបញ្ហាទាំងនោះកើតឡើងក្នុងរបៀបមិនត្រូវ ជាលទ្ធផលគ្រួសារនឹងបាត់បង់សុវត្ថិភាព និងអំណរជាមិនខាន។

យើងអះអាងថា ព្រះជាម្ចាស់គឺជាព្រះសិរសានៅក្នុងផ្ទះរបស់យើង នៅពេលដែលយើងនិយាយអំពីអ្វីដែលយើងអាននៅក្នុងព្រះគម្ពីរ សម្រាប់ការចំណាយពេលរបស់យើងជាមួយនឹងព្រះអង្គនៅថ្ងៃនោះ ឬក៏អំពីការយល់ដឹងណាមួយដែលយើងទទួលបានពីសៀវភៅគ្រីស្ទបរិស័ទ ឬក៏សេចក្តីអធិប្បាយនៅថ្ងៃអាទិត្យ។ យើងធ្វើការនោះនៅពេលដែលយើងផ្តល់កម្រិតខ្ពស់នៃការសន្ទនាយើងអំពីបញ្ហាណាមួយនៅក្នុងការអធិស្ឋាន។ យើងធ្វើដូចនោះនៅពេលយើងឃើញអ្វីមួយនៅលើកញ្ចក់ទូរទស្សន៍ ហើយពិភាក្សាគ្នាថា តើអ្វីដែលយើងបានឃើញស្របតាមព្រះបន្ទូលរបស់ព្រះដែរឬទេ។ យើងក៏ធ្វើបែបនោះនៅពេលដែលយើងចែកចាយទីបន្ទាល់ និងអំពីព្រះពរដែលព្រះជាម្ចាស់បានប្រទានដល់យើង និងអ្នកដទៃទៀតដែរ។ មានការស្កប់ចិត្តយ៉ាងខ្លាំងក្នុងការនិយាយអំពីរឿងដែលអស់កល្បជានិច្ច ដែលមាននៅក្នុងព្រះគម្ពីរ។ វាគាំទ្រសេចក្តីពិតដែលថា ព្រះជាម្ចាស់គឺជាគ្រឹះនៃគ្រួសាររបស់យើង។

ពិតណាស់ ប្រធានបទដែលទាក់ទងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺមិនគ្រាន់តែជាចំណុចមួយដែលដៃគូជីវិតនិយាយអំពីវានោះទេ។ វាជាការសំខាន់ណាស់ក្នុងការនិយាយអំពីបញ្ហាជាក់ស្តែងទាក់ទងនឹងដំណើរការនៅ

ក្នុងគ្រួសារ។ នៅពេលដែលកូនៗនៅតូចនៅឡើយ ប្រពន្ធទំនងជាមានការពិបាកក្នុងការមើលថែកូនៗ។ ប្តីក៏បានត្រឡប់មកពីធ្វើការវិញដោយអស់កម្លាំង បន្ទាប់ពីមានបន្ទុកការងារជាច្រើននៅថ្ងៃនោះ ហើយក៏មិនមានអារម្មណ៍ក្នុងការនិយាយលេងដែរ។ ប៉ុន្តែ វាពិតជារឿងដ៏សំខាន់ណាស់ក្នុងការដែលប្រពន្ធត្រូវនិយាយអំពីបទពិសោធន៍នៃការខកចិត្តរបស់គាត់នៅក្នុងថ្ងៃនោះ។ ប្រសិនបើគាត់មិនមានឱកាសដូចនោះទេ នោះគាត់អាចនឹងបានបញ្ចប់ដោយភាពជូរចត់ជាមិនខាន។ គោលបំណងសំខាន់របស់ឪពុកម្តាយនៃការរួបរួមគ្នាអំពីរបៀបដាក់វិន័យកូនៗក៏ទទួលបានការសម្រេច តាមរយៈការនិយាយជាមួយគ្នាដែរ។

កាលកូនៗរបស់យើងរស់នៅក្នុងផ្ទះជាមួយយើង ខ្ញុំនិងប្រពន្ធបានដាក់ច្បាប់មិនឲ្យយើងបើកមើលទូរទស្សន៍នៅពេលកំពុងញ៉ាំបាយនោះទេ។ បន្ទាប់ពីពួកគាត់បានធំឡើង និងបានទៅរស់នៅខាងក្រៅ នោះយើងក៏បានសម្រេចចិត្តថា ប្រសិនបើអាច យើងនឹងបរិភោគអាហារនៅពេលគេចាក់ផ្សាយព័ត៌មានវិញ។ ខ្ញុំមានចាប់អារម្មណ៍លើរឿងរ៉ាវបច្ចុប្បន្ននេះណាស់។ ប្រពន្ធរបស់ខ្ញុំក៏ចាប់អារម្មណ៍ដែរ ប៉ុន្តែមិនចាប់អារម្មណ៍ខ្លាំងដូចខ្ញុំនោះទេ។ គាត់យល់ថា វាជាការល្អដែលយ៉ាងហោចណាស់ គាត់ដឹងឲ្យបានបន្តិចបន្តួចអំពីអ្វីដែលខ្ញុំចូលចិត្ត។ ដូច្នេះ ខ្ញុំអាចពន្យល់គាត់ពីប្រវត្តិ ឬក៏បញ្ហាផ្សេងៗទាក់ទងទៅនឹងព្រឹត្តិការណ៍ផ្សេងៗដែលបានពិពណ៌នា។ បំណងប្រាថ្នារបស់គាត់ក្នុងការនិយាយជាមួយខ្ញុំអំពីអ្វីដែលខ្ញុំចូលចិត្តគឺជាចំណុចដ៏សំខាន់មួយនៃការរួបរួមគ្នារបស់យើង។ ជាទូទៅ បន្ទាប់ពីបរិភោគអាហារពេលល្ងាចហើយ យើងលាងចានជាមួយគ្នា។ ការនេះក៏ផ្តល់ឲ្យយើងមានឱកាសសន្ទនាគ្នាលេងផងដែរ។

តាមអ្វីដែលបានរៀបរាប់ខាងលើ សេចក្តីពិតគឺថា ប្តីនិងប្រពន្ធគឺជាមិត្តដ៏ល្អ ដែលចូលចិត្តនៅជាមួយគ្នា។ យើងងាយនឹងទទួលអារម្មណ៍នៃការរំខានពីសមាជិកនៅក្នុងគ្រួសាររបស់យើង។ ពីព្រោះការជំរុញឲ្យប្រព្រឹត្ត និងបង្ហាញមិនសូវខ្លាំងប៉ុន្មាននៅក្នុងផ្ទះ នោះយើងទំនងជាងាយបញ្ចេញអារម្មណ៍រំខានរបស់យើង ហើយធ្វើឲ្យផ្ទះរបស់យើងជាកន្លែងដែលមិនមានសុភមង្គល។ ការ

មួយក្នុងចំណោមការជាច្រើនដែលព្យាបាលការមិនមានភាពអត់ធ្មត់បែបនោះ គឺការចំណាយពេលនិយាយគ្នាឲ្យបានយូរ។ ជាទូទៅ ទំនាក់ទំនងមិត្តភាពរវាងប្តី និងប្រពន្ធអាចទៅមុខបាន តាមរយៈការសម្រេចចិត្តដែលពួកគាត់ប្តេជ្ញាថានឹងខិតខំប្រឹងប្រែងក្នុងការសន្ទនាគ្នា។ នៅពេលដែលមានភាពតានតឹងកើតឡើងនៅក្នុងទំនាក់ទំនង ការសន្ទនាដែលមានរយៈពេលយូរអំពីបញ្ហានោះនឹងជួយដោះស្រាយវាបាន។

វាពិតជាគួរឲ្យស្ងើចសរសើរណាស់ដែលដៃគូជីវិតមួយចំនួនចំណាយពេលនិយាយគ្នាជាច្រើនម៉ោងមុនពេលពួកគាត់រៀបការ ប៉ុន្តែក្រោយមកក៏និយាយគ្នាតិចទៅៗ។ ពេលខ្លះ ក្នុងពេលមមាញឹករបស់យើង យើងក៏មិនយកចិត្តទុកដាក់លើការសន្ទនាគ្នាដោយមិនដឹងខ្លួន។ ប្រសិនបើការនេះកើតឡើងមែន ម្នាក់ដែលឃើញអំពីការនេះត្រូវតែប្រាប់ប្តី ឬប្រពន្ធខ្លួនអំពីការនេះឲ្យបានឆាប់តាមដែលអាចធ្វើបាន។ ពេលខ្លះ នៅពេលខ្ញុំគិតថា ខ្ញុំ និងប្រពន្ធខ្ញុំកំពុងតែមានភាពល្អប្រសើរក្នុងជីវិតបែបជាដៃគូ នោះប្រពន្ធខ្ញុំក៏សួរខ្ញុំបែបដូចនេះថា៖ “បងដឹងទេថា យើងមិនបាននិយាយគ្នាឲ្យបានយូរអស់រយៈពេលពីរសប្តាហ៍ហើយ?”។ ខ្ញុំបានរវល់ខ្លាំងរហូតដល់ខ្ញុំមិនបានដឹងថា ការមិនយកចិត្តទុកដាក់នេះមានភាពធ្ងន់ធ្ងរ ដោយសារខ្ញុំមិនអើពើ។ ខ្ញុំមានការរំជួលចិត្តក្នុងការត្រឡប់ទៅរកការពិត និងជំរុញឲ្យមានវិធានការជាបន្ទាន់ក្នុងការជួសជុលស្ថានការណ៍នេះឡើងវិញ។ នៅពេលដែលដៃគូជីវិតបានដឹងថា ពួកគាត់បានព្រងើយកន្តើយដាក់គ្នាទៅវិញទៅមក ដោយមិនបានសន្ទនាជាមួយគ្នា នោះពួកគាត់គួរតែចាត់ទុកថាជារឿងអាសន្នដែលទាមទារឲ្យមានសកម្មភាពជាបន្ទាន់ ទោះបើជាវាមានភាពមិនស្រួលក្នុងការបញ្ចេញសកម្មភាពក៏ដោយ។

ពេលខ្លះ ដៃគូជីវិតចំណាយពេលជាមួយគ្នាតិចតួចមែនទែន ពីព្រោះវាមិនអាចទៅរួចបាន ក្នុងការធ្វើដូចនោះ។ នៅពេលខ្ញុំធ្វើដំណើរឆ្លងប្រទេស ទោះបើខ្ញុំ និងប្រពន្ធខ្ញុំបានទាក់ទងគ្នាជាច្រើនដងក្នុងមួយថ្ងៃក៏ដោយ ដែលជាទូទៅតាម WhatsApp ក៏ការឃ្លាតឆ្ងាយពីគ្នាបានកើតឡើងដោយសាររូបកាយ

យើងបាននៅដាច់ឆ្ងាយពីគ្នា។ ដូច្នេះ នៅពេលខ្ញុំត្រឡប់មកផ្ទះវិញ ខ្ញុំតែងតែចំណាយពេលនៅថ្ងៃបន្ទាប់ឲ្យទំនេរ ដើម្បីឲ្យយើងអាច “ចំណាយពេលជាមួយគ្នា”។ នៅពេលដែលខ្ញុំត្រូវបំពេញអ្វីមួយនៅក្នុងថ្ងៃនោះ ខ្ញុំតែងតែដឹងថាវាមិនល្អសម្រាប់ពួកយើងនោះទេ។ ការដកឃ្លានៅក្នុងកាលវិភាគរបស់យើងសម្រាប់ឲ្យមានពេលនិយាយគ្នាគឺជាអ្វីដែលយើងត្រូវតែធ្វើឲ្យបានជាប់លាប់ និងមានការប្តេជ្ញាចិត្តខ្ពស់។

លោក អេច. ណាមែន រ៉ាយថ៍ បានធ្វើបទបង្ហាញពីការសន្ទនាដែលបានកើតឡើងនៅក្នុងជីវិតអាពាហ៍ពិពាហ៍ជាច្រើន។ គាត់បានលើកឡើងថា “ជាញឹកញាប់ មនុស្សប្រុសបានសង់អត្តសញ្ញាណរបស់គាត់តាមរយៈការរកស៊ី ឬក៏ការងាររបស់គាត់”។ លោក រ៉ាយថ៍ បានកត់ចំណាំថា ឥឡូវនេះ តួនាទីប្រពៃណីរបស់ប្តី និងប្រពន្ធមានការផ្លាស់ប្តូរ ដោយស្រីៗក៏កំពុងស្វែងរកការងារ និងមុខរបររកស៊ីរបស់គាត់ដែរ។ ប៉ុន្តែ វានៅតែជាការពិតដែលប្តីគឺជាម្នាក់ដែលរកចំណូលចម្បងនៅក្នុងជីវិតអាពាហ៍ពិពាហ៍ជាច្រើន។ ប្តីរៀបការក្នុងពេលដំណាលគ្នាដែលគាត់កំពុងព្យាយាមអភិវឌ្ឍន៍ខ្លួននៅកន្លែងធ្វើការ។ ខណៈពេលដែលប្រពន្ធរបស់គាត់កំពុងស្វែងរកភាពស្និទ្ធស្នាល ប្តីកំពុងរវល់ក្នុងការស្វែងរកអត្តសញ្ញាណរបស់ខ្លួនតាមរយៈមុខរបររបស់គាត់។ ជាលទ្ធផលការខកចិត្តកើតមាន។ លោក រ៉ាយថ៍ បានលើកឡើងថា “យើងអាចពណ៌នាថាជាអត្តសញ្ញាណទល់នឹងភាពស្និទ្ធស្នាល”! ហើយនៅពេលមានកូន ប្រពន្ធ (ដែលបានខកចិត្តដោយសារខ្វះសេចក្តីស្រឡាញ់ពីប្តី) ក៏ផ្តោតលើការបង្ហាញសេចក្តីស្រឡាញ់ទៅកាន់កូនៗរបស់គាត់វិញ។

បន្ទាប់មក ការធ្វើបទបង្ហាញនោះក៏មានការផ្លាស់ប្តូរ។ លោក រ៉ាយថ៍ បានលើកឡើងថា “ប្តីជាច្រើនរូប នៅពេលដែលគាត់មានអាយុ៤០ឆ្នាំជាង ពួកគាត់ដឹងថាខ្លួនបានដល់ចំណុចបញ្ចប់នៃខ្សែបន្ទាត់ដែលនឹងរីកចម្រើនទៅមុខទៀតនៅក្នុងការងាររបស់ខ្លួន។ មិនមានកន្លែងណាដែលពួកគាត់អាចទៅមុខបានទៀតទេ ដូច្នេះ គោលបំណងរបស់ពួកគាត់ក៏ចាប់ផ្តើមផ្លាស់ប្តូរ។ ពួកគាត់អាច

នឹងត្រឡប់ទៅឯប្រពន្ធរបស់ខ្លួនវិញដោយមានបំណងប្រាថ្នាសាងភាពជិតស្និទ្ធ»។ មកដល់ពេលនោះ ទោះបីជាយ៉ាងណាក៏ដោយ ក៏កូនៗបានធំធាត់ឡើង ហើយប្រពន្ធក៏កំពុងគិតក្នុងការស្វែងរកមុខជំនាញ និងបន្តសិក្សានៃក្តីស្រមៃរបស់គាត់វិញ។ ប្រពន្ធមានការឈឺចាប់ដោយសារការព្រងើយកន្តើយពីប្តីក្នុងអំឡុងឆ្នាំដំបូងនៃជីវិតអាពាហ៍ពិពាហ៍ដ៏សំខាន់របស់ពួកគាត់ ដូច្នេះប្រពន្ធក៏មិនបានឆ្លើយតបចំពោះបំណងប្រាថ្នារបស់ប្តីក្នុងការមានភាពស្និទ្ធស្នាល ដូចអ្វីដែលប្តីរំពឹងចង់បាននោះទេ។[៩] លទ្ធផលគឺថា ពួកគាត់នឹងមិនដែលមានបទពិសោធន៍នៃភាពស្និទ្ធស្នាលដូចដែលពួកគាត់មានបំណងប្រាថ្នាចង់បាននោះទេ។ ដៃគូជីវិតត្រូវតែមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដូចនេះ ហើយប្រុងស្មារតីក្នុងការបន្តថែរក្សាការសន្ទនាក្នុងជីវិតអាពាហ៍ពិពាហ៍។ នៅក្នុងជំពូក៤ ខ្ញុំបានលើកឡើងថា វាទំនងជាការស្លាប់មួយប្រភេទសម្រាប់ប្តីក្នុងការនិយាយជាមួយប្រពន្ធរបស់គាត់ នៅពេលដែលគាត់អស់កម្លាំង និងមិនមានអារម្មណ៍ក្នុងការនិយាយស្តីអ្វីសោះ។ ប៉ុន្តែ គាត់ស្ម័គ្រចិត្តក្នុងការឱបក្រសោប «ការស្លាប់នោះ» ដើម្បីលះបង់ខ្លួនគាត់ចោលសម្រាប់ប្រយោជន៍ដល់ប្រពន្ធរបស់គាត់ ដូចដែលព្រះគ្រីស្ទបានធ្វើក្នុងការសុគតសម្រាប់ពួកជំនុំ (អេភេសូរ ៥:២៥)។

ការសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីនិយាយគ្នានៅពេលដែលបុគ្គលម្នាក់មិនមានអារម្មណ៍និយាយដូចនោះគឺជាគន្លឹះនាំឲ្យអាពាហ៍ពិពាហ៍មានសុភមង្គល។ ប្រសិនបើមិនមានពេលរំពឹងទុកក្នុងការនិយាយគ្នាភ្លាមៗនោះទេ យើងត្រូវតែស្វែងរករបៀបណាមួយឲ្យបានឆាប់រហ័សក្នុងការនិយាយគ្នា។ យើងអាចនឹងប្រើប្រាស់ការច្នៃប្រឌិតរបស់យើងក្នុងការធ្វើរឿងនេះឡើង។ ពីរថ្ងៃមុនពេលដែលខ្ញុំសរសេរអំពីរឿងនេះ ប្រពន្ធខ្ញុំ និងខ្ញុំបានស្ទះចរាចរណ៍មួយយ៉ាងខ្លាំង។ ការធ្វើដំណើរដែលយើងរំពឹងថាចំណាយពេល២ទៅបីនាទី បានក្លាយទៅជាជិតមួយម៉ោង។ នៅចុងបញ្ចប់នៃការធ្វើដំណើររបស់យើង ខ្ញុំបានប្រាប់ប្រពន្ធរបស់ខ្ញុំថា វាជាព្រះពរដ៏អស្ចារ្យណាស់ដែលយើងមានឱកាស

និយាយគ្នាដោយគ្មានការរំខាន។

ជាទូទៅ មនុស្សយើងកំណត់ពេលវេលាក្នុងការធ្វើអ្វីដែលខ្លួនចាត់ទុកថាសំខាន់បំផុត។ ប្រសិនបើលោកអ្នកចាត់ទុកការសន្ទនាជាការជួយបន្ធូរអារម្មណ៍ថាវាចាំបាច់បំផុត នោះលោកអ្នកនឹងរករបៀបណាមួយក្នុងការធ្វើវាជាមិនខាន។ ជាច្រើនលើកច្រើនសារ នៅក្នុងចំណុចនេះ ខ្ញុំបានលើកឡើងថាយើងត្រូវតែធ្វើការសម្រេចចិត្តដោយមានមនសិការក្នុងការនិយាយគ្នា។ ការនិយាយគ្នាជាមួយប្តី ឬប្រពន្ធរបស់យើងគឺជាចំណុចគន្លឹះដ៏សំខាន់មួយក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់។ ព្រះពរនៃការសន្ទនាបែបនេះនាំឲ្យកាន់តែមានការរួបរួមគ្នាទៅវិញទៅមកទៀតបាន។

## ការរួបរួមគ្នាក្នុងព័ន្ធកិច្ចរបស់យើង

វាជារឿងដ៏សំខាន់ណាស់ ចំពោះអស់អ្នកដែលចូលរួមចំណែកក្នុងព័ន្ធកិច្ចដូចជាអ្នកស្ម័គ្រចិត្ត ឬអ្នកទទួលបានប្រាក់ខែក្តីក្នុងការនិយាយអំពីព័ន្ធកិច្ចរបស់ខ្លួនជាមួយប្តី ឬប្រពន្ធ។ អ្នកដែលមិនទាន់រៀបការ ហើយមានបំណងចង់ធ្វើព័ន្ធកិច្ចគួរតែមានការប្រុងប្រយ័ត្នក្នុងការជ្រើសរើសប្តី ឬប្រពន្ធរបស់ខ្លួនដែលមិនមានបំណងប្រាថ្នាដូចគ្នា។ នៅក្នុងពេលកំពុងពេញស្រឡាញ់គ្នា ម្នាក់អាចគិតថាម្នាក់ទៀតនឹងលូតលាស់ក្នុងការមានចំណាប់អារម្មណ៍ធ្វើព័ន្ធកិច្ច។ មានពេលជាច្រើនដងហើយដែលមានការនេះបានកើតឡើង ប៉ុន្តែយើងមិនអាចប្រាកដថា វានឹងកើតមានឡើងនោះទេ។ មនុស្សម្នាក់ដែលគិតអំពីការបម្រើព្រះពេញម៉ោងគួរតែមានភាពច្បាស់លាស់ថា ម្នាក់ដែលគាត់កំពុងសង្ឃឹមនឹងរៀបការជាមួយក៏គួរយល់ឲ្យច្បាស់ពីការព្រមព្រៀងគ្នានៃការត្រាស់ហៅឲ្យធ្វើជាដៃគូជីវិតរបស់អ្នកធ្វើព័ន្ធកិច្ចពេញម៉ោងនោះសិន។

ដោយសារការបម្រើព័ន្ធកិច្ចត្រូវការពេលវេលាច្រើន នោះគ្រួសារត្រូវមានការលះបង់ខ្លាំងនៅពេលដែលមានសមាជិកណាម្នាក់ចូលរួមក្នុងការធ្វើព័ន្ធកិច្ច។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងគ្រួសារមិនបានដឹងថាបុគ្គលដែល

កំពុងធ្វើព័ន្ធកិច្ចនោះធ្វើអ្វីខ្លះទេ គាត់ពិតជាងាយនឹងថ្នាំងថ្នាក់ចិត្តចំពោះព័ន្ធកិច្ចនោះជាមិនខាន។ ការនេះក៏អាចកើតឡើងបានសូម្បីតែចំពោះប្តី ឬប្រពន្ធដែលមានការប្តេជ្ញាចិត្តខ្ពស់ចំពោះព័ន្ធកិច្ចដែរ។ ប៉ុន្តែ ក៏នៅមានការមួយចំនួនដែលយើងមិនអាចចែករំលែកជាមួយនឹងសមាជិកគ្រួសារយើងបានដែរ ដូចជាព័ត៌មានលម្អិតទាក់ទងជាមួយបញ្ហាផ្នែកផ្លូវភេទរបស់អ្នក ដែលយើងកំពុងប្រឹក្សាជួបប្រទះ ដែលយើងបានពិភាក្សាជាមួយ។ ប៉ុន្តែ គ្រួសារយើងត្រូវតែដឹងពីការដែលយើងធ្វើ ហើយថាការទាំងនោះសំខាន់ខ្លាំងប៉ុណ្ណា។

យើងត្រូវតែប្រាកដថា យើងនិយាយអំពីកាលវិភាគរបស់យើងជាមួយប្តី ឬប្រពន្ធរបស់យើង។ នេះគឺជាចំណុចមួយដែលខ្ញុំបានបរាជ័យក្នុងការធ្វើវាជាញឹកញាប់។ ប្រពន្ធខ្ញុំ និងខ្ញុំមានទម្លាប់មួយក្នុងការមើលសៀវភៅកំណត់ហេតុនៃការណាត់ជួបយ៉ាងទៀងទាត់ ដើម្បីឲ្យគាត់អាចកត់ទុកនូវការណាត់ជួបសំខាន់ៗរបស់ខ្ញុំនៅក្នុងសៀវភៅកំណត់ហេតុរបស់គាត់ដែរ។ ប៉ុន្តែ មានពេលជាច្រើនដងដែលការនេះមិនបានកើតឡើង។ ហើយជាលទ្ធផល មានពេលខ្លះដែលគាត់មិនបានដឹងអំពីការសំខាន់ កម្មវិធីដែលខ្ញុំត្រូវចំណាយពេលយូរក្នុងការចូលរួម។ នៅពេលដែលគាត់បានឃើញ គាត់មានការភ្ញាក់ផ្អើលមែន ហើយគាត់បានដឹងថា គាត់ក៏ត្រូវធ្វើការកែតម្រូវជាច្រើន ដើម្បីសម្របតាមកាលវិភាគរបស់ខ្ញុំវិញ។ ប៉ុន្តែក៏ដោយសារតែសេចក្តីមេត្តាករុណារបស់ព្រះអង្គ នោះទ្រង់ក៏ជួយយើងដោះស្រាយបញ្ហាទាំងនោះ ទោះបីជាខ្ញុំបានប្រព្រឹត្តដោយមិនសមរម្យក៏ដោយ!

ម្តាយជាច្រើននាក់ក៏អាចបាត់បង់សេចក្តីស្រឡាញ់របស់ខ្លួនក្នុងការបម្រើអំឡុងពេលដែលពួកគាត់មានបញ្ហាខកចិត្តជាច្រើនឆ្នាំក្នុងការចិញ្ចឹមកូនតូចៗរបស់ខ្លួន។ ជារឿយៗ ស្ត្រីដែលបម្រើនៅក្នុងព័ន្ធកិច្ចមានអំណរក្នុងការបម្រើមុនពេលដែលពួកគេមានកូន។ នៅពេលមានកូនតូចកើតមក ប្រពន្ធអាចនឹងមានអារម្មណ៍ថាជាប់ឃុំឃាំង ហើយគាត់ក៏អាចនឹងនឹកព័ន្ធកិច្ចយ៉ាងខ្លាំងដែរ។ ប្តីត្រូវតែបន្តប្រាប់ប្រពន្ធរបស់ខ្លួនអំពីអ្វីដែលកំពុងកើតឡើង ហើយអធិស្ឋានជា

មួយគាត់អំពីការទាំងនោះ។ ក្នុងរបៀបនេះ គាត់នឹងមិនមានអារម្មណ៍ឃ្លាតឆ្ងាយពីព័ន្ធកិច្ច។

ដៃគូជីវិតក៏អាចស្វែងរករបៀបមួយចំនួន ដើម្បីឲ្យប្រពន្ធខ្លួនអាចមានចំណែកនៅក្នុងការបម្រើព្រះដោយធ្វើការនៅផ្ទះផងដែរ។ កាលកូនៗរបស់យើងនៅតូចនៅឡើយ យើងមានស្ត្រីវ័យក្មេងមួយចំនួនដែលបានស្នាក់នៅជាមួយយើងក្នុងរយៈពេលខ្លី។ ស្ត្រីដែលរស់នៅម្នាក់ឯងទំនងជាស្ទើរតែមានជំងឺសរសៃប្រសាទ ប៉ុន្តែគាត់អាចទទួលបានសុខភាពល្អឡើងវិញក្នុងស្ថានភាពនៅផ្ទះជាមួយអ្នកដែលមើលថែយកចិត្តទុកដាក់លើគាត់។ ស្ត្រីដែលមិនមានកន្លែងស្នាក់នៅអាចស្នាក់នៅក្នុងផ្ទះណាមួយ ក្នុងរយៈពេលខ្លីរហូតទាល់តែគាត់បានដោះស្រាយបញ្ហាសិន។ យុវជនដែលត្រូវបានឪពុកធ្លាប់ធ្វើបាបអាចស្វែងរកកន្លែងសុវត្ថិភាពនៅក្នុងផ្ទះរបស់គ្រីស្ទបរិស័ទណាម្នាក់ រហូតទាល់តែមានការរៀបចំជាអចិន្ត្រៃយ៍បានកើតឡើង។បន្ទាប់ពីមានកុប្បកម្មនៃជនជាតិភាគតិចដ៏ធំមួយបានកើតឡើងនៅក្នុងប្រទេសស្រីលង្កា យើងបានបើកផ្ទះយើងទទួលស្វាគមន៍ដល់មនុស្សពីជាតិសាសន៍ផ្សេងៗគ្នាអស់រយៈពេលជាង៦ខែ ពីព្រោះផ្ទះរបស់ពួកគាត់ត្រូវបានដុតបំផ្លាញចោល។ ក្នុងអំឡុងពេលនោះ កូនប្រុសរបស់យើងក៏បានកើតផងដែរ ហើយកូនស្រីរបស់យើងទើបមានអាយុ៣ឆ្នាំ។ ប៉ុន្តែ យើងចងចាំពេលវេលានៃខែដ៏រវល់ទាំងនោះថាជាពេលវេលាដ៏សប្បាយ និងពោរពេញហូរហៀរណាស់។

ការអញ្ជើញគ្នាមកបរិភោគអាហារជាមួយគ្នាក៏ជួយរក្សាស្មារតីនៃការបម្រើនៅក្នុងផ្ទះបានផងដែរ។ លោកអ្នកមិនចាំបាច់ចំណាយពេលយូរ ក្នុងការរៀបចំអាហារយ៉ាងធំដុំនោះទេ។ ការនោះអាចជាបន្ទុកទៅវិញទេ។ គោលបំណងចម្បងនៃហេតុផលដែលយើងអញ្ជើញអ្នកដទៃ ព្រោះការប្រកបគ្នា មិនមែនផ្តោតលើម្ហូបអាហារនោះទេ។ ការផ្តោតខ្លាំងពេកទៅលើការរៀបចំផ្ទះឲ្យមើលទៅល្អឥតខ្ចោះ និងការចម្អិនម្ហូបឆ្ងាញ់ៗអាចក្លាយជាបន្ទុកទៅលើប្រពន្ធដែលជាម្តាយមានកូនតូចៗទៅវិញទេ។ ប៉ុន្តែ ទង្វើនៃការចម្អិនម្ហូប និងការប្រកបគ្នា

ដែលជាប្រយោជន៍សម្រាប់អ្នកខាងក្រៅក៏ជួយរក្សាឲ្យព័ន្ធកិច្ចមានដំណើរការទៅមុខទៀតបាន។

ប្រសិនបើរសជាតិនៃការបម្រើព័ន្ធកិច្ចនៅតែមាន តាមរយៈការចូលរួមតិចតួច នៅពេលដែលប្រពន្ធមានកូនតូចៗ នោះគាត់អាចត្រឡប់ទៅក្នុងជីវិតបម្រើព័ន្ធកិច្ចនៅខាងក្រៅវិញបាន នៅពេលដែលកូនៗបានធំឡើង។ ប៉ុន្តែ ជារឿងគួរឲ្យសោកស្តាយណាស់ដែលប្រពន្ធមួយចំនួនបានបាត់បង់រសជាតិនៃការមានអំណរក្នុងការបម្រើព័ន្ធកិច្ច ហើយទោះបើពួកគាត់ទំនេរក៏ដោយ ក៏ពួកគាត់មិនចូលរួមនៅក្នុងព័ន្ធកិច្ចទៀតដែរ។ ការនេះបានក្លាយជាប្រភពនៃការមិនរួបរួមគ្នា ប្រសិនបើប្តីនៅមានការរួមចំណែកបម្រើ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការបម្រើនៅក្នុងអំឡុងពេលលំបាកៗអាចធ្វើបានដោយលើសកំណត់ដែរ។ នៅពេលយើងត្រឡប់មើលក្រោយវិញ យើងឃើញថាកិច្ចការមួយចំនួនដែលយើងបានធ្វើ នៅពេលដែលកូនៗយើងនៅតូចៗអាចនាំឲ្យមានការលំបាកសម្រាប់ប្រពន្ធរបស់ខ្ញុំ។ អរគុណព្រះអង្គដែលគាត់បានឆ្លងកាត់ការទាំងនោះដោយមិនមានស្នាមរបួសធ្ងន់ធ្ងរខ្លាំងប៉ុន្មានដែរ។

វាជារឿងសំខាន់ណាស់ដែលយើងមិនត្រូវចាត់ទុកប្តី ឬប្រពន្ធរបស់យើងដោយមានផ្នត់គំនិតរួម ហើយរំពឹងឲ្យពួកគាត់ធ្វើតាមគំរូដែលមិនស័ក្តិសមសម្រាប់ពួកគាត់។ ប្រពន្ធរបស់ស្ថាបនិកនៃអង្គការយុវជនសម្រាប់ព្រះគ្រីស្ទដែលខ្ញុំបានបន្តតំណែងដឹកនាំ គាត់មានភាពសកម្មយ៉ាងខ្លាំងនៅក្នុងព័ន្ធកិច្ច ហើយគាត់ក៏ជាអ្នកបម្រើដែលមានភាពស្វាហាប់ និងអ្នកបម្រើព្រះគ្រីស្ទដែលគេស្រឡាញ់ផងដែរ។ ចរិតលក្ខណៈ និងអំណោយទានរបស់ប្រពន្ធខ្ញុំគឺមានភាពខុសគ្នាយ៉ាងខ្លាំង។ នៅពេលដែលយើងបានរៀបការហើយ ខ្ញុំបានដឹងថា មនុស្សជាច្រើនបានរំពឹងឲ្យប្រពន្ធខ្ញុំទៅចូលរួមគ្រប់ការប្រជុំជាសាធារណៈទាំងអស់ ដែលវាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការចូលរួម។ ប៉ុន្តែ ប្រពន្ធខ្ញុំមិនមានទំនោរចិត្តបែបហ្នឹងនោះទេ។ ព្រះជាម្ចាស់បានប្រទានអំណោយទានពិសេសផ្ទាល់ខ្លួននៅក្នុងព័ន្ធកិច្ចដល់គាត់ ហើយការងារជាច្រើនក្នុងព័ន្ធកិច្ចនោះគឺ

នៅក្នុងក្រុមជំនុំរបស់យើង។ ដូច្នេះ គាត់មិនមែនជាប្រពន្ធធម្មតារបស់អ្នកដឹកនាំអង្គការយុវជនសម្រាប់ព្រះគ្រីស្ទនោះទេ។ ប៉ុន្តែ យើងអនុញ្ញាតឲ្យគាត់ផ្តល់អាទិភាពទៅលើអ្វីដែលជាអំណោយទានរបស់គាត់។ មិនយូរប៉ុន្មាន វាក៏បានក្លាយជាភ័ស្តុតាងទៅកាន់គ្រប់គ្នាថា ប្រសិនបើខ្ញុំមានឥទ្ធិពលណាមួយក្នុងភាពជាអ្នកដឹកនាំរបស់ខ្ញុំ នោះប្រពន្ធរបស់ខ្ញុំក៏មានចំណែកយ៉ាងធំនៅក្នុងនោះដែរ។ សមាគមអង្គការយុវជនសម្រាប់ព្រះគ្រីស្ទបានឲ្យគាត់មានសេរីភាពក្នុងការដើរតាមផ្លូវដែលព្រះជាម្ចាស់បានជ្រើសរើសសម្រាប់គាត់។

គ្រីស្ទបរិស័ទចូលចិត្តរិះគន់ប្តី ឬក៏ប្រពន្ធរបស់អ្នកដឹកនាំណាស់ ជាពិសេសប្រពន្ធរបស់គ្រូគង្វាល។ ពួកគេប្រៀបធៀបគាត់ជាមួយប្តី ឬប្រពន្ធអ្នកដទៃ ហើយសន្និដ្ឋានថាពួកគាត់ខ្វះមិនដល់ស្តង់ដារដែលគេបានរំពឹងទុក។ នេះជារឿងគួរឲ្យសោកស្តាយណាស់ នៅក្នុងក្រុមជំនុំទាំងអស់ សុទ្ធតែមានអ្នកដែលមិនមានសន្តិភាព និងមនុស្សមិនសប្បាយចិត្តដែលស្វែងរកការបំពេញចន្លោះប្រហោងខ្លួនឯង តាមរយៈការរិះគន់អ្នកដទៃ។ យើងមិនត្រូវអនុញ្ញាតឲ្យមនុស្សដែលមិនកោតខ្លាចព្រះជាម្ចាស់ដូចនោះមកគ្រប់គ្រងលើជីវិតយើងឡើយ។ យើងត្រូវតែការពារប្តី ឬប្រពន្ធរបស់យើងពីមនុស្សទាំងនោះ ហើយមិនត្រូវបន្ថែមការឈឺចាប់ដោយផ្តល់ជាទម្ងន់នៃការរិះគន់ទាំងនេះច្រើនជាងអ្វីដែលគាត់សមនឹងទទួលបាននោះទេ។ ពេលខ្លះ គេបានរិះគន់ប្រពន្ធដោយគ្រាន់តែមើលថាផ្ទះរបស់គាត់រញ៉េរញ៉ៃប៉ុណ្ណោះ។ រឿងដែលអាក្រក់បំផុតគឺនៅពេលដែលម្តាយក្មេកគាត់រិះគន់អំពីការនេះ។ គាត់បានព្យាយាមយ៉ាងត្រដាបត្រដួសក្នុងការចិញ្ចឹមកូនៗរបស់គាត់ ហើយពេលខ្លះគាត់ក៏ត្រូវបង្ខំខ្លួនក្នុងការមិនយកចិត្តទុកដាក់ផ្នែករៀបចំផ្ទះខ្លះ។ ប្តីរបស់គាត់មិនអាចហាមគេមិនឲ្យរិះគន់គាត់បែបនេះបាននោះទេ ប៉ុន្តែគាត់អាចជួយបន្ថយការឈឺចាប់នោះ តាមរយៈការលើកទឹកចិត្ត និងបដិសេធមិនចូលរួមរិះគន់បែបនោះដែរ។ ប្តីអាចនឹងមានការល្បួងក្នុងការជេរ ស្តីបន្ទោសដល់ប្រពន្ធដោយសារគាត់មានសេចក្តីអៀនខ្មាសចំពោះការរិះគន់ទាំងនោះ ប៉ុន្តែគាត់មិនត្រូវចុះចូលចំពោះការល្បួងមួយនោះទេ។

## សេចក្តីសន្និដ្ឋាន

យើងឃើញថា ការរក្សាការរួបរួមគ្នាតម្រូវឲ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីប្តី និងប្រពន្ធ។ ការនេះស្របតាមការបង្រៀនរបស់សាវ័ក ប៉ុល អំពីការរួបរួមគ្នានៅក្នុងក្រុមជំនុំ។ គាត់ដាស់តឿនគ្រីស្ទបរិស័ទឲ្យ «ខំប្រឹងរក្សាសេចក្តីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្តីមេត្រី ទុកជាចំណងផង» (អេភេសូរ ៤:៣)។យើងមិនមែនជាអ្នកបង្កើតការរួបរួមគ្នានេះទេ។ វាជា «ការរួបរួមរបស់ព្រះវិញ្ញាណ»។ ប៉ុន្តែ យើងអាចធ្វើឲ្យវាខូច និងមានភាពរញ៉េរញ៉ៃបាន។ ដូច្នេះ សាវ័ក ប៉ុល បានប្រាប់ឲ្យយើង «រក្សា» ការនេះ។ ការនេះតម្រូវឲ្យយើងមានសកម្មភាពភ្លាមៗ ជាបន្ទាន់។កិរិយាសព្ទដែលគេបានបកប្រែថាជាការ «ខំប្រឹងរក្សា» («ស្ពូដាហ្សូ» spoudazō) នៅពេលដែលប្រើប្រាស់ដូចនៅត្រង់នេះ (ដោយមានកិរិយាសព្ទដើមបន្ទាប់) មានអត្ថន័យថា «ការកាន់តែមានសម្បជញ្ញៈក្នុងការរំដោះកាតព្វកិច្ច មានភាពឆេះឈ្នួល/ខំប្រឹងរក្សា ទទួលយកការឈឺចាប់ ខិតខំក្នុងគ្រប់ជំពូក គ្មានចេតនា»។[៥] ទាំងអស់នេះចង្អុលបង្ហាញទៅកាន់ភាពបន្ទាន់ដែលយើងត្រូវស្តាប់តាមការត្រាស់ហៅហើយមានភាពរួបរួមគ្នានៅក្នុងក្រុមជំនុំ ដែលជាការអនុវត្តន៍ក្នុងគ្រួសារ។

៩

# ការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នា

នៅក្នុងជំពូកមុននេះ យើងបាននិយាយអំពីភាពបន្ទាន់នៃការរក្សាការរួបរួមគ្នានៅក្នុងគ្រួសារ។ ប៉ុន្តែ គ្រួសារដែលមានសុភមង្គលភាគច្រើនមានពេលវេលាដោះស្រាយ នៅពេលមានការខុសគ្នាកើតឡើង នៅពេលមានការរួបរួមគ្នាក៏មានការបែកបាក់ ហើយនៅពេលមានជម្លោះកើតមានឡើងដែរ។ ខ្ញុំធ្លាប់បានឮដៃគូជីវិតមួយចំនួននិយាយថា ពួកគាត់មិនដែលឈ្លោះគ្នាទាល់តែសោះក្នុងរយៈពេលប៉ុន្មានឆ្នាំដែលពួកគាត់បានរៀបការជាមួយគ្នា។ ខ្ញុំមិនចង់មិនជឿលើអ្វីដែលពួកគាត់និយាយនោះទេ ប៉ុន្តែប្រសិនបើអ្វីដែលពួកគាត់និយាយគឺជាការពិតមែន នោះជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់គឺជាករណីលើកលែងដ៏កម្រ មិនមែនជាអ្វីដែលធម្មតានោះទេ។ បទពិសោធន៍នៃការមានជម្លោះរវាងប្ដី ឬប្រពន្ធភាគច្រើនគឺជាជម្លោះដែលយើងហៅថា «ការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នា»។[១] នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៤:២៥-២៧ សាវ័ក ប៉ុល បានផ្ដល់ច្បាប់សំខាន់ៗមួយចំនួនសម្រាប់ការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នា ហើយយើងនឹងមើលតាមការណែនាំដែលគាត់បានផ្ដល់ឲ្យនៅទីនេះ។

## ច្បាប់ទី១៖ និយាយតែការពិត

ច្បាប់ទីមួយសម្រាប់ការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នាគឺ «និយាយតែការពិត»។ សាវ័ក ប៉ុល បានលើកឡើងថា «ដូច្នេះ ដែលបានដោះសេចក្តីកំភូតចេញហើយ នោះត្រូវឲ្យនិយាយសេចក្តីពិត នឹងអ្នកជិតខាងរៀងខ្លួនវិញ ដ្បិតយើងរាល់គ្នាជាអវយវៈផងគ្នាទៅវិញទៅមក» (អេភេសូរ ៤:២៥)។ លទ្ធផលនៃការក្លាយជាសមាជិកក្នុងរូបកាយតែមួយគឺថា យើងមិនអាចកុហកគ្នាបានឡើយ។ បញ្ហា ការមិនស្របគំនិតគ្នា និងការរំខាននឹងមានក្នុងគ្រួសារជាមិនខាន។ យើងនឹងមានសេចក្តីល្បួងដែលនាំឲ្យកុហក ដើម្បីគេចផុតពីការប្រឈមមុខគ្នា ដែលនាំមិនឲ្យសប្បាយចិត្ត។ ប៉ុន្តែ ខណៈពេលយើងពន្យារពេលក្នុងការគេចចេញពីការប្រឈមមុខដាក់គ្នា ដែលនាំមិនឲ្យសប្បាយចិត្តការសម្តែងដូចជាមិនល្អទេសម្រាប់ជីវិតអាពាហ៍ពិពាហ៍។ វាបង្កើតឲ្យមានរនាំងដែលឃាំងមិនឲ្យមានការរួបរួមគ្នាយ៉ាងពេញលេញរវាងប្តី និងប្រពន្ធ។ ជាទូទៅ ស្នាមរបួសដែលមិនបានព្យាបាលនឹងបើកឲ្យមានការប្រឈមមុខដាក់គ្នា ដែលមិនសប្បាយចិត្តខ្លាំងជាងពេលដែលយើងអនុញ្ញាតឲ្យវាកើតឡើងចំពេលដែលវាបម្រុងនឹងកើតឡើងតាំងពីដើមទៀត។

សព្វថ្ងៃនេះ ការកុហកគឺជាផ្នែកមួយនៃវប្បធម៌ជាច្រើន ហើយមនុស្សគិតថាការកុហកមិនមែនជារឿងខុសឆ្គងទេ។ ពេលខ្លះ គេទទួលយកការបដិសេធថា មិនបានធ្វើខុស ប្រសិនបើការនោះបញ្ចៀសមិនឲ្យមានភាពអាម៉ាស់ចូលមកក្នុងគ្រួសារ ឬក៏ចំពោះអ្នកធ្វើខុសនោះ។ តាមពិតទៅ អ្នកខ្លះគិតថា ការសារភាពចំពោះការដែលយើងបានធ្វើខុស និងការប្រឈមមុខដាក់សេចក្តីខ្មាសអៀនចំពោះទង្វើនោះ គឺមានកំហុសខ្លាំងជាងការធ្វើខុសទៅទៀត។ ទោះជាយ៉ាងណាក៏ដោយ ជាលទ្ធផលក្នុងការកុហកម្តងហើយម្តងទៀត ក៏គ្រួសារស៊ាំនឹងការរស់នៅជាមួយបញ្ហាដែលមិនអាចដោះស្រាយបាន។ ពេលខ្លះ គ្រប់គ្នាដឹងហើយថា ឪពុកបានធ្វើអ្វីមួយខុស ប៉ុន្តែគ្រប់គ្នាធ្វើពុតជាមិនបានដឹងទៅវិញ។ ការធូរស្បើយដ៏អស្ចារ្យនឹងកើតមានដល់គ្រួសារ នៅពេលដែលពពក

យ៉ាងក្រាស់នៃការធ្វើពុតនោះបានដោះស្រាយរួចរាល់ ដោយអ្នកដែលធ្វើខុសបានទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបានធ្វើ។

ខ្ញុំធ្លាប់បានឃើញស្ថានភាពដែលប្រពន្ធបដិសេធមិនទទួលស្គាល់ថា ប្តីរបស់គាត់កំពុងមានទំនាក់ទំនងស្នេហាលួចលាក់ ទោះបើស្ទើរតែគ្រប់គ្នាដឹងអំពីអ្វីដែលកំពុងតែកើតឡើងក៏ដោយ។ ប្រពន្ធបានការពារប្តីយ៉ាងក្លាហាននៅកន្លែងសាធារណៈ ហើយបះបោរប្រឆាំងគ្រប់សកម្មភាពណែនាំដែលក្រុមជំនុំមានសម្រាប់ប្តីគាត់ដែរ។ ខណៈពេលដែលភាពស្មោះត្រង់របស់គាត់ចំពោះប្តីគួរឲ្យស្ញើចសរសើរ ក៏វាមិនបាន ឈរលើសេចក្តីពិតដែរ។ យើងមិនពិតជាអាចមានសេចក្តីសង្ឃឹមក្នុងការមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅក្នុងជីវិតអាពាហ៍ពិពាហ៍ដូចនេះបានឡើយ។ ការសារភាពរបស់ប្តីថា មានទំនាក់ទំនងជាមួយអ្នកផ្សេងអាចនាំឲ្យមានការឈឺចាប់យ៉ាងខ្លាំងនៅពេលដំបូង។ ប៉ុន្តែ ព្រះគុណរបស់ព្រះជាម្ចាស់ក៏ធំជាងអំពើបាបដ៏ធំបំផុតដែរ។ ប្រសិនបើយើងប្រើប្រាស់ព្រះគុណដោយមនសិការចំពោះស្ថានភាពដូចនោះ នោះយើងអាចបង្កើតឲ្យមានការរួបរួមគ្នាយ៉ាងជ្រាលជ្រៅបាន តាមរយៈទុក្ខលំបាកនេះផងដែរ។

ពេលខ្លះ មនុស្សមួយចំនួនប្រើប្រាស់យុទ្ធសាស្ត្រពោរពេញដោយការបោកប្រាស់ ក្នុងការបញ្ចុះបញ្ចូលប្តី ឬប្រពន្ធខ្លួនឲ្យឯកភាពជាមួយនឹងអ្វីដែលពួកគាត់កំពុងស្ទាក់ស្ទើរក្នុងការទទួលយក។ យើងឃើញបញ្ហាបែបនេះគ្រប់ពេលនៅក្នុងរឿងភាគក្នុងទូរទស្សន៍។ ខ្ញុំបាននិយាយអំពីការនេះនៅក្នុងជំពូកមុនដែលបានលើកឧទាហរណ៍អំពីប្រពន្ធម្នាក់ដែលឈប់លេបថ្នាំពន្យារកំណើតដោយមិនបានប្រាប់ប្តីខ្លួន ដោយប្តីគាត់មិនចង់មានកូននៅឡើយ ក្នុងពេលនោះ។

ការរក្សាសន្តិភាពខាងក្រៅដោយបដិសេធមិនប្រឈមមុខនឹងបញ្ហា ឬក៏ទទួលបាននូវអ្វីដែលខ្លួនចង់បានដោយប្រើល្បិចគឺជាការជះឥទ្ធិពលអវិជ្ជមានដល់ការរួបរួមគ្នា។ នៅពេលការនេះកើតឡើង គ្រួសារនឹងបាត់បង់សេរីភាព និងអំណរដែលកើតចេញពីទំនាក់ទំនងដែលមានការបើកចំហ និងទុកចិត្តដែល

សមាជិក “មានគំនិត មានសេចក្តីស្រឡាញ់តែមួយ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវមួយដូចគ្នា” (ភីលីព ២:២)។ លោកអ្នកមិនអាចមានគំនិតតែមួយបានទេ ប្រសិនបើលោកអ្នកមិនឈរលើសេចក្តីពិត។

## ច្បាប់ទី២៖ ចូរខឹងចុះ តែកុំប្រព្រឹត្តអំពើបាប

ជាបន្ទាប់សាវ័ក ប៉ុល បានលើកឡើងថា “ចូរខឹងចុះ តែកុំឲ្យធ្វើបាបឡើយ” (អេភេសូរ ៤:២៦ក)។ នៅពេលនរណាម្នាក់ដែលយើងស្រឡាញ់យ៉ាងខ្លាំងបានធ្វើខុស ឬធ្វើឲ្យយើងឈឺចាប់ ជាទូទៅការឆ្លើយតបរបស់យើងគឺការខឹងសម្បារ។ ពេលខ្លះ គេហៅថាជាកំហឹងសុចរិត។ មានពេលមួយ បន្ទាប់ពីខ្ញុំបានបញ្ចប់សេចក្តីអធិប្បាយអំពីកំហឹង មានម្នាក់បានជំទាស់នឹងខ្ញុំដោយបានលើកឡើងថា ឃ្លា “កំហឹងសុចរិត” មិនមាននៅក្នុងព្រះគម្ពីរនោះទេ។ ទោះបីជាដែលឃ្លាចំៗបែបនេះមិនមាននៅក្នុងព្រះគម្ពីរមែន ក៏ប៉ុន្តែគោលគំនិតគឺពិតជាមានមែនហើយ។ ព្រះគម្ពីរបានបង្ហាញថាព្រះជាម្ចាស់បានខ្ញាល់ចំពោះអំពើបាបនៃរាស្ត្ររបស់ទ្រង់។ ព្រះយេស៊ូវបានខ្ញាល់ចំពោះការមានពុតរបស់ពួកអាចារ្យ និងពួកផារិស៊ី។ សាវ័ក ប៉ុល បានពុះកញ្ជ្រោលពេញដោយកំហឹងក្នុងការដែលសាវ័ក ពេត្រុស និងលោក បាណាបាស បានបោះបង់ ដោយទៅឯខាងពិធីកាត់ស្បែកនៅក្រុមជំនុំកាឡាទីវិញ (កាឡាទី ២:១១-១៤)។ ប៉ុន្តែ សាវ័ក ប៉ុល ក៏បានលើកឡើងផងដែរថា យើងមិនត្រូវធ្វើបាបនៅពេលយើងខឹងនោះទេ។

ឥឡូវ ចូរយើងមើលឧទាហរណ៍មួយចំនួនអំពីរបៀបដែលយើងធ្វើបាប នៅពេលយើងមានកំហឹងអំឡុងពេលយើងឈ្លោះគ្នាដោយមានសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ។ នៅពេលយើងខឹង យើងអាចបាត់បង់ការគ្រប់គ្រងខ្លួនឯងហើយនិយាយអ្វីដែលយើងមិនគួរនិយាយ។ ដូច្នេះ វាជាការល្អបំផុតដែលយើងស្ងៀមស្ងាត់។ ខ្ញុំនិយាយលេងជាមួយប្រពន្ធរបស់ខ្ញុំថា បងពិតជាសប្បាយចិត្តណាស់ដែលព្រះជាម្ចាស់បានប្រទានឲ្យយើងមានធ្មេញ ពីព្រោះនៅពេលបង

ខឹង បងអាចនិយាយពាក្យពេចន៍មួយចំនួនដែលធ្វើឲ្យគាត់មានការឈឺចាប់ តែផ្ទុយពីការនោះ បងអាចទៅក្នុងបន្ទប់ហើយសង្កៀតធ្មេញបងជំនួសវិញ (ខ្ញុំមិនដឹងថា ខ្ញុំនឹងធ្វើអ្វីនៅពេលដែលខ្ញុំចាស់ទៅ ហើយអស់ធ្មេញនោះទេ!)។ ពាក្យសម្តីដែលមានពេញដោយការឈឺចាប់អាចមានឫសគល់យ៉ាងជ្រៅទៅក្នុងដួងចិត្តរបស់មនុស្ស ហើយអាចបន្តប៉ះពាល់ដល់គាត់ជាច្រើនឆ្នាំទៀតផង ទោះបីជាបន្ទាប់ពីមានការសូមអភ័យទោសហើយក៏ដោយ។ នៅពេលយើងនិយាយអ្វីមួយដោយកំហឹង នៅក្នុងដួងចិត្តរបស់យើង យើងមិនបានមានន័យដូចអ្វីដែលមាត់យើងបាននិយាយនោះទេ ប៉ុន្តែពាក្យពេចន៍ទាំងនោះបានចេញមក ហើយដូចដែលលោក យ៉ាកុប បានលើកឡើង ភ្លើងតែបន្តិចទេ អាចនឹងឆេះព្រៃធំៗបាន (យ៉ាកុប ៣:៥)។

យើងធ្វើបាបនៅពេលយើងរើកកាយរឿងចាស់ៗរបស់យើងកាលពីអតីតកាល ដែលបានអត់ទោសឲ្យហើយ ក្រោយពេលដែលយើងបានបំភ្លេចវាហើយ។ ដោយពណ៌នាអំពីព្រះពរនៃការតាំងសញ្ញាថ្មី ព្រះជាម្ចាស់បានមានបន្ទូលថា «ព្រោះអញនឹងអត់ទោសចំពោះអំពើទុច្ចរិតរបស់គេ ហើយនឹងលែងនឹកចាំពីអំពើបាបគេទៀតជាដរាបទៅ» (យេរេមា ៣១:៣៤)។ ទោះបើជាដែលព្រះជាម្ចាស់អាចនឹងលែងនឹកចាំពីអំពើបាបទៀតបាន យើងទំនងជាមិនអាចលុបចោលរាល់ការដែលគេបានធ្វើខុសឆ្គងមកលើយើងចេញពីគំនិតរបស់យើងបានទាំងស្រុងនោះទេ។ ប៉ុន្តែ យើងអាចប្រព្រឹត្តដូចជាមិនដែលមានអំពើបាបនោះកើតឡើងបាន។ នេះគឺជាការអនុវត្តមួយដែលសាវ័ក ប៉ុល បានលើកឡើងថា សេចក្តីស្រឡាញ់ «មិនប្រកាន់ទោស» (១កូរិនថូស ១៣:៥)។ ជាញឹកញាប់ កិរិយាសព្ទដែលគេបានប្រើនៅទីនេះ «ឡូហ្គីហ្សូម៉ៃ» (logizomai) ឃើញមានប្រើនៅក្នុងបរិបទនៃផ្នែកគណនេយ្យហិរញ្ញវត្ថុ។ ដូចដែលអ្នកកាន់បញ្ជីព្យាយាមរក្សាវិក្កយបត្រ ដើម្បីរក្សាទុកជាភ័ស្តុតាងសម្រាប់ពេលក្រោយ យើងក៏អាចធ្វើដូចនោះសម្រាប់ទង្វើដែលបានធ្វើខុសមកលើយើងផងដែរ។ សេចក្តីស្រឡាញ់បដិសេធមិនធ្វើដូចនោះទេ។ នៅពេលយើងរម្លឹកអំពើបាប

ពីអតីតកាល យើងនាំឲ្យមានភាពស្មុគស្មាញក្នុងការតយុទ្ធ ហើយក៏ព្យាយាម កេងចំណេញដោយអយុត្តិធម៌ដែលអាចជួយយើងឲ្យបានឈ្នះលើការប្រកែក គ្នានោះបាន ប៉ុន្តែបានបាត់បង់ការរួបរួមគ្នាជាមួយប្ដី ឬប្រពន្ធយើងវិញ។

ពេលខ្លះ មានការអាក្រក់យ៉ាងខ្លាំងបានកើតឡើងក្នុងគ្រួសារដែលប្ដី ឬ ប្រពន្ធត្រូវទទួលខុសត្រូវ។ ផលប៉ះពាល់នៅតែបន្តទៅមុខទៀត។ ឧទាហរណ៍ៈ ការធ្វេសប្រហែសក្នុងការបើកបររបស់ប្ដីបានបណ្ដាលឲ្យមានគ្រោះថ្នាក់ ចរាចរណ៍ ហើយកូនក៏បានស្លាប់។ រឿងនោះគឺជារឿងមួយដែលវេទនាខ្លាំង ណាស់ក្នុងការរស់នៅជាមួយ។ ប៉ុន្តែ មិនថាការនោះពិបាកខ្លាំងប៉ុណ្ណាក៏ដោយ ក៏ប្រពន្ធដែលជាគ្រីស្ទបរិស័ទព្យាយាមមិនបន្ទោសប្ដីខ្លួននោះទេ។ ការជឿលើ អំណាចនៃការអត់ទោសសម្រាប់អំពើរំលង និងលើអំណាចនៃអធិបតេយ្យ ភាពរបស់ព្រះជាម្ចាស់ក្នុងការជួយពួកគាត់ឲ្យចាប់ផ្ដើមជាថ្មី ប្រពន្ធបានរៀប ចំរបៀបរបស់គាត់ក្នុងការមិនលើកយករឿងគ្រោះថ្នាក់នោះមកនិយាយនោះ ទេ ទោះបើពេលដែលមានជម្លោះយ៉ាងខ្លាំងក៏ដោយ។

ដាច់ខាត យើងមិនត្រូវប្រើកម្លាំងវាយរាងកាយប្ដី ឬប្រពន្ធរបស់យើងជាដាច់ ខាត។ ខ្ញុំបាននិយាយអំពីការនេះនៅក្នុងជំពូក៤។ នៅពេលខ្ញុំបានសរសេរអំពី ការនោះ ខ្ញុំគិតថា អំពើហិង្សានៅក្នុងគ្រួសារគឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរមួយនៅក្នុង តំបន់ដែលខ្ញុំរស់នៅ ហើយថាមិនសូវសម្បូរនៅលោកខាងលិចនោះទេ។ ចាប់ តាំងពីពេលសរសេរអំពីការនោះមក ខ្ញុំបានដឹងថាវាក៏ជាបញ្ហាសម្រាប់លោក ខាងលិចដូចគ្នាដែរ។ ហើយក្រុមជំនុំក៏មិនបានរួចផុតពីការនេះផងដែរ។ សូម្បី តែក្នុងការប្រើប្រាស់កម្លាំងវាយរាងកាយតិចតួចបំផុតក៏ត្រូវតែមានទុក្ខសោក ការលន់តួ និងការអង្វរឲ្យលើកលែងទោសពីអ្នកដែលធ្វើខុសផងដែរ។ ប្រសិន បើមានការវាយម្ដងហើយ នោះវាទំនងជាត្រូវបានប្រើជាញឹកញាប់ជាងមុន បន្ទាប់ពីនោះមកជាមិនខាន។ ត្រូវតែមានវិធានការយ៉ាងតឹងរ៉ឹងចំពោះអស់ អ្នកដែលហ៊ានលើកដៃវាយប្ដី ឬប្រពន្ធរបស់ខ្លួន។ ការមានរចនាសម្ព័ន្ធនៃ ការមើលខុសត្រូវ—ដែលអ្នកល្មើសដឹងថា ប្រសិនបើគាត់ធ្វើម្ដងទៀត នោះ

នឹងមានម្នាក់ទៀតចូលមកជួយអន្តរាគមន៍ និងមានការដាក់វិន័យ—អាចជាជំនួយមួយយ៉ាងល្អនៅទីនេះ។

ការដែលដៃគូជីវិតប្រើប្រាស់ល្បិចកល ដែលភ្លាមនោះធ្វើឲ្យបុគ្គលម្នាក់ទៀតការពារខ្លួន មិនមែនជាប្រយោជន៍ដល់កូនរបស់ព្រះជាម្ចាស់ទេ។ នៅពេលដែលប្រពន្ធណាម្នាក់ប្រៀបធៀបប្ដីរបស់ខ្លួនជាមួយនឹងប្ដីប្អូនខ្លួន គឺគាត់កំពុងនាំមកនូវការឈឺចាប់ ដែលអាចមានការខូចខាតយ៉ាងខ្លាំង។ មនុស្សយើងមិនដូចគ្នានោះទេ ដូច្នេះយើងក៏មិនត្រូវរំពឹងថា អាកប្បកិរិយារបស់មនុស្សម្នាក់គួរតែដូចមនុស្សម្នាក់ទៀតឡើយ។ វាគឺជាការបង្ហាញពីការមិនមានភាពចាស់ទុំល្ងង់ខ្លៅ ហើយមិនមានចិត្តសប្បុរសទេក្នុងការយកឧទាហរណ៍របស់នរណាម្នាក់មកបង្ហាញពីភាពកម្សោយនៃប្ដី ឬប្រពន្ធរបស់យើង។

នៅពេលប្ដី ឬប្រពន្ធលើកឡើងពីបញ្ហាណាមួយ ម្ខាងទៀតមិនគួរបន្ទោសគាត់ពីចេតនាមិនល្អក្នុងការធ្វើបែបនេះនោះទេ។ ចូរមើលពីឧទាហរណ៍របស់ប្រពន្ធម្នាក់ដែលបានប្រាប់ប្ដីខ្លួនថា «អូនមិនចង់ឲ្យបងលេងសារ (Chat) ជាមួយសង្សារចាស់របស់បងទៀតទេ»។ ប្ដីអាចទទួលយកការនោះទុកជាដំបូន្មានដ៏ល្អ ជាជំនួយក្នុងការរម្លឹកឲ្យគាត់មានការប្រុងប្រយ័ត្នជាងនេះ។ ឬក៏គាត់អាចគោរពតាមដំបូន្មាននោះបានយ៉ាងសាមញ្ញដោយសារវាជាបំណងប្រាថ្នារបស់ប្រពន្ធជាទីស្រឡាញ់របស់គាត់។ សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំជឿថា វាពិតជាដំបូន្មានយ៉ាងល្អណាស់ក្នុងការប្រាប់នរណាម្នាក់មិនឲ្យចំណាយពេលច្រើនពេកជាមួយសង្សារចាស់របស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលដែលប្រពន្ធនិយាយបែបនេះ ប្ដីទំនងជាមានការឆ្លើយតបទៅកាន់ប្រពន្ធខ្លួនដោយកំហឹងដោយនិយាយបែបនេះថា «តើអូនគិតថា បងជាមនុស្សដូចហ្នឹងមែនឬ?» «តើអូនកំពុងចោទថា បងកំពុងលួចទាក់ទងជាមួយគេមែនឬ?» ឬក៏ «អូនអត់ទុកចិត្តបងទេ?» ប៉ុន្តែ ប្រសិនបើគាត់ឆ្លើយតបបែបនេះ នោះប្រពន្ធនឹងមិនចង់លើកឡើងនូវបញ្ហាដូចនោះម្ដងទៀតនោះទេ។ ដែលនេះមានន័យថា ពួកគាត់នឹងមិនមានឱកាសដោះស្រាយបញ្ហា នៅពេលដែលកើតមានឡើង

ឡើយ។ ដែគូជីវិតនេះនឹងឃ្លាតពីគ្នារៀងខ្លួន។

នៅពេលប្តី ឬប្រពន្ធរបស់យើងចង្អុលបង្ហាញពីកំហុស ឬពីគ្រោះថ្នាក់ដែលយើងមានទំនោរទៅរកនៅក្នុងជីវិតយើង វាអាចនឹងពិបាកក្នុងការទទួលយកវា។ យើងទំនងជាមានភាពអាម៉ាស់ចំពោះវា។ ប៉ុន្តែ វាអាចជាការផ្តល់សុខភាពល្អយ៉ាងខ្លាំងដល់យើងបាន។ កាលលោក យ៉ាកុប និយាយអំពីអ្នកដឹកនាំគាត់បានលើកឡើងថា «ដ្បិតយើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ» (យ៉ាកុប ៣:២ក)។ ខណៈពេលយើងងាយនឹងធ្វើខុសបែបនេះ ហើយប្រសិនបើយើងជាមនុស្សស្មោះត្រង់ និងមានកិត្តិយសមែន នោះយើងគួរតែទទួលយកគ្រប់ទាំងជំនួយទាំងអស់ដែលយើងអាចទទួលយកបាន ដើម្បីគេចចេញ និងយកឈ្នះលើចំណុចខ្វះខាតរបស់យើង។

ពិតណាស់ មានរបៀបដែលល្អក្នុងការលើកឡើងនូវបញ្ហាបាន។ យើងអាចធ្វើវាបានដោយមិនបង្ហាញពីការចោទប្រកាន់។ ឧទាហរណ៍៖ នៅពេលប្រពន្ធមានអារម្មណ៍ថា ប្តីរបស់គាត់មិនអើពើនឹងគាត់ នៅពេលប្តីត្រឡប់មកពីធ្វើការវិញ ប្រពន្ធអាចចោទគាត់ដោយកំហឹងថា «បងមិនស្រឡាញ់អូនទេ!» ឬក៏ម្យ៉ាងវិញទៀត គាត់អាចនិយាយថា «អូនចង់ឲ្យបងចំណាយពេលនិយាយលេងជាមួយអូនតិចតួច នៅពេលបងត្រឡប់មកពីធ្វើការវិញ»។ បន្ទាប់ពីខ្ញុំបានបញ្ចប់សេចក្តីអធិប្បាយនៅថ្ងៃអាទិត្យលើកណ្ឌគម្ពីរអេភេសូរជំពូកទី៤ មានមិត្តភក្តិម្នាក់បានប្រាប់ខ្ញុំថា «យើងបានហាមប្រាមមិនឲ្យប្រើពាក្យ "មិនដែល" និងពាក្យ "តែងតែ" នៅក្នុងគ្រួសាររបស់យើង»។ តាមរយៈឃ្លានេះ គាត់ចង់មានន័យថា «អ្នកមិនដែលជួយខ្ញុំ» និង «អ្នកតែងតែធ្វើឲ្យខ្ញុំឈឺចាប់» គឺជាឃ្លាហាមមិនឲ្យប្រើប្រាស់នៅក្នុងគ្រួសាររបស់គាត់ទេ។

បួនចំណុចក្នុងចំណោមទាំងប្រាំឧទាហរណ៍ដែលខ្ញុំបានលើកឡើងអំពីការធ្វើបាបក្នុងកំហឹងរបស់យើង គឺទាក់ទងទៅនឹងការប្រើប្រាស់អណ្តាត។ យើងត្រូវតែមានការប្រុងប្រយ័ត្នអំពីអ្វីដែលយើងនិយាយ នៅពេលយើងកំពុងខឹង។ សេចក្តីអធិស្ឋាននៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ១៤១:៣ គឺជាចំណុចមួយ

ដែលគួរតែមានភាពលេចធ្លោនៅក្នុងជីវិតគ្រីស្ទបរិស័ទដែលស្មោះត្រង់៖ «ឱព្រះយេហូវ៉ាអើយ សូមទ្រង់ដាក់ការយាមនៅមាត់ទូលបង្គំ ហើយថែរក្សាទ្វារបបូរមាត់របស់ទូលបង្គំផង!»។

## ច្បាប់ទី៣៖ កុំឲ្យថ្ងៃលិចដោយនៅមានកំហឹង

ច្បាប់បន្ទាប់របស់សាវ័ក ប៉ុល គឺថា «កុំឲ្យសេចក្ដីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ» (អេភេសូរ ៤:២៦ខ)។ គាត់កំពុងតែនិយាយថា យើងមិនត្រូវចុះចាញ់នៅក្នុងសមរភូមិនេះទេ រហូតទាល់តែយើងមានដំណោះស្រាយចំពោះបញ្ហាសិន។ ខ្ញុំបានអធិប្បាយសម្រាប់គូអាពាហ៍ពិពាហ៍ដំបូងគេ បន្ទាប់ពីខ្ញុំបានរៀបការបានមួយឆ្នាំ។ នៅក្នុងសេចក្ដីអធិប្បាយនោះ ខ្ញុំបានប្រាប់ដល់គូអាពាហ៍ពិពាហ៍ថា នៅពេលពួកគាត់មានបញ្ហា ពួកគាត់មិនត្រូវចូលដេកទាល់តែពួកគាត់បានដោះស្រាយបញ្ហានោះសិន។ មិត្តភក្ដិរបស់ខ្ញុំមួយចំនួនបានឆ្លើយតបមកកាន់សេចក្ដីអធិប្បាយមួយនោះដោយផ្ដល់ជាយោបល់ថា បន្ទាប់ពីបានរៀបការបីទៅបួនឆ្នាំទៀត នោះខ្ញុំនឹងរៀនបានថា អ្វីដែលខ្ញុំអធិប្បាយគឺមិនអាចអនុវត្តបានឡើយ។ ប៉ុន្តែ បន្ទាប់ពីបានរៀបការបាន៣៩ឆ្នាំហើយ ខ្ញុំនៅតែណែនាំអំពីការនោះ! ខ្ញុំដឹងថា បញ្ហាមានភាពស្មុគស្មាញ និងពិបាកដោះស្រាយបាន។ ប៉ុន្តែ យើងក៏មិនត្រូវឈប់រកដំណោះស្រាយចំពោះបញ្ហានោះដែរ។

មានករណីលើកលែងពីរយ៉ាងដែលខ្ញុំនឹងលើករំលេងចំពោះច្បាប់មួយនេះ។ ករណីទី១ វាមិនមែនជារឿងមានប្រាជ្ញានោះទេក្នុងការនិយាយអំពីបញ្ហា នៅពេលលោកអ្នកកំពុងតែខឹងគ្នាខ្លាំង។ យើងទើបតែបានពិភាក្សាអំពីចំណុចនោះ។ ចំណុចទី២ មានប្ដី ឬក៏ប្រពន្ធមួយចំនួនអាចមិនមានទំនុកចិត្តទាល់តែសោះរហូតដល់ពួកគាត់មិនអាចប្រឈមមុខនឹងបញ្ហាពិបាកបាន។ នេះគឺជាករណីលើកលែងដ៏កម្រមានណាស់ ហើយយើងក៏អាចកាត់ទោសប្ដី ឬប្រពន្ធយើងបានយ៉ាងស្រួលដោយគិតថា ពួកគាត់មិនអាចសមត្ថភាពដោះ

ស្រាយបញ្ហាដូចនោះបានទេ។ ចំពោះអ្នកដែលមានប្តី ឬប្រពន្ធដូចនោះ គាត់គួរតែអធិស្ឋានសម្រាប់ពួកគាត់ ដើម្បីឲ្យពួកគាត់កាន់តែមានទំនុកចិត្ត និងការទុកចិត្តដែលថា នឹងមានពេលមួយមកដល់ដែលពួកគាត់អាចចែកចាយបានដោយមានសេរីភាពនៅពេលដែលមានការមិនចុះសម្រុងគ្នាកើតមានឡើង។ ពួកគាត់ត្រូវតែដឹងថា ពួកគាត់អាចបោះបង់ទំនួលខុសត្រូវចោល ក្នុងការដោះស្រាយបញ្ហាពិបាកៗនោះ ដោយប្រើប្រាស់ភាពកម្សោយរបស់ប្តី ឬប្រពន្ធជាលេស។

ជារឿយៗ បញ្ហាកើតមានឡើងនៅក្នុងជីវិតអាពាហ៍ពិពាហ៍ណាមួយពេលដែលប្តី ឬប្រពន្ធម្នាក់ (ឬក៏ទាំងពីរនាក់) មានភាពមមាញឹកខ្លាំង។ នោះគឺជាពេលវេលាដែលដៃគូជីវិតចាប់ផ្តើមមានភាពព្រងើយកន្តើយដាក់គ្នាទៅវិញទៅមក។ ដោយសារតែមានភាពមមាញឹក ទំនោរធម្មជាតិរបស់យើងគឺពន្យារពេលក្នុងការប្រឈមមុខជាមួយនឹងបញ្ហានោះ រហូតទាល់តែយើងលែងរវល់នឹងវាទៀត។ ប៉ុន្តែ ការពន្យារពេលក្នុងការប្រឈមមុខជាមួយនឹងបញ្ហាអាចជាគ្រោះថ្នាក់ខ្លាំង។ ព្រះយេស៊ូវបានបញ្ជាក់អំពីភាពបន្ទាន់នៃការផ្សះផ្សាគ្នានៅក្នុងចំណោមសមាជិកនៅក្នុងក្រុមជំនុំ នៅក្នុងសេចក្តីបង្រៀនរបស់ព្រះអង្គនៅលើភ្នំដើមអូលីវ។ ព្រះអង្គបានមានបន្ទូលថាកាលណាអ្នកនាំយកដង្វាយមកដល់អាសនា ហើយនៅទីនោះអ្នកនឹកឃើញថា បងប្អូនណាមានហេតុអ្វីទាស់នឹងអ្នក នោះគាត់ត្រូវទុកដង្វាយរបស់ខ្លួននៅមុខអាសនា ហើយទៅរកជានឹងបងប្អូនជាមុនសិន រួចសឹមមកថ្វាយដង្វាយអ្នកចុះ (ម៉ាថាយ ៥:២៣-២៤)។ ប្រសិនបើការផ្សះផ្សាជាមួយអ្នកជឿមានភាពបន្ទាន់បែបនេះមែន ចុះតើវាកាន់តែមានភាពបន្ទាល់យ៉ាងណា ក្នុងការដែលយើងត្រូវមានការផ្សះផ្សាជាមួយសមាជិកគ្រួសាររបស់យើងផ្ទាល់!

ដៃគូជីវិតមួយទំនងជាត្រូវបន្តស្វែងរកមធ្យោបាយក្នុងការដោះស្រាយបញ្ហារហូតដល់ព្រឹកព្រលឹមក៏ថាបាន។ ពួកគាត់ទំនងជាទៅធ្វើការនៅព្រឹកបន្ទាប់ដោយមានភ្នែកឡើងក្រហម ដោយសារគេងមិនបានគ្រប់គ្រាន់។ ប៉ុន្តែ ពួក

គាត់នឹងបានទៅដោយមានដួងចិត្តដែលទទួលបានសេរីភាពរួចពីបន្ទុក ដោយមានអំណរក្នុងការរួបរួមគ្នាជាមួយមនុស្សដែលសំខាន់បំផុតនៅក្នុងជីវិតរបស់ខ្លួន។ ជារឿយៗ ជាពិសេសនៅក្នុងពេលមមាញឹក នៅពេលប្តី ឬប្រពន្ធមិនអើពើដាក់គ្នា នោះព្រះជាម្ចាស់អាចប្រើប្រាស់ជម្លោះ ដើម្បីនាំឲ្យពួកគាត់ត្រឡប់មកក្នុងផ្លូវរួបរួមគ្នាវិញ។

ជារឿងគួរឲ្យសោកស្តាយណាស់ ដែលមនុស្សមួយចំនួនមិនចង់ទទួលបានដំណោះស្រាយយ៉ាងពេញលេញសម្រាប់បញ្ហារបស់ពួកគាត់នោះទេ។ ពួកគាត់ស្វែងរកការស្អប់ចិត្តមួយចំនួនក្នុងការរក្សាគំនិតដែលថា ប្តី ឬប្រពន្ធរបស់ពួកគាត់បានធ្វើឲ្យពួកគាត់មានការឈឺចាប់។ ការអាណិតខ្លួនឯងគឺជាមិត្តភក្តិម្នាក់ដែលមិនធ្វើឲ្យយើងខកចិត្តនោះទេ ប្រសិនបើយើងចង់បណ្តុះកំហឹងរបស់យើងប្រឆាំងជាមួយនឹងអ្នកដែលធ្វើឲ្យយើងមានការឈឺចាប់។ ដៃគូជីវិតមួយចំនួនមិននិយាយរកគ្នាអស់រយៈពេលជាច្រើនថ្ងៃ បន្ទាប់ពីបានឈ្លោះគ្នាហើយ។ ខណៈពេលដែលនោះគឺជារឿងទូទៅ សូម្បីតែក្នុងចំណោមគ្រីស្ទបរិស័ទក៏ដោយ ក៏វាជាការរំលោភបំពានមកលើគោលការណ៍ព្រះគម្ពីរដែរ។ នៅពេលយើងលង់ក្នុងការអាណិតខ្លួនឯង នោះយើងកំពុងបង្អាក់ភ្លើងនៃសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តរបស់យើងហើយ។ ការមានសេចក្តីស្រឡាញ់សម្រាប់ខ្លួនឯងអាចរារាំងសេចក្តីស្រឡាញ់របស់យើងសម្រាប់ប្តី ឬប្រពន្ធរបស់យើង ប៉ុន្តែសេចក្តីស្រឡាញ់ពិតនឹងមិនឈប់សម្រាកនោះទេ រហូតទាល់តែមានការរួបរួមគ្នាពេញលេញត្រូវបានស្តារឡើងវិញសិន។

ពេលខ្លះ ការស្វែងរកដំណោះស្រាយត្រូវបានពន្យារពេលដោយសារប្តី ឬប្រពន្ធម្នាក់ (ឬក៏ទាំងពីរនាក់) ចង់បញ្ជាក់ថា ម្នាក់ទៀតជាមនុស្សមិនល្អ។ ហើយដោយសារម្នាក់ទៀត «មិនល្អ» ពួកគេនិយាយថា វាមិនអាចទៅរួចបានទេក្នុងការស្វែងរកដំណោះស្រាយ។ បើប្តី ឬក៏ប្រពន្ធដូចនោះនិយាយបែបនេះថា «គ្មានប្រយោជន៍ទេ។ វាខាតពេលអត់ប្រយោជន៍ក្នុងការស្វែងរកដំណោះស្រាយជាមួយមនុស្សដែលមិនកោតខ្លាចព្រះបែបនេះ»។ ដោយយក

"ផ្លូវសីលធម៌ខ្ពស់" ដូចនេះ មានប្រយោជន៍តែបន្តិចទេចំពោះការបង្កើតសុភមង្គលក្នុងគ្រួសារ។ យើងត្រឡប់មកមើលសេចក្ដីបង្រៀនសេចក្ដីបង្រៀនដែលយើងបាននិយាយគ្នានៅក្នុងជំពូកមុនៈ គ្រីស្ទបរិស័ទរាប់អ្នកដទៃល្អលើសជាងខ្លួនឯង (ភីលីព ២:៣)។ នេះគឺជាវិធីសាស្ត្រមូលដ្ឋានរបស់យើងមួយទៅកាន់អ្នកដទៃ។ ដោយមានអាកប្បកិរិយាបែបនេះ នោះយើងនឹងមិនត្រឡប់ទៅរកការឆ្លើយតបដោយនិយាយថា ម្នាក់នេះជាមនុស្សមិនល្អនោះទេ។

## ច្បាប់ទី៤៖ កុំផ្ដល់ឱកាសដល់អារក្ស

ចំណុចចុងក្រោយរបស់សាវ័ក ប៉ុល គឺថា "ក៏កុំឲ្យអារក្សមានឱកាសឲ្យសោះ" (អេភេសូរ ៤:២៧)។ នៅពេលយើងមិនដោះស្រាយការពុំព្រមព្រៀងគ្នាដែលធ្ងន់ធ្ងរ នោះយើងអាចបណ្ដាលឲ្យកំហឹងរបស់យើងមាននៅក្នុងដួងចិត្តរបស់យើងយ៉ាងយូរ។ ការនេះអាចផ្ដល់នូវឱកាសដល់អារក្សឲ្យមានឥទ្ធិពលលើយើង នៅក្នុងរបៀបមួយដែលបណ្ដាលឲ្យយើងបញ្ចប់ដោយប្រព្រឹត្តអំពើអាក្រក់ផងដែរ។ ការបកប្រែរបស់ ព្រះគម្ពីរខ្មែរបច្ចុប្បន្ន បានបកថា "កុំហុចឱកាសឲ្យមារមកល្បួងបងប្អូន"។ សាតាំងអាចចូលមកក្នុងផ្នែកដ៏តូចមួយនៃជីវិតរបស់យើង នៅពេលយើងធ្វើខ្លួនយើងឲ្យងាយរងការវាយប្រហាររបស់វាដោយការបណ្ដុះកំហឹង។ ការនេះអាចនាំឲ្យកាន់តែមានបញ្ហាធ្ងន់ធ្ងរជាងហ្នឹងទៅទៀត។ មិនយូរមិនឆាប់នោះទេ ការនេះអាចនាំឲ្យកាន់តែមានបញ្ហាធ្ងន់ធ្ងរជាងហ្នឹងទៅទៀត ចំពោះអ្នកណាដែលទុកកំហឹងរបស់ខ្លួននៅក្នុងដួងចិត្តនឹងធ្វើឲ្យអ្នកដទៃឈឺចាប់ជាមិនខាន។ កំហឹងទំនងជាអាចទប់បាន ប៉ុន្ដែវានឹងផ្ទុះឡើងនៅពេលណាមួយ។

អ្នកព្យាបាលគ្រួសារដែលជាជនជាតិអាមេរិកម្នាក់ គឺលោកស្រីវេជ្ជបណ្ឌិត សែនដ្រា ឌី. វៀលសិន (Dr. Sandra D. Wilson) បានសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា "មនុស្សឈឺចាប់ធ្វើឲ្យអ្នកដទៃឈឺចាប់" ("Hurt People Hurt People")។[២] លោកស្រីបង្ហាញអំពីរបៀបដែលមនុស្ស

ឈឺចាប់បានប្រព្រឹត្តឡើងដោយការឈឺចាប់នោះ ហើយបណ្ដាលឲ្យពួកគាត់ធ្វើឲ្យអ្នកដទៃទៀតឈឺចាប់ដែរ។ សៀវភៅនេះក៏មានប្រាប់អំពីរបៀបនៃការយកឈ្នះលើការឈឺចាប់ទាំងនេះផងដែរ។ មនុស្សមួយចំនួនដែលបានទទួលរងការឈឺចាប់នេះ អាចទំនងជាអ្នកដែលមានការប្ដេជ្ញាចិត្តនៅក្នុងក្រុមជំនុំ។ តាមពិតទៅ ក្នុងជម្លោះនៅក្នុងគ្រួសារ ពួកគាត់ទំនងជានៅក្នុងចំណុចត្រឹមត្រូវ។ ប៉ុន្តែ ដោយសារពួកគាត់រក្សាទុកសេចក្ដីកំហឹងនៅក្នុងដួងចិត្តរបស់ខ្លួន នោះពួកគាត់ក៏បានប្រព្រឹត្តដោយមិនមានការអត់ធ្មត់ជាមួយអ្នកដទៃ ហើយក៏បានបញ្ចប់ដោយធ្វើឲ្យមានការឈឺចាប់។ យើងអាចហៅមនុស្សទាំងនេះថា «សុចរិតតែអាក្រក់»។ ពួកគាត់អាចជាមូលហេតុដែលនាំឲ្យសេចក្ដីអំណរចាកចេញពីគ្រួសាររបស់គ្រីស្ទបរិស័ទ។

## គោលដៅគឺការរួបរួមគ្នា មិនមែនការយកឈ្នះ

ប្រទេសស្រីលង្កាបានរងគ្រោះពីសង្គ្រាមស៊ីវិលអស់រយៈពេលជិត៣០ឆ្នាំ។ សង្គ្រាមនោះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៩។ នៅក្នុងអំឡុងពេលខុសៗគ្នាក្នុងសង្គ្រាមនេះ ពួកក្រុមឧទ្ទាម និងកងកម្លាំងរាជរដ្ឋាភិបាលបានទទួលជ័យជម្នះមួយចំនួន។ បន្ទាប់ពីក្រុមរាជរដ្ឋាភិបាលបានទទួលជ័យជម្នះយ៉ាងសំខាន់មួយនៅក្នុងសមរភូមិ ប្រធានាធិបតីនៃប្រទេសស្រីលង្កា លោក អរ. ព្រីម៉ាដាសា (R. Premadasa) បានប្រាប់នៅក្នុងទូរទស្សន៍ជាតិដោយនិយាយថា ក្នុងសង្គ្រាម មិនមានអ្នកឈ្នះនោះទេ។ គាត់ចង់ប្រាប់ឲ្យបានដឹងថា ប្រជាជនស្រីលង្កាបានវាយជាមួយនឹងប្រជាជនស្រីលង្កាដូចគ្នា ហើយជ័យជម្នះនៅក្នុងជម្លោះបែបនេះមិនមែនជាដំណោះស្រាយសម្រាប់បញ្ហានោះទេ។ ដំណោះស្រាយដ៏ពិតគឺសន្តិភាព និងភាពសុខដុមរមនារវាងប្រជាជននៅក្នុងប្រទេសស្រីលង្កាទាំងអស់គ្នា។

ក្នុងរបៀបដូចគ្នានេះដែរ ការយកឈ្នះមិនមែនជាគោលដៅនៃការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នានៅក្នុងគ្រួសារនោះឡើយ។ នោះប្រៀបដូចជាឈ្នះក្នុង

ចម្បាំងតូចមួយនៅក្នុងសង្គ្រាមធំ ដោយមិនបានឈ្នះសង្គ្រាមខ្លួនឯងផ្ទាល់។ យើងអាចឈ្នះចម្បាំងតូចមួយ តែនៅតែអាចចាញ់សង្គ្រាមដដែល។ ជ័យជម្នះពិតប្រាកដគឺអាចទទួលបាន ហើយសង្គ្រាមដែលទទួលបានជ័យជម្នះ គឺនៅពេលមានការរួបរួមគ្នា គឺនៅពេលដែលគ្រួសារមានសុភមង្គល និងជាកន្លែងមួយដែលមានភាពសុខដុមរមនា។ ជ័យជម្នះដែលទទួលបាននៅក្នុងចម្បាំងតូចៗអាចបំពេញភាពស្កប់ស្កល់ដល់មនុស្សតូចៗតែប៉ុណ្ណោះ។ មនុស្សធំនឹងមើលទៅឯរូបភាពធំវិញ។ ដូច្នេះ នៅពេលយើងមានការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នា បំណងប្រាថ្នាចម្បងរបស់យើងគឺជាការរួបរួមគ្នា ភាពសុខដុមរមនា សេចក្ដីស្រឡាញ់ដែលមានការស្ដារឡើងវិញ និងឲ្យបញ្ហាដែលបណ្ដាលឲ្យកើតមានជម្លោះនោះត្រូវបានដោះស្រាយរួចរាល់ហើយ។ បំណងប្រាថ្នាក្នុងការទទួលបានអ្វីដែលយើងចង់បាន ឬការយកឈ្នះក្នុងការប្រកែកគ្នា គឺត្រូវបានដាក់បញ្ចូលនៅក្រោមបំណងប្រាថ្នាដ៏ធំជាងនេះទៅទៀត គឺជាភាពសុខដុមរមនានៅក្នុងគ្រួសារ។ ចំពោះអ្នកដែលពិតជាស្រឡាញ់ប្ដី ឬប្រពន្ធខ្លួនមែន គឺពួកគាត់ចង់បានការរួបរួមគ្នាជាងអ្វីៗទាំងអស់។ នៅពេលម្នាក់មានការស្កប់ចិត្តជាមួយការមានជ័យជម្នះតូចតាច នោះគឺជាសញ្ញាដែលបង្ហាញថា សេចក្ដីស្រឡាញ់ខ្លួនឯងបានយកឈ្នះលើសេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទហើយ។

## ការសុំទោសគ្នា

ជាធម្មតា នៅពេលមានជម្លោះដោយចេះស្រឡាញ់គ្នាបានកើតឡើង ទាំងសងខាងបានបរាជ័យនៅក្នុងរបៀបណាមួយហើយ។ មានម្នាក់ដែលស័ក្ដិសមនឹងទទួលបានការស្ដីបន្ទោសសម្រាប់បញ្ហាមួយនោះខ្លាំងជាង ប៉ុន្តែក្នុងអំឡុងពេលកំពុងឈ្លោះគ្នា ជាញឹកញាប់យើងក៏បានឃើញថា ម្នាក់ទៀតក៏បានធ្វើខុសដែរ។ រហូតទាល់តែអ្នកដែលមានទំនួលខុសត្រូវលើបញ្ហានោះបានសុំទោសហើយ នោះមិនអាចមានដំណោះស្រាយដែលគង់វង្សពីនោះបានទេ។

ប្រធានបទដែលសំខាន់ជាងគេនៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ១:៥-១០ គឺភាពចាំបាច់នៃការដើរក្នុងពន្លឺ។ ខ៥, ៨ និង១០ បានបង្ហាញថា គំនិតគន្លឹះនៃការដើរក្នុងពន្លឺគឺការទទួលស្គាល់ថា យើងបានធ្វើខុស។ យោងតាមខ៩ ការនេះត្រូវបានបង្ហាញដោយអស់អ្នកដែលព្យាយាមដើរនៅក្នុងពន្លឺ ដោយសារភាពអំពើបាបរបស់ខ្លួន (ទៅកាន់ព្រះជាម្ចាស់)។ ខ៧ក៏បានលើកឡើងអំពីគំនិតនៃការមានទំនាក់ទំនងក្នុងការដើរនៅក្នុងពន្លឺ៖ «តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក»។ តាមរយៈការមើលក្នុងអត្ថបទនៃខគម្ពីរមួយនេះ យើងអាចសន្និដ្ឋានបានថា ខនេះបង្រៀនយើងថា ប្រសិនបើយើងចង់មានការប្រកបគ្នាពិតប្រាកដ នោះយើងត្រូវតែព្យាយាមដើរតាមផ្លូវរបស់ព្រះជាម្ចាស់ និងលន់តួបាបនៅពេលដែលយើងបរាជ័យក្នុងការធ្វើនោះ។ ចំពោះអស់អ្នកដែលមិនមានភាពច្បាស់លាស់ក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់ និងការទទួលស្គាល់កំហុសរបស់ខ្លួន នោះពួកគាត់មិនអាចមានការប្រកបគ្នាជាមួយគ្រីស្ទបរិស័ទពិតប្រាកដបានឡើយ។ ពួកគាត់ទំនងជាអាចឱបគ្នា ថើបគ្នា ជជែកលេងជាមួយគ្នា និងសើចលេង ប៉ុន្តែក៏នៅមានរនាំងឃាំងការរួបរួមគ្នាដ៏ពិតប្រាកដដែរ។

កាលខ្ញុំនៅវ័យជំទង់ ខ្ញុំបានឮពីបេសកជនម្នាក់ដែលជាជនជាតិអាមេរិកដែលបានរស់នៅប្រទេសស្រីលង្កាគឺ លោក ដន រ៉ូបេស៍ (Don Rubesh) គាត់បានលើកឡើងថា «ពាក្យ៦ព្យាង្គដែលពិបាកនិយាយបំផុតនៅក្នុងផ្ទះរបស់ខ្ញុំគឺ "បងសូមទោស បងអ្នកខុស"»។ មិត្តភក្តិរបស់ខ្ញុំម្នាក់ធ្លាប់បានប្រាប់ខ្ញុំថា «ខ្ញុំមិនដែលឮប្រពន្ធខ្ញុំនិយាយពាក្យសូមទោសសោះ»។ មានស្ត្រីម្នាក់ក៏បានប្រាប់ខ្ញុំអំពីការដូចគ្នានោះ ដែលប្តីគាត់មិនដែលសូមទោសទេ។ លុះត្រាតែមនុស្សទាំងនេះជាទេវតា នោះប្រាកដណាស់ពួកគាត់នឹងមានមូលហេតុដែលត្រូវសូមអភ័យទោសជាមិនខាន។ យើងទាំងអស់គ្នាសុទ្ធតែបរាជ័យក្នុងការរស់នៅឲ្យបានស្របតាមស្តង់ដារដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ទោះជាយ៉ាង

ណាក៏ដោយ ក៏វាជាការអាម៉ាស់មួយដែរក្នុងការទទួលស្គាល់ថា យើងបានធ្វើខុស។ ក្នុងវប្បធម៌ដែលផ្តោតលើភាពអាម៉ាស់ និងកិត្តិយស ដូចវប្បធម៌នៅប្រទេសអាស៊ី នៅលោកខាងលិចមួយចំនួន (ជាពិសេសក្នុងចំណោមសង្គមជនជាតិភាគតិច) ការសុំអភ័យទោសគឺពិតជារឿងដែលពិបាកណាស់។ ដូចដែលបានលើកឡើងមុននោះបន្តិច មនុស្សមួយចំនួនចាត់ទុកថា ភាពអាម៉ាស់ដែលត្រូវបានលាតត្រដាងថាបានធ្វើខុសគឺអាក្រក់ជាងកំហុសដែលបានធ្វើផ្ទាល់ទៅទៀត។ ហេតុដូច្នេះហើយបានជាយើងត្រូវតែមានហេតុផលដ៏ល្អដែលត្រូវជឿថា វាមានតម្លៃណាស់ក្នុងការសូមអភ័យទោសគ្នា។

ហេតុផលដ៏មានអំណាចជាងគេក្នុងការសូមអភ័យទោសគ្នា គឺការទាក់ទងគ្នាជាមួយគោលលទ្ធិនៃព្រះគុណដែលមាននៅក្នុងព្រះគម្ពីរ។ អំពើបាបរបស់យើងរារាំងព្រះគុណរបស់ព្រះជាម្ចាស់មិនឲ្យចូលមកក្នុងជីវិតរបស់យើង។ ព្រះគុណគឺជាអ្វីមួយសំខាន់បំផុតនៅក្នុងជីវិតរបស់យើង។ ប្រសិនបើមានអ្វីមួយពិតជាមានតម្លៃនៅក្នុងជីវិតរបស់យើងមែន គឺយើងមានដោយសារព្រះគុណតែប៉ុណ្ណោះ។ ដូច្នេះ ការបាត់បង់ការទទួលបានព្រះគុណគួរតែជាអ្វីមួយដែលគួរឲ្យភ័យណាស់សម្រាប់គ្រីស្ទបរិស័ទ។ ការបរាជ័យរបស់យើងក្នុងការសូមអភ័យទោស គឺជាការរារាំងលំហូរនៃព្រះគុណ។ ដោយសារការនេះ ប្រសិនបើយើងបានធ្វើបាបចំពោះនរណាម្នាក់ យើងគួរតែសូមអភ័យទោសឲ្យបានឆាប់ តាមដែលអាចធ្វើបាននៅពេលដែលយើងបានដឹងថាយើងធ្វើខុស។ បំណងប្រាថ្នារបស់យើងសម្រាប់ព្រះគុណផ្តល់ជាកម្លាំងដល់យើងក្នុងការសូមអភ័យទោស។ អស់អ្នកដែលមានការភ័យខ្លាចក្នុងការសូមអភ័យទោសគឺមិនបានយល់ពីព្រះគុណរបស់ព្រះជាម្ចាស់នៅឡើយទេ។ ការនេះបានធ្វើឲ្យពួកគាត់ទន់ខ្សោយយ៉ាងខ្លាំង ដែលនាំឲ្យពួកគាត់មិនមានកម្លាំងក្នុងការសូមអភ័យទោស។

ហេតុផលមួយទៀតសម្រាប់ការសូមអភ័យទោសគឺដោយសារវាជាការស្តារកិត្តិយស និងសេរីភាពខាងវិញ្ញាណរបស់អ្នកដែលបានធ្វើខុស។ មុន

នេះបន្តិចនៅក្នុងជំពូកនេះ ខ្ញុំបាននិយាយអំពីពពកនៃការធ្វើពុតយ៉ាងក្រាស់ ដែលមាននៅក្នុងគ្រួសារដែលម្នាក់បានធ្វើខុស ប៉ុន្តែមិនបានសារភាពអំពើបាបនោះ។ ប្ដី ឬក៏ឪពុកអាចត្រូវបានគេគោរព ហើយអាចប្រើអំណាចរបស់គាត់ក្នុងនាមជាអ្នកដឹកនាំនៅក្នុងគ្រួសារ ប៉ុន្តែនោះគឺជាការគោរព និងការឲ្យតម្លៃបែបលោកីយ៍ ដែលបានផ្ដល់ឲ្យដោយសារគុណតម្លៃ និងតំណែង មិនមែនដោយសារគាត់សមនឹងទទួលបាននោះទេ។ តាមពិតទៅ ជាមួយនឹងអំណាចនៅលើផែនដីនេះ ក៏អាចនៅមានការថ្នាក់ថ្នាំងចិត្តដែលលាក់បាំងប្រឆាំងនឹងប្ដី ឬឪពុកដែរ។ នៅពេលដែលអ្នកធ្វើខុសទទួលយកទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួន នោះពពកដ៏ក្រាស់នៃការធ្វើពុតនេះនឹងត្រូវបានរសាត់ចេញ និងជំនួសមកវិញដោយសេរីភាពនៃការបើកចំហ និងការគោរពដល់អស់អ្នកដែលបានទទួលស្គាល់អំពើបាបរបស់ខ្លួន។ បន្ទាប់មក ដៃគូជីវិតអាចមានការប្រកបគ្នាយ៉ាងពិតប្រាកដ។ នេះជាសេចក្ដីបង្រៀននៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ១:៧៖ «តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សម្អាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់»។ យើងបានយល់បរិបទនៃបទគម្ពីរនេះរួចហើយ ដែលបានបង្ហាញគោលគំនិតមួយនៃការដើរក្នុងពន្លឺ គឺការទទួលសារភាពថាយើងបានធ្វើខុស។

កាលខ្ញុំនៅវ័យយុវជន មានការប្រជុំគណៈកម្មការមួយនៅផ្ទះរបស់យើង ដែលដឹកនាំដោយឪពុកខ្ញុំ។ ខ្ញុំអាចឮការឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងនៅក្នុងការប្រជុំនោះ។ មិនយូរមិនឆាប់ ការប្រកែកគ្នាក៏បានក្លាយជារឿងល្វីងជូរចត់ ដោយមានការនិយាយស្ដីមិនសមរម្យ និងមិនល្អ។ ក្នុងចំណោមអ្នកដែលកំពុងឈ្លោះគ្នាយ៉ាងខ្លាំងគឺ លោកប៊ីស្សព ឡាកស៍ម៉ាន វីក្រេមសីញ (Bishop Lakshman Wickremesinghe) ដែលគេសរសើរយ៉ាងខ្លាំង ហើយក៏ជាមនុស្សឆ្លាតវៃដែរ។ ថ្ងៃបន្ទាប់ការប្រជុំគ្នានោះ លោកប៊ីស្សព បានមកផ្ទះយើង

ហើយជួបជាមួយនឹងឪពុកខ្ញុំ ដើម្បីសុំទោសអំពីរបៀបដែលគាត់បាននិយាយស្តី។ ខ្ញុំមិនដែលភ្លេចរឿងនេះឡើយ។ ខ្ញុំតែងតែកោតសរសើរលោកប៊ីស្សព ពីព្រោះគាត់បង្ហាញការកោតខ្លាចព្រះ ក្នុងការបន្ទាបខ្លួនដូចនោះ។

ទោះជាយ៉ាងណាក៏ដោយ ក៏បុគ្គលលក្ខណៈរបស់យើងក៏ត្រូវឲ្យជះឥទ្ធិពលក្នុងការស្ម័គ្រចិត្តរបស់យើងក្នុងការសុំទោសគ្នាដែរ។ មនុស្សមួយចំនួនងាយនឹងសុំទោសជាងមនុស្សមួយចំនួនទៀត។ តាមធម្មតា ការឈ្លោះគ្នាដែលចេះស្រឡាញ់នឹងឈានដល់ទីបញ្ចប់ នៅពេលដែលទាំងសងខាងសុំទោសគ្នា។ ហើយជាធម្មតា វាគឺជាបុគ្គលដដែល ដែលសុំទោសមុនក្នុងការឈ្លោះគ្នាដែលចេះស្រឡាញ់។ នេះមិនគួរជាបញ្ហាទេ។ យើងត្រូវតែទទួលស្គាល់ថាមនុស្សយើងមានលក្ខណៈខុសៗគ្នា។ ចំណុចចម្បងគឺថា គ្រប់គ្នាដែលបានធ្វើអ្វីខុសត្រូវតែចេះសុំទោស ដើម្បីឲ្យមានភាពពេញលេញ និងការរួបរួមគ្នាដ៏ពិតបាន។ ចំណុចដែលថា មានបុគ្គលដដែលដែលតែងតែសុំទោសមុន គឺមិនមែនជាបញ្ហាធ្ងន់ធ្ងរនោះទេ។

## ព្រះជាម្ចាស់នៅទីនោះ

ខ្ញុំបានពណ៌នារួចមកហើយនៅក្នុងជំពូក១ និងនៅកន្លែងផ្សេងទៀតអំពីរបៀបដែលព្រះជាម្ចាស់មានឥទ្ធិពលនៅគ្រប់ផ្នែកទាំងអស់នៃជីវិតគ្រួសាររបស់យើង។ នេះក៏ជាការពិតនៃការឈ្លោះគ្នាដោយចេះស្រឡាញ់គ្នាដែរ៖

- ការទទួលស្គាល់ថា ព្រះជាម្ចាស់ធំជាងបញ្ហា ហើយនឹងប្រែបញ្ហានោះទៅជាការល្អវិញក៏ផ្តល់ការលើកទឹកចិត្តដល់យើងក្នុងការប្រឈមមុខជាមួយនឹងវា ដោយភាពស្មោះត្រង់ និងដើម្បីផ្តើមការសន្ទនាគ្នាដែលនាំឲ្យបានជាការឈ្លោះគ្នាដោយចេះស្រឡាញ់។
- ការជឿថា ពីព្រោះព្រះជាម្ចាស់មានអធិបតេយ្យភាព និងចូលរួមនៅក្នុងបញ្ហានោះ នោះព្រះអង្គនឹងដឹកនាំយើងទៅរកដំណោះ

ស្រាយ ផ្តល់ឲ្យយើងនូវការតស៊ូ ដើម្បីតយុទ្ធដោយមិនបោះបង់ចោល រហូតទាល់តែបានដំណោះស្រាយសិន។

• ការដឹងថា ព្រះជាម្ចាស់នៅទីនេះជាមួយយើងក៏ជួយយើងត្រួតពិនិត្យការតយុទ្ធជាមួយជម្លោះនោះដែរ។ ព្រះជាម្ចាស់ប្រៀបដូចជាមេអាជ្ញាកណ្តាលក្នុងការតយុទ្ធមួយអង្គអញ្ចឹង។ ការទទួលស្គាល់អំពីព្រះវត្តមានរបស់ទ្រង់ និងសុវត្ថិភាពរារាំងយើងមិនឲ្យមានភាពស្លន់ស្លោ និងការប្រព្រឹត្តបែបប្រញាប់ប្រញាល់នៅក្នុងរបៀបដ៏ល្ងីល្ងើ។ ព្រះវត្តមានរបស់ព្រះអង្គជួយការពារយើងមិនឲ្យប្រើអំពើហិង្សា ការជេរប្រមាថ និងពាក្យពេចន៍ឃោរឃៅ និងពេញដោយការឈឺចាប់។ លោកអ្នកនឹងមិនអាចនិយាយដូចនោះបានទេ ប្រសិនបើលោកអ្នកដឹងថាព្រះជាម្ចាស់កំពុងតែព្រះសណ្តាប់។ សាវ័ក ប៉ុល បានលើកឡើងថា “ចូរឲ្យសេចក្តីមេត្រីរបស់ព្រះគ្រីស្ទត្រួតត្រានៅក្នុងចិត្ត” (កូឡូស ៣:១៥ក)។ សន្តិភាពដែលយើងមាន ដោយសារព្រះគ្រីស្ទជាអង្គដឹកនាំ (គ្រប់គ្រង) លើអាកប្បកិរិយារបស់យើង និងរារាំងយើងមិនឲ្យឈានទៅរកសភាពដ៏ធ្ងន់ធ្ងរផងដែរ។

• ការអត់ទោសដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រទានដល់យើងជួយយើងឲ្យមានការចាប់ផ្តើមជាថ្មីម្តងទៀតបន្ទាប់ពីយើងបានបរាជ័យ។

• បទពិសោធន៍នៃការអត់ទោសដែលយើងមានអំណរជាមួយជួយជំរុញយើងឲ្យអត់ទោសដល់អ្នកដទៃដែលបានធ្វើខុសមកលើយើង។

• ដោយទទួលបានការអត់ទោស និងការដែលបានអត់ទោសដល់អ្នកដទៃ នោះយើងអាចចាប់ផ្តើមទំនាក់ទំនងជាថ្មីជាមួយអតីតកាល ដែលយើងបានចោលដោយចេតនា។

ព្រះរបស់យើងគឺជាព្រះដែលតែងតែធ្វើនូវអ្វីៗថ្មីជានិច្ច។ នៅពេលយើង

ប្រឈមមុខនឹងបញ្ហាដែលយើងមានដោយស្មោះត្រង់ ហើយចាប់ផ្ដើមរកដំណោះស្រាយលើបញ្ហានោះដោយប្រើប្រាស់របៀបរបស់ទ្រង់ នោះព្រះអង្គអាចប្រើប្រាស់បញ្ហាទាំងនោះជាព្រះពរថ្មីៗដល់ការរស់នៅរបស់យើងជាមួយគ្នាបាន។ សូមកុំមានការភ័យខ្លាចក្នុងការប្រឈមមុខនឹងបញ្ហាដែលនាំឲ្យមានការមិនសប្បាយចិត្តឡើយ។ ព្រះជាម្ចាស់ធំជាងបញ្ហាទាំងអស់នោះទៅទៀត!

## សេចក្ដីសន្និដ្ឋាន

សព្វថ្ងៃនេះ មនុស្សយើងមិនសូវរវីរវល់ខ្លាំងប៉ុន្មាន ទាក់ទងនឹងទំនាក់ទំនងជាមួយអ្នកដទៃទេ ដរាបណាវាដំណើរការដល់ទីបញ្ចប់។ មនុស្សយើងក៏មិនមានការប្ដេជ្ញាចិត្តខ្លាំងនៅក្នុងអង្គការ ឬក៏សូម្បីតែក្នុងក្រុមជំនុំផងដែរ។ ប្រសិនបើនរណាម្នាក់មិនអាចធ្វើឲ្យដល់គោលដៅនៃអង្គការ ឬក៏ក្រុមជំនុំនោះបានទេ ពួកគាត់ក៏បោះបង់ចោល ហើយទៅរកកន្លែងផ្សេងទៀត។ ជាការគួរឲ្យសោកស្ដាយណាស់ មនុស្សជាច្រើននាក់ក៏ហាក់បីដូចជាអនុញ្ញាតឲ្យការនេះចូលមកឈ្លានពានក្នុងជីវិតគ្រួសារផងដែរ។ ប្រសិនបើគ្រួសារមានដំណើរការ «ប្រកបដោយប្រសិទ្ធភាព» នោះសមាជិកហាក់បីដូចជាមានការពេញចិត្ត។ ប៉ុន្តែ គំរូនៃសហគមន៍នៅក្នុងព្រះគម្ពីរគឺថារូបកាយ—នៃមនុស្សដែលបានប្ដេជ្ញាចិត្តចំពោះគ្នាទៅវិញទៅមក និងការរស់នៅដោយមានដួងចិត្ត និងគំនិតតែមួយវិញ។ ប្រសិនបើដូចនោះមែន យើងត្រូវតែលះបង់ខ្លួនយើងយ៉ាងមុតមាំក្នុងការអនុវត្តគំរូមួយនេះនៅក្នុងជីវិតគ្រួសារ។ វាមិនមានប្រសិទ្ធភាពនោះទេ ហើយវាក៏ត្រូវការពេលវេលា និងថាមពលច្រើនដែរ។ ប៉ុន្តែ រង្វាន់ដែលយើងទទួលបាននោះគឺសុវត្ថិភាព សេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ និងការមានទំនុកចិត្តនៅក្នុងទំនាក់ទំនងរវាងសមាជិកគ្រួសារ។ នោះគឺជាគោលដៅដែលសមនឹងចំណាយតម្លៃយ៉ាងធំមួយក្នុងការទទួលបានវា។

# ១០

# ការសប្បាយចិត្តជាមួយនឹងកូនៗ

កូនៗរបស់យើងកំពុងធំធាត់ឡើងនៅក្នុងពិភពលោកមួយដែលខុសគ្នាពីពិភពលោកដែលឪពុកម្ដាយរបស់ពួកគាត់បានធំធាត់ឡើង ដែលឥឡូវនេះមូលដ្ឋានគ្រឹះនៃជំនឿនៃការដឹងខុសត្រូវមានភាពស្រអាប់។ គ្រប់ជំនាន់សុទ្ធតែមានចំណែកនៃការទាក់ទាញដ៏អាក្រក់ៗ។ ប៉ុន្តែ សព្វថ្ងៃនេះ សីលធម៌នៃការគ្មានខុសត្រូវគឺជាតម្លៃមួយដែលគេប្រកាន់ខ្ជាប់តាមយ៉ាងខ្លាំង ដល់ថ្នាក់ថាគេបានរាប់អស់អ្នកដែលឲ្យតម្លៃលើប្រពៃណីនៃការខុសត្រូវថា មិនមានភាពស៊ីគ្នាជាមួយនឹងប្រពៃណីបច្ចុប្បន្នទៀតទេ។ របៀបដ៏ល្អបំផុតមួយនៃការតយុទ្ធគឺការបង្កើតបរិយាកាសនៅក្នុងផ្ទះដែលល្អ និងមានអាកប្បកិរិយាទទួលយកគ្នាទៅវិញទៅមក ដើម្បីឲ្យកូនៗឃើញតម្លៃដែលគ្រួសាររបស់ពួកគាត់ប្រកាន់ខ្ជាប់ថា វាពិតជាបង្កើតបរិយាកាសដ៏ល្អបំផុតក្នុងការបំពេញជីវិតនេះ។ នៅក្នុងជំពូកនេះ និងជំពូកបន្ទាប់ យើងនឹងពិនិត្យមើលលក្ខណៈពិសេសនៃបរិយាកាសគ្រួសារដែលមានសុខភាពល្អ សម្រាប់ឲ្យកូនៗបានធំធាត់ឡើង។

## កូនៗគឺជាព្រះពរ

សព្វថ្ងៃនេះ លោកីយ៍ត្រូវបានគេកំណត់ថា មានយោបល់ផ្ទុយគ្នាអំពីកុមារច្រើនណាស់។ និយាយម៉្យាងទៅ ដៃគូអាពាហ៍ពិពាហ៍ភាគច្រើនមានបំណងចង់មានកូន ហើយក៏មិនសប្បាយចិត្តប្រសិនបើការព្យាយាមមានផ្ទៃពោះរបស់ពួកគាត់បរាជ័យ។ ប៉ុន្តែ និយាយម៉្យាងវិញទៀតទៅ ដៃគូអាពាហ៍ពិពាហ៍ជាច្រើនក៏បានពន្យារពេលក្នុងការមានកូនឲ្យបានយូរតាមដែលអាចធ្វើទៅបានដែរ ដើម្បីឲ្យការងារ និងស្ថិរភាពផ្នែកហិរញ្ញវត្ថុមានការនឹងនរសិន។ សូម្បីតែអស់អ្នកដែលចង់បានកូនយ៉ាងខ្លាំងក៏តែងតែមើលឃើញថាពេលមានកូននោះជាបន្ទុក និងជាបញ្ហាប្រឈមផងដែរ។ កាលពីមុន ការមានកូនច្រើន ចាត់ទុកថាជាព្រះពរ។ ឥឡូវនេះ ឪពុកម្តាយជាច្រើនចូលចិត្តកំណត់ចំនួននៃការមានកូនដែលពួកគាត់ចង់បានក្នុងហេតុផលជាក់ស្តែង ដោយរួមបញ្ចូលទាំងបញ្ហាផ្នែកហិរញ្ញវត្ថុផងដែរ។ ដូចសព្វមួយដង យើងនឹងមើលនៅក្នុងព្រះគម្ពីរដើម្បីឲ្យឃើញពីអ្វីដែលព្រះជាម្ចាស់ចង់ប្រាប់យើងអំពីប្រធានបទមួយនេះ។

រូបភាពដែលមានន័យច្បាស់លាស់ដែលយើងឃើញនៅក្នុងព្រះគម្ពីរគឺថាកូនៗគឺជាព្រះពរ។ កណ្ឌគម្ពីរ ទំនុកតម្កើង ១២៧:៣-៤ បានចែងថា «មើលកូនចៅជាមរដកមកពីព្រះយេហូវ៉ា ហើយផលកើតពីផ្ទៃ ក៏ជារង្វាន់ដែលទ្រង់ប្រទានដែរ កូនដែលឯងបង្កើតពីកាលនៅក្មេងនោះធៀបដូចជាព្រួញនៅដៃនៃមនុស្សខ្លាំងពូកែ»។ កណ្ឌគម្ពីរទំនុកតម្កើងក៏បានបន្តលើកឡើងទៀតថាការមានកូនច្រើនក៏ជាសញ្ញានៃការទទួលបានព្រះពរដែរ៖ «សប្បាយហើយអ្នកណាដែលមានបំពង់ព្រួញពេញ ដោយព្រួញយ៉ាងនោះ កាលណាត្រូវការនិយាយនឹងខ្មាំងសត្រូវនៅមាត់ទ្វារក្រុងនោះឯងមិនត្រូវខ្មាសឡើយ» (ខ៥ សូមអានបន្ថែមនៅក្នុង ១២៨:៣)។

ខ្ញុំគិតថា មិនមានខគម្ពីរណាដែលបញ្ជាក់ខ្លាំងពេកក្នុងការទាស់ប្រឆាំងនឹងការពន្យារពេលមានកូននោះទេ។ ពេលខ្លះ ការពន្យារពេលអាចជួយដៃគូជីវិតថ្មោងថ្មីផ្តោតអារម្មណ៍ក្នុងការស្គាល់ និងយល់ពីគ្នាទៅវិញទៅមកបានប្រសើរ

ជាងនេះ នៅក្នុងអំឡុងពេលមានព្យុះភ្លៀងនៅឆ្នាំដំបូងនៃជីវិតអាពាហ៍ពិពាហ៍របស់គេផងដែរ។ ប៉ុន្តែ យើងក៏មិនអាចនិយាយបានថា ព្រះគម្ពីរលើកទឹកចិត្តឲ្យពន្យារពេលបែបនោះបានដែរ។ ប្រហែលការពន្យារពេលក្នុងការមិនយកកូនអស់រយៈពេលជាយូរគឺជាការបង្ហាញឲ្យឃើញពីការបន្ថយតម្លៃនៃសារៈសំខាន់ដែលមានសម្រាប់កូនៗនៅក្នុងព្រះគម្ពីរ ដោយសារកត្តាមួយចំនួនដូចជាមិនមានផ្ទះស្អាត ឬក៏ចំណង់ចិត្តក្នុងការឡើងតំណែងនៅកន្លែងធ្វើការងារ។ ការមើលថែកូនៗគឺជាកិច្ចការដ៏អស្ចារ្យ ប៉ុន្តែមនុស្សជាច្រើននៅសព្វថ្ងៃនេះមិនគិតដូចនេះទេ។ មនុស្សជាច្រើនគិតថា ការមានកូនរារាំងការរីកចម្រើនរបស់ឪពុកម្តាយ ជាពិសេសសម្រាប់អ្នកម្តាយ។

ពេលខ្លះ ឪពុកម្តាយក៏ប្រាប់កូនៗរបស់ខ្លួនថា ពួកគាត់ជាបន្ទុក។ ម្តាយម្នាក់ទំនងជាប្រាប់កូនរបស់គាត់ដូចនេះថា៖ «បើមិនដោយសារកូនទេ នោះម៉ាក់អាចនឹងកាន់តំណែងខ្ពស់ហើយនៅសព្វថ្ងៃនេះ»។ ការលើកឡើងប្រយោគបែបនេះអាចធ្លោយចេញមកពីមាត់របស់ម្តាយដោយគាត់មិនបានប្រុងប្រយ័ត្ន ប្រសិនបើគាត់មានការតូចចិត្តនឹងការលះបង់ការងាររបស់គាត់ដោយសារកូន។ បន្ទាប់មក ម្តាយទំនងជានិយាយថា «ម៉ាក់បានបាត់បង់រូបរាងស្អាតដោយសារតែកូន»។ ជារឿយៗ ឪពុកម្តាយប្រាប់កូនៗរបស់ខ្លួនថា ពួកគាត់គឺជាការរំខានដល់ជីវិតពួកគាត់។ ការបង្ហាញអំពីការខកចិត្តចំពោះការយកកូនមកចិញ្ចឹមក៏អាចធ្លោយចេញពីមាត់របស់ឪពុកម្តាយបានដែរ ប្រសិនបើពួកគាត់មានបញ្ហាធំជាមួយនឹងកូននោះ។ ការលើកឡើងបែបនេះមានឥទ្ធិពលបំផ្លិចបំផ្លាញដល់កុមារ៖ ពាក្យទាំងនោះអាចបង្កប់នៅក្នុងគំនិតរបស់ពួកគាត់ ហើយនៅតែជារបួសដ៏ធ្ងន់ធ្ងរដល់ពួកគាត់ដែរ។ ចំពោះគំនិតដ៏សាមញ្ញ និងមិនមានភាពចាស់ទុំរបស់ពួកគាត់ ពាក្យទាំងនេះផ្តល់ជាសារដល់ពួកគាត់ថា ឪពុកម្តាយរបស់ពួកគាត់មិនសូវជាចង់បានពួកគាត់ប៉ុន្មានទេ ហើយជាលទ្ធផលពួកគាត់ក៏មានអសន្តិសុខយ៉ាងខ្លាំងដែរ។

នៅក្នុងព្រះគម្ពីរ ការមើលថែកូនៗគឺជាទំនួលខុសត្រូវមួយយ៉ាងធំ ហើយក៏

ជាការត្រាស់ហៅដ៏ខ្ពង់ខ្ពស់ពីព្រះជាម្ចាស់ផងដែរ។ សៀវភៅដ៏ល្អរបស់លោក ឃែនថ៍ (Kent) និងលោកស្រី បាបបារ៉ា ហ៊ីយ៉ូស៍ (Barbara Hughes) “វិន័យនៅក្នុងគ្រួសារដែលកោតខ្លាចព្រះ” ("The Disciplines of a Godly Family") បានដាស់តឿនខ្ញុំនូវចំណុចជាច្រើន ដែលមានលើកឡើងនៅក្នុងផ្នែកមួយនេះ។ លោក ហ៊ីយ៉ូស៍ បានដកស្រង់ពីគ្រូគង្វាលនៅក្នុងនិកាយប្រេសប៊ីធៀរៀននៅសតវត្សទី១៩ ដែលជាទេវវិទូម្នាក់ គឺលោក រ៉ូប៊ើត ដេបនី (Robert Dabney) ថា “ការអប់រំកូនៗសម្រាប់ព្រះជាម្ចាស់គឺជាជំនួញដ៏សំខាន់បំផុតនៅលើផែនដីនេះ”។[១] សព្វថ្ងៃនេះ មានតម្រូវការដ៏ធំក្នុងការស្តារឡើងវិញនូវកិត្តិយសនៃការមើលថែកូនៗ។ ការបាត់បង់កិត្តិយសនេះគឺជារោគសញ្ញានៃបញ្ហាមួយ ដែលយើងឃើញនៅក្នុងវប្បធម៌ និងនៅក្នុងក្រុមជំនុំ៖ ការងារផ្ទាល់ខ្លួនមិនមានតម្លៃខ្ពស់ដូចមុនទៀតទេ។ មនុស្សគិតថា មិនមានពេលវេលាសម្រាប់វានៅក្នុងលោកីយ៍ដ៏មមាញឹកនេះទៀតទេ។ ដូច្នេះ ពួកគេក៏និយាយគ្នាច្រើនទាក់ទងទៅនឹងតម្រូវការនៃការបង្កើតឲ្យមានអ្នកជឿថ្មីៗ ការមើលថែអ្នកដឹកនាំវ័យក្មេងៗ និងអ្នកធ្វើការដែលជាគ្រីស្ទបរិស័ទ ប៉ុន្តែគ្មានអ្នកណាហាក់បីដូចជាមានពេលសម្រាប់ការនេះសោះ។ អាកប្បកិរិយាបែបនេះក៏បានជ្រាបចូលក្នុងគំនិតរបស់យើងអំពីភាពជាឪពុកម្តាយផងដែរ។ លោក ហ៊ីយ៉ូស៍ បានហៅការនេះថាជា “គណិតវិទ្យាបោកបញ្ឆោតពីគំនិតលោកីយ៍ ដែលបានរាប់ថា ការវិនិយោគលើជីវិតមនុស្សតែពីរបីនាក់គឺជាការខ្ជះខ្ជាយសក្តានុពលដែលគួរឲ្យស្អប់ខ្ពើមណាស់”។[២]

ការមានកូននាំមកនូវការផ្លាស់ប្រែដ៏ធំនៅក្នុងជីវិតគ្រួសារ។ មានបញ្ហាផ្នែកហិរញ្ញវត្ថុថ្មីៗ និងបញ្ហាជាច្រើនសម្រាប់ឪពុកម្តាយ ជាពិសេសសម្រាប់អ្នកម្តាយ។ ប៉ុន្តែ យើងមិនត្រូវធ្លាក់ទៅក្នុងអន្ទាក់នៃការគិតថា នេះគឺជាបន្ទុកដែលបំផ្លាញជីវិតរស់នៅរបស់យើងនោះទេ។ អាកប្បកិរិយាបែបនោះនឹងមានប្រាប់ជាព័ត៌មានដល់កូនៗយើង ហើយក៏ផ្តល់ផលអាក្រក់ដល់ពួកគាត់យ៉ាងខ្លាំងដែរ។ អ្វីដែលមានតម្លៃខ្លាំងនៅក្នុងជីវិតនេះក៏ត្រូវមានការចំណាយច្រើនដែរ។

នេះគឺជារបៀបដែលយើងមើលអំពីការមើលថែកូនៗ។ វាគឺជាអភ័យឯកសិទ្ធិដ៏អស្ចារ្យមួយ ហើយយើងក៏ស្រឡាញ់កូនៗយើងយ៉ាងខ្លាំងដែរ ហើយក៏មិនអាចយកអ្វីនៅក្នុងលោកីយ៍នេះមកប្ដូរជាមួយពួកគាត់បានទេ ទោះបើការចិញ្ចឹមបីបាច់ពួកគាត់ជាពិបាកក៏ដោយ។

## សូមប្រាប់ឲ្យកូនៗដឹងថាលោកអ្នកសប្បាយចិត្តនឹងពួកគាត់

### ការសប្បាយចិត្តជាមួយនឹងកូន

ការរាប់កូនៗយើងថាជាព្រះពរក៏មានឥទ្ធិពលដល់អាកប្បកិរិយារបស់យើងលើពួកគាត់ផងដែរ។ សាវ័ក ប៉ុល ប្រាថ្នាចង់បាន ធីម៉ូថេ ជាកូនខាងវិញ្ញាណយ៉ាងខ្លាំង ហើយបានសរសេរថា «គឺនឹកចាំពីទឹកភ្នែករបស់អ្នក បានជាខ្ញុំរម្លឹកចង់ឃើញអ្នក ដើម្បីឲ្យខ្ញុំបានពេញជាសេចក្ដីអំណរឡើង» (២ធីម៉ូថេ ១:៤)។ វាជាការសំខាន់ណាស់សម្រាប់ឲ្យកូនៗដឹងថា ឪពុកម្ដាយរបស់ខ្លួនសប្បាយចិត្តនឹងពួកគាត់ ហើយប្រាថ្នាចង់ឃើញពួកគាត់ផងដែរ។ នេះគឺជារបៀបដែលព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ទតមើលមកយើង។ ជារឿយៗ យើងតែងតែនិយាយអំពីរបៀបដែលយើងគួរតែអរសប្បាយក្នុងព្រះជាម្ចាស់ ដែលនោះគឺជាប្រធានបទមួយយ៉ាងធំនៅក្នុងព្រះគម្ពីរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថាយើងមិនបាននិយាយគ្រប់គ្រាន់អំពីរបៀបដែលព្រះជាម្ចាស់សព្វព្រះទ័យនឹងយើងនោះទេ។ ខ្ញុំអាចរកឃើញមាន៦ខគម្ពីរដែលបានលើកឡើងយ៉ាងជាក់លាក់អំពីការនេះ (ទំនុកតម្កើង ៣៥:២៧; ៤១:១១; ៤៤:៣; ១៤៧:១១; ១៤៩:៤; អេសាយ ៦២:៤)។ ខគម្ពីរដែលខ្ញុំស្រឡាញ់ខ្លាំងជាងគេគឺនៅក្នុងកណ្ឌគម្ពីរ សេផានា ៣:១៧ ខនេះបានប្រើពាក្យមានសេចក្ដីរីករាយអរសប្បាយ ហើយក៏មានអត្ថន័យដូចគ្នាផងដែរ «ព្រះយេហូវ៉ាដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្ដាលឯង ទ្រង់ជាព្រះដ៏មានឥទ្ធិឫទ្ធិ ដើម្បីជួយសង្គ្រោះ ទ្រង់នឹងមានសេចក្ដីរីករាយអរសប្បាយចំពោះឯង ទ្រង់នឹងសម្រាកក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ ក៏នឹងអរសប្បាយនឹងឯង ដោយសំឡេង

ច្រៀង»។ វចនានុក្រមនៃភាសាហេព្រើរដែលគេចូលចិត្តប្រើមួយច្បាប់បានផ្ដល់អត្ថន័យលើពាក្យ « អរសប្បាយ» ថាជា «ការស្រែកដោយភាពសប្បាយត្រេកអរ ស្រែកដោយអំណរ»។[៣] តាមពិតទៅ ព្រះគម្ពីរបានបង្រៀនថា ព្រះមានព្រះទ័យរំភើបចំពោះយើងណាស់!

ប្រសិនបើនោះគឺជារបៀបដែលព្រះវរបិតាដែលគង់នៅស្ថានសួគ៌ទតមើលមកកូនៗរបស់ទ្រង់ នោះយើងក៏មានគំរូសម្រាប់ឲ្យឪពុកម្ដាយនៅលើផែនដីនេះគួរមើលចំពោះកូនៗរបស់ខ្លួនដែរហើយ។ ហើយដោយសារព្រះជាម្ចាស់បានប្រទានព្រះបន្ទូល ដែលជារបៀបមួយដ៏សំខាន់ក្នុងការប្រាប់សេចក្ដីពិត នោះយើងត្រូវតែបង្ហាញការអរសប្បាយរបស់យើងចំពោះកូនៗតាមរយៈពាក្យពេចន៍ដែរ។ នៅក្នុងជំពូក៦ ខ្ញុំបានលើកឡើងអំពីរបៀបនៃការសរសើរដែលជួយបំពេញអំណរនៅក្នុងទំនាក់ទំនង។ ដូច្នេះ នៅពេលយើងសរសើរកូនៗយើង នោះយើងបង្កើននូវសេចក្ដីអំណរដល់ពួកគាត់ និងដល់យើងដែរ។ មានគំរូជាច្រើនដែលសាវ័ក ប៉ុល បានបង្ហាញការសប្បាយចិត្តចំពោះកូនៗខាងឯព្រលឹងវិញ្ញាណរបស់គាត់ ដែលមានដូចនេះ៖ «ដូច្នេះ បងប្អូន ជាពួកស្ងួនភ្ងាហើយជាទីរឭក ជាទីត្រេកអរ ហើយជាមកុដរបស់ខ្ញុំអើយ ចូរឈរឲ្យមាំមួនក្នុងព្រះអម្ចាស់ចុះ ឱពួកស្ងួនភ្ងាអើយ» (ភីលីព ៤:១) ហើយ «ដ្បិតតើសេចក្ដីសង្ឃឹម សេចក្ដីអំណរ នឹងមកុដដែលនាំឲ្យយើងខ្ញុំរីករាយឡើង នោះជាអ្វី បើមិនមែនជាអ្នករាល់គ្នានៅចំពោះព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ក្នុងកាលដែលទ្រង់យាងមកប៉ុណ្ណោះ ដ្បិតអ្នករាល់គ្នាជាសិរីល្អ ហើយជាសេចក្ដីអំណររបស់យើងខ្ញុំពិតមែន» (១ថែស្សាឡូនីច ២:១៩-២០)។ កូនៗរបស់យើងគួរតែឮពាក្យពេចន៍ដ៏កក់ក្ដៅ និងមានការគាំទ្រចេញពីបបូរមាត់របស់យើងឲ្យបានញឹកញាប់។

យើងមិនគ្រាន់តែគាំទ្រកូនៗយើងប៉ុណ្ណោះទេ យើងក៏ត្រូវរីករាយនៅពេលដែលពួកគាត់ទទួលបានការគោរពដែរ។ សាវ័ក ប៉ុល បានលើកឡើងថា «បើមួយបានតម្កើងឡើង នោះទាំងអស់នឹងបានរីករាយជាមួយដែរ» (១កូរិនថូស

១២:២៦)។ ការគោរពរាប់អានដល់អ្នកដទៃគឺជាកិច្ចការដែលគ្រីស្ទបរិស័ទធ្វើដោយចិត្តខ្នះខ្នែង។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ខាងឯសេចក្តីរាប់អាន នោះឲ្យខំរាប់អានគេជាមុន» (រ៉ូម ១២:១០)។ ជាពិសេស យើងត្រូវការអនុវត្តការនេះជាមួយនឹងកូនៗរបស់យើង។ យើងគួរតែឆ្លើយតបដោយមានអំណរដែលមិនលាយទឡ្គ្នា នៅពេលពួកគាត់បានដល់ចំណុចជោគជ័យ ឬក៏ការគោរពណាមួយ។ ខ្ញុំបានប្រើប្រាស់ឃ្លាមិនលាយទឡ្គ្នា ពីព្រោះពេលខ្លះនៅពេលដែលអ្នកណាម្នាក់ធ្វើបានល្អ យើងទំនងជាបន្ថែមឃ្លាបញ្ជាក់ពីគុណសម្បត្តិបន្ទាប់ពីយើងបានបង្ហាញសេចក្តីអំណររបស់យើង ដូចជាការលើកឡើងថា «ពេលក្រោយ ចូរព្យាយាមធ្វើឲ្យបានល្អជាងនេះទៀត» ឬក៏ «ឥឡូវនេះ កុំទាន់មានមោទនភាពពេក ឯងគួរថ្វាយសិរីរុងរឿងទាំងអស់ដល់ព្រះជាម្ចាស់»។ ពេលខ្លះ គ្រួសារមិនអាចមានអំណរចំពោះភាពជោគជ័យបានយ៉ាងពេញទីនោះទេ ដោយសារឪពុកម្តាយរវល់តែអួតដល់អ្នកដទៃទៀត។ ខ្ញុំគិតថា វាជាគំនិតដ៏ល្អមួយក្នុងការដែលគ្រួសារចូលរួមអបអរដោយផ្តល់កិត្តិយសនៅក្នុងរបៀបណាមួយ។ គ្រួសារយើងធ្លាប់បានទៅក្រៅញ៉ាំការ៉េមកីនៅពេលកូនៗយើងធ្វើអ្វីមួយបានល្អ។ ការ៉េមកីគឺជាអ្វីមួយដែលគ្រួសាររបស់យើងអាចទៅទិញញ៉ាំបានតែយូរៗម្តងប៉ុណ្ណោះ។

យើងគួរតែមានការអនុវត្តជាក់លាក់មួយចំនួននៅក្នុងផ្ទះ ដែលប្រាប់អំពីគំនិតដែលឪពុកម្តាយអរសប្បាយជាមួយនឹងកូនៗរបស់ខ្លួន។ ចំណុចដំបូង និងចុងក្រោយគេក្នុងមួយថ្ងៃអាចជាការបង្ហាញពីការគាំទ្រចំពោះកូនៗ។ នៅពេលកូនក្រោកពីគេងនៅពេលព្រឹក ឪពុកម្តាយគួរតែស្វាគមន៍ពួកគាត់ដោយអំណរ។ នៅពេលកូនតូចៗចូលគេងនៅពេលយប់ វាសំខាន់ណាស់ដែលឪពុកម្តាយនៅជាមួយគាត់ ដោយអធិស្ឋាន ឬក៏និទានរឿងមុនចូលគេងផងដែរ។ វាជាគំនិតដ៏ល្អប្រសើរដែលឪពុកម្តាយនិយាយពាក្យរាត្រីសួស្តីទៅកាន់កូនៗដែលមានវ័យជំទង់ នៅពេលពួកគាត់ចូលគេង។

នៅពេលឪពុកត្រឡប់មកពីធ្វើការវិញ គាត់អាចបង្ហាញអំពីសេចក្តីអំណរ

មុនគេបង្អស់ដោយប្រាប់ប្រពន្ធរបស់ខ្លួនពេលឃើញនាង។ បន្ទាប់មក គាត់អាចទៅមើលកូនៗរបស់គាត់បាន។ គាត់អាចនិយាយដូចនេះទៅកាន់កូនង៉ែតស្រីតូចរបស់គាត់ថា «តើកូនស្រីសំណព្វចិត្តប៉ាៗនៅឯណា? អ៊ូ កូននៅទីនេះសោះ»! បន្ទាប់មក គាត់អាចសួរសុខទុក្ខនាង ហើយឱបនាង។ ពេលខ្លះ កូនៗពិតជាសប្បាយចិត្តយ៉ាងខ្លាំងចំពោះទម្លាប់ឪពុកដែលបានធ្វើបែបនេះដល់ថ្នាក់ថា ពួកគាត់នឹងរត់ទៅឯមាត់ទ្វារចាំទទួលឪពុក នៅពេលគាត់ត្រឡប់មកពីធ្វើការវិញដែរ។ មិនថាឪពុកម្ដាយរវល់ខ្លាំងប៉ុណ្ណាក៏ដោយ នៅពេលកូនៗចេញពីផ្ទះ ក៏ពួកគាត់ត្រូវតែបញ្ឈប់ការទាំងនោះសិន ដើម្បីទទួលស្គាល់កូនៗ ហើយនិយាយដូចនេះថា «ទៅចុះកូន! ជូនពរឲ្យសប្បាយ»។ ទង្វើទាំងអស់នេះបញ្ជាក់ថា កូនៗពិតជាទីស្រឡាញ់ដល់ឪពុកម្ដាយណាស់។ សម្រាប់ខ្ញុំ ឧទាហរណ៍ចុងក្រោយដែលខ្ញុំលើកឡើងអាចពិបាកធ្វើបន្តិច។ ជាទូទៅ នៅពេលខ្ញុំនៅការិយាល័យរបស់ខ្ញុំនៅផ្ទះ ខ្ញុំមានភាពមមាញឹកក្នុងការរៀនសូត្រ ឬក៏ធ្វើការឆ្លើយឆ្លងសាររបស់ខ្ញុំ។ ខ្ញុំត្រូវតែធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ក្នុងការឈប់ការងារនេះសិន ហើយចំណាយពេលជាមួយកូនៗរបស់ខ្ញុំ (ដែលឥឡូវធំទង់អស់ហើយ) ហើយលាពួកគាត់។

លោក វ៉ារ៉េន វៀសប៊ី (Warren Wiersbe) បានប្រាប់ក្រុមសិស្សដែលជាគ្រីស្ទបរិស័ទមួយក្រុម អំពីប្រធានបទនៃសេចក្ដីអធិស្ឋានដោយចង្អុលបង្ហាញថា ព្រះវរបិតាដែលគង់នៅស្ថានសួគ៌តែងតែព្រះសណ្ដាប់នៅពេលយើងស្រែកហៅរកព្រះអង្គ។ ដើម្បីពន្យល់អំពីការនេះ លោក វៀសប៊ី បានប្រាប់ពួកគាត់ថា អ្នកទទួលភ្ញៀវនៅការិយាល័យនៃព្រះវិហារដែលគាត់ធ្វើជាគ្រូគង្វាលមានបញ្ជីឈ្មោះដែលគាត់បានរៀបចំទុកឲ្យ។ មនុស្សទាំងនេះអាចជួបគាត់បានគ្រប់ពេលទាំងអស់ មិនថាគាត់កំពុងធ្វើអ្វីក៏ដោយ។ ទោះបើគាត់កំពុងប្រជុំជាមួយបុគ្គលិក ឬក៏កំពុងប្រឹក្សាយោបល់ក្ដី ប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមមនុស្សទាំងនេះទូរស័ព្ទមក អ្នកទទួលភ្ញៀវនោះត្រូវហៅលោក វៀសប៊ី ភ្លាមៗតែម្ដង។ នៅផ្នែកខាងលើនៃបញ្ជីនេះគឺជាឈ្មោះសមាជិកគ្រួសាររបស់គាត់។

ទោះបើហាក់បីដូចជាមានរឿងមិនសមហេតុផលសម្រាប់គាត់ក៏ដោយ ក៏លោករៀសប៊ី បាននិយាយថា «ខ្ញុំចង់ឲ្យគ្រួសាររបស់ខ្ញុំដឹងថា ខ្ញុំត្រៀមទទួលពួកគាត់ដែរ»។ បន្ទាប់ពីចប់ថ្នាក់រៀននោះហើយ មានសិស្សម្នាក់បានមកនិយាយនឹងគាត់ថា «តើលោកគ្រូអាចយកខ្ញុំធ្វើជាកូនចិញ្ចឹមបានទេ? ខ្ញុំមិនដែលអាចចូលនិយាយជាមួយឪពុករបស់ខ្ញុំបានទេ ហើយខ្ញុំក៏ត្រូវការការលើកទឹកចិត្តជាច្រើនពីគាត់ដែរ!»។[៤]

ពេលខ្លះ គ្រីស្ទបរិស័ទដែលមិនធ្លាប់មានបទពិសោធន៍ទទួលបានការសប្បាយបែបនេះចេញពីឪពុកម្ដាយរបស់ខ្លួនមានការពិបាកខ្លាំងណាស់ក្នុងការទទួលស្គាល់ថា ព្រះជាម្ចាស់សព្វព្រះទ័យជាមួយពួកគាត់។ ពួកគាត់មិនជឿថា ខ្លួនគឺជាមនុស្សដែលគេសប្បាយរីករាយជាមួយនោះទេ។ ដោយសារមិនធ្លាប់ទទួលបានគំរូនៃការសប្បាយរីករាយចេញពីឪពុកម្ដាយរបស់ខ្លួន នោះពួកគាត់ក៏ពិបាកក្នុងការបង្ហាញអំពីការរីករាយចំពោះកូនៗរបស់ខ្លួនដែរ។ ពួកគាត់គួរតែដឹងអំពីការនេះ ហើយខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការធ្វើនូវអ្វីដែលមិនកើតឡើងដោយធម្មជាតិសម្រាប់ពួកគាត់—គឺការបង្ហាញពីការរីករាយចំពោះកូនៗទៅកាន់ពួកគាត់ផ្ទាល់តែម្ដង។ កូនៗរបស់យើងមិនគួររងទុក្ខ ដោយសារភាពកម្សោយរបស់យើងនោះទេ។ យើងត្រូវតែព្យាយាមយកឈ្នះលើការទាំងនោះ ដូចដែលខ្ញុំនឹងបង្ហាញនៅចុងជំពូកនេះ យើងអាចធ្វើដូចនោះបានដោយសារមានជំនួយពីព្រះជាម្ចាស់។

## *ការចង់ជួយ*

សាវ័ក ប៉ុល បានពណ៌នាយ៉ាងល្អអំពីសេចក្តីស្រឡាញ់របស់គាត់សម្រាប់អ្នកនៅទីក្រុងថែស្សាឡូនីច ដោយប្រៀបធៀបការនោះទៅនឹងអាកប្បកិរិយារបស់ម្ដាយដែលមានចំពោះកូនៗ៖ «យើងខ្ញុំបាននៅកណ្ដាលអ្នករាល់គ្នា ដោយស្លូតបូតវិញ ប្រៀបដូចជាម្ដាយថ្នមកូន ដែលកំពុងនៅបៅ គឺយ៉ាងនោះហើយដែលយើងខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នា ដល់ម៉្លេះបានជាយើងខ្ញុំចូលចិត្ត

ចែកដំណឹងល្អពីព្រះ មកអ្នករាល់គ្នា មិនត្រឹមតែប៉ុណ្ណោះ ក៏ចូលចិត្តចែកទាំងជីវិតយើងខ្ញុំផង ដោយព្រោះអ្នករាល់គ្នាបានត្រឡប់ជាស្ងួនភ្ងាដល់យើងខ្ញុំ» (១ថែស្សាឡូនីច ២:៧-៨)។ មានបីពាក្យដែលសាវ័ក ប៉ុល ប្រើប្រាស់ក្នុងការពណ៌នាបានយ៉ាងល្អអំពីអាកប្បកិរិយារបស់ម្ដាយទៅកាន់កូនៗរបស់គាត់៖ គាត់ «ស្លូតបូត» មិនរឹងរូស និងមិនឆាប់ខឹង គាត់ «បានស្រឡាញ់» ដល់ពួកគេមិននៅឆ្ងាយ ហើយក៏មិនពិបាកទៅដល់ដែរ ហើយកូនៗរបស់គាត់ក៏ជាកូនៗ «ស្ងួនភ្ងា» ដល់គាត់ដែរ ដូច្នេះគាត់មិនប្រព្រឹត្តិដោយមិនសប្បាយចិត្តជាមួយពួកគាត់នោះទេ។ ពាក្យពេចន៍ទាំងនេះសុទ្ធតែបង្ហាញពីសេចក្តីស្រឡាញ់ និងការប្រាថ្នាចង់បាន។ ដើម្បីរក្សាបាននូវអាកប្បកិរិយាដូចនេះ ឪពុកម្ដាយត្រូវតែរក្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងបន្តទទួលយកនូវភាពស្រស់ស្រាយដែលសេចក្តីស្រឡាញ់របស់ទ្រង់បានប្រទានឲ្យ ដូចដែលយើងឃើញជាមួយគ្នានៅក្នុងរឿងស្ត្រីដែលមានអៀមចំអិនម្ហូបនៅក្នុងជំពូក១រួចមកហើយ។

ដោយប្រដាប់ខ្លួនដោយអាកប្បកិរិយាទាំងបីនេះសាវ័ក ប៉ុល បានលើកឡើងថា គាត់បានធ្វើបីចំណុចនៃអ្វីដែលម្ដាយធ្វើដែរ។ អ្នកម្ដាយបានធ្វើការដោយ «ថ្នមកូន» របស់គាត់។ ពាក្យដែលគេបានបកប្រែថា «ថ្នមកូន» មានន័យថា «ថែរក្សា ដោយបង្កប់នូវអត្ថន័យនៃសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ចំពោះ»។[៥] អ្នកម្ដាយមិនមែនគ្រាន់តែមើលថែកូនៗរបស់គាត់ប៉ុណ្ណោះនោះទេ គាត់ក៏បានស្រឡាញ់ថ្នាក់ថ្នមពួកគេ ដែលនេះមានន័យថា គាត់បានបង្ហាញអំពីសេចក្តីស្រឡាញ់ចំពោះពួកគេផងដែរ។ ជាបន្ទាប់ គាត់ក៏ផ្សាយដំណឹងល្អដល់ពួកគេ។ នេះគឺជាការដ៏ល្អបំផុតដែលឪពុកម្ដាយអាចធ្វើបានសម្រាប់កូនៗរបស់ខ្លួន—ក្នុងការជួយធានាអំពីភាពអស់កល្បជានិច្ចដ៏អស្ចារ្យសម្រាប់ពួកគេ។ ជាចំណុចចុងក្រោយ សាវ័ក ប៉ុល និងអ្នករួមព័ន្ធកិច្ចជាមួយគាត់ «ក៏ចូលចិត្តចែកទាំងជីវិតយើងខ្ញុំ» ជាមួយអ្នកនៅក្រុងថែស្សាឡូនីចផង។ អ្នកម្ដាយធ្វើការទាំងនេះបានយ៉ាងល្អណាស់។ ប៉ុន្តែ សាវ័ក ប៉ុល គឺជាឪពុកខាងឯព្រលឹងវិញ្ញាណ។ ការនេះក៏ផ្តល់ការណែនាំដល់ឪពុកទាំងអស់ថា ក៏គួរ

តែថែរក្សាកូនៗរបស់ខ្លួននៅក្នុងរបៀបដូចនេះផងដែរ។ ឪពុកម្ដាយ ដោយរួម ទាំងឪពុកផងដែរ ត្រូវតែចូលទៅឲ្យបានជិតកូនៗរបស់ខ្លួន និងមានចំណែក ចែកចាយពីជីវិតរបស់គាត់ជាមួយពួកគេ។

បើនិយាយដោយសង្ខេបទៅ ចូរយើង «ដេញតាមសេចក្តីស្រឡាញ់ [ជា របស់យើង]» (១កូរិនថូស ១៤:១) នៅក្នុងទំនាក់ទំនងជាមួយកូនៗចុះ។ បន្ទាប់មក យើងអាចធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីបំពេញបំណង ប្រាថ្នានោះ ទោះបើថាវារំខានដល់យើង និងមានការនឿយហត់ក៏ដោយ។ ឧទាហរណ៍ដ៏ល្អបំផុតសម្រាប់ការនេះគឺសេចក្តីស្រឡាញ់របស់ម្ដាយ ដែល ធ្វើឲ្យគាត់បន្តនៅដល់យប់ជ្រៅពីមួយយប់ទៅមួយយប់ទៀត ដើម្បីមើលកូន ពេលកូនឈឺ។ ប៉ុន្តែ ឪពុកទាំងអស់ក៏ត្រូវមានសេចក្តីស្រឡាញ់ដូចនោះដែរ។ កាលកូនៗរបស់យើងនៅតូចនៅឡើយ ពួកគាត់តែងតែសូមឲ្យខ្ញុំទៅយកពួក គាត់បន្ទាប់ពីជប់លៀងហើយ ឬក៏ការប្រជុំនៅយប់ជ្រៅ។ ឬថា ពួកគាត់ក៏សូម ឲ្យខ្ញុំជូនពួកគាត់ទៅស្ថានីយរថភ្លើង នៅពេលព្រឹកព្រលឹម—វាមិនងាយស្រួល ទេសម្រាប់អ្នកចូលចិត្តនៅដល់យប់ជ្រៅដូចខ្ញុំ! ហើយទោះបីជាខ្ញុំអស់កម្លាំង និងចង់បន្តគេងនៅពេលនោះក៏ដោយ ក៏ខ្ញុំអាចរៀបចំហើយជាស្រេច ដើម្បីធ្វើ ការទាំងនេះដែរ។ ខ្ញុំបានព្យាយាមប្រាប់ពួកគាត់ថា ខ្ញុំចង់ធ្វើការទាំងអស់នេះ ជាការដែលខ្ញុំសប្បាយចិត្តនឹងធ្វើវា។ ហើយភាពសប្បាយរីករាយគឺជាបទ ពិសោធន៍ដែលខ្ញុំទទួលបានពីការដែលខ្ញុំបានធ្វើការទាំងអស់នេះជានិច្ច។ ការស្រឡាញ់ត្រូវការការលះបង់ខ្លាំងណាស់ ប៉ុន្តែយើងមិនសង្កត់ធ្ងន់លើតម្លៃ នោះទេ ពីព្រោះយើងដឹងថាវាគឺជារឿងដ៏ល្អដែលយើងចង់ធ្វើ ជាអ្វីដែលមាន តម្លៃស័ក្តិសមក្នុងការបង់ថ្លៃ។ ជាទូទៅ បន្ទាប់ពីបានធ្វើការនេះហើយ យើង តែងតែសប្បាយចិត្តជាខ្លាំងដែលយើងបានធ្វើ។

សូមស្រមៃអំពីឪពុកម្នាក់ដែលបម្រើជាអ្នកដឹកនាំស្ម័គ្រចិត្តនៅក្នុងក្រុមជំនុំ។ កូនប្រុសរបស់គាត់កំពុងរត់ប្រណាំងនៅក្នុងការប្រកួតតាមតំបន់ដ៏សំខាន់មួយ ហើយបានឈានចូលដល់វគ្គផ្តាច់ព្រ័ត្រ។ ការប្រកួតចាប់ផ្តើមនៅថ្ងៃសៅរ៍នៅ

ម៉ោង៤:០០ល្ងាច។ ប៉ុន្តែ ឪពុករបស់គាត់ក៏មានការប្រជុំនៃសមាគមនៅក្នុងក្រុមជំនុំនៅម៉ោង២:០០ ដែលគាត់ត្រូវធ្វើជាប្រធានផងដែរ។ គាត់បានពន្យល់អំពីស្ថានភាពនោះទៅកាន់កូនប្រុសរបស់គាត់ ហើយប្រាប់កូនថាគាត់នឹងព្យាយាមទៅដល់វគ្គផ្តាច់ព្រ័ត្រនោះ ប៉ុន្តែគាត់ក៏បានលើកឡើងផងដែរថា គាត់ក៏ទំនងជាមិនអាចទៅបានដែរ។ គាត់បានទូរស័ព្ទទៅប្រាប់សមាជិកទាំងអស់នៅថ្ងៃសុក្រ ដោយប្រាប់ពួកគេអំពីស្ថានភាពរបស់គាត់ ហើយសូមឲ្យគេបានមកដល់កន្លែងប្រជុំទាន់ពេលវេលា។ គាត់ក៏បានធ្វើដូចគ្នានោះ នៅថ្ងៃសៅរ៍ពេលព្រឹកផងដែរ។

នៅថ្ងៃសៅរ៍ គាត់អាចចាប់ផ្តើមកិច្ចប្រជុំទាន់ពេលវេលា ហើយបញ្ចប់នៅម៉ោង៣:៣០។ ឪពុកប្រញាប់ទៅឯកីឡាដ្ឋានដែលជាកន្លែងដែលគេប្រកួតតាមដែលអាចធ្វើទៅបានដោយមិនបានល្មើសនឹងល្បឿនកំណត់បើកបរនោះទេ (ខ្ញុំលើកឡើងដូចនេះដោយសារមានពេលមួយ នៅពេលដែលខ្ញុំទៅចូលរួមការប្រកួតរបស់កូនស្រីខ្ញុំ ខ្ញុំបានល្មើសនឹងល្បឿនកំណត់បើកបរ ហើយត្រូវបានប៉ូលិសបានឃាត់)។ គាត់បានចតឡានទុក រត់ទៅឯទីលានប្រកួត ហើយបានទៅដល់ទីនោះចំពេលដែលកូនរៀបនឹងចាប់ផ្តើមរត់ប្រណាំង។ ខណៈពេលគាត់កំពុងរត់ កូនក៏បានឮឪពុកខ្លួនស្រែកឡើងថា «រត់កូន! រត់!» ដោយសារពាក្យសម្តីរបស់ឪពុកដែលបានជំរុញចិត្តគាត់ គាត់ក៏បានបោះជំហានទៅមុខយ៉ាងលឿនហើយក៏បានទទួលជ័យជម្នះនៅក្នុងការប្រកួតនោះ។

ឪពុកបានរត់ទៅរកកូន ដើម្បីអបអរសាទរគាត់។ កូនប្រុសបានកត់សម្គាល់ថា ឪពុករបស់គាត់ដកដង្ហើមដង្ហក់ជាងគាត់ទៅទៀត ហើយគាត់បានសួរឪពុកថា «ខ្ញុំជាអ្នករត់នៅក្នុងការប្រណាំងនេះ ហេតុអ្វីបានជាប៉ាដង្ហក់បែបនេះ?» ឪពុកក៏បានឆ្លើយថា «ប៉ាត្រូវមកដល់ទីនេះឲ្យទាន់ពេលកូនប្រណាំង ដូច្នេះប៉ាក៏បានរត់ដែរ»។ កូនប្រុសម្នាក់នោះប្រហែលជានឹងមិនខឹងចំពោះការចូលរួមរបស់ឪពុកគាត់នៅក្នុងក្រុមជំនុំទេ។ គាត់ដឹងថា ទោះបើឪពុកគាត់មានការយកចិត្តទុកដាក់សម្រាប់ក្រុមជំនុំក៏ដោយ ក៏គាត់សុខចិត្តលះបង់សម្រាប់

គាត់ នៅពេលមានពេលវេលាសំខាន់ផងដែរ។[៦] ការធ្វើការបន្ថែមក្នុងការហៅទូរស័ព្ទទៅសមាជិកនៅក្នុងសមាគមនៅថ្ងៃសុក្រ និងថ្ងៃសៅរ៍ ការប្រញាប់ប្រញាល់ទៅឯកីឡាដ្ឋាន ហើយការរត់ទៅឯទីប្រណាំងគឺជាផ្នែកនៃឈើឆ្កាងដែលមានជាមួយការព្យាយាមស្តាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងគ្រប់ផ្នែកទាំងអស់។ នេះជាអ្វីដែលខ្ញុំបានលើកឡើងនៅក្នុងជំពូក៤ ដែលថាតុល្យភាពនៃជីវិតរបស់យើងគឺតែងតែនៅឯឈើឆ្កាងរបស់យើង។ ប៉ុន្តែ សម្រាប់គ្រីស្ទបរិស័ទ ឈើឆ្កាងគឺជាអ្វីមួយដែលវិជ្ជមាន។ ឈើឆ្កាងមិនមែនជាអ្វីមួយដែលយើងមានការសោកស្តាយចំពោះនោះទេ។

*ពេលយើងមិនអាចនៅទីណាមួយ ដើម្បីគាំទ្រពួកគាត់បាន*

ពេលខ្លះ យើងមិនអាចធ្វើអ្វីដែលកូនៗរបស់យើងចង់ឲ្យយើងធ្វើសម្រាប់ពួកគាត់បាននោះទេ ដោយសារការងារព័ន្ធកិច្ច ឬក៏កាតព្វកិច្ចមួយចំនួនរបស់យើង។ ការនេះបានក្លាយជារឿងពិតដ៏គួរឲ្យសោកស្តាយនៅក្នុងជីវិតរបស់ខ្ញុំ ហើយក៏ជារឿងមួយដែលមានចំណុចឈឺចាប់បំផុតនៃការធ្វើដំណើរព័ន្ធកិច្ចរបស់ខ្ញុំដែរ។ ដោយសារកាលវិភាគនៃការធ្វើដំណើរទៅក្រៅស្រុករបស់ខ្ញុំបានពេញប្រហែលជាពីរទៅបីឆ្នាំមុន ខ្ញុំមិនអាចមានការអនុគ្រោះសម្រាប់ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងគ្រួសារបាន ដែលខ្ញុំទើបតែដឹងព័ត៌មាននោះទេ។ មិនមែនគ្រាន់តែអស់អ្នកដែលបម្រើនៅក្នុងព័ន្ធកិច្ចប៉ុណ្ណោះទេ ប៉ុន្តែមនុស្សរវល់ទាំងអស់គ្នាសុទ្ធតែមានពេលដែលពួកគាត់ធ្វើឲ្យកូនៗខកចិត្ត ដោយសារពួកគាត់មិនអាចទៅចូលរួមកម្មវិធីសំខាន់ៗបាន។

នៅពេលដែលយើងដឹងថា យើងមិនមានសមត្ថភាពទៅធ្វើអ្វីមួយ ឬក៏ទៅកន្លែងណាដែលកូនៗយើងចង់ឲ្យទៅ អ្វីដែលអាក្រក់បំផុតដែលយើងអាចធ្វើបាននោះគឺ ច្រឡោតដាក់ពួកគាត់ដោយនិយាយបែបនេះថា៖ «តើកូនមិនដឹងថា ប៉ាត្រូវធ្វើព័ន្ធកិច្ចព្រះដែរឬទេ?» ផ្ទុយទៅវិញ យើងគួរបង្ហាញអំពីទុក្ខព្រួយដែលកើតចេញពីដួងចិត្ត ដោយសារយើងមិនមានសមត្ថភាពធ្វើនូវអ្វីដែល

កូនៗយើងប្រាថ្នាចង់ឲ្យយើងធ្វើ។

សាវ័ក ប៉ុល ចង់ទៅសួរសុខទុក្ខក្រុមជំនុំថែស្សាឡូនីច ដោយសារពួកគាត់ត្រូវការការដឹកនាំពីគាត់ នៅពេលដែលពួកគាត់កំពុងប្រឈមមុខនឹងបញ្ហាពិបាកៗមួយចំនួន។ គាត់បានលើកឡើងថា «នោះយើងខ្ញុំមានចិត្តសង្វាតរម្លឹកចង់ឃើញមុខអ្នករាល់គ្នាវិញជាខ្លាំង» (១ថែស្សាឡូនីច ២:១៧)។ ប៉ុន្តែគាត់មិនអាចទៅបាន។ ដូច្នេះ ជាដំណោះស្រាយលើភាពរអាក់រអួល គាត់ក៏ជ្រើសរើសនៅតែឯងនៅក្រុងអាថែន ហើយក៏ចាត់ឲ្យលោក ធីម៉ូថេ ទៅតំណាងគាត់។ គាត់បានមានប្រសាសន៍ថា «ដូច្នេះ កាលទ្រាំមិនបានទៀត នោះយើងខ្ញុំបានគិតថា គួរឲ្យយើងខ្ញុំនៅក្រុងអាថែនតែម្នាក់ឯងចុះ ដើម្បីនឹងចាត់ធីម៉ូថេជាបងប្អូន គឺជាអ្នកបម្រើនៃព្រះ ដែលបានធ្វើការជាមួយនឹងយើងខ្ញុំ ក្នុងដំណឹងល្អនៃព្រះគ្រីស្ទ ឲ្យគាត់បានតាំងអ្នករាល់គ្នាឡើងជាមាំមួន ហើយជួយចំរើនខាងឯសេចក្តីជំនឿផង» (៣:១-២)។ បន្ទាប់មក គាត់ក៏បន្ថែមថា «យើងខ្ញុំទូលអង្វរដោយទទូចទាំងយប់ទាំងថ្ងៃ សូមឲ្យបានឃើញមុខអ្នករាល់គ្នា ហើយឲ្យបានបំពេញសេចក្តីអ្វីដែលខ្វះ ខាងឯសេចក្តីជំនឿរបស់អ្នករាល់គ្នាផង» (ខ១០)។ គាត់បានបង្ហាញអំពីទុក្ខព្រួយដ៏ធំមួយនៃការមិនអាចទៅទីនោះបាន ហើយបានធ្វើអ្វីទាំងអស់តាមដែលគាត់អាចធ្វើបាន ដើម្បីស៊ីសងគ្នានឹងការអវត្តមានរបស់គាត់។

ការទទួលសញ្ញាប័ត្ររបស់កូនស្រីខ្ញុំពីមហាវិទ្យាល័យគឺជាព្រឹត្តិការណ៍ដ៏ធំមួយនៅក្នុងគ្រួសារយើង។ គាត់បានបញ្ចប់ការសិក្សាដោយមានពិន្ទុខ្ពស់ ខ្ពស់ជាងឪពុករបស់គាត់ទៅទៀត! នេះគឺជាអំណរដ៏ធំមួយចំពោះខ្ញុំ។ ប៉ុន្តែ ខ្ញុំមិនមានសមត្ថភាពចូលរួមព្រឹត្តិការណ៍នោះ ពីព្រោះខ្ញុំទៅប្រទេសអង់គ្លេស។ ដូចមហាវិទ្យាល័យនានានៅក្នុងប្រទេសស្រីលង្កា គេប្រាប់ថ្ងៃពិធីទទួលសញ្ញាបត្រក្នុងពេលវេលាខ្លី ហើយខ្ញុំក៏បានរៀបចំគម្រោងធ្វើដំណើររួចបាត់ទៅហើយ។ នៅពេលនោះ យើងមិនមានមធ្យោបាយទាក់ទងគ្នាដូចដែលយើងមានឥឡូវនោះទេ ដូចជា Skype និង WhatsApp ប៉ុន្តែខ្ញុំបានផ្ញើសារទៅកាន់កូនស្រី

ខ្ញុំ ដោយរៀបរាប់អំពីការឈឺចិត្តរបស់ខ្ញុំ ដែលមិនអាចចូលរួមបាន និងអំពីការពេញចិត្តដ៏ធំរបស់ខ្ញុំ ទាក់ទងនឹងចំណុចដែលថាគាត់បានធ្វើល្អណាស់។ ខ្ញុំនៅចាំសារដែលគាត់បានឆ្លើយឆ្លងមកវិញ។ ខ្ញុំសង្ឃឹមថា ការឈឺចាប់ដែលគាត់មាន ដោយសារខ្ញុំមិនអាចចូលរួមបាន នោះគាត់ក៏បានទទួលការបន្ថយតាមរយៈការរៀបរាប់នៃការខូចចិត្តរបស់ខ្ញុំដែរ។

ទោះជាយ៉ាងណាក៏ដោយ មិនថាយើងខិតខំប្រឹងប្រែងប៉ុណ្ណា ក៏ពេលខ្លះសមាជិកគ្រួសារយើងនៅតែមិនយល់អំពីការលះបង់របស់យើងធ្វើ ហើយនៅតែមិនសប្បាយចិត្តចំពោះអ្វីដែលយើងបានធ្វើនៅក្នុងព័ន្ធកិច្ចរបស់យើងដែរ។ វាឈឺខ្លាំងពេកសម្រាប់ពួកគាត់។ យើងគួរឲ្យសមាជិកគ្រួសារយើងមានសេរីភាពក្នុងការជំទាស់ជាមួយនឹងយើង ហើយឲ្យពួកគាត់រៀបរាប់អំពីមូលហេតុដែលមិនឯកភាព ដោយមិនធ្វើឲ្យពួកគាត់ឈឺចាប់ តាមរយៈការខឹងរបស់យើងអំពីចំណុចអសមត្ថភាពរបស់ពួកគាត់ក្នុងការយល់។ នេះគឺជារឿងឯកា និងជាឈើឆ្កាងដែលឈឺចាប់ក្នុងការទ្រទ្រង់។ ព្រះយេស៊ូវក៏ត្រូវឆ្លងកាត់ការនេះដែរ។ លោក ម៉ាកុស បានសរសេរថា «ហើយមានមនុស្សប្រជុំគ្នាទាំងហ្វូងម្តងទៀត ដល់ម៉្លេះបានជាទ្រង់ ព្រមទាំងពួកសិស្សពុំអាចនឹងបរិភោគបានឡើយ» (ម៉ាកុស ៣:២០)។ នេះហាក់បីដូចជាចំណុចសម្រាប់សមាជិកគ្រួសាររបស់ព្រះយេស៊ូវ។ លោក ម៉ាកុស បានបន្តលើកឡើងថា «ដ្បិតគេស្មានថាទ្រង់វង្វេងស្មារតីហើយ» (ខ២១)។ មានមនុស្សជាច្រើនបានទទួលព្រះពរតាមរយៈការលះបង់របស់ព្រះយេស៊ូវ ប៉ុន្តែអស់អ្នកដែលនៅជិតទ្រង់បំផុតមិនបានឲ្យតម្លៃលើការនោះទេ។ ខគម្ពីរបន្ទាប់ពណ៌នាអំពីការឆ្លើយតបកាន់តែសាហាវទៅកាន់ព្រះយេស៊ូវ៖ «ឯពួកអាចារ្យ ដែលចុះមកពីក្រុងយេរូសាឡិម គេនិយាយឡើងថា អ្នកនោះមានអារក្សបេលសេប៊ូលចូល វាដេញអារក្ស ដោយអាងមេអារក្សទេ» (ខ២២)។ ការធ្វើជាអ្នកដឹកនាំគឺជាការត្រាស់ហៅដែលពិបាក និងត្រូវមានការលះបង់ច្រើន។ មិនថាយើងឈឺចាប់ប៉ុណ្ណាក៏ដោយ ក៏យើងត្រូវឆ្លើយតបដោយមានការគ្រប់គ្រងចិត្ត នៅពេលដែលយើងជួបប្រទះនូវការយល់ច្រឡំ

ហើយព្យាយាមគេចចេញពីការបង្កការឈឺចាប់បន្ថែមទៀតទៅកាន់អស់អ្នកដែលយើងស្រឡាញ់។

## *ការរក្សាសេចក្តីសន្យា*

ទិដ្ឋភាពនៃចំណុចដ៏សំខាន់មួយទៀតរបស់យើងទៅកាន់កូនៗគឺ ការរក្សាសេចក្តីសន្យាដែលយើងធ្វើទៅកាន់ពួកគាត់។ ទាំងព្រះយេស៊ូវ និងលោកយ៉ាកុប បានលើកឡើងថា យើងមិនចាំបាច់ស្បថទេ ពីព្រោះពាក្យថា “បាទ/ចាស ឬក៏ទេ” គឺគ្រប់គ្រាន់ហើយ (ម៉ាថាយ ៥:៣៣-៣៧; យ៉ាកុប ៥:១២)។ ការខូចខាតដែលកើតឡើងតាមរយៈការលេបសេចក្តីសន្យាម្តងហើយម្តងទៀតពីឪពុកម្តាយមានការស៊ីជម្រៅខ្លាំងជាងការខូចចិត្តដែលពួកកូនទទួលបទពិសោធន៍ តាមរយៈការមិនរក្សាសេចក្តីសន្យាតែមួយទៅទៀត។ ការបរាជ័យដូចនេះប្រាប់ទៅកាន់កូនៗនូវគំនិតដែលថា បុគ្គលដែលពួកគាត់មានការទុកចិត្តលើខ្លាំងជាងគេ គឺមិនអាចទុកចិត្តបានទេ។ ការនេះអាចនាំឲ្យមានជាលទ្ធផលនៃការមិនមានសន្តិភាពយ៉ាងខ្លាំង ដោយធ្វើឲ្យកូនៗឈឺចាប់ក្នុងរបៀបដែលជះឥទ្ធិពលលើពួកគាត់អស់រយៈពេលពេញមួយជីវិតរបស់គាត់។ ពួកគាត់អាចមានការពិបាកក្នុងការទុកចិត្តអ្នកដទៃ ឬក៏ទំនងជាមានប្រតិកម្មខ្លាំងពេក នៅពេលដែលអ្នកនៅជុំវិញខ្លួនប្រព្រឹត្តដោយមិនអាចទុកចិត្តបាន។ ពួកគាត់ក៏អាចមានការពិបាកក្នុងការជឿថា ខ្លួនអាចទុកចិត្តលើព្រះជាម្ចាស់បាន។ ឪពុកម្តាយគួរព្យាយាមមានភាពស្មោះត្រង់ដូចព្រះវរបិតារបស់ខ្លួនដែលគង់នៅស្ថានសួគ៌ដែរ ដែលព្រះអង្គរក្សានូវរាល់គ្រប់សេចក្តីសន្យារបស់ទ្រង់។

ពេលខ្លះ ឪពុកម្តាយសន្យាដោយមានភាពល្ងីល្ងើ ពីព្រោះវាពិបាកក្នុងការរក្សាសេចក្តីសន្យានោះ។ ប៉ុន្តែ ប្រសិនបើពួកគាត់បានសន្យា នោះពួកគាត់ត្រូវធ្វើទាំងអស់តាមដែលអាចធ្វើបាន ដើម្បីបំពេញវា ទោះបើវាមានន័យថាហត់ ឬក៏ពិបាកខ្លាំងប៉ុណ្ណាក៏ដោយ។ យើងទ្រាំទ្រការនឿយហត់ និងភាពលំបាកដោយសារយើងស្រឡាញ់កូនយើង។ ការនេះគួរធ្វើឲ្យយើងប្រុងប្រយ័ត្ន ក្នុង

ការធ្វើសេចក្តីសន្យាដែលយើងមិនអាចបំពេញបាន។ ពេលខ្លះ យើងអាចមានសមត្ថភាពក្នុងការបំពេញសេចក្តីសន្យានៅពេលក្រោយ ឬក៏ក្នុងរបៀបណាផ្សេងទៀត។ ឧទាហរណ៍ ឪពុកចាំបាច់ត្រូវមានការចូលរួមក្នុងការប្រជុំមួយដែលមិនអាចអវត្តមានបាន ដូច្នេះគាត់ត្រូវលុបចោលការទៅលេងសមុទ្រជាមួយនឹងគ្រួសារសិន ប៉ុន្តែគាត់ញែកពេលទំនេរក្នុងកាលវិភាគរបស់គាត់ដើម្បីធ្វើដំណើរ។ កូនៗរបស់គាត់ឃើញថា ខ្លួនអាចទុកចិត្តលើឪពុកបាន។ គាត់មិនភ្លេច។ គាត់ព្យាយាមរហូតទាល់តែគាត់មានសមត្ថភាពធ្វើនូវអ្វីដែលគាត់បានសន្យា។

ជាថ្មីម្តងទៀត នៅពេលដែលយើងមានការបង្ខំក្នុងការមិនរក្សាសេចក្តីសន្យាដោយសារកាលៈទេសៈដែលមិនអាចគេចផុតបាន នោះយើងគួរផ្តោតលើទុក្ខព្រួយ ដែលការផ្លាស់ប្តូរបានធ្វើមកលើយើង ជាជាងផ្តោតលើការមិនអាចគេចផុតបាននៃកាលៈទេសៈនោះវិញ។ យើងមិនគួរផ្តោតលើប្រយោគដូចជា “ឱអូនអើយ បងពិតជាចង់ទៅមែន។ ប៉ុន្តែ វាមិនអាចទៅរួចបានទេ។ បងសោកស្តាយណាស់”។ យើងត្រូវតែចងចាំថា ប្រសិនបើយើងនៅបន្តប្រាប់កូនៗយើងថា យើងមិនអាចធ្វើអ្វីដែលពួកគាត់ចង់ធ្វើបាន ដោយសារយើងកំពុងតែធ្វើការថ្វាយព្រះជាម្ចាស់ នោះកូនៗអាចមានភាពល្វីងជូរចត់ចំពោះការងារព្រះ។ ពួកគាត់អាចរាប់ទ្រង់ថាជាអ្នកសម្លាប់អំណររបស់ពួកគាត់!

## *ការចំណាយពេលជាមួយនឹងកូនៗរបស់យើង*

មានចំណុចតិចទេ ដែលបង្ហាញសេចក្តីស្រឡាញ់ទៅកាន់កូនៗរបស់យើងជាជាងការចំណាយពេលជាមួយនឹងពួកគាត់។ នេះគឺជារបៀបដែលឪពុកម្តាយចែករំលែកតម្លៃទៅកាន់កូនៗ។ នៅពេលដែលព្រះយេស៊ូវបានជ្រើសរើសពួកសាវ័កទាំង១២នាក់ ដើម្បីធ្វើជាក្រុមមូលដ្ឋានរបស់ទ្រង់ ការនោះគឺដើម្បី “ឲ្យបាននៅជាមួយនឹងទ្រង់” (ម៉ាកុស ៣:១៤)។ មូលហេតុពីរយ៉ាងទៀតដែលបានលើកឡើងគឺទាក់ទងទៅនឹងព័ន្ធកិច្ច៖ ប្រកាស ប្រោសជំងឺឲ្យ

ជា (ខ១៤ខ-១៥)។ ពេលខ្លះ ឪពុកម្តាយលើកឡើងថា ពួកគាត់មានពេលវេលាល្អជាមួយនឹងកូនៗ ជាជាងចំណាយពេលច្រើនជាមួយគ្នា។ ជាមួយនឹងកូនៗ ពេលវេលាល្អតម្រូវឲ្យមានពេលវេលាច្រើន។

លោកស្រី ដូរ៉ូធី (Dorothy) និងលោក អែមម័រ ផាធ័រសិន (Armour Patterson) បានលើកជាសម្រង់សម្ដីចេញពីសៀវភៅ "ការដេញតាមរបស់ស្ត្រីក្នុងការមានភាពស្មើគ្នាក្នុងសេដ្ឋកិច្ច" ("Women's Quest for Economic Equality") ដែលបានបោះពុម្ពនៅឆ្នាំ១៩៨៨ ដែលជាសៀវភៅមួយដែលបានអះអាងថា តាំងពីឆ្នាំ១៩៧០មក ពេលវេលារបស់កូនជាមួយនឹងឪពុកម្តាយបានធ្លាក់ចុះរហូតដល់១០ម៉ោងក្នុងមួយអាទិត្យ។[៧] ខ្ញុំមិនដឹងថា តើភាពពេញនិយមនេះបានបន្តក្នុងល្បឿននេះ និងថាមានតួលេខអ្វីក្នុងផ្នែកនៃពិភពលោកខ្ញុំទេ ប៉ុន្តែនេះគឺជាភស្តុតាងនៃលំនាំដែលគួរឲ្យភ្ញាក់ផ្អើលដែលយើងឃើញនៅពាសពេញពិភពលោក។ ក្នុងពេលថ្មីៗនេះ ឪពុកម្តាយក៏ត្រូវមានការតយុទ្ធជាមួយនឹងការប្រកួតប្រជែងជាមួយការចំណាយពេលនៅពីមុខកុំព្យូទ័រ និងកញ្ចក់ទូរទស្សន៍ដែរ។ យើងនឹងលើកឡើងអំពីប្រធានបទនេះនៅជំពូកបន្ទាប់។ សម្រាប់ឥឡូវនេះ យើងត្រូវតែលើកឡើងថា ការដែលកូនចំណាយពេលវេលាខ្លះមើលទូរទស្សន៍ ឬក៏កុំព្យូទ័រក៏អាចទំនងជានាំឲ្យឪពុកម្តាយមានការធូរស្រាលខ្លះដែរ ប៉ុន្តែមិនអាចជំនួសឲ្យការដែលឪពុកម្តាយលេងដោយផ្ទាល់ជាមួយនឹងកូនទេ។ យើងមិនគួរប្រើប្រាស់ហ្គេមកុំព្យូទ័រ និងកញ្ចក់ទូរទស្សន៍ទុកជាការងាយស្រួល និងរបៀបមើលកូនក្នុងតម្លៃថោកឡើយ![៨]

លោកបណ្ឌិត ឡាលីត មែនឌីស (Lalith Mendis) ដែលជាមិត្តភក្តិរបស់ខ្ញុំ ដែលធ្លាប់ធ្វើការជាគ្រូបង្រៀននៅមហាវិទ្យាល័យពេទ្យ ហើយឥឡូវនេះគឺជាគ្រូគង្វាលម្នាក់ គាត់មានចំណាប់អារម្មណ៍យ៉ាងពិសេសមកលើការលូតលាស់ទាក់ទងនឹងក្មេងៗ។ គាត់បានប្រាប់ខ្ញុំថា មានទំនាក់ទំនងជិតស្និទ្ធគ្នារវាងពេលវេលាដែលឪពុកម្តាយចំណាយពេលនិយាយជាមួយនឹងកូនៗ និងការដែលកូនៗលូតលាស់ដោយមានសុខភាពល្អ ជាពិសេសក្នុងផ្នែកនិយាយ

ស្តី។ គាត់បានលើកឡើងថា ជារឿយៗ មូលហេតុដែលមានបញ្ហាផ្នែកនិយាយស្តីគឺដោយសារម្តាយមិនបានចំណាយពេលវេលាគ្រប់គ្រាន់ក្នុងការនិយាយលេងជាមួយនឹងកូនៗ។ មានទិដ្ឋភាពគន្លឹះក្នុងការនិយាយស្តីបែបជាបុគ្គលដែលមិនមាននៅក្នុងកញ្ចក់ទូរទស្សន៍ ឬក៏ការនិយាយស្តីលើអេក្រង់ទូរស័ព្ទ។[៩]

កូនៗអាចទទួលសុវត្ថិភាពបានក្នុងការទទួលសេចក្តីស្រឡាញ់ តាមរយៈការចំណាយពេលយ៉ាងយូរជាមួយឪពុកម្តាយរបស់ខ្លួន ជាពិសេសជាមួយម្តាយ។ នេះគឺជាមូលហេតុដែលម្តាយគួរចំណាយពេល វេលាច្រើនជាមួយកូនៗរបស់ខ្លួនក្នុងអំឡុងពេល៥ឆ្នាំដំបូងនៃជីវិតរបស់ពួកគាត់។ ទោះបើយាយតា អ្នកមើលថែក្មេងៗ ស្ថាប័នមើលថែពេលថ្ងៃ និងសាលាមួយចំនួនអាចជួយកុមារបានក៏ពិតមែន តែក៏មិនមានអ្វីអាចជំនួសការយកចិត្តទុកដាក់ពីម្តាយបាននោះដែរ។ ដូច្នេះ នេះគួរជាកត្តាដ៏សំខាន់មួយដែលមានឥទ្ធិពលលើកិច្ចការងារ ដែលម្តាយវ័យក្មេងគ្រប់គ្នាគួរតែធ្វើ។ ម្តាយដែលជាគ្រីស្ទបរិស័ទជាច្រើនបានជ្រើសរើសពន្យារពេលរបស់ខ្លួនក្នុងការងារ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ជាមួយកូនៗរបស់ខ្លួនក្នុងអំឡុងឆ្នាំដំបូងៗរបស់ពួកគាត់។ ខ្ញុំមានមិត្តភក្តិម្នាក់ដែលប្រពន្ធរបស់គាត់បានសម្រាកជាច្រើនឆ្នាំពីការងារ ទាក់ទងជាមួយព័ន្ធកិច្ចគ្រីស្ទបរិស័ទ។ មិត្តភក្តិរបស់គាត់ជាច្រើនមានអារម្មណ៍ថា គាត់បានធ្វើការសម្រេចចិត្តខុសយ៉ាងខ្លាំង។ កូនៗពេញវ័យរបស់គាត់ ដែលមានការសប្បាយចិត្តឥឡូវនេះ បានធ្វើទីបន្ទាល់អំពីប្រាជ្ញាក្នុងការសម្រេចចិត្តរបស់គាត់។

ឪពុកក៏គួរតែចំណាយពេលពិសេសៗជាមួយកូនៗរបស់ខ្លួនផងដែរ។ ពួកគាត់អាចលេងជាមួយកូនៗ នាំកូនៗទៅកន្លែងផ្សេងៗ និងមើលទូរទស្សន៍ជាមួយពួកគាត់ ហើយពិភាក្សាអំពីអ្វីដែលបានមើល។ ខ្ញុំធ្លាប់មានឱកាសល្អៗក្នុងការនិយាយគ្នាជាមួយកូនៗខ្ញុំ នៅពេលខ្ញុំជូនពួកគាត់ទៅកន្លែងផ្សេងៗ។ ក្រោយមកទៀត នៅពេលពួកគេចាប់ផ្តើមប្រើប្រាស់អ៊ីមែល និងការផ្ញើរសារ ខ្ញុំមានការសន្ទនាយ៉ាងស៊ីជម្រៅជាមួយនឹងពួកគាត់ ជាពិសេសជាមួយនឹង

កូនប្រុសរបស់ខ្ញុំ ដោយប្រើប្រាស់មធ្យោបាយនោះ។ ពិតណាស់ យើងដែលជាឪពុកក៏ត្រូវតែដឹងអំពីអ្វីដែលកូនៗរបស់យើងចាប់អារម្មណ៍លើ ប្រសិនបើយើងចង់និយាយជាមួយពួកគាត់ឲ្យមានការស៊ីជម្រៅ។ ប្រសិនបើពួកគាត់ចូលចិត្តតន្ត្រី យើងត្រូវតែយល់អំពីមូលដ្ឋានគ្រឹះមួយចំនួននៃអ្វីដែលកំពុងពេញនិយមនៅក្នុងវិស័យនោះ។ វាក៏ដូចគ្នាជាមួយនឹងកីឡាដែរ។ យើងគួរតែស្គាល់មិត្តភក្តិរបស់ពួកគាត់ទាំងនៅសាលា និងអ្នកជិតខាងផងដែរ។ ការទាំងនេះគឺជាអ្វីដែលយើងត្រូវតែប្រឹងប្រែងរៀន ដោយសារមានការប្តេជ្ញាចិត្តចំពោះកូនៗយើង។

ការប្រកបគ្នាដ៏កក់ក្តៅបំផុតមួយនៅក្នុងគ្រួសារគឺនៅពេលដែលគ្រប់គ្នាមកជុំគ្នាបរិភោគអាហារ។ កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានអានអត្ថបទមួយអំពីការស្រាវជ្រាវមួយចំនួនដែលបានធ្វើឡើងអំពីការកើតជំងឺធ្លាក់ទឹកចិត្ត និងការសម្លាប់ខ្លួនដែលបានកើតឡើងនៅក្នុងចំណោមយុវជន។ អ្នកស្រាវជ្រាវបានរកឃើញថា បញ្ហានេះបានកើតឡើងតិចជាងនៅក្នុងចំណោមយុវជនដែលមកពីគ្រួសារដែលសមាជិកគ្រួសារបានបរិភោគអាហារជុំគ្នា យ៉ាងហោចណាស់មួយថ្ងៃម្តង។ មានទំនាក់ទំនងយ៉ាងកក់ក្តៅមួយដែលបានកើតឡើង នៅពេលគ្រួសារបរិភោគអាហារជាមួយគ្នា។ ការបរិភោគអាហារជាមួយគ្នាគឺជាលក្ខណៈសំខាន់មួយនៃការប្រកបគ្នានៅក្រុមជំនុំដំបូង។ លោក លូកា បានលើកឡើងថា «ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង ហើយបរិភោគអាហារ ដោយអំណរ នឹងចិត្តស្មោះត្រង់» (កិច្ចការ ២:៤៦)។

អត្ថបទនោះក៏បានបន្ថែមទៀតថា នៅពេលគ្រួសារបរិភោគអាហារជាមួយគ្នា គឺសមាជិកគ្រួសារនីមួយៗមានឱកាសយល់អារម្មណ៍គ្នា។ ការនេះជួយឲ្យកូនៗមានឱកាសនិយាយអំពីបទពិសោធន៍នៃភាពកង្វល់ ឬការមិនសប្បាយចិត្តដែលពួកគាត់មាននៅឯសាលារៀន។ ការមានឱកាសចែកចាយជាមួយអ្នកដែលយើងស្រឡាញ់ជួយឲ្យយើងកាត់បន្ថយភាពឯកា និងកម្រិតនៃភាពខ្វល់ខ្វាយរបស់កូនៗជំទង់បានផងដែរ។ ព្រះជាម្ចាស់បានបង្កើតយើងមក

ដើម្បីឲ្យយើងអាចជួយបំពេញ និងព្យាបាលគ្នាតាមរយៈការចែកចាយអំណរ និងការឈឺចាប់របស់យើងជាមួយអ្នកដទៃ។ កូនៗអាចរកបានជំនួយយ៉ាងពិសេសតាមរយៈការចែកចាយរបស់ពួកគាត់ជាមួយសមាជិកគ្រួសារ ពីព្រោះសមាជិកទាំងនោះមានចំណែកយ៉ាងសំខាន់នៅក្នុងជីវិតរបស់ពួកគាត់។

នេះហើយជាមូលហេតុដែលខ្ញុំមិនសូវសប្បាយចិត្តយ៉ាងខ្លាំងអំពីក្រុមជំនុំ និងអង្គការគ្រីស្ទបរិស័ទដែលមានសកម្មភាពច្រើនពេកនៅពេលល្ងាចក្នុងថ្ងៃធ្វើការ។ ពិតណាស់ យើងត្រូវតែបង់ថ្លៃ ដើម្បីចូលរួមកម្មវិធីមួយចំនួន។ ប៉ុន្តែយើងត្រូវតែប្រាកដថា គ្រួសារអាចមានពេលជាមួយគ្នានៅពេលល្ងាចឲ្យបានច្រើនដងក្នុងមួយសប្តាហ៍។ មានអ្នកស្ម័គ្រចិត្តវ័យក្មេងនៅក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទរបស់យើងជាច្រើននាក់មកពីគ្រួសារដែលបាក់បែក ដែលមិនមានទម្លាប់ក្នុងការមានអំណរ ពេលបរិភោគអាហារជាមួយគ្នា។ ដូច្នេះ យើងព្យាយាមលើកទឹកចិត្តពួកគាត់ឲ្យផ្លាស់ប្តូរនៅពេលដែលពួកគាត់បានរៀបការហើយ។ ពេលខ្លះ គ្រូគង្វាលដែលមកពីគ្រួសារដែលមិនមានរចនាសម្ព័ន្ធបែបនេះមិនយល់អំពីអំណរ និងសារៈសំខាន់នៃទម្លាប់នៃការបរិភោគអាហារជុំគ្នានៅក្នុងគ្រួសារដូចនេះបានទេ។ ការនេះមានគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារក្រុមជំនុំរបស់ពួកគាត់ទំនងជាបង្ហាញអំពីគំរូនៃជីវិតរបស់ក្រុមគ្រួសារដែលផ្ទុយគ្នាពីព្រះគម្ពីរ។

## បណ្តាំទៅកាន់ឪពុកម្តាយដែលមិនធ្លាប់ទទួលបានបទពិសោធន៍នៃការសប្បាយចិត្តពីឪពុកម្តាយខ្លួន

ជារឿងគួរឲ្យសោកស្តាយណាស់ ឪពុកម្តាយជាច្រើននាក់មិនដែលធ្លាប់ទទួលបានបទពិសោធន៍នៃសប្បាយចិត្តពីឪពុកម្តាយរបស់ពួកគាត់ផ្ទាល់។ ការនេះបានធ្វើឲ្យពួកគាត់មានការពិបាកមួយចំនួនក្នុងការបង្ហាញភាពសប្បាយរបស់ពួកគាត់ចំពោះកូនៗខ្លួន។ ការពិតនៃការមិនមានបទពិសោធន៍នៃគំនិតនៃសេចក្តីស្រឡាញ់ចេញពីឪពុកម្តាយបែបនេះមិនបានផ្លាស់ប្រែសេចក្តីពិតដែល

ថា ព្រះជាម្ចាស់នៅស្រឡាញ់ និងសព្វព្រះទ័យចំពោះកូនៗរបស់ទ្រង់ទេ។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា «អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន ១:១២)។ ព្រះគម្ពីរក៏បានបញ្ជាក់ផងដែរថា ព្រះជាម្ចាស់សព្វព្រះទ័យនឹងកូនៗរបស់ព្រះអង្គ ដូចដែលយើងបានឃើញខាងលើនេះ។ ដូច្នេះគ្រីស្ទបរិស័ទទាំងអស់គ្នាគួរតែបន្លឺសេចក្តីពិតនៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ៣:១-២ ដោយភាពសប្បាយរីករាយចុះ។ ខ្ញុំចង់លើកជាសម្រង់សម្តីនៃបកប្រែបច្ចុប្បន្នមួយពីភាសាអង់គ្លេស ដែលគេបានបកប្រែដើម្បីស្រួលយល់ ហើយការបកប្រែនោះក៏បានក្តោបអារម្មណ៍នៃខគម្ពីរទាំងពីរនេះ៖ «ព្រះវរបិតាបានបង្ហាញសេចក្តីស្រឡាញ់ដ៏អស្ចារ្យដល់យើង! សូមគ្រាន់តែមើល—ព្រះអង្គហៅយើងថាជាកូនរបស់ទ្រង់! នេះគឺជាលក្ខណៈសណ្ឋានរបស់យើង។ ប៉ុន្តែនេះក៏ជាមូលហេតុដែលលោកីយ៍នេះមិនទទួលស្គាល់យើង ឬក៏ស្តាប់យើងយកចិត្តទុកដាក់ ពីព្រោះលោកីយ៍នេះមិនស្គាល់ព្រះអង្គ ឬក៏ដឹងថាទ្រង់កំពុងតែធ្វើអ្វីដែរ។ ប៉ុន្តែ បងប្អូនអើយ នេះឯងគឺជាលក្ខណៈរបស់យើង៖ យើងជាកូនៗរបស់ព្រះ»។ គ្រប់ការបដិសេធ និងការព្រងើយកន្តើយនៅលើផែនដីនេះដែលយើងបានជួបប្រទះមិនបានផ្លាស់ប្រែសេចក្តីពិតដែលថា ព្រះជាម្ចាស់ពិតជាស្រឡាញ់យើងទេ ដូចឪពុកដែលមានពេញដោយសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះស្រឡាញ់កូនៗរបស់ទ្រង់ដែរ។

តាមពិតទៅ សេចក្តីស្រឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់លើយើងគឺធំប្រសើរជាងអ្វីដែលឪពុកម្តាយអាចផ្តល់ឲ្យបានទៅទៀត។ ព្រះអង្គបានប្រាប់រាស្ត្ររបស់ទ្រង់ថា «ចុះតើស្ត្រីនឹងភ្លេចកូនដែលកំពុងបៅដោះឥតមានអាណិតដល់កូនដែលចេញពីផ្ទៃខ្លួនមកបានដែរឬ អើ គេនឹងភ្លេចបាន ប៉ុន្តែអញមិនដែលភ្លេចឯងឡើយ» (អេសាយ ៤៩:១៥)។ សាវ័ក ប៉ុលពណ៌នាបានយ៉ាងក្បោះក្បាយអំពីសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់បានប្តេជ្ញានាំមកកាន់យើង ដោយគាត់បានលើកឡើងថា «សេចក្តីស្រឡាញ់របស់

ព្រះបានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធដែលព្រះបានប្រទានមកយើងហើយ» (រ៉ូម ៥:៥)។ ពាក្យដែលគេបានបកប្រែថា «បានផ្សាយ» [«អេកឃីអូ» (ekcheō)] មានន័យថា «បណ្តាលឲ្យនរណាម្នាក់មានបទពិសោធន៍នឹងអ្វីមួយដែលមានលក្ខណៈបរិបូរណ៍ និងពេញលេញ»។[១០] ការបកប្រែខ្លះទៀតបានបកប្រែវានៅក្នុងពាក្យនេះថា «បានចាក់បង្ហូរ»។ មិនមានភាពខ្វះខាតនោះទេ នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះ។ ភាពបរិបូរណ៍អាចមានច្រើនជាងការប៉ះប៉ូវដែលមានភាពខ្វះខាតនៃសេចក្តីស្រឡាញ់ និងការគាំទ្រដែលម្នាក់អាចមានកាលពីក្មេងបានទៅទៀត។

ប៉ុន្តែ យើងត្រូវតែបើកចិត្តយើងចំពោះសេចក្តីស្រឡាញ់មួយនេះ។ ខ្ញុំធ្លាប់បានឃើញមនុស្សមួយចំនួនដែលបានធ្វើដូចនោះហើយដែរ ហើយវាក៏បានបើកទ្វាឲ្យឃើញពីភាពចែងចាំងនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគាត់។ ឯមនុស្សមួយចំនួនទៀតក៏នៅតែបន្តរក្សាកំហឹងក្នុងជីវិតខ្លួន និងក្រាញនៀលនៅក្នុងការអាណិតខ្លួនឯង ចំពោះអ្វីដែលបានកើតឡើងលើពួកគាត់។ សេចក្តីកំហឹងរបស់មនុស្សដូចនោះនឹងច្បាស់ជាបង្ហាញខ្លួននៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃទៀតជាមិនខាន។ សាវ័ក ប៉ុល បានបង្រៀនថា ការរក្សាកំហឹងរបស់លោកអ្នកនៅដរាបដល់ថ្ងៃលិច និងការឲ្យអារក្សមានឱកាសមានទំនាក់ទំនងជាមួយគ្នា (អេភេសូរ ៤:២៦-២៧)។ នៅទីបំផុតអស់អ្នកដែលរក្សាកំហឹងរបស់ខ្លួននឹងក្លាយជាអ្នកតំណាងរបស់សាតាំងក្នុងការធ្វើឲ្យអ្នកដទៃឈឺចាប់ រួមបញ្ចូលទាំងកូនៗរបស់ខ្លួនដែរ។ ប្រសិនបើនេះជាការពិតមែន ការមួយដែលសំខាន់បំផុតចំពោះមនុស្សដែលប្រឈមនឹងការខ្វះសេចក្តីស្រឡាញ់ និងការគាំទ្រជួបប្រទះគឺថាពួកគាត់បានបើកចិត្តចំពោះសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ពួកគាត់ប្រហែលជាត្រូវការនរណាម្នាក់ណែនាំពួកគាត់ដូចជា អ្នកប្រឹក្សាយោបល់ មិត្តភក្តិ ឬក៏គ្រូគង្វាល ក្នុងដំណើរការនៃការស្វែងរកភាពធូរស្បើយចេញពីកំហឹង និងការបើកចិត្តចំពោះសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ប៉ុន្តែ ពួកគាត់ត្រូវតែធ្វើគ្រប់យ៉ាង ដើម្បីឲ្យពួក

គាត់នឹងមិនធ្វើឲ្យខ្លួនឯង និងកូនៗរបស់គាត់មានការឈឺចាប់។

## សេចក្តីសន្និដ្ឋាន

បញ្ហានៃការមើលថែកូនៗគឺជារឿងធំណាស់។ ខណៈពេលឪពុកម្តាយកំពុងប្រឈមមុខ ជាពិសេសនៅក្នុងអំឡុងឆ្នាំដំបូងៗនៃជីវិតកូនរបស់ពួកគាត់ ពួកគាត់អាចមានបន្ទុកយ៉ាងធ្ងន់ដល់ថ្នាក់ថា ពួកគាត់ភ្លេចថាកិច្ចការនៃការមើលថែកូនៗមានសារៈសំខាន់ប៉ុណ្ណា។ ពួកគាត់គួរតែព្យាយាមចងចាំថា ព្រះគម្ពីរបានរាប់ការងារនៃការមើលថែកូនៗថាជាការត្រាស់ហៅដ៏ខ្ពង់ខ្ពស់ណាស់។ នៅចុងបញ្ចប់ ជ័យជម្នះដ៏ធំជាច្រើនគឺជាការយកឈ្នះដោយមានការលះបង់យ៉ាងធំ។ ពិតណាស់ ឪពុកម្តាយមានការលះបង់ច្រើនណាស់ក្នុងការចិញ្ចឹមកូនៗ ដើម្បីឲ្យមានសុភមង្គលល្អ។ ទោះបើជាសង្គមទំនងជាមិនចាត់ទុកការចិញ្ចឹមមើលថែកូនៗថាជាកិច្ចការដែលមានកិត្យានុភាពក៏ដោយ ក៏វានៅតែជាការត្រាស់ហៅដ៏ខ្ពង់ខ្ពស់ និងការទទួលបានរង្វាន់នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ សូមឲ្យគំនិតនៅក្នុងព្រះគម្ពីរបានជួយទ្រទ្រង់ឪពុកម្តាយនៅពេលដែលពួកគាត់ស៊ូទ្រាំក្នុងភាពឈឺចាប់ និងភាពលំបាកក្នុងការមើលថែកូនៗ។

១១

# ការសប្បាយ ទំនៀមទម្លាប់ និង សុវត្ថិភាពសម្រាប់កូនៗ

នៅក្នុងជំពូកមុន យើងបានចាប់ផ្ដើមមើលអំពីបរិយាកាសនៅក្នុងផ្ទះគ្រីស្ទបរិស័ទ ដែលឪពុកម្ដាយគួរតែបង្កើតឲ្យមាន ដើម្បីឲ្យកូនៗមានសុខភាពល្អ ការសប្បាយចិត្ត និងមានពេញដោយភាពបរិសុទ្ធ។ យើងបានលើកឡើងថា ការសប្បាយចិត្តរបស់ឪពុកម្ដាយចំពោះកូនៗគឺជារឿងដ៏សំខាន់មួយនៅក្នុងផ្ទះគ្រីស្ទបរិស័ទ។ ឥឡូវនេះ យើងនឹងមើលជាមួយគ្នាអំពីរបៀបបីយ៉ាងដែលការសប្បាយរីករាយចំពោះកូនៗអាចដំណើរការបាន៖ ការសប្បាយ ទំនៀមទម្លាប់ និងសុវត្ថិភាព។

## កូនក្មេង និងក្មេងជំទង់ចូលចិត្តមានការសប្បាយ

### គ្រួសារដែលមានភាពរីករាយ និងការអរសប្បាយ

នៅពេលឪពុកម្ដាយគិតអំពីសុខុមាលភាពកូនៗរបស់ខ្លួន ជាទូទៅឪពុកម្ដាយគិតអំពីការការពារពួកគាត់ចេញពីឥទ្ធិពលនៃការមានគ្រោះថ្នាក់ និងលើកទឹកចិត្តឲ្យពួកគាត់អភិវឌ្ឍន៍ខ្លួននូវទម្លាប់ដែលនឹងជួយពួកគាត់ឲ្យមានដំណើរការ

ទៅមុខទៀតនៅក្នុងជីវិត។ ដូច្នេះ ពួកគាត់បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការណែនាំ និងការអប់រំផ្នែកសីលធម៌។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានចំណុចសំខាន់ផ្សេងៗទៀតនៃការលូតលាស់ឲ្យបានល្អ ដែលពួកគាត់មិនគួរព្រងើយកន្តើយជាមួយផងដែរ។ ចំណុចមួយក្នុងចំណុចទាំងនេះគឺតម្រូវការសម្រាប់ក្មេងៗ និងក្មេងវ័យជំទង់ដើម្បីឲ្យពួកគាត់ទទួលបានភាពសប្បាយរីករាយ ដែលមានសុខភាពល្អក្នុងអំឡុងឆ្នាំលូតលាស់របស់ពួកគាត់។

ដោយនិយាយអំពីការត្រឡប់មកវិញដោយមានសន្តិភាព និងភាពចម្រុងចម្រើននៃទីក្រុងយេរូសាឡឹម ហោរា សាការី បានលើកឡើងថា «អស់ទាំងផ្លូវទីក្រុងនឹងបានពេញដោយកូនប្រុសស្រី ដែលកំពុងតែលេងក្នុងផ្លូវ» (សាការី ៨:៥)។ ព្រះយេស៊ូវបានប្រើប្រាស់រូបភាពពីការដែលក្មេងៗលេងនៅតាមផ្លូវជារឿងប្រៀបប្រដូចមួយ។ ហើយការលេងនេះប្រហែលជាលេងរៀបការ ដែលមានរួមបញ្ចូលទាំងការរាំលេង ជាការឆ្លើយតបចំពោះការផ្លុំខ្លុយ (ម៉ាថាយ ១១:១៦-១៧)។ ទោះបើដែលមិនមានអ្វីបញ្ជាក់អំពីការលេងតុក្កតានៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ បុរាណវិទូបានរកឃើញ «កញ្ចែ ប្រដាប់រណ្តំគ្នា កូនក្រមុំឈើ សត្វ (ពេលខ្លះមានកង់) និងរបស់ជាច្រើនទៀតនៅកន្លែងជាច្រើននៅទឹកដីប៉ាឡេស្ទីន [ដែល] ផ្តល់ការបើកបង្ហាញមួយចំនួនអំពីប្រដាប់លេងដែលក្មេងៗសាសន៍អ៊ីស្រាអែលលេងជាមួយ។[១] យើងអាចនិយាយបានដោយមានសុវត្ថិភាពថា ការសប្បាយរីករាយគឺជាផ្នែកដ៏សំខាន់មួយនៅក្នុងជីវិតរបស់ក្មេងៗនៅសម័យកាលព្រះគម្ពីរ។

ជារឿយៗ ខ្ញុំបានប្រាប់ឪពុកម្តាយដែលមានកូនតូចៗថា វាទំនងជាសំខាន់ជាងសម្រាប់កូនៗរបស់ពួកគាត់ក្នុងការចំណាយពេលលេង ក្នុងវ័យដំបូងៗរបស់ពួកគាត់ ជាជាងការរៀនសូត្រ។ ពួកគាត់អាចចាប់ផ្តើមរៀនសូត្រនៅពេលពួកគាត់ទៅសាលា។ វាជារឿងសំខាន់ណាស់ដែលអតីតកាលនៃកុមារភាពរបស់ពួកគាត់មានពេញដោយការចងចាំដ៏រីករាយ ដោយរួមបញ្ចូលទាំងការលេងជាមួយសមាជិកក្នុងគ្រួសារ និងអ្នកដទៃដែរ។ ឪពុកម្តាយគួរស្វែង

រកកន្លែងកម្សាន្តផ្សេងៗសម្រាប់កូនៗ ហើយនាំពួកគាត់ទៅទីនោះឲ្យបានញឹកញាប់។ ហើយពួកគាត់ក៏គួរតែញែកពេលវេលានៅក្នុងកាលវិភាគរបស់ខ្លួន ដើម្បីលេងជាមួយនឹងកូនៗដែរ។ យើងទំនងជាមិនមានអារម្មណ៍ធ្វើដូចនោះទេ ប៉ុន្តែវាអាចជាព្រះពរយ៉ាងខ្លាំងចំពោះកូនៗយើង និងខ្លួនយើងផ្ទាល់។ ខ្ញុំធ្លាប់បានលើកឡើងរួចហើយអំពីរបៀបនេះ នៅពេលកូនប្រុសរបស់ខ្ញុំបបួលខ្ញុំលេងបាល់ជាមួយគាត់ ជាញឹកញាប់ខ្ញុំមិនមានអារម្មណ៍ទំនោរទៅលេងដូច្នោះទេ។ ប៉ុន្តែ ដោយសារការយល់ពីកាតព្វកិច្ច នោះខ្ញុំក៏បានចេញទៅលេង ហើយខ្ញុំតែងតែត្រឡប់មកវិញដោយមានភាពស្រស់ស្រាយ និងសប្បាយចិត្តដែលខ្ញុំបានទៅលេង។

យើងគួរតែរៀបចំផ្ទះរបស់យើងឲ្យក្លាយជាកន្លែងដែលមានភាព “អរសប្បាយ និងរួសរាយរាក់ទាក់”។ ពេលខ្លះ យើងចាប់អារម្មណ៍ខ្លាំងលើការរៀបចំឲ្យផ្ទះយើងមើលទៅស្អាត និងមានរបៀបរៀបរយដែលធ្វើឲ្យកូនៗយើងមានការពិបាកលេងដោយសប្បាយរីករាយបាននៅផ្ទះ។ ការនោះមិនមែនជារឿងដែលល្អនោះទេ។ ខ្ញុំស្គាល់គ្រួសារជាច្រើនដែលបានកំណត់ជញ្ជាំងមួយក្នុងផ្ទះ សម្រាប់ឲ្យកូនតូចៗអាចសរសេរ ឬគូររូបលេងលើនោះបាន។ កូនប្រុសរបស់យើងចូលចិត្តលេងបាល់ណាស់។ ប៉ុន្តែ ទីធ្លាលេងរបស់យើងគឺនៅក្បែរបង្អួច ដែលធ្វើឲ្យបាល់ងាយត្រូវ ហើយបែកបង្អួចនោះបាន។ បុគ្គលិកម្នាក់នៅក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទរបស់យើងបានច្នៃ ដោយធ្វើស៊ុមការពារបង្អួច ធ្វើចេញពីឈើ និងសំណាញ់លួស។ ការរៀបចំនោះមិនស្អាតទេ ប៉ុន្តែវាបានការពារបង្អួច ហើយឲ្យកូនប្រុសខ្ញុំមានសេរីភាពក្នុងការលេង ដោយមិនមានការព្រួយបារម្ភ។ ការអនុញ្ញាតឲ្យកូនៗលេងដោយមិនមានការភ័យខ្លាចគឺជាគន្លឹះមួយ។ ប្រសិនបើពួកគាត់មានអាកប្បកិរិយាវិជ្ជមានក្នុងការលេង នោះពួកគាត់នឹងបើកចិត្តច្រើនជាងក្នុងការស្ដាប់យើងនៅពេលយើងឲ្យគាត់ឈប់នៅពេលណាមួយ ដើម្បីមកផ្ទះវិញហើយធ្វើលំហាត់កិច្ចការសាលា។ សេរីភាពក្នុងការលេងនឹងមិនមែនជាអ្វីមួយដែលពួកគាត់ត្រូវតែប្រឆាំងតវ៉ា

ជាមួយ ក្នុងការការពារនោះទេ។

កណ្ឌគម្ពីរសាស្តាទទួលស្គាល់ទំនោរចិត្តរបស់ក្មេងៗវ័យជំទង់ក្នុងការមានភាពសប្បាយរីករាយ ហើយក៏បានលើកទឹកចិត្តដល់ពួកគាត់ក្នុងការបង្ហាញអំពីវា៖ «ឱមនុស្សកំលោះអើយ ចូរឲ្យមានចិត្តរីករាយក្នុងវ័យកំលោះរបស់ឯងចុះ ហើយឲ្យចិត្តឯងបណ្តាលឲ្យអរសប្បាយ ក្នុងជំនាន់ដែលឯងនៅក្មេងផង ចូរដើរតាមផ្លូវនៃចិត្តឯង ហើយតាមតែភ្នែកឯងមើលឃើញដែរ» (សាស្តា ១១:៩ក)។ ពិតណាស់ ខគម្ពីរនេះក៏បានបន្តថែងទៀតថា «ប៉ុន្តែ ត្រូវឲ្យដឹងថា ព្រះទ្រង់នឹងហៅឯងមកជំនុំជម្រះ ដោយព្រោះអំពើទាំងនេះជាមិនខាន» (ខ៩ខ) ដែលកំពុងបង្ហាញថា យើងត្រូវតែមានការសប្បាយដោយរក្សាបញ្ញត្តិរបស់ព្រះជាម្ចាស់ផងដែរ—ការសប្បាយដែលបរិសុទ្ធ។ ការមានភាពសប្បាយរីករាយមិនមែនជាគោលបំណងចម្បងសម្រាប់កូនៗរបស់យើងនោះទេ ប៉ុន្តែភាពបរិសុទ្ធនោះទេទើបជាគោលបំណងចម្បងវិញ។ កូនៗត្រូវតែរៀនអំពីរបៀបនៃការអរសប្បាយដែលមានទំនួលខុសត្រូវ ការសប្បាយដែលមិនធ្វើឲ្យអ្នកដទៃឈឺចាប់ ឬក៏ការពិបាកដល់អ្នកដទៃនោះទេ។ កន្លែងដ៏ល្អ ដើម្បីរៀនអំពីការនោះគឺនៅផ្ទះ។ យើងបានជួបប្រទះនឹងបញ្ហាមួយទាក់ទងនឹងការមានភាពសប្បាយរីករាយនៅក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទរបស់យើង ក្នុងចំណោមយុវជនដែលយើងកំពុងឈោងចាប់។ យើងជឿយ៉ាងខ្លាំងក្នុងការជួយឲ្យយុវជនមានឱកាសក្នុងការមានភាពសប្បាយរីករាយដែលស្អាតស្អំ។ ប៉ុន្តែជារឿយៗ ពួកគាត់ឈានដល់កម្រិតមួយដែលធ្ងន់ធ្ងរ ហើយការអរសប្បាយរបស់ពួកគាត់ក៏បានក្លាយជារឿងមិនបរិសុទ្ធវិញ។ ខ្ញុំគិតថា មូលហេតុចម្បងសម្រាប់ការនេះគឺថា ពួកគាត់មិនបានរៀនអំពីរបៀបនៃការមានភាពសប្បាយរីករាយដែលមានភាពស្អាតស្អំ និងមានទំនួលខុសត្រូវនៅផ្ទះរបស់ខ្លួននោះទេ។

យើងតែងតែដកស្រង់ឃ្លាមួយដែលមានពីរខបន្ទាប់ទៀត «ចូរនឹកចាំពីព្រះដ៏បង្កើតខ្លួន ក្នុងគ្រាដែលឯងនៅក្មេង» (សាស្តា ១២:១ក)។ ប៉ុន្តែ យើងភ្លេច

មូលហេតុដែលបានផ្តល់មកសម្រាប់ឲ្យនឹកចាំអំពីព្រះអាទិកររបស់យើង ក្នុងគ្រាដែលយើងនៅក្មេង៖ «...មុនដែលអស់ទាំងថ្ងៃអាក្រក់មកដល់ ហើយអស់ទាំងឆ្នាំមកជិត ដែលឯងនឹងថា “អញអស់សប្បាយហើយ”» (ខ១ខ)។ ខគម្ពីរបន្ទាប់ៗនេះបង្ហាញថាហេតុផលនៃផ្នត់គំនិតគឺថា មនុស្សដែលមានវ័យចំណាស់ ដោយមានការចុករោយខ្នង និងការឈឺឆ្អឹងឆ្អែងរបស់ពួកគាត់មិនអាចមានការសប្បាយរីករាយក្នុងជីវិតនេះ ដូចក្មេងៗបាននោះទេ។ ដូច្នេះហើយបានជាព្រះគម្ពីរបានប្រាប់ក្មេងជំទង់ឲ្យនឹកចាំអំពីព្រះអាទិកររបស់ខ្លួននៅក្នុងអំឡុងពេលដែលពួកគាត់កំពុងមានភាពសប្បាយរីករាយ—ដ្បិតនៅក្នុងការសប្បាយរបស់យើងជាមួយទំនាក់ទំនងជាមួយនឹងព្រះអាទិករ នោះយើងអាចមានការអរសប្បាយដែលល្អបំផុត និងសប្បាយបំផុតជាមួយបាន។

នៅពេលក្មេងៗ និងក្មេងជំទង់លូតលាស់ឡើងក្នុងការមានភាពអរសប្បាយដែលស្អាតស្អំ និងល្អនៅផ្ទះ នោះពួកគាត់នឹងមិនងាយធ្លាក់ក្នុងការសប្បាយនៃការល្បួងនៃអំពើបាប ដែលមិនយូរមិនឆាប់នឹងវាយប្រហារពួកគាត់យ៉ាងខ្លាំងនោះទេ។ លោកីយ៍នេះគិតថា ដើម្បីសប្បាយរីករាយបាន ម្នាក់ៗត្រូវតែប្រព្រឹត្តអំពើបាប! ខ្ញុំធ្លាប់បានឃើញសំបុត្រខួបកំណើតម្តងដែលគេសរសេរថា៖ «នេះជាថ្ងៃកំណើតរបស់អ្នក! ចូររីករាយជាមួយខ្លួនឯង ហើយធ្វើបាបបន្តិចបន្តួចចុះ!»។ យើងត្រូវតែបកស្រាយប្រាប់កូនៗយើងថា ភាពសប្បាយរីករាយក៏មានភាពស្របគ្នាជាមួយនឹងជំនឿគ្រីស្ទបរិស័ទដែរ ហើយថាមានរបៀបតែមួយគត់ដើម្បីឲ្យពិតជាអាចមានអំណរបាន គឺការធ្វើវាជាមួយព្រះជាម្ចាស់។ តាមរយៈការអនុញ្ញាតឲ្យពួកគាត់មានអំណរក្នុងការមានពេលវេលាសប្បាយៗជាមួយនឹងឪពុកម្តាយខ្លួននៅលើផែនដីនេះ គឺជារបៀបមួយយ៉ាងល្អក្នុងការបើកគំនិតរបស់ពួកគាត់ទៅកាន់ចំណុចមួយដែលថា ពួកគាត់ក៏អាចមានអំណរក្នុងការចំណាយពេលវេលាជាមួយព្រះវរបិតាដែលគង់នៅស្ថានសួគ៌បានដែរ។

### *ពាណិជ្ជភាវូបនីយកម្ម និងការប្រកួតប្រជែងគ្នាក្នុងការសប្បាយ*

វាហាក់បីដូចជាថា ស្ទើរតែគ្រប់អ្វីៗទាំងអស់នៅក្នុងជីវិតនេះបានក្លាយជាការផ្សព្វផ្សាយពាណិជ្ជកម្ម និងទទួលការប្រកួតប្រជែងយ៉ាងខ្លាំង ហើយជារឿងដែលគួរឲ្យសោកស្ដាយណាស់ កីឡា និងសកម្មភាពសប្បាយៗមួយចំនួនសម្រាប់កុមារ និងក្មេងជំទង់ក៏បានក្លាយទៅជារបៀបនេះដែរ។ កីឡាមិនមានមុខងារជាប្រភពនៃការមានអំណរសម្រាប់អ្នកលេងកីឡាជាច្រើនសព្វថ្ងៃនេះទេ។ តាមពិតទៅ កីឡាអាចក្លាយជាព្រះមួយនៅក្នុងកុមារភាពរបស់អ្នកណាម្នាក់បាន។ យើងគួរលើកទឹកចិត្តកុមារដែលមានទេពកោសល្យពិតប្រាកដនៅក្នុងកីឡាឲ្យបន្តលេង ប៉ុន្តែយើងក៏គួរតែមានការប្រុងប្រយ័ត្នអំពីការជំរុញពួកគាត់ខ្លាំងពេកនៅក្នុងចំណុចនេះដែរ។ ពេលខ្លះ ឪពុកម្ដាយមួយចំនួនចង់ឲ្យកូនៗរបស់ខ្លួនសម្រេចបាននូវអ្វីមួយដែលពួកគាត់មិនអាចសម្រេចបានកាលខ្លួននៅវ័យជំទង់ ដូច្នេះពួកគាត់បានដាក់សម្ពាធដែលមិនល្អដល់ការលេងរបស់កូនៗ។ មានអ្នកចាប់ផ្ដើមតែ១១នាក់ និងអ្នកជំនួសតែ២-៣នាក់ប៉ុណ្ណោះទេ ដែលអាចបង្កើតក្រុមបាល់ទាត់មួយបាន។ នេះមានន័យថា ក្មេងជាច្រើននឹងមិនអាចចូលរួមបានទេ។ ឪពុកម្ដាយគួរចងចាំអំពីចំណុចនេះ ហើយមិនគួរដាក់សម្ពាធមិនសមរម្យលើកូនៗរបស់ខ្លួនឡើយ។ ពួកគាត់អាចធ្វើឲ្យកូនៗបាត់បង់លក្ខណសម្បត្តិនៃអំណរ។

ពេលខ្លះ ការលេងកីឡា ការប្រគំតន្ត្រី ការច្រៀង និងកម្មវិធីផ្សេងៗធ្វើឡើងនៅថ្ងៃអាទិត្យអំឡុងពេលថ្នាក់កុមារថ្ងៃអាទិត្យ ឬពេលម៉ោងថ្វាយបង្គំ។ នៅក្នុងករណីទាំងនេះ ក្មេងៗអាចមានការខកខានមិនបានចូលរួមក្រុមជំនុំអស់ពេលមួយរដូវកាលទាំងស្រុងតែម្តង។ នៅប្រទេសស្រីលង្កា ក្មេងៗមួយចំនួនមិនទៅព្រះវិហារ ដោយសារពួកគាត់ត្រូវទៅរៀនគួរបន្ថែម ក្នុងអំឡុងពេលថ្វាយបង្គំ។ ដូចលោក ជីព អ៊ីងរ៉ែម (Chip Ingram) បានលើកឡើង «នោះគឺជាការដ៏ល្អមួយក្នុងការបង្រៀនដល់កូនៗរបស់លោកអ្នកថា ការធ្វើជាតារានោះគឺសំខាន់ជាងអ្នកថ្វាយបង្គំព្រះ»។[១២] ឪពុកម្តាយត្រូវតែចងចាំព្រះបន្ទូលរបស់

ព្រះយេស៊ូវជានិច្ច ដែលទ្រង់បានលើកឡើងថា “ដ្បិតបើមនុស្សណានឹងបាន លោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរឲ្យបានព្រលឹងខ្លួនវិញ?” (ម៉ាកុស ៨:៣៦-៣៧)។

## *ទូរទស្សន៍ និងពិភពបណ្តាញសង្គម*

យើងត្រូវលើកឡើងបន្តិចអំពីគំនូរជីវចលសម្រាប់កុមារ និងកម្មវិធីមួយចំនួនទៀតនៅលើទូរទស្សន៍ ដែលតែងតែផ្តល់ជូនឪពុកម្តាយឲ្យមានការសម្រាកពីភាពតានតឹងក្នុងការមើលថែកូនតូច។ ការមើលគំនូរជីវចលដែលបានជ្រើសរើសដោយប្រុងប្រយ័ត្នមួយចំនួន និងកម្មវិធីផ្សេងៗដូចជាវិទ្យាសាស្ត្រ ធម្មជាតិ និងកម្មវិធីកីឡា និងខ្សែភាពយន្តល្អៗ ក៏ដូចជារឿងអប់រំខ្លីៗអាចជាការល្អដល់ក្មេងៗដែរ។ ប៉ុន្តែ ការស្រាវជ្រាវបានបង្ហាញថា ការមើលច្របូកច្របល់អាចបង្កើតជាគ្រោះថ្នាក់ដល់ពួកគាត់វិញ។ ការមើលរឿងដែលប្រើប្រាស់អំពើហិង្សានៅលើកញ្ចក់ទូរទស្សន៍អាចធ្វើឲ្យកុមារមិនសូវមានការឈឺចាប់ ឬទទួលការរងទុក្ខ។ គេក៏បានលើកឡើងផងដែរថា ល្បឿននៃរូបភាពក៏អាចបំផ្លាញខួរក្បាល និងកែវភ្នែករបស់ក្មេងដែរ។ ភាពព្រងើយកន្តើយរបស់កុមារខណៈពេលដែលពួកគាត់កំពុងមើលក៏ត្រូវបានគេលើកឡើងថាជាការបង្អាក់ការអភិវឌ្ឍន៍ក្នុងការនិយាយដ៏ត្រឹមត្រូវរបស់កុមារដែរ។[៣] ដូច្នេះ ឪពុកម្តាយត្រូវតែធ្វើការស្រាវជ្រាវ ដើម្បីឲ្យប្រាកដថាអ្វីដែលកូនៗកំពុងតែមើលមិនផ្តល់ផលអាក្រក់ដល់ពួកគាត់នោះទេ។[៤]

យើងក៏អាចលើកឡើងដូចនេះបានអំពី អាយភេដ (iPads) កុំព្យូទ័រ ទូរស័ព្ទ និងលេងវីដេអូហ្គេមជាដើម ដែលទាំងនេះជះឥទ្ធិពលដល់ក្មេងៗខ្លាំងជាងការមើលទូរទស្សន៍ទៅទៀត។ សព្វថ្ងៃនេះ ចំពោះឪពុកម្តាយដែលដឹងអំពីរឿងនេះក៏បានបញ្ឈប់ការប្រើប្រាស់ឧបករណ៍ដូចនោះ រហូតដល់ពេលដែលកូនៗរបស់គាត់លើសអាយុនៃឆ្នាំដំបូងដូចនោះ ដោយសារអាចមានការជះឥទ្ធិពលបែបអវិជ្ជមាន មកលើចំណុចលូតលាស់សំខាន់ៗ។ អ្វីដែលខ្ញុំរៀនបានជាច្រើន

អំពីការនេះគឺខ្ញុំបានរៀនពីកូនៗរបស់ខ្ញុំ។ ជំនាន់របស់ពួកគាត់ដឹងច្រើនជាងជំនាន់របស់ខ្ញុំឆ្ងាយណាស់ ជាពិសេសអំពីពិភពក្នុងបណ្តាញសង្គម។ វាអាចជាអំណរដ៏អស្ចារ្យមួយចំពោះកូនៗយើងក្នុងការឃើញពីតួនាទី ដែលផ្លុយគ្នានៅពេលពួកគាត់បង្រៀនយើងពីរបៀបដែលពិភពក្នុងបណ្តាញសង្គម និងឧបករណ៍ផ្សេងៗដូចជាទូរស័ព្ទមានដំណើរការ!

ចំណុចមួយដែលមានផលប៉ះពាល់ដ៏អាក្រក់បំផុតក្នុងការមើលទូរទស្សន៍ទូរស័ព្ទ និងកុំព្យូទ័រដល់កុមារគឺថា ការទាំងអស់នេះប្លន់ពួកគាត់ពីសកម្មភាពដែលធ្វើឲ្យរាងកាយមានសុខភាពល្អ ដោយមិនមានពេលលេងហ្គេម និងកីឡានៅក្រៅផ្ទះ។ ពេលវេលាដែលក្មេងៗជំនាន់មុនចំណាយក្នុងការលេងនៅក្រៅផ្ទះ ឥឡូវនេះក្មេងៗជំនាន់បច្ចុប្បន្នចំណាយពេលលេងនៅក្នុងផ្ទះនៅមុខកុំព្យូទ័រ ជាមួយទូរស័ព្ទ ឬក៏អង្គុយនៅមុខទូរទស្សន៍ផងដែរ។ តាមរយៈការដកខ្លួនទៅចំណាយពេលតែឯងនៅមុខកុំព្យូទ័រ ទូរទស្សន៍ និងវីដេអូហ្គេម នោះក្មេងជាច្រើនក៏កំពុងតែមិនទទួលបានអត្ថប្រយោជន៍នៃការលេងកីឡាបែបជាក្រុម តែជួយបង្កើតចរិតល្អតាមរយៈការលេងទាំងនោះ។ ការដាក់ច្បាប់ដោយមានការគិតគូរយ៉ាងប្រុងប្រយ័ត្នសម្រាប់សកម្មភាពទាំងអស់នេះអាចជួយឲ្យក្មេងៗលូតលាស់បានយ៉ាងល្អ។

ឳពុកម្តាយគួរដឹងអំពីអ្វីដែលកើតឡើងនៅពេលដែលកូនៗខ្លួនលេងអ៊ីនធឺណិត។ ការលេងសារ (chats) បែបឯកជននៅក្នុងបណ្តាញសង្គម ជាពិសេសជាមួយកម្មវិធីដូចជា ស្នាបឆែត (Snapchat) អាចមានផលប៉ះពាល់យ៉ាងអាក្រក់ៗ។ មនុស្សវ័យជំទង់អាចមើល និងលេងសារជាមួយស្ត្រីដែលមានរូបអាក្រាតដោយមានការផ្សាយផ្ទាល់ (live webcams) ដោយឥតគិតថ្លៃបាន—គាត់គ្រាន់តែត្រូវចុចតែម្តងតែប៉ុណ្ណោះ![៩] ដូចគ្នានឹងរឿងផ្សេងៗទៀតដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍ព័ត៌មានបច្ចេកវិទ្យា ប្រព័ន្ធបណ្តាញសង្គមក៏អាចទទួលការប្រើប្រាស់ក្នុងគោលបំណងល្អ និងអាក្រក់បានផងដែរ។ នៅប្រទេសស្រីលង្កា មានក្មេងស្រីជាច្រើនបានសម្រេចចិត្តសម្លាប់ខ្លួន ដែលនោះ

ជាលទ្ធផលនៃការសម្លាប់អត្តចរិតនៅលើបណ្ដាញហ្វេសប៊ុក ដែលកើតឡើងជាចម្បងតាមរយៈការដែលសង្សារចាស់បង្ហោះរូបពួកគាត់ ក្នុងកាលៈទេសៈដែលមានការព្រមព្រៀងគ្នា។ ឪពុកម្ដាយត្រូវតែដឹងអំពីសកម្មភាពដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងបែបនោះចំពោះកូនៗរបស់ខ្លួន។

ឪពុកម្ដាយក៏គួរតែដឹងថាកូនៗមានការងាយស្រួលណាស់ក្នុងការចូលទៅមើលរូបភាពអាសអាភាសផងដែរ។ ឪពុកម្ដាយគួរតែអាចតាមដានសកម្មភាពកូនៗរបស់ខ្លួននៅលើកុំព្យូទ័រ និងនៅក្នុងទូរស័ព្ទក្នុងរបៀបណាមួយដែរ។ ការនេះវាងាយស្រួលជាងក្នុងការនិយាយជាជាងការធ្វើ។ ពួកគាត់ត្រូវតែរៀបចំការដាក់កំហិត ដាក់រនាំងការពារ និងបណ្ដាញត្រួតត្រា ដើម្បីកុំឲ្យកូនរបស់ខ្លួនបំផ្លាញជីវិតចោល។ ហើយនេះពិតជាមានតម្លៃណាស់ក្នុងការចំណាយពេល ដើម្បីការពារកូនៗរបស់យើង (និងខ្លួនឯង)។ យើងគួរព្រមានក្មេងៗអំពីការមើលអ្វីមួយដែលបំផ្លាញភាពបរិសុទ្ធរបស់ពួកគាត់នៅលើទូរស័ព្ទរបស់ខ្លួន។ ជារឿងគួរឲ្យសោកស្ដាយណាស់ដែលមានមនុស្សវ័យក្មេងជាច្រើនបានបំផ្លាញជីវិតអាពាហ៍ពិពាហ៍មុនពេលពួកគាត់ចាប់ផ្ដើម ដោយមើលរឿងជាច្រើនដែលបំផ្លាញចិត្តគំនិតរបស់ខ្លួន។ ការមើលរូបអាសអាភាស និងការលេងវីដេអូហ្គេមគឺជាការញៀនយ៉ាងខ្លាំង ហេតុដូច្នេះហើយបានជាឪពុកម្ដាយគួរតែមានការពិចារណាឲ្យបានហ្មត់ចត់អំពីរបៀបដែលពួកគាត់អាចជួយការពារកូនៗរបស់ខ្លួនមិនឲ្យទទួលផលប៉ះពាល់ដ៏អាក្រក់នេះ។ ឪពុកម្ដាយមិនត្រូវបន្តដោយមិនមានការចូលរួមនោះទេ ដោយនិយាយថា ខ្លួនមិនដឹងអំពីការទាំងនេះឡើយ ខណៈពេលកូនៗខ្លួនកំពុងតែបំផ្លាញជីវិតរបស់ខ្លួនចោល។

សាតាំងបានស្វែងរកផ្លូវជាច្រើនក្នុងការបង្ខូចគ្រប់ទាំងការល្អនៅលើផែនដីនេះ។ នោះហើយគឺជាអ្វីដែលវាបានធ្វើជាមួយភាពសប្បាយរីករាយដែរ។ សូមឲ្យព្រះជាម្ចាស់ស្ដារភាពសប្បាយរីករាយនៅក្នុងជីវិតរបស់យើង និងក្នុងជីវិតកូនៗយើងឡើងវិញ ដើម្បីឲ្យយើងអាចមានប្រភេទនៃការអរសប្បាយដ៏ល្អបំផុតបានគឺៈ ការសប្បាយដែលបរិសុទ្ធ!

## ទំនៀមទម្លាប់ និងពិធីអបអរសាទរ

របៀបមួយក្នុងរបៀបជាច្រើនដែលយើងអាចរក្សាបរិយាកាសនៃសេចក្តីអំណរបាននៅក្នុងផ្ទះ គឺតាមរយៈការមានទំនៀមទម្លាប់ និងការអបអរសាទររបស់គ្រួសារដែលរីករាយ។ ខ្ញុំមានពូម្នាក់ដែលគាត់គឺជាវេជ្ជបណ្ឌិតផ្នែកជំងឺកុមារ។ កាលកូនទីមួយរបស់យើងនៅជាទារកនៅឡើយ គាត់បានប្រាប់ខ្ញុំអំពីអ្វីមួយដែលបានជះឥទ្ធិពលគួរឲ្យកត់សម្គាល់លើវិធីដែលយើងចិញ្ចឹមកូនៗរបស់យើង។ គាត់បាននិយាយថា ក្មេងៗត្រូវការភាពទៀងទាត់។ បើមិនមានទម្លាប់ទៀងទាត់នោះទេ នោះពួកគាត់នឹងមិនមានសុវត្ថិភាពឡើយ។ នេះគឺជាចំណុចដ៏សំខាន់មួយសម្រាប់ខ្ញុំ ព្រោះការត្រាស់ហៅរបស់ខ្ញុំធ្វើឲ្យកាលវិភាគរបស់ខ្ញុំមិនមានភាពទៀងទាត់ក្នុងរបៀបណាមួយទេ។ ដូចដែលក្មេងៗចង់ឲ្យពិភពលោកនៅជុំវិញខ្លួនមានអារម្មណ៍ថាមានសុវត្ថិភាព នោះពួកគាត់ក៏ស្វែងរកការបំពេញយ៉ាងពិសេសនៅក្នុងការអនុវត្តទៀងទាត់ដែលមានការប្តេជ្ញាចិត្តការមានអំណរដែលក្លាយជាទំនៀមទម្លាប់នៅក្នុងផ្ទះដែរ។ លោក ចិម ស្វាហ្វិត បានលើកឡើងថា «វាជាការរៀបចំរបស់យើងក្នុងនាមជាមនុស្សដើម្បីកំណត់ពេលវេលា និងថ្ងៃជាក់លាក់ណាមួយក្នុងការអបអរសាទរ»។[៦] យើងត្រូវតែរៀបចំឱកាសបែបនេះឲ្យអាចទៅរួចបាននៅក្នុងគ្រួសាររបស់យើង។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានប្រទានការផ្តត់ផ្គង់សម្រាប់ការនេះ ដោយឲ្យចាប់ផ្តើមប្រារព្ធពិធី ឬជប់លៀងផ្សេងៗ ដែលជាទូទៅត្រូវបានប្រារព្ធនៅក្នុងពេលវេលាសំខាន់ៗនៅក្នុងគ្រួសារ ដូចជាការរៀបអាពាហ៍ពិពាហ៍ (លោកុប្បត្តិ ២៩:២២) ឬការផ្តាច់ដោះកូន (លោកុប្បត្តិ ២១:៨) ឬការមកលេងរបស់ភ្ញៀវ (លោកុប្បត្តិ ១៩:៣) ឬក៏ជាការចាប់ផ្តើមនៃរដូវចម្រូត (និក្ខមនំ ២៣:១៦)។ ព្រះគម្ពីរបានលើកឡើងថា នៅថ្ងៃចម្រើនព្រះជន្មផារ៉ោន និងស្តេច ហេរ៉ូឌ ជាឱកាសនៃការជប់លៀង (លោកុប្បត្តិ ៤០:២០; ម៉ាកុស ៦:២១) ប៉ុន្តែមិនមែនជាថ្ងៃកំណើតនៃរាស្ត្រតាំងសញ្ញារបស់ព្រះជាម្ចាស់ទេ។ កណ្ឌគម្ពីរ យ៉ូប ១:៤ បានចែងថា «កូនប្រុសៗរបស់លោក គេ

តែងជប់លៀងគ្នា នៅផ្ទះគេរៀងខ្លួនតាមវេន»។ ថ្ងៃទាំងនោះអាចទំនងជាថ្ងៃខួបកំណើតរបស់ពួកគាត់។ ខ្ញុំជឿថា គំនិតនៃការធ្វើកម្មវិធីខួបកំណើតស៊ីគ្នាជាមួយគោលគំនិតនៅក្នុងព្រះគម្ពីរនៃការប្រារព្ធកម្មវិធីជាមួយនឹងអ្នកដទៃ នៅក្នុងពេលវេលាពិសេសណាមួយ ដើម្បីអរព្រះគុណដល់ព្រះជាម្ចាស់។

ថ្ងៃសប្ប័ទគឺជាថ្ងៃជប់លៀងបែបសង្គម ថ្ងៃចូលខែជាប្រចាំ និងពិធីជប់លៀង ៣ដងប្រចាំឆ្នាំ៖ បុណ្យរំលង បុណ្យថ្ងៃទី៥០ និងបុណ្យរោងឧបោសថ។ ការប្រារព្ធពិធីទាំងនេះបានសង្កត់ន័យយ៉ាងធ្ងន់លើសកម្មភាពក្នុងគ្រួសារ និងលើការផ្គត់ផ្គង់របស់ព្រះជាម្ចាស់។ ដូច្នេះ ព្រះគម្ពីរបានណែនាំឲ្យគ្រួសារមានការបរិភោគបែបជប់លៀងជាមួយគ្នាដោយអំណរ (ចោទិយកថា ១៦:១១; ១៤-១៥; ២របាក្សត្រ ៣០:២១)។ ពិធីទាំងនោះគឺជាឱកាសដ៏ពិសេសៗណាស់។ «ទោះបីសង្គមហេព្រើរមិនសូវមានសាច់ច្រើនក៏ដោយ ក៏តែងតែនៅមានសាច់យ៉ាងជាក់ស្តែងក្នុងពិធីជប់លៀងមួយចំនួនផងដែរ ដែលតម្រូវឱ្យមានការថ្វាយយញ្ញបូជា ដើម្បីឲ្យប្រាកដថាមានសាច់ច្រើននៅក្នុងពិធីជប់លៀង»។[៧] សៀវភៅវចនានុក្រមនៃរូបភាពព្រះគម្ពីរ ("Dictionary of Biblical Imagery") បានលើកឡើងថា "បរិយាកាសនៃការសម្រាកក៏សាយភាយពាសពេញពិធីជប់លៀងក្នុងព្រះគម្ពីរសញ្ញាចាស់» ហើយលើកឡើងការពណ៌នាដូចតទៅអំពីបុណ្យពោរ៖ «គឺដោយហេតុនោះបានជាពួកសាសន៍យូដា…គេកាន់ថ្ងៃ១៤ ខែផល្គុន ជាថ្ងៃសម្រាប់រីករាយសាទរ ហើយជប់លៀង ជាថ្ងៃសប្បាយ ហើយជាពេលជូនជំនូនទៅវិញទៅមក» (នាងអេសធើរ ៩:១៩)។ អត្ថបទនោះបន្តលើកឡើងថា ពិធីជប់លៀង «មានអមទៅដោយអារម្មណ៍រំភើប និងការលះបង់ចោលអារម្មណ៍អៀនប្រៀន។[៨]

ពេលវេលានៃការប្រារព្ធពិធីរួមគ្នាក៏ត្រូវបានកត់សម្គាល់ដោយមានបទចម្រៀងបង្ហាញអំពីសេចក្តីអំណរ និងការអរព្រះគុណ ដូចដែលមានពណ៌នាខាងក្រោមនេះដែរ៖

ចូរបន្លឺសម្លេងឡើង ច្រៀងថ្វាយព្រះដ៏ជាកម្លាំងនៃយើងខ្ញុំ
ចូរបញ្ចេញសំឡេងអំណរថ្វាយព្រះនៃយ៉ាកុបចុះ

ចូរច្រៀងទំនុក ហើយវាយក្រាប់ចុះ
ព្រមទាំងចាប់ស៊ុងដ៏ពីរោះ នឹងដេញពិណាផង

ចូរផ្លុំត្រែក្នុងថ្ងៃដើមខែ ថ្ងៃពេញបូណ៌
នឹងថ្ងៃបុណ្យរបស់យើងខ្ញុំផង

ដ្បិតនោះហើយជាច្បាប់សម្រាប់សាសន៍អ៊ីស្រាអែល
គឺជាបញ្ញត្តិរបស់ព្រះនៃយ៉ាកុប (ទំនុកតម្កើង ៨១:១-៤)។

ព្រះជាម្ចាស់បានចេញព្រះរាជបញ្ជាឲ្យពួកគាត់មានអំណរជាមួយតន្ត្រីនៅថ្ងៃជប់លៀង។

វាមិនមែនជារឿងចៃដន្យនោះទេដែលតន្ត្រីបានក្លាយជាកត្តាដ៏សំខាន់មួយនៅក្នុងការប្រារព្ធកម្មវិធីចម្បងៗពីរយ៉ាងរបស់គ្រីស្ទបរិស័ទ៖ ថ្ងៃព្រះអង្គមានព្រះជន្មរស់ឡើងវិញ និងថ្ងៃបុណ្យណូអែល។ លោកគ្រូ ចន វែសលី (John Wesley) បានមានប្រសាសន៍ថា «ការច្រៀងក៏ជាភាសានៃអំណរបរិសុទ្ធ ដូចជាការអធិស្ឋានជាសេចក្តីប្រាថ្នាដ៏បរិសុទ្ធដែរ»។[៩] ពេលខ្លះ ការដែលយើងផ្តោតលើការសម្តែងការធ្វើកម្មវិធីបុណ្យណូអែល និងថ្ងៃព្រះអង្គមានព្រះជន្មរស់ឡើងវិញអាចដកសេចក្តីអំណរចេញបាន ប៉ុន្តែវាមិនចាំបាច់ត្រូវតែដូចនេះនោះទេ។ យើងអាចប្តេជ្ញាចិត្តឲ្យបានលទ្ធផលដែលល្អបាន ដោយមិនចាំបាច់មានការលះបង់អំណរចោល។ មានគេធ្លាប់សួរករី យ៉ូសែប ហេដិន (Joseph Haydn ឆ្នាំ១៧៣២-១៨០៩) ថា ហេតុអ្វីបានជាក្រុមជំនុំរបស់គាត់មានបទចម្រៀងដែលមានភាពរីករាយ។ គាត់បានឆ្លើយតបថា៖ «នៅពេលខ្ញុំគិតអំពីព្រះជាម្ចាស់ ដួងចិត្តរបស់ខ្ញុំមានពេញដោយអំណរ ដែលការនោះនាំឲ្យអក្សរភ្លេងលោតរាំ ដូចដែលវាបានធ្វើ ចេញពីទឹកប៊ិចរបស់ខ្ញុំ ហើយដោយសារព្រះជាម្ចាស់បានប្រទានដួងចិត្តដែលមានការរីករាយដល់ខ្ញុំ នោះខ្ញុំក៏និងទទួលបានការអភ័យទោសលើកលែង ដោយបម្រើទ្រង់ដោយមានចិត្តរីករាយដែរ។[១០]

កូនៗគួរតែដឹងថា ពួកគាត់អាចទន្ទឹងរង់ចាំពេលវេលាសប្បាយៗក្នុងអំឡុងពេលមានថ្ងៃបុណ្យណាមួយ។ ប៉ុន្តែ លោក ស្វាហ្វូនដ៍ បានចង្អុលបង្ហាញអំពីការប្រឈមមុខធំមួយ ដែលអ្នកដឹកនាំជួបប្រទះក្នុងការប្រារព្ធ៖ «ការប្រារព្ធកម្មវិធីណាមួយទាមទារឲ្យមានពេលវេលា។ មនុស្សដែលមមាញឹកមិនមានពេលវេលាគ្រប់គ្រាន់ដែលកម្មវិធីទាមទារឲ្យមានក្នុងការចូលរួមទេ។ ទោះបើវាជាថ្ងៃបុណ្យជាតិក៏ដោយ...ក៏ពួកគាត់នៅចង់បានភាពជោគជ័យយ៉ាងខ្លាំងរហូតដល់ថាពួកគាត់មិនបានសម្រាក និងចូលរួមប្រារព្ធឡើយ។ ពួកគាត់មិនបានឃើញពីគោលបំណងទាល់តែសោះ»។ ការនេះកើតចេញពីការយល់ឃើញថា ទំនៀមទម្លាប់ និងការប្រារព្ធទាំងនេះមិនមែនជាអំណោយដែលព្រះជាម្ចាស់បានប្រទានដល់យើង។ លោក ស្តាហ្វ័ត ក៏បន្តទៀតថា៖ «ថ្ងៃឈប់សម្រាកមិនមានគោលបំណងចង់បានតែផលប្រយោជន៍នោះទេ។ មិនមានអ្វីដែលយើងអាចរៀនបានចេញពីការដើរជាក្បួនទេ។ ដែលនោះគឺជាផ្នែកមួយនៃគោលបំណង។ គោលបំណងគឺថា មិនមានគោលបំណងអ្វីទេ។ ការមានសេចក្តីអំណរមិនមែនតែអំពីភាពជោគជ័យក្នុងការសម្រេចបានអ្វីមួយនោះទេ»។[១១]

កាលកូនៗយើងនៅជាមួយយើង យើងបានបង្កើតទំនៀមទម្លាប់មួយចំនួន ដែលបានក្លាយជាទិដ្ឋភាពដ៏មានអត្ថន័យសម្រាប់ការប្រារព្ធពិធីបុណ្យណូអែល។ យើងបានកំណត់ពេលមួយថ្ងៃក្នុងខែធ្នូ ដើម្បីដើរទិញរបស់របរ។ ដោយសាររដូវកាលបុណ្យណូអែលជាពេលវេលាដ៏រវល់សម្រាប់ខ្ញុំ ខ្ញុំក៏បានកត់ត្រាថ្ងៃនៃការដើរទិញរបស់របរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្ញុំជាច្រើនសប្តាហ៍មុនថ្ងៃបុណ្យណូអែលមកដល់។ នៅពេលកូនស្រីរបស់ខ្ញុំមានវ័យធំល្មម នោះគាត់ក៏ចាប់ផ្តើមរៀបគម្រោងផែនការសម្រាប់ថ្ងៃនោះ៖ ទីកន្លែងទៅទិញរបស់របរ ទីកន្លែងញ៉ាំ។ល។ យើងតែងតែរៀបចំតុបតែងផ្ទះនៅយប់មុនថ្ងៃបុណ្យណូអែល។ យើងក៏បានធ្វើការនេះបែបជាគ្រួសារដែរ។

ពួកសាសន៍យូដាក៏រាប់ថ្ងៃសប្ប័ទថាជាថ្ងៃបុណ្យដែរ។ ពួកគាត់មានទំនៀមទម្លាប់ពិសេសៗក្នុងការរក្សាថ្ងៃនេះទុក ដែលជាថ្ងៃសម្រាប់ផ្តោតលើគ្រួសារ។

សព្វថ្ងៃនេះ យើងក៏គួរតែព្យាយាមប្រាកដថា យើងនឹងមានថ្ងៃឈប់សម្រាកនេះដែរ ដើម្បីឲ្យគ្រួសាររបស់យើងមានភាពស្រស់ស្រាយឡើងវិញ។ សម្រាប់យើងដែលបម្រើក្នុងព័ន្ធកិច្ច ថ្ងៃអាទិត្យគឺមិនមែនជាថ្ងៃសម្រាកទេ។ ខ្ញុំធ្លាប់យកថ្ងៃពុធជាថ្ងៃឈប់សម្រាកជារៀងរាល់សប្តាហ៍ (ឥឡូវនេះ ទោះបើខ្ញុំព្យាយាមមានថ្ងៃសម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍ វាមិនចាំបាច់ជាថ្ងៃដូចគ្នារាល់សប្តាហ៍នោះទេ)។ ប្រសិនបើកូនៗរបស់ខ្ញុំឮការសន្ទនាមួយដែលជំរុញឲ្យខ្ញុំមិនទំនេរនៅថ្ងៃពុធ នោះពួកគាត់នឹងនិយាយដោយលើកឡើងដូចនេះថា «ប៉ុន្តែ នេះគឺជាថ្ងៃសម្រាករបស់ប៉ា!»។ ពួកគាត់បានទន្ទឹងរង់ចាំចំណុចដែលថា ថ្ងៃនោះគ្រួសារនឹងទទួលបានចំណាប់អារម្មណ៍របស់ខ្ញុំទាំងស្រុង។

វិស្សមកាលក៏ជាទំនៀមទម្លាប់ដ៏សំខាន់មួយសម្រាប់គ្រួសារដែរ។ ប្រសិនបើយើងសួរក្មេងវ័យជំទង់ណាម្នាក់អំពីបទពិសោធន៍នៃការចងចាំដ៏សប្បាយដែលគាត់មានកាលនៅក្មេង នោះគាត់នឹងមានការលើកឡើងអំពីវិស្សមកាលសម្រាប់គ្រួសារជាមិនខាន។ សព្វថ្ងៃនេះ អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទជាច្រើននាក់មិនមានលទ្ធភាពក្នុងការមានទំនៀមទម្លាប់នៃការចេញទៅដើរលេងបែបនេះទៀតទេ។ ដូច្នេះ ពួកគាត់ត្រូវតែប្រើប្រាស់ភាពច្នៃប្រឌិតក្នុងការស្វែងរកកន្លែងផ្សេងៗ ដែលនឹងនាំឲ្យគ្រួសារមានអំណរក្នុងការចំណាយពេលក្នុងថ្ងៃឈប់សម្រាកនោះជាមួយគ្នា។ ខ្ញុំស្គាល់អ្នកដែលទៅលេងមិត្តភក្តិ និងសាច់ញាតិដែលរស់នៅទីក្រុងមួយផ្សេងទៀត។ កាលកូនៗខ្ញុំនៅតូចនៅឡើយ យើងបានទៅកន្លែងមួយនៅក្បែរមាត់សមុទ្រសម្រាប់ថ្ងៃសម្រាករបស់យើង។ នៅពេលយើងចេញពីឡាន កូនស្រីរបស់ខ្ញុំបាននិយាយថា «កូនសង្ឃឹមថានឹងមិនមានគ្រីស្ទបរិស័ទនៅទីនេះទេ!»។ គាត់ដឹងថា ប្រសិនបើមានគ្រីស្ទបរិស័ទនៅទីនោះ នោះខ្ញុំនឹងមានការបែកអារម្មណ៍ ដោយសារនឹងមានអ្នកចង់មកនិយាយលេងជាមួយខ្ញុំ។ ខណៈពេលដែលយើងដើរចូលទៅក្នុងរីស៊ត នៅខាងមុខយើងក៏មានក្រុមមួយដែលមកពីក្រុមជំនុំដែលខ្ញុំឧស្សាហ៍ទៅអធិប្បាយ។ ពួកគាត់បានមកបោះជំរុំបែបជាក្រុមជំនុំ។ ប្រហែលជាអ្នកដឹកនាំបានប្រាប់

ក្រុមជំនុំឲ្យទុកពេលឲ្យយើងសម្រាកហើយ ដោយសារមិនមាននរណាមកនិយាយរកយើងសោះ! ហេតុការណ៍នេះបានបង្ហាញឲ្យយើងឃើញថា កូនៗរបស់យើងចង់ឲ្យយើងមានពេលជាមួយនឹងពួកគាត់យ៉ាងពេញលេញ ក្នុងអំឡុងពេលសប្បាយៗ។

នៅមានកម្មវិធីផ្សេងៗទៀតដែលខ្ញុំអាចគិតបានដូចជា ថ្ងៃខួបកំណើត និងខួបអាពាហ៍ពិពាហ៍ជាដើម។ ជាថ្មីម្តងទៀត យើងគួរតែគិតអំពីការមានអំណរក្នុងពេលវេលាបែបនេះ មិនមែនជាការបង្អួតនោះទេ ប៉ុន្តែសម្រាប់ជាអំណរនៅក្នុងគ្រួសាររបស់យើងផ្ទាល់វិញ។ សម្រាប់ថ្ងៃខួបកំណើតខ្ញុំ ជាញឹកញាប់ខ្ញុំនិងប្រពន្ធខ្ញុំបានសម្រេចចិត្តថា យើងនឹងគ្រាន់តែធ្វើបែបលក្ខណៈជាគ្រួសារដោយមិនអញ្ជើញអ្នកដទៃឲ្យចូលរួមទេ។ វាជាផ្នែកមួយនៃការងាររបស់ខ្ញុំក្នុងការចូលរួមការប្រារព្ធកម្មវិធីផ្សេងៗរបស់មនុស្សជាច្រើន។ យើងបានគិតថាជាការទូទាត់គ្នាមួយក្នុងការមានជីវិតរស់នៅបែបជាសាធារណៈនោះ គឺការធ្វើកម្មវិធីខួបកំណើតបែបឯកជនភាពសម្រាប់យើងផ្ទាល់។ ចំណែកឯកូនៗវិញ ពួកគាត់ចូលចិត្តធ្វើកម្មវិធីខួបរបស់ខ្លួនជាមួយនឹងមិត្តភក្តិ។ ប៉ុន្តែ យើងត្រូវចងចាំថា គោលការណ៍ដ៏សំខាន់នៃអំណរដ៏ពិតរបស់យើង គឺលើសពីរូបរាងខាងក្រៅទៅទៀត។ នៅប្រទេសស្រីលង្កា មានមនុស្សមួយចំនួនចូលចិត្តធ្វើកម្មវិធីធំៗសម្រាប់ខួបដំបូងនៃកូនៗរបស់ខ្លួនណាស់—ជាថ្ងៃដែលកូននោះនឹងមិនបានចាំទេ។ ប្រសិនបើវាជាកម្មវិធីធំ នោះវាអាចក្លាយជាបទពិសោធន៍ច្របូកច្របល់ និងធ្វើឲ្យមានការភ័យខ្លាចដល់កូនជាមិនខាន។ ខ្ញុំស្គាល់មនុស្សមួយចំនួនដែលបានជំពាក់បំណុលគេ ដោយសារធ្វើកម្មវិធីធំៗដូចនោះ។ ការជប់លៀងដូចនោះមិនបានផ្តល់នូវអំណរដល់គ្រួសារទេ ជាពិសេសប្រសិនបើបញ្ចប់ដោយគ្រួសារជាប់បំណុលដូចនោះ។

## ការមើលថែរក្សាកូនៗឲ្យមានសុវត្ថិភាព

យើងរស់នៅក្នុងពិភពលោកមួយ ដែលខ្វះសន្តិភាពបានក្លាយជាសមាមាត្រនៃជំងឺរាតត្បាតហើយ។ ទស្សនៈជ្រុលនិយម និងកំហឹងនៃជំងឺផ្លូវចិត្តបាននាំឲ្យយើងងាយឈឺចាប់ចំពោះតុល្យភាពនៃការក្លាយជាជនរងគ្រោះនៃការវាយប្រហារដ៏ឃោរឃៅ។ វប្បធម៌របស់យើងបានជំរុញយើងឲ្យមើលអ្នកដទៃថាជាអ្នកប្រកួតប្រជែងជាមួយយើង ដែលជាលទ្ធផល យើងឃើញមនុស្សដែលគួរតែជាមិត្តភក្តិរបស់យើងថាជាអ្នកគម្រាមកំហែងយើងទៅវិញ។ ការចង់បានភាពស្រណុកសុខស្រួលអាចទំនងជានាំឲ្យយើងស្តីបន្ទោសអ្នកដទៃ ជាពិសេសកូនៗ ទាក់ទងនឹងការដកភាពស្រណុកសុខស្រួលរបស់យើង។ វត្តមាននៃមនុស្សដែលកេងប្រវ័ញ្ចប្រយោជន៍អ្នកដទៃដូចនេះ ជាពិសេសអស់អ្នកដែលប្រព្រឹត្តចំពោះក្មេងៗ ក៏អាចធ្វើឲ្យពិភពលោកនេះបានក្លាយជាកន្លែងដែលមិនមានសុវត្ថិភាពសម្រាប់ក្មេងៗផងដែរ។

តើយើងអាចតទល់នឹងការធ្វើបែបនេះបានដោយរបៀបណា? របៀបមួយដែលមនុស្សអាចលូតលាស់នៅក្នុងបុគ្គលលក្ខណៈបានគឺតាមរយៈការមានបទពិសោធន៍យ៉ាងកក់ក្តៅចេញពីសេចក្តីស្រឡាញ់ និងការបារម្ភអំពីក្រុមគ្រួសាររបស់ខ្លួន។  នៅពេលមនុស្សបានធំធាត់ឡើងដោយទទួលបាននូវសេចក្តីស្រឡាញ់ នោះពួកគាត់នឹងមិនសូវងាយធ្លាក់ក្នុងសេចក្តីល្បួងនៃការទៅរករបៀបមិនល្អៗណាមួយ ដើម្បីស្វែងរកសុវត្ថិភាពនៅក្នុងជីវិតទេ។

### *សេចក្តីស្រឡាញ់របស់អ្នកម្តាយការពារកូនៗ*

នៅក្នុងជំពូកមុន យើងបានឃើញអំពីការដែលសាវ័ក ប៉ុល បានពណ៌នាអំពីព័ន្ធកិច្ចរបស់គាត់នៅទីក្រុងថែស្សាឡូនីចថា ស្រដៀងគ្នាទៅនឹងអាកប្បកិរិយារបស់ម្តាយម្នាក់។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា “គឺយ៉ាងនោះហើយដែលយើងខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នា ដល់ម៉្លេះបានជាយើងខ្ញុំចូលចិត្តចែកដំណឹងល្អពីព្រះ មកអ្នករាល់គ្នា មិនត្រឹមតែប៉ុណ្ណោះ ក៏ចូលចិត្តចែកទាំង

ជីវិតយើងខ្ញុំផង ដោយព្រោះអ្នករាល់គ្នាបានត្រឡប់ជាស្ងួនភ្ងាដល់យើងខ្ញុំ» (១ថែស្សាឡូនិច ២:៨)។ គេបានបកប្រែឃ្លា «យើងខ្ញុំបានស្រឡាញ់...ដល់ម្ល៉េះ» ពីភាសាក្រិកថា «ហូមៀរ៉ូម៉ាអី» (homeiromai) ដែលនោះមានជាគំនិតនៃការមានបទពិសោធន៍ក្នុងការប្រាថ្នាស្រឡាញ់នរណាម្នាក់។[១២] ដូចដែលយើងបានលើកឡើងនៅក្នុងជំពូកមុន កូនៗគួរតែដឹងថា ម្ដាយរបស់ខ្លួនមានសេចក្ដីប្រាថ្នាចំពោះពួកគាត់។ ពួកគាត់មិនមែនជាលទ្ធផលនៃកំហុស ឬក៏ជាអ្នករំខាននោះទេ។ សាវ័ក ប៉ុល កំពុងលើកឡើងថា ម្ដាយមានចិត្តចង់ឃើញកូនៗរបស់ខ្លួនខ្លាំង ហើយគាត់ «មានបំណង» (គខប) ដល់ទៅស៊ូប្ដូរជីវិត សម្រាប់បងប្អូនថែមទៀតផងដែរ។ នៅពេលដែលគាត់មើលកូនៗខ្លួន ដោយមានការលះបង់ផ្ទាល់ខ្លួនយ៉ាងខ្លាំង គឺគាត់មិនធ្វើដោយមានការស្ទាក់ស្ទើរចិត្តទេ តែធ្វើពីការមានតួនាទី និងការស្ម័គ្រចិត្ត ដែលកើតចេញពីអាកប្បកិរិយានៃការពេញចិត្ត។

យើងបានមើលអំពីតម្លៃនៃភាពអរសប្បាយរបស់ឪពុកម្ដាយទៅលើកូនៗរបស់ខ្លួន នៅក្នុងជំពូកមុននេះ។ នៅត្រង់នេះ ខ្ញុំចង់ពិភាក្សាអំពីគុណប្រយោជន៍នៃការមើលថែបែបនេះ។ ចាប់តាំងពីពេលដែលពួកគាត់នៅក្មេងៗនៅឡើយ ពួកគាត់បានប្រឈមមុខនឹងការបដិសេធ និងរងគ្រោះការឈឺចាប់ពីវប្បធម៌ដ៏ឃោរឃៅផងដែរ។ វាពិតជារឿងដ៏ភ្ញាក់ផ្អើលណាស់ដែលក្មេងៗក៏ទទួលរងការឈឺចាប់ពីមិត្តភក្ដិរបស់ខ្លួននៅឯសាលារៀន សូម្បីតែនៅមុនវ័យជំទង់ដែរ។ ក្នុងលោកីយ៍ដែលពេញដោយការប្រកួតប្រជែង ដែលក្មេងៗតែងតែប្រឈមមុខនឹងការបដិសេធ ហើយក៏ទទួលអារម្មណ៍នៃការអន់ចិត្តពីអ្នកដទៃដែរ នោះពួកគាត់នឹងមានភាពស្រស់ស្រាយឡើងវិញតាមរយៈការដឹងថា ម្ដាយរបស់ខ្លួនសប្បាយរីករាយចំពោះពួកគាត់ ហើយក៏ពេញចិត្តក្នុងការធ្វើអ្វីៗដែលចាំបាច់សម្រាប់សុខុមាលភាពរបស់ពួកគាត់ផងដែរ។ ការធ្វើបែបនេះបានធ្វើឲ្យពួកគាត់ដឹងអំពីតម្លៃរបស់ខ្លួន។ សេចក្ដីស្រឡាញ់ និងការឲ្យដោយចិត្តសប្បាយរីករាយរបស់អ្នកម្ដាយជួយយកឈ្នះលើបទពិសោធន៍

នៃការបដិសេធរបស់ក្មេងៗ (១ថែស្សាឡូនិច ២:៨)។

នៅក្នុងផ្នែកដូចគ្នានៃកណ្ឌគម្ពីរថែស្សាឡូនីចខ្សែទី១ សាវ័ក ប៉ុល ក៏បានមានប្រសាសន៍ផងដែរថា «យើងខ្ញុំបាននៅកណ្តាលអ្នករាល់គ្នា ដោយស្លូតបូតវិញ ប្រៀបដូចជាម្តាយថ្នមកូន ដែលកំពុងនៅបៅ» (ខ៧)។ ដូចដែលខ្ញុំបានកត់សម្គាល់នៅក្នុងជំពូកមុន ពាក្យដែលបានបកប្រែថា "ថ្នម" មានន័យថា "ថែរក្សា" ដោយបង្ហាប់នូវអត្ថន័យនៃសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ចំពោះ។ លោក លេអូន ម៉ូរិស៍ (Leon Morris) បានលើកឡើងថា "កិរិយាសព្ទនៃពាក្យ "ថ្នម" មានន័យជាចម្បងថា "ធ្វើឲ្យមានភាពកក់ក្តៅ" គេបានប្រើប្រាស់ពាក្យនេះសម្រាប់មេសត្វចាប (ចោទិយកថា ២២:៦) ហើយពាក្យនេះក៏នាំមកកាន់អត្ថន័យបន្ទាប់បន្សំមួយទៀតថា "ជាការថ្នាក់ថ្នម" "ការមើលថែដោយសេចក្តីស្រឡាញ់""»។[១៣] ចំណុចដែលថា ការនេះមានការប្រព្រឹត្តឡើងដោយមានការថ្នាក់ថ្នមនាំមកនូវគោលគំនិតដែលថា ម្តាយមានការយល់អំពីតម្រូវការពិសេសៗរបស់កូន និងបុគ្គលិកលក្ខណៈរបស់កូនដែរ។

ខ្ញុំគិតថា សព្វថ្ងៃនេះ កុមារងាយទទួលយកឥទ្ធិពលអាក្រក់ៗខ្លាំងជាងពេលមុនៗ នៅក្នុងប្រវត្តិសាស្ត្រទៅទៀត។ សព្វថ្ងៃនេះ ការរំលោភបំពានផ្លូវភេទកុមារកំពុងរីករាលដាលនៅលើពិភពលោកនេះខ្លាំងណាស់។ ក្មេងៗពិតជាងាយនឹងបានមើលរូបអាសអាភាស និងអំពើហិង្សាតាមរយៈបណ្តាញសង្គម ឬក៏អ៊ីនធឺណិត ហើយយើងក៏មិនអាចប្រាកដបានយ៉ាងច្បាស់ថា ក្មេងៗទទួលបានការការពារចេញពីការជះឥទ្ធិពលអាក្រក់ៗពីអ្នកជិតខាង និងនៅសាលារៀនដែរ។ ការប្រុងប្រយ័ត្នពីម្តាយ (និងឪពុក) មានដំណើរការល្អក្នុងការប្រយុទ្ធប្រឆាំងចំពោះឥទ្ធិពលអាក្រក់ៗទាំងនេះបាន។ ដូចដែលសាវ័ក ប៉ុល បានពណ៌នាថា ការប្រុងប្រយ័ត្ននេះកើតឡើងដោយសេចក្តីស្រឡាញ់ ការឲ្យដោយចិត្តសប្បាយរីករាយ និងការមើលថែថ្នាក់ថ្នមដោយចិត្តសុភាពរបស់អ្នកម្តាយ។ ការមានសុវត្ថិភាពគឺជាលទ្ធផលនៃសេចក្តីស្រឡាញ់របស់អ្នកម្តាយដូចនេះ។ បំណងប្រាថ្នារបស់យើងសម្រាប់កូនៗ និងភាពសប្បាយរីករាយ

នៅក្នុងកូនៗរបស់យើងផ្តល់ឲ្យពួកគាត់នូវការឲ្យតម្លៃលើខ្លួន នៅក្នុងវប្បធម៌នៃការប្រកួតប្រជែងដែលតែងតែមានមនុស្សបដិសេធ។ ការមើលថែដោយចិត្តសុភាពផ្តល់ឲ្យកូនៗមានការការពារឲ្យរួចផុតពីឥទ្ធិពលដែលមានគ្រោះថ្នាក់។

## *ការមិនផ្តោតអារម្មណ៍ពេញលេញអាចនាំឲ្យកូនៗមានបញ្ហា*

ពេលខ្លះខ្ញុំមានអំនួតក្នុងការដែលខ្ញុំអាចធ្វើកិច្ចការជាច្រើនក្នុងពេលតែមួយ ទោះបើឥឡូវសមត្ថភាពខ្ញុំបានថយចុះដោយសារខ្ញុំចាស់ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយក៏ការធ្វើកិច្ចការជាច្រើនក្នុងពេលតែមួយអាចនាំឲ្យមានបញ្ហាក្នុងទំនាក់ទំនងដែរ។ ប្រពន្ធរបស់ខ្ញុំមានអារម្មណ៍រំខានពីខ្ញុំ នៅពេលខ្ញុំធ្វើការជាមួយកុំព្យូទ័រ ឬចុចទូរស័ព្ទខណៈពេលដែលគាត់កំពុងនិយាយជាមួយខ្ញុំ។ ខ្ញុំអះអាងថា ខ្ញុំអាចបន្តការសន្ទនាបានយ៉ាងល្អ ខណៈពេលដែលខ្ញុំធ្វើការទាំងនេះ ប៉ុន្តែខ្ញុំដឹងថាខ្ញុំមិនបានផ្តោតអារម្មណ៍ពេញលេញទៅលើគាត់នោះទេ។

ការផ្តោតអារម្មណ៍មិនពេញលេញបែបនេះអាចជាការបំផ្លាញដល់ក្មេងៗយ៉ាងខ្លាំងផងដែរ។ ប្រសិនបើម្តាយរបស់ពួកគាត់តែងតែធ្វើការនៅលើទូរស័ព្ទខណៈពេលពួកគាត់កំពុងមើលកូនៗរបស់ខ្លួន នោះកូនៗនឹងខកខានក្នុងការទទួលបានភាពសម្បូរបែប ដែលកើតចេញពីការមិនបែកអារម្មណ៍របស់ម្តាយ។ ដោយពិចារណាលើភាពមមាញឹក ដែលជាបញ្ហាធ្ងន់ធ្ងរ សម្រាប់ឪពុកម្តាយនៅសព្វថ្ងៃនេះ នោះពួកគាត់គួរតែមានការប្រុងប្រយ័ត្នខ្ពស់អំពីការបន្ថែមការងារណាផ្សេងទៀត ដែលរារាំងពួកគាត់មិនឲ្យផ្តោតអារម្មណ៍ពេញលេញចំពោះកូនៗរបស់ខ្លួន និងចំពោះគ្នាទៅវិញទៅមកផងដែរ។

ការមានមិត្តភក្តិរាប់រយនាក់នៅក្នុងហ្វេសប៊ុកអាចធ្វើឲ្យយើងមិនមានពេលគ្រប់គ្រាន់ក្នុងការបណ្តុះទំនាក់ទំនងដែលមានភាពស៊ីជម្រៅ និងមានភាពជិតស្និទ្ធជាមួយអ្នកដែលនៅជិតយើងបំផុត។ កណ្ឌគម្ពីរ សុភាសិត ១៨:២៤ អាចទំនងជាមានអ្វីមួយសំខាន់ក្នុងការប្រាប់ពួកយើងដែលកំពុងរស់នៅក្នុងជំនាន់ឌីជីថល (digital) ដោយមានការញៀនជាមួយនឹងប្រព័ន្ធបណ្តាញ

សង្គមៈ «អ្នកណាដែលមានមិត្តភក្តិច្រើន នោះនាំឲ្យវិនាសខ្លួនទេ ប៉ុន្តែ មានមិត្តសម្លាញ់ម្យ៉ាង ដែលនៅជាប់ជាងបងប្អូនទៅទៀត»។ បើមានមិត្តភក្តិជាច្រើនដែលយើងគ្រាន់តែមានទំនាក់ទំនងសើៗជាមួយពួកគេ នោះយើងអាចទំនងជាបំផ្លាញទំនាក់ទំនងជាមួយអស់អ្នកដែលសំខាន់បំផុតសម្រាប់យើង ដូចជា ដៃគូជីវិតយើង កូនៗ និងមិត្តជិតស្និទ្ធរបស់យើងដែរ។

ខ្ញុំមានទំនាក់ទំនងស្និទ្ធស្នាលជាមួយនឹងសង្គមគ្រីស្ទបរិស័ទដែលញៀនថ្នាំនៅប្រទេសស្រីលង្កា អស់រយៈពេលប៉ុន្មានជាលើស២០ឆ្នាំហើយ។ ចំណុចសង្កេតមួយដែលខ្ញុំបានឃើញគឺថា ម្តាយជាច្រើននាក់នៃសិស្សទាំងនោះនៅក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ ដែលស្នាក់នៅមណ្ឌលកែប្រែអ្នកញៀនថ្នាំ សុទ្ធតែធ្វើការនៅកន្លែងឆ្ងាយៗពីគ្រួសារ អស់រយៈពេលជាច្រើនឆ្នាំខណៈពេលដែលពួកសិស្សកំពុងតែធំធាត់ឡើង។ ក្រោយមកទៀត នេះគឺជាការពិតសម្រាប់មនុស្សជាច្រើននាក់នៅក្នុងប្រទេសដែរ។ ដើម្បីជួយគ្រួសារឲ្យរួចផុតពីភាពក្រីក្រ ម្តាយក៏ត្រូវចាកចេញពីផ្ទះ ហើយទៅធ្វើការយ៉ាងនឿយហត់។ ដោយមិនមានប្រពន្ធនៅជិត នោះប្តីក៏ចាប់ផ្តើមផឹកស្រា ហើយពេលខ្លះទៀតក៏មានអំពើកំផិតជាមួយស្រីផ្សេងដែរ។ កូនៗមិនទទួលបានការថែរក្សាត្រឹមត្រូវទេ។ យាយតា ឬក៏សាច់ញាតិដែលមើលថែពួកគាត់មិនមានចំណេះដឹង ឬលទ្ធភាពត្រឹមត្រូវក្នុងការការពារពួកគាត់ឲ្យរួចផុតពីការទាំងនោះ ដូចជាការរំលោភបំពាន និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតជាដើម។ ហើយជាលទ្ធផលក្មេងៗជាច្រើននាក់ក្នុងចំណោមក្មេងៗទាំងនោះ ជាពិសេសក្មេងស្រី ក៏ត្រូវទទួលរងគ្រោះនូវការរំលោភបំពានខាងឯផ្លូវភេទ។ ក្មេងប្រុសៗក៏ញៀនជាមួយនឹងការមើលរូបអាសអាភាស។ បញ្ហាទាំងនេះអាចបំផ្លាញឱកាសនៃការមានទំនាក់ទំនងផ្លូវភេទដ៏រីករាយបាន នៅក្នុងជីវិតអាពាហ៍ពិពាហ៍។ ភ្លាមៗនោះដែរ ពួកគាត់ក៏បានរកឃើញថា ការប្រើប្រាស់គ្រឿងញៀនជាបណ្តោះអាសន្នតែងតែបំពេញចន្លោះនៃការឈឺចាប់នៅក្នុងដួងចិត្តរបស់ពួកគាត់ ដែលកើតឡើងមកពីម្តាយមិនមានវត្តមាន។

ចំពោះអ្នកម្ដាយដែលចេញទៅធ្វើការនៅខាងក្រៅផ្ទះ ពួកគាត់គួរតែដឹងអំពីគ្រោះថ្នាក់ទាំងនេះនៅក្នុងគំនិតរបស់ពួកគាត់ ហើយសួរថាតើពួកគាត់នឹងមានការខកខានក្នុងការផ្ដល់ឲ្យកូនៗរបស់ខ្លួននូវឱកាសនៃការលូតលាស់ក្នុងបរិយាកាសដែលមានសុវត្ថិភាព ឬក៏យ៉ាងណា។ ពួកគាត់អាចជ្រើសរើសយកការងារណាមួយដែលមានចំណូលមិនស័ក្ដិសមនឹងសមត្ថភាពរបស់គាត់ដើម្បីឲ្យគាត់អាចមានពេលនៅជាមួយកូនៗរបស់គាត់បានច្រើនជាងមុន។ ឬក៏ពួកគាត់អាចសម្រេចចិត្តនៅផ្ទះក្នុងរយៈពេលពីរទៅបីឆ្នាំដំបូង នៅពេលកូនៗនៅតូចនៅឡើយ។ ការធ្វើបែបនេះអាចរារាំងការឡើងតំណែងក្នុងការងាររបស់ពួកគាត់ ប៉ុន្តែនេះជាតម្លៃមួយដ៏ស័ក្ដិសមក្នុងការលះបង់ ដើម្បីចិញ្ចឹមកូនៗឲ្យមានសុវត្ថិភាពល្អ។

ក្មេងៗដែលគេធ្លាប់ធ្វើបាបនឹងធំធាត់ឡើងដោយមានពិការភាពធ្ងន់ធ្ងរ។ ចំពោះក្មេងៗដែលត្រូវបានគេធ្លាប់ដាក់វិន័យយ៉ាងអយុត្តិធម៌ក៏ទំនងអាចជាមានកំហឹងខ្លាំង ខុសពីធម្មតា នៅពេលដែលពួកគាត់ធំធាត់ឡើង ហើយឃើញការប្រព្រឹត្តអយុត្តិធម៌។ នៅក្នុងសៀវភៅរបស់លោក ដេវីឌ ស៊ីមែន (David Seamands) ដែលមានចំណងជើងថា “ការព្យាបាលអារម្មណ៍ដែលបានខូចខាត” (“Healing for Damaged Emotions”) គាត់បានចង្អុលបង្ហាញថា “នៅពេលដែលលោកអ្នកមានបទពិសោធន៍ក្នុងការឆ្លើយតបផ្ទាល់ ដោយមានសមាមាត្រខុសពីការជំរុញ សូមមានការប្រុងប្រយ័ត្ន។ លោកអ្នកទំនងជាបានប៉ះអ្វីមួយ ដែលមានការលាក់បានយ៉ាងជ្រាលជ្រៅទាក់ទងទៅនឹងការឈឺចាប់ផ្នែកអារម្មណ៍”។[១៤] ពេលខ្លះ មនុស្សយើងមានបញ្ហាប្រឈមយ៉ាងខ្លាំងជាមួយនឹងភាពត្រេកត្រអាលដែលជាផលពិបាកនៃការរំលោភបំពានខាងផ្លូវភេទកាលគាត់នៅក្មេងនៅឡើយ។ គ្មាននរណាម្នាក់ដឹងទេ រហូតទាល់តែមានការភ្លាត់ចេញខាងផ្នែកសីលធម៌មួយរំពេចតែម្ដង នោះទើបគ្រប់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ប៉ុន្តែ ការរំលោភបំពានខាងផ្លូវភេទក៏អាចមានលទ្ធផលនៅក្នុងការឆ្លើយតបផ្ទុយពីនេះដែរ—ការមិនចូលចិត្តការរួមដំណេកយ៉ាងខ្លាំង

ដែលនេះក៏អាចមានការប៉ះពាល់មិនល្អដល់ជីវិតអាពាហ៍ពិពាហ៍ដែរ។

តែអរព្រះគុណដល់ព្រះអង្គ តាមរយៈការប្រឹក្សាលើការឈឺចាប់នេះអាចនាំឲ្យមានការព្យាបាលដល់ស្នាមរបួសដូចនោះ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់។ យើងត្រូវតែនិយាយអំពីបញ្ហាទាំងនេះនៅក្នុងរង្វង់គ្រីស្ទបរិស័ទ ដើម្បីឲ្យអស់អ្នកដែលមានរបួសដូចនេះអាចមានភាពក្លាហានក្នុងការស្វែងរកអ្នកជំនួយ។ ប៉ុន្តែ តើវានឹងប្រសើរខ្លាំងប៉ុណ្ណាទៅ ប្រសិនបើពួកគាត់ទទួលបានការការពារ មិនឲ្យមានបទពិសោធន៍បែបដូចនេះ!

ការការពារកូនៗគឺជាផ្នែកដ៏សំខាន់មួយរបស់ឪពុកម្តាយ—ជាការងារមួយដែលសព្វថ្ងៃនេះកាន់តែពិបាកទៅៗណាស់។ ព្រះគម្ពីរមានផ្ទុកនូវការព្រមានដល់រាស្ត្ររបស់ព្រះជាម្ចាស់ឲ្យប្រឆាំងនឹងការជះឥទ្ធិពល ដែលបង្កឲ្យមានគ្រោះថ្នាក់ផ្សេងៗ។ មានកិរិយាសព្ទពីរប្រភេទនៅក្នុងកណ្ឌគម្ពីរដំណឹងល្អ ដែលមានគោលគំនិតក្នុងការព្រមានអំពីការមានគ្រោះថ្នាក់។ ពាក្យមួយគឺ “ប្រូសេកូ” (prosechō) ដែលបានបកប្រែថា “ប្រយ័ត្នខ្លួនឲ្យមែនទែន” ឬក៏ “ចូរប្រយ័ត្ន”។ ពាក្យនេះមានប្រើប្រាស់១០ដងនៅក្នុងដំណឹងល្អ។ ហើយពាក្យមួយទៀតគឺ “ប្លេកូ” (blepō) ដែលជាទូទៅមានន័យថា “មើល” ហើយមានប្រើប្រាស់១០ដងនៅក្នុងដំណឹងល្អដោយមានន័យថា “ចូរប្រយ័ត្ន” “ចូរប្រុងមើល ហើយប្រយ័ត្ន” ឬក៏ “ប្រុងប្រយ័ត្ន”។ ដូច្នេះ យើងឃើញថា មាន២០ដងនៅក្នុងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវដែលនាំមកនូវគំនិតនៃការព្រមានអំពីគ្រោះថ្នាក់។ សាវ័ក ប៉ុល តែងតែព្រមានដល់មិត្តអ្នកអានសំបុត្ររបស់គាត់អំពីគ្រោះថ្នាក់នៃគោលលទ្ធិ និងខាងផ្នែកសីលធម៌។ ដូចគ្នាផងដែរ ឪពុកម្តាយក៏គួរតែព្រមានកូនៗខ្លួនអំពីគ្រោះថ្នាក់ នៅក្នុងលោកីយ៍នេះ។ ខ្ញុំពិតជាអរគុណយ៉ាងខ្លាំងដល់អ្នកម្តាយខ្ញុំ ដែលគាត់តែងតែព្រមានខ្ញុំជានិច្ចអំពីគ្រោះថ្នាក់នៃតម្លៃមិនពិតក្នុងវប្បធម៌ទំនើបនេះ កាលពីខ្ញុំនៅវ័យជំទង់។ ខ្ញុំគិតថា ការនោះបានផ្តល់នូវការស្អប់លោកីយ៍នេះ យ៉ាងត្រឹមត្រូវ ហើយជាលទ្ធផលបាននាំឲ្យខ្ញុំខ្លាចធ្លាក់ក្នុងលោកីយ៍ដ៏ទាន់សម័យនេះ។ ដូច្នេះ ឪពុកម្តាយត្រូវតែប្រាកដ

ថា កូនៗរបស់ខ្លួននឹងមិនចាញ់ការជះឥទ្ធិពលនានា ដែលអាចនាំឲ្យការលូតលាស់របស់ពួកគាត់មានគ្រោះថ្នាក់។

*សេចក្ដីស្រឡាញ់របស់ឪពុកម្ដាយប្រយុទ្ធនឹងការប្រៀបធៀប*

កូនៗយើងប្រឈមមុខនឹងពិការភាពយ៉ាងខ្លាំង ដោយសារការធំធាត់ឡើងនៅក្នុងប្រពៃណីដែលគេប្រៀបធៀប និងបង្ហាញភាពផ្ទុយគ្នាជាមួយនឹងអ្នកដទៃ និងការដែលមនុស្សម្នាបន្ទាបបន្ថោកពួកគាត់។ នៅប្រទេសស្រីលង្កា យោងតាមអត្ថន័យនៃតម្លៃរបស់លោកីយ៍ដែលមានការប្រទាក់ប្រទិនគ្នាអំពីមនុស្ស នោះគេរាប់មនុស្សស្រីដែលមានស្បែកសថាស្អាតជាងស្រីដែលមានស្បែកខ្មៅ។ ខ្ញុំធ្លាប់បានឮគ្រីស្ទបរិស័ទ—ជាអ្នកដែលខ្ញុំជឿថា មិនមានបំណងអាក្រក់ទេ—បាននិយាយដោយមានពាក្យសម្ដីមិនល្អទៅកាន់កុមារដូចជាថា “ហេតុអីបានជាឯងខ្មៅម្ល៉េះ?” ឬក៏ថា “នាងសជាងឯងឆ្ងាយណាស់”។ ឬក៏ប្រយោគមួយចំនួនទៀតដូចជា “ហេតុអីបានជាឯងទាបម្ល៉េះ?” ឬក៏ “តើឯងអត់សម្រកគីឡូខ្លះទេអី?”។ ក្មេងៗដែលប្រឈមមុខនឹងការបដិសេធបែបនេះ ដោយសារមានពិការភាពដែលគេទទួលស្គាល់ អាចនឹងទំនងជាធំធាត់ឡើងដោយមិនមានសុវត្ថិភាព ដោយគិតថាខ្លួន មិនមានអ្នកណាប្រាថ្នាចង់បាន ជាពិសេសចំពោះភេទផ្ទុយគ្នា ពីព្រោះពួកគាត់ “មិនស្អាត”។ នៅពេលដែលពួកគាត់ក្លាយជាមនុស្សវ័យជំទង់ នោះពួកគាត់ទំនងជាងាយមានទំនាក់ទំនង ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់គាត់ដែរ។

យើងធ្លាប់បានឃើញការនេះកើតឡើងនៅក្នុងព័ន្ធកិច្ចយើង។ ក្មេងស្រីម្នាក់បានទទួលជឿព្រះគ្រីស្ទ ហើយស្វែងរកបានទីជម្រក ចេញពីលោកីយ៍នេះ នៅក្នុងការប្រកបយ៉ាងកក់ក្ដៅរបស់គ្រីស្ទបរិស័ទ។ គាត់បានត្រៀមចិត្តរួចរាល់ ហើយក្នុងការបម្រើព្រះជាម្ចាស់។ ប៉ុន្តែ គាត់នៅមានស្នាមរបួសដែលកើតមានឥតឈប់ឈរ ដោយសារពាក្យពេចន៍នៃការបដិសេធដែលគាត់បានជួបប្រទះនៅក្នុងផ្ទះ ឬក៏នៅសាលារៀនជាដើម។ បន្ទាប់មក គាត់បានជួបបុរស

វ័យក្មេងម្នាក់ដែលបង្ហាញពីការយកចិត្តទុកដាក់ និងគាំទ្រគាត់ដែលមិនធ្លាប់មាននរណាម្នាក់ធ្វើដាក់គាត់បែបនេះពីមុនៗមកទាល់តែសោះ។ គាត់មិនអាចទប់ទល់នឹងភាពទាក់ទាញនៃការសរសើរគាំទ្របែបនេះបានទេ។ គាត់ក៏មានទំនាក់ទំនងជាមួយបុរសនោះ ហើយអាចនឹងរើចូលទៅនៅជាមួយគាត់ ដែលមើលទៅហាក់បីដូចជាស្រឡាញ់គាត់ខ្លាំងណាស់។ ប៉ុន្តែ ក្នុងរយៈពេលពីរទៅបីថ្ងៃ គាត់បានឃើញថាគាត់បានធ្វើកំហុសធំមួយ ដោយសារបុរសវ័យក្មេងនោះក៏ចាប់ផ្ដើមប្រព្រឹត្តចំពោះគាត់ដោយធ្វើបាប។ ដោយសារភាពស្រេកឃ្លានចង់បានការគាំទ្រ នោះអ្នកដែលខ្វះការគាំទ្របែបនេះអាចធ្លាក់ក្នុងអន្ទាក់នៃការមានទំនាក់ទំនងបែបរ៉ូមែនទិចជាមួយបុគ្គលដំបូង ដែលបង្ហាញការនោះចំពោះគាត់—ជាបុគ្គលម្នាក់ដែលមិនស័ក្តិសមនឹងគាត់ទាំងស្រុងតែម្តង។

ជារឿយៗ ឪពុកម្តាយមានកំហុសក្នុងការធ្វើឲ្យកូនៗរបស់ខ្លួនមានរបួសតាមរយៈពាក្យពេចន៍មិនសមរម្យ។ ពេលខ្លះ ឪពុកម្តាយប្រៀបធៀបពួកគាត់ជាមួយអ្នកដទៃ ដើម្បីជំរុញពួកគាត់ឲ្យធ្វើបានល្អ។ ឪពុកម្តាយដែលមានបទពិសោធន៍ទទួលបានការប្រៀបធៀបដូចនេះកាលពីពួកគាត់នៅវ័យជំទង់ទំនងជាអាចប្រៀបធៀបកូនៗរបស់ខ្លួននៅក្នុងរបៀបដូចគ្នាដែរ។ នេះគឺជាអាកប្បកិរិយាដែលរៀនបានដែលយើងត្រូវព្យាយាមលះបង់ចោលវិញ។ ប៉ុន្តែ ជារឿងដ៏គួរឲ្យសោកស្តាយណាស់ ការរៀនលះបង់របៀបនេះចោលគឺពិបាកធ្វើណាស់។ វាអាចជាទំនោរផ្នែកធម្មជាតិមួយយ៉ាងខ្លាំងរបស់ឪពុកម្តាយ ដែលគាត់ប្រៀបធៀបបែបនេះដោយមិនដឹងខ្លួន។ នៅពេលកូនមកពីសាលាវិញ ដោយមានសំបុត្ររបាយការណ៍ចុងឆ្នាំមកជាមួយ ម្តាយរបស់គាត់អាចនឹងយកមកមើលហើយក៏ចាប់ផ្តើមសួរអំពីចំណាត់ថ្នាក់របស់នាង រស្មី ដែលជាបងប្អូនជីដូនមួយ។ ភ្លាមៗនោះក្មេងស្រីក៏ឃើញថា តម្លៃរបស់គាត់គឺត្រូវបានកំណត់តាមរបៀបរៀបរយដែលបងប្អូនជីដូនមួយរបស់គាត់បានធ្វើ។

នេះគឺគ្រាន់តែជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលក្មេងៗជួបប្រទះនៅក្នុងពិភពលោកនេះ ដែលកំណត់តម្លៃរបស់ពួកគាត់តាមរយៈសម្រស់

ប្រាជ្ញា ទេពកោសល្យ ទ្រព្យសម្បត្តិ និងប្រវត្តិគ្រួសារជាដើម។ ព្រះគម្ពីរបានបង្រៀនអំពីតម្លៃដែលមិនអាចកាត់ថ្លៃបានរបស់មនុស្សម្នាក់ៗនៅក្នុងលោកីយ៍នេះ។ ប៉ុន្តែ លោកីយ៍នេះនៅតែបន្តវាយប្រហារគោលគំនិតមួយនោះ។ ឪពុកម្ដាយដែលគាំទ្រកូនៗរបស់ខ្លួន និងប្រាប់ពួកគាត់នូវសារដ៏ច្បាស់លាស់អំពីតម្លៃរបស់ពួកគាត់ដែលអាចជួយព្យាបាលរបួស ដែលក្មេងៗទាំងនោះទទួលបានពីការប្រៀបធៀប និងការបដិសេធនៅក្នុងលោកីយ៍ ដែលនៅជុំវិញពួកគាត់។ ក្មេងណាម្នាក់ដែលទទួលបានការគាំទ្រ និងមិនធ្លាប់ទទួលរងគ្រោះដោយសារការប្រៀបធៀបនៅផ្ទះនឹងលូតលាស់ឡើងក្លាយជាយុវជនដែលមានសុវត្ថិភាពម្នាក់។ ប្រសិនបើកុមារទទួលអារម្មណ៍ថា ឪពុកម្ដាយគាត់រាប់គាត់ថាជាមនុស្សស្អាតនៅផ្ទះ នោះការប្រកាសអំពីភាពមិនស្អាតរបស់គាត់ពីមនុស្សដែលមិនសមរម្យនឹងមិនមានអំណាចលើគាត់ទេ។ ប៉ុន្តែ ចំពោះកុមារដែលទទួលបានការប្រៀបធៀបជាមួយអ្នកដទៃ ហើយមិនសូវទទួលការគាំទ្រនឹងអាចទំនងជាធំធាត់ឡើង ដោយក្លាយជាមនុស្សពេញវ័យដែលមិនសប្បាយចិត្ត។

នៅពេលដែលឪពុកម្ដាយប្រៀបធៀបកូនៗខ្លួនឯង នោះបងប្អូននឹងធំធាត់ឡើងដោយមានស្នាមរបួសដែលទាក់ទងគ្នាជាមួយបងប្អូនរបស់ខ្លួន។ ស្នាមរបួសបែបនេះអាចលេចចេញឡើងនៅក្នុងជីវិតជំទង់របស់ពួកគាត់ នៅពេលដែលពួកគាត់ឈ្លោះគ្នា។ ឪពុកម្ដាយមានការស្រងាកចិត្តនៅពេលដែលកូនៗឈ្លោះគ្នាអំពីរឿងទ្រព្យសម្បត្តិគ្រួសារ ឬក៏ប្រហែលជាលើការមើលថែរបស់ឪពុកម្ដាយផងដែរ។ ផលវិបាកដែលកើតឡើងដែលពិបាកបំផុតគឺនៅពេលដែលឪពុកម្ដាយស្រឡាញ់កូនម្នាក់ខ្លាំងជាងម្នាក់ទៀត។ នៅត្រង់នេះ ស្នាមរបួសក៏កាន់តែជ្រៅជាងមុន ហើយការមិនចុះសម្រុងគ្នាក៏អាចកាន់តែមានការកត់សម្គាល់ច្រើនជាងមុនផងដែរ។ ដំណើររឿងនៃកូនប្រុសៗរបស់លោកយ៉ាកុប បានបង្ហាញអំពីទីបន្ទាល់នៃភាពល្វីល្វើនៃការមានកំហុសដូចនេះដែលបណ្ដាលមកពីការស្រឡាញ់កូនម្នាក់ខ្លាំងជាងម្នាក់ទៀត។

ដំណោះស្រាយនោះគឺ ឪពុកម្តាយត្រូវតែស្រឡាញ់កូនៗខ្លួនឲ្យបានស្មើៗគ្នា ហើយមិនឲ្យមានការរំពឹងទុកសម្រាប់កូនម្នាក់ៗដូចគ្នាឡើយ។ កូនម្នាក់អាចពូកែខាងផ្នែកបច្ចេកវិទ្យា ខណៈពេលដែលកូនម្នាក់ទៀតអាចពូកែខាងឯការសិក្សា។ ពួកគាត់ម្នាក់ៗមានអំណោយទានផ្ទាល់ខ្លួនខុសៗគ្នា ហើយឪពុកម្តាយត្រូវតែក្រឡេកមើលអំណោយទានទាំងនោះ និងលើកទឹកចិត្តពួកគាត់។ ពិតណាស់! យើងអាចយកមនុស្សណាម្នាក់សមជាគំរូមកធ្វើជាគំរូបានដែរ។ ប៉ុន្តែ ការនេះគួរតែធ្វើឡើងក្នុងរបៀបមួយដែលជំរុញពួកគាត់ ជាជាងកាត់បន្ថយតម្លៃរបស់ពួកគាត់។ ដោយមានការបដិសេធដែលមនុស្សជួបប្រទះនៅក្នុងពិភពលោកនេះដែលជាសត្រូវយើង នោះផ្ទះសម្បែងគួរតែជាកន្លែងមួយដែលមានពេញដោយការគាំទ្រ និងការទទួលយក។

## សេចក្តីសន្និដ្ឋាន

នេះគឺជាជំពូកដែលគួរឲ្យភ័យខ្លាចបន្តិចហើយ! យើងបានពិភាក្សាអំពីឥទ្ធិពលនៃគ្រោះថ្នាក់ដែលក្មេងៗប្រឈមមុខនៅសព្វថ្ងៃនេះ។ ប៉ុន្តែ ប្រសិនបើមានគេប្រាប់លោកអ្នកអំពីការអាក្រក់ណាមួយមុនវាកើតឡើង នោះក៏មានន័យថាលោកអ្នកបានត្រៀមខ្លួនក្នុងការប្រឈមមុខនឹងការអាក្រក់នឹងការនោះដែរ។ ការយល់ដឹងអំពីបញ្ហាប្រឈមដែលកូនៗយើងកំពុងជួបប្រទះអាចជួយយើងឲ្យជួយផ្គត់ផ្គង់ពួកគាត់ឲ្យចេះប្រឈមជាមួយនឹងបញ្ហាទាំងនោះដោយមានប្រាជ្ញាបាន។ យើងត្រូវមើលរបៀបចិញ្ចឹមបីបាច់កូនដោយមានការប្តេជ្ញាចិត្តដ៏ខ្ពស់ក្នុងការរៀននូវអ្វីដែលយើងអាចរៀនបាន សម្រាប់ជាប្រយោជន៍ដល់កូនៗយើង។ យើងចង់បាននូវអ្វីដែលល្អបំផុតសម្រាប់ពួកគាត់ ដូច្នេះយើងត្រូវបង់ថ្លៃនូវតម្លៃ ដើម្បីរៀនអំពីរបៀបផ្តល់ឲ្យពួកគាត់នូវឱកាសដ៏ល្អបំផុត ក្នុងការលូតលាស់ឲ្យបានក្លាយជាកុមារដែលមានសុខភាពល្អ ភាពរីករាយ និងបរិសុទ្ធ។

# ១២

# ការដាក់ពិន័យកូនៗ

នៅក្នុងពីរជំពូកមុន យើងបានពិភាក្សាជាមួយគ្នាអំពីប្រធានបទដូចជាការសប្បាយចិត្តជាមួយនឹងកូនៗ និងការអរសប្បាយ។ ប៉ុន្តែ យើងមិនអាចឈប់ត្រឹមហ្នឹងបានទេ។ កូនៗត្រូវការឱកាសទទួលបានភាពរីករាយ និងការផ្តល់ឱកាសក្នុងការសប្បាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកគាត់បានកើតមកក្នុងភាពពុករលួយ ដែលនេះមានន័យថា ពួកគាត់ក៏ធ្វើខុស ហើយក៏អាចធ្លាក់ក្នុងការល្បួងឲ្យធ្វើអ្វីមួយដែលមិនត្រឹមត្រូវបានផងដែរ។ ដូច្នេះ ពួកគាត់ក៏ត្រូវការការដាក់ពិន័យ។

ជារឿយៗ ព្រះគម្ពីរតែងតែលើកឡើងអំពីរបៀបដែលព្រះជាម្ចាស់វាយផ្ចាលយើង។ ជាទូទៅ គឺត្រូវបានប្រើប្រាស់ជាឧទាហរណ៍ក្នុងការដែលឪពុកវាយផ្ចាលកូនៗរបស់ខ្លួន។ លោក ម៉ូសេ បានសរសេរថា «ក៏ត្រូវនឹកពិចារណាក្នុងចិត្តថា ព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់បានវាយផ្ចាលឯង ដូចជាមនុស្សវាយផ្ចាលកូនរបស់ខ្លួន» (ចោទិយកថា ៨:៥)។ ការវាយផ្ចាល ឬក៏ដាក់ពិន័យកូនៗគឺជាទំនួលខុសត្រូវដ៏សំខាន់មួយរបស់ឪពុកម្តាយ។

## ចូរណែនាំឲ្យពួកគាត់ស្គាល់ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់

មូលដ្ឋាននៃការប្រៀនប្រដៅនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ គឺទាក់ទងជាមួយលក្ខណៈរបស់ព្រះជាម្ចាស់។ ដោយសារព្រះអង្គបរិសុទ្ធ នោះព្រះអង្គស្អប់អំពើបាបយើង។ កណ្ឌគម្ពីរ ហាបាគុក ១:១៣ បានថែងថា ព្រះជាម្ចាស់ «មានព្រះនេត្របរិសុទ្ធក្រៃលែង និងទតមើលការអាក្រក់មិនបាន ក៏និងពិនិត្យមើលការទុច្ចរិតមិនបានដែរ»។ ប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែលគឺជាដំណើររឿងមួយនៃការមិនស្តាប់បង្គាប់ ដោយមានការវាយផ្ចាល ហើយមានការប្រែចិត្តដែលជាលទ្ធផលនៃការវាយផ្ចាលនោះ។ ដូច្នេះ ព្រះបានប្រាប់សាសន៍អ៊ីស្រាអែលជាញឹកញាប់ថា ឲ្យចងចាំអំពីរបៀបដែលព្រះជាម្ចាស់បានវាយផ្ចាលដល់ពួកគាត់។ កណ្ឌគម្ពីរ ចោទិយកថា ១១:១ និង៨ដាស់តឿនឲ្យប្រជាជនអ៊ីស្រាអែលស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់។ ហើយនៅចន្លោះខទាំងពីរនេះក៏មានការរៀបរាប់ឡើងវិញអំពីរបៀបដែលព្រះជាម្ចាស់បានដឹកនាំពួកគាត់ដោយអំណាចព្រះចេស្តារបស់ទ្រង់ (ខ២-៤) និងអំពីរបៀបដែលព្រះអង្គបានដាក់ទោសដល់ពួកគាត់យ៉ាងធ្ងន់ធ្ងរដោយសារអំពើបាបរបស់ពួកគាត់ដែរ (ខ៥-៧)។ នេះគឺជាលំនាំនៃប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រទានពរដល់រាស្ត្ររបស់ទ្រង់ ប៉ុន្តែព្រះអង្គក៏ត្រូវតែដាក់ទណ្ឌកម្មដល់ពួកគាត់ ដើម្បីឲ្យពួកគាត់រៀនរស់នៅដោយមានភាពបរិសុទ្ធដែរ។ បន្តិចក្រោយមកទៀតលោក ម៉ូសេ បានមានប្រសាសន៍ថា «មើល៍ នៅថ្ងៃនេះ អញដាក់ព្រះពរ ហើយនិងសេចក្តីបណ្តាសា សំពៀងនៅមុខឯងរាល់គ្នា បើឯងស្តាប់តាមអស់ទាំងបញ្ញត្តិរបស់ព្រះយេហូវ៉ា ជាព្រះនៃឯងដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះនឹងបានពរ តែបើមិនស្តាប់តាមអស់ទាំងបញ្ញត្តិរបស់ព្រះយេហូវ៉ាជាព្រះនៃឯងទេ» (ចោទិយកថា ១១:២៦-២៨)។

បន្ទាប់ពីបានរៀបរាប់អំពីរឿងមួយចំនួនអំពីការដាក់ទោសនៅក្នុងព្រះគម្ពីរសញ្ញាចាស់រួចហើយ នោះសាវ័ក ប៉ុល បានលើកឡើងថា «រីឯការទាំងនោះបានកើតមកដល់គាត់ទុកជាគំរូ ហើយបានកត់ទុក សម្រាប់ជាសេចក្តីទូន្មាន

ប្រដៅ ដល់យើងរាល់គ្នា» (១កូនរិនថូស ១០:១១)។ ប្រសិនបើនោះជាគោល បំណងសម្រាប់កត់ត្រារឿងនៅក្នុងព្រះគម្ពីរអំពីការដាក់ទោស និងការរំដោះ នោះយើងក៏ត្រូវតែប្រាប់កូនៗរបស់យើងអំពីរឿងទាំងនោះផងដែរ។ ដូចនោះ គំនិតនេះនឹងចូលទៅក្នុងចិត្តគំនិតរបស់ពួកគាត់ដែលថា អំពើបាបគឺពិតជាធ្ងន់ធ្ងរណាស់ នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ សាវ័ក ប៉ុល បានប្រាប់ក្រុមជំនុំនៅទីក្រុងរ៉ូមថា «ដូច្នេះ ចូរមើលសេចក្តីសប្បុរស និងសេចក្តីប្រិតប្រៀបនៃព្រះ គឺទ្រង់ប្រិតនឹងពួកអ្នកដែលដួល តែសប្បុរសនឹងអ្នកវិញ បើអ្នកនៅជាប់នឹងសេចក្តីសប្បុរសនោះ ពុំនោះ អ្នកនឹងត្រូវកាត់ចេញដែរ» (រ៉ូម ១១:២២)។

កូនៗរបស់យើងត្រូវតែធំធាត់ឡើងដោយមានគំនិតអំពីព្រះជាម្ចាស់នៅក្នុងរបៀបនេះ ហើយដើម្បីឲ្យការនោះអាចកើតឡើងបាន នោះពួកគាត់ត្រូវការរបបអាហារដ៏ល្អនៃប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ការបរាជ័យរបស់យើងក្នុងការផ្តល់របបអាហារបែបនេះនឹងក្លាយជាហេតុដែលនាំឲ្យកូនៗយើងធំធាត់ឡើងដោយមានអាកប្បកិរិយាបែបមិនអើពើចំពោះអំពើបាបៈ ជាអាកប្បកិរិយាដែលពួកគាត់យកមកពីវប្បធម៌ដែលពួកគាត់កំពុងតែរស់នៅ។ ពួកគាត់នឹងមានការពិបាកយល់អំពីមូលហេតុដែលជំនាន់ឪពុកម្តាយរបស់ខ្លួនមានការតវ៉ាប្រឆាំងយ៉ាងខ្លាំងម្ល៉េះចំពោះរឿងដូចជាការរៀបការជាមួយភេទដូចគ្នា និងការរំលូតកូន រហូតដល់ចំណុចនៃការបដិសេធមិនអនុញ្ញាតឲ្យពួកគាត់អនុវត្តនៅក្នុងរង្វង់គ្រីស្ទបរិស័ទផងដែរ។ កូនៗកំពុងរស់នៅក្នុងវប្បធម៌មួយដែលមានការទទួលយកការរៀបការជាមួយអ្នកដែលស្រឡាញ់ភេទដូចគ្នា និងការរំលូតកូន ដែលឥឡូវគេបានចាត់ទុកការនោះថាជាសិទ្ធផ្ទាល់ខ្លួនរបស់មនុស្សហើយ។ អាកប្បកិរិយាបែបនោះក៏ជារឿងទូទៅនៅក្នុងសម័យព្រះគម្ពីរដែរ ជាពិសេសនៅទីក្រុងកូរិនថូស។ ដូច្នេះ នៅពេលដែលសាវ័ក ប៉ុល បានឃើញអំពើបាបខាងឯផ្លូវភេទដ៏អាក្រក់ៗដូចនោះនៅទីនោះនោះគាត់បានមានប្រសាសន៍ថា អ្នកប្រព្រឹត្តិអំពើបាបគួរតែទទួលការកាត់ទោស (១កូរិនថូស ៥:៥)។ កូនៗយើងអាចនឹងមើលឃើញថា នេះជាការ

រំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ ពួកគាត់ត្រូវតែដឹងអំពីមនសិការនៃការបង្រៀននៅក្នុងព្រះគម្ពីរ ទាំងបទគម្ពីរដែលពួកគាត់ពេញចិត្តដែលនិយាយអំពីព្រះពរ និងបទគម្ពីរពិបាកៗដែលនិយាយអំពីការជំនុំជម្រះផងដែរ។ ការបរាជ័យរបស់យើងក្នុងការប្រាប់រឿងទាំងនេះទៅកាន់កូនៗរបស់យើងនឹងធ្វើឲ្យពួកគាត់មានការពិបាកក្នុងការមានអាកប្បកិរិយាស្របតាមព្រះគម្ពីរចំពោះការប្រៀនប្រដៅពីឪពុកម្ដាយរបស់ខ្លួន។

## ចូរស្ដាប់តាមការដំបូន្មានរបស់សាវ័ក ប៉ុល

សាវ័ក ប៉ុល មានការបង្រៀនសំខាន់ៗមួយចំនួនសម្រាប់ឪពុកគ្រប់រូបអំពីការប្រៀនប្រដៅកូនៗ ជាសេចក្ដីបង្រៀនដែលយើងស័ក្ដិសមគិតពិចារណាឲ្យបានហ្មត់ចត់។ កណ្ឌគម្ពីរ អេភេសូរ ៦:៤ គឺជាមូលដ្ឋានដ៏ល្អមួយក្នុងការប្រើប្រាស់សម្រាប់ការសិក្សានេះ។ នៅត្រង់ចំណុចនោះ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ឪពុករាល់គ្នាអើយ កុំឲ្យចាក់រុកកូនរបស់ខ្លួនឡើយ ចូរបង្រៀនវាទៅតាមដំបូន្មាន និងសេចក្ដីដាស់តឿនរបស់ព្រះអម្ចាស់វិញ»។ ខ្ញុំចង់ឲ្យយើងមើលការបញ្ជាក់គាំទ្រនីមួយៗដែលមាននៅក្នុងខគម្ពីរមួយនេះ។

### *កុំឲ្យចាក់រុកកូន*

ជាដំបូង សាវ័ក ប៉ុល បានប្រាប់ឪពុកទាំងឡាយមិនឲ្យ «ចាក់រុក» កូនៗរបស់ខ្លួននោះឡើយ។ នៅក្នុងបរិបទនៃការប្រៀនប្រដៅ ការធ្វើឲ្យកូនៗខឹងបែបនោះគួរមានរួមបញ្ចូលទាំងការមិនមានហេតុផល ភាពអយុត្តិធម៌ ការមិនអាចគ្រប់គ្រងលើបាន ឬក៏ការប្រមាថចំពោះការប្រៀនប្រដៅ។ ជារឿយៗ ឪពុកម្ដាយប្រៀនប្រដៅកូនៗគាត់ដោយកើតចេញពីការរំខានរបស់ពួកគាត់ផ្ទាល់។ ខ្ញុំគិតថា នេះគឺជារឿងដែលគេចមិនរួច។ វាគឺជារឿងធម្មជាតិទេដែលឪពុកម្ដាយមានអារម្មណ៍រំខាន នៅពេលដែលកូនៗរបស់ពួកគាត់បានធ្វើខុស។ ប៉ុន្តែ ពួកគាត់ក៏អាចប្រព្រឹត្តលើសផងដែរ ដល់ថ្នាក់ថាសារចម្បងដែលកូនៗទទួលបានគឺថា

“ប៉ាកំពុងតែខឹង” ជាជាងថា “ខ្ញុំបានធ្វើខុស ប៉ុន្តែការដាក់វិន័យនេះគឺសម្រាប់ជាប្រយោជន៍ដល់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចផ្លាស់ប្រែបាន”។

កណ្ឌគម្ពីរ កូឡូស ៣:២១ គឺជាខគម្ពីរស្របគ្នាមួយទៅនឹងកណ្ឌគម្ពីរអេភេសូរ ៦:១-៩ ហើយសាវ័ក ប៉ុល បានលើកឡើងថា “ឪពុករាល់គ្នាអើយ កុំឌុកដាន់កូនចៅឡើយ ក្រែងវារសាយចិត្តចេញ”។ ការប្រៀនប្រដៅគួរតែជាការលើកទឹកចិត្តដល់កូនៗ។ នៅពេលដែលសាវ័ក ប៉ុល បាននិយាយអំពីអ្វីដែលគួរធ្វើជាមួយអស់អ្នកដែលបង្កឲ្យមានបញ្ហានៅក្នុងក្រុមជំនុំ នោះគាត់បានប្រើប្រាស់ភាសាធ្ងន់ៗមួយចំនួនទៅកាន់លោក ធីម៉ូថេ ដែលមានភាពខ្មាសអៀន៖ “ឱធីម៉ូថេ ជាកូនអើយ ខ្ញុំប្រគល់ពាក្យបណ្ដាំនេះទុកនឹងអ្នក តាមសេចក្ដីទំនាយដែលបានទាយពីអ្នកជាមុន ដើម្បីឲ្យអ្នកបានច្បាំងជាចម្បាំងយ៉ាងល្អ ដោយសារសេចក្ដីទាំងនោះ” (១ធីម៉ូថេ ១:១៨)។ នៅក្នុងភាសាដើម ពាក្យដែលគេបានបកប្រែថា “ប្រគល់” គឺជាពាក្យដែលប្រើប្រាស់នៅក្នុងជួរកងទ័ព ដែលមានន័យថា “បញ្ជា” ឬក៏ក្នុងការបកប្រែព្រះគម្ពីរខ្មែរបច្ចុប្បន្នបានប្រើពាក្យ “ផ្ដាំផ្ញើ”។ ប៉ុន្តែ សាវ័ក ប៉ុល បានលើកឡើងថា ប្រវត្តិនៃពាក្យប្រគល់ដែលគាត់បានលើកឡើងគឺ “តាមសេចក្ដីទំនាយដែលបានទាយពីអ្នកជាមុន”។ ទំនាយទាំងនោះហាក់បីដូចជាមូលដ្ឋាននៃសេចក្ដីប៉ងប្រាថ្នារបស់សាវ័ក ប៉ុល សម្រាប់លោក ធីម៉ូថេ ហើយការបញ្ជាគឺជាជំហានមួយនៃការជួយឲ្យគាត់សម្រេចបានសេចក្ដីប៉ងប្រាថ្នាទាំងនោះ។ ការប្រៀនប្រដៅគួរតែជាការលើកទឹកចិត្តដល់កូនៗឲ្យមានសេចក្ដីប្រាថ្នាចំពោះអ្វីដែលប្រសើរជាង ជាជាងបំបាក់ទឹកចិត្តពួកគាត់ក្នុងការគិតថា ខ្លួនជាមនុស្សមិនមានតម្លៃ។

នេះគឺជាប្រយោគមួយចំនួនដែលបំបាក់ទឹកចិត្តកូនៗ៖ “អាភ្លើ!” “អាអត់ប្រយោជន៍” “ឯងនាំតែរឿងឲ្យគ្រួសារ!” “ថីបានមិនធ្វើដូចបងប្រុសឯង?” ឬក៏ “ឯងជាមនុស្សរំខានដល់ហើយ!”។ ប៉ុន្តែ ប្រយោគដែលមិនបំបាក់ទឹកចិត្តកូនៗមានដូចនេះវិញ៖ “តើកូនធ្វើការអាក្រក់បែបនេះបានដោយរបៀបណា? នេះមិនមែនជាអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យកូនធ្វើទេ!” “តើកូនមិន

ដឹងថា ការនេះធ្វើឲ្យកូនឈឺចាប់ប៉ុណ្ណាទេឬ?» «យើងត្រូវតែដាក់ទោសកូន ដោយសារប៉ាម៉ាក់ចង់ឃើញកូនបែរចេញពីការប្រព្រឹត្តិមិនត្រឹមត្រូវបែបនេះ» ឬក៏ «ព្រះជាម្ចាស់បង្កើតកូនមកជាមនុស្សដ៏ល្អ ហើយព្រះអង្គនឹងជួយកូន តាមរយៈការនេះ»។

មានក្មេងជំទង់ម្នាក់បានប្រាប់អ្នកអធិប្បាយជនជាតិអាមេរិកដ៏ល្បីម្នាក់ គឺលោក វ៉ារ៉េន វៀសប៊ី ថា «ឪពុកខ្ញុំប្រើប្រាស់កាំភ្លើងត្បាល់សម្រាប់សម្លាប់មូស!»។[១] តើមានក្មេងប៉ុន្មាននាក់ដែលបានទទួលរងការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ដោយសារភាពអយុត្តិធម៌ និងការផ្ទុះកំហឹងដែលនាំឲ្យមានរបួសពីឪពុកម្ដាយ? ខ្ញុំធ្លាប់មាន «ពិធីនៃការព្យាបាល» មួយចំនួនជាមួយនឹងក្មេងជំទង់ដែលទទួលការឈឺចាប់ពីឪពុកម្ដាយរបស់ពួកគាត់ (ជាទូទៅពីឪពុក)។ នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និងតាមរយៈការប្រើប្រាស់ព្រះគម្ពីរ យើងក៏ឆ្លងកាត់ការចងចាំដ៏ឈឺចាប់ និងស្វែងរកការអនុវត្តពីសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់ពួកគាត់បាន។ សេចក្តីសង្ឃឹមគឺថាពួកគាត់នឹងអត់ទោសឲ្យឪពុកម្ដាយរបស់ខ្លួន និងទទួលស្គាល់ថា ព្រះជាម្ចាស់នឹងប្ដូរបទពិសោធន៍ដែលពោរពេញទៅដោយការឈឺចាប់នេះឲ្យទៅជាអ្វីមួយដែលល្អវិញ។

ការទាំងអស់នេះបង្ហាញថា យើងត្រូវការជំនួយពីព្រះជាម្ចាស់នៅពេលយើងប្រៀនប្រដៅកូនៗ។ នៅពេលដែលសាវ័ក ប៉ុល នៅទីក្រុងទីរ៉ុស អ្នកតំណាងជនជាតិរ៉ូមម្នាក់បានបង្ហាញអំពីការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះដំណឹងល្អ។ ប៉ុន្តែ មានគ្រូអាបធ្មប់ជនជាតិយូដាម្នាក់ឈ្មោះ អេលីម៉ាស (Elymas) បានព្យាយាមរារាំងលោកមិនឲ្យស្ដាប់ព្រះបន្ទូល។ សាវ័ក ប៉ុល ក៏បានស្តីបន្ទោសដល់គ្រូអាបធ្មប់នោះ ហើយគ្រូនោះក៏បានខ្វាក់ភ្នែកជាយូរបន្តិចទៅ។ ការរៀបរាប់អំពីពាក្យពេចន៍ខ្លាំងៗដែលសាវ័ក ប៉ុល បាននិយាយត្រូវបាននាំមុខដោយឃើញថាគាត់ «បានពេញជាព្រះវិញ្ញាណបរិសុទ្ធ» (កិច្ចការ ១៣:៩)។ យើងក៏ត្រូវការភាពពេញលេញខាងឯព្រះវិញ្ញាណបរិសុទ្ធ នៅពេលដែលយើងស្ដី

បន្ទោសកូនៗ។ ដូច្នេះ ខណៈពេលដែលយើងស្តីបន្ទោសដល់កូនៗ យើងគួរតែមានការចំណាយពេលស្ងាត់ស្ងៀម ដើម្បីអធិស្ឋានឲ្យបានច្រើន ដោយទូលអង្វរសូមជំនួយពីព្រះជាម្ចាស់។ ប៉ុន្តែ ជារឿងគួរឲ្យសោកស្តាយណាស់ នៅពេលយើងខឹងនឹងកូនៗយើងដោយសារដែលពួកគាត់បានធ្វើអ្វីមួយខុស នោះយើងប្រព្រឹត្តិហាក់បីដូចជាបានដកខ្លួនចេញពីព្រះអង្គមួយរយៈ ដើម្បីធ្វើនូវអ្វីដែលយើងត្រូវធ្វើ។

ទាក់ទងនឹងចំណុចនេះ ដាច់ខាត ខ្ញុំត្រូវការលើកឡើងអំពីកាលៈទេសៈខ្លះៗ ដែលខ្ញុំតែងតែឃើញ។ ម្តាយព្យាយាមផ្តល់សុវត្ថិភាពដល់គ្រួសារ ដែលឪពុកបានបំផ្លាញចោល តាមរយៈអាកប្បកិរិយាដែលមិនមានទំនួលខុសត្រូវ។ ដោយញៀនថ្នាំ ញៀនស្រា និងមានស្រីក្រៅចំណងអាពាហ៍ពិពាហ៍ ឬក៏គ្មានក្តីមេត្តាករុណាសោះ ដូច្នេះប្តីក៏មិនបានផ្គត់ផ្គង់ថវិកាដល់គ្រួសារ ហើយនៅពេលដែលគាត់នៅផ្ទះ គាត់តែងតែខឹង ហើយធ្វើអ្វីដែលនាំឲ្យមានការឈឺចាប់ ជាពិសេសចំពោះប្រពន្ធរបស់ខ្លួន។ ប្រពន្ធត្រូវធ្វើការយ៉ាងនឿយហត់ក្នុងការរក្សាសេដ្ឋកិច្ចគ្រួសារឲ្យនៅមានលំនឹង។ តាមរយៈការនៅក្រោមសម្ពាធយ៉ាងខ្លាំងបែបនេះ គាត់ងាយទទួលបានការរំខានពីការផ្សេងៗដែលកូនៗធ្វើ ហើយច្រើនតែមានប្រតិកម្មខ្លាំងពេកចំពោះកូនៗ។ ហើយជាលទ្ធផល កូនៗងាយទទួលរងការឈឺចាប់ដោយសារមនុស្សម្នាក់ដែលបានលះបង់ជីវិតរបស់គាត់សម្រាប់ពួកគេ។ ក្នុងកាលៈទេសៈធម្មតាដូចនេះ ក្រុមជំនុំត្រូវតែធ្វើតាមអ្វីដែលអាចធ្វើបាន ដើម្បីថែទាំគ្រួសារដែលទទួលការរងគ្រោះដ៏អាក្រក់បែបនេះ—ខាងឯព្រលឹងវិញ្ញាណ អារម្មណ៍ ផ្លូវច្បាប់ និងសេដ្ឋកិច្ច។ យើងមិនអាចទទួលយកប្រតិកម្មរបស់ម្តាយបានទេ ប៉ុន្តែស្ថានភាពរបស់គាត់គឺពិតជាពិបាកណាស់ ដែលតម្រូវឲ្យមានការជួយអន្តរាគមន៍ពីរាស្ត្ររបស់ព្រះជាម្ចាស់។

អ្វីដែលខ្ញុំបានលើកឡើងខាងលើនេះមិនមែនមានន័យថា យើងមិនខឹងកូនៗយើង នៅពេលគាត់ធ្វើខុសនោះទេ។ សេចក្តីក្រោធគឺជាផ្នែកមួយនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ ព្រះអង្គស្រឡាញ់យើងដល់ម្ល៉េះបានជា

ព្រះអង្គខ្ញាល់ចំពោះអ្វីដែលយើងធ្វើខុស។ ហើយក្នុងនាមជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ យើងក៏ត្រូវតែមានការខឹងនៅពេលដែលអ្នកដែលយើងស្រឡាញ់បានធ្វើអ្វីមិនត្រឹមត្រូវ។ ប៉ុន្តែ ដូចអ្វីដែលសាវ័ក ប៉ុល បានលើកឡើងថា "ចូរខឹងចុះ តែកុំឲ្យ [យើង] ធ្វើបាបឡើយ" (អេភេសូរ ៤:២៦)។ នេះហើយជាមូលហេតុដែលសំខាន់ណាស់ដែលត្រូវមានព្រះវត្តមានរបស់ព្រះជាម្ចាស់ នៅពេលដែលយើងប្រៀនប្រដៅកូន។ យើងមិនអាចនិយាយអ្វីដែលមានពេញដោយការឈឺចាប់ និងអាក្រក់ៗនៅពេលយើងដឹងថា ព្រះជាម្ចាស់មានព្រះវត្តមានជាមួយយើងបានទេ! នៅពេលដែលលោកអ្នកកំពុងខឹង នោះលោកអ្នកដឹងថា ព្រះជាម្ចាស់គង់នៅជាមួយលោកអ្នកដែរ។ ការនោះផ្តល់ដល់លោកអ្នកនូវសុវត្ថិភាពដែលបានរុំព័ទ្ធដោយព្រះជាម្ចាស់ដ៏មានពេញដោយអំណាចព្រះចេស្តា។ សុវត្ថិភាពនេះដើរតួនាទីក្នុងការការពារយើងមិនឲ្យបង្ហាញកំហឹងរបស់យើងនៅក្នុងរបៀបដែលមានគ្រោះថ្នាក់។

*ដាក់ពិន័យដោយស្រឡាញ់*

ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងនៅអាចប្រព្រឹត្តលើស ក្នុងប្រតិកម្ម ដែលនាំឲ្យមានការជះឥទ្ធិពលដែលឈឺចាប់ នៅពេលដាក់ពិន័យខ្លាំងពេក។ លោក ជេមស៍ ដបសិន បានលើកឡើងថា "មានការនិពន្ធជាច្រើនអំពីគ្រោះថ្នាក់នៃការដាក់ពិន័យខ្លាំងពេក ការសង្កត់សង្កិន និងការដាក់ពិន័យដែលមិនមានសេចក្តីស្រឡាញ់ ការព្រមានទាំងនោះត្រឹមត្រូវ ហើយក៏គួរយកទៅអនុវត្តផងដែរ។ ទោះជាយ៉ាងណាក៏ដោយក៏នៅមានគេលើកឡើងថា លទ្ធផលនៃការដាក់ពិន័យដែលមានការសង្កត់សង្កិនគឺជាការលះបង់ចោលសម្រាប់អ្នកដឹកនាំ។ នេះគឺជារឿងល្ងីល្ងើ"។[២] ការបញ្ជាក់បន្ថែមបន្ទាប់របស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៦:៤ បានផ្តល់នូវតម្រូវការនៃការកែតម្រង់ចំពោះគ្រោះថ្នាក់មួយនេះ។ បន្ទាប់ពីគាត់បានលើកឡើងថា "ឪពុករាល់គ្នាអើយ កុំឲ្យចាក់រុកកូនរបស់ខ្លួនឡើយ" គាត់ក៏បានបន្ថែមទៀតថា "ចូរបង្រៀនវាទៅ

តាមដំបូន្មាន...របស់ព្រះអម្ចាស់វិញ»។

យើងត្រូវបង្រៀនកូនៗ។ ពាក្យដែលគេបានបកប្រែថា «ចូរបង្រៀន» («ភីឌៀ» "paideia") មាននូវគំនិតនៃ «ការបង្ហាត់អ្នកណាម្នាក់តាមច្បាប់នៃការប្រព្រឹត្ត និងអាកប្បកិរិយាដែលត្រឹមត្រូវ។[៣] ចេញពីពាក្យនៃភាសាក្រិកនោះ យើងទទួលបានពាក្យ «គរុកោសល្យ» ដែលបញ្ជាក់អំពីការឈ្លាសវៃរបស់គ្រូ សេចក្តីប៉ិនប្រសប់សម្រាប់គ្រូក្នុងការបង្រៀន។ នៅពេលឪពុកម្តាយប្រៀនប្រដៅកូនៗ ការផ្តោតសំខាន់គឺលើការបង្ហាត់បង្រៀន ជាជាងការដាក់ពិន័យ។

ព្រះគម្ពីរបានបង្ហាញអំពីការប្រៀនប្រដៅរបស់ឪពុកទុកជាឧទាហរណ៍នៃការប្រៀនប្រដៅរបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់។ កណ្ឌគម្ពីរ ហេព្រើរ ១២:៧ បានចែងថា «បើសិនជាអ្នករាល់គ្នាត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះគឺព្រះអង្គទ្រង់ប្រព្រឹត្តនឹងអ្នករាល់គ្នា ដូចជាកូនហើយ ដ្បិតតើមានកូនឯណាដែលឪពុកមិនវាយផ្ចាលនោះ»។ ព្រះគម្ពីរសញ្ញាចាស់បានបង្ហាញថា លោក អេលី បានបរាជ័យក្នុងនាមជាឪពុក ក្នុងការប្រៀនប្រដៅដល់កូនៗរបស់គាត់។ ព្រះជាម្ចាស់បានប្រាប់ទៅកាន់ សាំយូអែល ដែលមានវ័យក្មេង អំពីលោក អេលី ថា៖ «ដ្បិតអញបានប្រាប់លោកហើយថា អញនឹងជំនុំជម្រះពួកគ្រួលោកជាដរាបទៅ ដោយព្រោះអំពើដ៏លាមកដែលលោកបានដឹងពីពួកកូនលោក ជាការដែលនាំឲ្យគាត់ត្រូវបណ្តាសា ហើយលោកមិនបានហាមឃាត់ដល់គាត់ទេ» (១សាំយូអែល ៣:១៣)។ កណ្ឌគម្ពីរសុភាសិតបានចែងថា «អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថា ស្អប់កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយផ្ចាលវា» (១៣:២៤) ហើយ «កុំឲ្យខាននឹងវាយប្រដៅកូនឡើយ ដ្បិតបើវាយនឹងរំពាត់ គង់តែមិនស្លាប់ដែរ» (២៣:១៣)។ ប្រទេសជាច្រើនបានចាត់ទុកការវាយប្រដៅកូនៗថាជា ការខុសច្បាប់ ដោយសារពេលខ្លះវាបានបង្កគ្រោះថ្នាក់ជាអចិន្ត្រៃយ៍ដល់កុមារ។ ប៉ុន្តែ សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរដែលថាកូនៗត្រូវតែទទួលបានការប្រៀនប្រដៅក៏នៅតែមានសារៈសំខាន់ជាបន្ទាន់នៅគ្រប់ទីកន្លែងដែរ។

យើងមិនត្រូវភ្លេចទេថា ការប្រៀនប្រដៅគឺជាការបង្ហាញអំពីសេចក្ដីស្រឡាញ់ ហើយថាការពិតនោះត្រូវតែភ្លឺថែងចាំងឡើង តាមរយៈការប្រៀនប្រដៅរបស់យើង។ កណ្ឌគម្ពីរសុភាសិតបានចែងថា «ដ្បិតអ្នកណាដែលព្រះយេហូវ៉ាទ្រង់ស្រឡាញ់ នោះទ្រង់ក៏ស្ដីប្រដៅផង គឺដូចជាឪពុកធ្វើចំពោះកូន ដែលជាទីគាប់ចិត្តដល់ខ្លួនដែរ» (៣:១២)។ កូនៗគួរតែយល់ថា ឪពុកម្ដាយប្រៀនប្រដៅពួកគាត់គឺដោយសារតែសេចក្ដីស្រឡាញ់ដែលមានសម្រាប់ពួកគាត់ ហើយថាអាកប្បកិរិយារួមរបស់ពួកគាត់ចំពោះកូនៗគឺជាការរីករាយមួយដែរ។

លោក ដបសិន បានបង្ហាញថា ការប្រៀនប្រដៅកូនៗដែលត្រឹមត្រូវគឺជាទង្វើនៃការគាំទ្រពីតម្លៃខ្លួនឯងរបស់កូនៗ។ ប្រសិនបើឪពុកម្ដាយមិនអើពើចំពោះអ្វីដែលកូនបានធ្វើខុសទេ នោះវាជាសារបញ្ជាក់ដល់កូនៗថា ទង្វើរបស់គាត់មិនសំខាន់គ្រប់គ្រាន់ក្នុងការទទួលបានការឆ្លើយតបនោះឡើយ។ នៅទីបំផុតក្មេងៗដូចនោះអាចនឹងក្លាយជាជនប្រព្រឹត្តិល្មើស—ដោយធ្វើទង្វើខុសឆ្គងដ៏ធំសម្បើម ដើម្បីទទួលបានចំណាប់អារម្មណ៍ពីរបស់អ្នកដទៃ។[៩] ការប្រៀនប្រដៅដែលត្រឹមត្រូវជួយឲ្យក្មេងៗស្វែងរកអត្តសញ្ញាណដ៏ពិតប្រាកដរបស់ពួកគាត់ថាខ្លួនជាសមាជិកដ៏មានតម្លៃម្នាក់នៅក្នុងគ្រួសារ ជាម្នាក់ដែលគ្រួសារយកចិត្តទុកដាក់លើសកម្មភាពរបស់គាត់យ៉ាងខ្លាំង។ កណ្ឌគម្ពីរហេព្រើរបានចែងថា «តែបើសិនជាអ្នករាល់គ្នាមិនដែលត្រូវផ្ចាញ់ផ្ចាលសោះ ជាសេចក្ដីដែលគ្រប់គ្នាត្រូវរងទ្រាំ នោះអ្នករាល់គ្នាជាកូនឥតខាន់ស្លាទេ មិនមែនជាកូនពិតប្រាកដឡើយ» (១២:៨)។ ការបរាជ័យក្នុងការប្រៀនប្រដៅគឺជាសញ្ញាបង្ហាញថា ឪពុកម្ដាយមិនបានចាត់ទុកថាកូននោះជាសមាជិកដ៏ពិតប្រាកដនៅក្នុងគ្រួសារ។

នៅក្នុងវគ្គមុន ខ្ញុំបានចង្អុលបង្ហាញអំពីការបង្រៀននៅក្នុងបទគម្ពីរអំពីគ្រោះថ្នាក់នៃការប្រៀនប្រដៅដែលមិនអាចគ្រប់គ្រងលើបាន។ នៅក្នុងវគ្គមួយនេះ ខ្ញុំគ្រាន់តែបានគូសបញ្ជាក់យ៉ាងសាមញ្ញនូវចំណុចមួយចំនួនអំពីភ័ស្តុតាងដ៏រឹងមាំមួយដែលថា ការប្រៀនប្រដៅកូនៗគឺជាទំនួលខុសត្រូវដ៏សំខាន់មួយនៅក្នុងរបៀបរបស់ព្រះគម្ពីរចំពោះជីវិតគ្រួសារ។ ឪពុកម្ដាយគួរតែគិតអំពីការ

នេះឲ្យបានហ្មត់ចត់ និងបង្កើតរបៀបរបស់ខ្លួនឲ្យស្របតាមព្រះគម្ពីរ។ បុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗមានចំណុចខុសៗគ្នា ហើយភាគច្រើន៖ ឪពុក និងម្ដាយមានរបៀបខុសៗគ្នាក្នុងការប្រៀនប្រដៅកូន។ ការនោះមិនជាបញ្ហាទេ ដរាបណាមិនមានការខ្វែងគំនិតគ្នាអំពីការប្រៀនប្រដៅកូនៗនៅមុខពួកគាត់ផ្ទាល់—ដូចដែលយើងនឹងមើលជាមួយគ្នានៅខាងក្រោមនេះ។

## *ណែនាំដោយមានចំណេះដឹង*

ការបង្រៀនកូនៗគឺជាដំបូន្មានបន្ទាប់ដែលសាវ័ក ប៉ុល បានឲ្យដល់ឪពុកគ្រប់គ្នានៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៦:៤។ គាត់បានលើកឡើងថា «ចូរបង្រៀនវាទៅតាមដំបូន្មាន…របស់ព្រះអម្ចាស់វិញ»។ ពាក្យដែលគេបានបកប្រែថា «ចូរបង្រៀន» គឺមកពីពាក្យក្រិក «នូធីសៀ» (nouthesia) ដែលមានន័យថា «ជាការផ្ដល់នូវការណែនាំ ដើម្បីកែតម្រូវអាកប្បកិរិយា និងជំនឿ»។[៩] ការប្រៀនប្រដៅផ្ដល់ឲ្យឪពុកម្ដាយមានឱកាសបង្រៀនណែនាំដល់កូនៗ។ យើងត្រូវតែប្រាប់ពួកគាត់អំពីមូលហេតុដែលទង្វើខ្លះមិនត្រឹមត្រូវ។ យើងត្រូវតែប្រាប់ពួកគាត់អំពីមូលហេតុនៃរបៀបរបស់គ្រីស្ទបរិស័ទក្នុងការធ្វើអ្វីមួយថា វាជារបៀបដ៏ល្អបំផុត។

ដូចដែលក្មេងៗសព្វថ្ងៃនេះរស់នៅក្នុងពិភពលោកមួយដែលខុសគ្នាយ៉ាងខ្លាំងពីពិភពលោកដែលឪពុកម្ដាយរបស់ពួកគាត់បានរស់នៅ  នោះឪពុកម្ដាយត្រូវតែរៀនស្វែងយល់អំពីពិភពលោកមួយនេះដែរ។ ឪពុកម្ដាយត្រូវធ្វើការស្រាវជ្រាវ ហើយពេលខ្លះរបៀបដ៏ល្អបំផុតក្នុងការធ្វើការនេះគឺតាមរយៈការសួរនាំពីកូនៗរបស់ខ្លួនអំពីវាផ្ទាល់តែម្ដង។ ការទទួលយកការឈឺចាប់ក្នុងការស្វែងយល់អំពីពិភពលោកនៃកូនៗរបស់ពួកគាត់ គឺជាគន្លឹះមួយនៃការប្ដេជ្ញាចិត្តរបស់ពួកគាត់ចំពោះកូនៗ។

យើងត្រូវតែត្រៀមខ្លួនក្នុងការដែលពួកគាត់មិនយល់ស្របជាមួយយើង និងចង់មានការសន្ទនាជាមួយយើងចំពោះសេចក្ដីពិតដែលយើងកំពុងទូន្មាននោះ

ដែរ។ នៅពេលដែលយើងដឹងអំពីរបៀបដែលកូនៗយើងកំពុងគិត នោះយើងប្រហែលជាត្រូវធ្វើការសិក្សាមួយចំនួនឲ្យបានហ្មត់ចត់ ដើម្បីឲ្យយើងអាចមានការឆ្លើយតបដោយមានប្រាជ្ញាចំពោះសំណួរ និងការជំទាស់របស់ពួកគាត់។ ប្រសិនបើយើងដាក់ច្បាប់ដោយមិនស្ដាប់ពីការជំទាស់របស់ពួកគាត់ នោះយើងនឹងចាញ់ការប្រយុទ្ធនេះសម្រាប់គំនិតរបស់ពួកគាត់ជាមិនខាន។ ការណែនាំកូនៗរបស់យើងគឺជាទិដ្ឋភាពមួយនៃការត្រាស់ហៅរបស់យើងក្នុងការ «ទូន្មានឲ្យខំតយុទ្ធ ដើម្បីការពារសេចក្ដីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសម្រេច» (យូដាស ១:៣)។ ការហ៊ានសុំទោសកូនគឺជាទិដ្ឋភាពដ៏សំខាន់មួយសម្រាប់ឪពុកម្ដាយក្នុងការចិញ្ចឹមកូន។ យើងណែនាំកូនៗរបស់យើងដូចជាបេសកជនរៀនឆ្លងកាត់វប្បធម៌ខុសគ្នាអញ្ចឹងដែរ។ យើងមានការអត់ធ្មត់ និងស្រេកឃ្លានក្នុងការរៀន ហើយព្យាយាមយល់អំពីអត្តសញ្ញាណរបស់ពួកគាត់ រៀនចេញពីទស្សនៈលោកីយ៍របស់ពួកគាត់ ហើយយើងក៏អាចជះឥទ្ធិពលដល់ពួកគាត់ឲ្យឆ្ពោះទៅរកគំនិតរបស់ព្រះជាម្ចាស់បានដែរ។ យើងនឹងនិយាយបន្ថែមទៀតអំពីការនេះនៅក្នុងជំពូកបន្ទាប់។

គោលបំណងរបស់យើងក្នុងការបង្រៀនគឺ ដើម្បីផ្ដល់ឲ្យកូនៗយើងនូវការយល់ដឹងបែបគ្រីស្ទបរិស័ទ ទាក់ទងនឹងបញ្ហាដែលពួកគាត់កំពុងប្រឈមមុខជាមួយ។ កណ្ឌគម្ពីរ រ៉ូម ១២:១-២ រៀបរាប់អំពីការថ្វាយរូបកាយរបស់យើងថាជាយញ្ញបូជារស់ និងអំពីការមិនត្រាប់តាមសម័យនៃលោកីយ៍នេះ។ ទាំងនេះសុទ្ធតែជាការពិបាកឲ្យក្មេងៗយល់។ ប៉ុន្ដែ សាវ័ក ប៉ុល បានបន្ដដោយមានប្រសាសន៍ថា «ដើម្បីឲ្យអ្នករាល់គ្នាអាចស្គាល់អ្វីជាព្រះហឫទ័យរបស់ព្រះ—គឺអ្វីដែលល្អ អ្វីដែលព្រះអង្គគាប់ព្រះហឫទ័យ ហើយគ្រប់លក្ខណ៍»។ នៅពេលយើងបង្រៀនកូនៗយើង យើងបង្ហាញពួកគាត់អំពីរបៀបដែលយើងចង់ឲ្យពួកគាត់ធ្វើនោះថា ជារបៀបដ៏ល្អបំផុតសម្រាប់ពួកគាត់។ វាមិនមែនគ្រាន់តែ «ល្អ» នោះទេ ប៉ុន្ដែក៏ «គាប់ព្រះហឫទ័យ ហើយគ្រប់លក្ខណ៍» ដែរ។

*ការថែរក្សា*

នៅមានពាក្យមួយទៀតដែលបានប្រើប្រាស់នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៦:៤ ដែលយើងត្រូវតែមើលជាមួយគ្នា។ ព្រះគម្ពីរបានបង្គាប់ដល់ឪពុករាល់គ្នាថា «ចូរបង្រៀនវាទៅតាមដំបូន្មាន និងសេចក្ដីដាស់តឿនរបស់ព្រះអម្ចាស់វិញ»។ ឃ្លា «ចូរបង្រៀន» មកពីពាក្យ «អែកទ្រេហ្វូ» (ektrephō) ដែលមានន័យថា «ថែរក្សា និងអប់រំប្រដៅប្រដៅ»។ គោលគំនិតនៃការនេះគឺ «ចិញ្ចឹមកូនៗឲ្យបានពេញវ័យឡើងដោយផ្ដល់នូវតម្រូវការខាងឯផ្លូវកាយ និងផ្លូវចិត្ត»។[៦] កូនៗគួរតែដឹងថា ឪពុករបស់ខ្លួននឹងនៅជាមួយពួកគាត់មិនថាមានរឿងអ្វីកើតឡើងក៏ដោយ ហើយថា ឪពុកមានការប្ដេជ្ញាចិត្តយ៉ាងពេញទីចំពោះការថែរក្សា ហើយនិងធ្វើគ្រប់យ៉ាង ដើម្បីឲ្យវាអាចសម្រេចបាន។ ឪពុកម្ដាយមិនគ្រាន់តែទូន្មាន ណែនាំ និងប្រៀនប្រដៅប៉ុណ្ណោះទេ។ កូនៗរបស់ពួកគាត់គួរតែដឹងថា ឪពុកម្ដាយរបស់ខ្លួននឹងនៅជាមួយពួកគាត់ ដើម្បីគាំទ្រពួកគាត់នៅពេលពួកគាត់មានវិបត្តិ ឬក៏នៅក្រោមការវាយប្រហារណាមួយ។ ពួកគាត់គួរតែដឹងថា ឪពុកម្ដាយរបស់ខ្លួនមានការប្ដេជ្ញាចិត្តទាំងស្រុងក្នុងការធ្វើនូវអ្វី ដែលល្អបំផុតសម្រាប់សុខុមាលភាពរបស់ពួកគាត់។ ជាទូទៅ មនុស្សយើងរាប់ការបារម្ភ និងខ្វល់ខ្វាយបែបនោះថាជាអ្វីដែលម្ដាយធ្វើ។ ប៉ុន្តែ វាជារឿងដ៏សំខាន់ណាស់ដែលការណែនាំរបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរអេភេសូរគឺបានប្រាប់មកកាន់ឪពុកវិញ។

ការអធិស្ឋានគឺជារបៀបមួយដ៏ល្អក្នុងការថែរក្សាកូនៗ។ ព្រះគម្ពីរបានបង្ហាញថា ការអធិស្ឋានគឺជាកិច្ចការមួយដែលយើងធ្វើសម្រាប់អ្នកដទៃ (សូមអាននៅក្នុងកណ្ឌគម្ពីរ កូឡុស ៤:១២-១៣; យ៉ាកុប ៥:១៦)។ កូនៗគួរតែដឹងថា ឪពុករបស់ខ្លួនអធិស្ឋានឲ្យពួកគាត់ជាប្រចាំថ្ងៃ ហើយថានៅពេលដែលពួកគាត់មានតម្រូវការអ្វីមួយ នោះឪពុក (មិនមែនគ្រាន់តែម្ដាយនោះទេ) នឹងអធិស្ឋានឲ្យពួកគាត់ជាមិនខាន។ កាលកូនៗរបស់ខ្ញុំនៅផ្ទះ ហើយខ្ញុំបានធ្វើដំណើរទៅក្រៅប្រទេស ហើយប្រសិនបើពួកគាត់មានបញ្ហាអ្វីមួយ នោះពួកគាត់នឹងប្រាប់

ម្ដាយរបស់ពួកគាត់ឲ្យប្រាប់ដល់ខ្ញុំ។ ពួកគាត់ដឹងថា ខ្ញុំនឹងអធិស្ឋានសម្រាប់ការនោះ។ ការនេះបានកើតឡើងមុនពេលមានទូរស័ព្ទនៅឡើយ។ សព្វថ្ងៃនេះ ពួកគាត់ផ្ញើសារប្រាប់ខ្ញុំផ្ទាល់តែម្ដង។ នៅពេលដែលឪពុកដែលបារម្ភម្នាក់ដឹងថា កូនរបស់គាត់មានបញ្ហាខាងឯរូបកាយ ព្រលឹងវិញ្ញាណ ឬក៏ផ្នែកអារម្មណ៍ នោះគាត់នឹងទូរស័ព្ទមកផ្ទះយ៉ាងទៀងទាត់ ដើម្បីឲ្យបានដឹងថាកូននោះយ៉ាងណាហើយ។ ការនេះបង្ហាញពីសាមគ្គីភាពរបស់គាត់ជាមួយកូននៅក្នុងស្ថានភាពរបស់ពួកគាត់។

ប្រសិនបើកូនស្រីរៀបចំចេញទៅប្រឡង ហើយទើបតែដឹងថាគាត់មិនមានសម្ភារៈដែលជាតម្រូវការរបស់គាត់ដូចជាប៊ិច ឬជ័រលុបនោះទេ នោះឪពុកក៏ស្ម័គ្រចិត្តប្រញាប់រត់ទៅហាងជិតនោះ ដើម្បីទិញវាមកឲ្យកូនភ្លាម។ ប្រសិនបើកូនប្រុសកំពុងតែរៀបចេញទៅកម្មវិធីជប់លៀងណាមួយ ហើយគាត់ទើបតែដឹងថាស្បែកជើងរបស់គាត់ត្រូវការដុសខាត់ ដោយសារគាត់ទើបតែបានដើរកាត់ភក់ នោះឪពុកនឹងប្រញាប់ទៅសម្អាតវាឲ្យបានស្អាតរលោងឡើងវិញ។ ទាំងនេះជាទង្វើដែលកើតចេញមកពីបំណងប្រាថ្នានៃការផ្គត់ផ្គង់ដល់កូនៗ។ ពិតណាស់ វាក៏ជាលក្ខណសម្បត្តិនៃគ្រួសារដែលមានសុភមង្គលដែរ។

## ឆ្លើយតបដោយមានភាពដូចៗគ្នា

ការឆ្លើយតបដោយមានភាពទៀងទាត់ទៅកាន់ស្ថានភាពដែលមានពេញដោយភាពតានតឹងគឺជាគន្លឹះដ៏សំខាន់មួយនៃការប្រៀនប្រដៅកូន។ វាជួយឲ្យក្មេងៗអភិវឌ្ឍន៍នូវអាកប្បកិរិយាដ៏ត្រឹមត្រូវចំពោះអ្វីដែលខុស និងត្រូវ ហើយផ្ដល់ឲ្យពួកគាត់មាននូវបរិយាកាសមួយដែលអាចជំរុញឲ្យមានការលើកទឹកចិត្តផងដែរ។ ការទាំងពីរនេះពិតជាសំខាន់ណាស់ក្នុងការជួយឲ្យកូនៗលូតលាស់ឡើងបានដោយមានសុខភាពល្អ។

*ឯកភាពគ្នាលើការដាក់ពិន័យ*

លោកស្រី ខែតធើរីន ប៊ូស (Catherine Booth) គឺជាភរិយាដែលមានសមត្ថភាពម្នាក់របស់លោក វីលៀម ប៊ូស (William Booth) ដែលជាស្ថាបនិកនៃអង្គការកងទ័ពសង្គ្រោះ (Salvation Army)។ ពួកគាត់ទាំងពីរអ្នកជាមនុស្សប្រកាន់តាមគំនិតផ្ទាល់ខ្លួន ប៉ុន្តែពួកគាត់ក៏មានជីវិតអាពាហ៍ពិពាហ៍ដែលមានសុភមង្គល និងមានផលផ្លែខ្លាំងដែរ។ មុនពេលដែលពួកគាត់បានរៀបការ លោកស្រី ខែតធើរីន បានដាក់ច្បាប់ចំនួនបួនយ៉ាងដែលគាត់សង្ឃឹមថា វានឹងជួយគ្រប់គ្រងលើទំនាក់ទំនងរបស់ពួកគាត់។ ច្បាប់ទាំងបួននោះមានដូចជា៖ (១) មិនត្រូវមានការលាក់បាំងនោះទេ (២) មិនត្រូវកាន់លុយដាច់ដោយឡែកពីគ្នា (៣) ត្រូវនិយាយអំពីភាពខុសគ្នា ដើម្បីធានាថាឲ្យបានភាពសុខដុម ជាជាងធ្វើពុតថាមិនមានភាពខុសគ្នាកើតឡើង ហើយ (៤) ហើយមិនត្រូវប្រកែកគ្នានៅមុខកូនៗទាល់តែសោះ។[៧] ច្បាប់ទីបួនរបស់លោកស្រី ប៊ូស គឺសំខាន់ក្រៃលែង ជាពិសេសនៅពេលនិយាយអំពីការប្រៀនប្រដៅកូនៗ។ កូនៗមិនមានភាពចាស់ទុំគ្រប់គ្រាន់ ដើម្បីដឹងអំពីរបៀបដោះស្រាយនៅពេលពួកគាត់ឃើញឪពុកម្ដាយកំពុងប្រកែកគ្នានៅមុខពួកគេនោះទេ។ ពាក្យសម្ដីអចេតនាអាក្រក់ទៅលើកូនអាចនាំជាលទ្ធផលឲ្យគាត់គិតថា ខ្លួនជាមូលហេតុដែលនាំឲ្យឪពុកម្ដាយឈ្លោះគ្នា។ ក្រោយមកទៀត នៅពេលណាដែលឪពុកម្ដាយរបស់ពួកគេឈ្លោះគ្នា នោះពួកគេអាចគិតថា ខ្លួនជាដើមហេតុដែលបណ្ដាលឲ្យមានរឿងកើតមានឡើង។

ប៉ុន្តែ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀតគឺថា នៅពេលដែលឪពុកម្ដាយមិនយល់ស្របជាមួយគ្នាអំពីការប្រៀនប្រដៅកូនៗនៅមុខពួកគាត់ ការនោះនឹងធ្វើឲ្យកូនៗមិនគោរពលើការដាក់ពិន័យ។ កូនម្នាក់អាចក្លាយជាកូនមានល្បិច ហើយធ្វើឲ្យឪពុក ឬម្ដាយរបស់ខ្លួនមិនត្រូវគ្នាបាន។ ឧបមាថា ឪពុកបង្ហាញអំពីការមិនសប្បាយចិត្តនៅមុខកូនប្រុសរបស់គាត់ចំពោះភាពមិនសមរម្យដែលម្ដាយបានធ្វើក្នុងការប្រៀនប្រដៅកូននោះ។ នៅថ្ងៃក្រោយ ពេលឪពុក

ត្រឡប់មកពីធ្វើការវិញ កូនប្រុសនោះអាចនឹងមកត្អូញត្អែររៀបរាប់ប្រាប់ឪពុកអំពីអ្វីដែលម្ដាយបានធ្វើក្នុងការប្រៀនប្រដៅគាត់។ ហើយប្រសិនបើឪពុកនោះឆ្លើយតបម្ដងទៀតដោយស្ដីបន្ទោសដល់ម្ដាយ នោះជាលទ្ធផល កូនប្រុសនោះនឹងបាត់បង់នូវការគោរពចំពោះម្ដាយរបស់គាត់ និងគំនិតនៃការប្រៀនប្រដៅជាមិនខាន។ ការនេះនឹងបណ្ដាលឲ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរចំពោះសុខភាពនៃការលូតលាស់របស់គាត់។

### *ឈរឲ្យមាំ*

នេះគឺជាដំណើររឿងធម្មតាមួយៈ ក្មេងស្រីតូចម្នាក់បានសុំអ្វីមួយពីម្ដាយរបស់គាត់ ហើយម្ដាយបានបដិសេធ។ កូននោះក៏ចាប់ផ្ដើមស្រែកយំ ហើយទាមទារថាគាត់ចង់បានវា។ ម្ដាយមិនអាចគ្រប់គ្រងសម្ពាធក្នុងការស្ដាប់កូនស្រីគាត់ស្រែកយំនោះ ដូច្នេះគាត់ក៏បានចុះចូល ហើយឲ្យនូវអ្វីដែលកូននោះចង់បាន។ កូនស្រីនោះដឹងថា ប្រសិនបើគាត់ស្រែកយំឲ្យឮៗ ហើយយូរល្មម នោះគាត់នឹងអាចទទួលបាននូវអ្វីដែលម្ដាយរបស់គាត់មិនចង់ឲ្យ។ ការនេះប្រាប់ដល់កុមារនោះអំពីដំណើររឿង។ វាបានផ្ដល់ជាព័ត៌មានដល់កុមារថាៈ “នៅទីបំផុត ម្ដាយខ្ញុំឲ្យរបស់ផ្សេងៗដល់ខ្ញុំ មិនមែនពឹងផ្អែកលើអ្វីដែលខុស ឬអ្វីដែលត្រូវនោះទេ ប៉ុន្តែដោយពឹងលើការល្បួងលោមចិត្ត និងភាពងាយស្រួលរបស់គាត់។ ប្រសិនបើខ្ញុំអាចធ្វើឲ្យម្ដាយរបស់ខ្ញុំមានអារម្មណ៍មិនស្រួល នោះខ្ញុំអាចទទួលបានរបស់ជាច្រើនដែលម្ដាយរបស់ខ្ញុំមិនចង់ឲ្យខ្ញុំ”។

ព្រះគម្ពីរបានបង្រៀនថា កុំឲ្យយើងស្បថឲ្យសោះ ពីព្រោះយើងគួរមានន័យដូចអ្វីដែលយើងនិយាយ។ លោក យ៉ាកុប បានលើកឡើងថា “តែបងប្អូនអើយ កុំឲ្យស្បថជាដើម ទោះបើនឹងស្ថានសួគ៌ ឬនឹងផែនដីក្ដី ក៏កុំឲ្យស្បថយ៉ាងណាឲ្យសោះ តែឲ្យពាក្យ “បាទ” របស់អ្នករាល់គ្នា បាននៅតែ “បាទ” ហើយពាក្យ “ទេ” នៅតែ “ទេ” ដដែល ក្រែងអ្នករាល់គ្នាធ្លាក់ទៅជាមានទោស” (យ៉ាកុប ៥:១២; សូមអានបន្ថែមនៅក្នុង ម៉ាថាយ ៥:៣៣-៣៧)។ ដូចដែល

ព្រះជាម្ចាស់ស្មោះត្រង់ និងមិនចេះប្រែប្រួលនៅក្នុងគ្រប់ផ្លូវរបស់ទ្រង់ នោះអ្នកដើរតាមព្រះអង្គក៏គួរមានចិត្តទៀងត្រង់ដែរ។ កូនៗរៀនការនោះបានតាមរយៈឪពុកម្ដាយរបស់ខ្លួន។

ប៉ុន្តែ នៅមានសារដ៏សំខាន់មួយទៀត ដែលតាមរយៈការបដិសេធរបស់អ្នកម្ដាយ ក្នុងការមិនចុះចូល កំពុងតែប្រាប់ទៅកាន់កូន នៅពេលដែលកូនកំពុងស្រែកយំ។ នៅពេលដែលម្ដាយនៅស្ងៀម ដោយមិនព្រមតាមកូន នោះកូនស្រីរបស់គាត់នឹងរៀនបានថា ក្នុងជីវិតនឹងមានពេលជាច្រើនដែលគាត់មិនទទួលបានអ្វីដូចដែលគាត់ចង់បាននោះឡើយ។ នេះគឺជាការពិតនៅក្នុងជីវិតរបស់មនុស្សពេញវ័យ។ ប្រសិនបើកូនៗមិនបានរៀនអំពីរបៀបស្កប់ចិត្តនៅពេលមានចម្លើយថា «ទេ» នៅក្នុងបទពិសោធន៍នៃជីវិតរបស់ខ្លួន នោះពួកគាត់នឹងក្លាយទៅជាមនុស្សមិនសប្បាយចិត្តជាមិនខាន។ ជីវិតនេះនាំមកនូវការជាច្រើនដែលយើងមិនចូលចិត្ត និងបំណងប្រាថ្នាជាច្រើនដែលយើងមិនអាចបំពេញបាន។ ឪពុកម្ដាយមានទំនួលខុសត្រូវយ៉ាងធំសម្បើមក្នុងការបង្ហាត់បង្រៀនកូនៗរបស់ពួកគាត់ឲ្យទទួលយកបទពិសោធន៍នៃពាក្យថា «ទេ» ដោយចិត្តមេត្តា។ របៀបមួយដ៏ល្អបំផុតក្នុងការធ្វើការនោះគឺ ជាការមិនមានភាពប្រែប្រួលចំពោះពាក្យថា «ទេ» និង «បាទ/ចាស» របស់ពួកគាត់។

## លើកទឹកចិត្តឲ្យមានអាកប្បកិរិយាដោយចេះគោរព

ការឆ្លើយតបទៀងទាត់របស់ឪពុកម្ដាយចំពោះភាពរឹងរូសរបស់កូនៗក៏ជួយឲ្យពួកគាត់បង្កើតអាកប្បកិរិយាដោយចេះគោរពដល់កូនៗរបស់ខ្លួនដែរ។ លោក ដបសិន បានលើកឡើងថា៖

> នឹងមានពេលវេលាដែលកូនដែលមានឆន្ទៈមោះមុតនឹងក្ដាប់ដៃ ហើយហ៊ានហៅឪពុកម្ដាយឲ្យប្រឈមមុខនឹងគាត់។ ការនេះមិនបានកើតឡើងដូចដែលយើងគិតជាទូទៅថា វាកើតចេញពីការខកចិត្ត ឬក៏ការជំទាស់ពីក្នុងចិត្តនោះទេ។ គាត់គ្រាន់តែចង់ដឹងថា ព្រំដែននៅកន្លែងណា ហើយថាអ្នកណានឹងអនុវត្តតាមច្បាប់នោះ។

អ្នកឯកទេសដែលមានចេតនាល្អជាច្រើននាក់បានប្រើប្រាស់លើសនៃការអត់ទ្រាំ ប៉ុន្តែមិនបានផ្តល់ដំណោះស្រាយអ្វីសោះសម្រាប់ការបះបោរនេះ។ ពួកគាត់ផ្តោតលើចំណុចសំខាន់នៃការដែលឪពុកម្តាយគួរយល់ចិត្តកូន ហើយខ្ញុំក៏ឯកភាពជាមួយដែរ។ ប៉ុន្តែ យើងក៏ត្រូវតែបង្រៀនកូនៗយើងថា ពួកគាត់ក៏មានចំណុចមួយចំនួនដែលត្រូវរៀនអំពីឪពុកម្តាយដែរ![៩]

ការគោរពអ្នកដែលស័ក្តិសមនឹងទទួលការគោរពគឺជាតម្លៃដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរ។ លទ្ធផលមួយដែលកើតចេញពីការដែលឪពុកម្តាយប្រៀនប្រដៅឲ្យបានជាប់លាប់គឺ ដើម្បីឲ្យកូនៗគោរពឪពុកម្តាយរបស់ខ្លួន។ កណ្ឌគម្ពីរ ហេព្រើរ ១២:៩ បានចែងថា «មួយទៀតយើងរាល់គ្នាមានឪពុកខាងសាច់ឈាម ដែលវាយផ្ចាលយើង ហើយយើងក៏កោតខ្លាចដល់គាត់ដែរ» ។ ក្រឹត្យវិន័យបួនប្រការដំបូងក្នុងចំណោមក្រឹត្យវិន័យទាំងដប់គឺមានទំនាក់ទំនងជាមួយយើង ហើយនិងព្រះជាម្ចាស់។ ហើយក្រឹត្យវិន័យប្រាំមួយបន្ទាប់ទៀតគឺមានទំនាក់ទំនងជាមួយយើងនឹងអ្នកដទៃទៀត ហើយក្រឹត្យវិន័យដំបូងនៅក្នុងចំណោមប្រាំមួយនោះគឺទាក់ទងទៅនឹងការគោរពប្រតិបត្តិដល់ឪពុកម្តាយៈ «ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ» (និក្ខមនំ ២០:១២)។ សាវ័ក ប៉ុល បានពណ៌នាអំពីការនេះថា «ជាបញ្ញត្តិមុនដំបូង ដែលជាប់មានទាំងសេចក្តីសន្យាផង» (អេភេសូរ ៦:២)។ ដូច្នេះ ការរៀនគោរពឪពុកម្តាយគឺជាគន្លឹះដ៏សំខាន់មួយនៃការលូតលាស់របស់កុមារដែលមានសុខភាពល្អ។

ចេញពីការរៀនគោរពឪពុកម្តាយរបស់ខ្លួន កូនៗរៀនបានថា ការគោរពគឺជាគុណតម្លៃយ៉ាងសំខាន់នៅក្នុងជីវិត។ ចេញពីការនោះ ពួកគាត់ក៏រៀនគោរពអ្នកដទៃដែរ។ សាវ័ក ប៉ុល បានបង្រៀនថា «ដូច្នេះ ចូរសងដល់លោកទាំងនោះតាមដែលអ្នកជំពាក់ចុះ...ត្រូវមានសេចក្តីកោតខ្លាច ចំពោះលោកណាដែលគួរកោតខ្លាច ហើយត្រូវគោរពប្រតិបត្តិ ដល់លោកណាដែលគួរគោរពដែរ» (រ៉ូម ១៣:៧)។ ព្រះគម្ពីរបានប្រាប់អ្នកជឿឲ្យចេះគោរព (១ថែស្សាឡូនិច ៥:១២)

នឹកចាំពីគំរូ (ហេព្រើរ ១៣:៧) ព្រមទាំងស្ដាប់តាម និងចុះចូលចំពោះ (ហេព្រើរ ១៣:១៧) អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទផង។ សាវ័ក ប៉ុល បានដាស់តឿនជាច្រើនលើកច្រើនសាឲ្យនិយោជិតទាំងអស់ចុះចូលជាមួយចៅហ្វាយ ឬនិយោជករបស់ខ្លួន (អេភេសូរ ៦:៥; កូឡូស ៣:២២; ១ធីម៉ូថេ ៦:១; ទីតុស ២:៩)។ សាវ័ក ពេត្រុស ក៏ហ៊ានបន្តដោយបានលើកឡើងថា «ឱពួកអ្នកបម្រើអើយ ចូរចុះចូលចំពោះចៅហ្វាយ ដោយកោតខ្លាចគ្រប់យ៉ាង មិនមែនត្រឹមតែចៅហ្វាយណាដែលស្លូតបូតល្អប៉ុណ្ណោះ ទោះទាំងចៅហ្វាយដែលកាចក៏ដែរ» (១ពេត្រុស ២:១៨)។ យើងឃើញយ៉ាងច្បាស់ថា ការគោរពអ្នកដទៃដែលជាអ្នកដឹកនាំគឺជាលក្ខណៈរបស់គ្រីស្ទបរិស័ទ។

ជារឿងដ៏គួរឲ្យសោកស្ដាយណាស់ តម្លៃមួយនេះត្រូវបានបាត់បង់យ៉ាងរហ័សចេញពីសង្គមយើង។ ជារឿយៗ ប្រសិនបើគ្រូដាក់ពិន័យដល់សិស្ស ឬក៏គ្រូបង្វឹកបានដកកូនណាម្នាក់ចេញពីក្រុម នោះឪពុកម្ដាយតវ៉ាយ៉ាងខ្លាំង។ លទ្ធផលគឺថា គ្រូៗមិនអាចធ្វើអ្វីបាន ហើយពួកគាត់ក៏មិនអាចប្រៀនប្រដៅ ឬដាក់ពិន័យដល់ក្មេងៗបានដែរ។ ពិតណាស់ មានករណីធ្ងន់ធ្ងរមួយចំនួនដែលត្រូវការឲ្យឪពុកម្ដាយជួយអន្តរាគមន៍ដែរ។ ប៉ុន្តែ ឪពុកម្ដាយគួរតែថ្លឹងថ្លែងអំពីជម្រើសឲ្យបានប្រុងប្រយ័ត្នមុននឹងធ្វើការនេះ ក្នុងន័យថា ការគោរពគ្រូបង្រៀនក៏ជាអ្វីមួយដែលពួកគាត់គួរជួយជំរុញកូនៗរបស់ខ្លួនឲ្យរីកចម្រើនឡើង។

ការស្រដៀងគ្នានេះក៏បានកើតឡើងនៅក្នុងក្រុមជំនុំដែរ។ ឪពុកម្ដាយនៅតែបន្តត្អូញត្អែរទៅកាន់កូនៗអំពីថ្នាក់ថ្ងៃអាទិត្យ ឬក៏ការប្រកបយុវជនដែលកូនៗបានចូលរួម ដោយលើកឡើងថា «នេះមិនមែនជារបៀបដែលយើងធ្វើនោះទេ! ហេតុអ្វីបានជាកូនមិនទន្ទេញខគម្ពីរ? នោះគឺជាអ្វីដែលយើងបានធ្វើកាលដែលយើងនៅថ្នាក់ថ្ងៃអាទិត្យ» ឬក៏ថា «កាលយើងនៅថ្នាក់ថ្ងៃអាទិត្យ គ្រូៗបានបង្រៀនអំពីការប្រៀនប្រដៅ»។ ដោយពាក្យចំអកឡកឡឺយទាំងនោះអំពីការប្រៀនប្រដៅបែបនេះ នោះវាអាចធ្វើឲ្យប៉ះពាល់ដល់វិន័យកុមារដែរ។ ប្រសិនបើកូនៗដឹងថា ឪពុកម្ដាយរបស់ខ្លួនមិនគោរពអ្នកដឹកនាំយុវជន និង

គ្រូៗថ្នាក់ថ្ងៃអាទិត្យរបស់ពួកគាត់ទេ នោះកូនៗក៏ទំនងជាមិនគោរពគ្រូៗដែរ។ ជាលទ្ធផល ពួកគាត់ក៏អាចចាប់ផ្តើមបដិសេធមិនព្រមចុះចូលចំពោះអ្នកដឹកនាំ ឬគ្រូៗទាំងនោះផង។ ពួកគាត់អាចពូនក្រោយអាកប្បកិរិយារបស់ឪពុកម្តាយរបស់ខ្លួន និងបដិសេធក្នុងការចុះចូលចំពោះវិន័យដ៏ចាំបាច់របស់ក្រុមផងដែរ។ ហើយជាលទ្ធផល នោះពួកគេនឹងមិនមានការលូតលាស់ទៅមុខនោះទេ។

ប្រសិនបើឪពុកម្តាយចង់រិះគន់ថ្នាក់ថ្ងៃអាទិត្យ ឬក៏ការប្រកបគ្នារបស់យុវជន នោះពួកគាត់គួរតែប្រាប់អ្នកដឹកនាំនៃក្រុមទាំងនេះ ឬក៏អ្នកដឹកនាំនៅក្នុងក្រុមជំនុំដែលមានដូចជាគ្រូគង្វាលជាដើម។ ពួកគាត់មិនគួរឲ្យក្មេងៗមានការពាក់ព័ន្ធទេ។ ការរិះគន់ដូចរបៀបដែលខ្ញុំបានលើកឡើងខាងលើអាចជាសញ្ញានៃការមិនមានសន្តិសុខរបស់ឪពុកម្តាយ។ ពួកគាត់ប្រហែលជាមានការស្ទាក់ស្ទើរក្នុងការឲ្យអ្នកដទៃគ្រប់គ្រងលើកូនៗរបស់ខ្លួន ដោយចង់រក្សាការគ្រប់គ្រងទាំងស្រុងរបស់ពួកគាត់ចំពោះកូនៗនោះ។ ពួកគាត់ទទួលបានការគម្រាមកំហែងនៅពេលមាននរណាម្នាក់មានឥទ្ធិពលលើកូនៗរបស់គាត់។ នៅទីបំផុត លទ្ធផលគឺថាកូនៗទាំងនេះអាចប្រឆាំងជំទាស់នឹងការគ្រប់គ្រងបែបនេះរបស់ឪពុកម្តាយខ្លួន។

## សម្រាប់សុភមង្គលរបស់ពួកគាត់ មិនមែនកេរ្តិ៍ឈ្មោះរបស់យើងទេ

ចំណុចចុងក្រោយដែលខ្ញុំចង់និយាយគឺថា រាល់គ្រប់ការដែលយើងប្រៀនប្រដៅ និងបង្រៀនណែនាំទៅកាន់កូនៗរបស់យើងជាចម្បងនោះ គឺសម្រាប់សុភមង្គលរបស់ពួកគាត់តែម្តង មិនមែនដោយសារឪពុកម្តាយរបស់ពួកគាត់ជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំនោះទេ។ ការដែលឪពុកម្តាយត្រូវខ្មាសគេ ដោយសារសកម្មភាពរបស់កូនៗគឺជាបញ្ហាបន្ទាប់បន្សំទេ។ កូនៗអាចមានការអន់ចិត្តជាមួយនឹងការរួមចំណែករបស់ឪពុកម្តាយក្នុងក្រុមជំនុំ បែបជាអ្នកដឹកនាំ ប្រសិនបើពួកគាត់ទទួលការទូលសូមឲ្យធ្វើ ឬក៏មិនធ្វើអ្វីមួយ គឺគ្រាន់តែដោយសារឪពុកម្តាយរបស់ពួកគាត់បម្រើនៅក្នុងព័ន្ធកិច្ច។ យើងដែលជាមនុស្សធំគឺ

ជាអ្នកដែលបានឆ្លើយតបចំពោះការត្រាស់ហៅក្នុងការបម្រើព័ន្ធកិច្ច មិនមែនកូនៗរបស់យើងទេ។ ក្នុងអត្ថន័យមួយ ដៃគូជីវិតរបស់យើងបានឆ្លើយតបចំពោះការត្រាស់ហៅ ដោយសារគាត់បានជ្រើសរើសរៀបការជាមួយនឹងអស់អ្នក ដូចជាយើង ដែលបម្រើក្នុងព័ន្ធកិច្ច។ កូនៗរបស់យើងមិនបានជ្រើសរើសយកការកើតមកក្នុងគ្រួសារដែលបម្រើព័ន្ធកិច្ចនោះទេ។ ការនិយាយប្រយោគមួយចំនួនដូចជា "តើអ្នកដទៃនឹងគិតដូចម្ដេច?" ឬក៏ "នោះមិនមែនជារបៀបដែលកូនៗរបស់អ្នកដឹកនាំធ្វើនោះទេ" មិនមែនជារបៀបល្អមួយក្នុងការជំរុញកូនៗឲ្យមានភាពបរិសុទ្ធនោះឡើយ។ សមាជិកក្រុមជំនុំ ដែលមិនសូវមានការយោគយល់ ឬក៏ភាពពេញវ័យអាចទំនងជានិយាយដូចនេះទៅកាន់កូនៗរបស់អ្នកដឹកនាំ។ វាពិតជាគួរឲ្យសោកស្ដាយណាស់។ ប៉ុន្តែ ដាច់ខាត នោះមិនត្រូវជាកត្តាជំរុញ ក្នុងការបង្ខំឲ្យកូនៗយើងជ្រើសរើសផ្លូវដោយការប្រព្រឹត្តណាមួយទេ។

យើងស្នើឲ្យកូនៗយើងអធិស្ឋាន និងអានព្រះគម្ពីរជារៀងរាល់ថ្ងៃ ដោយសារនោះជាការល្អសម្រាប់ពួកគាត់ មិនមែនដោយសារពួកគាត់ជាកូនៗរបស់អ្នកដឹកនាំនោះទេ។ នោះគឺជាបំណងប្រាថ្នារបស់យើងសម្រាប់ក្មេងៗទាំងអស់នៅក្នុងសហគមន៍របស់យើង—មិនមែនត្រឹមតែសម្រាប់កូនៗរបស់អ្នកដឹកនាំឡើយ។ ក្មេងៗគ្រប់រូបត្រូវការមានភាពបរិសុទ្ធ។ ប្រសិនបើយើងហាមឃាត់កូនៗរបស់យើងមិនឲ្យទៅកន្លែងណាមួយ ឬក៏ចូលរួមកម្មវិធីណាមួយ គឺវាមិនមែនដោយសារកន្លែងនោះមិនល្អសម្រាប់ពួកគាត់ទេ ឬក៏មិនមែនដោយសារកូនៗរបស់អ្នកដឹកនាំគ្រីស្ទបរិស័ទមិនគួរមានវត្តមាននៅកន្លែងដូចនោះដែរ។ ជារឿយៗមនុស្សម្នាតែងតែរអ៊ូរទាំ ប្រឆាំងនឹងអាកប្បកិរិយារបស់កូនអ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទ។ ប្រសិនបើការជំទាស់គឺជាការពិត នោះយើងគួរស្ដីបន្ទោសកូនៗ ហើយក៏ទំនងត្រូវដាក់ពិន័យពួកគាត់ដែរ។ ប៉ុន្តែ កូនៗត្រូវតែយល់ថា ការដាក់ពិន័យគឺដោយសារពួកគាត់បានប្រព្រឹត្តខុស និងសម្រាប់ជាប្រយោជន៍របស់ពួកគាត់ មិនបានដោយសារមានគេនិយាយអំពីអាកប្ប

កិរិយារបស់ពួកគាត់ឡើយ។

ខ្ញុំក៏ត្រូវលើកឡើងផងដែរថា កូនៗរបស់យើងមិនត្រូវទទួលបានការយកចិត្តទុកដាក់ពិសេសនៅក្នុងក្រុមគ្រីស្ទបរិស័ទរបស់ពួកគាត់ ដោយសារយើងនៅក្នុងចំណោមអ្នកដឹកនាំនោះទេ។ គោលគំនិតនៃ “មកុដព្រះអង្គម្ចាស់” ដោយមានអភ័យឯកសិទ្ធិមិនមានកន្លែងសម្រាប់វាទេ នៅក្នុងសហគមន៍រស់នៅរបស់គ្រីស្ទបរិស័ទ។ កូនៗរបស់ខ្ញុំទាំងពីរមានអាយុ៣០ឆ្នាំជាងអស់ហើយ ហើយក៏នៅបន្តក្នុងការមានចិត្តឆេះឆួលក្នុងការចូលរួមបម្រើក្នុងអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ ម្នាក់បានធ្វើជាបុគ្គលិកពេញម៉ោង ហើយម្នាក់ទៀតបានធ្វើការជាអ្នកស្ម័គ្រចិត្ត។ ប៉ុន្តែ ពួកគាត់មិនទទួលបានការយកចិត្តទុកដាក់យ៉ាងពិសេស កាលពួកគាត់ទៅវ័យជំទង់នោះទេ។ ពេលខ្លះ ខ្ញុំបានបង្រៀននៅក្នុងការបោះជំរុំ ហើយពួកគាត់ក៏បាននៅក្នុងចំណោមអ្នកចូលរួមបោះជំរុំនោះដែរ។ ជារឿយៗ អ្នកបោះជំរុំផ្សេងទៀតមិនបានដឹងថា ពួកគាត់ជាកូនៗរបស់ខ្ញុំទេ។ ពេលខ្លះ ពួកគាត់បានប្រាប់ខ្ញុំ និងប្រពន្ធរបស់ខ្ញុំមិនឲ្យនិយាយជាមួយពួកគាត់ (ហើយយើងក៏សប្បាយចិត្តនៅពេលដែលពួកគាត់មកនិយាយជាមួយពួកយើងដែរ)។

ប្រពន្ធរបស់ខ្ញុំ ហើយនិងខ្ញុំពិតជាសប្បាយចិត្តណាស់ នៅពេលដែលកូនប្រុសរបស់យើងមានអារម្មណ៍ថា ព្រះជាម្ចាស់កំពុងត្រាស់ហៅគាត់ឲ្យបម្រើក្នុងព័ន្ធកិច្ចនៃអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ។ ប៉ុន្តែ យើងមិនបានលើកទឹកចិត្តគាត់ខ្លាំងពេកនៅក្នុងការនេះទេ។ យើងចង់ឲ្យគាត់មានភាពច្បាស់លាស់មួយនៃការត្រាស់ហៅពីព្រះជាម្ចាស់ ដោយមិនមានការបង្ខំពីយើង។ ដូច្នេះ នៅពេលដែលគាត់បានបញ្ចប់បរិញ្ញាបត្រផ្នែកវិស្វករប្រូក្រាមកុំព្យូទ័រ (software engineer) គាត់បានប្រាប់យើងថា គាត់នៅតែចង់ចូលរួមធ្វើការជាមួយអង្គការយុវជនសម្រាប់ព្រះគ្រីស្ទ ហើយយើងក៏បានសូមឲ្យគាត់ធ្វើការមួយជាមុនសិន។ បន្ទាប់ពីបានចំណាយពេលមួយឆ្នាំក្នុងការធ្វើការងារនោះ គាត់បានប្រាប់យើងថា គាត់មិនមានមន្ទិលសង្ស័យនោះទេ ដែលគាត់ទទួល

បានការត្រាស់ហៅនេះ ហើយយើងក៏ឲ្យគាត់មានសេរីភាពក្នុងការដើរតាមការត្រាស់ហៅមួយនោះ។

## សេចក្ដីសន្និដ្ឋាន

ចំណុចដែលបានលើកឡើងម្ដងហើយម្ដងទៀតនៅក្នុងជំពូកនេះគឺថា យើងត្រូវតែអនុវត្តគោលការណ៍នៅក្នុងព្រះគម្ពីរដោយយកចិត្តទុកដាក់ក្នុងការចិញ្ចឹមកូនៗរបស់យើង។ វាជាកិច្ចការដ៏សំខាន់មួយ ប៉ុន្តែវាមិនមែនជាការងាយស្រួលឡើយ។ ជារឿយៗ យើងជួបការល្បួង ដែលនាំឲ្យប្រព្រឹត្តក្នុងរបៀបជាច្រើនដែលមិនបានត្រាប់តាមរបៀបរស់នៅ ដែលស្របតាមព្រះគម្ពីរនោះទេ។ ដូច្នេះ យើងត្រូវតែគិតឲ្យបានល្អិតល្អន់ និងពិភាក្សាជាមួយប្ដី ឬប្រពន្ធរបស់យើងអំពីបញ្ហានានា ដើម្បីឲ្យយើងអាចប្រព្រឹត្តតាមរបៀបដែលថ្វាយព្រះកិត្តិនាមដល់ព្រះជាម្ចាស់ និងជាជំនួយដល់កូនៗរបស់យើងផងដែរ។

១៣

# ការណែនាំកូនៗ

នៅក្នុងជំពូកមុននេះ ខ្ញុំបានដកស្រង់សម្រង់សម្ដីពីគ្រូគង្វាលនៅក្នុងនិកាយប្រេសប៊ីធៀរៀននៅសតវត្សទី១៩គឺ លោកទេវវិទូ រ៉ូប៊ើត ដែបនី ដែលមានប្រសាសន៍ថា «ការអប់រំកូនៗសម្រាប់ព្រះជាម្ចាស់គឺជាជំនួញដ៏សំខាន់បំផុតនៅលើផែនដីនេះ»។[១] ផ្ទះគឺជាកន្លែងដ៏ចម្បងមួយដែលកូនៗទទួលបានការបង្រៀនចំណុចសំខាន់ៗបំផុតជាច្រើននៅក្នុងជីវិតនេះ។ ផ្នែកមួយយ៉ាងធំនៅក្នុងកណ្ឌគម្ពីរសុភាសិត ជាពិសេសនៅក្នុងជំពូក១ដល់៩ គឺមានការទាក់ទងជាមួយនឹងការដែលឪពុកម្ដាយបង្រៀនកូនៗ និងការឆ្លើយតបរបស់កូនៗ។

យើងមិនអាចរំពឹងថា កូនៗនឹងទទួលបានការណែនាំពីសាលាឲ្យបានទូលំទូលាយអំពីរបៀបរស់នៅនោះទេ ដែលភាគច្រើនសាលាឥឡូវនេះគឺផ្ដោតលើតែកម្មវិធីសិក្សាដែលបានតម្រូវសម្រាប់ការរីកចម្រើនក្នុងការសិក្សា និងមានការលើកទឹកចិត្តតែតិចតួចប៉ុណ្ណោះ ឲ្យស្វែងរកតម្លៃនៃជីវិតរបស់គ្រីស្ទបរិស័ទនេះ។ ឧទាហរណ៍៖ សម្រាប់វប្បធម៌នៅលោកខាងលិចគឺគេនឹងមិនបង្រៀនកូនៗយើងថា ការរួមដំណេកក្រៅចំណងអាពាហ៍ពិពាហ៍គឺជារឿងមិនត្រឹមត្រូវនោះទេ។ ជារឿងគួរឲ្យសោកស្ដាយណាស់ ដែលក្រុមជំនុំជាច្រើនក៏មិនបានសង្កត់ធ្ងន់លើការបង្រៀនដូចគ្នានេះផងដែរ។ នេះគឺដោយសារទំនងជា

មានមនុស្សវ័យក្មេងជាច្រើននាក់បានមានទំនាក់ទំនងខាងឯផ្លូវភេទដោយរួម ដំណេកក្រៅចំណងអាពាហ៍ពិពាហ៍មុនពេលរៀបការហើយ ដូច្នេះក្រុមជំនុំមាន ការភ័យខ្លាចថា មនុស្សវ័យក្មេងទាំងនោះនឹងមានការពិបាក ហើយប្រហែលជា អាចនឹងចាកចេញពីក្រុមជំនុំ ប្រសិនបើក្រុមជំនុំនិយាយប្រឆាំងនឹងការនេះ។ វាមិនមែនជារឿងដ៏គួរឲ្យភ្ញាក់ផ្អើលនោះទេ ដោយសារមានការស្រាវជ្រាវបាន បញ្ជាក់ថា ក្មេងៗដែលមានវ័យជំទង់ជាច្រើននៃក្រុមអ្នកផ្សាយដំណឹងល្អ នៅ លោកខាងលិចបានបោះបង់ទស្សនៈនៃព្រះគម្ពីរអំពីការរួមភេទចោលដែល ថា៖ វាគួរតែមានព្រំដែនសម្រាប់ទំនាក់ទំនងរវាងបុរស និងស្ត្រីនៅក្នុងចំណង អាពាហ៍ពិពាហ៍។ ឥទ្ធិពលនៃវប្បធម៌បានជះឥទ្ធិពលយ៉ាងខ្លាំងជាងឥទ្ធិពល ដែលមាននៅក្នុងផ្ទះ និងក្រុមជំនុំទៅទៀត។ ការនេះបានចង្អុលបង្ហាញអំពី តម្រូវការនៃភាពបន្ទាន់ក្នុងការឲ្យឪពុកម្តាយណែនាំកូនៗរបស់ខ្លួនអំពីក្រម សីលធម៌នៃការប្រព្រឹត្តរបស់គ្រីស្ទបរិស័ទ។

ការណែនាំនៅក្នុងផ្ទះអាចធ្វើបានតាមរបៀបជាច្រើន។ យើងនឹងមើលរបៀប មួយចំនួននៃរបៀបទាំងនេះនៅក្នុងជំពូកនេះតែម្តង។

## ការណែនាំតាមរយៈជីវិត

លោក ជីព អ៊ីងរ៉ែម បានលើកឡើងនៅក្នុងសៀវភៅដ៏ល្អដែលគាត់បាននិពន្ធ មានចំណងជើងថា «ការចិញ្ចឹមកូនដែលមានប្រសិទ្ធភាពក្នុងពិភពលោក ដែលមានខូច» (“Effective Parenting in a Defective World”) ថា “គេ តែងតែអាចចាប់យកបានចរិតលក្ខណៈ ជាជាងទទួលបានចរិតលក្ខណៈនោះ តាមរយៈការបង្រៀន គឺតែងតែអាចចាប់យកបានដូច្នោះ»។[២] ខ្ញុំមិនដឹងទេថា តើមានការគាំទ្រនៅក្នុងព្រះគម្ពីរសម្រាប់ចំណុចនេះ ឬក៏អត់នោះទេ។ ខណៈ ពេលដែលមានការលើកឡើងអំពីសារៈសំខាន់នៃគំរូ ព្រះគម្ពីរក៏តែងតែលើក ឡើងជាច្រើនដងអំពីអំណាចនៃពាក្យពេចន៍ដែលផ្លាស់ប្រែចរិតលក្ខណៈរបស់ មនុស្ស។ ខ្ញុំគិតថា ទាក់ទងនឹងចរិតលក្ខណៈ គេអាចចាប់បាន និងទទួលបាន

តាមរយៈការបង្រៀន។

ទោះបីជាយ៉ាងណាក្ដី ក៏មានការគាំទ្រខាងឯព្រះគម្ពីរយ៉ាងខ្លាំងដែរសម្រាប់អំណាចនៃគំរូនៅក្នុងការបង្កើតចរិតលក្ខណៈ។ សាវ័ក ប៉ុល បានលើកឡើងថា "ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ" (១កូរិនថូស ១១:១)។ គាត់បានធ្វើការអះអាងស្រដៀងៗគ្នាយ៉ាងតិចណាស់ចំនួន៥ដងទៀតនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៤:១៦; ១០:៣៣ ភីលីព ៣:១៧; ១ថែស្សាឡូនិច ១:៦; ២ថែស្សាឡូនិច ៣:៩។ គាត់បានប្រាប់លោក ធីម៉ូថេ ដែលជាកូនខាងឯវិញ្ញាណរបស់គាត់ថា "តែចំណែកអ្នក អ្នកបានស្គាល់គ្រប់សេចក្ដីដែលខ្ញុំបង្រៀន កិរិយាដែលប្រព្រឹត្ត នឹងបំណងចិត្ត សេចក្ដីជំនឿ សេចក្ដីអត់ធ្មត់ សេចក្ដីស្រឡាញ់ សេចក្ដីខ្ជាប់ខ្ជួនរបស់ខ្ញុំហើយ ព្រមទាំងការដែលគេបៀតបៀនដល់ខ្ញុំ នឹងសេចក្ដីទុក្ខលំបាករបស់ខ្ញុំដែរ" (២ធីម៉ូថេ ៣:១០-១១)។ លោក ដូណាល់ ហ្គូទ្រី (Donald Guthrie) បានបង្ហាញថា ពាក្យដែលគេបានបកប្រែ "បានស្គាល់" "ផារ៉ាកូលូធីអូ" (parakoloutheō) មានន័យថា "ជាការគូសដានទុកជាគំរូ"។[៣] ជីវិតរបស់សាវ័ក ប៉ុល គឺប្រៀបដូចជាសៀវភៅមួយក្បាលដែលបានបើកឲ្យឃើញចំពោះលោក ធីម៉ូថេ ហើយគាត់រៀនបានតាមរយៈការសង្កេតមើលអំពីរបៀបដែលសាវ័ក ប៉ុល បានប្រព្រឹត្តនៅក្នុងស្ថានភាពខុសៗគ្នា។

ទស្សនៈដ៏ស៊ីជម្រៅរបស់កុមារអំពីព្រះជាម្ចាស់ក៏ទទួលបានការជះឥទ្ធិពលយ៉ាងខ្លាំងពីអាកប្បកិរិយារបស់ឪពុកម្ដាយដែរ។ ដោយប្រើប្រាស់ឧទាហរណ៍អំពីសេចក្ដីស្រឡាញ់របស់ម្ដាយ នោះហោរា អេសាយ ក៏បានបង្រៀនអំពីការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ដែលមិនអាចបញ្ឈប់បាន ប៉ុន្តែបានបង្ហាញថា វាលើសពីការមើលថែរបស់អ្នកម្ដាយឆ្ងាយណាស់៖ "ចុះតើស្ត្រីនឹងភ្លេចកូនដែលកំពុងបៅដោះ ឥតមានអាណិតដល់កូនដែលចេញពីផ្ទៃខ្លួនមកបានដែរឬ អើ គេនឹងភ្លេចបាន ប៉ុន្តែអញមិនដែលភ្លេចឯងឡើយ" (អេសាយ ៤៩:១៥)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គំរូនេះបានផ្ដល់ឲ្យ

ទុកជាឧទាហរណ៍ក្នុងការបង្ហាញពីភាពផ្ទុយគ្នានៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជាមួយនឹងម្តាយដែលមិនមានភាពស្មោះត្រង់ នោះវាក៏បង្ហាញឲ្យឃើញថា ម្តាយដ៏ស្មោះត្រង់អាចឲ្យកូនៗរបស់ពួកគាត់ឃើញអំពីរូបភាពនៃលក្ខណៈរបស់ព្រះជាម្ចាស់បានដែរ។ ម្តាយបានឆ្លងកាត់ភាពមិនស្រណុកសុខស្រួលអស់រយៈពេល៩ខែ១០ថ្ងៃ ហើយបន្ទាប់មកក៏ឆ្លងកាត់ការឆ្លងទន្លេ ដើម្បីឲ្យកូនអាចមានវត្តមាននៅលើផែនដីនេះ។ ក្នុងរយៈពេលកូននៅក្នុងផ្ទៃរយៈពេល៩ខែ១០ថ្ងៃនោះ ហើយនៅក្នុងអំឡុងពេលប៉ុន្មានខែដំបូងបន្ទាប់ពីបានសម្រាលកូនហើយ ម្តាយក៏បានផលិតទឹកដោះសម្រាប់ចិញ្ចឹមចេញពីរាងកាយរបស់គាត់ផ្ទាល់សម្រាប់កូនរបស់គាត់។ ហើយសូម្បីតែបន្ទាប់ពីនោះមក ក៏គាត់មានទំនួលខុសត្រូវក្នុងការផ្តល់នូវការចិញ្ចឹមដ៏ល្អបំផុតដល់កូនគាត់ដែរ។ គាត់មិនបានគេង ដោយសារមើលថែកូនក្នុងអំឡុងពេលដែលកូនឈឺ ដែលមើលទៅហាក់បីដូចជាការលះបង់បែបអធិធម្មជាតិ និងគ្មានដែនកំណត់។ គ្រប់ការទាំងនេះបង្ហាញអំពីការផ្គត់ផ្គង់តម្រូវការរបស់ព្រះជាម្ចាស់សម្រាប់យើងដែលឈានដល់ចំណុចនៃការសុគតរបស់ព្រះគ្រីស្ទ ដើម្បីសង្គ្រោះយើង។ សេចក្តីស្រឡាញ់របស់ម្តាយចំពោះកូនដែលចេះតែប្រឆាំងបះបោរក៏ផ្តល់ឲ្យយើងឃើញនូវរូបភាពមួយអំពីព្រះជាម្ចាស់ ដែលព្រះអង្គនៅតែមិនព្រមបោះបង់សេចក្តីស្រឡាញ់សម្រាប់ស្នាព្រះហស្តដែលព្រះអង្គបានបង្កើតមកដែលបះបោរនឹងទ្រង់ ការនោះបានបណ្តាលឲ្យព្រះអង្គចាត់ព្រះរាជបុត្រារបស់ព្រះអង្គមកដើម្បីសង្គ្រោះយើង។[៤]

ព្រះគម្ពីរបានបង្ហាញថាឪពុកជាគំរូនៃសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់៖ “ព្រះយេហូវ៉ាទ្រង់មានព្រះហឫទ័យអាណិតដល់អស់អ្នក ដែលកោតខ្លាចទ្រង់ ដូចជាឪពុកមានចិត្តអាសូរដល់កូនរបស់ខ្លួនដែរ” (ទំនុកតម្កើង ១០៣:១៣)។ ព្រះគម្ពីរក៏បានបង្ហាញថា ឪពុកជាសេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ ក្នុងការធ្វើជាគំរូនៃឆ្លើយតបចំពោះតម្រូវការរបស់យើងដែរ៖ “ចុះបើអ្នករាល់គ្នាដែលអាក្រក់ អ្នកចេះឲ្យរបស់ល្អដល់កូនខ្លួនដូច្នេះ នោះចំណង់បើព្រះវរបិតានៃអ្នក

ដែលទ្រង់គង់នៅស្ថានសួគ៌ ទ្រង់នឹងប្រទានរបស់ល្អ មកអស់អ្នកដែលសូម តើជាងអម្បាលម៉ានទៅទៀត!» (ម៉ាថាយ ៧:១១)។ ត្រង់នេះ ការផ្ដោតគឺលើរបៀបដែលថា យើងអាចទុកចិត្តលើព្រះជាម្ចាស់ខ្លាំងជាង។ ប៉ុន្តែ សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវត្រង់នេះក៏បង្ហាញថា ឪពុកក៏គួរបង្ហាញអំពីការទុកចិត្តលើព្រះជាម្ចាស់តាមរយៈទង្វើខ្លួនដែរ។ បុគ្គលដែលមិនបានទទួលបទពិសោធន៍នៃការស្រឡាញ់បែបនេះ និងភាពស្មោះត្រង់ជាទៀងទាត់ពីឪពុកម្ដាយខ្លួនក៏នឹងមានការពិបាកក្នុងការជឿថា ព្រះជាម្ចាស់ស្រឡាញ់គាត់ និងយកចិត្តទុកដាក់លើគាត់ ក្នុងបទពិសោធន៍ទាំងអស់ក្នុងជីវិតនេះ។ ជាការដែលគួរឲ្យសោកស្ដាយណាស់ ខ្ញុំត្រូវតែលើកឡើងថា ខ្ញុំបានឃើញរឿងដូចនេះក្នុងជីវិតមនុស្សជាច្រើននាក់ ដែលឪពុកម្ដាយ (ឬក៏តែឪពុក ឬតែម្ដាយ) បានបង្ហាញថាអាចទុកចិត្តលើបាន ឬក៏ថាបានធ្វើឲ្យពួកគាត់ខកចិត្តយ៉ាងខ្លាំង។ រឿងនេះធ្វើឲ្យពួកគាត់ពិតជាពិបាកជឿថា ព្រះជាម្ចាស់នឹងមើលថែពួកគាត់។

កូនៗរៀនបានមេរៀនច្រើនយ៉ាងចេញពីការសង្កេតមើលឪពុកម្ដាយរបស់ខ្លួន។ ពួកគាត់យកអាកប្បកិរិយារបស់ឪពុកម្ដាយដោយវិចារណញ្ញាណថា ពួកគាត់អាចធ្វើបានដូចគ្នា។ លោក ឌី. អិល. ម៉ូឌី បានប្រាប់អំពីដំណើររឿងរបស់ម្ដាយម្នាក់ ដែលមានការភ្ញាក់ដោយសារឮកណ្ដឹងទ្វារ ហើយបានងាកដើម្បីមើលថាតើអ្នកណានៅទីនោះ ហើយក៏បានធ្វើឲ្យកែវបែកក្នុងពេលនោះដែរ។ នៅពេលគាត់បានទៅដល់ផ្ទះបាយវិញ គាត់បានឃើញថា កូនស្រីពៅរបស់គាត់ ដោយកំពុងគិតថាការបំបែកកែវទាំងនោះគឺជារឿងត្រឹមត្រូវ ក៏បានបំបែកកែវទាំងនោះតាមដែលគាត់អាចចាប់យកមកបំបែកបាន។[៥] នៅប្រទេសស្រីលង្កា ឪពុកម្ដាយតែងតែកុហកកូនៗរបស់ខ្លួន ដើម្បីឲ្យរួចខ្លួនមួយគ្រាៗ។ ពួកគាត់បញ្ជើះកូនៗឲ្យប្រាប់ដល់ភ្ញៀវ ដែលពួកគាត់មិនចង់ឲ្យមកលេងថា ខ្លួនមិននៅផ្ទះទេ។ ពួកគាត់ទំនងជាប្រាប់ថា មានមនុស្សអាក្រក់ដូចជា «ប្រម៉ាត់ប្រម៉ង់» នឹងមកចាប់ពួកគេទៅ ប្រសិនបើពួកគេមិនញ៉ាំបាយឲ្យអស់នោះទេ។ នៅពេលដែលឪពុកចាកចេញពីផ្ទះទៅធ្វើដំណើរឆ្ងាយ ហើយ

កូនតូចនោះយំដោយព្រោះឪពុកចាកចេញ ដូច្នេះដើម្បីឲ្យកូនតូចឈប់យំ ម្ដាយក៏ប្រាប់កូននោះថា ឪពុកទៅហាងជិតនោះ ទិញនំឲ្យកូន ហើយគាត់នឹងមកវិញឆាប់ៗនេះ។ មិនយូរមិនឆាប់ កូននោះក៏ឃើញថា ឪពុកម្ដាយរបស់គាត់ (ទោះបើជាគ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំក៏ដោយ) ក៏កុហកជាញឹកញាប់ដើម្បីទទួលបានការសម្រេចផ្សេងៗដែរ ហើយកូននោះក៏បានសន្មតថា វាជារឿងធម្មតាទេដែលគ្រីស្ទបរិស័ទកុហក។

ក្រមសីលធម៌របស់គ្រីស្ទបរិស័ទមានភាពខុសគ្នាពីក្រមសីលធម៌ដែលមានមនុស្សជាច្រើនដើរតាមនៅក្នុងវប្បធម៌ដែលយើងកំពុងរស់នៅនេះ។ កូនៗយើងនឹងទទួលបានការជះឥទ្ធិពលយ៉ាងខ្លាំងពីក្រមសីលធម៌នោះ ក្នុងការរស់នៅតាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន និងតាមរយៈបណ្ដាញសង្គមរបស់ពួកគាត់។ គំនិតទូទៅគឺថា ការរស់នៅដោយគ្រាប់តាមគោលការណ៍នៃជំនឿគ្រីស្ទបរិស័ទមិនមានប្រយោជន៍ទេក្នុងពិភពលោកនេះ។ ឪពុកម្ដាយអាចបង្ហាញអំពីចំណុចខុសឆ្គងនៃគំនិតនោះ ដោយរស់នៅតាមគោលការណ៍នៃជំនឿ។ ឬក៏ តាមរយៈគំរូរបស់ខ្លួន ពួកគាត់អាចបង្ហាញទៅកាន់កូនៗថា គោលការណ៍នៃជំនឿគ្រីស្ទបរិស័ទពិតជាមិនមានប្រយោជន៍មែន។

មានគ្រួសារមួយនៅប្រទេសឥណ្ឌាបានធ្វើដំណើរផ្លូវឆ្ងាយតាមរថភ្លើង ហើយឪពុកទទួលបានកៅអីដ៏ល្អៗដោយគាត់បានបង់សំណូក ហើយផ្ដោះជួរកៅអី។ នៅពេលកូនប្រុសគាត់បានសួរអំពីការនេះ ឪពុកក៏បានឆ្លើយថា «នរណាៗក៏ធ្វើអញ្ចឹងដែរ!»។ លុះដល់ពេលកូនប្រុសនោះត្រូវចូលរៀននៅសកលវិទ្យាល័យដែលមានឈ្មោះល្បីមួយ ឪពុកគាត់ក៏បានបង់ជាសំណូកម្ដងទៀត។ នៅពេលកូនប្រុសនោះបានសួរសំណួរសមរម្យម្ដងទៀតទៅកាន់ឪពុក នោះឪពុកក៏ឆ្លើយថា «នរណាៗក៏ធ្វើអញ្ចឹងដែរ!»។ ក្រោយមក ឪពុកម្ដាយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលសកលវិទ្យាល័យបញ្ឈប់កូនប្រុសនោះ ដោយឃើញថាគាត់លួចចម្លងពេលប្រឡង។ នៅពេលឪពុកម្ដាយដែលមិនសប្បាយចិត្តបានសួរកូននោះ «កូនអើយ! ហេតុអ្វីបានកូនធ្វើដូចនោះ?»

កូនក៏បានឆ្លើយថា «នរណាៗក៏ធ្វើអញ្ចឹងដែរ!»។

## នៅពេលដែលឪពុកម្ដាយបរាជ័យ

កូនៗអាចបដិសេធជំនឿរបស់គ្រីស្ទបរិស័ទ នៅពេលដែលពួកគាត់ឃើញឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទមិនធ្វើតាមគោលការណ៍នៃជំនឿរបស់គ្រីស្ទបរិស័ទ។ នេះគឺជារឿងដ៏ធ្ងន់ធ្ងរណាស់! ព្រះយេស៊ូវបានមានបន្ទូលថា «បើគេយកថ្មត្បាល់កិនយ៉ាងធំ ទៅចងកអ្នកនោះ ទម្លាក់ចុះទៅក្នុងសមុទ្រ នោះមានប្រយោជន៍ដល់អ្នកនោះ ជាជាងទុកឲ្យនៅធ្វើហេតុនាំឲ្យកូនតូចណាមួយនេះរវាតចិត្តវិញ» (លូកា ១៧:២)។

នៅសព្វថ្ងៃនេះ អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទជាច្រើនបានស្គាល់ព្រះគ្រីស្ទកាលនៅក្នុងវ័យជំទង់ ជាអាយុនៃការទាស់ប្រឆាំងនឹងគំនិតទូទៅ។ ពួកគាត់បានឃើញថាគំនិតទូទៅទាំងនោះគឺជាការធ្វើពុត និងមិនប្រាកដប្រជា ហើយក៏បានបើកចំហចិត្តចំពោះជំនឿគ្រីស្ទបរិស័ទដែលពិតប្រាកដវិញ។ អ្នកទាំងនោះបានបះបោរទាស់ប្រឆាំងនឹងអ្វីដែលចំពោះពួកគាត់មើលទៅហាក់បីដូចជាថា ជីវិតរស់នៅរបស់ឪពុកម្ដាយរបស់ខ្លួនមិនប្រាកដប្រជា ហើយបានរកឃើញថា ជំនឿរបស់គ្រីស្ទបរិស័ទផ្ដល់ឲ្យពួកគាត់មានជីវិតដែលប្រាកដប្រជា។ ការទទួលយកជំនឿដ៏រស់រវើករបស់គ្រីស្ទបរិស័ទគឺជាលទ្ធផលនៃការបដិសេធរបស់ពួកគាត់ទៅលើវប្បធម៌សាសនារបស់ឪពុកម្ដាយខ្លួន។ ឥឡូវនេះ ពួកគាត់ក៏បានក្លាយជាអ្នកដឹកនាំ ហើយកូនៗរបស់ខ្លួនក៏មានវ័យជំទង់ដែរ។ វាគឺជាពេលដែលក្មេងៗវ័យជំទង់ទាំងនេះត្រូវទាស់ប្រឆាំងជាមួយនឹងគំនិតទូទៅម្ដង។ ចំពោះពួកគាត់ ការទាស់ប្រឆាំងនឹងគំនិតទូទៅមានន័យថាជាការទាស់ប្រឆាំងជាមួយជំនឿរបស់គ្រីស្ទបរិស័ទ។ ដូច្នេះ ឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទត្រូវតែធ្វើគ្រប់ការទាំងអស់ ដែលអាចធ្វើបាន ដើម្បីបង្ហាញទៅកាន់កូនៗរបស់ខ្លួនថា ជំនឿគ្រីស្ទបរិស័ទគឺជាជំនឿដ៏ពិត។

កូនៗមួយចំនួនដែលឃើញឪពុកម្ដាយរបស់ខ្លួន ដែលជាគ្រីស្ទបរិស័ទ

សកម្ម បំពានគោលការណ៍ចម្បងរបស់គ្រីស្ទបរិស័ទបានក្លាយជាអ្វីដែលយើងអាចហៅថា “គ្រីស្ទបរិស័ទតាមវប្បធម៌”។ អ្នកទាំងនេះគឺជាអ្នកដែលចាត់ទុកជំនឿរបស់គ្រីស្ទបរិស័ទថាជាផ្នែកមួយនៃអត្តសញ្ញាណនៅក្នុងសង្គមរបស់ខ្លួន ហើយថាក្រុមជំនុំគឺជាស្ថាប័នដែលបណ្ដុះបណ្ដាលឲ្យមានអត្តសញ្ញាណនោះ។ ចំពោះពួកគាត់ ក្រុមជំនុំសំខាន់ណាស់។ពួកគាត់ចូលរួមជាមួយក្រុមជំនុំ ហើយទំនងជាអាចមានតួនាទីណាមួយនៅក្នុងក្រុមជំនុំដែរ។ ប៉ុន្តែ ដូចឪពុកម្ដាយរបស់ខ្លួន ពួកគាត់មិនបានដើរតាមគោលការណ៍ដែលព្រះគម្ពីរបានបង្រៀននោះទេ។

នេះគឺជាស្ថានភាពមួយដែលមានគ្រោះថ្នាក់ណាស់។ ក្រុមជំនុំមានផលប៉ះពាល់មិនល្អ នៅពេលសមាជិកដែលមានឥទ្ធិពលមិនគ្រាប់តាមគោលការណ៍ដែលជាគន្លឹះមូលដ្ឋាននៃជីវិតនៅក្នុងក្រុមជំនុំនោះ។ វាក៏ជាគ្រោះថ្នាក់មួយយ៉ាងខ្លាំងសម្រាប់គ្រីស្ទបរិស័ទតាមវប្បធម៌ទាំងនោះដែរ។ ការនៅក្នុងក្រុមជំនុំ ពួកគាត់បានដឹងពីគោលការណ៍នៃជំនឿរបស់គ្រីស្ទបរិស័ទ ប៉ុន្តែពួកគាត់មិនគ្រាប់តាមគោលការណ៍ទាំងនោះ។ ព្រះយេស៊ូវបានពណ៌នាអំពីវាសនារបស់មនុស្សទាំងនេះ នៅក្នុងពាក្យពេចន៍ដែលគួរឲ្យភ័យខ្លាចដូចនេះ៖ “អ្នកបម្រើណាដែលស្គាល់ចិត្តចៅហ្វាយ តែមិនបានរៀបចំ ឬធ្វើតាមចិត្តលោកសោះ នោះនឹងត្រូវរំពាត់ជាយ៉ាងច្រើន ឯអ្នកណាដែលមិនបានស្គាល់ តែបានប្រព្រឹត្តគួរនឹងត្រូវរំពាត់ នោះនឹងត្រូវវាយតិចវិញ ឯអស់អ្នកណាដែលគេប្រគល់ទុកជាច្រើនឲ្យ នោះគេនឹងទារជាច្រើនពីអ្នកនោះវិញ គេនឹងសូមលើសទៅទៀតពីអ្នកណាដែលគេបានផ្ញើទុកជាច្រើនផង” (លូកា ១២:៤៧-៤៨)។

ខ្ញុំក៏ត្រូវតែលើកឡើងអំពីការដែលខ្ញុំធ្លាប់បានជួបកូនៗរបស់អ្នកដឹកនាំដែលជាគ្រីស្ទបរិស័ទមួយចំនួន ដែលមិនសប្បាយចិត្តដោយការបរាជ័យរបស់ឪពុកម្ដាយរបស់ខ្លួន ក្នុងការដើរតាមគោលការណ៍របស់គ្រីស្ទបរិស័ទនៅផ្ទះផងដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏កូនៗទាំងនោះសម្រេចចិត្តដើរតាមព្រះគ្រីស្ទដោយស្មោះត្រង់ផងដែរ។ នៅក្នុងករណីទាំងនោះ ឥទ្ធិពលនៃព្រះគុណធំ

ប្រសើរជាងឥទ្ធិពលនៃភាពមិនខ្ជាប់ខ្ជួនរបស់ឪពុកម្តាយរបស់ពួកគាត់ ដែលជាគ្រីស្ទបរិស័ទទៅទៀត។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ការពិតគឺថាយើងទាំងអស់គ្នាខ្វះមិនដល់គោលការណ៍របស់ព្រះជាម្ចាស់ទេ។ កណ្ឌគម្ពីរ យ៉ាកុប ៣:២ បានសំដៅទៅកាន់គ្រូៗ ដោយបានលើកឡើងថា «ដ្បិតយើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ»។ យើងអាចមានការគេចចេញពីការខូចខាតជាច្រើននៃកំហុសទាំងនេះបាន ប្រសិនបើយើងទទួលស្គាល់ថាយើងបានធ្វើខុស ហើយសុំទោសសមាជិកគ្រួសាររបស់យើង។ យើងបានរៀបរាប់អំពីការនេះនៅក្នុងជំពូក៩រួចហើយ។ យើងបានលើកឡើងថា នៅពេលដែលសមាជិកគ្រួសារជាពិសេសឪពុក ឬម្តាយបានធ្វើខុស នោះមានពពកដ៏ក្រាស់នៅក្នុងផ្ទះរបស់ពួកគាត់។ អ្នកដទៃនៅក្នុងគ្រួសារមានការខកចិត្ត ខឹងសម្បារ មិនសប្បាយចិត្ត ឬក៏មិនមានភាពងាយស្រួលអំពីអាកប្បកិរិយាចំពោះអ្នកដែលបានធ្វើខុសនោះ។ នៅពេលដែលកូនៗពេញវ័យ ហើយចាប់ផ្តើមសួរនាំអំពីអ្វីដែលស្តាប់ទៅហាក់បីដូចជាមិនប្រាកដប្រជា នោះពួកគាត់ទំនងជាសួរអំពីភាពពិតនៃជំនឿរបស់ឪពុក ឬក៏ម្តាយដែលអះអាងថាខ្លួនជាគ្រីស្ទបរិស័ទ ប៉ុន្តែបដិសេធមិនទទួលស្គាល់អំពើបាបរបស់ខ្លួន។ ជាការពិតណាស់ ការទទួលស្គាល់អំពើបាបគឺជាមូលដ្ឋានគ្រឹះមួយនៃការអនុវត្ត នៅក្នុងជីវិតគ្រីស្ទបរិស័ទ។ នៅពេលដែលសមាជិកនៅក្នុងគ្រួសារសារភាពថា គាត់បានធ្វើខុស ហើយសូមអភ័យទោស នោះដុំពពកនោះក៏បានស្រឡះឡើងវិញ។

កាលកូនៗខ្ញុំនៅតូចនៅឡើយ ហើយប្រសិនបើខ្ញុំស្ថិតនៅក្រោមសម្ពាធជាច្រើនពីកន្លែងធ្វើការ នោះមានពេលខ្លះ ខ្ញុំខឹងពួកគាត់ដោយមិនសមហេតុផល។ នៅពេលដែលខ្ញុំបានធ្វើដូចនេះ ខ្ញុំដឹងថាខ្ញុំត្រូវតែទៅសុំទោសពួកគាត់។ ប៉ុន្តែ ខ្ញុំតែងតែរកលេសជាច្រើនក្នុងការគេចពីការបន្ទាបខ្លួនមួយនេះ! ខ្ញុំនឹងលើកជាហេតុផលថា នោះគឺជាការល្អសម្រាប់ពួកគាត់ក្នុងការប្រឈមមុខជាមួយបញ្ហាដូចនោះ ដោយសារពួកគាត់ក៏នឹងត្រូវប្រឈមមុខជាមួយនឹង

បញ្ហាដែលមិនសមហេតុសមផលដូចនេះដែរ នៅពេលពួកគាត់ចេញទៅរស់នៅក្នុងពិភពខាងក្រៅ។ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំមិនអាចទទួលយកហេតុរបស់ខ្ញុំបានយ៉ាងពិតប្រាកដទេ។ ខ្ញុំដឹងថា ខ្ញុំត្រូវតែទៅសុំទោសពួកគាត់។ ចំពោះឪពុកម្ដាយ ទោះបើការសុំទោសគឺជាការបន្ទាបខ្លួនក៏ដោយ ក៏ខ្ញុំជឿថា ពួកគាត់ទទួលបានការគោរពពីកូនៗ នៅពេលដែលពួកគាត់ធ្វើដូចនោះដែរ។ ជាលទ្ធផលផ្ទុយ ពួកគាត់នឹងបាត់បង់អំណាចខាងឯព្រលឹងវិញ្ញាណ ប្រសិនបើពួកគាត់បដិសេធមិនទទួលស្គាល់ថា ខ្លួនបានធ្វើខុស។ ទំនងពួកគាត់អាចនៅមានសន្តិភាពខាងក្រៅបាន ដោយកូនៗបង្ហាញការគោរពដល់ពួកគាត់ ដោយសារកូនៗត្រូវធ្វើបែបនោះ។ ប៉ុន្តែ ពួកគាត់បានបាត់បង់ភាពដែលគួរឲ្យទុកចិត្តបាន។ តាមរយៈអំពើបាបរបស់ពួកគាត់ ពួកគាត់មិនបានថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ទេ ហើយការមិនថ្វាយព្រះកិត្តិយសនេះក៏ត្រូវមានការលាយឡំគ្នា តាមរយៈការបដិសេធរបស់ពួកគាត់ មិនព្រមទទួលស្គាល់ថាខ្លួនបានធ្វើខុសដែរ។

នៅពេលឪពុកម្ដាយ ដែលជាគ្រីស្ទបរិស័ទ សុំទោសប្ដី ឬប្រពន្ធ ឬក៏កូនៗរបស់ខ្លួន នោះពួកគាត់កំពុងបង្រៀនដល់កូនៗថា ការធ្វើខុសត្រូវមានការប្រឆាំងដោយស្មោះត្រង់ និងមានទំនួលខុសត្រូវសម្រាប់ឲ្យអាចទទួលយកការនោះបាន។ ពួកគាត់ក៏លើកតម្កើងភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ដែរ ដោយបដិសេធមិនទទួលស្គាល់នូវអាកប្បកិរិយាមិនបរិសុទ្ធរបស់ខ្លួន។ ដូចនេះ ការសុំទោសគួរតែជាការអនុវត្តមួយឲ្យបានទៀងទាត់នៅក្នុងផ្ទះរបស់គ្រីស្ទបរិស័ទ។

## ការណែនាំតាមរយៈការបង្រៀន

ខគម្ពីរដ៏សំខាន់បំផុតមួយនៅក្នុងព្រះគម្ពីរដែលអំពីការឆ្លើយតបទៅកាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយរាស្ត្ររបស់ទ្រង់ គឺនៅក្នុងកណ្ឌគម្ពីរចោទិយកថាជំពូកទី៤។ មានចំណុចមួយចំនួននៅទីនោះដែលបង្ហាញអំពី

អ្វីដែលមនុស្សយើងត្រូវធ្វើជាមួយនឹងព្រះបន្ទូល។ នៅចំចំណុចកណ្ដាលនៃបទគម្ពីរនេះ មានការណែនាំពីរយ៉ាងអំពីការដែលឪពុកម្ដាយបង្រៀនព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ទៅកាន់កូនៗរបស់ពួកគាត់។ កណ្ឌគម្ពីរចោទិយកថា ៤:៩ បានចែងថា «ត្រូវឲ្យឯងប្រាប់ពីការទាំងនោះដល់កូនចៅឯងឲ្យដឹងតរៀងទៅវិញ»។ នៅក្នុងខបន្ទាប់ លោក ម៉ូសេ បានលើកឡើងនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយបានលើកឡើងថា «ចូរប្រមូលពួកបណ្ដាជនមកឯអញ នោះអញនឹងឲ្យគេឮអស់ទាំងពាក្យរបស់អញ ដើម្បីឲ្យគេរៀនឲ្យចេះកោតខ្លាចដល់អញ នៅគ្រប់១ជីវិតដែលគេរស់នៅលើផែនដី ហើយឲ្យគេបានបង្រៀនដល់កូនចៅគេថែមទៀត»។ ព្រះបន្ទូលនេះបានបង្ហាញថា ឪពុកម្ដាយត្រូវបង្រៀនអំពីកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់កូនៗរបស់ខ្លួន។ នៅក្នុងព្រះគម្ពីរ ឪពុកម្ដាយគឺជាគ្រូបង្រៀនព្រះបន្ទូលដ៏សំខាន់បំផុតសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់។ ពួកគាត់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីឲ្យពួកគាត់អាចរៀនចេះកោតខ្លាចព្រះអង្គ ព្រមទាំងបង្រៀនទៅកាន់កូនៗរបស់ពួកគាត់ផងដែរ។

កណ្ឌគម្ពីរ សុភាសិត ១:៨ បានផ្ដល់ជាការសង្ខេបដ៏ល្អអំពីឥទ្ធិពលរបស់ឪពុកម្ដាយទៅលើកូនៗពួកគាត់៖ «នែ កូនអើយ ចូរស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះ កុំឲ្យកូនបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយឯងឡើយ»។ ប្រហែលជាយើងមិនចាំបាច់លើកឡើងអំពីភាពខុសគ្នាខ្លាំងពេករវាងពាក្យ «សេចក្ដីទូន្មាន» របស់អ្នកម្ដាយ និងពាក្យ «ប្រៀនប្រដៅ» របស់លោកឪពុកទេ។ នេះគឺជាលក្ខណៈនៃការស្របគ្នារបស់កំណាព្យនៅក្នុងភាសាហេព្រើរ—មានពីរឃ្លាដែលមានន័យស្ទើរតែដូចគ្នា។ ប៉ុន្តែ វាជារឿងសំខាន់ត្រង់ថា ពាក្យដែលគេបានបកប្រែមកថា «សេចក្ដីទូន្មាន» គឺជាពាក្យទូទៅតូរ៉ា (Torah) ជាពាក្យដែលបានសរសេរនៅក្នុងព្រះគម្ពីរប្រាំកណ្ឌដំបូង នៅក្នុងព្រះគម្ពីរដោយជនជាតិអ៊ីស្រាអែល។ ពាក្យដែលបានប្រើនៅទីនេះ វាប្រាកដជាមានអត្ថន័យនៃការបង្រៀនមួយនៅក្នុងព្រះគម្ពីរ។ ពាក្យដែលបានប្រើប្រាស់សម្រាប់តួនាទី

របស់ឪពុក ដែលគេបានបកប្រែថា «ប្រៀនប្រដៅ» មានអត្ថន័យថា «ការដាក់ពិន័យ ការកែតម្រង់ ការបង្ហាត់បង្រៀន ការរម្លឹកដាស់តឿន និងការព្រមាន» ដែលសង្កត់ធ្ងន់លើការអនុវត្តតាមបទគម្ពីរ។ ជាថ្មីម្តងទៀត ដោយមានការប្រុងប្រយ័ត្ន ដែលយើងមិនចាំបាច់លើកឡើងអំពីភាពខុសគ្នាខ្លាំងពេកនោះទេ នោះយើងអាចនិយាយបានថា ក្មេងៗត្រូវការទាំងពីរ គឺការទទួលបានសេចក្តីបង្រៀនដែលមាននៅក្នុងព្រះគម្ពីរ និងជាការអនុវត្តនៅក្នុងជីវិតរស់នៅពីមួយថ្ងៃទៅមួយថ្ងៃផងដែរ។ ជាទូទៅ ម្តាយគឺជាអ្នកដែលរកពេលរៀបចំការបង្រៀនបែបតាមប្រព័ន្ធ ហើយឪពុកគឺជាអ្នកដែលមានភាពប៉ិនប្រសប់ក្នុងការអនុវត្តសេចក្តីពិតនៅក្នុងបទគម្ពីរនៅក្នុងបញ្ហាដែលកូនៗជួបប្រទះ នៅក្នុងជីវិតនេះផងដែរ។ ពិតណាស់ តួនាទីទាំងពីរនេះអាចមានការផ្លាស់ប្តូរគ្នាបាន។ ប៉ុន្តែ យើងក៏ត្រូវតែចងចាំថា ឪពុកក៏មានតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀនកូនៗរបស់ខ្លួនដែរ។ កណ្ឌគម្ពីរសុភាសិតចង្អុលបង្ហាញអំពីការនេះជាញឹកញាប់ (សូមអាននៅក្នុងកណ្ឌគម្ពីរ សុភាសិត ១:៨; ៤:១; ៦:២០; ១៣:១; ១៥:៥)។

អត្ថបទគំរូអំពីការបង្រៀនព្រះបន្ទូលទៅកាន់កូនៗគឺនៅក្នុងកណ្ឌគម្ពីរចោទិយកថា ៦:៦-៩៖

> «សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ ត្រូវឲ្យប្រិតប្រៀនសេចក្តីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាលក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយក្រោកឡើងផង ត្រូវចងសេចក្តីទាំងនេះជាប់នៅដៃឯងទុកជាទីសម្គាល់ ហើយត្រូវធ្វើជាស្លាកនៅកណ្តាលថ្ងាសឯងផង ក៏ត្រូវកត់នៅក្របទ្វារផ្ទះ ឯង ហើយនៅទ្វារកំផែងរបស់ឯងផង»។

គ្រប់ឃ្លានីមួយៗនៅក្នុងអត្ថបទនេះមានការបញ្ជាក់គាំទ្រសំខាន់ៗដែលយើងនឹងពិចារណា ក៏ដូចជាមើលជាមួយគ្នាឲ្យកាន់តែស៊ីជម្រៅនៅក្នុងកណ្ឌ

គម្ពីរចោទិយកថាជំពូកទី៤។

*ចូរបង្រៀនព្រះបន្ទូល*

ព្រះជាម្ចាស់បានបង្គាប់ឲ្យឪពុកម្ដាយ «ប្រិតប្រៀន [ព្រះបន្ទូលរបស់ព្រះជាម្ចាស់] សេចក្ដីទាំងនេះដល់កូនចៅឯង» (ចោទិយកថា ៦:៧ក)។ នៅក្នុងភាសាហេព្រើរ ពាក្យ «ប្រិតប្រៀន» គឺជាពាក្យតែមួយដែលមានន័យថា «ធ្វើម្ដងហើយម្ដងទៀត»។ ឧស្សាហកម្មផ្សាយពាណិជ្ជកម្មបានយល់អំពីចំណុចសំខាន់នៃការលើកឡើងម្ដងហើយម្ដងទៀត ក្នុងការជួយឲ្យកូនៗទទួលបានសារណាមួយ។ កាសែតប្រវត្តិហ៊ូស្តុន (The Houston Chronicle) បានលើកឡើងថា «អ្នកស្រាវជ្រាវនៅសាន់ឌីអាហ្គោ (San Diego) បានតាមដានការមើលទូរទស្សន៍៩៥ម៉ោងនៃពេលរសៀលនៅថ្ងៃធ្វើការ និងព្រឹកថ្ងៃសៅរ៍ថា ការចាក់បញ្ចាំងសំដៅទៅកាន់ក្មេងៗ។ ការស្រាវជ្រាវអស់រយៈពេលពីរខែបានបើកបង្ហាញថា ក្នុងរយៈពេលមួយម៉ោង ក្មេងៗបានមើលពាណិជ្ជកម្ម២១ដង»។[៦] នេះគឺជាករណីនៃការបង្រៀនជាប់លាប់ និងម្ដងហើយម្ដងទៀត។ វាមានភាពជិតស្និទ្ធជាងគំរូនៃការបង្រៀន ដែលពណ៌នាជាចម្បង ទាក់ទងនឹងការដែលម្ដាយធ្វើ។

ខ្ញុំចូលចិត្តគិតអំពីខ្លួនឯងថាជាគ្រូបង្រៀនព្រះគម្ពីរម្នាក់។ ខ្ញុំបានរៀនអំពីសិល្បៈនៃការបកស្រាយព្រះគម្ពីរ និងការបង្រៀនចេញពីការអានសៀវភៅ (ពីបណ្ណាល័យរបស់ឪពុកខ្ញុំសម្រាប់មនុស្សទូទៅ) ពីអ្នកនិពន្ធនិងល្បីល្បាញមួយចំនួន ដែលមានដូចជាលោក ចន ស្តុត (John Stott), អេស្វ. អេស្វ. ប្រ៊ូស (F. F. Bruce), និងលោក លីអន ម៉ូរីស (Leon Morris) និងចេញពីការបង្រៀនដោយគ្រូដ៏ល្អៗពីសាលាព្រះគម្ពីរដែលមានដូចជាលោក រ៉ូប៊ើត ត្រេណា (Robert Traina), លោក ដានីយ៉ែល ហ្វូល័រ (Daniel Fuller), លោក ដូណាល់ដ៍ ឌីម៉ារ៉េ (Donald Demaray), លោក រ៉ូប៊ើត ខូលេមែន (Robert Coleman), លោក ចន អសវ៉ាលថ៍ (John Oswalt) និងលោក

យ៉ូសែប វ៉ាង (Joseph Wang)។ ប៉ុន្តែ ទាក់ទងទៅនឹងសាច់រឿងនៅក្នុងព្រះគម្ពីរ និងអាកប្បកិរិយារបស់ខ្ញុំចំពោះព្រះគម្ពីរ គ្រូដែលមានឥទ្ធិពលខ្លាំងជាងគេបំផុតនៅក្នុងជីវិតរបស់ខ្ញុំគឺម្ដាយរបស់ខ្ញុំ។ គាត់តែងតែដាស់កូនៗរបស់គាត់ស្ទើរតែរាល់ព្រឹក ឲ្យយើងជុំគ្នា ហើយរៀនព្រះគម្ពីរជាមួយគ្នា។ គាត់បានបង្រៀនទាំងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី។

ពីមុនអ្នកម្ដាយរបស់ខ្ញុំគឺជាពុទ្ធសាសនិកម្នាក់ ហើយគាត់បានទទួលជឿព្រះគ្រីស្ទនៅពេលគាត់មានវ័យជំទង់។ តាមដែលខ្ញុំដឹង គាត់មិនដែលបានចូលរៀនអំពីរបៀបសិក្សាព្រះគម្ពីរទេ។ ប៉ុន្តែ គាត់ស្គាល់ព្រះបន្ទូល ហើយគាត់បានបង្រៀនដល់យើងដែរ។ កូនៗទាំងប្រាំរបស់គាត់គឺជាគ្រីស្ទបរិស័ទដែលមានការប្ដេជ្ញាចិត្តក្នុងការបម្រើព្រះជាម្ចាស់ ខ្លះស្ម័គ្រចិត្ត ឬក៏ខ្លះទៀតពេញម៉ោងខ្លះដែរ។ ដោយគ្រាប់តាមគំរូរបស់គាត់ ប្រពន្ធខ្ញុំក៏បានបង្រៀនព្រះគម្ពីរដល់កូនៗរបស់យើងដែរ។ ជាដំបូង គាត់បានប្រើប្រាស់សៀវភៅ «ព្រះគម្ពីររូបភាព» (The Picture Bible) ដែលបោះពុម្ពដោយលោក ដាវីឌ ស៊ី. យុក (David C. Cook)[៧] ដែលនៅក្នុងសៀវភៅនោះជាតុ្តកអប់រំ ហើយបានលើកឡើងសាច់រឿងស្ទើរតែទាំងអស់ និងសេចក្ដីបង្រៀនជាច្រើននៅក្នុងព្រះគម្ពីរ។ គាត់បានអានសៀវភៅនេះទាំងមូលជាមួយកូនៗម្នាក់ឲ្យបានពីរដង។ ហើយនៅពេលកូនៗចេះអាន ពួកគាត់បានអានសៀវភៅនោះដោយផ្ទាល់ដែរ។ ដូចដែលការបង្រៀនរបស់ម្ដាយមានឥទ្ធិពលយ៉ាងខ្លាំងដល់ខ្ញុំ នោះខ្ញុំក៏ចាត់ទុកឥទ្ធិពលប្រពន្ធរបស់ខ្ញុំទៅលើកូនៗខ្ញុំថាជាកត្តាដ៏សំខាន់បំផុតសម្រាប់មនុស្ស ក្នុងការប្ដេជ្ញាចិត្តរបស់ពួកគាត់ចំពោះព្រះគ្រីស្ទ និងចំពោះព័ន្ធកិច្ចរបស់គ្រីស្ទបរិស័ទ។

### *ចូរនិយាយអំពីព្រះបន្ទូល*[៨]

ការគាំទ្របញ្ជាក់បន្ទាប់នៅក្នុងកណ្ឌគម្ពីរចោទិយកថាជំពូកទី៦ គឺការលើកឡើងអំពីការនិយាយអំពីព្រះបន្ទូល «ព្រមទាំងនិយាយដំណាល [ព្រះបន្ទូលរបស់ព្រះ] ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវ ក្នុងកាលដែល

ដេក ហើយក្រោកឡើងផង» (៦:៧ខ)។ រូបភាពនៅត្រង់នេះគឺអំពីការដំណាល ឥតឈប់ឈរនៅក្នុងជីវិតរបស់កូនៗយើង។

មានការលើកឡើងអំពីទិដ្ឋភាពផ្សេងៗគ្នានៃជីវិតនៅក្នុងគ្រួសារ។ ឪពុកម្ដាយត្រូវតែនិយាយអំពីព្រះបន្ទូលនៅពេលពួកគាត់ «អង្គុយ នៅក្នុងផ្ទះ [របស់ពួកគាត់]»។ ពេលញ៉ាំអាហារនៅផ្ទះគឺជាពេលល្អសម្រាប់ការសន្ទនាដូចនោះ។ ជាទូទៅ មានបរិយាកាសបែបធម្មតា និងកក់ក្ដៅនៅពេលបរិភោគអាហារ ដែលនោះគឺជាពេលវេលាដ៏ស័ក្តិសមក្នុងការបង្កើតការពិភាក្សាដូចនេះ។ ពេលវេលាដ៏សប្បាយៗបំផុតមួយចំនួននៅក្នុងជីវិតគ្រួសារគឺនៅពេលដែលពួកគាត់នៅញ៉ាំបាយជុំគ្នា នៅពេលដែលពួកគាត់និយាយអំពីរឿងសំខាន់ៗនៅក្នុងជីវិត។

ជាបន្ទាប់ ព្រះជាម្ចាស់ក៏បង្គាប់ឲ្យឪពុកម្ដាយបង្រៀនកូនៗរបស់ខ្លួនអំពីព្រះបន្ទូលរបស់ទ្រង់នៅពេល «[ពួកគាត់] ដើរតាមផ្លូវ» ដែរ។ នៅក្នុងវប្បធម៌ជាច្រើនក្នុងពេលសព្វថ្ងៃនេះ ឃ្លា «[ការ] ដើរតាមផ្លូវ» អាចប្ដូរទៅជា «[ការ] បើកបរបែបជាគ្រួសារ» វិញក៏បាន។ ពេលវេលាក្នុងការធ្វើដំណើរផ្ដល់ឱកាសល្អសម្រាប់ការសន្ទនាយ៉ាងរស់រវើក។

ជាចុងក្រោយ ព្រះជាម្ចាស់បានបង្គាប់ឲ្យឪពុកម្ដាយនិយាយអំពីព្រះបន្ទូល «ក្នុងកាលដែល [ពួកគាត់] ដេក ហើយ [ពួកគេ] ក្រោកឡើងផង»។ ពួកគាត់ត្រូវតែជួយកូនៗឲ្យចេះគិតអំពីព្រះជាម្ចាស់នៅពេលពួកគេចាប់ផ្ដើម និងបញ្ចប់ថ្ងៃរបស់ខ្លួន។ ការនោះនឹងជួយពួកគាត់ឲ្យចេះកោតខ្លាចព្រះពេញមួយថ្ងៃតែម្ដង។ តាមរយៈការធ្វើបែបនេះ យើងទទួលស្គាល់ថា គ្រប់ផ្នែកនៃជីវិតគឺស្ថិតនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់ ហើយថាព្រះអង្គគង់នៅជាមួយនឹងយើងដែរ។ ដូច្នេះ យើងមិនចាំបាច់ភ័យខ្លាចទេ ពីព្រោះព្រះជាម្ចាស់នឹងមើលថែយើង។ ជារឿយៗ យើងមិនស្ដាប់បង្គាប់ដោយសារយើងមានទំនុកចិត្តលើព្រះជាម្ចាស់ក្នុងការមើលថែយើងនៅក្នុងស្ថានភាពណាមួយ។ សារពីពិភពលោកនេះបានយកឈ្នះលើឥទ្ធិពលនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ របៀបដ៏ល្អបំផុតមួយក្នុងការទប់ទល់ការនេះ គឺត្រូវនៅឲ្យជាប់លាប់ជាមួយនឹង

ព្រះបន្ទូល។ នៅក្នុងសម័យកាលព្រះគម្ពីរសញ្ញាចាស់ ដែលនៅពេលនោះមនុស្សម្នាមិនទទួលបានសារមិនស៊ីគ្នានឹងព្រះគម្ពីរ ដោយបំផុះតាមរយៈបណ្ដាញសង្គម ដូចដែលយើងទទួលបាននៅសព្វថ្ងៃនេះ គឺថាពួកគាត់មានពេលវេលាច្រើនក្នុងការចំណាយពិភាក្សាអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ច្រើនជាងពេលសព្វថ្ងៃនេះ។ ដោយសារសព្វថ្ងៃនេះយើងមានធនធានច្រើន នោះយើងក៏ចំណាយពេលជាមួយនឹងព្រះបន្ទូលច្រើនជាងអ្នកនៅសម័យកាលព្រះគម្ពីរសញ្ញាចាស់ ដើម្បីប្រឆាំងនឹងសារដែលទាស់ប្រឆាំងនឹងគោលជំនឿគ្រីស្ទបរិស័ទ ដែលយើងប្រឈមមុខជាមួយ! ពិតណាស់ នេះគឺជាចំណុចដែលតម្រូវឲ្យមានការផ្ដល់អារម្មណ៍លើភ្លាមៗ។

